# សំណួរពិបាកៗ
# សម្រាប់
# គ្រីស្ទបរិស័ទ

៥០ចម្លើយសម្រាប់ក្រុមជំនុំ និងគ្រូគង្វាល
50 Answers for Pastors and Churches

**JOHN PIPER**

សៀវភៅ **ទី២**

រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម៖ John Piper All rights reserved. Used by permission

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
បកប្រែដោយ៖ លោក ឈាង បូ៉ា, កញ្ញា គឹម បូព្រឹក, លោក ឯក សត្យា, លោក ផេន ប៉ុក,
លោក ខែម បូឡុង និងលោក ពេជ្រ ប៊ុនណា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ហុង សម្កុស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង,
លោកស្រី ឡញ ស្រីរដ្ឋ, កញ្ញា សឿន ចាន់, លោក សឹម រក្សា, លោក ជួប ប៊ុនហាក់,
លោក ង៉ែត វិទូ, លោក ស្រី កែវ សិរីវុឌ្ឍី, លោក ស្រី ថាវ ប៊ុនរី, និងកញ្ញា ហុង រស្មី

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ, ឬចែកចាយបន្តរួមបញ្ចូលទាំង ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថតចម្លង, ការថតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើម។

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ព្រះគម្ពីរកែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និងលោក វណ្ណដ្ឋា សុតវ៉ាប៊ី
For ordering information please visit: plovpitshop.com
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ plovpitshop.com
បោះពុម្ពលើកទី១ ចំនួន២០០០ក្បាល គ.ស. ២០២៥ ព្រះរាជាណាចក្រកម្ពុជា
ISBN: 9789924566250

“ការចេះដឹងទាំងអស់ សុទ្ធតែជាផលផ្លែដែលកើតចេញពីការសួរសំណួរ
និងការស្វែងរកចម្លើយ”។

JOHN PIPER (1975)

# សេចក្តីផ្តើម

មានតែព្រះទេដែលអាចប្រទានប្រាជ្ញា ដែលយើងត្រូវការ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ និងស្រឡាញ់មនុស្សទាំងឡាយ ហើយអរសប្បាយអស់កល្បជានិច្ចក្នុងព្រះវត្តមានព្រះអង្គ។ ប្រាជ្ញានោះត្រូវបានកត់ទុក ក្នុងកន្លែងមួយ ដែលមិនចេះខុស។ កន្លែងនោះគឺជាព្រះគម្ពីរ។ ព្រះបន្ទូលព្រះគឺជាគ្រឹះ និងជាកត្តាជំរុញចិត្តនៃកម្មវិធីសំណួរចម្លើយពិបាកៗ។

ព្រះគ្រីស្ទបានប្រទានមកពួកជំនុំរបស់ព្រះអង្គនូវ «គ្រូគង្វាល និងគ្រូបង្រៀន» (អេភេសូរ ៤:១១)។ នេះជាការត្រាស់ហៅដ៏គ្រោះថ្នាក់។ ព្រះគម្ពីរបានធានា ហើយក៏ដាស់តឿន ចំពោះការត្រាស់ហៅនេះថា «បងប្អូនអើយ កុំឲ្យធ្វើជាគ្រូច្រើនគ្នាពេកឡើយ ពីព្រោះដឹងហើយថា យើងនឹងត្រូវទោសធ្ងន់ជាងគេ» (យ៉ាកុប ៣:១)។

កម្មវិធីសំណួរចម្លើយនេះបានផ្តល់ឲ្យនូវចម្លើយ សម្រាប់សំណួរដែលស្ថិតក្នុងចំណោមសំណួរពិបាកបំផុតអំពីជីវិត ប៉ុន្តែ បើគ្មានព្រះបន្ទូលព្រះទេ ការឆ្លើយសំណួរក្នុងកម្មវិធីនេះ គ្រាន់តែជាការនិយាយចេញនូវពាក្យសម្តីដ៏ល្ងង់ខ្លៅប៉ុណ្ណោះ។ ហើយប្រសិនបើកម្មវិធីនេះឆ្លើយសំណួរផ្អែកទៅលើព្រះបន្ទូលព្រះ ហើយទទួលជំនួយពីព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ក៏ការងារនេះត្រូវធ្វើឡើង ដោយការកោតខ្លាចព្រះ «យ៉ាងញាប់ញ័រ» គឺដូចដែលព្រះអម្ចាស់បានប្រកាសថា «អញនឹងយកចិត្តទុកដាក់ចំពោះមនុស្សយ៉ាងនេះវិញ គឺចំពោះអ្នកណាដែលក្រលំបាក ហើយមានចិត្តខ្ទេចខ្ទាំ ជាអ្នកដែលញ័រញាក់ដោយឮពាក្យរបស់អញ» (អេសាយ ៦៦:២)។

ការងារនេះជាការងារដែលយើងបានធ្វើឡើងដោយអំណរ នៅចំពោះ

គ្រោះថ្នាក់ និងការកោតខ្លាចព្រះដ៏ញាប់ញ័រ។ គ្រូតែងតែចេះជាងសិស្ស។ ព្រះទ្រង់បានកំណត់មកថា៖ ដែលឲ្យនោះមានពរជាទទួល (កិច្ចការ ២០:៣៥)។ ប៉ុន្តែ យើងមិនគ្រាន់តែមានអំណរក្នុងការរៀន ប៉ុន្តែក៏មានអំណរកាន់តែខ្លាំងថែមទៀត ក្នុងការស្គាល់រស់ជាតិនៃផលផ្លែក្នុងជីវិតអ្នកដែលស្តាប់។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងបានលើកទឹកចិត្តអ្នកឲ្យចូលរួមស្តាប់កម្មវិធីសំណួរចម្លើយពិបាកៗ។ សេចក្តីស្រឡាញ់គឺជាគោលដៅនៃចំណេះដឹង (១ធីម៉ូថេ ១:៥)។ អាកប្បកិរិយាដែលលើកតម្កើងព្រះគ្រីស្ទ កើតចេញពីចិត្តដែលស្រឡាញ់ព្រះគ្រីស្ទ គឺមិនគ្រាន់តែបង្ហូរចេញពីគំនិតដែលស្គាល់ព្រះគ្រីស្ទប៉ុណ្ណោះទេ។ កម្មវិធីសំណួរចម្លើយនេះ ក៏កើតចេញពីការជឿថា ព្រះនាមទ្រង់បានតម្កើងឡើងខ្លាំងបំផុត នៅក្នុងអ្នកស្តាប់កម្មវិធីរបស់យើង នៅពេលដែលពួកគេមានការស្កប់ចិត្តបំផុតក្នុងព្រះអង្គ។ ដូចនេះ យើងមិនអាចគ្រាន់តែចែកចាយទស្សនៈថ្មីៗប៉ុណ្ណោះទេ។ គោលដៅរបស់យើង គឺដើម្បីបណ្តាលចិត្តឲ្យមានក្តីស្រឡាញ់ជាថ្មី។ យើងខ្ញុំសង្ឃឹមថា អ្នកអាចយល់អំពីគោលបំណងរបស់យើងខ្ញុំ។ សូមឲ្យអ្នករាល់គ្នាបានស្គាល់សិរីល្អរបស់ព្រះដែលបានតម្កើងឡើង នៅក្នុងវិញ្ញាណដែលយកព្រះជាទីមួយ។

# ការណែនាំខ្លះៗ មុនពេលចាប់ផ្តើមអានសៀវភៅនេះ

១. សូមស្តាប់កម្មវិធីសំណួរចម្លើយពិបាកៗ នៅលើផេកផ្លូវពិត។ សៀវភៅដែល លោកអ្នកកំពុងកាន់ក្នុងដៃនេះ គឺជាមគ្គុទ្ទេសក៍សម្រាប់ណែនាំទៅកាន់វេបសាយរបស់ផ្លូវពិត។ វេបសាយនេះបានផ្តល់ឲ្យនូវភាពងាយស្រួល ក្នុងការចូលមើល ដែលបានធ្វើឲ្យបណ្ណាល័យអនឡាញនេះកាន់តែមានតម្លៃ និងមានប្រយោជន៍។ សៀវភៅនេះត្រូវបានរៀបរៀងមកជាលក្ខណៈសង្ខេបខ្លីៗ។ សៀវភៅដែលយើងខ្ញុំមាននៅតាមអនឡាញមានលក្ខណៈពេញលេញជាង និងសមស្របនឹងគ្រូគង្វាលជាង។ សូមប្រើសៀវភៅទាំងពីរប្រភេទនេះជាមួយគ្នា។

២. អ្នកប្រហែលមិនយល់ស្របនឹងចំណុចទាំងអស់នៅក្នុងសៀវភៅនេះ ឬក្នុងកម្មវិធីសំណួរចម្លើយនោះទេ។ តែមិនអីទេ។ សូមអាន និងស្តាប់ដូចពួកជំនុំដ៏ល្អនៅទីក្រុងបេរា ដោយបើកមើលព្រះគម្ពីរ ដើម្បីធ្វើការផ្ទៀងផ្ទាត់យ៉ាងសកម្ម។

៣. អ្វីៗគ្រប់យ៉ាងដែលមានក្នុងសៀវភៅនេះ មិនមែនសុទ្ធតែជាអ្វីដែលអ្នកត្រូវការទេ។ អ្នកប្រហែលមិនទាន់ត្រូវការនៅពេលនេះឡើយ។ សៀវភៅនេះផ្តល់ឲ្យនូវចម្លើយសម្រាប់សំណួរជាទូទៅអំពីក្រមសីលធម៌គ្រីស្ទបរិស័ទជាសំណួរដែលកំពុងមានការពេញនិយមបំផុត។

៤. ទោះជាយ៉ាងណាក៏ដោយ បើអ្នកជាអ្នកដឹកនាំគ្រីស្ទបរិស័ទ និងជាគ្រូគង្វាល អ្នកគួរតែអានពាក្យពេចន៍នីមួយៗក្នុងសៀវភៅនេះ។ ប្រធានបទ

ទាំងនេះនឹងណែនាំអ្នកឲ្យយល់គំនិតរបស់លោកគ្រូ ចន ផាបភ័រ ខណៈពេលដែលគាត់លើកយកសំណួរដែលពិបាកឆ្លើយអំពីក្រមសីលធម៌ពីក្នុងព្រះគម្ពីរ។ ខ្ញុំសង្ឃឹមថា តាមរយៈចម្លើយទាំងនេះ អ្នកនឹងបានយល់កាន់តែច្បាស់ អំពីរបៀបដែលលោកគ្រូ ផាបភ័រ ឆ្លើយសំណួរពិបាកៗ។ របៀបឆ្លើយសំណួររបស់គាត់ ជួយឲ្យយើងមានការយល់ដឹងកាន់តែច្បាស់តាមព្រះគម្ពីរ។ យើងអរព្រះគុណព្រះអង្គ ដែលលោកគ្រូ ផាបភ័រ បាននិពន្ធសៀវភៅនេះឡើង ហើយបានអធិប្បាយព្រះបន្ទូល និយាយរួមយើងរៀនឆ្លើយសំណួរពិបាកបំផុត តាមរយៈចម្លើយរបស់គាត់។

៥. សូមយើងកត់សម្គាល់អំពីវិធីសាស្ត្រដែលលោកគ្រូគង្វាល ចន បានប្រើ ក្នុងការឆ្លើយសំណួរអំពីក្រមសីលធម៌។ គាត់បានប្រើវិធីសាស្ត្រ «ខគម្ពីរយោងជាអាទិភាព»។ សម្រាប់សំណួរនីមួយៗនៅចំពោះមុខ ជាដំបូង លោកគ្រូគង្វាល ចន បានចាប់ផ្តើមឆ្លើយ ដោយប្រើខគម្ពីរយោងច្បាស់លាស់បំផុតជាមុនសិន បន្ទាប់មក គាត់លើកហេតុផល ឲ្យត្រូវតាមបរិបទ។ ជួនកាលពួកជំនុំអាចធ្វើការពិភាក្សា ឬជជែកវែកញែកលឿនពេក ដើម្បីឆ្លើយសំណួរអំពីក្រមសីលធម៌ ហើយមានពេលញឹកញាប់ពេកហើយ ដែលពួកគេបានរំលងជំហានទីមួយ ដែលត្រូវប្រើខគម្ពីរយោង ជាគ្រឹះនៃអ្វីៗគ្រប់យ៉ាង។ ដើម្បីប្រយោជន៍ពួកជំនុំ វិធីសាស្ត្រប្រើខគម្ពីរយោងជាអាទិភាព នឹងនៅតែធ្វើជាក្បួនដ៏សំខាន់ សម្រាប់អ្នកនិពន្ធ សាស្ត្រាចារ្យ អ្នកប្រឹក្សាយោបល់ គ្រូគង្វាល គ្រូអធិប្បាយ ឪពុកម្តាយជាគ្រីស្ទបរិស័ទ និងនរណាក៏ដោយដែលប្រើក្រមសីលធម៌គ្រីស្ទបរិស័ទ។ គោលបំណងនៃកម្មវិធីសំណួរចម្លើយ និងសៀវភៅនេះ គឺដើម្បីជួយអ្នកមានការយល់ដឹងអំពីក្រមសីលធម៌របស់គ្រីស្ទបរិស័ទ និងយល់អំពីរបៀបដែលយើងអាចយកព្រះគម្ពីរមកអនុវត្តក្នុងការរស់នៅប្រចាំថ្ងៃ ក្នុងសម័យទំនើប។

៦. ដែលសំខាន់បំផុតនោះ ចូរយើងមានចិត្តប្រាថ្នារកព្រះ។ ព្រះទ្រង់ «មានលក្ខណៈសម្បត្តិដែលធំបណ្តាច់ មិនមានអ្វីបង្កើតព្រះអង្គ ហើយព្រះអង្គក៏មិនពឹងផ្អែកទៅលើអ្វីទាំងអស់» (និក្ខមនំ ៣:១៤)។ ព្រះទ្រង់មិនមានដើមកំណើត និងគ្មានទីបញ្ចប់។ ព្រះអង្គគ្មានតម្រូវការ គ្មានការផ្លាស់ប្តូរ ហើយក៏មិនត្រូវការកែលំអដែរ។ នៅពីក្រោម ពីក្រោយ ពីលើ និងជុំវិញកម្មវិធីសំណួរចម្លើយពិបាកៗ គឺមានព្រះអាទិករនៃចក្រវាល ដែលមានភាពគ្រប់គ្រាន់ដោយខ្លួនឯង មានព្រះទ័យសប្បាយគ្មានទីបញ្ចប់ចំពោះខ្លួនឯង។ ប្រធានបទផ្សេងទៀត រាប់ចាប់តាំងពីប្រធានបទអំពីសេចក្តីសង្គ្រោះ និងការប្រើទូរស័ព្ទទំនើប រហូតដល់ប្រធានបទអំពីការធ្លាក់ទឹកចិត្ត និងផ្លូវភេទ គឺអាចបកស្រាយ តាមទស្សនៈរបស់គ្រីស្ទបរិស័ទតែប៉ុណ្ណោះ ក្នុងព្រះវត្តមាននៃអំណរដ៏ពេញលេញនៃព្រះអាទិករ។ ចាប់តាំងពីអស់កល្បជានិច្ចរាងមកមុនដែលព្រះទ្រង់បង្កើតពេលវេលា ព្រះអង្គមានព្រះជន្មរស់ដោយក្តីអំណរដ៏ហូរហៀរ។ ក្តីអំណរមានសារៈសំខាន់ ចំពោះលក្ខណៈសម្បត្តិរបស់ព្រះក្នុងការប្រកបគ្នា នៃព្រះត្រៃឯកដែលមានអំណរ និងបរិសុទ្ធអស់កល្បជានិច្ច។ ព្រះវរបិតាស្រឡាញ់ព្រះរាជបុត្រា ហើយក៏សព្វព្រះទ័យនឹងទ្រង់លើសអ្វីទាំងអស់។ ព្រះរាជបុត្រាក៏ស្រឡាញ់ព្រះវរបិតា ហើយសព្វព្រះទ័យនឹងទ្រង់គ្រប់យ៉ាង។ ព្រះវិញ្ញាណបរិសុទ្ធក៏បានបង្ហូរចេញនូវក្តីអំណរដោយអំណាចចេស្តាក្នុងការប្រកបជាមួយព្រះវបិតា និងព្រះរាជបុត្រា។ ដូចនេះ ព្រះទ្រង់មិនត្រូវការអ្វីទេ។ ព្រះអង្គមិនមានការខ្វះខាតសោះឡើយ។ ព្រះអង្គក៏មិនមានសេចក្តីអាក្រក់ទាល់តែសោះ ហើយមានពេញដោយសេចក្តីល្អគ្រប់យ៉ាង។

សកម្មភាពទាំងអស់ដែលព្រះអង្គធ្វើជាបន្តបន្ទាប់ ដោយអធិបតេយ្យភាពរបស់ព្រះអង្គ គឺបានបង្ហាញចេញនូវភាពឯករាជ្យដែលមានគ្រប់អំណាចចេស្តា។ ព្រះទ្រង់ «មានព្រះទ័យសប្បាយទាំងស្រុង» នៅក្នុងអង្គទ្រង់ ពោលគឺ «អរសប្បាយនៅក្នុងចំណុចស្នូលនៃអង្គទ្រង់ ដោយភាពគ្រប់

គ្រាន់ទាំងស្រុង»។ ព្រះអង្គបានបង្កើតពិភពលោក ដោយភាពគ្រប់គ្រាន់ដោយឯកឯងដោយក្តីស្រឡាញ់ ធ្វើជាកន្លែង «សម្រាប់ចែករំលែកក្តីអំណរជាមួយមនុស្សដែលព្រះអង្គបង្កើតឲ្យដូចរូបអង្គទ្រង់ គឺក្តីអំណរដែលព្រះអង្គមានក្នុងអង្គទ្រង់»។ ព្រះទ្រង់មិនត្រូវការស្នាព្រះហស្តរបស់ព្រះអង្គ។ គឺមិនត្រូវការអ្នក និងខ្ញុំទេ។ ប៉ុន្តែ ព្រះអង្គ «សប្បាយព្រះទ័យយ៉ាងឥតខ្ចោះ» និងយ៉ាងខ្លាំង ក្នុងអង្គទ្រង់ បានជាព្រះអង្គសម្រេចព្រះទ័យបង្កើតយើងមក និងប្រោសលោះយើងឲ្យរួចពីបាប តាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ទ ដើម្បីឲ្យយើងអាចដកពិសោធន៍ជាមួយនឹងអំណរដ៏អស់កល្ប ក្នុងការអសប្បាយនឹងព្រះអង្គ។ ហេតុនេះហើយយើងត្រូវឆ្លងកាត់វដ្តដ៏អស្ចារ្យនៃការអសប្បាយនឹងព្រះ និងសរសើរតម្កើងព្រះ។ គោលបំណងពីរក្លាយជាគោលបំណងតែមួយ។ ដូចនេះ ព្រះទ្រង់ទន្ទឹងរង់ចាំសុភមង្គលដែលព្រះអង្គនឹងមាននៅក្នុងការឆ្លុះបញ្ចាំងឲ្យឃើញភាពល្អប្រសើររបស់អង្គទ្រង់ នៅក្នុងការសរសើរដោយអំណរខ្ពស់បំផុតរបស់ពួកបរិសុទ្ធ។ ក្រៅពីសុភមង្គលដែលព្រះអង្គមានក្នុងអង្គទ្រង់ គ្មានសុភមង្គលណា ដែលប្រសើរជាងនេះទេ។ ដូចនេះ រាល់ការសម្រេចចិត្តនីមួយៗក្នុងជីវិតយើង និងការស្វែងយល់ជំពូកនីមួយៗក្នុងសៀវភៅនេះគួរតែធ្វើឡើង ដើម្បីគោលដៅសំខាន់បំផុតដ៏អស់កល្បនេះ គឺដើម្បីឲ្យព្រះអង្គបានតម្កើងឡើងក្នុងការស្កប់ស្កល់ដែលយើងមានក្នុងព្រះអង្គ។

# មាតិកា


## ផ្នែកទី១
## ទេវវិទ្យា និងការសិក្សាព្រះគម្ពីរ

**សំណួរទី១៖**

ផ្ទុយពីសាសនាកាតូលិករ៉ូម៉ាំង ព្រះគម្ពីរគឺជាអំណាច
គ្រប់គ្រាន់សម្រាប់យើង . . . . . . . . . . . . . . . . . . . . . . . . . .២៥

**សំណួរទី២៖**

តើ «ផែនដីចាស់» កើតចេញពីការវិវត្តន៍មែនឬ? . . . . . . . . . . . . . . ៣១

**សំណួរទី៣៖**

វិធីប្រាំយ៉ាងព្រះយេស៊ូវផ្លាស់ប្តូរទំនាក់ទំនងរបស់យើង
ជាមួយនឹងព្រះគម្ពីរសញ្ញាចាស់ . . . . . . . . . . . . . . . . . . . . . . .៣៣

**សំណួរទី៤៖**

រូបភាពអាសអាភាស និងការទប់ទល់
នឹងអំណាចនៃសេចក្តីល្បួង . . . . . . . . . . . . . . . . . . . . . . . . ៤៣

**សំណួរទី៥៖**

តើការជ្រមុជទឹកដោយព្រះវិញ្ញាណបរិសុទ្ធជាអ្វី? . . . . . . . . . . . . . . .៤៩

**សំណួរទី៦៖**

ហេតុអ្វីបានជាព្រះគម្ពីរសង្កត់ធ្ងន់ទៅលើ
អំណាចនៃព្រះនាមព្រះយេស៊ូវ? . . . . . . . . . . . . . . . . . . . . . . .៥៩

## ផ្នែកទី២

## ការលូតលាស់ខាងឯវិញ្ញាណ


**សំណួរទី៧៖**

តើព្រះគម្ពីរបង្រៀនថា ខ្ញុំពិសេសដែរឬទេ? . . . . . . . . . . . . . . . . . . .៧១

**សំណួរទី៨៖**

តើខ្ញុំអាចថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់

នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំបានដោយរបៀបណា? . . . . . . . . . . . . . . .៧៩

**សំណួរទី៩៖**

តើយើងដើរដោយព្រះវិញ្ញាណដោយរបៀបណា? . . . . . . . . . . . . . . . .៨៧

**សំណួរទី១០៖**

តើសេចក្តីអំណររបស់ព្រះគ្រីស្ទប់ក្លាយជា

សេចក្តីអំណររបស់ខ្ញុំបានដោយរបៀបណា? . . . . . . . . . . . . . . . . . ៩៣

**សំណួរទី១១៖**

ខ្ញុំនឹងស្លាប់ទាំងវ័យក្មេង តើខ្ញុំអាចតយុទ្ធ

សម្រាប់សេចក្តីសង្ឃឹមបានដោយរបៀបណា? . . . . . . . . . . . . . . . .១០១

**សំណួរទី១២៖**

តើមានមហាបេសកកម្មសម្រាប់គ្រីស្ទបរិស័ទ

គ្រប់ៗរូបមែនឬ? . . . . . . . . . . . . . . . . . . . . . . . . . . . . . . .១១១

**សំណួរទី១៣៖**

កត្តាជំរុញចិត្តបីយ៉ាងដើម្បីអធិស្ឋាន . . . . . . . . . . . . . . . . . . . . . .១១៩

**សំណួរទី១៤៖**

ហេតុអ្វីបានជាគ្រីស្ទបរិស័ទថ្វាយបង្គំជាមួយគ្នានៅថ្ងៃអាទិត្យ? . . . . . . .១២៥


## ផ្នែកទី៣

## ការអាន និងការមិនអានព្រះគម្ពីរ


**សំណួរទី១៥៖**

កត្តាជំរុញដ៏ល្អក្នុងការចងចាំព្រះគម្ពីរ. . . . . . . . . . . . . . . . . . . . ១៣៥

**សំណួរទី១៦៖**

តើខ្ញុំអាចទទួលប្រយោជន៍ជាច្រើនតាមរយៈការអាន

ព្រះគម្ពីរជាប្រចាំថ្ងៃបានដោយរបៀបណា? . . . . . . . . . . . . . . . . ១៣៩

**សំណួរទី១៧៖**

តើយើងអាចរកបានអត្ថន័យនៅក្នុងដំណើរនៃសាច់រឿង

ណាមួយបានយ៉ាងដូចម្តេច? . . . . . . . . . . . . . . . . . . . . . . . . .១៤៧

**សំណួរទី១៨៖**

របៀបនៃអានព្រះគម្ពីរសម្រាប់ក្មេងៗវ័យជំទង់ . . . . . . . . . . . . . . .១៥៩

**សំណួរទី១៩៖**

ខ្ញុំមានពេលមួយថ្ងៃមួយម៉ោងសម្រាប់អាន

តើខ្ញុំគួរចំណាយពេលប៉ុន្មាននាទីសម្រាប់អានព្រះគម្ពីរ? . . . . . . . . . .១៦៩

**សំណួរទី២០៖**

ខ្ញុំអានព្រះគម្ពីរ ហើយមិនមានអារម្មណ៍អ្វីសោះ តើខ្ញុំគួរធ្វើដូចម្តេច? . . .១៧៥

**សំណួរទី២១៖**

ខ្ញុំមិនដែលអានព្រះគម្ពីរទេ

តើខ្ញុំគួរចាប់ផ្តើមនៅត្រង់ណា? . . . . . . . . . . . . . . . . . . . . . . ១៨៣

**សំណួរទី២២៖**

តើការអានព្រះគម្ពីររបស់ខ្ញុំបែបជាការសិក្សា

ខ្លាំងពេកមែនឬ? . . . . . . . . . . . . . . . . . . . . . . . . . . . . . .១៨៩

**សំណួរទី២៣៖**

តើការអានព្រះគម្ពីរត្រូវបញ្ចប់ដោយមាន. . . . . . . . . . . . . . . . . . . .១៩៧
ការអនុវត្តគ្រប់ពេល? . . . . . . . . . . . . . . . . . . . . . . . . . . . . .១៩៧

**សំណួរទី២៤៖**

មូលហេតុ១០យ៉ាងក្នុងការអានព្រះគម្ពីរប្រចាំថ្ងៃ. . . . . . . . . . . . . . . ២០៣

## ផ្នែកទី៤
## អំពើបាប និងសេចក្ដីសង្គ្រោះ

**សំណួរទី២៥៖**

ការតយុទ្ធនឹងសេចក្ដីច្រណែនឈ្នានីស. . . . . . . . . . . . . . . . . . . . ២១៣

**សំណួរទី២៦៖**

តើខ្ញុំអាចជឿលើព្រះគម្ពីរទាំងមូល
ហើយព្រះអង្គនៅមិនបានជ្រើសរើសខ្ញុំដែរឬទេ?. . . . . . . . . . . . . . . .២១៩

**សំណួរទី២៧៖**

តើព្រះបានតម្រូវទុកជាមុន ឲ្យអ្នកខ្លះធ្លាក់នរកឬ? . . . . . . . . . . . . . ២២៥

**សំណួរទី២៨៖**

តើការ «ធ្វើបាបស្ម័គ្រពីចិត្ត» គម្រាមកំហែងលើ
សេចក្ដីសង្គ្រោះរបស់ខ្ញុំដែរឬទេ? . . . . . . . . . . . . . . . . . . . . . . ២៣១

**សំណួរទី២៩៖**

គ្រូគង្វាលរបស់ខ្ញុំមិនអធិប្បាយទាស់ប្រឆាំងនឹង
អំពើបាបសោះ តើការនោះមិនអីទេ?. . . . . . . . . . . . . . . . . . . . . ២៣៩

**សំណួរទី៣០៖**

ខគម្ពីរដ៏សំខាន់បំផុតក្នុងព្រះគម្ពីរ . . . . . . . . . . . . . . . . . . . . . .២៤៩

**សំណួរទី៣១៖**

តើអ្វីទៅជាការថ្វាយបង្គំរូបព្រះ? . . . . . . . . . . . . . . . . . . . . . . .២៥៥

**សំណួរទី៣២៖**

នៅពេលគ្រីស្ទបរិស័ទមិនព្រមប្រែចិត្តចេញពី
អំពើបាបខាងផ្លូវភេទ . . . . . . . . . . . . . . . . . . . . . . . . . . . . ២៦៣

**សំណួរទី៣៣៖**

ហេតុអ្វីព្រះរើសពួកអ្នកលួងលើ? . . . . . . . . . . . . . . . . . . . . . . .២៦៩

## ផ្នែកទី៥
## ការចែចង់គ្នា និងទំនាក់ទំនងស្នេហា

**សំណួរទី៣៤៖**

តើយើងមានអស្ថេរភាពខាងហិរញ្ញវត្ថុ
នៅក្នុងការរៀបការមែនទេ?. . . . . . . . . . . . . . . . . . . . . . . . . ២៧៩

**សំណួរទី៣៥៖**

តើជារឿងសំខាន់ទេដែលយើងត្រូវទទួលបាន
ការយល់ស្របពីឪពុកម្ដាយសម្រាប់អាពាហ៍ពិពាហ៍?. . . . . . . . . . . ២៨៣

**សំណួរទី៣៦៖**

តើទំនាក់ទំនងនៃការចែចង់របស់ខ្ញុំមានលក្ខណៈ
ដូចការថ្វាយបង្គំរូបព្រះមែនឬ? . . . . . . . . . . . . . . . . . . . . . .២៨៥

**សំណួរទី៣៧៖**
តើមិត្តប្រុសរបស់អ្នកមានភាពចាស់ទុំគ្រប់គ្រាន់
ឬនៅសម្រាប់អ្នក?. . . . . . . . . . . . . . . . . . . . . . . . . . . . . .២៩១
**សំណួរទី៣៨៖**
បែបបទនៃការចែចង់គ្នា ដោយមានការពឹងអាងលើ . . . . . . . . . . . . .២៩៥
**សំណួរទី៣៩៖**
តើសេចក្តីស្រឡាញ់ជាអ្វី?. . . . . . . . . . . . . . . . . . . . . . . . . . . .៣០៣
**សំណួរទី៤០៖**
បើព្រះមានភាពគ្រប់គ្រាន់សម្រាប់គាត់
ហេតុអ្វីលោក អ័ដាម មានភាពឯកោ?. . . . . . . . . . . . . . . . . . . ៣១១

## ផ្នែកទី៦
## ការចិញ្ចឹមបីបាច់ថែរក្សាកូន

**សំណួរទី៤១៖**
រកពេលអានព្រះគម្ពីរ សម្រាប់ម្តាយដែលរវល់ . . . . . . . . . . . . . . ៣១៩
**សំណួរទី៤២៖**
តើការចិញ្ចឹមកូនគឺជារឿងស្មុគស្មាញ
ឬក៏ជារឿងសាមញ្ញ?. . . . . . . . . . . . . . . . . . . . . . . . . . . . ៣២៥
**សំណួរទី៤៣៖**
របៀប៦យ៉ាងសម្រាប់ឪពុកម្តាយ
ដែលមានកូនរឹងចចេសអាចតយុទ្ធជាមួយបាន ដើម្បីជំនឿ. . . . . . . . ៣២៩
**សំណួរទី៤៤៖**
ការថែរក្សាព្រលឹងសម្រាប់អ្នកម្តាយវ័យក្មេងដែលនឿយហត់. . . . . . .៣៣៧
**សំណួរទី៤៥៖**
តើអ្វីទៅជាគោលដៅប្រចាំថ្ងៃនៃការចិញ្ចឹមកូន?. . . . . . . . . . . . . . ៣៤៥

## ផ្នែកទី៧
## ការប្រើប្រាស់បណ្តាញសង្គម និងបច្ចេកវិទ្យា

**សំណួរទី៤៦៖**
តើការស្វែងរកខគម្ពីរដោយប្រើប្រព័ន្ធឌីជីថល (digital)
ល្អជាងការចងចាំខគម្ពីរមែនឬ? . . . . . . . . . . . . . . . . . . . . ៣៥១
**សំណួរទី៤៧៖**
ធ្វើដូចម្តេចឲ្យខ្ញុំអាចស្រឡាញ់ព្រះ
ខ្លាំងជាងការកម្សាន្តសប្បាយរបស់ខ្ញុំ? . . . . . . . . . . . . . . . . . . ៣៥៥
**សំណួរទី៤៨៖**
ប្រសិនបើខ្ញុំស្តាប់ការអធិប្បាយ
ហេតុអ្វីខ្ញុំត្រូវអានព្រះគម្ពីរទៀត? . . . . . . . . . . . . . . . . . . . . . .៣៦៣
**សំណួរទី៤៩៖**
តើការចំណាយពេលស្តាប់ព្រះគម្ពីរជាសំឡេងគ្រប់គ្រាន់
សម្រាប់ការចំណាយពេលជាមួយនឹង ព្រះជាម្ចាស់ដែរឬទេ?. . . . . . . ៣៦៩
**សំណួរទី៥០៖**
ហេតុអ្វីទំនាក់ទំនងមានភាពទន់ខ្សោយនៅក្នុង
សម័យកាលដ៏ទំនើបនេះ?. . . . . . . . . . . . . . . . . . . . . . . . . . .៣៧៧
**កំណត់យោង** . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៣៨៣

# ផ្នែកទី១
# ទេវវិទ្យា និងការសិក្សាព្រះគម្ពីរ

# សំណួរទី១៖
# ផ្ទុយពីសាសនាកាតូលិករ៉ូម៉ាំង ព្រះគម្ពីរគឺជាអំណាចគ្រប់គ្រាន់សម្រាប់យើង

ខគម្ពីរដែលល្បីនៅក្នុងសម័យកំណែទម្រង់ (The Reformation) គឺកណ្ឌគម្ពីរ រ៉ូម ១:១៧ «ដ្បិតសេចក្តីសុចរិតនៃព្រះ បានសម្តែងមកក្នុងដំណឹងល្អនោះ ដោយសារសេចក្តីជំនឿ ហើយឲ្យបានសេចក្តីជំនឿចម្រើនច្រើនឡើងផង ដូចមានសេចក្តីចែងទុកមកថា “មនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្តីជំនឿ”»។ នេះគឺជាខគម្ពីរដែលលោកគ្រូ ម៉ាធិន លូស៊ើរ (Martin Luther) បានវែកញែកនៅសម័យនោះ។

លោកគ្រូដឹងហើយថា នៅឆ្នាំនេះ ខួបសម័យកំណែទម្រង់គឺនៅថ្ងៃអង្គារទី៣០ ខែតុលា ឆ្នាំ២០២៣។ ឆ្នាំនេះគឺជាខួបលើកទី៥០៦ឆ្នាំ ដោយសារព្រឹត្តិការណ៍នេះបានកើតឡើងនៅឆ្នាំ១៥១៧។ លោកគ្រូ លូស៊ើរ បានសរសេរនិក្ខេបបទ៩៥ (Ninety-Five Theses) របស់គាត់ ហើយផ្ញើទៅកាន់លោកមហាសន្និបាត (Archbishop) នៅសម័យនោះ។ ខ្ញុំមានពីរសំណួរ ទាក់ទងនឹងចំណុចដែលនាំឲ្យពួកក្រុងរ៉ូម (Rome) បែកគ្នាពីទីក្រុងហ្សឺណែវ (Geneva)។

*«ជម្រាបសួរលោកគ្រូ! ថ្មីៗនេះ ខ្ញុំមានមិត្តភក្តិដែលជាអ្នកនិកាយប្រូតេស្តង់មួយចំនួន ដែលតឡូវពួកគាត់បានប្តូរជំនឿទៅជានិកាយរ៉ូម៉ាំងកាតូលិក (Roman Catholic) ហើយចំណុចគន្លឹះមួយគឺទាក់ទងទៅនឹងសំណួរដែលថា តើព្រះគម្ពីរគឺជាអំណាចផ្តាច់ការនៅក្នុងជំនឿរបស់យើងមែនឬ? បន្ទាប់ពីខ្ញុំបានពិនិត្យមើលចំណុចវែកញែករបស់និកាយរ៉ូម៉ាំងកាតូលិក ខ្ញុំក៏ចាប់ផ្តើមឲ្យតម្លៃលើចំណុចបញ្ចុះបញ្ចូលរបស់ពួកគាត់។ ប៉ុន្តែ ខណៈពេលដែល*

*ខ្ញុំព្យាយាមវែកញែកជាមួយនឹងអ្នកនិកាយប្រូតេស្តង់ នោះខ្ញុំមិនទាន់បានឃើញថា ពួកគាត់មិនមានចំណុចវែកញែកឆ្លើយតបយ៉ាងម៉ឺងម៉ាត់ ដែលមានសភាពស្មើគ្នាទៅនឹងចំណុចរបស់និកាយកាតូលិករ៉ូម៉ាំង ទាក់ទងទៅនឹងគោលជំនឿកំណែតម្រង់ «តាមរយៈតែព្រះបន្ទូលប៉ុណ្ណោះ» (Sola scriptura)។ សូមលោកគ្រូជួយវែកញែកដោយបញ្ចុះបញ្ចូលឲ្យខ្ញុំយល់ ដើម្បីឲ្យខ្ញុំពិតជាជឿលើគោលជំនឿសម័យកំណែទម្រង់មែន»។*

ខ្ញុំមិនដឹងថា ខ្ញុំនឹងអាចបញ្ចុះបញ្ចូលអ្នកសួរបានដែរ ឬក៏អត់ទេ។ ខ្ញុំគិតថាមានអត្ថបទមួយចំនួនដែលអាចជួយបាន ប៉ុន្តែនេះគឺជាអ្វីដែលខ្ញុំចង់លើកឡើង។ នេះជាអ្វីដែលបានទ្រទ្រង់ខ្ញុំ ហើយខ្ញុំសង្ឃឹមថា វាអាចជាជំនួយដល់អ្នកសួរដែរ។ ខ្ញុំមានបីចំណុច ក្នុងការឆ្លើយតប ដែលខ្ញុំសង្ឃឹមថានឹងជួយ គឺជួយឲ្យអ្នកសួរបដិសេធក្នុងការធ្លាក់ក្នុងសេចក្តីល្បួងនៃការប្តូរនិកាយចូលសាសនាកាតូលិករ៉ូម៉ាំង។

## ១) ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

ចំណុចនេះមានន័យថា គ្មានអំណាចមនុស្សណា ឬក៏ស្ថាប័នណាដែលអាចបម្រើដោយកំពុងនៅជាប់ជាមួយនឹងព្រះគម្ពីរ ដោយមានអំណាចស្មើគ្នាបានទេ។ មិនថាសម្តេច ប៉ាប អ្នកប្រឹក្សា វិជ្ជាករ បូជាចារ្យ គ្រូគង្វាល ឬក៏បវេណីមនុស្សណាម្នាក់ទេ ទាំងអស់មិនមានអំណាចស្មើនឹងព្រះគម្ពីរ ប្រសិនបើព្រះគម្ពីរគឺពិតជាព្រះបន្ទូលរបស់ព្រះជាម្ចាស់មែន។ ហើយយើងដឹងហើយថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតមែន។

លើសពីនេះទៅទៀត គ្មានកន្លែងណាក្នុងព្រះគម្ពីរ ដែលមានចែងអំពីការផ្តល់អំណាចដល់បុគ្គលណា ឬក៏និកាយក្រុមជំនុំណា ដែលមានលក្ខណៈស្មើគ្នាទៅនឹងព្រះគម្ពីរផ្ទាល់នោះទេ។ ព្រះគ្រីស្ទបានប្រទានដល់ក្រុមជំនុំឲ្យមានគ្រូគង្វាល និងគ្រូបង្រៀន (អេភេសូរ ៤:១១)។ តួនាទីរបស់



ពួកគាត់គឺមិនមែនប្រកាសការបើកសម្តែងថ្មីៗ ប៉ុន្តែគឺឲ្យឈរលើមូលដ្ឋានគ្រឹះនៃពួកសាវ័ក និងពួកហោរាវិញ។ ហើយសាវ័ក ប៉ុល ក៏បានលើកឡើងយ៉ាងច្បាស់លាស់ផងដែរថា នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៨ ត្រង់ថាអំណាចរបស់អ្នកដែលកាន់នៅក្នុងក្រុមជំនុំ គឺពួកគាត់ត្រូវតែមានការឆ្លើយតបជាមួយនឹងព្រះបន្ទូល គឺមិនមែនជាមួយនឹងខ្លួនឯងនោះទេ។ នេះគឺជាការឆ្លើយតបដំបូងរបស់ខ្ញុំ។

## ២) សតិសម្បជញ្ញៈរបស់ខ្លួន

ការអនុញ្ញាតឲ្យសតិសម្បជញ្ញៈរបស់ខ្លួនចុះចូលក្រោមអំណាចរបស់មនុស្ស ក្រៅពីព្រះគម្ពីរ គឺមិនមែនជាអ្វីដែលស្របតាមព្រះគម្ពីរ ហើយក៏ជាអ្វីដែលមានប្រាជ្ញាដែរ។ នេះគឺជាពាក្យដ៏ល្បីមួយរបស់លោកគ្រូ ម៉ាធិន លូសើរ។ ប្រាកដណាស់ វាមិនអាចទៅរួចបានទេ—សូមព្យាយាមយល់ចំណុចនេះ—វាមិនអាចទៅរួចបានទេ ក្នុងការមានជំនឿដែលស្របតាមព្រះគម្ពីរក្នុងសេចក្តីពិតណាមួយដែលយើងជឿថា មិនមាននៅក្នុងព្រះគម្ពីរ។ នេះមិនមែនជាលក្ខណៈនៃជំនឿដែលស្របតាមព្រះគម្ពីរទេ។ នេះមិនមែនជាលក្ខណៈនៃការចុះចូលចំពោះព្រះជាម្ចាស់ ដែលស្របតាម ឬក៏មានភាពស៊ីគ្នាទៅនឹងព្រះគម្ពីរ នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ក្នុងការឱនក្រាបចុះចូលក្រោមអំណាចរបស់បុគ្គលណាម្នាក់ដែលបង្រៀននៅអ្វីដែលផ្ទុយគ្នាពីព្រះបន្ទូល។

នេះមានន័យថា ទីកន្លែងចុងក្រោយ និងពិតប្រាកដនៃអំណាចគឺមានតែនៅក្នុងព្រះបន្ទូលប៉ុណ្ណោះ ហើយតុលាការចុងក្រោយនៃការកាត់ស្រាយនូវអ្វីដែលព្រះបន្ទូលបង្រៀនគឺមានតែតាមរយៈការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងសតិសម្បជញ្ញៈរបស់យើងដែរ។ ហើយខ្ញុំចង់បញ្ជាក់ថា អំណាចនោះគឺមិនមែនមាន ជាបន្ទាប់បន្សំ ជាមួយនឹងបុគ្គលណាម្នាក់នៅក្រៅព្រះគម្ពីរ និងនៅក្រៅសតិសម្បជញ្ញៈនៅឡើយ។ ជំនឿស៊ុបនេះមាន

ឬសគល់តែនៅក្នុងលក្ខណសម្បត្តិនៃជំនឿដែលស្របតាមព្រះគម្ពីរ និងនៅក្នុងតែលក្ខណសម្បត្តិនៃការចុះចូលដែលស្របតាមព្រះគម្ពីរប៉ុណ្ណោះ។ នេះគឺជាអ្វីដែលខ្ញុំចង់មានអត្ថន័យ។

ការបង្រៀនថា មានអំណាចមួយណាផ្សេងទៀត នៅក្រៅព្រះគម្ពីរ ដែលអាចចងសតិសម្បជញ្ញៈរបស់មនុស្សយើងឲ្យទាស់នឹងអ្វីដែលវាឃើញនៅក្នុងព្រះបន្ទូល គឺជាការទាមទារឲ្យជំនឿ និងការចុះចូលនោះក្លាយជាទង្វើដែលមិនមែនជាការយល់ដឹង ប៉ុន្តែគ្រាន់តែជាទង្វើនៃការចុះចូលដែលខ្វាក់ចំពោះអំណាចនោះ នៅខាងក្រៅវិញ។ គឺមាននៅក្នុងលក្ខណៈនៃជំនឿដែលបុគ្គលណាម្នាក់មិនអាចទទួលជឿថា មានអ្វីមួយស្របតាមព្រះគម្ពីរ ខណៈពេលដែលគាត់ឃើញថាវាផ្ទុយគ្នាទាំងស្រុងពីអ្វីដែលគាត់ឃើញមានចែងនៅក្នុងព្រះគម្ពីរ ដោយពឹងលើអ្វីដែលបុគ្គលណាម្នាក់ផ្សេងទៀតលើកឡើងថាជាការពិត។ បុគ្គលនោះមិនអាចធ្វើដូច្នេះបានឡើយ។ នេះគឺជាលក្ខណៈនៃជំនឿ។

លោកអ្នកមិនអាចទទួលជឿថា មានចំណុចណាមួយស្របតាមព្រះគម្ពីរបានឡើយ ខណៈពេលដែលលោកអ្នកមិនឃើញថា វាស្របតាមព្រះគម្ពីរទាល់តែសោះ មិនថាមាននរណាមកប្រាប់ឲ្យលោកអ្នកជឿយ៉ាងដូច្នោះក៏ដោយ។ ប្រសិនបើខ្ញុំឃើញថា មានចំណុចណាមួយនៅក្នុងព្រះគម្ពីរ ប៉ុន្តែចុះចូលក្រោមអំណាចដែលបង្រៀននូវចំណុចដែលខុសគ្នាទាំងស្រុងពីព្រះគម្ពីរ នោះមានន័យថា ខ្ញុំកំពុងតែក្បត់ជំនឿ ហើយក៏កំពុងតែលើកអំណាចនោះខ្ពស់ជាងព្រះគម្ពីរដែរ។ ហើយនេះមានន័យថា ខ្ញុំក៏កំពុងតែធ្វើនូវអ្វីដែលមិនអាចធ្វើទៅរួចបាន៖ ការបង្ខំឲ្យខ្លួនឯងជឿថា មានចំណុចណាមួយស្របតាមព្រះគម្ពីរ ខណៈពេលដែលខ្ញុំឃើញថាចំណុចនោះមិនស្របតាមព្រះគម្ពីរឡើយ។ នេះគឺជាការឆ្លើយតបទី២របស់ខ្ញុំ។



### ៣) សូមសម្រេចចិត្តថា លោកអ្នកនឹងទៅក្រុមជំនុំមួយណា

នេះគឺជាចំណុចដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ពីព្រោះវាមិនមែនជាអ្វីដែលមនុស្សជាច្រើនធ្វើឡើយ ពោលគឺចូលរួមក្រុមជំនុំមួយណាឲ្យបានជាក់លាក់ និងជាប់លាប់។ ក្នុងរំពេចនេះ ទាក់ទងនឹងសំណួរមួយនេះ សូមកុំគ្រាន់តែផ្តោតលើចំណុចនៃអំណាច ដោយមិនផ្តោតលើចំណុចនៃគោលជំនឿផ្សេងៗ។

ការធ្វើបែបនោះគឺហាក់បីដូចជាថា អ្នកប្រកាន់ភ្ជាប់តាមជំនឿនិកាយប្រូតេស្តង់ ដែលមានជំនឿស៊ីបស្របតាមសេចក្តីពិតនៅក្នុងព្រះគម្ពីរ គឺគាត់កំពុងតែដើរចូលសេចក្តីងងឹតដោយបិទភ្នែក ដើម្បីឱបក្រសោបគោលជំនឿសាសនាកាតូលិករ៉ូម៉ាំង ដែលបង្រៀនថា៖ ១) ការជ្រមុជទឹកអាចនាំឲ្យមានការកើតជាថ្មី ដែលតាមពិតទៅការបង្រៀនបែបនេះកំពុងតែបន្ទាបចំណុចសំខាន់នៃព្រះគម្ពីរទាក់ទងទៅនឹងជំនឿដែលសង្គ្រោះ ដែលថានេះគឺគ្រាន់តែជាសញ្ញាសម្គាល់នៃការកើតជាថ្មីតែប៉ុណ្ណោះ ២) គោលជំនឿនៃការរាប់ជាសុចរិតលើអ្វីដែលព្រះជាម្ចាស់បានធ្វើការនៅក្នុងខ្ញុំ ដែលមិនមានមូលដ្ឋានលើព្រះគ្រីស្ទមួយអង្គ តាមរយៈជំនឿតែមួយគត់ ៣) គោលជំនឿនៃការប្តូរធាតុក្នុងពិធីលៀងព្រះអម្ចាស់ និងការបង្ហូរព្រះគុណតាមរយៈនំប៉័ង និងស្រាទំពាំងបាយជូរ ៤) គោលជំនឿនៃការបង់លុយលោះបាបកម្មជាយុទ្ធសាស្ត្រនៃវិប្បដិសារីទណ្ឌកម្ម និងការអត់ទោសដែលសម្តេច ប៉ាប ទើបតែបង្រៀនជាថ្មីម្តងទៀត ហើយក៏បានសង្កត់លើយ៉ាងច្បាស់លាស់។

យើងបានគិតថា ការបង្រៀនបែបនោះលែងមានទៀតហើយ ប៉ុន្តែតាមពិតទៅ វានៅមាននៅឡើយទេ ដូចជាការបង្រៀនអំពីការអភិសេកនាង ម៉ារា ការអធិស្ឋានទៅព្រះមាតា ដោយលើកឋានៈនាងស្មើទៅនឹងព្រះសង្គ្រោះ។ ការបង្រៀនបែបនេះបន្ទាបបន្ថោកចំណុចស្នូលរបស់ព្រះយេស៊ូវគ្រីស្ទ ក្នុងជំនឿរបស់មនុស្សរាប់លាននាក់។

សរុបសេចក្តីទៅ បើនិយាយម្យ៉ាងវិញទៀត នៅពេលដែលលោកអ្នកគិតអំពីចំណុចនៃអំណាច—ដែលនេះផ្តោតទៅលើព្រះគម្ពីរតែមួយគត់ ជាជាងទៅលើអំណាចក្រុមជំនុំនិកាយសាសនារ៉ូម៉ាំងកាតូលិក—តើលោកអ្នកពិតជាហ៊ានផ្តោតតែលើចំណុចនេះមែន? ក្នុងនាមជាអ្នកប្រកាន់ភ្ជាប់តាមនិកាយប្រូតេស្តង់ តើលោកអ្នកហ៊ានមើលរំលងពិធីបង្គួរព្រះគុណរបស់និកាយសាសនាកាតូលិក ដែលពិធីនោះផ្ទុយគ្នាទាំងស្រុងពីអ្វីដែលលោកអ្នកឃើញនៅក្នុងព្រះគម្ពីរមែនឬ? ប្រសិនបើហ៊ាន តើលោកអ្នកស្ម័គ្រចិត្តក្នុងការបោះបង់សតិសម្បជញ្ញៈរបស់ខ្លួនចោល ហើយនិយាយថា «ខ្ញុំមិនឃើញនូវអ្វីដែលខ្ញុំឃើញនោះទេ»។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
Contrary to Roman Catholics, the Bible Is Our Sufficient Authority
**ផ្ទុយពីសាសនាកាតូលិករ៉ូម៉ាំង ព្រះគម្ពីរគឺជាអំណាចគ្រប់គ្រាន់សម្រាប់យើង**
https://www.desiringgod.org/interviews/
contrary-to-roman-catholics-the-bible-is-our-sufficient-authority



## សំណួរទី២៖
## តើ «ផែនដីចាស់» កើតចេញពីការវិវត្តន៍មែនឬ?

«តើលោកគ្រូជឿថា «ផែនដីចាស់» ហើយកើតចេញពីការវិវត្តន៍មែនឬ?»

ប្រសិនបើតាមរយៈពាក្យ «ទទួលជឿ» អ្នកសួរចង់មានន័យថា «តើមានគ្នាក្នុងចំណោមពួកចាស់ទុំយើង ដែលប្រកាន់ខ្ជាប់តាមទ្រឹស្តីដែលថាផែនដីចាស់?» នោះចម្លើយគឺថា «មែនហើយ មាន!»។

ប្រសិនបើតាមរយៈពាក្យ «ទទួលជឿ» អ្នកសួរចង់មានន័យថា «តើនេះគឺជាទស្សនៈដែលខ្ញុំប្រកាន់ខ្ជាប់តាមផ្ទាល់មែនឬ?» នេះគឺជាចម្លើយដែលខ្ញុំបានលើកឡើង។ ខ្ញុំគិតថា មានទស្សនៈពីរយ៉ាងយោងតាមព្រះគម្ពីរ។

### ១) ផែនដីថ្មី

យោងតាមកណ្ឌគម្ពីរលោកុប្បត្តិ ជំពូក១៖ មើលទៅហាក់បីដូចជាថាក្នុងអត្ថន័យដើមគឺផែនដីមានអាយុកាលនៅក្មេង ព្រោះនេះសំដៅទៅលើថ្ងៃដែលមាន២៤ម៉ោង មិនមែនថ្ងៃបែបជាសម័យកាលឡើយ។

### ២) ទស្សនៈរបស់លោកគ្រូ ចន សិលហាម័រ (John Sailhamer)

ក្នុងសៀវភៅដែលគាត់បាននិពន្ធដែលមានចំណងជើងជាភាសាអង់គ្លេសថា “Genesis Unbound” ក៏ដូចជានៅ ក្នុងសៀវភៅនានារបស់គាត់ គាត់បានលើកឡើងថា ការបង្កើតទាំងអស់បានកើតឡើងក្នុងអំឡុងពេលនៃខ១ និងខ២នៃកណ្ឌគម្ពីរលោកុប្បត្តិ ជំពូក១។ ផែនដីអាចមានអាយុកាល ៤ទ្រីលានឆ្នាំ ទាក់ទងទៅនឹងអ្វីដែលគាត់បានចាប់អារម្មណ៍ ហើយអ្វីដែលបានកើតឡើងក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ជំពូក១៖ ថ្ងៃនីមួយៗមិនមែនជាការនាំមកនូវការបង្កើតនៃផែនដី និងរូបរាងផ្សេងៗរបស់វានោះទេ

ប៉ុន្តែផ្ទុយទៅវិញ គឺសំដៅទៅលើការរៀបរៀង ពោលគឺការគ្រប់គ្រង និងការរចនានានា។ ចំណុចនេះអនុញ្ញាតឲ្យមានពេលវេលាទាំង២៤ម៉ោង និងផែនដីចាស់។

ខ្ញុំផ្អែកលើជំហរនេះជាង។ ខ្ញុំជឿថាលោក អ័ដាម មិនបានវិវត្តន៍ក្លាយជាមនុស្សនោះទេ។ ខ្ញុំជឿថា ព្រះជាម្ចាស់បានបង្កើតលោក អ័ដាម មកចេញពីដី។ ខ្ញុំជឿថាគាត់ពិសេស ហើយគាត់ក៏ជាបិតានៃរាល់មនុស្សជាតិទាំងអស់ដែរ—លោក អ័ដាម និងនាង អេវ៉ា—ហើយថាគាត់ក៏មិនមែនជាលទ្ធផលពីការវិវត្តន៍ដែលកើតឡើងអស់ជាច្រើនឆ្នាំនោះឡើយ។ ខ្ញុំមិនអាចកាត់ស្រាយខគម្ពីរនេះឲ្យទៅជាអ្វីដែលខគម្ពីរមិនមានអត្ថន័យបាននោះទេ។

ខ្ញុំក៏គិតថាវាជាការដ៏សំខាន់ណាស់ដែលថាលោក អ័ដាម គឺជាបុគ្គលពិតមែនក្នុងប្រវត្តិសាស្ត្រ ពីព្រោះនោះឯងគឺជារបៀបដែលអ្នកនិពន្ធកណ្ឌគម្ពីរផ្សេងៗបានចាត់ទុកគាត់។ ប្រសិនបើលោក អ័ដាម មិនមែនជាបុគ្គលពិតក្នុងប្រវត្តិសាស្ត្រ នោះចំណុចស្នូលនៃកណ្ឌគម្ពីរ រ៉ូម ជំពូក៥ និងដួលរលំចុះ ហើយចំណុចដែលថាព្រះជាម្ចាស់បានធ្វើសេចក្ដីតាំងសញ្ញាជាមួយនឹងលោក អ័ដាម ហើយបន្ទាប់មកគាត់បានបរាជ័យ ហើយថាព្រះគ្រីស្ទគឺជាលោក អ័ដាម ទីពីរនឹងគ្មានន័យជាមិនខាន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Do You Accept "Old Earth" and Evolution?
**តើ «ផែនដីចាស់» កើតចេញពីការវិវត្តន៍មែនឬ?**
https://www.desiringgod.org/interviews/do-you-accept-old-earth-and-evolution



## សំណួរទី៣៖
# វិធីប្រាំយ៉ាងព្រះយេស៊ូវផ្លាស់ប្ដូរទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគម្ពីរសញ្ញាចាស់

តើព្រះយេស៊ូវបានផ្លាស់ប្ដូរទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគម្ពីរសញ្ញាចាស់ដោយរបៀបណា? វាជាសំណួរមួយដែលគេតែងតែសួរយើងស្ទើរតែគ្រប់ពេលតែម្ដង។ នេះជាឧទាហរណ៍ថ្មីៗពីរ។

នេះជាសំណួររបស់ប្រិយមិត្តអ្នកស្ដាប់ម្នាក់ឈ្មោះ តុលា មកពីទីក្រុងភ្នំពេញ៖ «ជម្រាបសួរ លោកគ្រូ! តើក្រឹត្យវិន័យទាំងដប់ប្រការមានតួនាទីអ្វីខ្លះ នៅក្នុងជីវិត និងព័ន្ធកិច្ចរបស់ក្រុមជំនុំសញ្ញាថ្មី? ប្រសិនបើក្រឹត្យវិន័យទាំងនេះ ជាផ្នែកនៃការតាំងសញ្ញាតាមលក្ខខណ្ឌរបស់ព្រះជាម្ចាស់ជាមួយនឹងរាស្ត្រអ៊ីស្រាអែល ដែលបានបាក់បែកនោះ តើមានការកាន់ខ្ជាប់ណាមួយនៃការប្រើប្រាស់សេចក្ដីបង្គាប់ទាំងនេះដែរឬទេ នៅក្នុងការផ្សាយដំណឹងល្អ ឬការណែនាំខាងឯសីលធម៌?»

នេះជាសំណួរផ្សេងទៀតមកពីប្រិយមិត្តអ្នកស្ដាប់ម្នាក់ឈ្មោះ ផាត់៖ «ជម្រាបសួរ លោកគ្រូ! តើមានច្បាប់សំខាន់ៗណាខ្លះ ដែលមានប្រយោជន៍ក្នុងការបកស្រាយក្រឹត្យវិន័យជាក់លាក់ណាមួយរបស់ព្រះគម្ពីរសញ្ញាចាស់ដែលមានឥទ្ធិពលចំពោះជីវិតរបស់គ្រីស្ទបរិស័ទសព្វថ្ងៃនេះដែរឬទេ ហើយតើហេតុអ្វី? ឧទាហរណ៍៖ កណ្ឌគម្ពីរលេវីវិន័យជំពូកទី ១៨-១៩ មានពេញទៅដោយក្រឹត្យវិន័យផ្សេងៗគ្នា ដែលទាស់ប្រឆាំងនឹងអំពើអសីលធម៌ផ្លូវភេទ និងការថ្វាយទារកជាយញ្ញបូជា។ ខ្ញុំគិតថា វាមានសុវត្ថិភាពក្នុងការនិយាយថា អ្នកស្ដាប់ភាគច្រើននៃការផ្សាយដំណឹងល្អនឹងយល់ស្របតាមថា បទបញ្ញត្តិទាំងនេះមានឥទ្ធិពលទៅលើគ្រីស្ទបរិស័ទបច្ចុប្បន្ន។ ទោះជាយ៉ាងណា

នៅជំពូកដដែលបានព្រមានទាស់នឹងការស្លៀកពាក់អ្វី ដែលលាយដោយអំបោះពីរយ៉ាង (លេវីវិន័យ ១៩:១៩) មិនត្រូវកោរសក់ក្រឡឹងជុំវិញក្បាល (លេវីវិន័យ ១៩:២៧) និងមិនត្រូវសាក់ខ្លួនផង (លេវីវិន័យ ១៩:២៨)។ តើមានវិធីដ៏មានប្រយោជន៍ណាមួយ ដើម្បីចូលទៅកាន់ព្រះគម្ពីរសញ្ញាចាស់ ដែលនឹងអាចជួយឲ្យបានយល់អំពីក្រឹត្យវិន័យផ្សេងៗទាំងនេះដែរឬទេ»។

លោកគ្រូ តើលោកគ្រូនឹងឆ្លើយដូចម្ដេច ចំពោះសំណួរទាំងនេះ ក៏ដូចជាសំណួររបស់ប្អូនប្រុស តុលា និងប្អូនប្រុស ផាត់ ដែរ?

## ព្រះគ្រីស្ទបានយាងមក

សំណួរដែលខ្ញុំកំពុងតែព្យាយាមឆ្លើយ គឺសាមញ្ញទេ «តើគ្រីស្ទបរិស័ទសញ្ញាថ្មី ដែលជឿថាព្រះយេស៊ូវគ្រីស្ទជាព្រះមេស្ស៊ីនោះ គួរតែធ្វើយ៉ាងណា ដើម្បីឲ្យបានស្របទៅនឹងបទបញ្ញត្តិទាំងឡាយរបស់ព្រះគម្ពីរសញ្ញាចាស់ នៅសម័យយើងនេះ»?

ខ្ញុំនឹងចាប់ផ្ដើម ដោយការនិយាយថា សូម្បីតែអ្នកនិពន្ធព្រះគម្ពីរសញ្ញាចាស់ក៏យល់ស្របដែរថា វានឹងមានភាពផ្ទុយគ្នាទៅនឹងព្រះគម្ពីរសញ្ញាចាស់ ក្នុងការធ្វើឲ្យស្របទៅតាមបទបញ្ញត្តិទាំងឡាយរបស់ព្រះគម្ពីរសញ្ញាចាស់ ក្រោយពីព្រះមេស្ស៊ីបានយាងមកហើយ តែធ្វើដូចកាលទ្រង់មិនទាន់បានយាងមកទេវិញ។ សូម្បីតែអ្នកនិពន្ធព្រះគម្ពីរសញ្ញាចាស់ក៏និយាយបែបនេះដែរ។

ព្រះមេស្ស៊ីបានយាងមកហើយ។ ព្រះយេស៊ូវគ្រីស្ទ ជាព្រះមេស្ស៊ី ហេតុដូច្នេះហើយ បានជាយើងមិនគ្រាន់តែធ្វើឲ្យតែស្របតាមបទបញ្ញត្តិទាំងឡាយរបស់ព្រះគម្ពីរសញ្ញាចាស់សម្រាប់ជីវិតរបស់យើងរាល់គ្នា ដូចកាលទ្រង់មិនទាន់បានយាងមកនោះដែរ។

ដូច្នេះ សូមឲ្យខ្ញុំចង្អុលបង្ហាញនូវវិធីប្រាំយ៉ាង ដែលព្រះគម្ពីរសញ្ញា



ថ្មីនិយាយអំពីការផ្លាស់ប្ដូរក្នុងការដែលយើងរាល់គ្នាប្រើប្រាស់បទបញ្ញត្តិទាំងឡាយរបស់ព្រះគម្ពីរសញ្ញាចាស់ ចាប់តាំងពីព្រះយេស៊ូវបានយាងមក។

## ការសុគតនៃយញ្ញបូជា

នេះជាចំណុចទីមួយ។ វិធីដ៏សាមញ្ញបំផុតក្នុងការរកឃើញពីការជាប់ពាក់ព័ន្ធដ៏មហិមានៃការយាងមកវិញរបស់ទ្រង់ គឺដើម្បីដឹងថា នៅពេលទ្រង់សុគត នៅពេលព្រះគ្រីស្ទបានសុគតជំនួសអំពើបាបរបស់ផងយើងរាល់គ្នា ទ្រង់បានបញ្ចប់រាល់ប្រព័ន្ធនៃការថ្វាយយញ្ញបូជាទាំងអស់នៅព្រះគម្ពីរសញ្ញាចាស់—ដោយសារការថ្វាយសត្វទាំងនោះជាយញ្ញបូជា និងការប្រតិបត្តិពិធីសាសនាទាំងនេះ នៅក្នុងព្រះវិហារ ឬរោងឧបោសថបានចង្អុលឆ្ពោះទៅកាន់យញ្ញបូជាដ៏ប្រសើរ ចុងក្រោយបង្អស់ ដែលបានពិពណ៌នានៅក្នុងកណ្ឌគម្ពីរអេសាយជំពូក៥៣ នៅពេលព្រះមេស្ស៊ីយាងមក។

ដូច្នេះ បទបញ្ញត្តិ និងច្បាប់រាប់រយទាក់ទងទៅនឹងការថ្វាយសត្វជាយញ្ញបូជា និងភាពជាសម្ដេចសង្ឃដ៏សកម្ម បានទិញលោះ ដើម្បីបញ្ចប់នូវរាល់ការថ្វាយយញ្ញបូជាទាំងអស់—«ធ្វើឲ្យសម្រេចវិញ» ដូចព្រះយេស៊ូវមានព្រះបន្ទូល នៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៥:១៧។ ដោយសារព្រះជន្ម និងការសុគតរបស់ផងព្រះយេស៊ូវ—ជាយញ្ញបូជាចុងក្រោយបង្អស់របស់ផងយើង និងជាសម្ដេចសង្ឃដ៏ខ្ពស់ចុងក្រោយបង្អស់របស់ផងយើង—គ្រប់ទាំងការថ្វាយយញ្ញបូជានឹងត្រូវផុតរលត់ទៅ។ នេះជាអ្វីដែលកណ្ឌគម្ពីរហេព្រើរចែងមកដើម្បីប្រាប់យើង។

ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ៧:២៧៖ «ទ្រង់មិនចាំបាច់នឹងថ្វាយយញ្ញបូជាជារាល់ថ្ងៃ ដូចជាសម្ដេចសង្ឃ ដែលថ្វាយដោយព្រោះបាបខ្លួនជាមុនដំបូង រួចមកដោយព្រោះបាបរបស់ជនទាំងឡាយនោះទេ ដ្បិតទ្រង់បានថ្វាយយញ្ញបូជានោះ១ដងជាសម្រេច គឺក្នុងកាលដែលទ្រង់

ថ្វាយព្រះអង្គទ្រង់នោះឯង»។ នោះគឺជាឃ្លាមួយក្នុងចំណោមឃ្លាសំខាន់បំផុតនានា នៅក្នុងកណ្ឌគម្ពីរ ហេព្រើរ៖ «១ដងជាសម្រេច គឺក្នុងកាលដែលទ្រង់ថ្វាយព្រះអង្គទ្រង់នោះឯង»។ ឃ្លានោះ «១ដងជាសម្រេច» គឺសំខាន់ណាស់។ សូមកត់ទុកនូវការប្រើប្រាស់ទាំងអស់របស់វានៅក្នុងកណ្ឌគម្ពីរហេព្រើរ។

### ពួករាស្ត្រថ្មីរបស់ព្រះជាម្ចាស់

ហេតុនេះ វាគឺជាការផ្លាស់ប្តូរដ៏ធំទីពីរ ដែលបានកើតឡើងជាមួយនឹងការត្រឡប់មកវិញរបស់ផងព្រះយេស៊ូវ។ វាចង្អុលទៅកាន់ការផ្លាស់ប្តូរមួយអំពីរបៀបនៃការប្រើប្រាស់ក្រឹត្យវិន័យ។ ព្រះយេស៊ូវកំពុងតែបង្កើតពួករាស្ត្រថ្មីរបស់ព្រះជាម្ចាស់ឡើង។ ក្រុមនេះត្រូវបានបង្កើតឡើងមិនមែនតែពីសាសន៍យូដានោះទេ ប៉ុន្តែពីមនុស្សទាំងអស់នៅលើពិភពលោកដែលបានជឿដល់ទ្រង់។

ដូច្នេះ នៅចុងកណ្ឌគម្ពីរម៉ាថាយមានចែងថា៖ «ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ» (ម៉ាថាយ ២៨:១៩)។ សាសន៍យូដា និងមនុស្សដទៃរាប់ពាន់នាក់ផ្សេងទៀតនៃក្រុមមនុស្សផ្សេងៗនៅលើភពផែនដីយើងនេះគួរតែធ្វើជាពួកសាវ័ក។ ដ្បិតពេលវេលាបានកន្លងហួសទៅហើយ សម្រាប់ការផ្តោតសំខាន់ជាចម្បងរបស់ព្រះជាម្ចាស់ទៅលើសាសន៍អ៊ីស្រាអែល ថាគេជារាស្ត្រនៃសេចក្តីតាំងសញ្ញាដែលទ្រង់បានប្រោះលោះ ដែលទ្រង់បានធ្វើអស់ជាងពីរពាន់ឆ្នាំមកហើយ។ នៅក្នុងកណ្ឌគម្ពីរលូកាបានចែងបែបដូច្នេះថា៖ «ពែងនេះជាសញ្ញាថ្មី ដែលតាំងដោយនូវឈាមខ្ញុំ គឺជាឈាម ដែលត្រូវច្រួចចេញសម្រាប់អ្នករាល់គ្នា» (លូកា ២២:២០)។ នេះរាប់បញ្ចូលដល់អស់អ្នកណា ដែលជឿដល់ព្រះមេស្ស៊ី និងអស់អ្នកណាដែលមានដួងចិត្តថ្មី។

ព្រះយេស៊ូវមានព្រះបន្ទូលជាការព្រមាននៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២១:៤៣។ ទ្រង់មានព្រះបន្ទូលថា «ដូច្នេះ ខ្ញុំប្រាប់អ្នករាល់គ្នាថា នគរព្រះនឹងត្រូវហូតចេញពីអ្នករាល់គ្នា»—កំពុងសំដៅដល់អ្នកដឹកនាំសាសន៍យូដា ដែលជាអ្នកតំណាងនៃសាសន៍អ៊ីស្រាអែល—«ហើយប្រគល់ទៅឲ្យសាសន៍១ទៀត ដែលគេនឹងបង្កើតផលរបស់នគរនោះ»។ នោះជាក្រុមជំនុំដែលរួមបញ្ចូលអស់ទាំងសាសន៍យូដាដែលជឿដល់ទ្រង់។

គ្រប់ជាតិសាសន៍ទាំងអស់ និងអស់ទាំងសាសន៍យូដាដែលជឿដល់ទ្រង់ ជាបណ្តារាស្ត្រថ្មីដែលបង្កើតផលផ្លែ ហើយការផ្លាស់ប្តូរបានកើតឡើងដោយប្តូរពីការផ្តោតសំខាន់តែទៅលើសាសន៍អ៊ីស្រាអែលត្រឡប់ទៅជាការផ្តោតសំខាន់ទៅលើបណ្តារាស្ត្រថ្មីរបស់ផងព្រះជាម្ចាស់នេះវិញ។

ការជាប់ពាក់ព័ន្ធនេះ កើតមានឡើងសម្រាប់ភាពសមស្របទៅនឹងបទបញ្ញត្តិទាំងឡាយរបស់ព្រះគម្ពីរសញ្ញាចាស់គឺថា បទបញ្ញត្តិទាំងអស់ដែលមានក៏ដូចជាការរចនារបស់វា មានភាពខុសប្លែកគ្នារវាងពិធីសាសនារបស់សាសន៍អ៊ីស្រាអែល និងប្រជាជាតិនានាបានដល់ទីបញ្ចប់ហើយ ដោយសារពេលនេះប្រជាជាតិទាំងនោះត្រូវបានរាប់បញ្ចូលទៅជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយនាំងឧបសគ្គផ្នែកវប្បធម៌ក៏កំពុងត្រូវបានដកចេញដែរ—ដូចជាបទបញ្ញត្តិទាក់ទងទៅនឹងការកាត់ស្បែក ម្ហូបអាហារ និងការតមអាហារផ្សេងៗ ក៏ដូចជាការត្បាញក្រណាត់ពីរផ្សេងគ្នា ដែលពួកគេមិនគួរពាក់ ដើម្បីបង្ហាញថាមានភាពខុសប្លែកគ្នារវាងអ៊ីស្រាអែល និងប្រជាជាតិនានា។ ព្រះយេស៊ូវមានបន្ទូលយ៉ាងចំៗនៅក្នុងកណ្ឌគម្ពីរ ម៉ាកុស ៧:១៩ ថាឥឡូវនេះអស់ទាំងម្ហូបអាហារបានសម្អាតសម្រាប់លោកអ្នករាល់គ្នាហើយ។

## ការវិលត្រឡប់ទៅកាន់ការបង្កើតវិញ

វិធីទីបី ក្នុងការរកឃើញពីការផ្លាស់ប្តូរដែលព្រះយេស៊ូវបាននាំមក ដែលនៅពេលនេះទ្រង់នាំយើងត្រឡប់ទៅក្រោយបទបញ្ញត្តិទាំងឡាយរបស់លោកម៉ូសេនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទៅនឹងការរចនាដំបូងរបស់ព្រះជាម្ចាស់ក្នុងការបង្កើត។ បន្ទាប់មក ទ្រង់ជំទាស់ថា បទបញ្ញត្តិនៅក្នុងករណីខ្លះ គឺការសម្របសម្រួលបណ្តោះអាសន្នជាមួយនឹងអំពើបាប ប៉ុន្តែកាលដើមដំបូងវាមិនមែនដូច្នេះទេ វាខុសពីនេះ។

នោះជាវិធីដែលទ្រង់ដោះស្រាយជាមួយនឹងព្រះគម្ពីរសញ្ញាចាស់—ឧទាហរណ៍៖ ទាក់ទងនឹងច្បាប់នៃការលែងលះ។ ខ្ញុំគិតដូចគ្នាទៅនឹងរឿងពហុពន្ធភាព។ ទ្រង់មានព្រះបន្ទូលថា ច្បាប់អនុញ្ញាតឲ្យលែងលះគ្នាបានតាក់តែងឡើង គឺដោយព្រោះតែ «ចិត្តអ្នករាល់គ្នារឹងរូសប៉ុណ្ណោះ» (ម៉ាកុស ១០:៥)។ បន្ទាប់មក ទ្រង់បានលើកយកកណ្ឌគម្ពីរ លោកុប្បត្តិ ២:២៤ មកមានព្រះបន្ទូលថា ព្រះជាម្ចាស់បានបង្កើតមនុស្សមកជាសាច់តែមួយ ដែលកុំឲ្យអ្នកណានឹងពង្រាត់ការផ្សំផ្គុំនេះឡើយ (ម៉ាកុស ១០:៤-៦)។ ដូច្នេះមានវិវាទនៃការបង្កើតនេះ ដែលនៅក្នុងការយាងមករបស់ផងព្រះយេស៊ូវមានអាទិភាពលើការសម្របសម្រួលផ្លូវច្បាប់នៅក្នុងព្រះគម្ពីរសញ្ញាចាស់។

## វិធីថ្មីក្នុងការចូលទៅជិតព្រះជាម្ចាស់

នេះជាវិធីទីបួន និងចុងក្រោយដែលខ្ញុំនឹងលើកមកនិយាយ។ វិធីទីបួនក្នុងការរកឃើញពីរបៀប ដែលរឿងរ៉ាវបានផ្លាស់ប្តូរជាមួយនឹងការត្រឡប់មកវិញរបស់ផងព្រះគ្រីស្ទ គឺដើម្បីឲ្យបានដឹងថា ដោយការសុគត និងព្រះវិញ្ញាណដែលគង់នៅរបស់ផងទ្រង់ ព្រះគ្រីស្ទបានដាក់ទំនាក់ទំនងរបស់យើងជាមួយផងព្រះជាម្ចាស់នៅលើទំព័រថ្មី។

«ដោយសារព្រះជន្ម និងការសុគតរបស់ផងព្រះយេស៊ូវ—ជាយញ្ញបូជាចុងក្រោយ និងជាសម្តេចសង្ឃខ្ពស់ចុងក្រោយបំផុតរបស់យើង—រាល់ប្រព័ន្ធនៃការថ្វាយយញ្ញបូជាទាំងអស់នឹងត្រូវផុតរលត់ទៅ»។

ច្បាប់របស់លោក ម៉ូសេ មិនមានគោលជំហរដូចគ្នានោះទេ សម្រាប់អស់អ្នកណាដែលបានស្លាប់ជាមួយព្រះគ្រីស្ទ និងរស់ឡើងវិញ ដើម្បីឲ្យបានដើរក្នុងជីវិតថ្មី។ បទគម្ពីរគន្លឹះនៅត្រង់នេះ គឺនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៧:៤-៦៖ «យ៉ាងដូច្នោះ បងប្អូនអើយ អ្នករាល់គ្នាក៏បានស្លាប់ពីខាងឯក្រឹត្យវិន័យដែរ ដោយសាររូបអង្គនៃព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានទៅជារបស់ផងអ្នកម្នាក់ទៀត»។ ដ្បិតពីមុនលោកអ្នករាល់គ្នាជាកម្មសិទ្ធិរបស់ក្រឹត្យវិន័យ ឥឡូវនេះ អ្នករាល់គ្នាបានទៅជារបស់ផងអ្នកម្នាក់ទៀត—«ដែលបានរស់ពីស្លាប់ឡើងវិញ ប្រយោជន៍ឲ្យយើងបានបង្កើតផលថ្វាយព្រះ»។

ម្យ៉ាងទៀត មានទំព័រថ្មីមួយបានលេចឡើង ជាវិធីថ្មីមួយក្នុងការដេញតាមសេចក្តីសុចរិត ហើយវាមិនមែនជាការគ្រាប់តាមបញ្ជី ឬគ្រាប់តាមច្បាប់នោះទេ។ វាជាការបង្កើតផលផ្លែ ពីព្រោះលោកអ្នករាល់គ្នាជារបស់ផងព្រះយេស៊ូវគ្រីស្ទ។ សាវ័ក ប៉ុល បានបន្ត៖ «ដ្បិតកាលយើងនៅខាងសាច់ឈាមនៅឡើយ នោះសេចក្តីរំជួលរបស់អំពើបាប ដែលកើតដោយនូវក្រឹត្យវិន័យបានបណ្តាលឲ្យអស់ទាំងអវយវៈ ក្នុងរូបកាយរបស់យើងរាល់គ្នា បង្កើតផលដល់សេចក្តីស្លាប់ តែឥឡូវនេះ យើងបានរួចពីក្រឹត្យវិន័យហើយ ដោយបានស្លាប់ក្នុងសេចក្តីដែលឃុំឃាំងយើងទុក ប្រយោជន៍ឲ្យយើងបានគោរពប្រតិបត្តិ ដោយវិញ្ញាណដែលបានកែជាថ្មីវិញ មិនមែនតាមតែន័យពាក្យពីបុរាណនោះទៀតឡើយ» (រ៉ូម ៧:៤-៦)។

នេះមិនមានន័យថា ក្រឹត្យវិន័យមិនមានកន្លែងឈរនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទទៀតទេ។ សូមពិចារណាលើឧទាហរណ៍មួយនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៧:១៩៖ «ព្រោះការកាត់ស្បែកមិនជាអ្វីទេ ឬដែលមិនកាត់ស្បែកនោះក៏មិនជាអ្វីដែរ តែដែលមានប្រយោជន៍ នោះគឺស្រេចនឹងកាន់តាមបញ្ញត្តិ

របស់ព្រះវិញ»។

នេះជាអត្ថបទដែលជាចំណោទមួយ ដោយសារតែការកាត់ស្បែក គឺជាបញ្ញត្តិមួយមែនទេ? ដូច្នេះ ទ្រង់កំពុងធ្វើការបែងចែកមួយចំនួននៅទីនោះថា តើបទបញ្ញត្តិណាមួយដែលយើងនៅបន្តគ្រាប់តាម ហើយមួយណាដែលមិនគ្រាប់តាម។

ឬនៅកណ្ឌគម្ពីរ ១យ៉ូហាន ៥:៣៖ «ដ្បិតនេះហើយជាសេចក្តីស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ ឯបញ្ញត្តិទ្រង់ នោះមិនមែនជាបន្ទុកដ៏ធ្ងន់ទេ»។

សំណួរចុងក្រោយ នៅក្នុងវិធីទីបួននៃការមើលទៅលើការផ្លាស់ប្តូរនេះ តើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដែលព្រះគម្ពីរសញ្ញាថ្មីបានផ្តល់មកឲ្យយើងនូវភាពសមស្របទៅនឹងការគ្រាប់តាមបទបញ្ញត្តិនានារបស់ព្រះជាម្ចាស់? សូមអនុញ្ញាតឲ្យខ្ញុំបានលើកឡើងនូវចំណុចបី។

## សេចក្តីស្រឡាញ់

ចំណុចទីមួយ ខ្ញុំកំពុងតែគិតអំពីសេចក្តីស្រឡាញ់។ ខ្ញុំកំពុងតែគិតអំពីកណ្ឌគម្ពីរ ម៉ាថាយ ២២:៣៧-៤០៖ «នោះព្រះយេស៊ូវឆ្លើយថា "ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង" នេះជាបញ្ញត្តិយ៉ាងសំខាន់ទី១ ហើយបញ្ញត្តិទី២ក៏បែបដូចគ្នា គឺថា៖ "ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង" បណ្តាក្រឹត្យវិន័យនិងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សម្រេចនៅបទបញ្ញត្តិទាំង២ប្រការនេះឯង»។

ឬនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១២:៧៖ «បើអ្នករាល់គ្នាបានយល់ន័យសេចក្តីដែលថា "អញចង់បានសេចក្តីមេត្តាករុណា មិនមែនយញ្ញបូជាទេ" នោះអ្នករាល់គ្នាមិនបានបន្ទោស ដល់ពួកអ្នកដែលគ្មានទោសឡើយ»។



ម្យ៉ាងទៀត មានសេចក្តីមេត្តាករុណា និងបញ្ញត្តិច្បាប់នានា ដែលរួមមានច្បាប់ទាំងឡាយ ក្រមសីលធម៌ ហើយបានក្លាយទៅជាគោលការណ៍ណែនាំសម្រាប់យើងសព្វថ្ងៃនេះ។

## គោលលទ្ធិដ៏ត្រឹមត្រូវ

ចំណុចទីពីរ យើងមានគោលលទ្ធិត្រឹមត្រូវស្របតាមដំណឹងល្អ។ ខ្ញុំកំពុងតែគិតអំពីកណ្ឌគម្ពីរ ១ធីម៉ូថេ ១:៨៖ «ឯយើងៗ ដឹងថា ក្រឹត្យវិន័យល្អមែន បើអ្នកណាប្រើតាមត្រឹមត្រូវ»។ បន្ទាប់មក ខគម្ពីរនេះនឹងផ្តល់បញ្ជីនៃបទបញ្ញត្តិផ្សេងៗទៀត ហើយបញ្ចប់ទៅដោយ «ព្រមទាំងការអ្វីដែលទាស់ទទឹងនឹងសេចក្តីបង្រៀនដ៏ត្រឹមត្រូវដែរ» (១ធីម៉ូថេ ១:១០)។

នោះជាអ្វីដែលបទបញ្ញត្តិទាំងឡាយត្រូវបង្កើតឡើងសម្រាប់៖ តើការទាស់ទទឹងនឹងសេចក្តីបង្រៀនដ៏ត្រឹមត្រូវជាអ្វី? សាវ័ក ប៉ុល បានបន្ថែម «នោះគឺតាមដំណឹងពីសិរីល្អនៃព្រះដ៏មានពរ» (១ធីម៉ូថេ ១:១១)។ តើមានបទបញ្ញត្តិណាខ្លះ ដែលស្របតាមច្បាប់នេះ?

## ធម្មជាតិ

ចំណុចចុងក្រោយទីបី តើអ្វីជាឫសគល់នៃធម្មជាតិ នៅពេលដែលព្រះជាម្ចាស់បានបង្កើតវាឡើង។

នោះគឺជារបៀបដែលសាវ័ក ប៉ុល បានវែកញែកនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១៣ ដូចមានទាក់ទងទៅនឹងអំណាចរបស់ស្ត្រីលើបុរស ហើយនោះគឺជារបៀបដែលគាត់បានវែកញែកនៅក្នុងកណ្ឌគម្ពីររ៉ូមជំពូក១ ដែលទាក់ទងទៅនឹងការស្រឡាញ់ភេទដូចគ្នា។

## ការស្វែងយល់បន្ថែម

ឥឡូវនេះ មានការចង្អុលបង្ហាញបន្ថែមជាច្រើនទៀតក្នុងព្រះគម្ពីរ

សញ្ញាថ្មី អំពីរបៀបដែលធ្វើឲ្យស្របទៅនឹងបទបញ្ញត្តិទាំងឡាយរបស់ព្រះគម្ពីរសញ្ញាចាស់ ប៉ុន្តែរបៀបទាំងនេះអាចគ្រប់គ្រាន់ក្នុងការចង្អុលបង្ហាញទៅកាន់ផ្លូវ។

ក្នុងការបញ្ចប់អត្ថបទនេះ ខ្ញុំចង់ព្យាយាមធ្វើឲ្យមានភាពសាមញ្ញ។ ប្រសិនបើខ្ញុំកំពុងតែជួយកុមារឲ្យអានព្រះគម្ពីរ ខ្ញុំនឹងនិយាយបែបដូច្នេះថា៖ «កូនតូចៗអើយ! រឿងមួយចំនួនបានបង្គាប់ក្នុងព្រះគម្ពីរសញ្ញាចាស់ មិនមែនជាអ្វីដែលយើងគួរធ្វើនៅសព្វថ្ងៃនេះទេ។ ពួកគេនិយាយត្រូវហើយ ពីអ្វីដែលរាស្ត្ររបស់ព្រះជាម្ចាស់ត្រូវធ្វើនៅពេលនោះ ប៉ុន្តែឥឡូវនេះ ព្រះយេស៊ូវបានយាងមក ហើយរឿងរ៉ាវសំខាន់ៗមួយចំនួនត្រូវបានផ្លាស់ប្តូរ»។

លោកអ្នករាល់គ្នាប្រហែលជាចំណាយពេលមួយខែ ដើម្បីជួយឲ្យកូនរបស់ខ្លួនយល់ថានោះជាអ្វី។ ប៉ុន្តែបន្ទាប់មក ខ្ញុំនឹងបញ្ចប់ដូចនេះ៖ «ឥឡូវនេះ នៅជំនាន់របស់យើង វិធីដែលមានសុវត្ថិភាពបំផុត ក្នុងការដឹងថាអ្វីត្រូវ និងអ្វីខុស គឺត្រូវឲ្យប្រាកដថាព្រះគម្ពីរសញ្ញាថ្មីបានបង្គាប់ឲ្យធ្វើវា ឬហាមឃាត់មិនឲ្យធ្វើវា»។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Five Ways Jesus Changes Our Relationship to the Old Testament
**វិធីប្រាំយ៉ាងព្រះយេស៊ូវផ្លាស់ប្តូរទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគម្ពីរសញ្ញាចាស់**
https://www.desiringgod.org/interviews/
five-ways-jesus-changes-our-relationship-to-the-old-testament



## សំណួរទី៩៖
# រូបភាពអាសអាភាស និងការទប់ទល់នឹងអំណាចនៃសេចក្តីល្បួង

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០១ លោកគ្រូបានអធិប្បាយនៅព្រះវិហារមួយនៅកណ្តាលគម្ពីរ រ៉ូម:៧។ អត្ថបទនោះមានចំណងជើងថា «សារៈសំខាន់នៃការស្គាល់អំពើបាបរបស់យើង»។ ប្រសិនបើសាវ័ក ប៉ុល បានអះអាងថា យើងត្រូវតែស្គាល់នូវអំណាចរបស់អំពើបាប នោះយើងនឹងត្រូវសួរសំណួរតាមបែបតក្កដូចតទៅ៖ តើមានន័យដូចម្តេច ដែលយើងត្រូវតែភ្លក់នូវបទពិសោធន៍នៃអំពើបាប ដើម្បីបានស្គាល់ពីអំណាចនៃអំពើបាប? នៅក្នុងការអធិប្បាយនៅឆ្នាំ២០២១នោះ លោកគ្រូបានឆ្លើយនូវសំណួរទាំងនោះក្នុងទម្រង់អវិជ្ជមាន ហើយគាត់បានលើកយករឿងប្រស្នាប្រៀបប្រដូចមួយអំពីការទប់ទល់នឹងសេចក្តីល្បួង។ នេះគឺជាអ្វីដែលគាត់បាននិយាយ៖

### រឿងប្រៀបប្រដូចនៃភាពយន្តអាសអាភាស

កុំធ្វើការពិសោធន៍នឹងអំពើបាប ដើម្បីឲ្យបានស្គាល់អំពើបាបឲ្យសោះ។ មានវិធីប្រសើរជាងនេះ។ សូមឲ្យខ្ញុំប្រើរឿងប្រស្នាប្រៀបប្រដូចមួយក្នុងការនិយាយអំពីវា។ អ្វីដែលខ្ញុំកំពុងធ្វើអ្វីនៅត្រង់នេះ គឺឆ្លើយទៅនឹងសំណួរ «តើលោកអ្នកមិនចាំបាច់ត្រូវតែធ្វើជាមនុស្សមានបាបទេ—ខ្ញុំចង់មានន័យថា ទៅប្រព្រឹត្តអំពើបាបខ្លះៗ ដើម្បីបានស្គាល់អំពើបាប គឺដូចជាលោកអ្នកគួរតែស្គាល់បាបនោះឡើយ?» នោះមិនមែនជាបញ្ហានោះទេ។

«កុំធ្វើការពិសោធន៍នឹងអំពើបាប ដើម្បីឲ្យបានស្គាល់អំពើបាបឲ្យសោះ។ មានវិធីប្រសើរជាងនេះ»។

កាលពីយូរលង់ណាស់មកហើយ មានបុរសបីនាក់ឈរនៅខាងមុខរណ្តៅជ្រៅមួយ។ រណ្តៅជ្រៅនោះជារណ្តៅនៃតណ្ហា (ខ្ញុំរៀបរាប់អំពីពួកបុរសៗ)។ គេបានចងចង្កេះពួកគេនឹងខ្សែមួយ ជាខ្សែដែលនឹងត្រូវសាកល្បងនឹងទម្ងន់មួយពាន់គីឡូក្រាម។ ខ្សែនោះនឹងទាញចូលទៅក្នុងរណ្តៅជ្រៅ។ រណ្តៅជ្រៅនោះ មើលទៅពិតជាគួរឲ្យទាក់ទាញខ្លាំងណាស់ តែវាអាចមានគ្រោះថ្នាក់ដល់អាយុជីវិត។ មានសត្វពស់ជាច្រើននៅបាតរណ្តៅដ៏ជ្រៅនោះ។ វាគឺជារណ្តៅនៃតណ្ហា រណ្តៅនៃរូបភាពអាសអាភាស ជារណ្តៅនៃរូបភាពអាក្រាតនៅលើអ៊ីនធឺណិត។ វាគ្រាន់តែចុចតែម្តងដល់បាតរណ្តៅភ្លាម។ បុរសទីមួយចាប់ផ្តើមប៉ះខ្សែពួរ ខ្សែនោះចាប់ផ្តើមទាញគាត់ចូលទៅក្នុងរណ្តៅភ្លាម ហើយគាត់បានទប់ទល់នឹងវា។

ទម្ងន់ដប់គីឡូក្រាម ដប់ប្រាំគីឡូក្រាម ម្ភៃគីឡូក្រាមទាញគាត់។ គាត់ប្រឹងយកកែងជើងគាត់ទប់។

ទម្ងន់សាមសិបគីឡូក្រាម ទាញគាត់។ គាត់និយាយថា៖ «ទេ»។

សាមសិបប្រាំគីឡូក្រាម ទាញគាត់។ វាកាន់តែតឹងឡើងៗ គាត់លែងទប់ទល់នឹងវា រួចក៏លោតចូលទៅក្នុងរណ្តៅនោះទៅ។

ចុចពឹប។

បុរសទីពីរ ចាប់ផ្តើមមានអារម្មណ៍ថា ខ្សែនោះកំពុងតែទាញនៅជុំវិញចង្កេះគាត់។

ទម្ងន់ប្រាំ ដប់ ដប់ប្រាំ ម្ភៃ ម្ភៃប្រាំ សាមសិបគីឡូក្រាមទាញគាត់។ គាត់ប្រឹងយកកែងជើងគាត់ទប់។ គាត់និយាយថា៖ «ទេ»។

ទម្ងន់សែសិប សែសិបប្រាំ ហាសិបគីឡូក្រាមទាញគាត់។ «ទេ!» គាត់ប្រឹងទប់ខ្លួនមកក្រោយ វាចាប់ផ្តើមតឹងឡើងៗធ្វើឲ្យគាត់រឹតតែពិបាកដកដង្ហើម។

ទម្ងន់ហាសិប ហាសិបប្រាំគីឡូក្រាមទាញគាត់។ «ទេ»។



ទម្ងន់ហុកសិបគីឡូក្រាមទាញគាត់។ គាត់លែងទប់ទល់រួចលោតចូលទៅ។

ចុចពឹប។

«តើលោកអ្នកមិនត្រូវធ្វើអំពើបាបឲ្យកាន់តែច្រើន ដើម្បីឲ្យបានដឹងថាអ្នកជាមនុស្សមានបាបកម្រិតណានោះទេ? ហើយចម្លើយគឺ ទេ លោកអ្នកមិនចាំបាច់ទេ»។ បុរសទីបីក៏បានចាប់ផ្តើមទាញចុះទៅដែរ។

ទម្ងន់ប្រាំ ដប់ ដប់ប្រាំ ម្ភៃប្រាំ សាមសិបគីឡូក្រាមទាញគាត់។ គាត់ប្រឹងយកកែងជើងគាត់ទប់។ គាត់ស្រែកលឺៗថា៖ «អត់ទេ»។

ទម្ងន់សែសិប សែសិបប្រាំ ហាសិបគីឡូក្រាមទាញគាត់។ វាចាប់ផ្តើមកាន់តែតឹងឡើងៗ ដង្ហើមរបស់គាត់ត្រូវបានដាច់ទៅ។ «អត់ទេ»។ គាត់ព្យាយាមទប់ខ្លួនមកក្រោយ គាត់ស្រែកយ៉ាងលឺៗឲ្យគេជួយថា៖ «ជួយផង!»។

គាត់បានឃើញមែកឈើមួយ ហើយក៏បានទាញមែកឈើនោះទៅ។ មែកឈើនោះមានរាងដូចជាឈើឆ្កាងអញ្ចឹង។

ទម្ងន់ហុកសិបប្រាំ ចិតសិបគីឡូក្រាម។

ហើយនៅជ្រុងម្ខាងនៅទីវាល—ក្រសែភ្នែកនៅក្នុងគំនិតរបស់គាត់មើលតាមអ័ព្ទយ៉ាងក្រាស់—គាត់បានឃើញប្រពន្ធរបស់គាត់កំពុងតែទៅធ្វើការ ហើយទុកចិត្តគាត់។ នៅជ្រុងម្ខាងទៀត គាត់បានឃើញកូនៗរបស់គាត់កំពុងតែលេងយ៉ាងសប្បាយរីករាយ ហើយនៅក្នុងចិត្តរបស់ពួកគេកំពុងតែកោតសរសើរគាត់។

នៅមើលគាត់បើកភ្នែករបស់គាត់មើលទៅជើងមេឃ ហើយគាត់បានឃើញព្រះយេស៊ូវ ដែលមានប្រឡោះយ៉ាងធំនៃចំហៀងទ្រង់ ហើយទ្រង់បានលើកព្រះហស្តទ្រង់ឡើង និងក្តាប់ដៃគាត់យ៉ាងណែន ព្រមទាំងមានស្នាមញញឹមយ៉ាងធំ។

ដល់ទម្ងន់ប៉ែតសិបប្រាំ កៅសិបគីឡូក្រាម ហើយខ្សែនោះចាប់ផ្ដើមដាច់ចូលទៅខាងទ្រង់។ «អត់ទេ»។ ហើយគាត់បានមើលទៅលើ។ ដល់ទម្ងន់កៅសិបប្រាំ មួយរយគីឡូក្រាម។ ធូរទ្រូង! មិនបានចុចទេ។

**ការទប់ទល់មានន័យថា ការបង្ហូរឈាម**

ឥឡូវនេះ នេះជាសំណួររបស់ខ្ញុំ៖ តើម្នាក់ណាក្នុងចំណោមបុរសទាំងបីនាក់នោះ ស្គាល់ពីអំណាចនៃអំពើបាប? ប្រសិនបើនេះជាការអធិប្បាយអំពីតណ្ហា ខ្ញុំនឹងដំឡើងសម្លេងរបស់ខ្ញុំនៅត្រង់ចំណុចនេះ ហើយមើលទៅក្រុមជំនុំនេះ ហើយស្រែកថា៖

តើនៅទីនេះមានអ្នកធ្វើទាហានដែរឬទេ? តើមានអ្នកណាប្រឡាក់ឈាមនៅលើអាវដែរឬទេ? សូមបង្ហាញខ្ញុំស្នាមនោះឲ្យខ្ញុំបានឃើញផងមុនពេលលោកអ្នកនិយាយអំពីអំណាចនៃអំពើបាប។ សូមកុំបង្ហាញកែងជើងដែលបាក់របស់លោកអ្នកនៅបាតរណ្ដៅនោះមក ខ្ញុំចង់ឃើញមានឈាមប្រឡាក់ដៃនោះ។

ប៉ុន្តែ វាមិនមែនជាសេចក្ដីអធិប្បាយអំពីតណ្ហានោះទេ ដូច្នេះខ្ញុំនឹងរំលងការនោះ ហើយត្រឡប់ទៅចំណុចសំខាន់វិញ។

«លោកអ្នកលោតចូលនៅទម្ងន់ម្ភៃប្រាំគីឡូក្រាម ហើយលោកអ្នកគ្មានស្លាកស្នាមនៅលើរាងកាយរបស់លោកអ្នកនោះឡើយ»។

អ្វីៗទាំងអស់ដែលខ្ញុំកំពុងធ្វើនឹងរឿងប្រស្នាប្រៀបធៀបតូចនេះ ជាការឆ្លើយទៅនឹងសំណួរ «លោកអ្នកមិនត្រូវធ្វើអំពើបាបឲ្យកាន់តែច្រើន ដើម្បីឲ្យបានដឹងថាអ្នកជាមនុស្សមានបាបកម្រិតណានោះទេ?» ហើយចម្លើយនោះគឺ «ទេ លោកអ្នកមិនគួរធ្វើបែបនោះទេ»។ តាមការពិត ពួកមនុស្សកំសាកដែលបោះបង់ត្រឹមទម្ងន់សាមសិប និងហុកសិបគីឡូក្រាម ពួកគេមិនដឹងទេ។ ពួកគេគិតថា ពួកគេដឹង។ ពួកគេហៅវាថា «ជាប់ឃុំឃាំង»។ ពួកគេ



នឹងប្រើសូម្បីតែពាក្យ «ធ្លាក់»។ លោកអ្នកអាចនឹងសម្គាល់ឃើញ ខ្ញុំមិនប្រើពាក្យ «ធ្លាក់» ទេ។ ខ្ញុំនិយាយថា «លោតចូល» វិញ។ លោកអ្នកមិនបានធ្លាក់ទេ លោកអ្នកបានលោតចូលទៅវិញទេតើ។ លោកអ្នកបានលោតចូលនៅត្រឹមទម្ងន់ម្ភៃប្រាំគីឡូក្រាម ហើយលោកអ្នកក៏មិនមានស្លាកស្នាមនៅលើរាងកាយរបស់លោកអ្នកនោះឡើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Pornography and Resisting the Power of Temptation
***រូបភាពអាសអាភាស និងការទប់ទល់នឹងអំណាចនៃសេចក្ដីល្បួង***
https://www.desiringgod.org/interviews/pornography-and-resisting-the-power-of-temptation

# សំណួរទី៥៖
# តើការជ្រមុជទឹកដោយព្រះវិញ្ញាណបរិសុទ្ធជាអ្វី?

នេះជាសំណួរមួយដ៏សំខាន់ ដែលយើងទទួលបានតាមទូរស័ព្ទនៅថ្ងៃនេះពីប្រិយមិត្តម្នាក់ពីទីក្រុងភ្នំពេញ។ តើយើងត្រូវយល់យ៉ាងដូចម្ដេចអំពីពិធីបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ? ឃ្លានេះហាក់បីដូចជាមានន័យខុសគ្នានៅក្នុងព្រះគម្ពីរ—ហើយវាពិតជាមានអត្ថន័យខុសៗគ្នាទៅតាមការអនុវត្តន៍នៃនិកាយ និងក្រុមជំនុំផ្សេងៗដែរ។ នេះគឺសំណួររបស់យើង៖

«ជម្រាបសួរលោកគ្រូ! ខ្ញុំមានការលំបាកនៅក្នុងការស្វែងយល់ និងការកាន់ខ្ជាប់នៃ «ពិធីជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ» ជាពិសេសការបើកសម្ដែង នៅពេលនរណាម្នាក់សើច និងប្រមៀលទៅវិញទៅមកនៅលើឥដ្ឋសន្លប់សាមសិបនាទី ឬយូរជាងនេះក៏មាន។ ខ្ញុំធ្លាប់ឃើញក្រុមជំនុំផ្សេងៗធ្វើបែបនេះ ហើយដាក់ការផ្ដោតអារម្មណ៍យ៉ាងច្រើនទៅលើបទពិសោធន៍ទាំងនេះ ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ដូចជាមិនសូវស្រួលចិត្តសោះ។ តើលោកគ្រូអាចពន្យល់ពីអ្វី ដែលព្រះគម្ពីរសំដៅទៅលើ «ពិធីជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ» ដូចដែលវាមានការជាប់ទាក់ទងទៅនឹង៖ (១) បទពិសោធន៍នៃសេចក្ដីសង្គ្រោះដំបូងរបស់យើង ហើយបន្ទាប់មក ថាតើវាមែន ឬមិនមែនក្នុងការដែលយើងរំពឹងទុក ឬស្វែងរក បន្ទាប់ពីការជ្រមុជទឹកជាបន្តបន្ទាប់ដោយព្រះវិញ្ញាណនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទនៅពេលក្រោយ»?

## ការប្រាថ្នាក្នុងការភ្លក់នូវបទពិសោធន៍ពីព្រះវិញ្ញាណ

ក្រុមគ្រីស្ទបរិស័ទថ្ងៃបុណ្យទីហាសិបនិយមគឺត្រូវបានគេកំណត់ន័យថា ជាចលនាមួយនៅក្នុងគ្រីស្ទសាសនា ដែលចាត់ទុកពិធីជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធថាជាបទពិសោធន៍ទីពីរ បន្ទាប់ពីការប្រែចិត្តជឿ ដែលអាច

កំណត់សម្គាល់បានដោយការនិយាយភាសាដទៃ។ យ៉ាងណាមិញ នោះគឺជាផ្ទុត់គំនិតរបស់ក្រុមគ្រីស្ទបរិស័ទថ្ងៃបុណ្យទីហាសិបនិយម ។ នោះគឺធ្វើឲ្យងាយយល់ច្រឡំ។

«ការសង្កត់ធ្ងន់ទៅលើលក្ខណៈនៃបទពិសោធន៍ពីព្រះវិញ្ញាណ គឺជាមូលហេតុដែលចលនាបុណ្យថ្ងៃទី៥០ បានសាយភាយជាសាកល»។

ខ្ញុំទើបតែបានអានចប់សៀវភៅមួយក្បាលរបស់លោក អេលេន ហ៉ីតុន អ៊ែនឌឺស៊ុន (Allan Heaton Anderson) ដែលមានចំណងជើងថា រហូតដល់អវសាននៃភពផែនដី (To the Ends of the Earth)៖ ក្រុមគ្រីស្ទបរិស័ទថ្ងៃបុណ្យទីហាសិបនិយម និងការបំផ្លាស់បំប្រែរបស់គ្រីស្ទសាសនាពិភពលោក។ លោកបង្ហាញថា មានការយល់ដឹងចម្រុះកាន់តែច្រើនពីព្រះវិញ្ញាណបរិសុទ្ធ និងកិច្ចការរបស់ទ្រង់នៅក្នុងចំណោមក្រុមគ្រីស្ទបរិស័ទថ្ងៃបុណ្យទីហាសិបនិយមសាកលលើសពីការដឹងរបស់យើងទៅទៀត។ អ្វីដែលសាមញ្ញនៅក្នុងចំណោមមែកធាងនៃក្រុមគ្រីស្ទបរិស័ទថ្ងៃបុណ្យទីហាសិបនិយម គឺមិនមែនជាទស្សនៈតែមួយនៃការជ្រមុជក្នុងព្រះវិញ្ញាណទេ ប៉ុន្តែការសង្កត់ធ្ងន់ទៅលើលក្ខណៈបទពិសោធន៍របស់ព្រះវត្តមាននៃព្រះវិញ្ញាណនៅក្នុងជីវិតអ្នកជឿ។

ខ្ញុំគិតថា ការនេះសង្កត់ធ្ងន់ទៅលើធម្មជាតិនៃបទពិសោធន៍របស់ព្រះវិញ្ញាណថាមានភាពជាក់លាក់ ហេតុដូច្នេះហើយបានជាចលនានោះមានកម្លាំងសន្ទុះ និងសាយភាយយ៉ាងមានប្រសិទ្ធិភាពជាសាកល។ មនុស្សម្នាគ្រប់ទីកន្លែងស្រេកឃ្លានចង់ភ្លក់បទពិសោធន៍នៃសេចក្ដីពិត មិនមែនគ្រាន់តែជាសេចក្ដីពិតខាងឯគោលលទ្ធិ ឬប្រវត្តិសាស្ត្រ ដែលបានបញ្ជាក់អះអាងដោយបញ្ញាញាណនោះឡើយ។

នោះគឺជាផ្ទុត់គំនិតលើគ្រីស្ទបរិស័ទនៅលោកខាងលិច។ យើងមានបញ្ជីនៃគោលលទ្ធិ បញ្ជីនៃអាកប្បកិរិយាទាំងឡាយ។ យើងជឿទៅលើគោលលទ្ធិ និងសម្ដែងចេញនូវអាកប្បកិរិយាទាំងឡាយ ហើយយើងសន្និដ្ឋានថា យើងជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ និងថាអ្វីដែលជាការអស្ចារ្យកំពុងតែកើតឡើង ប៉ុន្តែគ្មាននរណាម្នាក់ធ្លាប់បានទទួលបទពិសោធន៍អ្វីទាំងអស់។ ហេតុនេះហើយបានជាក្រុមគ្រីស្ទបរិស័ទថ្ងៃបុណ្យទីហាសិបនិយមទទួលបានជោគជ័យ ពីព្រោះពួកគេនិយាយត្រូវចំពោះការនេះ។ ពួកគេនិយាយត្រូវត្រង់ថា ការមានព្រះវិញ្ញាណបរិសុទ្ធ គឺជាការមានសេចក្ដីពិតដែលបុគ្គលម្នាក់បានទទួលបទពិសោធន៍។

## ការប្រើប្រាស់ពីរផ្សេងគ្នា

វាជារឿងសំខាន់ដែលយើងបញ្ជាក់ពីអត្ថន័យនៃពាក្យនៅក្នុងព្រះគម្ពីរដូចជា «ពិធីជ្រមុជទឹកក្នុង (ឬដោយ) ព្រះវិញ្ញាណបរិសុទ្ធ» ព្រោះវាជាពាក្យមួយនៅក្នុងព្រះគម្ពីរ។ វាជាផ្នែកមួយនៃបទពិសោធន៍របស់គ្រីស្ទបរិស័ទ។

អ្វីដែលខ្ញុំនឹងផ្ដល់យោបល់ គឺជារបៀបដែលសាវ័ក ប៉ុល បានប្រើនៅឃ្លាមួយក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១២:១៣ និងរបៀបដែលសាវ័ក លូកា បានប្រើ (ឬព្រះយេស៊ូវ ដែលត្រូវបានដកស្រង់យកដោយសាវ័ក លូកា) នៅក្នុងកណ្ឌគម្ពីរកិច្ចការជំពូកទី១៥ គឺមិនដូចគ្នាទេ។ នោះគឺជាការសន្និដ្ឋានដំបូងរបស់ខ្ញុំ ដែលបញ្ចៀសកុំឲ្យមានការយល់ច្រលំលើជាច្រើន ប្រសិនបើមនុស្សជឿលើការទាំងនេះ។ ដូច្នេះ លោកអ្នកអាចពិនិត្យមើលដោយខ្លួនឯងបាន។

នេះមានន័យថា នៅពេលយើងសួរ តើឃ្លា «ជ្រមុជទឹកក្នុង (ឬជ្រមុជទឹកដោយ) ព្រះវិញ្ញាណបរិសុទ្ធ» មានន័យដូចម្ដេច? យើងត្រូវសួរថា «តើលោកអ្នកកំពុងនិយាយអំពីការប្រើប្រាស់ឃ្លារបស់សាវ័ក ប៉ុល ឬការប្រើប្រាស់ឃ្លារបស់លោក លូកា នៅពេលដែលគាត់បានដកស្រង់សម្រង់សម្ដីរបស់ព្រះយេស៊ូវ?» វាមិនផ្ទុយគ្នានោះទេ។ ខ្ញុំក៏មិនប្រកែកថា វាមានការ

ប្រឆាំងគ្នាទេ។ ខ្ញុំនិយាយថា គេប្រើពាក្យដដែលៗតាមវិធីផ្សេងៗគ្នា។ ពួកគេប្រើឃ្លាដូចគ្នាតាមរបៀបផ្សេងៗគ្នា។ សូមអនុញ្ញាតឲ្យខ្ញុំបកស្រាយអំពីចំណុចទាំងនោះ។

## ការទទួលព្រះវិញ្ញាណនៅពេលតែប្រែចិត្តទទួលជឿ

កណ្ឌគម្ពីរ ១កូរិនថូស ១២:១២-១៣ សាវ័ក ប៉ុល បានលើកឡើងថា៖

ដ្បិតដូចជារូបកាយ១មានអវយវៈជាច្រើន តែអវយវៈទាំងនោះ ទោះមានច្រើនក៏ពិត គង់តែរួមគ្នាមកជារូបតែ១ទេ នោះព្រះគ្រីស្ទក៏ដូច្នោះដែរ ១៣ ដ្បិតយើងទាំងអស់គ្នា ទោះបើជាសាសន៍យូដា ឬសាសន៍ក្រេក បាវបម្រើ ឬអ្នកជាក្តី យើងបានទទួលបុណ្យជ្រមុជ ចូលក្នុងរូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១ ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ (១កូរិនថូស ១២:១២-១៣)។

គោលគំនិតសាវ័ក ប៉ុល អំពីពិធីបុណ្យជ្រមុជដោយព្រះវិញ្ញាណដែលមានការឯកភាពយ៉ាងទូលំទូលាយ ជាកិច្ចការដែលព្រះវិញ្ញាណផ្សារភ្ជាប់យើងទៅកាន់ព្រះយេស៊ូវគ្រីស្ទ និងរូបកាយរបស់ទ្រង់ ដែលជាក្រុមជំនុំ។ យើងអាចនិយាយម្យ៉ាងទៀតថា វាជាការប្រែចិត្តជឿ។ ការក្លាយជាគ្រីស្ទបរិស័ទ។ នេះគឺជាអត្ថន័យនៃការក្លាយជាគ្រីស្ទបរិស័ទ៖ ត្រូវបានជំរុញដោយព្រះវិញ្ញាណបរិសុទ្ធក្នុងសណ្ឋានដែលយើងទទួលបានសេចក្តីជំនឿ និងការរួបរួមជាមួយព្រះយេស៊ូវ។

## ការប្រទានអំណាចដោយព្រះវិញ្ញាណ

ខ្ញុំមិនគិតថា នោះគឺជារបៀបដែលព្រះយេស៊ូវ និងសាវ័ក លូកា បានប្រើប្រាស់ឃ្លាដូចគ្នានៅក្នុងកណ្ឌគម្ពីរ កិច្ចការ ១:៤-៥។ អ្វីដែលព្រះយេស៊ូវបានមានព្រះបន្ទូលដូចសាវ័ក លូកា បានដកស្រង់សម្រង់សម្តីទ្រង់៖

រួចមក កាលបានប្រជុំទាំងអស់គ្នាហើយ នោះទ្រង់ហាមមិនឲ្យគេចេញពីក្រុងយេរូសាឡឹមឡើយ ដោយព្រះបន្ទូលថា ត្រូវឲ្យនៅចាំសេចក្តីសន្យានៃព្រះវរបិតា «ដែលអ្នករាល់គ្នាបានឮខ្ញុំថ្លែងប្រាប់ហើយ ដ្បិតពិតជាលោកយ៉ូហានបានធ្វើបុណ្យជ្រមុជដោយទឹក ប៉ុន្តែនៅបន្តិចទៀត អ្នករាល់គ្នានឹងទទួលបុណ្យជ្រមុជ ដោយព្រះវិញ្ញាណបរិសុទ្ធវិញ»។

លោកបានស្រង់សម្រង់សម្តីលោក យ៉ូហាន-បាទីស្ទ ពីកណ្ឌគម្ពីរ លូកា ៣:១៦ ដែលលោក យ៉ូហាន បានលើកឡើងថា «នោះយ៉ូហានប្រាប់គេគ្រប់គ្នាថា ឯខ្ញុំៗ ធ្វើបុណ្យជ្រមុជឲ្យអ្នករាល់គ្នាដោយទឹកក៏ពិត ប៉ុន្តែមានព្រះ១អង្គមក ដែលមានអំណាចលើសជាងខ្ញុំទៅទៀត ខ្ញុំមិនគួរនឹងស្រាយខ្សែសុព័ណ៌បាទទ្រង់ផង ព្រះអង្គនោះនឹងធ្វើបុណ្យជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនិងភ្លើងវិញ»។

ខ្ញុំមិនគិតថា ព្រះយេស៊ូវចង់មានន័យថា ពួកសាវ័កទ្រង់នឹងប្រែចិត្តពីការមិនជឿទៅជាជឿលើពិធីបុណ្យជ្រមុជទឹកនេះ ដែលពួកគេគួរតែចាំនៅក្រុងយេរូសាឡឹម។ ខ្ញុំគិតថា លោកលូកាបានឃើញពួកសាវ័កថា ជាពួកអ្នកជឿដែលកើតជាថ្មីដ៏ស្មោះត្រង់ មុនពេលសេចក្តីសន្យានៃពិធីជ្រមុជទឹកនេះបានកើតឡើងចំពោះពួកគេ។

លោក លូកា បានបញ្ចប់កណ្ឌគម្ពីរដំណឹងល្អរបស់គាត់ជាមួយនឹងការពណ៌នារបស់ពួកសាវ័ក មុនពេលដែលពួកគេគួរតែរង់ចាំការត្រាស់ហៅសម្រាប់បុណ្យជ្រមុជទឹកដោយព្រះវិញ្ញាណបរិសុទ្ធ។ ដូចមានសេចក្តីចែងទុកក្នុងកណ្ឌគម្ពីរ លូកា ២៤:៥២-៥៣ «គេក៏ក្រាបថ្វាយបង្គំទ្រង់ រួចត្រឡប់ទៅឯក្រុងយេរូសាឡឹមវិញ ដោយអំណរជាខ្លាំង ក៏នៅក្នុងព្រះវិហារជានិច្ច ទាំងសរសើរ ហើយលើកតម្កើងព្រះ»។ មានមនុស្សមួយក្រុមកំពុងតែថ្វាយបង្គំព្រះយេស៊ូវ។ ពួកគេមានសេចក្តីអំណរជាខ្លាំង។ ពួកគេសរសើរតម្កើងព្រះតាមរយៈព្រះយេស៊ូវនៅក្នុងព្រះវិហារ។ ពួកគេមិនមែនជាពួកសាវ័ក ដែលមិនទាន់បានផ្លាស់ប្រែជាថ្មី ដែលកំពុងរង់ចាំនៅក្នុងការកើតជាថ្មីដោយការ

យាងមកដល់នៃព្រះវិញ្ញាណបរិសុទ្ធនោះឡើយ។

**ទូលសូមការជ្រមុជថ្មី**

តើព្រះយេស៊ូវមានន័យដូចម្ដេចនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ១:៥ និង កណ្ឌគម្ពីរ លូកា ជំពូក៣? ខ្ញុំគិតថា នៅពេលទ្រង់មានព្រះបន្ទូលថា អ្នករាល់គ្នានឹងទទួលបុណ្យជ្រមុជ ដោយព្រះវិញ្ញាណបរិសុទ្ធវិញ ទ្រង់មានន័យថា អ្នករាល់គ្នានឹងទទួលបានអំណាចដ៏ចម្លែកអស្ចារ្យសម្រាប់ការតម្កើងព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ។ នោះគឺជាអត្ថន័យរបស់ទ្រង់ តាមការគិតរបស់ខ្ញុំ។ អ្នករាល់គ្នានឹងទទួលបានអំណាចដ៏អស្ចារ្យសម្រាប់ការធ្វើព័ន្ធកិច្ចដែលលើកតម្កើងព្រះគ្រីស្ទ។

«ប្រភេទនៃការផ្ដល់អំណាចដែលយើងបានទទួលនៅក្នុងពិធីជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាបទពិសោធន៍ដែលយើងត្រូវការម្ដងហើយម្ដងទៀត»។

បទពិសោធន៍នោះអាចនឹងមកជាលក្ខណៈខុសពីធម្មតា ជាបទពិសោធន៍ដែលគួរឲ្យកត់សម្គាល់ ក្រោយពីការប្រែចិត្តជឿ—មួយថ្ងៃ មួយសប្ដាហ៍ មួយឆ្នាំ ឬមួយនាទី—កើតជាបន្តមកទៀត ដោយការចាក់បង្ហូរចាក់បំពេញ ឬការជ្រមុជដោយព្រះវិញ្ញាណជាបន្តបន្ទាប់ពេញមួយជីវិត។ ឬបទពិសោធន៍នឹងមកនៅខណៈពេលនៃការប្រែចិត្តជឿ ហើយបទពិសោធន៍នៃការផ្ដល់អំណាចក្នុងព្រះវិញ្ញាណបរិសុទ្ធនឹងកើតមានជាបន្តបន្ទាប់។ វានឹងមកនៅក្នុងរបៀបផ្សេងៗគ្នា ទទួលការចាក់បំពេញ និងការទទួលព្រះពរក្នុងជីវិតនេះ ដែលយើងមិនអាចទាយដឹងមុនបានឡើយ ហើយក៏អាចមានលក្ខណៈផ្សេងៗគ្នាផងដែរ។

ខ្ញុំគិតថា វាអាចនឹងជាកំហុសក្នុងការកំណត់ការជ្រមុជក្នុង ដោយ ឬជាមួយព្រះវិញ្ញាណបរិសុទ្ធទៅនឹងព្រឹត្តិការណ៍មួយវិនាទី បន្ទាប់ពីការប្រែចិត្តជឿ។ ទោះបីជាលោកអ្នកអាចមានបទពិសោធន៍ម្ដង នោះមិនមែនមានន័យថា វាជារបៀបធម្មតាដែលការជ្រមុជអាចយល់បាន។ ខ្ញុំគិតថា ការបំពេញ និងការផ្ដល់អំណាចដែលយើងទទួលបានក្នុងបទពិសោធន៍ ជាអ្វីដែលយើងត្រូវការម្ដងហើយម្ដងទៀតនៅក្នុងជីវិតជាគ្រីស្ទបរិស័ទនេះ។ វាមិនមែនជាអ្វីដដែលៗ មិនផ្លាស់ប្ដូរគ្រប់កាលៈទេសៈនៃជីវិតគ្រីស្ទបរិស័ទនោះទេ។

ខ្ញុំគិតថា វាជារឿងត្រឹមត្រូវសម្រាប់ការជ្រមុជថ្មី។ នោះគឺជាភាសានៃក្រុមជំនុំបរិសុទ្ធនិយម។ នោះគឺជាភាសានៃលោក ម៉ាទីន ឡូយដ៍ ចូនស៍ (Martyn Lloyd-Jones)។ នោះគឺជាភាសារបស់ខ្ញុំម្ដងហើយម្ដងទៀត នៅពេលខ្ញុំឡើងអាសនា ដើម្បីអធិប្បាយ នោះខ្ញុំទូលសូមពីព្រះអង្គ។ ខ្ញុំទូលថា «ឱព្រះអម្ចាស់អើយ! ទូលបង្គំត្រូវការជ្រមុជថ្មី។ ទូលបង្គំត្រូវការចាក់ប្រេងតាំងថ្មី។ ទូលបង្គំត្រូវការការចាក់បំពេញថ្មី។ ទូលបង្គំត្រូវការការស្រោចស្រង់ដោយព្រះវិញ្ញាណបរិសុទ្ធ ជាថ្មីម្ដងទៀត»។

**ដែលចាក់បំពេញ និងផ្ដល់អំណាច**

ខ្ញុំគិតថាកណ្ឌគម្ពីរកិច្ចការបានប្រើប្រាស់ភាសាខុសៗគ្នាសម្រាប់ការទាំងអស់នោះ ដែលមិននៅបន្តកើតមានទៀតទេ។ លោកអ្នកមានសាវ័កប៉ុល នៅកោះគីប្រុស ហើយគាត់រៀបនឹងនិយាយ។ ដូចដែលបានរៀបរាប់ថា គាត់បានចាក់បំពេញដោយព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់មកលោកមានអំណាចដ៏ចម្លែកអស្ចារ្យក្នុងការចាត់ការនឹងពួកចេះអាគមអាបធ្មប់នៅលើកោះនោះ (កិច្ចការ ១៣:៨-១២)។ នោះគឺជាប្រភេទនៃរឿងដែលខ្ញុំគិតថាព្រះយេស៊ូវមានព្រះបន្ទូលៈ «យើងចង់ឲ្យអ្នករាល់គ្នាស្គាល់បទពិសោធន៍នេះ នៅពេលអ្នករាល់គ្នាចេញទៅផ្សាយដំណឹងល្អទៅកាន់លោកីយ៍»។ សូមឲ្យខ្ញុំបានផ្ដល់នូវ៤ចំណុចអំពីមូលហេតុដែលខ្ញុំគិតថាលោក លូកា និងព្រះយេស៊ូវបានប្រើប្រាស់ពាក្យទាំងនោះ។

ចំណុចទីមួយ សាវ័ក លូកា បានពណ៌នាការជ្រមុជដំបូងនៃព្រះវិញ្ញាណថា ជាការចាក់បំពេញ។ គាត់បានប្រើពាក្យ «ការបំពេញ» ជាភាសានិយាយនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២:៤។ គាត់បាននិយាយថា «ត្រូវឲ្យនៅចាំសម្រាប់ការជ្រមុជនោះ» (កិច្ចការ ១:៤-៥) ហើយបន្ទាប់មក ពេលគាត់បានពណ៌នាអំពីវានៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២:៤ គាត់បានសរសេរថា «រួចគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់»។ សម្រាប់គាត់ ទាំងនេះគឺជាសេចក្តីពិតដែលកើតឡើងទន្ទឹមគ្នា (ភាពពេញលេញ និងការជ្រមុជ)។ ហើយបន្ទាប់មកទៀត ពាក្យ «បានពេញជាព្រះវិញ្ញាណបរិសុទ្ធ» គឺបានលើកឡើងម្តងហើយម្តងទៀតនៅក្នុងជីវិតពួកអ្នកជឿ មិនគ្រាន់តែម្តងនោះទេ។

ចំណុចទីពីរ លោក លូកា បាននិយាយថា ការជ្រមុជដោយព្រះវិញ្ញាណគឺជាសម្រេចនៃព្រះបន្ទូលសន្យានៃកណ្ឌគម្ពីរ យ៉ូអែល ២ («ត្រូវឲ្យនៅចាំសម្រាប់ការជ្រមុជនោះ»)។ បន្ទាប់មក យើងក៏មានសេចក្តីសន្យានៅកណ្ឌគម្ពីរយ៉ូអែល ដែលបានសម្រេចនៅកណ្ឌគម្ពីរ កិច្ចការ ២១:៦ ហើយនឹងនៅបន្តដល់ខខាងមុខៗទៀតផងដែរ។ ការតាំងសញ្ញានៅកណ្ឌគម្ពីរ យ៉ូអែល២ មិនមែនជាការតាំងសញ្ញានិយាយពីការកើតជាថ្មីទេ។ វាគឺជាការតាំងសញ្ញានៃសេចក្តីសន្យាពីអំណាចដ៏អស្ចារ្យ៖ អ្នករាល់គ្នានឹងនិយាយដោយអំណាចដ៏អស្ចារ្យ។

«នៅពេលគាត់និយាយថា អ្នករាល់គ្នានឹងជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ គាត់មានន័យថា អ្នករាល់គ្នានឹងទទួលបានអំណាចដ៏អស្ចារ្យសម្រាប់ការធ្វើព័ន្ធកិច្ចដែលនឹងលើកតម្កើងព្រះគ្រីស្ទ»។

ចំណុចទីបី សាវ័ក លូកា បានពណ៌នាការជ្រមុជដោយព្រះវិញ្ញាណ ថាជាការទទួលបាននូវអំណាចសម្រាប់ការធ្វើជាទីបន្ទាល់ (កិច្ចការ ១:៨)។ គាត់បាននិយាយថា «កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនិងធ្វើជាទីបន្ទាល់ពីខ្ញុំ រហូតដល់ចុងផែនដីបំផុតផង»។ នោះគឺជាការពិពណ៌នាភ្លាមៗចំពោះអ្វីដែលនឹងកើតឡើង ប្រសិនបើអ្នករាល់គ្នារង់ចាំសម្រាប់ការជ្រមុជនោះ។ ដូច្នេះ វាគឺជាការប្រទានអំណាចសម្រាប់ប្រសិទ្ធភាពនៃការលើកតម្កើងព្រះគ្រីស្ទជាសកល។

ចុងក្រោយ ចំណុចទីបួន សាវ័ក លូកា បាននិយាយថា ការជ្រមុជក្នុងព្រះវិញ្ញាណ គឺជាការគ្របដណ្តប់ដោយព្រះចេស្តាពីស្ថានលើ ដូច្នេះព្រះរាជសាររបស់ព្រះគ្រីស្ទអាចយកទៅប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពទូទាំងសកលលោក។ នោះគឺជាអ្វីដែលកណ្ឌគម្ពីរ លូកា ២៤:៤៩ បានលើកឡើងនៅពេលដែលព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា «ចូរអ្នករាល់គ្នានៅតែក្នុងក្រុងយេរូសាឡឹម ដរាបដល់ព្រះចេស្តាពីស្ថានលើ បានមកគ្របដណ្តប់លើអ្នករាល់គ្នា»។

## ចុះភាសាដទៃវិញ?

ការយល់ដឹងរបស់ខ្ញុំអំពីពិធីជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធគឺថា សាវ័ក ប៉ុល ប្រើទម្រង់មួយនៃឃ្លានេះ ដើម្បីសំដៅទៅលើអ្វីដែលកើតឡើងនៅពេលកើតជាថ្មី។ សាវ័ក លូកា ប្រើទម្រង់មួយនៃឃ្លានេះ នៅពេលលើកពីព្រះបន្ទូលព្រះយេស៊ូវអំពីការប្រទានអំណាចដោយព្រះវិញ្ញាណ។

ដើម្បីឆ្លើយសំណួរអំពីសញ្ញាប្លែកៗ ដែលវាអាច ឬមិនអាចដាក់បញ្ចូលសញ្ញាផ្សេងៗ ដូចជាភាសាដទៃ ឬការបើកសម្តែងលើសពីធម្មតា។ ក្នុងន័យនេះ ខ្ញុំគិតថា គ្រីស្ទបរិស័ទគ្រប់រូបគួរតែស្វែងរកការជ្រមុជថ្មីៗ ម្តងហើយម្តងទៀត ដើម្បីប្រសិទ្ធភាពនៃព័ន្ធកិច្ច។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
What Is the Baptism of the Holy Spirit?
**តើការជ្រមុជទឹកដោយព្រះវិញ្ញាណបរិសុទ្ធជាអ្វី?**
https://www.desiringgod.org/interviews/what-is-the-baptism-of-the-holy-spirit



## សំណួរទី៦៖
# ហេតុអ្វីបានជាព្រះគម្ពីរសង្កត់ធ្ងន់ទៅលើអំណាចនៃព្រះនាមព្រះយេស៊ូវ?

ហេតុអ្វីបានជា ព្រះគម្ពីរសង្កត់ធ្ងន់ទៅលើអំណាចនៃព្រះនាមព្រះយេស៊ូវ? នេះជាសំណួរមួយមកពីប្រិយមិត្តអ្នកស្តាប់ម្នាក់ឈ្មោះ ដានីញ៉ែល។ «ជម្រាបសួរ លោកគ្រូ! ខ្ញុំបាទមានសំណួរមួយសម្រាប់លោកគ្រូ ជាសំណួរដែលខ្ញុំ និងភរិយាខ្ញុំមានចម្ងល់អំពីវាអស់មួយរយៈហើយ។ ហេតុអ្វីបានជាព្រះគម្ពីរសង្កត់ធ្ងន់ទៅលើការសរសើរតម្កើងព្រះនាមព្រះយេស៊ូវ? ហើយនឹងការអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ? ជាការពិតណាស់ យើងចង់ធ្វើបែបនេះ ហើយវាគឺជាលំនាំដែលយើងឃើញនៅពាសពេញព្រះគម្ពីរសញ្ញាថ្មីទាំងមូលតែម្តង ជាពិសេសនៅក្នុងកណ្ឌគម្ពីរ កិច្ចការ (២:៣៨; ៣:៦; ៣:១៦; ៤:១០, ១៨; ៥:៤០-៤១; ៨:១២; ៩:២៧; ១០:៤៨; ១៦:១៨; ១៩:១៣; ២៦:៩) និងនៅក្នុងកណ្ឌគម្ពីរ សំបុត្រសាវ័ក ប៉ុល (១កូរិនថូស ១:២; ភីលីព ២:១០)។ ក្នុងការសួរក្នុងរបៀបមួយផ្សេងទៀត៖ តើហេតុអ្វីបានមានអំណាចក្នុងព្រះនាមព្រះគ្រីស្ទច្រើនជាង ការនិយាយថា មានអំណាចក្នុងអង្គព្រះយេស៊ូវ?» តើលោកគ្រូនឹងឆ្លើយយ៉ាងណាទៅកាន់ប្អូនប្រុសដានីញ៉ែល និងភរិយារបស់គាត់?

ចម្លើយសម្រាប់សំណួរចុងក្រោយគឺងាយទេ៖ មិនមាននោះទេ។ គឺមិនមានអំណាចក្នុងព្រះនាមព្រះគ្រីស្ទ ច្រើនជាងការនិយាយថាមានអំណាចក្នុងអង្គព្រះគ្រីស្ទទេ។ មានអំណាចក្នុងព្រះនាមព្រះយេស៊ូវ ពីព្រោះមានអំណាចក្នុងអង្គព្រះគ្រីស្ទផ្ទាល់។ ប៉ុន្តែ ប្អូនប្រុស ដានីញ៉ែល ចូរដឹងថា វាគ្រាន់តែជាពាក្យចម្លែកតែប៉ុណ្ណោះ។

អ្វីដែលគាត់ពិតជាចង់ដឹង ខ្ញុំគិតថា គឺជាអ្វីដែលគាត់បាននិយាយកាលពីដំបូង៖ ហេតុអ្វីបានជា យើងឃើញមានការសង្កត់ធ្ងន់ទៅការសរសើរតម្កើងព្រះនាមព្រះយេស៊ូវ និងការអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ ការធ្វើគ្រប់កិច្ចការទាំងអស់ក្នុងព្រះនាមព្រះយេស៊ូវ? តើអ្វីទៅជាការផ្តោតសំខាន់ទៅលើព្រះនាមទ្រង់ ដែលបានសបញ្ជាក់ឲ្យយើងឃើញនៅក្នុងព្រះគម្ពីរសញ្ញាថ្មី? ដូច្នេះ សូមឲ្យខ្ញុំសាកព្យាយាមឆ្លើយនូវសំណួរនោះជាបីចំណុច។

## តើមានអ្វីនៅក្នុងឈ្មោះ?

ការពិតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានបង្កើតឲ្យរបៀបមួយ ដើម្បីឲ្យមានទំនាក់ទំនងរវាងឈ្មោះដែលព្រះបានប្រទានឲ្យបុគ្គលម្នាក់ និងរឿងដ៏សំខាន់ចាំបាច់អំពីបុគ្គលម្នាក់នោះថាមានសារៈសំខាន់។ ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ១៧:៥ លោក អាប់រ៉ាម បានប្តូរឈ្មោះទៅជា អ័ប្រាហាំវិញ «ឈ្មោះឯងមិនត្រូវហៅថា អាប់រ៉ាមទៀតទេ គឺត្រូវហៅថា អ័ប្រាហាំវិញ ដ្បិតអញបានតាំងឯងឲ្យធ្វើជាឪពុកនៃសាសន៍ជាច្រើន»។ ឬនាង សារ៉ាយ បានប្តូរមកជា សារ៉ាវិញ «ឯសារ៉ាយជាប្រពន្ធឯង នោះឯងមិនត្រូវហៅថា សារ៉ាយទៀតទេ គឺត្រូវហៅថា សារ៉ាវិញ អញនឹងឲ្យពរដល់នាង ហើយនឹងឲ្យឯងមានកូនពីនាងដែរ អញនឹងឲ្យពរដល់នាងជាពិត នាងនឹងធ្វើជាម្តាយនៃនគរផ្សេងៗ ហើយនឹងមានស្តេចនៃសាសន៍ជាច្រើនចេញពីនាងមក» (លោកុប្បត្តិ ១៧:១៥-១៦)។ ហើយព្រះជាម្ចាស់បានប្តូរឈ្មោះលោក យ៉ាកុប ទៅជាលោក អ៊ីស្រាអែល នៅពេលដែលព្រះជាម្ចាស់មានព្រះបន្ទូលថា «ឈ្មោះឯងមិនត្រូវហៅថា យ៉ាកុបទៀតទេ គឺត្រូវហៅថា អ៊ីស្រាអែលវិញ ពីព្រោះឯងមានអំណាចចំពោះព្រះហើយនឹងមនុស្សក៏បានឈ្នះផង» (លោកុប្បត្តិ ៣២:២៨)។

ហើយការដែលសំខាន់បំផុត គឺព្រះនាមរបស់ព្រះផ្ទាល់តែម្តង។



ព្រះអង្គបានប្រទានព្រះនាមឲ្យទ្រង់ផ្ទាល់។ នេះជាអត្ថបទមួយមានសារៈសំខាន់បំផុតនៅក្នុងព្រះគម្ពីរ បើតាមខ្ញុំគិត។ នៅក្នុងកណ្ឌគម្ពីរ និក្ខមនំ ៣:១៣-១៤៖

«ម៉ូសេក៏ទូលទៅព្រះថា "មើល កាលណាទូលបង្គំទៅប្រាប់ពួកកូនចៅអ៊ីស្រាអែលថា 'ព្រះនៃឰយុកោអ្នករាល់គ្នាទ្រង់បានចាត់ខ្ញុំឲ្យមកឯអ្នករាល់គ្នា' ហើយគេសួរទូលបង្គំថា 'តើព្រះទ្រង់ព្រះនាមជាអ្វី' នោះតើត្រូវឲ្យទូលបង្គំប្រាប់គេថាដូចម្តេច' ព្រះទ្រង់មានបន្ទូលទៅម៉ូសេថា 'អញជាព្រះដ៏ជាព្រះ' រួចទ្រង់មានបន្ទូលទៀតថា 'ឯងត្រូវឆ្លើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះដ៏ជាព្រះទ្រង់បានចាត់ឲ្យខ្ញុំមកឯអ្នករាល់គ្នា'"»។

ដូច្នេះ យេហូវ៉ា ជានាមដែលព្រះគម្ពីរសញ្ញាចាស់បានប្រើប្រាស់ជាង៦ពាន់ដងសម្រាប់ព្រះជាម្ចាស់—ក្នុងភាសាខ្មែរយើងបានបកថា ព្រះអម្ចាស់—ត្រូវបានបង្កើតឡើងនៅក្នុងឃ្លា៖ «អញជាព្រះដ៏ជាព្រះ»។ យើងអាចនិយាយម៉្យាងទៀតថា គ្រប់ពេលយើងអានព្រះនាមនៃព្រះ គឺព្រះនាមអសាធារណ៍របស់ព្រះយេហូវ៉ា ទ្រង់ចង់ឲ្យយើងចងចាំពីភាពសំខាន់របស់ទ្រង់។ នេះគឺជាចំណុចសំខាន់។ «នៅពេលឯងនិយាយអំពីព្រះនាមរបស់យើង ចូរចងចាំភាពសំខាន់របស់យើង។ យើងគឺពិតជាយើងមែន។ ហេតុដូច្នេះ ទើបបានយើងបានដាក់ព្រះនាមមួយឲ្យខ្លួនឯងដែលមានអត្ថន័យមួយ។ គ្មានដើមដំបូង គ្មានទីបញ្ចប់ គ្មានការក្លាយជា និងគ្មានការប្រែប្រួល។ យើងគឺពិតជាយើងមែន។ យើងជាម្នាក់សេចក្តីពិត។ ខ្ញុំជាម្នាក់អាចទុកចិត្តបាន»។ គ្រប់ពេលលោកអ្នកនិយាយថា ព្រះអម្ចាស់ គឺលោកអ្នកកំពុងសំដៅទៅដល់ព្រះនាម ព្រះយេហូវ៉ា សូមចងចាំពាក្យនោះ។ នេះហើយគឺជាការសង្កេតមើលទី១។

## ការតំណាងឲ្យសេចក្តីពិត

ការសង្កេតទី២ នៅពេលព្រះរាជបុត្រានៃព្រះបានយាងចុះមកផែនដីនេះ ក្នុងនាមជាអ្នកតំណាងនៃព្រះជាម្ចាស់ផ្ទាល់ ហើយទទួលព្រះនាមថា៖ យេស៊ូវ។ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប (ម៉ាថាយ ១:២១)។ «យេស៊ូវ» មានន័យថា អ្នកសង្គ្រោះ។ ទ្រង់ជាម្នាក់ដែលចម្រើនឡើង ហើយទ្រង់ក៏មិនបានថមថយចុះវិញដែរ។ «ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល» ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ (ម៉ាថាយ ១:២៣)។ យើងគួរតែហៅព្រះនាមទ្រង់ថា ព្រះគ្រីស្ទ ពីព្រោះទ្រង់ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់។ កណ្ឌគម្ពីរ ម៉ាថាយ ១៦:១៦ បានចែងថា «ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់»។

កណ្ឌគម្ពីរ ភីលីព ២:១០ បានចែងថា ព្រះយេស៊ូវបានជំនួសឲ្យគ្រប់ទាំងព្រះនាមនៃព្រះយេហូវ៉ា ដែលនេះមានការបន្ទរដូចគ្នា នៅក្នុងកណ្ឌគម្ពីរ អេសាយ ៤៥:២៣។ នៅពេលគាត់បានដកស្រង់សម្តីនៅក្នុងអត្ថបទនោះ សាវ័ក ប៉ុល បានជំនួសព្រះនាម ព្រះយេស៊ូវនៅក្នុងនេះ «ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះឲ្យគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ»។ ព្រះគម្ពីរសញ្ញាចាស់បានចែងថា គ្រប់ទាំងជង្គង់នឹងត្រូវលុតចុះចំពោះព្រះយេហូវ៉ា។ ដូច្នេះ សាវ័កប៉ុលនិយាយដោយសេចក្តីក្លាហានថា ព្រះយេស៊ូវ គឺជាព្រះយេហូវ៉ា ហើយអ្វីក៏ដោយជាការពិតដោយនូវព្រះនាមនោះ គឺឥឡូវនឹងក្លាយជាការពិតដោយនូវព្រះនាមព្រះយេស៊ូវ។

អញ្ចឹង ដូចដែលប្អូនប្រុស ដានីញ៉ែល បានលើកឡើងនៅក្នុងសំណួររបស់គាត់កាលពីដំបូង ឈ្មោះ សំដៅទៅលើភាពសំខាន់ ជាការកំណត់ភាពពិតរបស់បុគ្គលណាម្នាក់។ ហើយលោកអ្នកនឹងឃើញវាដដែលៗថា ពាក្យឈ្មោះនៅត្រង់ចំណុចនៃការកំណត់លក្ខណៈណាមួយរបស់បុគ្គលណាម្នាក់ជាមិនខាន។ លោកអ្នកនឹងឃើញវាម្តងហើយម្តងទៀតថា មានកន្លែងដែលឈ្មោះ និងបុគ្គលអាចជំនួសគ្នាទៅវិញទៅមកបាន។

ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរ កូឡុស ៣:១៧ បានចែងថា «ហើយក្នុងគ្រប់ទាំងអស់ ទោះបើការអ្វីដែលអ្នករាល់គ្នានឹងធ្វើ ដោយពាក្យសម្តី ឬកិរិយាក៏ដោយ ចូរធ្វើទាំងអស់ ដោយព្រះនាមនៃព្រះអម្ចាស់យេស៊ូវ»។ បន្ទាប់មក ខគម្ពីរនោះបានបន្តយ៉ាងដូចនេះថា «ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតា ដោយសារទ្រង់ផង»។ ជំនួសដោយការនិយាយព្រះនាមព្រះយេស៊ូវម្តងទៀត គាត់បាននិយាយថា «ដោយសារទ្រង់ផង»។ ដូច្នេះ ចូរធ្វើគ្រប់កិច្ចការទាំងអស់នៅក្នុងព្រះនាមព្រះយេស៊ូវ ទាំងអរព្រះគុណតាមរយៈទ្រង់ផង ពីព្រោះទ្រង់ និងព្រះនាមនៃព្រះយេស៊ូវអាចប្រើជំនួសគ្នាទៅវិញទៅមកបាននៅក្នុងខគម្ពីរនោះ។ នោះហើយគឺជាការសង្កេតមើលទី២។

## ផែនដីមួយដែលគ្មានងារ

អ្វីដែលប្អូនប្រុស ដានីញ៉ែល កំពុងតែចង់សួរ ក៏ដូចជាសំណួរដែលខ្ញុំចង់សួរដែរ៖ តើហេតុអ្វី? យើងរាល់គ្នាបានឃើញការទាំងអស់នេះនៅក្នុងព្រះគម្ពីរថា ឈ្មោះពិតជាសំខាន់ណាស់ ហើយឈ្មោះពិតជាតំណាងឲ្យភាពសំខាន់។ យើងបានសម្រួលភាសារបស់យើងទៅនឹងការនោះ។ យើងមិនទាំងហ៊ានព្រិចភ្នែកផង នៅពេលយើងអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវ ឬធ្វើការអ្វីមួយនៅក្នុងព្រះនាមព្រះយេស៊ូវ។ ប៉ុន្តែ ហេតុអ្វីការយោងនេះជាញឹកញាប់មានលក្ខណៈគួរឲ្យកត់សម្គាល់ទៅនឹងឈ្មោះ? ហើយនេះជាការខិតខំប្រឹងរបស់ខ្ញុំក្នុងការឆ្លើយ ព្រោះព្រះគម្ពីរមិនបានបញ្ជាក់ប្រាប់ក្នុងរបៀបទេវវិទ្យា ក្នុងរបៀបជាប្រព័ន្ធ ដោយនិយាយថា «នេះជាការពន្យល់អំពីមូលហេតុដែលខ្ញុំប្រើឈ្មោះជាច្រើនដង» បែបនេះ។

សូមស្រមៃថា នឹងមានរឿងអ្វីកើតឡើង បើជាមិនមានឈ្មោះនោះទេ។ មិនមានការសម្គាល់ មិនមានសូម្បីតែលេខ។ លោកអ្នកមិនមានលេខសូម្បីតែតួលេខសោះ។ លោកអ្នកមិនត្រូវបានសម្គាល់ដោយប្រើលេខសម្គាល់ខ្លួន ៧២៣៨៩។ តើយើងនឹងបាត់បង់អ្វីខ្លះ ប្រសិនបើគ្មាននរណាម្នាក់មានឈ្មោះ គ្មាននរណាម្នាក់មានលេខសម្គាល់ខ្លួន ហើយគ្មាននរណាម្នាក់មានការកំណត់ជាផ្លូវការលើខ្លួននោះទេ? តើយើងនឹងត្រូវបាត់បង់អ្វីខ្លះ?

វាហាក់ដូចជាថា យើងនឹងបាត់បង់ភាពងាយស្រួលក្នុងការនិយាយទៅកាន់នរណាម្នាក់ដោយផ្ទាល់ខ្លួន។ តើលោកអ្នកអាចនឹងទទួលចំណាប់អារម្មណ៍បានដោយរបៀបណា? វាដូចជាមិនសូវជិតដិតសោះក្នុងការនិយាយទៅកាន់មនុស្សម្នាក់ថា «ហេ៎ អ្នក» ហើយវាពិបាកក្នុងការនិយាយ «ហេ៎ អ្នក» បែបនេះជាច្រើនដង។ ហើយលោកអ្នកមិនអាចធ្វើឲ្យខ្លួនឯងជាទីពេញចិត្តដល់នរណាម្នាក់បានឡើយនៅក្នុងការសន្ទនាដោយការនិយាយតែពាក្យ «ហេ៎ អ្នក» រហូតបែបនេះ ហើយមិនដែលប្រើការពាក្យសម្គាល់ខ្លួនសម្រាប់សម្គាល់ថាពួកគេម្នាក់ជានរណា។ ដូច្នេះ នេះជាចំណុចទី១។ យើងនឹងបាត់បង់របៀបផ្ទាល់ខ្លួនក្នុងការនិយាយ។

ចំណុចទី២ យើងពិបាកក្នុងការនិយាយពីនរណាម្នាក់ ប្រសិនបើយើងចង់ពិភាក្សាអំពីពួកគេ។ ខ្ញុំមិនសំដៅទៅលើការនិយាយពីពួកគេក្នុងន័យនិយាយដើមគេនោះទេ។ ខ្ញុំគ្រាន់តែចង់សំដៅទៅលើការនិយាយលេងក្នុងរបៀបមួយវិជ្ជមានអំពីនរណាម្នាក់។ សូម្បីតែឈ្មោះពួកគេក៏យើងមិនយើងមិនស្គាល់ដែរ។ តើយើងអាចដឹងថា យើងកំពុងនិយាយពីនរណាម្នាក់ដោយរបៀបណា ប្រសិនបើយើងមិនស្គាល់ឈ្មោះរបស់គេផងនោះ? យើងមិនអាចសូម្បីតែនិយាយអំពីពួកគេផង ឲ្យយើងអាចនឹងសរសើរគេបានយ៉ាងម៉េចទៅ។

ចំណុចទី៣ យើងពិបាកក្នុងការច្រៀងចម្រៀងសរសើរដល់នរណាម្នាក់



ប្រសិនបើយើងមិនទាំងស្គាល់ឈ្មោះគេផង។ ដូច្នេះ បើមិនមានឈ្មោះទេ គ្រប់ទាំងអស់នឹងត្រូវដួលរលំ—គ្រប់រាល់ទំនាក់ទំនងដែលជាប់ទាក់ទងគ្នានឹងត្រូវកាត់ផ្តាច់។ ព្រះជាម្ចាស់បានជ្រាបអំពីរឿងនេះជាមុន បានជាទ្រង់បានចាប់ផ្តើមពិភពលោកនេះដោយការដាក់ឈ្មោះឲ្យរបស់សព្វសារពើ។ ក្រោយពីព្រះជាម្ចាស់បានប្រទានឈ្មោះឲ្យរបស់សព្វសារពើហើយ លោក អ័ដាមក៏បានដាក់ឈ្មោះឲ្យរបស់សព្វសារពើបន្តពីទ្រង់ គាត់បានដាក់ឈ្មោះដល់គ្រប់ទាំងសត្វ ហើយគាត់ក៏បានដាក់ឈ្មោះមួយឲ្យប្រពន្ធរបស់គាត់ផងដែរ។ ហើយការនោះធ្វើឲ្យមានទំនាក់ទំនងអាចកើតឡើងបាន។ ក្រោយមកទៀតព្រះជាម្ចាស់បានប្រទានឈ្មោះត្រូវគ្នាទៅនឹងអ្វីដែលសំខាន់ដែលមនុស្សណាម្នាក់មាន ឬនឹងមាន។

និយាយទៅ វាគ្រាន់តែជាផ្តល់នូវការអត្ថាធិប្បាយបន្តិចបន្តួចនៅចំណុចនេះ ខ្ញុំគ្រាន់តែលើកទឹកចិត្តឪពុកម្តាយឲ្យព្យាយាមគិតបន្តិច នៅពេលពួកគេដាក់ឈ្មោះឲ្យកូនៗសំណព្វចិត្តរបស់ខ្លួន ដើម្បីដាក់ឈ្មោះមួយដែលមានអត្ថន័យឲ្យពួកគេ អញ្ចឹងនៅពេលពួកគេធំឡើងគេបានប្រសើរដូចជាឈ្មោះរបស់ពួកគេ។ សូមកុំគ្រាន់តែគិតថា «អូ! ស្តាប់ទៅឡូយណាស់»។ ប្រាកដណាស់ ជីវិតពិតគឺមានន័យលើសពីការស្តាប់ទៅឡូយណាស់ហ្នឹងទៅទៀត។ សូមបិទវង់ក្រចកត្រឹមតែប៉ុណ្ណេះសិនចុះ។ សម្រាប់ការពន្យល់អំពីការនេះ ចាំជួបគ្នានៅពេលក្រោយទៀត។

## សម្រាប់ជាកិត្តិសព្ទនៃព្រះនាមទ្រង់

ដូច្នេះ នេះជាចំណុចជាប់ទាក់ទងគ្នា៖ ការសំដៅទៅលើព្រះនាមព្រះយេស៊ូវយ៉ាងញឹកញាប់ ជារបៀបមួយនៃការនិយាយថា «មនុស្សម្នាក់នេះមិនអាចប្រព្រឹត្តនឹងគាត់ដោយស្ងាត់ៗបានទេ។ ទ្រង់មិនត្រូវបានលាក់ទុកទេ ជាការលាក់របស់សំខាន់មួយទុកនៅក្នុងដួងចិត្តរបស់លោកអ្នក ឬនៅក្នុង

ទូរសំលៀកបំពាក់របស់លោកអ្នក។ យើងត្រូវតែបង្ហាញទ្រង់ជាសាធារណៈ សាកលលោកត្រូវតែទទួលស្គាល់ទ្រង់ ទទួលស្គាល់ថាជាមនុស្សម្នាក់ដែលមានអត្តសញ្ញាណ ដែលមនុស្សទាំងឡាយត្រូវនិយាយទៅកាន់ និងមនុស្សទាំងឡាយនិយាយអំពី—នោះមនុស្សទាំងពួងនាំគ្នាច្រៀងសរសើរតម្កើងអំពីទ្រង់»។ ការសង្កត់ធ្ងន់ទៅលើព្រះនាមទ្រង់ចាប់ផ្ដើមពីការផ្ដោតសំខាន់ទៅលើសាធារណភាពរបស់ទ្រង់ នៅខាងក្រៅ និងការប្រកាសជាសាកលរបស់ចំណាប់អារម្មណ៍នៃមហាជនទាំងឡាយ។

- រ៉ូម ១:៥ «ដែលយើងខ្ញុំបានទទួលព្រះគុណ នឹងងារជាសាវ័ក ដោយសារទ្រង់ សម្រាប់ឲ្យមានមនុស្សចុះចូល តាមសេចក្ដីជំនឿ នៅកណ្ដាលអស់ទាំងសាសន៍ ទុកជាប្រយោជន៍ដល់ព្រះនាមទ្រង់»។
- រ៉ូម ៩:១៧ «ដ្បិតមានបទគម្ពីរសម្ដែងដល់ផារ៉ោនថា «អញបានតាំងឯងឡើងសម្រាប់ការនេះឯង គឺដើម្បីសម្ដែងឫទ្ធិបារមីអញក្នុងខ្លួនឯង ប្រយោជន៍ឲ្យគេប្រកាសប្រាប់ពីឈ្មោះអញទូទៅពេញលើផែនដី»»។
- រ៉ូម ១៥:៩ «ហេតុនោះបានជាទូលបង្គំនឹងសរសើរតម្កើងទ្រង់ក្នុងពួកសាសន៍ដទៃ ហើយទូលបង្គំនឹងច្រៀងទំនុកបរិសុទ្ធ ថ្វាយព្រះនាមទ្រង់»។
- រ៉ូម ១០:១៣ «ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ»។

ដូច្នេះ របៀបមួយក្នុងការគិតអំពីការនេះ គឺព្រះនាមព្រះយេស៊ូវដើរទន្ទឹមនឹងព្រះកិត្តិសព្ទនៃព្រះយេស៊ូវ។ ខ្ញុំគិតថា ប្រហែលជាវិធីងាយស្រួលមួយក្នុងការចងចាំនូវអ្វីដែលខ្ញុំកំពុងព្យាយាមនិយាយ។ ព្រះនាមព្រះយេស៊ូវដើរទន្ទឹមនឹងព្រះកិត្តិសព្ទរបស់ព្រះយេស៊ូវ។ ឈ្មោះ គឺជាវិធីមួយក្នុងការប្រាស្រ័យទាក់ទងគ្នា និងជាវិធីមួយក្នុងការទំនាក់ទំនងទៅកាន់ពិភពលោកទាំងមូល ដូចជាបុគ្គលដែលលោកអ្នកកំពុងតែនិយាយអំពី ហើយព្រះយេស៊ូវមានព្រះវត្តមាន ដើម្បីឲ្យគេបានស្គាល់ ព្រះអង្គមានព្រះជន្មដើម្បីឲ្យគេថ្លែងទៅកាន់



ព្រមទាំងសរសើរតម្កើងនៅពាសពេញពិភពលោក។ ពាក្យថា ឈ្មោះ ត្រូវបានទាក់ទាញចំណាប់អារម្មណ៍ម្ដងហើយម្ដងទៀតចំពោះសាធារណជនទាំងឡាយ ដែលជាគោលដៅផ្ទាល់មាត់ចំពោះព្រះកិត្តិនាមទ្រង់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Why Does the Bible Stress the Power of Jesus's Name?
**ហេតុអ្វីបានជាព្រះគម្ពីរសង្កត់ធ្ងន់ទៅលើអំណាចនៃព្រះនាមព្រះយេស៊ូវ?**
https://www.desiringgod.org/interviews/what-is-the-baptism-of-the-holy-spirit

# ផ្នែកទី២
# ការលូតលាស់ខាងវិញ្ញាណ

## សំណួរទី៧៖
# តើព្រះគម្ពីរបង្រៀនថា ខ្ញុំពិសេសដែរឬទេ?

មាន ស្ទីកឃ័រ (sticker) មួយបិទនៅក្រោយឡានថា «អ្នកពិសេស»។ ហើយនៅក្រោម ស្ទីកឃ័រ នោះមានការសរសេរ ដោយអក្សរតូចៗថា «ដូចគ្រប់គ្នាដែរ»។ ពិតជាគួរឲ្យចាប់អារម្មណ៍មែន ប៉ុន្តែក៏នៅមានសំណួរដ៏សំខាន់មួយដែលយើងត្រូវសួរដែរ ទាក់ទងទៅនឹងចំណុចពិសេសរបស់មនុស្សជាតិ។ យោងតាមព្រះគម្ពីរ តើព្រះអង្គបានបង្កើតយើងក្នុងរបៀបដ៏ពិសេសដែរឬទេ?

«ជម្រាបសួរលោកគ្រូ! ខ្ញុំមានសំណួរមួយ៖ តើព្រះបានបង្កើតខ្ញុំក្នុងរបៀបដ៏ពិសេសដែរឬទេ? ខ្ញុំត្រូវតែសន្មតថា មានមនុស្សជាច្រើនដែលស្រដៀងខ្ញុំពាសពេញផែនដីនេះ ហើយថាខ្ញុំមិនសូវពិសេសក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ទេ។ ខ្ញុំបានឃើញខគម្ពីរជាច្រើនបានលើកឡើងថា ព្រះជាម្ចាស់បានបង្កើតយើងក្នុងគោលបំណងជាក់លាក់ ដែលត្រូវបានគ្រោងទុក។ ហើយក៏មានខគម្ពីរដែលរៀបរាប់អំពីភាពស្និទ្ធស្នាលរបស់ព្រះជាម្ចាស់ដែរ។ ព្រះអង្គជ្រាបចំនួនសក់នៅលើក្បាលរបស់យើង និងគ្រប់ដំណក់ទឹកភ្នែកដែលយើងស្រក់ដែរ។ ប៉ុន្តែ តើព្រះគម្ពីរបង្រៀនថា ខ្ញុំពិសេសដែរឬទេ បើប្រៀបធៀបជាមួយនឹងអ្នកដទៃ? ខ្ញុំមិនអាចរកឃើញខគម្ពីរជាក់លាក់ណាមួយដែលគាំទ្រចំណុចនេះទេ ប៉ុន្តែខ្ញុំបានឮគ្រូអធិប្បាយជាច្រើន ដែលខ្ញុំទុកចិត្តលើ គាំទ្រចំណុចនេះ។ ប៉ុន្តែ តើចំណុចនេះមាននៅក្នុងព្រះគម្ពីរដែរឬទេ? តាមរយៈព្រះគម្ពីរ តើយើងអាចគាំទ្រចំណុចពិសេសនេះបានដែរឬទេ?»

ខ្ញុំគិតថា តាមរយៈព្រះគម្ពីរបាន យើងអាចគាំទ្រចំណុចពិសេសនៃបុគ្គលនីមួយៗ ប៉ុន្តែមិនអាចគាំទ្រដោយត្រង់ៗបាននោះទេ—ដែលនេះមានន័យថា យើងមិនអាចគាំទ្របានតាមរយៈសម្រង់សម្តីផ្ទាល់យ៉ាងចំៗ

ទេ ប៉ុន្តែគាំទ្របានតែតាមរយៈចំណុចបញ្ចិតបញ្ចៀងប៉ុណ្ណោះ។ បើនិយាយម៉្យាងទៀត ខ្ញុំមិនស្គាល់ខគម្ពីរណាផ្ទាល់ដែលគាំទ្រចំណុចថា ក្នុងរបៀបណាមួយមនុស្សម្នាក់ៗមានចំណុចខុសៗគ្នាពីមនុស្សផ្សេងទៀតនោះទេ។ ទំនងជាមាន ប៉ុន្តែខ្ញុំមិនស្គាល់ទេ។ (ប្រសិនបើលោកអ្នកស្គាល់ សូមជួយប្រាប់យើងផង)។ ទី១ សូមអនុញ្ញាតឲ្យខ្ញុំពន្យល់អំពីអ្វីដែលខ្ញុំមានន័យថា ព្រះគម្ពីរបានចង្អុលបង្ហាញ ឬក៏តាមរយៈការបង្រៀនបញ្ចិតបញ្ចៀងថា មនុស្សយើងពិសេស ហើយមូលហេតុដែលការនោះសំខាន់។ ហើយខ្ញុំនឹងបញ្ចប់អត្ថបទនេះដោយលើកឡើងនូវអ្វីដែលខ្ញុំគិតថា សំខាន់ជាងនោះទៅទៀត។

ចំណុចដំបូងដែលយើងត្រូវធ្វើគឺបញ្ជាក់សេចក្តីពិតលើមូលដ្ឋានពីរយ៉ាងសិន ទាក់ទងនឹងរបៀបដែលព្រះជាម្ចាស់មានទំនាក់ទំនងជាមួយនឹងមនុស្សម្នាក់ៗ។

១. ព្រះអង្គ «ផ្សំគ្រឿង» សម្រាប់បុគ្គលនីមួយៗនៅក្នុងផ្ទៃម្តាយ។

២. តាមរយៈអធិបតេយ្យភាពរបស់ព្រះអង្គ ទ្រង់គ្រប់គ្រងលើរាល់ការជះឥទ្ធិពលរាប់លាន ដែលរចនាយើងទៅជាបុគ្គលដែលថា យើងជាយើងនៅសព្វថ្ងៃនេះ—ចាប់តាំងពីពេលដែលយើងកើតរហូតដល់ពេលគេកប់យើងវិញ។

## បានផ្សំគ្រឿងជាមួយគ្នា

ជាដំបូង ព្រះអង្គបានបង្កើតមនុស្សគ្រប់ៗរូប។ ព្រះអង្គបានបង្កើតពួកគាត់នៅក្នុងរបៀបដ៏ស្មុគស្មាញ ដោយទ្រង់បានផ្តោតចំណាប់អារម្មណ៍លើគ្រប់ចំណុចអំពីពួកគាត់ទាក់ទងទៅនឹងហ្សែន (និងចំណុចផ្សេងៗទៀត) ក្នុងផ្ទៃម្តាយរបស់ពួកគាត់។

ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ (ទំនុកតម្កើង ១៣៩:១៣)។



ចំណុចគឺថា៖ រូបភាពនេះគឺមិនមែនអំពីការដែលព្រះអង្គបង្កើតយើងក្នុងលក្ខណដូចៗគ្នាទាំងស្រុងនោះទេ។ រូបភាពគឺអំពីការដែលព្រះជាម្ចាស់ផ្សំគ្រឿងដោយត្បាញយើងនៅក្នុងព្រះហស្តរបស់ទ្រង់ ដូចជាការបង្កើតជាសម្លៀកបំពាក់ពីការដេរមួយម្ជុលទៅមួយម្ជុលទៀត។ ព្រះជាម្ចាស់បានបង្កើតលោកអ្នក តាមរយៈព្រះប្រាជ្ញារបស់ទ្រង់ដែលគ្មានព្រំដែន ដែលមានរួមទាំងអ្វីៗដែលលោកអ្នកចូលចិត្តអំពីខ្លួនឯង និងអ្វីៗដែលលោកអ្នកមិនចូលចិត្តអំពីខ្លួនឯង មានរួមទាំងចំណុចខ្លាំង និងចំណុចខ្សោយទាំងអស់ រាល់សមត្ថភាពទាំងអស់ និងពិការភាពទាំងអស់—ព្រះអង្គបានផ្សំគ្រឿងទាំងនោះនៅក្នុងផ្ទៃម្តាយរបស់លោកអ្នក។ នៅពេលដែលលោកម៉ូសេ បានត្អូញត្អែរទៅកាន់ព្រះជាម្ចាស់ថាគាត់មិនចេះនិយាយ ហើយថាព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងទៅជាមួយគាត់ កាលនោះមិនសូវជាកម្សាន្តចិត្តគាត់ប៉ុន្មានទេ។ ដូច្នេះ ព្រះជាម្ចាស់បានស្តីបន្ទោសមន្ទិលសង្ស័យរបស់គាត់ ដោយប្រើប្រាស់ព្រះបន្ទូលដ៏អស្ចារ្យនេះ៖

តើអ្នកណាបានបង្កើតមាត់មនុស្ស តើអ្នកណាដែលធ្វើឲ្យគ ឬឲ្យថ្លង់ ឲ្យភ្លឺ ឬឲ្យខ្វាក់នោះ បើមិន មែនអញជាព្រះយេហូវ៉ាប៉ុណ្ណោះទេ ដូច្នេះ ចូរឯងទៅឥឡូវចុះ អញនឹងនៅជាមួយនឹងមាត់ឯង ព្រមទាំងបង្រៀនសេចក្តីដែលឯងត្រូវនិយាយផង (និក្ខមនំ ៤:១១-១២)។

ដូច្នេះ នេះគឺជាសម្មតិកម្មដំបូងរបស់ព្រះគម្ពីរ៖ ព្រះជាម្ចាស់បានបង្កើតមនុស្សគ្រប់ៗរូប ដោយត្បាញភ្ជាប់យើងក្នុងរបៀបដ៏ស្មុគស្មាញ និងរៀងៗខ្លួននៅក្នុងផ្ទៃម្តាយយើង ក្នុងលក្ខណៈដែលយើងមានឥឡូវនេះ។

## ក្រោមអធិបតេយ្យភាពរបស់ទ្រង់

ទី២ ព្រះជាម្ចាស់មានការគ្រប់គ្រងលើគ្រប់ចំណុច និងគ្រប់កិច្ចការនៃរាល់បទពិសោធន៍របស់យើង។ គ្មានអ្វីកំពុងកើតឡើងចំពោះលោកអ្នក ឬ

ក៏ដែលធ្លាប់បានកើតឡើងចំពោះលោកអ្នក ឬក៏នឹងកើតឡើងចំពោះលោកអ្នក ដោយបានកើតឡើងក្រៅពីក្រោមផែនការរបស់ព្រះជាម្ចាស់ឡើយ។ ព្រះយេស៊ូវបានបើកបង្ហាញចំណុចនេះ ដោយប្រើប្រាស់ព្រឹត្តិការណ៍ដ៏ចៃដន្យមួយនៅលើលោកនេះ ហើយបានបង្រៀនថាមានតែព្រះជាម្ចាស់ទេដែលអាចធ្វើការនោះបាន។

តើគេមិនលក់ចាប២ថ្លៃ១លុយទេឬអី តែគ្មានចាបណាមួយធ្លាក់ទៅដីឥតព្រះវរបិតានៃអ្នករាល់គ្នាជ្រាបឡើយ (ម៉ាថាយ ១០:២៩)។

សត្វចាបមិនសូវសំខាន់ទេ! សត្វចាបរាប់លានក្បាលនៅលើផែនដីនេះកំពុងតែងាប់ជាប្រចាំថ្ងៃ ហើយមិនសំខាន់ ហើយមនុស្សយើងក៏មិនដឹងទៀតផង ប៉ុន្តែមិនមានសត្វចាបមួយក្បាលណាដែលបានធ្លាក់ងាប់ពីដើមឈើ ក្រៅពីការគ្រោងទុករបស់ព្រះជាម្ចាស់ឡើយ។ ឬក៏ដូចកណ្ឌគម្ពីរសុភាសិត ១៦:៣៣ បានលើកឡើងអំពីព្រឹត្តិការណ៍ចៃដន្យមួយទៀត ដូចជាការក្រឡុកគ្រាប់ឡុកឡាក់ ដែលយើងអាចនិយាយសម្រាយថា៖ «ការក្រឡុកគ្រាប់ឡុកឡាក់នៅផ្ទត់សំពត់ និងរាល់ការសម្រេចទាំងអស់មិនកើតឡើងក្រៅពីការគ្រោងទុករបស់ព្រះជាម្ចាស់ នៅឯកន្លែងលេងល្បែងទេ»។ ដូច្នេះ ចំណុចគឺថា មិនមានអ្វីដែលកំពុងកើតឡើងចំពោះលោកអ្នក ឬក៏អ្វីដែលបានកើតឡើងចំពោះលោកអ្នក ឬក៏អ្វីដែលនឹងកើតឡើងចំពោះលោកអ្នក បានកើតឡើងក្រៅពីការរចនាទុករបស់ព្រះជាម្ចាស់ឡើយ។

## ព្រីស [prism] នៃសិរីល្អ

ប្រសិនបើយើងអាចឈរលើសម្មតិកម្មទាំងពីរនោះបាន—(១) ត្រង់ថាព្រះជាម្ចាស់បានបង្កើតលោកអ្នក រហូតដល់គ្រាប់អាតូម និងម៉ូលេគុលនៃឌីអិនអេរបស់លោកអ្នក និង (២) ព្រះជាម្ចាស់បានមានផែនការសម្រាប់រាល់គ្រប់បទពិសោធន៍របស់លោកអ្នក រហូតដល់កម្រិតនៃការដែលខ្យល់បក់



ប៉ះសរសៃសក់របស់លោកអ្នក—នោះមានន័យថា រាល់គ្រប់ចំណុចខាងឯសាច់ឈាម ផ្លូវចិត្ត ទំនាក់ទំនង និងលក្ខណៈខុសៗគ្នាខាងឯវិញ្ញាណរបស់លោកអ្នក ទាំងអស់នោះសុទ្ធតែជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់។ ទាំងអស់គឺជារបស់ព្រះជាម្ចាស់។

អ្វីដែលយើងធ្វើបន្ទាប់គឺ យកសេចក្ដីពិតទាំងពីរនោះ ហើយគិតអំពីចំណុចអនុវត្ត ឬក៏បញ្ជិតបញ្ចៀង។ នេះហើយគឺជាមូលហេតុដែលខ្ញុំបានលើកឡើងថា ចំណុចនេះមិនមែនជាសេចក្ដីបង្រៀនចំៗ ប៉ុន្តែជាសេចក្ដីបង្រៀនបញ្ជិតបញ្ចៀងវិញ។ ព្រះគម្ពីរបង្រៀនឲ្យយើងធ្វើបែបនេះ៖ «ចូរពិចារណាសេចក្ដីដែលខ្ញុំប្រាប់ទាំងនេះចុះ ដ្បិតព្រះអម្ចាស់ទ្រង់នឹងប្រទានឲ្យអ្នកមានយោបល់ ក្នុងគ្រប់ការទាំងអស់» (២ធីម៉ូថេ ២:៧)។

ហើយនៅពេលដែលលោកអ្នកគិតអំពីចំណុចពិតទាំងពីរនោះ នោះលោកអ្នកនឹងយល់ឃើញថា៖ គ្មានអ្នកណា គឺគ្មានអ្នកណាទាល់តែសោះដែលមានបទពិសោធន៍ដូចគ្នាទាំងស្រុងទៅនឹងបទពិសោធន៍ដែលលោកអ្នកមានទេ។ ពួកគាត់អាចមានបទពិសោធន៍ស្រដៀងៗគ្នាបាន ប៉ុន្តែមិនអាចមានបទពិសោធន៍ដូចលោកអ្នកទាំងស្រុងបានឡើយ។ លោកអ្នកមានបទពិសោធន៍រាប់លាន ទាំងតូច និងធំ បទពិសោធន៍ដែលអាចមាននៅក្នុងមួយវិនាទី ឬក៏មួយឆ្នាំ ទាំងបទពិសោធន៍ដែលមាននៅក្នុងសតិសម្បជញ្ញៈ និងបទពិសោធន៍ដែលមិនមាននៅក្នុងសតិសម្បជញ្ញៈ—ហើយរាល់គ្រប់បទពិសោធន៍ទាំងនោះបានរចនាលោកអ្នកឡើង។ ជារៀងរាល់ថ្ងៃ យើងកំពុងតែទទួលបានការរចនាឡើង តាមរយៈបទពិសោធន៍ដែលយើងមាន។ ផ្លូវនានានៅក្នុងខួរក្បាលយើងកំពុងតែទទួលបានការចាក់សាប។ ខួរក្បាលយើងកំពុងតែរក្សាទុកព័ត៌មាន។ ហើយគ្មានអ្នកណា—គឺគ្មានអ្នកណាទាល់តែសោះនៅលើផែនដីនេះ—ដែលមានការប្រមូលទុករាប់លានបទពិសោធន៍ដូចគ្នាទាំងស្រុងដែលកំពុងរចនាលោកអ្នកឡើង ដូចដែលលោកអ្នកមាន

នោះទេ។ ស្រដៀងគ្នា? អាចមានបាន។ ដូចគ្នាទាំងស្រុង? មិនអាចមានបានទេ។

មានតែលោកអ្នកទេដែលជាបុគ្គលដែលអាចមានបទពិសោធន៍ដែលលោកអ្នកមានបាន។ ដូច្នេះ មានតែលោកអ្នកទេដែលជាលោកអ្នកនៅលើផែនដីនេះ និងនៅក្នុងប្រវត្តិសាស្ត្រ—គឺក្នុងគ្រប់ចំណុចទាំងអស់។ ហើយដោយសារព្រះជាម្ចាស់គឺជាព្រះអាទិករនៃអង្គដែលបង្កើតបទពិសោធន៍នោះនៅក្នុងផ្ទៃម្តាយ  និងជាអង្គដែលគ្រប់គ្រងលើបទពិសោធន៍នៅក្នុងជីវិត ចំណុចពិសេសរបស់លោកអ្នកគឺលោកអ្នកផ្ទាល់ តាមរយៈការរចនារបស់ទ្រង់។ លោកអ្នកមិនមែនជាមនុស្សដែលកើតឡើងដោយចៃដន្យនោះទេ។ ហើយលោកអ្នកក៏មិនមែនជាវត្ថុគំរូនៃមនុស្សជាតិដែរ។ លោកអ្នកគឺជាលោកអ្នកតាមរយៈការបង្កើតរបស់ព្រះជាម្ចាស់ និងរចនាឡើងដោយមានការគ្រប់គ្រងពីទ្រង់។

ហើយមូលហេតុដែលចំណុចនេះសំខាន់គឺដោយសារព្រះគម្ពីរបានបង្រៀនថា  រាល់គ្រប់អ្វីៗ  ដែលមានរួមទាំងរាល់គ្រប់បុគ្គលនីមួយៗ  គឺព្រះអង្គបានបង្កើតមកសម្រាប់សិរីល្អរបស់ព្រះគ្រីស្ទ និងសិរីល្អរបស់ព្រះជាម្ចាស់។ ដ្បិតរាល់គ្រប់អ្វីៗគឺទ្រង់បានបង្កើតមកដោយសារព្រះគ្រីស្ទ ហើយសម្រាប់ទ្រង់ទាំងអស់ផង—សម្រាប់ព្រះគ្រីស្ទ និងសម្រាប់សិរីល្អរបស់ទ្រង់ (កូឡូស ១:១៦)។ ទាំងអស់កើតមកពីទ្រង់ ដោយសារទ្រង់ ហើយសម្រាប់ទ្រង់។ ទាំងអស់គឺសម្រាប់ទ្រង់ សម្រាប់សិរីល្អរបស់ទ្រង់—គឺទាំងអស់ (រ៉ូម ១១:៣៦)។ នេះមានន័យថា បុគ្គលិកលក្ខណៈរបស់លោកអ្នកផ្ទាល់ ដែលមានរួមទាំងចំណុចពិសេសនៃហ្សែន ដែលបានរចនាលោកអ្នកឡើង និងរាល់គ្រប់បទពិសោធន៍របស់លោកអ្នកទាំងអស់ គឺមានដើម្បីថ្វាយសិរីល្អទៅកាន់ព្រះគ្រីស្ទ និងសិរីល្អរបស់ព្រះជាម្ចាស់។

លោកអ្នកប្រៀបដូចជាព្រីសមួយ (prism) ដែលមានរូបរាងមិនដូចព្រីសណាផ្សេងទៀតនៅលើផែនដីនេះ ដែលថានៅពេលដែលពន្លឺរបស់ព្រះជាម្ចាស់ចែងចាំងលើលោកអ្នក នោះមានរង្វើកនៃកាំរស្មី ការលាយទ្បំពណ៌ដែលយើងអាចនិយាយបានថា គឺមានតែលោកអ្នកតែមួយគត់ប៉ុណ្ណោះទេដែលអាចធ្វើឲ្យពន្លឺកាំរស្មីព្រីសនោះអាចព្រាកចេញបាន។ ហើយនេះឯងជាមូលហេតុដែលលោកអ្នកសំខាន់។ ជីវិតរបស់លោកអ្នកដែលមានភក្តីភាពទៅកាន់ព្រះជាម្ចាស់ឆ្លុះបញ្ចាំងសិរីល្អរបស់ទ្រង់ ក្នុងរបៀបដែលមិនអាចមានជីវិតរបស់អ្នកណាផ្សេងទៀតអាចធ្វើបានឡើយ។ ស្រដៀងគ្នា? បាន។ ប៉ុន្តែមិនអាចដូចគ្នាទាំងស្រុងបានឡើយ។ ភាពពិសេសនៃភក្តីភាពរបស់លោកទៅអ្នកកាន់ព្រះគ្រីស្ទគឺជាសិរីល្អមួយសំដៅទៅកាន់ព្រះគ្រីស្ទ ដែលមិនអាចមានអ្នកផ្សេងទៀតមានដូចលោកអ្នកទាំងស្រុងបានទេ។

## ការផ្តោតចំណាប់អារម្មណ៍ដ៏ពិសេសលើលោកអ្នក

ខណៈពេលដែលខ្ញុំបានស្រាវជ្រាវបន្ថែមទៀតក្នុងព្រះបន្ទូល ដោយព្យាយាមស្វែងរកប្រយោគចំៗអំពីចំណុចពិសេសរបស់យើងរៀងៗខ្លួន ខគម្ពីរដែលចំជាងគេដែលខ្ញុំបានរកឃើញគឺកណ្ឌគម្ពីរ វិវរណៈ ២:១៧ ដែលព្រះយេស៊ូវបានលើកឡើងដូចតទៅ៖ «ឯអ្នកណាដែលឈ្នះ នោះអញនឹងឲ្យ…គ្រួសស១ដល់អ្នកនោះ នៅគ្រួសនោះមានឆ្លាក់ជាឈ្មោះថ្មី ដែលគ្មានអ្នកណាស្គាល់ឡើយ ស្គាល់បានតែអ្នកដែលទទួលប៉ុណ្ណោះ»។

ខ្ញុំយល់ថា ខ្ញុំមិនអាចបង្ហាញភស្តុតាងថា ឈ្មោះរបស់លោកអ្នកនៅលើថ្មនោះនឹងមិនដូចឈ្មោះដែលព្រះអង្គបានសរសេរនៅលើថ្មរបស់អ្នកជឿផ្សេងៗទៀតបានទេ ព្រោះខគម្ពីរមិនបានបញ្ជាក់អំពីចំណុចនេះឡើយ។ ប៉ុន្តែ នេះគឺជាអ្វីដែលខគម្ពីរបានលើកឡើង (ហើយនេះគឺជាអ្វីដែលខ្ញុំបានសំដៅលើពីដើម នៅពេលដែលខ្ញុំថា យើងនឹងបញ្ចប់ឯកសារលើចំណុចដែលសំខាន់ជាងភាពពិសេសរបស់យើង)។ កណ្ឌគម្ពីរ វិវរណៈ ២:១៧

បានបញ្ជាក់ថា មានការផ្ដោតចំណាប់អារម្មណ៍លើដ៏ពិសេសដែលព្រះគ្រីស្ទបានធ្វើលើរាល់គ្រប់រាស្ត្ររបស់ទ្រង់ម្នាក់ៗ—ទំនាក់ទំនងដ៏ពិសេសផ្ទាល់—ពីព្រោះព្រះអង្គបានមានបន្ទូលថា «គ្មានអ្នកណាស្គាល់ឡើយ ស្គាល់បានតែអ្នកដែលទទួលប៉ុណ្ណោះ»។

បើនិយាយម្យ៉ាងវិញទៀត ព្រះអង្គបានបង្វែរចំណាប់អារម្មណ៍របស់យើងចេញពីចំណុចពិសេសនៃឈ្មោះរបស់យើង ទៅកាន់ចំណុចពិសេសនៃទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់វិញ។ មិនថាលោកអ្នកមានឈ្មោះអ្វីក៏ដោយ (ហើយខ្ញុំគិតថា ឈ្មោះរបស់លោកអ្នកក៏ពិសេសដែរ) ក៏មានតែព្រះគ្រីស្ទតែមួយអង្គគត់ដែលស្គាល់ឈ្មោះនោះ ហើយអាចមានទំនាក់ទំនងផ្ទាល់ជាមួយនឹងលោកអ្នក ដោយឈ្មោះនោះបាន។ សរុបសេចក្ដីទៅ ខ្ញុំចង់លើកទឹកចិត្តបងប្អូនទាំងអស់គ្នាឲ្យផ្ដោតលើចំណុចពិសេសនៃជីវិតរបស់យើងជាការថ្វាយសិរីល្អទៅកាន់ព្រះគ្រីស្ទ ហើយឲ្យតម្លៃលើចំណុចពិសេសនៃចំណាប់អារម្មណ៍របស់ព្រះគ្រីស្ទមកលើយើង ខ្ពស់ជាងចំណុចពិសេសនៃជីវិតរបស់យើងវិញ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Does the Bible Say I Am Unique?
**តើព្រះគម្ពីរបង្រៀនថា ខ្ញុំពិសេសដែរឬទេ?**
https://www.desiringgod.org/interviews/does-the-bible-say-i-am-unique



## សំណួរទី៨៖
# តើខ្ញុំអាចថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំបានដោយរបៀបណា?

តើយើងអាចថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃបានដោយរបៀបណា? ថ្ងៃនេះ ប្អូន រក្សា បានសួរសំណួរដូចតទៅ៖ «ជម្រាបសួរលោកគ្រូ! ខ្ញុំបានអានសៀវភៅខាងលោកគ្រូ ហើយវាពិតជាអស្ចារ្យមែនក្នុងការដែលយើងដឹងថា ព្រះជាម្ចាស់បានបញ្ជាឲ្យយើងមានការអរសប្បាយដ៏ខ្ពង់ខ្ពស់ និងមានអំណរក្នុងទ្រង់! សាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១០:៣១ ថា «ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សម្រាប់ចម្រើនសិរីល្អដល់ព្រះចុះ»។ តើខ្ញុំអាចថ្វាយសិរីល្អទៅកាន់ព្រះអង្គបានដោយរបៀបណា តាមរយៈការមានអំណរក្នុងព្រះអង្គដោយចំណីអាហារ? តើខ្ញុំអាចធ្វើការនេះបានតាមរយៈការដឹងថា ព្រះអង្គគឺជាអង្គដែលបានផ្គត់ផ្គង់ម្ហូបសម្រាប់ខ្ញុំនៅថ្ងៃនេះ ដូច្នេះខ្ញុំអាចរីករាយជាមួយនឹងការញ៉ាំម្ហូបនេះបានមែនឬ? ឬក៏ឧទាហរណ៍មួយទៀត គឺសប្បាយចិត្តនៅពេលដែលកូនយើងរៀនបានពិន្ទុល្អនៅសាលារៀន។ ខ្ញុំចង់ដឹងថា តើខ្ញុំអាចសប្បាយចិត្តនៅក្នុងព្រះអម្ចាស់បានក្នុងរបៀបដែលត្រឹមត្រូវ ដើម្បីខ្ញុំអាចថ្វាយសិរីល្អទៅកាន់ព្រះអង្គ ក្នុងរបៀបដ៏ខ្ពង់ខ្ពស់បំផុតបានដោយរបៀបណា។ តើខ្ញុំអាចធ្វើគ្រប់អ្វីៗទាំងអស់ ដើម្បីថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់បានដោយរបៀបណា?»

គ្រប់បុគ្គលទាំងអស់គួរតែសង្វាតស្វែងរកឲ្យអស់ពីកម្លាំងរបស់យើងក្នុងការប្រើប្រាស់កម្លាំងឲ្យអស់ពីសមត្ថភាពក្នុងឋានៈដ៏ខ្ពស់បំផុត និងអំឡុងពេលនៃការដែលយើងមានអំណរក្នុងព្រះជាម្ចាស់លើសគ្រប់អ្វីៗទាំងអស់

ពីព្រោះព្រះជាម្ចាស់ទទួលបានសេរីល្អច្រើនបំផុតនៅក្នុងយើង នៅពេលដែលយើងកាន់តែមានការស្កប់ស្កល់ចិត្តនៅក្នុងទ្រង់។

ប្រសិនបើលោកអ្នកមានការស្កប់ស្កល់ចិត្តយ៉ាងខ្លាំងនៅក្នុងគ្រួសារ ការងារ ភាពល្បីល្បាញ ភាពជោគជ័យ លុយកាក់ ចំណីអាហារ តន្ត្រី សុខភាព ឬក៏ការបន្តរស់នៅ—ប្រសិនបើលោកអ្នកមានការស្កប់ស្កល់ចិត្តនៅក្នុងចំណុចណាមួយនេះយ៉ាងខ្លាំង ជាជាងនៅក្នុងព្រះជាម្ចាស់—នេះមានន័យថា លោកអ្នកបានបន្ទាបបន្ថោកសិរីល្អរបស់ទ្រង់ ហើយលោកអ្នកបានលើកតម្កើងសិរីល្អនៃអ្វីមួយដែលខ្លួនកំពុងតែស្កប់ស្កល់ចិត្តជាមួយយ៉ាងខ្លាំងហើយ។ ព្រះគម្ពីរបានលើកឡើងយ៉ាងច្បាស់ថា យើងគួរតែរស់នៅ ដើម្បីបង្ហាញតម្លៃដ៏ឧត្តុង្គឧត្តម ភាពអស្ចារ្យ និងសិរីល្អរបស់ព្រះជាម្ចាស់។ នេះគឺជាមូលហេតុចម្បងនៃការដែលយើងមានជីវិត។

## ការឈឺចាប់ ឬក៏ការសប្បាយ

មានចំណុចចម្បងពីរយ៉ាងដែលសាតាំងប្រើប្រាស់ ដើម្បីបន្ទាបបន្ថោកសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ធ្វើឲ្យយើងផ្តល់តម្លៃលើអ្វីមួយផ្សេងទៀតជាជាងលើព្រះជាម្ចាស់៖ ១. ការឈឺចាប់ ២. ការអរសប្បាយ។ នេះគឺជាយុទ្ធសាស្ត្រពីរយ៉ាងរបស់សាតាំង ដើម្បីបង្ខូចរបៀបដែលយើងថ្វាយសិរីល្អទៅកាន់ព្រះអង្គ។

ការឈឺចាប់អាចធ្វើឲ្យយើងឲ្យតម្លៃលើអ្វីផ្សេងទៀតជាជាងលើព្រះជាម្ចាស់ ដោយធ្វើឲ្យយើងខឹងព្រះអង្គ ដោយសារយើងកំពុងតែប្រឈមមុខនឹងការឈឺចាប់នេះ ហើយវាក៏ធ្វើឲ្យយើងចង់ឆ្លងផុតជាជាងធ្វើឲ្យយើងចង់ឱបក្រសោបយកព្រះជាម្ចាស់ដែរ។ នេះមានន័យថា ការឈឺចាប់គឺជាឱកាសមាសក្នុងការធ្វើឲ្យយើងថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់ តាមរយៈការដែលយើងបង្ហាញថា ព្រះអង្គមានតម្លៃចំពោះយើងខ្លាំងជាងភាពស្រណុកសុខស្រួល ឬក៏ការឆ្លងផុតការឈឺចាប់នេះ។ ការអរសប្បាយក៏អាចធ្វើឲ្យយើងឲ្យតម្លៃលើអ្វីផ្សេងទៀតខ្ពស់ជាងព្រះជាម្ចាស់ដែរ—មិនមែនតាមការរយៈធ្វើឲ្យយើងខឹងព្រះអង្គ ប៉ុន្តែតាមរយៈការដែលយើងភ្លេចព្រះអង្គ ពីព្រោះយើងស្កប់ចិត្តពេកក្នុងការអរសប្បាយជាមួយនឹងអំណោយទាន ដែលព្រះអង្គបានប្រទានមកកាន់យើង។ យើងអាចឃើញចំណុចនេះនៅក្នុងកណ្ឌគម្ពីរអេសេគាល ១៦:១៤-១៥ នៅពេលដែលព្រះអង្គមានបន្ទូលទៅសាសន៍អ៊ីស្រាអែល៖

«ឯកិត្តិសព្ទពីលំអរុងរឿងរបស់ឯង បានខ្ចរខ្ចាយទៅដល់អស់ទាំងនគរ ពីព្រោះលំអរបស់ឯងបានគ្រប់លក្ខណ៍ ដោយសាររស្មីរបស់អញ ដែលអញបានឲ្យស្ថិតលើឯង នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា។ ប៉ុន្តែ ឯងបានទុកចិត្តនឹងរូបលំអរបស់ឯង ហើយបានធ្វើជាស្រីសំផឹង»។

បើនិយាយម្យ៉ាងវិញទៀត ព្រះអង្គបានផ្តល់ដល់សាសន៍អ៊ីស្រាអែលនូវអំណោយទាននៃរូបលំអ ជាជាងឲ្យអំណោយទាននោះថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់ ពួកគាត់បែរជាលង់ស្នេហ៍ជាមួយនឹងអំណោយទាននោះវិញ។ ពួកគាត់ចង់បានអំណោយទានជាជាងចង់បានអ្នកប្រទានឲ្យ។ តាមរយៈការមិនស្កប់ចិត្តជាមួយព្រះអង្គ នោះពួកគាត់មិនបានថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់ទេ ប៉ុន្តែបែរជាលង់ស្នេហ៍ជាមួយនឹងអំណោយទានដ៏ល្អរបស់ព្រះអង្គវិញ។ ពួកគាត់ចង់បានអំណោយទានជាជាងអ្នកដែលប្រទានឲ្យ។

ការឈឺចាប់ និងការអរសប្បាយគឺជាយុទ្ធសាស្ត្ររបស់សាតាំងក្នុងការបង្ខូចការដែលយើងថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់។ ការមិនឲ្យនូវអ្វីដែលល្អក៏អាចធ្វើឲ្យយើងខូចដែរ។ ហើយការឲ្យនូវអ្វីដែលល្អក៏អាចធ្វើឲ្យយើងខូចដែរ។ ទាំងពីរអាចក្លាយជាឱកាសនៃការដែលយើងមិនថ្វាយព្រះកិត្តិយសទៅកាន់ព្រះជាម្ចាស់ ក៏ដូចជាមិនថ្វាយសិរីល្អទៅកាន់ទ្រង់—ឬក៏អាចប្រាកដជាចំណុចដែលថ្វាយសិរីល្អទៅកាន់ទ្រង់ក៏ថាបាន។ សំណួររបស់ប្អូន រក្សា

ទាក់ទងទៅនឹងចំណុចចុងក្រោយនេះ៖ តើយើងអាចថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់តាមរយៈរបស់ល្អៗដែលទ្រង់ប្រទានមកកាន់យើងបានដោយរបៀបណា? គាត់បានលើកឡើងអំពីម្ហូប និងកូនៗ។

## ព្រះអង្គនៅក្នុងអ្វីដែលល្អៗ

ខ្ញុំនឹងគ្រាន់តែលើកឡើងនូវខគម្ពីរមួយចំនួនដែលផ្តល់ផ្នែកខ្លះៗនៃចម្លើយលើសំណួរនេះ។ នៅក្នុងកណ្ឌគម្ពីរ ភីលីព ៤:១១-១៣ សាវ័ក ប៉ុល បានលើកឡើងថា៖

«ខ្ញុំបានរៀនឲ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ»។

សាវ័ក ប៉ុល បានលើកឡើងយ៉ាងច្បាស់ថា មានចំណុចអាថ៌កំបាំងខាងឯវិញ្ញាណ អ្វីដែលជ្រៅ ហើយអស្ចារ្យដែលយើងអាចរៀនបាននៅក្នុងជីវិតជាគ្រីស្ទបរិស័ទ ដែលនេះគ្រាន់តែធ្វើឲ្យបុគ្គលណាម្នាក់បន្ទាបខ្លួន ប៉ុន្តែក៏អាចធ្វើឲ្យគាត់មានហូរហៀរ មិនមែនគ្រាន់តែចំពោះភាពស្រេកឃ្លាន ប៉ុន្តែដើម្បីឲ្យមានយ៉ាងច្រើន ហើយការមានច្រើនហូរហៀរក៏អាចជាចំណុចពិបាកក្នុងការសិរីល្អទៅកាន់ព្រះជាម្ចាស់នៅក្នុងជីវិតយើងដូចទៅនឹងការដែលយើងកំពុងតែរងទុក្ខផងដែរ។ ដូច្នេះ សាវ័ក ប៉ុល ត្រូវរៀនអ្វីដែលចម្លែក ពិសេស និងស៊ីជម្រៅ ដើម្បីជួយឲ្យគាត់ដឹងអំពីរបៀបនៃការមានហូរហៀរបាន។ ហើយនេះគឺជាសំណួររបស់ប្អូនរក្សា។

ហើយខ្ញុំគិតថាចម្លើយរបស់សាវ័ក ប៉ុល ទាក់ទងទៅនឹងចំណុចអាថ៌កំបាំងនៃការមានយ៉ាងបរិបូណ៌គឺមាននៅក្នុងកណ្ឌគម្ពីរ ភីលីព ៣:៧-៨។ ចំណុចអាថ៌កំបាំងគឺមិនទាក់ទងទៅនឹងការចុះតម្លៃ ឬក៏បន្ទាបបន្ថោកសេចក្តីសប្បុរសនៃអំណោយទានរបស់ព្រះជាម្ចាស់នោះទេ ប៉ុន្តែគឺទាក់ទងទៅនឹងការស្គាល់ព្រះគ្រីស្ទយ៉ាងច្បាស់ ស្រឡាញ់ព្រះអង្គយ៉ាងខ្លាំង ហើយមានការស្កប់ស្កល់ចិត្តក្នុងទ្រង់ដល់ថ្នាក់ថា យើងអាចទទួលយកអ្វីៗដែលល្អពីព្រះហស្តទ្រង់ថាជាអំណោយទានដែលលើកតម្កើងព្រះគ្រីស្ទ ហើយថាព្រះអង្គអាចដកអ្វីៗដែលល្អនោះចេញពីដៃយើងក្នុងលក្ខណៈដែលនៅលើកតម្កើងព្រះគ្រីស្ទ ដើម្បីដាក់ពិន័យយើង។ នេះគឺជាអ្វីដែលសាវ័ក ប៉ុល បានសរសេរនៅក្នុងកណ្ឌគម្ពីរ ភីលីព ៣:៧-៨៖

«ប៉ុន្តែ សេចក្តីអ្វីដែលមានប្រយោជន៍ដល់ខ្ញុំពីមុន នោះខ្ញុំបានរាប់ជាខាតវិញ ដោយព្រោះព្រះគ្រីស្ទ ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេចក្តីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ ដែលដោយយល់ដល់ទ្រង់ ខ្ញុំបានខាតគ្រប់ទាំងអស់ ហើយបានរាប់ទាំងអស់ទុកដូចជាសំរាម ប្រយោជន៍ឲ្យបានព្រះគ្រីស្ទវិញ»។

ចំណុចដែលថាគាត់បានរាប់អ្វីដែលមានប្រយោជន៍ថាជាខាត ឬក៏ថាជាសំរាមមិនមែនមានន័យថា គាត់មិនអាចអរសប្បាយជាមួយនឹងអ្វីៗទាំងនោះទេ ប៉ុន្តែវាអាចមានន័យថា ក្នុងពេលដែលរបស់ទាំងនោះប្រកួតប្រជែងជាមួយនឹងការអស្ចារ្យដ៏ឧត្តុង្គឧត្តម តម្លៃ សិរីល្អ និងការស្កប់ស្កល់ចិត្តក្នុងព្រះគ្រីស្ទ នោះវានឹងក្លាយជាសត្រូវ និងជាសំរាមវិញ។ ប៉ុន្តែ សាវ័ក ប៉ុល បានស្គាល់ចំណុចអាថ៌កំបាំង៖ ប្រសិនបើព្រះគ្រីស្ទមានតម្លៃលើសអ្វីៗទាំងអស់នោះទាំងអ្វីដែលបានបាត់បង់ និងបច្ចុប្បន្នកាល—ការទទួលបានអ្វីដែលល្អៗ—គឺជាឱកាសក្នុងការយកព្រះគ្រីស្ទធ្វើជាទ្រព្យសម្បត្តិ។

ខគម្ពីរមួយទៀតដែលខ្ញុំគិតថា ចង្អុលបង្ហាញទៅលើចម្លើយគឺកណ្ឌគម្ពីរ ១ធីម៉ូថេ ៤:៣-៥ នៅក្នុងខនេះសាវ័ក ប៉ុល បានលើកឡើងថា អ្នកខ្លះបានហាមមិនឲ្យរៀបការ និងតមពីអាហារណាមួយដែលព្រះជាម្ចាស់បានបង្កើតមក ដោយឲ្យអស់អ្នកដែលជឿ និងស្គាល់សេចក្តីពិតទទួលដោយ

ដឹងគុណ។ អ្វីៗដែលព្រះជាម្ចាស់បានបង្កើតមកគឺសុទ្ធតែល្អ ហើយយើងក៏មិនគួរបដិសេធអ្វីដែរ ប្រសិនបើយើងទទួលយកដោយដឹងគុណ ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសេចក្ដីអធិស្ឋានបានធ្វើឲ្យវាបរិសុទ្ធរួចហើយ។ «ព្រមទាំងហាមប្រាមមិនឲ្យយកប្ដីប្រពន្ធ ហើយឲ្យត្រូវតមអាហារ ដែលព្រះបានបង្កើតមក សម្រាប់ពួកអ្នកជឿ និងពួកអ្នកដែលស្គាល់សេចក្ដីពិតឲ្យបានទទួលដោយអរព្រះគុណ ដ្បិតសត្វទាំងអស់ដែលព្រះទ្រង់បង្កើតមក នោះសុទ្ធតែល្អ ហើយមិនត្រូវចោល១ឡើយ ឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ ដ្បិតបានញែកជាបរិសុទ្ធ ដោយសារព្រះបន្ទូល ហើយសេចក្ដីអធិស្ឋាន»។

ស្ទើរតែគ្រប់ពាក្យពេចន៍នៅក្នុងខគម្ពីរនេះតម្រូវឲ្យមានការបកស្រាយបន្ថែមទៀត។ ហើយបន្ទាប់មកសាវ័ក ប៉ុល ក៏បានបន្ថែមការព្រមាន «ដល់ពួកអ្នកមាន នៅលោកីយ៍នេះ» នៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៦:១៧ បានព្រមានថា «កុំឲ្យគេ…ទុកចិត្តនឹងទ្រព្យសម្បត្តិ ដែលមិនទៀងនោះឡើយ ត្រូវទុកចិត្តនឹងព្រះដ៏មានព្រះជន្មរស់វិញ ដែលទ្រង់ប្រទានគ្រប់ទាំងអស់មកយើងរាល់គ្នាជាបរិបូរ ឲ្យយើងបានអរសប្បាយ»។

## ការហូបក្រូចច្របាច់ ដើម្បីសិរីល្អព្រះ

ខ្ញុំចង់បញ្ចប់អត្ថបទដោយលើកឡើងបើកបទបង្ហាញមួយចំនួននៃរបៀបដែលយើងអាចហូបក្រូចច្របាច់ ដើម្បីថ្វាយសិរីល្អដល់ព្រះ។

១. ខ្ញុំចង់គាំទ្រព្រះបន្ទូលរបស់ព្រះដោយអំណរថា ពណ៌លឿងគឺជាអំណោយទានពីព្រះជាម្ចាស់។ រសជាតិផ្អែមគឺជាអំណោយទានពីព្រះជាម្ចាស់។ សារធាតុចិញ្ចឹម និងរបៀបដែលរូបកាយខ្ញុំប្រើប្រាស់វាគឺជាអំណោយទានពីព្រះជាម្ចាស់។ ព្រះអាទិត្យ និងភ្លៀងដែលធ្វើឲ្យដើមក្រូចដុះគឺជាអំណោយទានពីព្រះជាម្ចាស់។ ការដឹកជញ្ជូនក្រូចនោះចូលកន្លែងលក់ ដែលខ្ញុំអាចទិញបាន គឺជាអំណោយទានពីព្រះជាម្ចាស់។ល។ ខ្ញុំចង់ប្រកាសការនេះឲ្យឮៗ ដោយសារខ្ញុំដឹងវាជាក់ច្បាស់។

២. ខ្ញុំនឹងបញ្ចេញសម្លេងឲ្យអស់ពីចិត្តក្នុងការអរព្រះគុណព្រះអង្គ។ ហើយខ្ញុំនឹងព្យាយាមធ្វើការនេះជាញឹកញាប់ ដើម្បីឲ្យអ្នកដទៃដឹងពីកន្លែងដែលការដឹងគុណនេះកើតចេញ និងដើម្បីឲ្យពួកគេដឹងថា ព្រះជាម្ចាស់ល្អមានពេញទៅដោយប្រាជ្ញាញាណ និងឥទ្ធិឫទ្ធិ។

៣. ខ្ញុំនឹងរម្លឹកខ្លួនឯងថា ខ្ញុំមិនស័ក្តិសមនឹងទទួលក្រូចច្របាច់នេះទេ។ តាមពិតទៅ ខ្ញុំស័ក្តិសមទៅស្ថាននរក។ ហេតុដូច្នេះហើយបានជាខ្ញុំនឹងអរព្រះគុណព្រះអង្គ ដោយសារទ្រង់បានអត់ទោសអំពើបាបខ្ញុំ ហើយថាការដែលខ្ញុំអាចអរសប្បាយជាមួយនឹងក្រូចច្របាច់គឺដោយសារព្រះអង្គបានទិញវាសម្រាប់ខ្ញុំ។ ព្រះអង្គបានទិញក្រូចច្របាច់នេះដោយព្រះលោហិតទ្រង់ ដើម្បីឲ្យជាអំណោយទានដល់កូនៗទ្រង់ ដែលកំពុងតែធ្វើដំណើរទៅកាន់ស្ថានសួគ៌។

៤. ខ្ញុំនឹងរម្លឹកខ្លួនឯងថា ការអរសប្បាយមួយនេះ រសជាតិមួយនេះ ភាពត្រជាក់មួយនេះនៅលើអណ្ដាតរបស់ខ្ញុំ សារជាតិចិញ្ចឹមជីវិតមួយនេះ បានបើកបង្ហាញចំណុចមួយនៃការយល់ដឹង និងព្រលឹងរបស់ខ្ញុំអំពីព្រះជាម្ចាស់ ដែលខ្ញុំមិនអាចដឹងបានក្នុងរបៀបណាផ្សេងទៀត។ នេះជាមូលហេតុដែលទ្រង់បានបង្កើតផែនដីនេះ ពីព្រោះទាំងអស់នេះគឺហាក់បីដូចជាព្រីស (prism) ដែលជួយឲ្យយើងយល់ចំណុចផ្សេងទៀតនៃសិរីល្អរបស់ព្រះជាម្ចាស់។

៥. បន្ទាប់មក ខ្ញុំនិងចែកចាយក្រូចច្របាច់នេះជាមួយនឹងអ្នករួមតុបាយខ្ញុំដោយក្ដីស្រឡាញ់។ ខ្ញុំនឹងមិនទុកតែសម្រាប់ខ្លួនឯងទេ។

៦. ហើយជាចុងក្រោយ ខ្ញុំនឹងប្រើប្រាស់កម្លាំងដែលព្រះអង្គបានប្រទានមកកាន់ខ្ញុំឲ្យអាចរស់នៅ ដើម្បីថ្វាយសិរីល្អទៅកាន់ទ្រង់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How Do I Glorify God in My Daily Life
**តើខ្ញុំអាចថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំបានដោយរបៀបណា?**
https://www.desiringgod.org/interviews/how-do-i-glorify-god-in-my-daily-life



## សំណួរទី៩៖
# តើយើងដើរដោយព្រះវិញ្ញាណដោយរបៀបណា?

លោកគ្រូ តើសាវ័ក ប៉ុល ចង់មានន័យដូចម្ដេច នៅពេលដែលគាត់បានបង្គាប់ឲ្យគ្រីស្ទបរិស័ទ «ដើរដោយព្រះវិញ្ញាណ» ឬ «រក្សាជំហានក្នុងព្រះវិញ្ញាណ?» (រ៉ូម ៨:៤, កាឡាទី ៥:១៦,២៥)។ តើសាវ័ក ប៉ុល ចង់មានន័យដូចម្ដេចចំពោះឃ្លាទាំងនោះ?

នៅព្រឹកនេះ ជាទម្លាប់នៃការអានព្រះគម្ពីរដ៏ទៀងទាត់របស់ខ្ញុំ ខ្ញុំបានអានកណ្ឌគម្ពីរកាឡាទីជំពូក៥  ហើយគ្រប់ពេលដែលខ្ញុំអានកណ្ឌគម្ពីរកាឡាទី ៥:១៦-២៥ ខ្ញុំចាប់ផ្ដើមជាប់គាំងម្ដងទៀត ដោយការផ្ដុំនៃឃ្លានានាអំពីរបៀបដែលខ្ញុំគួរតែ «រស់នៅដោយព្រះវិញ្ញាណ» ។ នេះជាខគម្ពីរយោងនៃឃ្លាទាំងនោះ៖

- ខ១៦៖ ដើរដោយព្រះវិញ្ញាណ
- ខ១៨៖ ដឹកនាំដោយព្រះវិញ្ញាណ
- ខ២២៖ ផលផ្លែនៃព្រះវិញ្ញាណ
- ខ២៥៖ រស់នៅដោយព្រះវិញ្ញាណ នោះត្រូវរក្សាជំហាននៅក្នុងព្រះវិញ្ញាណដែរ។

### ការទទួលព្រះវិញ្ញាណបរិសុទ្ធ

ឃ្លាខុសគ្នាទាំង៥ ហើយរាល់ពេលដែលខ្ញុំអានខទាំងនោះ ខ្ញុំនិយាយថា «ឱព្រះអម្ចាស់អើយ ទូលបង្គំចង់ធ្វើការនោះណាស់។ ខ្ញុំចង់ស្គាល់វា ចង់ភ្លក់បទពិសោធន៍ពីការនោះ ដែលថា ការដើរដោយព្រះវិញ្ញាណ ការដឹកនាំដោយព្រះវិញ្ញាណ ការបង្កើតផលផ្លែដោយព្រះវិញ្ញាណ ការរស់នៅដោយព្រះវិញ្ញាណ និងការបន្តដើរដោយព្រះវិញ្ញាណ» មានន័យយ៉ាងដូច

ម្ដេច? ខ្ញុំគិតថា ចំណុចគន្លឹះគឺត្រូវត្រឡប់ទៅមើលនៅក្នុងកណ្ឌគម្ពីរកាឡាទី ជំពូក៣វិញ ពីព្រោះនៅចំណុចនោះយើងទទួលបានការណែនាំអំពីរបៀបដែលព្រះវិញ្ញាណបានយាងមកឯយើងរាល់គ្នាជាលើកដំបូង និងអំពីរបៀបដែលទ្រង់នៅតែបន្តប្រទានមក។

ដូច្នេះ នៅក្នុងកណ្ឌគម្ពីរកាឡាទី ៣:២ បានចែងថា «តើអ្នករាល់គ្នាបានទទួលព្រះវិញ្ញាណ ដោយប្រព្រឹត្តតាមក្រឹត្យវិន័យ ឬដោយបានស្ដាប់ទាំងមានសេចក្ដីជំនឿ?» ដូច្នេះ ខគម្ពីរនេះបានប្រាប់លោកអ្នកថា ព្រះវិញ្ញាណបានយាងមកឯលោកអ្នកដោយសារសេចក្ដីជំនឿជាលើកដំបូង។ លោកអ្នកបានទទួលព្រះវិញ្ញាណបរិសុទ្ធ នៅពេលលោកអ្នកទុកចិត្តលើព្រះគ្រីស្ទ។ ជំនឿនោះបានក្លាយជាប្រព័ន្ធមួយ។ ខ្ញុំគិតថា ព្រះវិញ្ញាណបានបង្កើតប្រព័ន្ធនោះ ហើយលោកអ្នកដែលបានរួបរួមជាមួយនឹងព្រះគ្រីស្ទ ថែមទាំងបានទទួលព្រះវិញ្ញាណបង្ហូរចូលមកលើខ្លួន ដោយសារការរួបរួមរបស់លោកអ្នកជាមួយនឹងព្រះគ្រីស្ទ តាមរយៈសេចក្ដីជំនឿផងដែរ។

ហើយបន្ទាប់មក គាត់បានលើកឡើងនៅខ៥ថា៖ «ដែលទ្រង់ប្រទានព្រះវិញ្ញាណមកអ្នករាល់គ្នា»—ឥឡូវនេះ យើងអាចនិយាយបានថា មិនមែនជាការទទួលតែនៅពេលអតីតកាលទេ ប៉ុន្តែជាការនៅតែបន្តទទួលបាន—«ដែលទ្រង់ប្រទានព្រះវិញ្ញាណមកអ្នករាល់គ្នា ហើយធ្វើការឫទ្ធិបារមីក្នុងពួកអ្នករាល់គ្នា»—ហើយខ្ញុំគិតថា នោះមិនមែនគ្រាន់តែជា «ទីសម្គាល់ និងការអស្ចារ្យ» នៃការអស្ចារ្យនោះទេ បើទោះបីជាត្រូវបានដកចេញក៏ដោយ។ វាក៏ជាសេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ រឿងដែលពិតជាធ្វើឲ្យយើងមានការខកចិត្តនោះ គឺយើងមិនអាចធ្វើឲ្យល្អប្រសើរជាងនេះបាន។ នោះគឺជាព្រះវិញ្ញាណដែលធ្វើការទាំងនោះវិញទេតើ—«ធ្វើដូច្នេះ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យ ឬដោយការស្ដាប់ដោយសេចក្ដីជំនឿ?»។ យើងបញ្ចប់វាដូចគ្នាទៅនឹងរបៀបដែលយើងបានចាប់ផ្ដើម។



**បទពិសោធន៍ខាងព្រលឹងវិញ្ញាណ**

ដូច្នេះ លោកអ្នកបានចាប់ផ្ដើមដោយបានទទួលព្រះវិញ្ញាណតាមរយៈសេចក្ដីជំនឿ។ លោកអ្នកនៅតែបន្តទទួលបានការប្រទានមកនៃព្រះវិញ្ញាណតាមរយៈសេចក្ដីជំនឿ។ ដូច្នេះ ប្រសិនបើមនុស្សម្នាក់សួរថា «ការទាំងនេះស្ដាប់ទៅដូចជាអសកម្មណាស់៖ បានដឹកនាំដោយព្រះវិញ្ញាណ បង្កើតផលផ្លែក្នុងព្រះវិញ្ញាណ» ការទាំងនេះគឺបែបដូច្នេះហើយ។ ខ្ញុំចង់មានន័យថា ព្រះវិញ្ញាណជាព្រះ ទ្រង់កំពុងធ្វើការលើយើង និងក្នុងយើង ប៉ុន្តែយើងត្រូវបានត្រាស់ហៅឲ្យធ្វើនោះ គឺដើម្បីស្ដាប់បង្គាប់ព្រះជាម្ចាស់។ ខ្ញុំគិតថា ការនោះមានន័យថា ត្រូវស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះ ត្រូវស្ដាប់បង្គាប់តាមសេចក្ដីសន្យារបស់ព្រះ ត្រូវស្ដាប់បង្គាប់តាមដំណឹងល្អរបស់ព្រះ ហើយជឿលើសេចក្ដីទាំងនោះចុះ។ ហើយតាមរយៈសេចក្ដីជំនឿនោះ ព្រះវិញ្ញាណបរិសុទ្ធយាងមកគង់ជាមួយយើង។

ជាក់ស្ដែង ខ្ញុំគិតថា នេះគឺជារបៀបដែលការនេះមានដំណើរការ។ យ៉ាងហោចណាស់ នេះជារបៀបដែលខ្ញុំព្យាយាមដើរដោយព្រះវិញ្ញាណ ដឹកនាំដោយព្រះវិញ្ញាណ និងបង្កើតផលផ្លែនៃព្រះវិញ្ញាណ។ ផលផ្លែមួយនៃព្រះវិញ្ញាណ—លោកអ្នកអាចធ្វើតាមផលផ្លែនៃព្រះវិញ្ញាណទាំងប្រាំបួននេះ—គឺការអត់ធ្មត់។ ដូច្នេះ ផលផ្លែនៃព្រះវិញ្ញាណគឺការអត់ធ្មត់។ នៅពេលដែលព្រះ វិញ្ញាណបរិសុទ្ធកំពុងដឹកនាំខ្ញុំ ព្រមទាំងកំពុង បង្កើតផលផ្លែនៅក្នុងជីវិតរបស់ខ្ញុំ ពេលនោះ ហើយដែលខ្ញុំកំពុងតែបោះជំហានជាមួយនឹង ព្រះវិញ្ញាណបរិសុទ្ធ គឺការនោះធ្វើឲ្យខ្ញុំមានភាពអត់ធ្មត់។

ឥឡូវនេះ តើអ្វីដែលធ្វើឲ្យលោកអ្នកមិនមានការអត់ធ្មត់? មានការខ្លះចូលមកក្នុងជីវិតរបស់លោកអ្នក ហើយឆ្លងកាត់ឆន្ទៈរបស់លោកអ្នក។ មានគម្រោងខ្លះមិនបានទៅតាមអ្វីដែលលោកអ្នកចង់បានទេ។ លោកអ្នកទទួលបានការបង្អាក់ទឹកចិត្ត។ មាននរណាម្នាក់និយាយអ្វីមួយពីលោកអ្នក។

លោកអ្នកមានបំណងចង់ទៅកន្លែងណាមួយ ប៉ុន្តែចរាចរណ៍កកស្ទះ ហើយភាពមិនសប្បាយចិត្ត ឬកំហឹងនេះ ឬការខកចិត្តនោះបានកើនឡើងនៅក្នុងចិត្តរបស់លោកអ្នក។ វាជាការបង្ហាញអំពីភាពមិនចេះអត់ធ្មត់។ ដូច្នេះ តើគួរធ្វើអ្វីនៅចំណុចនេះ? លោកអ្នកត្រូវតែមានការទុកចិត្ត លោកអ្នកត្រូវតែជឿ។ លោកអ្នកត្រូវតែស្ដាប់រឿងអ្វីមួយដោយសេចក្ដីជំនឿ។ ហើយមានសេចក្ដីសន្យាជាច្រើន ដែលទាក់ទងទៅនឹងការអត់ធ្មត់នេះ៖

«តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ» (រ៉ូម ៨:២៨)។ សូមនឹកចាំអំពីដំណើររឿងរបស់លោកយ៉ូសែប និងរបៀបដែលគាត់មានការខកចិត្តយ៉ាងខ្លាំង ហើយគាត់មិនចង់អត់ធ្មត់ចំពោះរឿងរ៉ាវទាំងដប់បីឆ្នាំនោះទេ ដែលវាហាក់បីដូចជាអាក្រក់ខ្លាំងណាស់សម្រាប់គាត់។ ហើយព្រះជាម្ចាស់កំពុងដឹកនាំគាត់ទៅកាន់តំណែងជាអ្នកគ្រប់គ្រងស្រុកអេស៊ីព្ទបន្ទាប់ពីស្ដេច ដើម្បីជួយសង្គ្រោះប្រជាជាតិមួយ (លោកុប្បត្តិ ៣៧-៥០)។ លោកអ្នកត្រូវរម្លឹកខ្លួនលោកអ្នកថា៖ ព្រះជាម្ចាស់មានពេញដោយអធិបតេយ្យភាព។ ព្រះជាម្ចាស់មានពេញដោយព្រះប្រាជ្ញា ព្រះជាម្ចាស់គឺល្អណាស់។ ព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងរាល់ទាំងចរាចរណ៍។ ព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងលើការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍។ ព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះអ្វីដែលមនុស្សនិយាយអំពីលោកអ្នក ឬនិយាយទៅកាន់លោកអ្នក។ ដូច្នេះ លោកអ្នកត្រូវទុកចិត្តលើទ្រង់។ ហើយដោយការប្រព្រឹត្តដោយសេចក្ដីជំនឿ លោកអ្នកនិយាយបានថា «ឱព្រះជាម្ចាស់អើយ ទូលបង្គំទុកចិត្តលើទ្រង់។ ទូលបង្គំជឿលើទ្រង់ហើយ។ ទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ ដើម្បីសុគតជំនួសទូលបង្គំ។ ទ្រង់បានទិញលោះសេចក្ដីសន្យានេះសម្រាប់ទូលបង្គំ ឥឡូវនេះទូលបង្គំជឿទុកចិត្តលើទ្រង់ហើយ»។

នៅកំឡុងពេលកំពុងសម្រាកដោយសេចក្ដីជំនឿនោះ ព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើការ។ នេះគឺជាកិច្ចការដែលកំពុងធ្វើនៅក្នុង និងតាមរយៈសេចក្ដីជំនឿ។ ដូច្នេះ ការសម្រាកដោយសេចក្ដីជំនឿពេលកំពុងស្ទះ គឺជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ។

**ព្រះវិញ្ញាណដែលថ្វាយសិរីល្អដល់ព្រះគ្រីស្ទ**

ខ្ញុំបានសួរខ្លួនឯងមួយសំណួរទៀតនៅព្រឹកនេះ។ ខ្ញុំបានសួរថា «ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើក្នុងរបៀបនេះ? ហេតុអ្វីបានជាទ្រង់ភ្ជាប់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងបន្តប្រទានមកនូវព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងការទុកចិត្តរបស់ខ្ញុំនៅក្នុងព្រះគ្រីស្ទ ព្រមទាំងដំណឹងល្អ និងសេចក្ដីសន្យារបស់ទ្រង់?»។

ខ្ញុំគិតថា បើយោងទៅតាមកណ្ឌគម្ពីរយ៉ូហានជំពូក១៦ ចម្លើយនោះគឺព្រះវិញ្ញាណបរិសុទ្ធបានប្រទានមក ដើម្បីតម្កើងដល់ព្រះគ្រីស្ទ។ ព្រះយេស៊ូវមានព្រះបន្ទូលថា៖ «ខ្ញុំនឹងចាត់ទ្រង់ឲ្យទៅ ហើយទ្រង់នឹងតម្កើងដល់ខ្ញុំ»។ ក្រៅតែព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុង និងតាមរយៈសេចក្ដីជំនឿរបស់យើងនៅក្នុងព្រះគ្រីស្ទ តើព្រះវិញ្ញាណបរិសុទ្ធតម្កើងដល់ព្រះគ្រីស្ទបានដោយរបៀបណា? ព្រះគ្រីស្ទបានធ្វើកិច្ចការមួយសម្រាប់យើងរាល់គ្នា។ ទ្រង់បានសុគត ហើយទ្រង់បានមានព្រះជន្មរស់ឡើងវិញ។ ទ្រង់មានព្រះបន្ទូលថា «ដ្បិតយើងនៅជាមួយនឹងឯង» ហើយទ្រង់ធ្វើការសន្យាជាមួយយើងថា៖ យើងនឹងជួយឯង យើងនឹងចម្រើនកម្លាំងដល់ឯង (អេសាយ ៤១:១០)។ ហើយការទុកចិត្តលើទ្រង់នោះ ព្រះវិញ្ញាណបរិសុទ្ធនឹងប្រទានសេចក្ដីសុខសាន្តមកយើងរាល់គ្នា ដូច្នេះ ព្រះគ្រីស្ទទទួលបានការលើកតម្កើង។ ព្រះគ្រីស្ទទទួលបានការថ្វាយសិរីល្អ ដោយសារតែយើងកំពុងតែទុកចិត្តលើសេចក្ដីសន្យារបស់ព្រះគ្រីស្ទ។

ដូច្នេះ នៅព្រឹកនេះរឿងរ៉ាវទាំងអស់មិនមែនជារឿងថ្មីទេសម្រាប់ខ្ញុំ។ ខ្ញុំ

បានសរសេរទុកនូវរាល់ព្រះគុណទាំងពេលអនាគត និងនៅកន្លែងផ្សេងទៀត ប៉ុន្តែគ្រប់ពេលដែលខ្ញុំអានមកដល់ចំណុចនេះ ហាក់បីដូចជាព្រះជាម្ចាស់បានលាងសម្អាតខ្ញុំម្តងហើយម្តងទៀតជាមួយនឹងសំណួរ៖ «តើនេះឯងកំពុងតែធ្វើអី? តើឯងបានរស់នៅដោយព្រះវិញ្ញាណហើយឬនៅ? តើឯងកំពុងតែបង្កើតផលផ្លែនៃព្រះវិញ្ញាណមែនទេ? តើឯងបានរក្សាជំហានក្នុងព្រះវិញ្ញាណដែរឬទេ?» ហើយខ្ញុំត្រូវតែឈប់បន្តិចសិនដោយពោលថា «ឱព្រះអង្គម្ចាស់អើយ! ទូលបង្គំអាចធ្វើបានប្រសើរជាមុនច្រើន។ ទូលបង្គំចង់រីករាយក្នុងការប្រកបជាមួយនឹងទ្រង់ នៅក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ»។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How Do We walk by the Spirit?
**តើយើងដើរដោយព្រះវិញ្ញាណដោយរបៀបណា?**
https://www.desiringgod.org/interviews/how-do-we-walk-by-the-spirit



## សំណួរទី១០៖
## តើសេចក្តីអំណររបស់ព្រះគ្រីស្ទប់ក្លាយជាសេចក្តីអំណររបស់ខ្ញុំបានដោយរបៀបណា?

ពិតណាស់ ព្រះទ្រង់រីករាយនៅក្នុងអង្គទ្រង់។ អាម៉ែន។ ហើយព្រះអង្គក៏សព្វព្រះហឫទ័យចង់ឲ្យយើងបានរីករាយនៅក្នុងអង្គទ្រង់ដែរ។ អាម៉ែន។ ប្រសិនបើអ្នកចាប់ផ្តើមអនុវត្តតាមអត្ថបទព្រះគម្ពីរនៅទីនេះ នោះអ្នកនឹងចាប់ផ្តើមសួរសំណួរនេះជាមិនខាន៖ តើសេចក្តីអំណររបស់ព្រះគ្រីស្ទប់ក្លាយជាសេចក្តីអំណររបស់ខ្ញុំបានដោយរបៀបណា? នោះជាសំណួររបស់យើងនៅថ្ងៃនេះ—គឺជាសំណួរយ៉ាងល្អ—មកពីអ្នកស្តាប់ម្នាក់ឈ្មោះ សុធារ៉ា មកពីទីក្រុងភ្នំពេញ។

នាងបានសរសេរថា «សួស្តីលោកគ្រូ សូមអរគុណសម្រាប់សេចក្តីអធិប្បាយមួយនេះ»។ «សំណួររបស់ខ្ញុំសម្រាប់លោកគ្រូគឺទាក់ទងជាមួយនឹងនិស្ស័យរបស់ព្រះជាម្ចាស់   និងរបៀបដែលទ្រង់ភ្ជាប់ជាមួយសេចក្តីអំណររបស់យើង។ តើលោកគ្រូអាចជួយពន្យល់ខ្ញុំចេញពីព្រះគម្ពីរអំពីអង្គព្រះវិញ្ញាណបរិសុទ្ធ និងកិច្ចការរបស់ទ្រង់ដែលជាសេចក្តីស្រឡាញ់ និងសេចក្តីអំណរដែលត្រូវបានចែករំលែកគ្នារវាងព្រះវរបិតា និងព្រះរាជបុត្រាបានទេ? ខ្ញុំមិនអាចយល់ច្បាស់បាន ដោយមិនធ្វើឲ្យអង្គទ្រង់ក្លាយទៅជាកម្លាំង ឬជាលោហៈធាតុជំរុញណាមួយ។ ហើយថា តើដោយរបៀបណាដែលអង្គព្រះវិញ្ញាណបរិសុទ្ធធ្វើឲ្យយើងមានបទពិសោធន៍នៃសេចក្តីអំណររបស់ព្រះនៅក្នុងយើង? មើលទៅវាហាក់បីដូចជាការពិតទាំងពីរនេះជាប់ទាក់ទងគ្នា គឺអង្គព្រះវិញ្ញាណបរិសុទ្ធ និងសេចក្តីអំណរនៅក្នុងយើង។ ប៉ុន្តែវាហាក់បីដូចជាមិនជាប់ទាក់ទងគ្នាសោះសម្រាប់ខ្ញុំ។ មិនទាន់នៅឡើយ។

សូមលោកគ្រូជួយពន្យល់អំពីចំណុចទាំងពីរនេះចេញពីព្រះគម្ពីរផង?»

ខ្ញុំគិតថា វាពិតជាសំខាន់ណាស់ក្នុងការដែលយើងព្យាយាមស្វែងយល់អំពីទំនាក់ទំនងរបស់យើងជាមួយព្រះវិញ្ញាណបរិសុទ្ធ គឺត្រង់ថា យើងត្រូវយល់ឲ្យបានត្រឹមត្រូវនៅក្នុងគំនិតរបស់យើងថា យើងកំពុងតែទាក់ទងជាមួយអង្គបុគ្គលមួយផ្សេងទៀត។ យើងត្រូវយល់ចំណុចនេះ ដើម្បីឲ្យអ្វីដែលមិនពិតប្រាកដលែងនៅជាមិនពិតប្រាកដទៀត៖ អង្គបុគ្គលម្នាក់ ព្រះមួយអង្គ អង្គបុគ្គលទីបីនៃព្រះត្រៃឯក។

## រួមប្រកបជាមួយព្រះវិញ្ញាណ

ការពិតទៅ ថ្មីៗនេះខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង—សូម្បីតែមុនពេលដែលខ្ញុំបានឮសំណួរនេះ—អំពីរបៀបដែល ព្រះគម្ពីរសញ្ញាថ្មីបានលើកទឹកចិត្តយើងឲ្យរីករាយ ក្នុងការប្រកបជាមួយនឹងអង្គបុគ្គលទាំងបីនៃព្រះត្រៃឯក មិនមែនគ្រាន់តែរួមប្រកបជាមួយព្រះនៅក្នុងរបៀបអរូបី ឬរបៀបទូទៅប៉ុណ្ណោះឡើយ ប៉ុន្តែការប្រកបជាមួយព្រះវរបិតា ការរួមប្រកបជាមួយព្រះរាជបុត្រា និងការរួមប្រកបជាមួយព្រះវិញ្ញាណបរិសុទ្ធ។ ឧទាហរណ៍៖ កណ្ឌគម្ពីរ ១កូរិនថូស ១:៩ បានចែងថា ព្រះទ្រង់ត្រាស់ហៅយើង «ឲ្យមានសេចក្ដីប្រកបនឹងព្រះរាជបុត្រាទ្រង់»។ នៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ១៣:១៤ សំដៅលើ «សេចក្ដីប្រួមគ្នានឹងព្រះវិញ្ញាណបរិសុទ្ធ»។ កណ្ឌគម្ពីរ ១យ៉ូហាន ១:៣ បានចែងថា «រីឯសេចក្ដីប្រកបរបស់យើងខ្ញុំ នោះគឺប្រកបនឹងព្រះវរបិតា»។ ដូច្នេះ យើងទទួលបានការបង្រៀនឲ្យមានសេចក្ដីប្រកប—ការរួមប្រកប ទំនាក់ទំនងផ្ទាល់—ជាមួយព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។

សៀវភៅដែលខ្ញុំផ្ដល់យោបល់ឲ្យអានគឺសៀវភៅរបស់លោកគ្រូ ចន អូវិន (John Owen) «ការរួមប្រកបជាមួយព្រះត្រៃឯក» (“Communion with the Triune God”)។ ខ្ញុំគិតថា គ្មាននរណាម្នាក់នៅក្នុងប្រវត្តិសាស្ត្រក្រុមជំនុំដែលបានជួយមនុស្សយើងឲ្យយល់អំពីអត្ថន័យនៃការរួមប្រកបជាមួយអង្គបុគ្គលនីមួយៗនឹងព្រះត្រៃឯកដូចជាលោក ចន អូវិន ឡើយ។ ខ្ញុំសូមផ្ដល់យោបល់ថា ទាំងអស់គ្នាគួរអានសៀវភៅ «ការរួមប្រកបជាមួយព្រះត្រៃឯក» ដែលនិពន្ធដោយលោក ចន អូវិន ចុះ។

ចំណុចនេះបញ្ជាក់ថា ព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គបុគ្គល—ជាអង្គបុគ្គលម្នាក់ដែលយើងអាចភ្ជាប់ទំនាក់ទំនងបាន អាចនិយាយជាមួយបាន—នោះគឺជារបៀបដែលព្រះយេស៊ូវបានមានបន្ទូលអំពីទ្រង់។ ទ្រង់មានបន្ទូលនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៤:២៦ ថា «ព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់»—ត្រូវហើយ «ទ្រង់» ត្រង់នេះគឺជាភេទប្រុស មិនមែនគ្មានភេទនោះទេ (ដើម្បីយល់ស្របនឹងភេទនៃ «ភ្នូមា» “pneuma” ប្រែថា «ព្រះវិញ្ញាណ»)—«ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់»។ ដូច្នេះ ព្រះវិញ្ញាណគឺពិតជាដាច់ដោយឡែកពីព្រះវរបិតា ពីព្រោះព្រះវរបិតាជាអង្គដែលចាត់ឲ្យទ្រង់មក ហើយនៅពេលទ្រង់បានយាងមកដល់ទ្រង់គឺជាគ្រូបង្រៀន មិនមែនជាកម្លាំង ឬឧស្ម័នណាមួយនោះទេ។

សាវ័ក ប៉ុល បានលើកបន្តអំពីការពិតនៃព្រះវិញ្ញាណបរិសុទ្ធថាពិតជាដាច់ដោយឡែកពីព្រះវរបិតាមែន ហើយទ្រង់ក៏ជាគ្រូបង្រៀនផ្ទាល់ខ្លួននៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ២:១០, ១៣៖ «ព្រះវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់...សេចក្ដីជ្រាលជ្រៅនៃព្រះ»។ វាពិតជាប្រយោគមួយយ៉ាងអស្ចារ្យ។ «ព្រះវិញ្ញាណស្ទង់មើល... សេចក្ដីជ្រាលជ្រៅនៃព្រះ...ហើយយើងនិយាយ [អ្វីៗអំពីព្រះ] ក្នុងពាក្យសម្ដី....ដែលព្រះវិញ្ញាណបង្រៀន»។ ដូច្នេះ សាវ័ក ប៉ុល ក៏បានបង្រៀនដូចព្រះយេស៊ូវដែរ។ សាវ័ក ប៉ុល បានលើកមក ហើយបន្តបង្រៀននូវអ្វីដែលព្រះយេស៊ូវបានបង្រៀន។ ព្រះយេស៊ូវ និងសាវ័ក

ប៉ុល បានបង្រៀនអំពីព្រះវិញ្ញាណបរិសុទ្ធថា មិនមែនគ្រាន់តែជាកម្លាំង ឬអំណាចធម្មតាឡើយ ប៉ុន្តែថាជាអង្គបុគ្គលដែលបានយាងមក ហើយបង្រៀនព្រមទាំងគង់នៅក្នុងអ្នកជឿ ហើយទ្រង់ក៏ជាអង្គបុគ្គលដែលអាចមានទំនាក់ទំនងផ្ទាល់ជាមួយយើងផងដែរ។

**ព្រះវិញ្ញាណនៃវិញ្ញាណ?**

សូមគិតពិចារណាអំពីអ្វីដែលព្រះយេស៊ូវបានមានព្រះបន្ទូលនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ៤:២៤៖ «ឯព្រះ ទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ និងសេចក្ដីពិតដែរ»។ នៅក្នុងន័យមួយទៀត យើងអាចនិយាយបានថា ព្រះទ្រង់មិនមែនជាសម្ភារៈទេ។ ព្រះអង្គមិនមានរូបរាងកាយ។ ព្រះអង្គទ្រង់ជាវិញ្ញាណ នេះមានន័យថា នៅពេលដែលយើងនិយាយថា ទ្រង់ជាម្នាក់ក្នុងចំណោមព្រះត្រៃឯកគឺជាព្រះវិញ្ញាណនៃព្រះ នោះគឺយើងកំពុងនិយាយថា ទ្រង់គឺជាព្រះវិញ្ញាណនៃវិញ្ញាណមួយ។

តើនេះមានន័យយ៉ាងដូចម្ដេច? តើនេះមានន័យដូចម្ដេចក្នុងការនិយាយថា វិញ្ញាណមានវិញ្ញាណមួយ? យើងមិនមែននិយាយថា ទ្រង់គឺជារូបភាពនៃវិញ្ញាណ ឬជារស្មីចែងចាំងនៃវិញ្ញាណ ឬជាព្រះបន្ទូល ឬជាព្រះបន្ទូលនៃព្រះវិញ្ញាណដែរ ដែលទាំងអស់នេះជាការពណ៌នាអំពីព្រះបុត្រាវិញ។ ដូច្នេះ តើយើងកំពុងតែនិយាយអំពីអ្វី នៅពេលដែលយើងសំដៅទៅកាន់ព្រះវិញ្ញាណបរិសុទ្ធនៃព្រះ ដែលអង្គទ្រង់ផ្ទាល់គឺជាម្នាក់ក្នុងចំណោមព្រះត្រៃឯក?

លោក យ៉ូណាថាន់ អែដវ៉ដ (Jonathan Edwards)—ជាអ្នកដែលបានជួយខ្ញុំយ៉ាងច្រើន—គាត់បាននិយាយថា៖ «ពាក្យថា "វិញ្ញាណ" នៅក្នុងព្រះគម្ពីរ នៅពេលដែលប្រើភ្ជាប់ទាក់ទងនឹងគំនិត...គឺជាការបញ្ចេញអាកប្បកិរិយា មានទំនោរ ឬអារម្មណ៍នៃគំនិត»។ ឧទាហរណ៍៖ កណ្ឌគម្ពីរ អេភេសូរ ៤:២៣ បានចែងថា «ហើយឲ្យគំនិតក្នុងចិត្តបានកែប្រែជាថ្មីឡើង» គឺសំដៅទៅកាន់អាកប្បកិរិយា ឬអារម្មណ៍នៃគំនិតរបស់យើង។ លោក អែដវ៉ដ បានបន្តលើកឡើងថា «ដូច្នេះ ខ្ញុំគិតថា នៅពេលដែលយើងអានអំពីព្រះវិញ្ញាណនៃព្រះ ដែលព្រះគម្ពីរបានប្រាប់យើងថា ទ្រង់ជាវិញ្ញាណ នោះយើងគួរតែត្រូវយល់ថា នេះគឺជាអាកប្បកិរិយា អារម្មណ៍ ឬជាសេចក្ដីស្រឡាញ់នៃព្រះចិន្តារបស់ព្រះជាម្ចាស់...ឥឡូវនេះ ការរួមបញ្ចូលគ្នានៃអាកប្បកិរិយា ឬអារម្មណ៍នៃព្រះគឺជាសេចក្ដីស្រឡាញ់ ដ្បិតព្រះអង្គជាសេចក្ដីស្រឡាញ់អស់កល្បជានិច្ច។ («កិច្ចការរបស់លោក យ៉ូណាថាន់ អែដវ៉ដ» “Works of Jonathan Edwards” ២១:១២២)។

នៅពេលដែលគាត់និយាយបែបនេះ យើងត្រូវតែប្រឆាំង—ដូចជាកញ្ញា សុធារ៉ា បានលើកឡើង—សេចក្ដីល្បួងក្នុងការគិតថា សេចក្ដីស្រឡាញ់គឺជាកម្លាំងជំរុញ ឬអំណាចជាជាងមនុស្ស។ លោក អែដវ៉ដ មិនបានបដិសេធបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ នៅពេលដែលគាត់បាននិយាយអំពីទ្រង់ជាអារម្មណ៍ ឬអាកប្បកិរិយា ឬជាសេចក្ដីស្រឡាញ់នៃព្រះ។ គាត់គ្រាន់តែព្យាយាមដាក់ផ្នែកផ្សេងៗនៃព្រះគម្ពីរចូលគ្នាប៉ុណ្ណោះ។

**សេចក្ដីស្រឡាញ់ដ៏អស់កល្បរបស់ព្រះ**

ព្រះគម្ពីរសញ្ញាថ្មីមិនបានបើកមក ហើយប្រាប់យើងនៅក្នុងប្រយោគជាគោលលទ្ធិថា «ព្រះវិញ្ញាណបរិសុទ្ធគឺជាបុគ្គល» ឬ «បុគ្គលនេះជាតំណាងនៃសេចក្ដីស្រឡាញ់របស់ព្រះឡើយ»។ ព្រះគម្ពីរមិនបានលើកឡើងបែបនោះទេ។ ប៉ុន្តែ ប្រយោគផ្សេងៗនៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានចង្អុលបង្ហាញនៅក្នុងទិសដៅនេះ។ តែលោកអ្នកត្រូវតែដាក់បំណែកផ្សេងៗនោះចូលគ្នា ដែលនេះមានន័យថាយើងត្រូវការមានការប្រុងប្រយ័ត្នខ្ពស់—ត្រូវប្រុងប្រយ័ត្នយ៉ាងខ្លាំង—ក្រែងយើងធ្លាក់ចេញពីផ្លូវ ហើយក្លាយជាអ្នកខុសឆ្គង។ ខ្ញុំគិត

ថា គ្រប់ទាំងការខិតខំប្រឹងប្រែងនៃភាពជាមនុស្សរបស់យើង—ឥឡូវនេះខ្ញុំចង់និយាយទូទៅអំពីលោក អែដវ៉ដ ឬក៏ខ្លួនខ្ញុំផ្ទាល់ ឬអ្នកណាផ្សេងទៀត—ដើម្បីយល់អំពីទំនាក់ទំនងនៅក្នុងព្រះត្រៃឯក យើងត្រូវតែសារភាពថាខ្លួនមើលតាមរយៈកញ្ចក់ស្រអាប់រហូតដល់ថ្ងៃដែលយើងស្គាល់ទ្រង់ដូចជាទ្រង់បានស្គាល់យើង (១កូរិនថូស ១៣:១២) នេះមានន័យថា «យើងត្រូវតែប្រុងប្រយ័ត្នឲ្យមែនទែន»។

នេះគឺជាការចង្អុលបង្ហាញមួយទៀតទៅកាន់សំណួរដែលកញ្ញា សុធារ៉ា បានមានការព្រួយបារម្ភ។ កណ្ឌគម្ពីរ ១យ៉ូហាន ៤:១២-១៣ ចង្អុលបង្ហាញអំពីព្រះវិញ្ញាណបរិសុទ្ធថាជាសេចក្តីស្រឡាញ់នៃព្រះនៅក្នុងយើង។ នេះជាអ្វីដែលអត្ថបទគម្ពីរបានចែង៖ «បើយើងស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្តីស្រឡាញ់របស់ទ្រង់បានពេញខ្នាតក្នុងយើងដែរ គឺយ៉ាងនោះឯងដែលយើងដឹងថា យើងនៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងយើង ពីព្រោះទ្រង់បានប្រទានព្រះវិញ្ញាណទ្រង់មកយើងរាល់គ្នា»។ ដូច្នេះ ប្រសិនបើយើងដាក់ទាំងអស់បញ្ចូលគ្នា—ព្រះនៅក្នុងយើង សេចក្តីស្រឡាញ់របស់ទ្រង់នៅក្នុងយើង ព្រះវិញ្ញាណទ្រង់នៅក្នុងយើង—នោះគ្រប់យ៉ាងមើលដូចជាចង្អុលបង្ហាញទៅកាន់ការពិតថា របៀបដែលសេចក្តីស្រឡាញ់របស់ព្រះនៅជាប់ក្នុងយើងគឺតាមរយៈព្រះវិញ្ញាណរបស់ព្រះអង្គ។ នោះគឺជាអាកប្បកិរិយារបស់ទ្រង់ និងអារម្មណ៍របស់ព្រះអង្គ។ នោះគឺជាសេចក្តីស្រឡាញ់របស់ព្រះអង្គក្នុងនាមជាបុគ្គល គឺបាននៅក្នុងយើងតាមរយៈបុគ្គលនៃអង្គព្រះវិញ្ញាណបរិសុទ្ធ។

## សេចក្តីអំណរដ៏អស់កល្បរបស់ព្រះ

អំណរគឺជាបំណែកដែលនៅសល់ដែលត្រូវដាក់បញ្ចូលសម្រាប់សំណួររបស់កញ្ញា សុធារ៉ា។ នេះគឺជាការដាក់បញ្ចូលបន្ទាប់ពីការសញ្ជឹងគិតថា



សេចក្តីស្រឡាញ់របស់ព្រះដែលកើតចេញពីភាពអស់កល្បជានិច្ចមិនមែនជាសេចក្តីស្រឡាញ់ដែលត្រូវលះបង់រវាងព្រះវរបិតា និងព្រះបុត្រាឡើយ។ ទាំងពីព្រះអង្គមានភាពស្រស់ស្អាតតាំងពីអស់កល្បជានិច្ចមក ស័ក្តិសមចំពោះសេចក្តីស្រឡាញ់ដល់គ្នាតាំងពីអស់កល្បជានិច្ច ដែលនេះមានន័យថា ព្រះអង្គមានការរីករាយចំពោះគ្នាអស់កល្បជានិច្ច។ នោះហើយជាសេចក្តីស្រឡាញ់របស់ព្រះអង្គ។

«នោះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញ [យ៉ាងខ្លាំង] ណាស់»—នេះជាពាក្យរៀបរាងរបស់ខ្ញុំសម្រាប់ «ជាទីពេញចិត្ត» (ម៉ាថាយ ៣:១៧)។ ការនិយាយថា សេចក្តីស្រឡាញ់នៃព្រះវរបិតា និងព្រះរាជបុត្រាសម្រាប់គ្នាទៅវិញទៅមកគឺបង្កប់នៅក្នុងព្រះវិញ្ញាណគឺជាការនិយាយថាព្រះវិញ្ញាណផ្ទាល់ជាសេចក្តីស្រឡាញ់ដ៏ពេញដោយអំណររបស់ព្រះ គឺជាសេចក្តីស្រឡាញ់ដ៏រីករាយនៅក្នុងអង្គទ្រង់ផ្ទាល់ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះតាំងពីអស់កល្បគឺជាសេចក្តីរីករាយរបស់ព្រះអង្គតាំងពីអស់កល្ប។ នោះគឺជារបៀបដែលព្រះត្រៃឯកបានមានទំនាក់ទំនងនឹងគ្នា។ ព្រះអង្គមិនមានការអាក់អន់ព្រះទ័យ ព្រះអង្គមិនចាំបាច់ជំនះនូវឧបសគ្គណាមួយ ដើម្បីមានអំណរចំពោះគ្នាឡើយ។

ដូច្នេះ នៅពេលដែលព្រះយេស៊ូវមានបន្ទូលថា «សេចក្តីអំណរដែលខ្ញុំប្រទានឲ្យអ្នករាល់គ្នា» ( យ៉ូហាន ១៥:១១) ឬនៅពេលព្រះអង្គមានបន្ទូលថា «ចូរឲ្យឯងប្រកបដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ» (ម៉ាថាយ ២៥:២១) គឺព្រះអង្គកំពុងតែស្វាគមន៍យើងចូលទៅក្នុងបទពិសោធន៍ដ៏ពេញលេញនៃសេចក្តីស្រឡាញ់របស់ព្រះរាជបុត្រាសម្រាប់ព្រះវរបិតា។ ដូច្នេះ វាជាការត្រឹមត្រូវណាស់ក្នុងការនិយាយថានេះគឺជាការមានបទពិសោធន៍នៃការពេញដោយព្រះវិញ្ញាណ ដែលទ្រង់ផ្ទាល់គឺជាអង្គបុគ្គលជាសេចក្តីស្រឡាញ់ ហើយជាសេចក្តីអំណរនៃព្រះជាម្ចាស់។ សាវ័ក ប៉ុល បានលើកឡើងនៅ

ក្នុងកណ្ឌគម្ពីរ ១ថែស្សាឡូនិច ១:៦ អំពី «សេចក្តីអំណររបស់ព្រះវិញ្ញាណបរិសុទ្ធ» ដែលជាសេចក្តីអំណរដែលព្រះវិញ្ញាណបរិសុទ្ធបានប្រទានមកតាមរយៈអង្គទ្រង់ ដោយទ្រង់បានយាងមកគង់នៅក្នុងយើងដែលនោះជាសេចក្តីស្រឡាញ់ និងសេចក្តីអំណរនៃព្រះ។

ខ្ញុំអធិស្ឋានសូមឲ្យព្រះជួយក្មួយស្រី ព្រមទាំងយើងទាំងអស់គ្នា នៅពេលដែលយើងបន្ទាបខ្លួន ហើយព្យាយាមយ៉ាងប្រុងប្រយ័ត្នក្នុងការដាក់បំណែកផ្សេងៗនៃព្រះបន្ទូលដ៏ល្អប្រពៃរបស់ព្រះបញ្ចូលគ្នា។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How Does God’s Joy Become My Joy?
**តើសេចក្តីអំណររបស់ព្រះត្រឡប់ក្លាយជាសេចក្តីអំណររបស់ខ្ញុំបានដោយរបៀបណា?**
https://www.desiringgod.org/interviews/how-does-gods-joy-become-my-joy



## សំណួរទី១១៖
# ខ្ញុំនឹងស្លាប់ទាំងវ័យក្មេង តើខ្ញុំអាចតយុទ្ធសម្រាប់សេចក្តីសង្ឃឹមបានដោយរបៀបណា?

សំណួរថ្ងៃនេះ បានមកពីប្រិយមិត្តអ្នកស្តាប់ម្នាក់ឈ្មោះ ម៉េង។ «ជម្រាបសួរលោកគ្រូ! យោងទៅតាមការធ្វើរោគវិនិច្ឆ័យខាងផ្នែកវេជ្ជសាស្ត្រនាពេលថ្មីៗនេះ ហើយដោយយោងតាមស្ថានភាពនៃជីវិតរបស់ខ្ញុំ លទ្ធភាពដែលខ្ញុំអាចនឹងរស់បានដល់វ័យពាក់កណ្តាលគឺពិតជាស្តួចស្តើងណាស់។

«ខ្ញុំមានវ័យ២០ឆ្នាំក្រាស់ហើយ ប្អូនប្រុសរបស់ខ្ញុំបានស្លាប់នៅអាយុ១៨ឆ្នាំ។ ការរំពឹងទុកជាមុននេះបានបណ្តាលឲ្យខ្ញុំឈានចូលទៅក្នុងចម្បាំងនៃការទុកចិត្តលើព្រះជាម្ចាស់ និងការតយុទ្ធជាមួយជំងឺបាក់ទឹកចិត្ត។ ខ្ញុំយល់ថា ព្រះជាម្ចាស់មានអធិបតេយ្យភាព ហើយខ្ញុំគ្មានសិទ្ធិក្នុងការសួរថា ហេតុអ្វីបានជាទ្រង់បង្កើតខ្ញុំមកបែបនេះនោះទេ។ ខ្ញុំកំពុងទន្ទឹងរង់ចាំក្នុងការបង្កើតដ៏ល្អឥតខ្ចោះនោះ ប៉ុន្តែកំឡុងពេលរង់ចាំការនោះមកដល់ តើខ្ញុំអាចរស់នៅពេញមួយជីវិតដោយអាកប្បកិរិយាពេញដោយការលើកទឹកចិត្ត ដែលនោះជាការថ្វាយសិរីល្អដល់ព្រះបានដោយរបៀបណា? តើខ្ញុំអាចទប់ស្កាត់ការរំពឹងទុកជាមុននៃការស្លាប់មុនកំណត់ និងពីការនាំខ្ញុំឲ្យណាយចិត្តចំពោះព្រះអម្ចាស់ដែលមានអធិបតេយ្យភាពបានដោយរបៀបណា?

### កន្លែងដ៏វិសុទ្ធ

ការឆ្លើយតបរបស់ខ្ញុំចំពោះសំណួរប្អូនប្រុស ម៉េង គឺជាការគោរពដ៏គួរឲ្យសរសើរ។ អ្វីដែលខ្ញុំចង់មានន័យគឺថា គ្រប់ពេលដែលខ្ញុំឈរនៅចំពោះមុខនរណាម្នាក់—ហើយក្នុងនាមជាគ្រូគង្វាលម្នាក់ ខ្ញុំកំពុងមានវត្តមាននៅ

ចំពោះមុខមនុស្សជាច្រើន—ដែលបានប្រាប់ថា ជីវិតរបស់គេនឹងត្រូវស្លាប់ឆាប់ៗ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងឈរនៅកន្លែងដ៏ពិសិដ្ឋ។ ខ្ញុំមានអារម្មណ៍ថា ដូចជាភាពអស់កល្បជានិច្ចបានឈានចូលមកនៅខណៈនោះ និងនៅកន្លែងនោះផងដែរ។

ដូច្នេះ ប្អូនប្រុស ម៉េង អើយ! សូមដឹងថា ខ្ញុំចង់ឆ្លើយតបទៅសំណួររបស់ប្អូនដោយយល់ពីទម្ងន់នៃការពិត ដែលប្អូនប្រុសបានបាត់បង់ប្អូនប្រុសម្នាក់នៅវ័យ១៨ឆ្នាំ ហើយប្អូនផ្ទាល់នឹងត្រូវបាត់បង់ជីវិតក្នុងពេលយ៉ាងខ្លីមិនអាចសូម្បីតែឈានចូលដល់វ័យកណ្តាល។ ខ្ញុំមិនគិតថា វាជារឿងតូចតាចនោះឡើយ។

## ហេតុអ្វីក៏ទៅជាបែបនេះ?

ទោះជាយ៉ាងណាក្តី រឿងដំបូងគេដែលខ្ញុំចង់ធ្វើនោះគឺ ធ្វើការឆ្លើយតបចំពោះប្រយោគរបស់ប្អូនប្រុសទៅវិញថា ប្អូនប្រុសគ្មានសិទ្ធិក្នុងការសួរព្រះជាម្ចាស់ថា ហេតុអ្វីបានទ្រង់បង្កើតប្អូនប្រុសបែបនេះទៅវិញ។ ខ្ញុំដឹងថា នោះគឺជាសម្រង់សម្តីផ្ទាល់ពីកណ្ឌគម្ពីររ៉ូម ៩:២០-២១។ ប្អូនប្រុសពិតជាម្នាក់ដែលស្គាល់ព្រះគម្ពីរមែន។ ខ្ញុំអាចប្រាប់បានថា ប្អូនប្រុសបានអានខគម្ពីរទាំងនេះរួចហើយ។ នេះជាអ្វីដែលកណ្ឌគម្ពីរ រ៉ូម ៩:២០-២១ បានចែង៖

«ប៉ុន្តែ ឱមនុស្សអើយ តើអ្នកជាអ្វី ដែលហ៊ានឆ្លើយទាស់នឹងព្រះដូច្នេះ តើរបស់ដែលជាងស្មូនបានសូនធ្វើហើយ និងនិយាយទៅជាងនោះថា ហេតុអ្វីបានជាសូនធ្វើអញដូច្នេះឬអី [នោះគឺជាសម្រង់សម្តីដែលប្អូនប្រុស ម៉េង កំពុងតែសំដៅទៅលើ]។ តើជាងស្មូនគ្មានអំណាចលើដីឥដ្ឋ និងយកដុំដីដដែលធ្វើជាវត្ថុ១សម្រាប់ការដ៏ប្រសើរ ហើយ១ទៀតសម្រាប់ការមិនប្រសើរទេឬអី»។

ដូច្នេះ ប្អូនប្រុស ម៉េង គឺកំពុងសំដៅទៅលើការឆ្លល់ថា «ជាការល្អ ខ្ញុំគួរតែបិទមាត់ប្រសើរជាង ដោយសារសាវ៉ក ប៉ុល បានបន្ទោសដល់មនុស្សណាដែលបានសួរថា “ហេតុអ្វីបានជាទ្រង់បង្កើតខ្ញុំមកបែបនេះទៅវិញ?”»

ទោះបីជាយ៉ាងណាក្តី ខ្ញុំគិតថា អ្វីដែលសាវ៉ក ប៉ុល កំពុងបដិសេធនៅត្រង់នេះ មិនមែនជាសំណើដោយបន្ទាបខ្លួននោះទេ ប៉ុន្តែសម្រាប់ជាការយល់ដឹងអមដោយការពេញចិត្តក្នុងការទទួលយកចម្លើយរបស់ព្រះជាម្ចាស់ជាជាងសំណួរមួយដែលមានការទាស់ប្រឆាំង៖ «ហេតុអ្វីបានជាទ្រង់បង្កើតខ្ញុំមកបែបនេះទៅវិញ!» ការនេះមកជាមួយគ្នានឹងការមិនពេញចិត្តដោយក្រអឺតក្រទមក្នុងការទទួលយកចម្លើយរបស់ព្រះជាម្ចាស់។

ការសន្មតរបស់ខ្ញុំគឺប៉ុន្មានឆ្នាំនេះ សម្រាប់ប្អូនប្រុស ម៉េង ព្រះជាម្ចាស់នឹងប្រទានចម្លើយមួយចំនួនដ៏មានតម្លៃចំពោះពាក្យ «ហេតុអ្វី»។ វាមិនខុសទេក្នុងការបន្ទាបខ្លួនសួរព្រះជាម្ចាស់នូវសំណួរទាំងនោះ ហើយអមនឹងសំណើជាមួយនឹងការពេញចិត្តក្នុងការយល់ស្របនឹងចម្លើយរបស់ទ្រង់ដោយថា «មែន»។

## ការស្លាប់ដោយមានកិត្តិយស

ប្អូនប្រុសបានបង្ហាញអំពីបំណង ប្រាថ្នាពីរយ៉ាងនៅក្នុងសំណួររបស់ប្អូន។

១. ប្អូនប្រុសចង់ចំណាយពេលដែលសេសសល់ រស់នៅក្នុងរបៀបមួយដែលអាចថ្វាយសិរីល្អដល់ព្រះជាម្ចាស់។

២. ប្អូនប្រុសមិនចង់មានការណាយចិត្តចំពោះព្រះជាម្ចាស់ នៅក្នុងអធិបតេយ្យភាពរបស់ទ្រង់ក្នុងជីវិតរបស់ប្អូនទេ។

វាជារឿងដ៏អស្ចារ្យមួយដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់មានបន្ទូលដោយផ្ទាល់ទៅកាន់បំណងប្រាថ្នាទាំងពីរនោះ ដែលប្អូនប្រុសបានលើកឡើង—បញ្ហាក្នុងការថ្វាយសិរីល្អដល់ព្រះអម្ចាស់ក្នុងការប្រឈមមុខនឹង

សេចក្តីស្លាប់ និងបញ្ហានៃការមិនណាយចិត្តក្នុងការប្រឈមមុខចំពោះសេចក្តីស្លាប់។

របៀបដំបូងដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីការថ្វាយសិរីល្អគឺនៅក្នុងកណ្ឌគម្ពីរភីលីព ១:២០។ ខ្ញុំប្រាកដថា ប្អូនបានដឹងអំពីរឿងនេះហើយ ប៉ុន្តែសូមឲ្យគ្រប់ការទាំងអស់គ្រាន់តែជាការរម្លឹកអំពីរបៀបដែលព្រះគ្រីស្ទមានព្រះបន្ទូលដោយក្តីបារម្ភទៅនឹងការថ្វាយសិរីល្អដល់ទ្រង់អំពីការលើកឡើងរបស់សាវ័ក ប៉ុល នៅទីនេះ៖ «តាមសេចក្តីដែលខ្ញុំទន្ទឹងចាំ ហើយសង្ឃឹមអស់ពីចិត្តថា ខ្ញុំមិនត្រូវខ្មាសក្នុងការអ្វីឡើយ គឺឲ្យតែខ្ញុំបានតម្កើងព្រះគ្រីស្ទក្នុងរូបកាយខ្ញុំវិញ ដោយចិត្តក្លាហានគ្រប់ជំពូក ក្នុងពេលឥឡូវនេះចុះ ដូចជាពីដើមរៀងមកដែរ ទោះរស់ឬស្លាប់ក្តី»។ ការទន្ទឹងរង់ចាំរបស់ប្អូនគឺជាការទន្ទឹងរង់ចាំដូចគ្នាតែមួយទៅនឹងការទន្ទឹងរង់ចាំរបស់សាវ័ក ប៉ុល ដែរ ហើយក៏នៅក្នុងស្ថានភាពតែមួយដូចគ្នាទៀតផង។

តើដូចគ្នាដោយរបៀបណា? តើគាត់អាចដេញតាមការនោះដោយរបៀបណា? គាត់បានផ្តល់ចម្លើយនៅក្នុងកណ្ឌគម្ពីរ ភីលីព ១:២១-២៣៖ «ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសម្រាប់ព្រះគ្រីស្ទទេ ហើយដែលស្លាប់ទៅនោះជាកម្រៃវិញ ប៉ុន្តែបើរស់ខាងឯសាច់ឈាម និងនាំឲ្យការខ្ញុំកើតផល នោះខ្ញុំមិនដឹងរើសយកខាងណាទេ ខ្ញុំមានសេចក្តីបណ្តាលទាំងសងខាង ក៏មានចិត្តចង់ចេញទៅនៅជាមួយនឹងព្រះគ្រីស្ទ ដែលល្អជាជាងនោះផង»។

ដូច្នេះ សាវ័ក ប៉ុល បានលើកឡើងថា នៅពេលការស្លាប់របស់គាត់ខិតចូលមកដល់ ព្រះគ្រីស្ទនឹងទទួលបានសិរីល្អ ប្រសិនបើគាត់អាចមើលឃើញ និងការភ្លក់បទពិសោធន៍ជាមួយទ្រង់ថា វិសេសជាងជីវិតទៅទៀត។ វាមិនមែនជារឿងចៃដន្យនោះទេ សម្រាប់គ្រីស្ទបរិស័ទដ៏ល្អមួយចំនួន នៅពេលពួកគាត់ខិតចូលទៅជិតចុងបំផុតនៃជីវិតរបស់ខ្លួន ពួកគាត់បានផ្លាស់ប្តូររាល់ទាំងការផ្តោតសំខាន់ៗទៅលើការមើលឃើញ និងការភ្លក់បទពិសោធន៍នៃ



ការសរសើរតម្កើងព្រះគ្រីស្ទនៅក្នុងកណ្ឌគម្ពីររបស់ទ្រង់។ តាមពិតទៅ នៅពេលដែលលោកគ្រូ ចន អូវិន បានដឹងថា គាត់កំពុងតែជិតស្លាប់ហើយ គាត់បានចំណាយពេលចុងក្រោយរបស់គាត់សរសេរអំពីសិរីល្អរបស់ព្រះគ្រីស្ទ។

## ជាព្រះពរ មិនមែនជាបណ្តាសាទេ

ចំណុចទីពីរ ទាក់ទងនឹងការទន្ទឹងរង់ចាំ ដែលប្អូនមិនបានណាយចិត្តនៅក្នុងអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ វាជារឿងគួរឲ្យកត់សម្គាល់ដែលពិតជាផ្ទុយពីការណាយចិត្តចំពោះព្រះអម្ចាស់ គឺជាការថ្វាយព្រះពរដល់ព្រះអង្គមែនទេ? ខ្ញុំគិតថា ការនោះមានភាពផ្ទុយគ្នា។ ខ្ញុំកំពុងក្លាយជាមនុស្សមានភាពនឿយណាយចិត្ត ឬល្វីងជូរចត់ចំពោះព្រះជាម្ចាស់ ឬក៏ជាម្នាក់ដែលថ្វាយព្រះពរដល់ព្រះអង្គ។ នោះហើយគឺជារបៀបដែលលោក យ៉ូប បានឆ្លើយតបចំពោះការស្លាប់របស់កូនៗទាំងដប់នាក់របស់គាត់។

ពួកគេត្រូវស្លាប់ទាំងវ័យក្មេងនៅចំពោះមុខគាត់តែម្តង។ ខ្ញុំគិតថា ស្ទើរតែគ្រប់គ្នាដែលបានស្តាប់ឮហើយនឹងនិយាយថា ពួកគាត់សុខចិត្តស្លាប់ជំនួសវិញ ជាជាងឲ្យកូនទាំងដប់នាក់របស់គាត់ស្លាប់។ ប្រាកដណាស់យើងនឹងធ្វើបែបហ្នឹង។ ដូច្នេះ នេះជាការឆ្លើយតបរបស់លោក យ៉ូប៖

«នោះយ៉ូបក៏ក្រោកឡើងហែកអាវខ្លួន ហើយកោរសក់ រួចផ្តួលខ្លួនក្រាបចុះដល់ដីថ្វាយបង្គំ ដោយពាក្យថា “ទូលបង្គំបានចេញពីផ្ទៃម្តាយមកដោយខ្លួនទទេ ហើយនឹងត្រឡប់ទៅវិញដោយទទេដែរ ព្រះយេហូវ៉ាទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ សូមឲ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរចុះ [មិនមែននឿយណាយចិត្តទេ]”» (យ៉ូប ១:២០-២១)។

ឥឡូវនេះសូមឈប់បន្តិចសិន ហើយឲ្យការនោះជ្រាបចូលក្នុងចិត្ត—យើងរាល់គ្នាចុះ។ លោក យ៉ូប បាននិយាយថា៖ «សូមឲ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរចុះ»។ គាត់មិនបាននិយាយថា៖ «សូមឲ្យព្រះនាមព្រះ

យេហូវ៉ាត្រូវបណ្ដាសានោះទេ» ឬ «ឲ្យណាយចិត្តក្នុងព្រះនាមព្រះយេហូវ៉ាឡើយ» ផ្ទុយទៅវិញគាត់បាននិយាយ៖ សូមឲ្យព្រះនាមទ្រង់ទទួលបានព្រះពរ—ទទួលបានការសរសើរតម្កើង បានពោលពាក្យល្អៗដោយការគោរពវិញ។

## កុំណាយចិត្តឡើយ

តើយើងទទួលបានបទពិសោធន៍មកពីព្រះជាម្ចាស់ថា ជាព្រះពរ—ព្រះនាមព្រះយេហូវ៉ាបានព្រះពរ បានពោលពាក្យល្អៗដោយការគោរពបានសរសើរតម្កើង—ជាជាងការណាយចិត្តចំពោះការប្រឈមមុខនឹងការបដិសេធ និងចំពោះសេចក្ដីស្លាប់ បើទោះជាយើងនឹងត្រូវស្លាប់ឆាប់ៗនេះបានដោយរបៀបណា?

សាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៤:១៦ ថា៖ «ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ»។ មានប្រយោគផ្សេងទៀតផ្ទុយពីការណាយចិត្ត។ «យើងមិនណាយចិត្តឡើយ»។ គាត់កំពុងនិយាយត្រូវនឹងស្ថានភាពរបស់ប្អូនប្រុស ម៉េង តែម្ដង។

សាវ័ក ប៉ុល បានដឹងថា ដែលលោកអ្នកអាចមានការណាយចិត្ត៖ «ខ្ញុំឆ្អែតនឹងការទាំងអស់នេះហើយ។ ខ្ញុំបរាជ័យហើយ។ ខ្ញុំមិនអាចយកចិត្តរបស់ខ្ញុំត្រឡប់មកវិញបានទៀតទេ។ ខ្ញុំជាម្នាក់មានចិត្តរឹងរូស និងនឿយណាយ»។ សាវ័ក ប៉ុល បាននិយាយថា៖ «ទេ សូមកុំគិតបែបនោះអី»។ គាត់បានលើកឡើងថា៖

«យើងមិនណាយចិត្តឡើយ ប៉ុន្តែទោះបើមនុស្សខាងក្រៅរបស់យើងខ្ញុំកំពុងតែពុករលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែប្រែជាថ្មីឡើងរាល់ថ្ងៃជានិច្ចវិញ ដ្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់



កល្បជានិច្ចវិញ ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ» (២កូរិនថូស ៤:១៦-១៨)។

## បង្កើតមកសម្រាប់ភាពអស់កល្បជានិច្ច

តាមរយៈរឿងមួយនេះដែលខ្ញុំនឹងប្រាប់អាចជួយដល់ប្អូនប្រុស ម៉េង ក្នុងការបញ្ចប់អត្ថបទនេះ។ វាប្រហែលជាជួយដល់យើងក្នុងការផ្ដោតលើចិត្តរបស់យើងវិញ។

វាជារឿងមួយអំពីលោកគ្រូ ម៉ាហ្សល ហ្សែលលីយ៍ (Marshall Shelley)។ ខ្ញុំផ្ទាល់ស្គាល់លោកគ្រូ ម៉ាហ្សល ហ្សែលលីយ៍ (Marshall Shelley) តាំងពីមុនយូរហើយ។ ខ្ញុំខាននិយាយជាមួយគាត់ច្រើនឆ្នាំដែរ។ គាត់បានបង្រៀននៅសាលាគម្ពីរ ដែនវ័រ (Denver Seminary)។ ខ្ញុំគិតថា  គាត់មានវ័យប្រហាក់ប្រហែលនឹងខ្ញុំ ឬប្រហែលជាបងខ្ញុំមួយ ឬពីរឆ្នាំ។ គាត់បានបាត់បង់កូនម្នាក់នៅឆ្នាំ ១៩៩១ ហើយគាត់បានសរសេររឿងនោះជាអត្ថបទមួយ ហើយបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី គ្រីស្ទបរិស័ទថ្ងៃនេះ (Christianity Today) កាលនោះគេបានហៅថា «ពីរនាទីមុនភាពអស់កល្បជានិច្ច» (Two Minutes to Eternity)។

នេះគឺជាអ្វីដែលគាត់បាននិយាយ៖ «[គាត់បានដាក់ឈ្មោះឲ្យកូនប្រុសរបស់គាត់ថា ថូប៊ី (Toby)] គាត់បានចូលមកកាន់ពិភពនៃពន្លឺ និងខ្យល់នៅម៉ោង ៨:២០ នាទី យប់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩១។ វេជ្ជបណ្ឌិតបាននិយាយថា ទារកនោះបានចាកចេញទៅវិញហើយ «នៅម៉ោង ៨:២២ នាទីយប់»។ ហេតុអ្វីបានជាព្រះជាម្ចាស់បានបង្កើតក្មេងម្នាក់មក ដើម្បីឲ្យរស់បានត្រឹមតែ២នាទីដូច្នេះ?

**គាត់បានលើកឡើងថា៖**

«ទ្រង់មិនបានធ្វើដូច្នេះទេ។ ទ្រង់មិនបានបង្កើត ថូប៊ី មក ដើម្បីឲ្យរស់បានត្រឹមតែពីរនាទី ឬ ម៉ែនឌី (Mandy) ដើម្បីឲ្យរស់បានត្រឹមតែពីរឆ្នាំនោះទេ។ ទ្រង់មិនបានបង្កើតខ្ញុំមក ដើម្បីឲ្យរស់បានត្រឹមតែ៤០ឆ្នាំទេ ឬថាតើចំនួនប៉ុន្មានឆ្នាំដែលទ្រង់នឹងជ្រើស ដើម្បីពន្យារថ្ងៃនៃអាយុរបស់ខ្ញុំនៅលើពិភពលោកនេះទេ។ ព្រះជាម្ចាស់បានបង្កើត ថូប៊ី មកសម្រាប់ភាពអស់កល្បជានិច្ច។ ទ្រង់បានបង្កើតយើងម្នាក់ៗមកសម្រាប់ភាពអស់កល្បជានិច្ច ជាកន្លែងដែលយើងរាល់គ្នានឹងមានការភ្ញាក់ផ្អើលចំពោះការរកឃើញការត្រាស់ហៅដ៏ពិតប្រាកដរបស់យើងរាល់គ្នា ដែលតែងតែហាក់បីដូចផែនដីនេះមិនអាចឈោងដល់»។

**ជីវិតដ៏ពិតប្រាកដ**

សូមស្តាប់ពីរបៀបដែលសាវ័ក ប៉ុល ពណ៌នាអំពីជីវិតនាកល្បខាងមុខ៖ «យ៉ាងនោះឯង ទើបឈ្មោះថា គេនឹងប្រមូលទ្រព្យសម្បត្តិទុកជាគោលយ៉ាងល្អសម្រាប់ខ្លួនដល់ថ្ងៃក្រោយវិញ ដើម្បីឲ្យគេចាប់បានជីវិតអស់កល្បជានិច្ច» (១ធីម៉ូថេ ៦:១៩)។ ម្យ៉ាងទៀត ជីវិតដ៏អស់កល្បខាងមុខ មិនមែនជាសេចក្តីបញ្ចប់នៃជីវិតដ៏ពិតប្រាកដនោះទេ ផ្ទុយទៅវិញជីវិតនេះ គឺជាសេចក្តីផ្តើមនៃជីវិតដ៏ពិតប្រាកដវិញទេតើ។

នោះគឺជាអ្វីដែលគាត់កំពុងនិយាយនៅក្នុងឃ្លាជីវិតដ៏ពិតប្រាកដ។ សាវ័ក ប៉ុល បានពិពណ៌នាថា «ដើម្បីឲ្យទ្រង់បានសម្តែង ឲ្យអស់ទាំងកល្បខាងមុខ បានឃើញព្រះគុណដ៏ធ្ងន់លើសលប់របស់ទ្រង់ ដោយសេចក្តីសប្បុរស ដែលទ្រង់ផ្តល់មកយើង ក្នុងព្រះគ្រីស្ទយេស៊ូវ» (អេភេសូរ ២:៧)។ វានឹងរាប់ពីអស់កល្បខាងមុខទៅដល់អស់កល្បខាងមុខមួយទៀត ដើម្បីឲ្យព្រះជាម្ចាស់សម្តែងរាល់សេចក្តីសប្បុរសមកយើងរាល់គ្នា ដោយសារតែ



វាធ្ងន់លើសលប់»។

នេះជាទស្សនៈរបស់គ្រីស្ទបរិស័ទទាំងឡាយ។ នោះគឺជាអ្វីដែលយើងរាល់គ្នាត្រូវមាន—សម្រាប់ខ្ញុំ ប្អូនប្រុស ម៉េង និងយើងរាល់គ្នា។ រឿងរបស់ថូប៊ី និងជីវិតរបស់សាវ័ក ប៉ុល បានជួយខ្ញុំច្រើនណាស់។ ខ្ញុំសូមអធិដ្ឋានឲ្យប្អូនប្រុស ម៉េង ដើម្បីឲ្យប្អូនមានអារម្មណ៍ល្អប្រសើរឡើងវិញចំពោះសេចក្តីសប្បុរសដែលធ្ងន់លើសលប់ ដែលនឹងត្រូវចាក់បង្ហូរមកលើជីវិតដ៏អស់កល្បជានិច្ចរបស់ប្អូន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
I Will Die Young—How Can I Fight for Hope?
**ខ្ញុំនឹងស្លាប់ទាំងវ័យក្មេង តើខ្ញុំអាចតយុទ្ធសម្រាប់សេចក្តីសង្ឃឹមបានដោយរបៀបណា?**
https://www.desiringgod.org/interviews/i-will-die-young-how-do-i-fight-for-hope

## សំណួរទី១២៖
# តើមានមហាបេសកកម្មសម្រាប់គ្រីស្ទបរិស័ទ គ្រប់ៗរូបមែនឬ?

ព្រះយេស៊ូវបានប្រទានមហាបេសកកម្មមកកាន់យើង។ ក្នុងមហាបេសកកម្មនេះ ព្រះអង្គបានបង្គាប់ឲ្យយើងឈោងចាប់មនុស្សគ្រប់រូបនៅលើផែនដីនេះជាមួយនឹងដំណឹងល្អ។ ប៉ុន្តែ តើព្រះយេស៊ូវកំពុងតែមានព្រះបន្ទូលទៅកាន់អ្នកណា? តើបង្គាប់នោះសម្រាប់តែពួកសាវ័កដំបូងមែនឬ? ទៅកាន់ក្រុមជំនុំទាំងមូល? ទៅកាន់ក្រុមជំនុំតាមតំបន់ណាមួយមែនឬ? ទៅកាន់អស់អ្នកដែលកំពុងតែបម្រើនូវជួរមុខ ដែលជាអ្នកគិតអំពីបេសកកម្ម? ឬក៏ទៅកាន់គ្រីស្ទបរិស័ទគ្រប់ៗរូប?

ប្អូនប្រុសម្នាក់បានសួរដូចតទៅ៖ «ជម្រាបសួរលោកគ្រូ។ ថ្មីៗនេះមិត្តភក្តិរបស់ខ្ញុំម្នាក់បានលើកឡើងថា យើងគួរកាត់ស្រាយបញ្ហានៃមហាបេសកកម្មក្នុងការបង្កើតសិស្សថាសំដៅទៅកាន់ក្រុមជំនុំទាំងមូល មិនមែនជាបញ្ហាទៅកាន់គ្រីស្ទបរិស័ទរៀងៗខ្លួននោះទេ។ តើលោកគ្រូគិតថា វាជាការល្អទេដែលយើងកាត់ស្រាយបញ្ហានៃការឈោងចាប់មនុស្សជាតិថាសម្រាប់ពួកសាវ័ក អ្នកដឹកនាំក្រុមជំនុំ និងសូម្បីតែសម្រាប់ក្រុមជំនុំតាមតំបន់ទាំងមូល? ឬក៏ថា នេះគឺជាបញ្ហាបែបបុគ្គលពីព្រះយេស៊ូវ ដែលទ្រង់បានប្រទានទៅកាន់អ្នកជឿរៀងៗខ្លួនវិញ?»។

**តើអ្នកណាជាក្រុមជំនុំ?**

ចូរយើងចាប់ផ្តើមដោយវែកញែកសំណួរផ្ទាល់សិន។ ទី១ «តើយើងគួរកាត់ស្រាយបញ្ហានៃមហាបេសកកម្មថាសំដៅទៅលើក្រុមជំនុំទាំងអស់

ហើយថាមិនមែនជាបញ្ញត្តិសំដៅទៅលើអ្នកជឿរៀងៗខ្លួនមែនឬ?» ដូច្នេះ តើនេះមានន័យថាយ៉ាងដូចម្ដេច ប្រសិនបើយើងកាត់ស្រាយថា បញ្ញត្តិនៃមហាបេសកកម្មគឺសម្រាប់ "ក្រុមជំនុំទាំងអស់"? តើការធ្វើបែបនោះនឹងមិនបន្សល់នូវសំណួរដូចគ្នាដែលថា សម្រាប់អ្នកជឿរៀងៗខ្លួន ហាក់បីដូចជាថាបញ្ញត្តិនោះគឺ សំដៅផ្ទាល់ទៅលើគាត់?

ប្រសិនបើលោកអ្នកគិតថា ព្រះអង្គបានប្រទានបញ្ញត្តិនេះទៅកាន់ក្រុមជំនុំទាំងអស់ ហើយលោកអ្នកមិនបានគិតថា ក្រុមជំនុំទាំងអស់នឹងមិនទៅឈោងចាប់មនុស្សជាតិទាំងអស់ ប៉ុន្តែគ្រាន់តែសំដៅទៅលើបុគ្គលនីមួយៗនៅក្នុងក្រុមជំនុំទាំងអស់វិញ នោះលោកអ្នកត្រូវតែសម្រេចថា តើបុគ្គលមួយណានឹងចេញទៅធ្វើនូវអ្វីដែលក្រុមជំនុំទាំងមូលធ្វើ។ បើដូច្នោះមែន នោះបញ្ញត្តិនេះគឺសម្រាប់បុគ្គលនីមួយៗដូចគ្នា ហាក់បីដូចជាថា បញ្ញត្តិនោះគឺសំដៅទៅលើគាត់ផ្ទាល់តែម្ដង៖ តើចំណុចនេះមានន័យថាខ្ញុំផ្ទាល់ត្រូវទៅមែនឬ ឬក៏មានន័យថា ខ្ញុំផ្គត់ផ្គង់បេសកកម្មតាមរយៈអស់អ្នកដែលចេញទៅផ្ទាល់វិញ?

ដូច្នេះ ខ្ញុំគិតថាការធ្វើបែបនោះមិនដោះស្រាយចំណុចអនុវត្តផ្ទាល់ទាល់តែសោះ ក្នុងការលើកឡើងថា បញ្ញត្តិនេះគឺសំដៅទៅលើក្រុមជំនុំទាំងអស់។ នេះគឺជាការវែកញែកដំបូងរបស់ខ្ញុំលើសំណួរនេះ។ ខាងក្រោមនេះគឺជាការវែកញែកទី២។

## មិនមែនថាគ្រប់គ្នាចេញទៅនោះទេ

នៅត្រង់នេះ យើងក៏ត្រូវវែកញែកឲ្យបានច្បាស់លាស់សិនដែរ៖ «តើនេះជាបញ្ជាបែបបុគ្គលពីព្រះយេស៊ូវ ដែលទ្រង់បានប្រទានទៅកាន់អ្នកជឿរៀងៗខ្លួនមែនឬ?»។ ប្រសិនបើយើងឆ្លើយថា «បាទ/ចាស» នោះយើងក៏ត្រូវតែបន្តវែកញែកឲ្យបានច្បាស់លាស់ដោយសួរថា៖ «តើលោកអ្នកមានន័យថា ព្រះ



យេស៊ូវបានបញ្ជាអ្នកជឿគ្រប់ៗរូបឲ្យធ្វើជាបេសកជនទៅមនុស្សជាតិជាមួយនឹងដំណឹងល្អ និងផ្ដោតលើការឆ្លងវប្បធម៌ និងឈោងចាប់មនុស្សជាតិទាំងអស់ ដែលតាមពិតទៅនោះគឺជាការផ្ដោតលើបញ្ញត្តិនៃមហាបេសកកម្ម (មិនដែលគ្រាន់តែសម្រាប់ការផ្សាយដំណឹងល្អតាមតំបន់នោះទេ)?»។

ចម្លើយលើសំណួរហ្នឹងគឺច្បាស់ណាស់៖ ទេ! ព្រះអង្គមិនបានរំពឹងទុកដូចនោះ ហើយក៏មិនបានបញ្ជាដូចនោះដែរ។ កណ្ឌគម្ពីរ រ៉ូម ១៥ គឺជាភស្ដុតាងមួយ ដែលត្រង់នេះសាវ័ក ប៉ុល កំពុងតែបបួលអស់អ្នកដែលនៅទីក្រុងរ៉ូមថាមិនឲ្យទៅស្រុកអេស្ប៉ាញជាមួយគាត់ ប៉ុន្តែឲ្យផ្គត់ផ្គង់ដល់គាត់ខណៈពេលដែលគាត់ចេញទៅស្រុកអេស្ប៉ាញវិញ។

គាត់ដឹងថា អ្នកទាំងអស់នោះដែលគាត់កំពុងតែសរសេរសំបុត្រផ្ញើទៅទីក្រុងរ៉ូម—គ្រីស្ទបរិស័ទទាំងនោះដែលទទួលបានដំណឹងល្អ—មានការងារ។ ពួកគាត់មានទំនាក់ទំនងជាមួយនឹងអ្នកដទៃទៀត។ ដូច្នេះ គាត់មិនមែនហៅពួកគាត់ «ឱអស់អ្នកដែលជាអ្នកជឿពិតអើយ គ្រប់គ្នាសូមឡើងទូកហើយចេញទៅស្រុកអេស្ប៉ាញជាមួយខ្ញុំ» នោះទេ។ គាត់កំពុងតែលើកឡើងថា «សូមផ្គត់ផ្គង់មកកាន់ខ្ញុំ ខណៈពេលដែលខ្ញុំចេញទៅ»។

ដូច្នេះ ព្រះគម្ពីរសញ្ញាថ្មីបានលើកឡើងយ៉ាងច្បាស់លាស់ថា ព្រះជាម្ចាស់មិនបានរំពឹងឲ្យបុគ្គលគ្រប់ៗរូបដែលបានឮអំពីមហាបេសកកម្មចេញទៅ ឆ្លងវប្បធម៌ ហើយធ្វើជាបេសកជននោះទេ។ ខ្ញុំគិតថាកណ្ឌគម្ពីរ ១ពេត្រុស ២:៩ បានណែនាំឲ្យអ្នកជឿគ្រប់ៗគ្នាប្រកាសអំពីភាពឧត្ដុង្គឧត្ដមរបស់ព្រះគ្រីស្ទ ក្នុងបណ្ដាញទំនាក់ទំនងរបស់ខ្លួន៖ «តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានសម្ដែងចេញ ឲ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្ដីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់»។

ប៉ុន្តែ ព្រះគម្ពីរសញ្ញាថ្មីក៏មិនបានថាឲ្យគ្រប់អ្នកជឿគួរឆ្លងវប្បធម៌ ហើយធ្វើជាបេសកជននោះទេ ដោយព្យាយាមឈោងចាប់អស់អ្នកដែលមិនទាន់បានជឿក្នុងនាមជាបេសកជននៅជួរមុខឡើយ។

## ដរាបដល់បំផុតកល្ប

ដូច្នេះ ចូរយើងត្រឡប់ទៅមើលមហាបេសកកម្មបន្ទិចក្នុងកណ្ឌគម្ពីរម៉ាថាយជំពូក២៨។ ប្រយោគដែលថា «ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍» (ខ១៩) គឺព្រះយេស៊ូវកំពុងតែសំដៅទៅលើពួកសាវ័កទាំង១១នាក់។ យើងឃើញអំពីការនេះនៅក្នុងខ១៦។ យើងឃើញថាពួកសាវ័កទាំង១១នាក់បានមកជួបជុំគ្នា។

តម្រុយដែលព្រះយេស៊ូវមានសម្រាប់បញ្ញត្តិនេះគឺមិនមែនគ្រាន់តែសម្រាប់ពួកសាវ័កទាំង១១នាក់ទេ ប៉ុន្តែក៏សំដៅទៅលើក្រុមមនុស្សដែលនឹងរស់នៅយូរជាងពួកសាវ័កទាំង១១នាក់វិញ យើងឃើញតម្រុយនេះនៅក្នុងខ២០។ ដីកា ជំហរ និងការគាំទ្របញ្ញត្តិនេះ គឺសេចក្តីសន្យាដែលថា «ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ»។ ហើយព្រះអង្គបានប្រាប់ថាដីកានេះនឹងនៅយូរប៉ុណ្ណា៖ «ដរាបដល់បំផុតកល្ប»។

កិច្ចការនេះនឹងនៅបន្តមានយូរតាមដែលព្រះជាម្ចាស់សន្យាថានឹងជួយខណៈពេលដែលកិច្ចការនោះនៅមាន៖ «ខ្ញុំនឹងនៅជួយអ្នករាល់គ្នាជារាល់ថ្ងៃក្នុងកិច្ចការនេះ ដរាបដល់បំផុតកល្ប»។

ដូច្នេះ សំណួរសួរថា—ហើយគ្រប់ជំនាន់នៃអ្នកជឿក៏ត្រូវតែសួរសំណួរនេះដដែលៗដែរ—តើអ្នកណានឹងបន្តព័ន្ធកិច្ចនៅក្នុងសតវត្សរ៍បន្ទាប់? វាមិនគ្រប់គ្រាន់ទេក្នុងការលើកឡើងថា ទំនងបុគ្គលគ្រប់ៗរូប ឬក៏ក្រុមជំនុំទាំងមូលត្រូវបន្តព័ន្ធកិច្ចនេះ។ ចម្លើយនោះមិនគ្រប់គ្រាន់ទេ ពីព្រោះវាមិនបានឆ្លើយថាអ្នកណានឹងបន្តចេញទៅធ្វើឡើយ។



## អ្នកណានឹងចេញទៅធ្វើ?

អ្នកណានឹងងើបឡើងចេញទៅ ហើយហ៊ានប្តូរផ្តាច់ជីវិត ក្នុងការឈោងចាប់អស់អ្នកដែលមិនទាន់បានជឿនៅលើផែនដីនេះ? នេះគឺជាចំណុចសំខាន់។ បុគ្គលនីមួយៗមិនធ្វើការនោះ ហើយក្រុមជំនុំទាំងមូលក៏មិនធ្វើការនោះដែរ។ គឺបុគ្គលជាក់លាក់ណាម្នាក់ទេ ដែលធ្វើការនោះ។

យើងសង្ឃឹមថាបុគ្គលជាក់លាក់នោះនឹងទទួលការផ្គត់ផ្គង់ពីបុគ្គលនីមួយៗ និងពីក្រុមជំនុំទាំងមូល។ គឺបុគ្គលនីមួយៗដែលនាំដំណឹងល្អឆ្លងវប្បធម៌ទៅកាន់អ្នកដទៃ។ តើពួកគាត់មកពីណា? តើពួកគាត់ជានរណា? តើពួកគាត់ឈានទៅដល់ចំណុចនោះដោយរបៀបណា? តើពួកគាត់ទទួលបានអំណាច អំណោយទាន ចំណេះដឹង និងការទ្រទ្រង់ខ្លួនដោយរបៀបណា?

នេះគឺជាចំណុចដែលខ្ញុំឃើញនៅក្នុងព្រះគម្ពីរដែលចង្អុលបង្ហាញទៅកាន់ចម្លើយ។ ព្រះយេស៊ូវបានមានបន្ទូលនៅក្នុង កណ្ឌគម្ពីរ យ៉ូហាន ១០:១៥-១៦ ថា៖ «ខ្ញុំស៊ូប្តូរជីវិតខ្ញុំនឹងចៀម ខ្ញុំក៏មានចៀមឯទៀត ដែលមិនទាន់នៅក្នុងក្រោលនេះនៅឡើយ ត្រូវតែខ្ញុំនាំចៀមទាំងនោះមកដែរ វានឹងស្តាប់តាមសំឡេងខ្ញុំ នោះនឹងមានហ្វូងតែ១ និងអ្នកគង្វាលតែ១វិញ»។ បើនិយាយម្យ៉ាងទៀតទៅ ព្រះយេស៊ូវបានខ្ចាយព្រះលោហិតរបស់ទ្រង់—«ខ្ញុំស៊ូប្តូរជីវិតខ្ញុំនឹងចៀម»—ដើម្បីប្រមូលចៀមឯទៀតរបស់ទ្រង់ ដែលមិនមែនជាសាសន៍យូដា ឲ្យចូលក្នុងក្រោលដែរ។

យោងតាមកណ្ឌគម្ពីរ យ៉ូហាន ១១:៥២ ចៀមបានខ្ចាត់ខ្ចាយពាសពេញផែនដី ហើយព្រះអង្គត្រូវប្រមូលឲ្យពួកគាត់មកវិញ។ ព្រះអង្គបានប្តូរជីវិតទ្រង់ ដើម្បីប្រមូលពួកគាត់។ បន្ទាប់មក ព្រះអង្គបានមានបន្ទូលថា «វានឹងស្តាប់តាមសំឡេងខ្ញុំ»។ តើពួកគាត់នឹងស្តាប់សំឡេងទ្រង់ដោយរបៀបណា? ពួកគាត់នឹងឮសំឡេងទ្រង់ តាមរយៈសំឡេងមនុស្ស ដែល

នឹងប្រកាសសេចក្ដីពិតអំពីព្រះយេស៊ូវឲ្យពួកគាត់ដឹង។

ព្រះយេស៊ូវបានអធិស្ឋាននៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៧:២០៖ «ទូលបង្គំមិនអធិស្ឋាន ឲ្យអ្នកទាំងនេះតែប៉ុណ្ណោះ គឺឲ្យដល់ទាំងអ្នកណា ដែលនឹងជឿដល់ទូលបង្គំ ដោយសារពាក្យរបស់គេថែមទៀតដែរ»។ យើងឃើញថា នៅទីណាដែលគេបានបន្ទរពាក្យពេចន៍របស់ពួកសាវ័ក តាមរយៈបបូរមាត់របស់ទូតព្រះយេស៊ូវ នោះមនុស្សម្នាក៏បានបើកចិត្តជឿដែរ។

ដូច្នេះ តើយើងអាចឈោងចាប់ជាតិសាសន៍ និងមនុស្សជាតិបានដោយរបៀបណា? គឺតាមរយៈអ្នកជឿដែលបើកមាត់ខ្លួន ដោយប្រកាសអំពីដំណឹងល្អដែលពួកសាវ័កផ្ញើទុកនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ទាក់ទងទៅនឹងដំណឹងល្អរបស់ព្រះយេស៊ូវ។ ហើយតើអ្នកណាជាទូត ដែលឆ្លងកាត់វប្បធម៌នោះ? តើពួកគាត់ជាអ្នកណា? គឺបុគ្គលនីមួយៗ។

## ការត្រាស់ហៅដ៏អាថ៌កំបាំង

នៅពេលនោះ ខ្ញុំបានបម្រើជាគ្រូគង្វាលអស់រយៈពេល៣៣ឆ្នាំ—ដោយមានបន្ទុកនេះ និងលើកឡើងនូវសំណួរនេះជាច្រើនដង ហើយរស់នៅដោយគិតអំពីអស់អ្នកដែលមិនទាន់ជឿពាសពេញផែនដី—អស់រយៈពេល៣៣ឆ្នាំនោះ គឺវាពិតជាអស្ចារ្យ ពេញដោយសិរីល្អ និងភាពស្អាតស្អំក្នុងកាលឃើញព្រះជាម្ចាស់តែងតាំងមនុស្សមួយចំនួនក្នុងចំណោមកូនៗរបស់ទ្រង់ ដែលមានការត្រាស់ហៅដ៏អស្ចារ្យផ្ទាល់ ឥតឈប់ឈរ មិនអាចបដិសេធបាន ទទួលការណែនាំពីព្រះគម្ពីរ ពេញវ័យខាងឯវិញ្ញាណ មានមូលដ្ឋានលើក្រុមជំនុំ ក្នុងការចេញទៅធ្វើព័ន្ធកិច្ចនៅជួរមុខ ឆ្លងវប្បធម៌សម្រាប់ប្រយោជន៍ព្រះគ្រីស្ទ។

ដូច្នេះ ចម្លើយសង្ខេបរបស់ខ្ញុំគឺថា៖ អ្នកដែលស្រឡាញ់ព្រះយេស៊ូវត្រូវតែស្រឡាញ់ ផ្គត់ផ្គង់ និងគាំទ្រមហាបេសកកម្ម ដូចដែលព្រះយេស៊ូវបានស្រឡាញ់ដែរ។ យើងមិនស្រឡាញ់ការនេះមិនបានទេ។

ក្នុងចំណោមអ្នកទាំងនេះ គឺក្នុងក្រុមជំនុំដែលប្រកាសដំណឹងល្អ ហើយបានលើកស្ទួយបន្ទុកបេសកកម្មឡើង នោះព្រះជាម្ចាស់នឹងត្រាស់ហៅទូតជួរមុខរបស់ទ្រង់ក្នុងរបៀបដែលពេញទៅដោយអាថ៌កំបាំង ការអស្ចារ្យ និងធ្វើឲ្យភ្ញាក់ផ្អើលជាមិនខាន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is the Great Commission for Every Individual Christian?
**តើមានមហាបេសកកម្មសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូបមែនឬ?**
https://www.desiringgod.org/interviews/is-the-great-commission-for-every-individual-christian

## សំណួរទី១៣៖
# កត្តាជំរុញចិត្តបីយ៉ាងដើម្បីអធិស្ឋាន

ហេតុអ្វីបានជាយើងចំណាយពេលវេលា និងកម្លាំងយើងក្នុងការអធិស្ឋាន? នេះគឺជាសំណួរដែលលោកគ្រូ ចន ផាបភ័រ បានលើកឡើងនៅក្នុងសេចក្តីអធិប្បាយរបស់គាត់នៅខែធ្នូ ឆ្នាំ២០០៧ ថា៖ «ចូរអធិស្ឋានបែបយ៉ាងនេះវិញថា៖ សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ»។ នេះគឺជាអ្វីដែលលោកគ្រូ ចន ផាបភ័រ បានលើកឡើង៖

**១. ព្រះជាម្ចាស់បង្គាប់យើងឲ្យអធិស្ឋាន**

ទី១ យើងគួរតែអធិស្ឋានដោយសារព្រះជាម្ចាស់បានបង្គាប់យើងជាច្រើនលើកច្រើនសារម្តងហើយម្តងទៀតឲ្យធ្វើបែបនោះ។ តើព្រះជាម្ចាស់មិនបានបង្គាប់យើងឲ្យអធិស្ឋានទេឬអី? នេះគឺជាឧទាហរណ៍មួយចំនួន៖

- យ៉ាកុប ៥:១៦ “ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យបានជាចុះ”។ តើមានអ្នកជំងឺប៉ុន្មាននាក់នៅក្នុងក្រុមជំនុំដោយសារយើងមិនបានអធិស្ឋានឲ្យគ្នាទៅវិញទៅមក ដែលព្រះជាម្ចាស់នឹងសព្វព្រះទ័យក្នុងការព្យាបាល?
- ១ថែស្សាឡូនីច ៥:១៧ “ចូរអធិស្ឋានឥតឈប់ឈរ”។
- កណ្ឌគម្ពីរ លូកា ២២:៤០ បានចែងថា “ចូរអធិស្ឋានទៅ ដើម្បីកុំឲ្យត្រូវសេចក្តីល្បួងឡើយ”។
- លូកា ១៨:១ បានចែងថា “នោះព្រះអម្ចាស់ទ្រង់មានបន្ទូលជាពាក្យប្រៀបប្រដូចទៅគេ ដើម្បីនឹងបង្ហាញថា ត្រូវតែអធិស្ឋានជានិច្ច ឥតរសាយចិត្តឡើយ”។
- លូកា ៦:២៨ “ចូរឲ្យពរដល់អ្នកណាដែលប្រទេចផ្តាសាអ្នក ហើយ

អធិស្ឋានឲ្យអ្នកណាដែលធ្វើទុក្ខអ្នក»។ តើលោកអ្នកនៅក្នុងស្ថានភាពអាក្រក់ ទទួលការកេងប្រវ័ញ្ចពីអ្នកដទៃ ត្រូវគេកុហកឬ? ចូរអធិស្ឋាន អធិស្ឋាន ហើយអធិស្ឋានទៀតសម្រាប់ពួកគេចុះ។

- កណ្ឌគម្ពីរ ម៉ាថាយ ៦:៩ បានចែងថា “ចូរអធិស្ឋានបែបយ៉ាងនេះវិញថា ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ”។

នោះគឺជាចំណុចទី១។ យើងអធិស្ឋានដោយសារជាច្រើនលើកច្រើនសារនៅក្នុងព្រះគម្ពីរ ព្រះអង្គបានបង្គាប់យើងឲ្យអធិស្ឋាន។ ហើយព្រះជាម្ចាស់ស្រឡាញ់យើង។ ព្រះអង្គមិនបានបង្គាប់យើងឲ្យធ្វើអ្វីមួយដែលជាការមិនល្អដល់យើងនោះទេ។ វាជាការល្អណាស់សម្រាប់យើង។

## ២. សេចក្តីអធិស្ឋានបង្កើនសេចក្តីអំណររបស់យើង

យើងអធិស្ឋាន ពីព្រោះវាជាមធ្យោបាយមួយក្នុងការបង្កើនសេចក្តីអំណររបស់យើង។ ឥឡូវនេះ លោកអ្នកទំនងជាគិតថា «ជាការពិតណាស់ យើងគិតថា លោកគ្រូនឹងនិយាយបែបនោះ»។ ប៉ុន្តែ លោកអ្នករំពឹងឲ្យខ្ញុំនិយាយដូចនោះដោយសារខ្ញុំជាគ្រីស្ទបរិស័ទដែលឲ្យតម្លៃលើការសង្វាតដេញតាមអំណរ។ ប៉ុន្តែ ការពិតគឺថា ខ្ញុំគឺជាគ្រីស្ទបរិស័ទដែលឲ្យតម្លៃលើការសង្វាតដេញតាមអំណរដោយសារបទគម្ពីរដូចនេះបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំងកាលពី៣៥ឆ្នាំមុន។ ព្រះយេស៊ូវបានមានបន្ទូលថា «តាំងពីដើមមក អ្នករាល់គ្នាមិនបានសូមអ្វី ដោយនូវឈ្មោះខ្ញុំទេ ឥឡូវ ចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បីឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញពិត» (យ៉ូហាន ១៦:២៤)។

ចូរទូលសូម! ចូរទូលសូមចុះ! ពីព្រោះការចូលមកឯយើងក្នុងនាមជាមនុស្សមានតម្រូវការ និងពឹងផ្អែកលើយើងសម្រាប់គ្រប់ការទាំងអស់ដែលអ្នកត្រូវការ នោះអំណររបស់អ្នកនឹងបានពោរពេញជាងការដែលអ្នកព្យាយាម



រកតម្រូវការមួយនោះតាមរបៀបផ្សេងទៀតផង។ ព្រះអង្គសព្វព្រះទ័យឲ្យលោកអ្នកមានការរីករាយក្នុងទ្រង់ ហើយព្រះអង្គមានបន្ទូលថា «ចូរសូមចុះ ដើម្បីឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញពិត»។

## ៣. ការអធិស្ឋានគឺជាអភ័យឯកសិទ្ធិ

ការអធិស្ឋានគឺជាអភ័យឯកសិទ្ធិដ៏សាមញ្ញ និងអស្ចារ្យមួយ។ វាគឺជាអភ័យឯកសិទ្ធិដ៏អស្ចារ្យណាស់។ ឥឡូវនេះ លោកអ្នកត្រូវតែគិតអំពីការនេះ។ យើងត្រូវតែមានការភ្ញាក់ផ្អើលដោយសារការនេះ។ ព្រះជាម្ចាស់គ្រប់គ្រងពិភពលោកនេះដោយព្រះប្រាជ្ញាញាណដ៏គ្មានដែនកំណត់។ ខ្ញុំ និងលោកអ្នកមិនដែលទូលសូមអ្វីដល់ព្រះអង្គដោយទ្រង់មិនបានជ្រាបជាមុននោះទេ។ យើងមិនអាចនឹងបន្ថែមប្រាជ្ញាទៅដល់ព្រះអង្គបានឡើយ។ នៅពេលយើងអធិស្ឋាន យើងមិនបានធ្វើឲ្យព្រះប្រាជ្ញាញាណរបស់ព្រះអង្គគិតថាទ្រង់គួរធ្វើអ្វីបន្ទាប់នោះដែរ។ នេះគឺជាមូលដ្ឋានចាំបាច់ណាស់។ នេះជាការបង្ហាញថា ព្រះជាម្ចាស់ជាអ្នកណា។ «តើអ្នកណាបានស្គាល់គំនិតនៃព្រះអម្ចាស់ ឬធ្វើជាអ្នកជួយគំនិតទ្រង់បាន តើអ្នកណាបានថ្វាយដល់ទ្រង់ជាមុន នោះនឹងបានប្រគល់មកអ្នកនោះវិញ ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសម្រាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច» អាម៉ែន (រ៉ូម ១១:៣៤-៣៦)។

គ្មាននរណាម្នាក់ជួយផ្តល់គំនិតដល់ទ្រង់បាននោះទេ។ គ្មាននរណាម្នាក់ឲ្យអ្វីមួយទៅកាន់ព្រះអង្គដែលទ្រង់មិនមានរួចហើយនោះដែរ។ យើងមិនអាចផ្គាប់ព្រះទ័យព្រះជាម្ចាស់ក្នុងការឲ្យព្រះអង្គធ្វើអ្វីមួយចេញពីតម្រូវការរបស់ទ្រង់សម្រាប់យើងនោះឡើយ។ ព្រះអង្គមិនត្រូវការពួកយើងឡើយ។ ហើយព្រះអង្គមិនត្រូវការសេចក្តីអធិស្ឋានរបស់លោកអ្នកដែរ។ ព្រះអង្គមិនត្រូវការអ្វីទាំងអស់ពីលោកអ្នកបងប្អូន។ នោះគឺជាអត្ថន័យរបស់ព្រះ

ជាម្ចាស់។ ព្រះអង្គមិនត្រូវការអ្វីទាំងអស់។ យើងទាំងអស់គ្នាទើបជាអ្នកមានតម្រូវការ។ ព្រះអង្គគឺជាអង្គដែលបំពេញតម្រូវការ។ ហើយរបៀបដែលទ្រង់ដែលជាអង្គបំពេញតម្រូវការទទួលបានសិរីរុងរឿងគឺតាមរយៈការដែលព្រះអង្គឆ្លើយតបនូវតម្រូវការនៃសេចក្តីអធិស្ឋានរបស់យើង។

ឥឡូវ សូមកត់សម្គាល់អំពីការនេះ៖ វាគឺជាការដ៏គួរឲ្យភ្ញាក់ផ្អើលដែលព្រះជាម្ចាស់ (ដែលគ្រប់គ្រងពេញដោយអធិបតេយ្យភាពលើចក្រវាលមួយនេះ) នឹងតែងតាំងថាសេចក្តីអធិស្ឋានរបស់យើងបណ្តាលឲ្យមានអ្វីមួយកើតឡើង។ សេចក្តីអធិស្ឋានបណ្តាលឲ្យមានការអ្វីមួយកើតឡើង ដែលការនោះនឹងមិនអាចកើតឡើងបានទេ ប្រសិនបើលោកអ្នកមិនបានអធិស្ឋាន។ ខ្ញុំសង្ស័យថា មានគ្រីស្ទបរិស័ទកាល់វីននិយម (Calvinists) មួយចំនួនកំពុងតែជំទាស់ហើយមើលទៅ។

សូមស្តាប់អំពីការនេះ។ នៅពេលដែលកណ្ឌគម្ពីរ យ៉ាកុប ៤:២ មានចែងថា «អ្នករាល់គ្នាមិនបានអ្វីសោះ ពីព្រោះមិនសូម» នោះមិនមែនមានន័យថា អ្នករាល់គ្នានឹងមានទោះបីជាអ្នកមិនបានសូមក៏ដោយ ដោយសារព្រះអង្គមានផែនការរួចហើយនោះទេ។ ខគម្ពីរមួយនេះមិនបានមានន័យផ្ទុយពីអ្វីដែលបានលើកឡើងឡើយ។ ខគម្ពីរនេះបានចែងថា «អ្នករាល់គ្នាមិនបានអ្វីសោះ ពីព្រោះមិនសូម»។ នោះមានន័យថា សេចក្តីអធិស្ឋានបណ្តាលឲ្យមានការអ្វីមួយកើតឡើង ដែលការនោះនឹងមិនអាចកើតឡើងបានទេ ប្រសិនបើលោកអ្នកមិនបានអធិស្ឋាន។ នេះគឺជាអភ័យឯកសិទ្ធិពេញដោយសិរីរុងរឿងដ៏អស្ចារ្យមួយ ដែលព្រះជាម្ចាស់ដ៏ជាព្រះពេញដោយអធិបតេយ្យភាពនៃចក្រវាលនេះទទួលបាន ដែលព្រះអង្គគ្រប់គ្រងលើគ្រប់ទាំងអស់ស្របតាមព្រះប្រាជ្ញាញាណដ៏គ្មានដែនកំណត់របស់ព្រះអង្គ ហើយក៏បានកើតឡើងតាមការដែលព្រះអង្គបណ្តាល។

នេះគឺជាការដ៏គួរឲ្យភ្ញាក់ផ្អើលណាស់។ ប្រសិនបើលោកអ្នកមិនប្រើ



ប្រាស់អភ័យឯកសិទ្ធិនៃការចូលរួមជាមួយព្រះជាម្ចាស់នៅក្នុងរបៀបដែលសំណូមពរអធិស្ឋានរបស់លោកអ្នកអាចនាំឲ្យមានព្រឹត្តិការណ៍ណាមួយកើតឡើងនៅក្នុងចក្រវាលនេះដែលនឹងមិនមានកើតឡើងប្រសិនបើលោកអ្នកមិនបានអធិស្ឋាន នោះលោកអ្នកកំពុងធ្វើដូចជាមនុស្សល្ងីល្ងើដ៏ខ្លាំងម្នាក់ហើយ។ ខ្ញុំកំពុងគិតយ៉ាងសមហេតុផល។ ប្រសិនបើលោកអ្នកផ្តល់នូវអភ័យឯកសិទ្ធិនៃការចូលរួមជាមួយព្រះជាម្ចាស់នៅក្នុងរបៀបមួយដែលសំណូមពរអធិស្ឋានរបស់លោកអ្នកអាចនាំឲ្យមានរឿងអ្វីមួយកើតឡើងបាន ដែលបើមិនដូច្នេះទេការនោះមិនអាចកើតឡើងបានទេ ហើយការប្រើប្រាស់អភ័យឯកសិទ្ធិនោះគឺជាភាពល្ងីល្ងើនៅក្នុងលំដាប់ដ៏ខ្ពស់បំផុត (ឬទាបបំផុត) មួយហើយ។ នេះគឺជាមូលហេតុដែលយើងត្រូវអធិស្ឋាន៖ ព្រះជាម្ចាស់កំពុងត្រាស់ហៅយើងឲ្យមានចំណែកជាមួយទ្រង់ក្នុងដំណើរការនៃចក្រវាលនេះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Three Motivations to Pray
**កត្តាជំរុញចិត្តបីយ៉ាងដើម្បីអធិស្ឋាន**
https://www.desiringgod.org/interviews/three-motivations-to-pray

## សំណួរទី១៩៖

# ហេតុអ្វីបានជាគ្រីស្ទបរិស័ទថ្វាយបង្គំជាមួយគ្នានៅថ្ងៃអាទិត្យ?

ពួកយើងទទួលបានសំណួរជាច្រើនពីប្រិយមិត្តអ្នកអាន តើព្រះជាម្ចាស់សម្រេចផែនការនៃការសង្គ្រោះក្រោយ ឬក៏មុនពេលមនុស្សធ្លាក់ក្នុងអំពើបាប (Infralapsarian/Supralapsarian) ជាការជជែកវែកញែកអំពីព័ត៌មានលម្អិតដ៏គួរឲ្យឆ្ងល់ ទាក់ទងនឹងគ្រាចុងក្រោយ (Eschatology) សម្រាប់អស់អ្នកដែលចង់ដឹងពីគោលលទ្ធិកាល់វិននិយម (Calvinism) និងគោលលទ្ធិកំណែទម្រង់ថ្មី (Reformed Theology) ពួកគាត់ចង់យល់អំពីដំណឹងល្អ និងសូម្បីតែចង់ដឹងអំពីមូលហេតុដែលគ្រីស្ទបរិស័ទទៅក្រុមជំនុំតាំងពីដំបូង ហើយតើហេតុអ្វីបានជាទៅនៅថ្ងៃអាទិត្យ?

សូមចាប់ផ្ដើមដោយឆ្លើយសំណួរ៖ តើគ្រីស្ទបរិស័ទជានរណា? ខ្ញុំយល់ថា សំណួរនេះមានមូលដ្ឋានមកពីអ្នកសួរដែលបើមើលតែសំបកក្រៅនោះគាត់ប្រហែលពុំមានគំនិតច្បាស់លាស់ សូម្បីតែថា តើគ្រីស្ទបរិស័ទជានរណា?

### តើគ្រីស្ទបរិស័ទមានលក្ខណៈដូចម្ដេច?

គ្រីស្ទបរិស័ទគឺជាក្រុមមនុស្សដែលទទួលស្គាល់ថា ទោះបីជាយើងត្រូវបានបង្កើតមកក្នុងរូបអង្គនៃព្រះជាម្ចាស់ ដូចជាមនុស្សផ្សេងៗទៀតក៏ដោយ ក៏យើងខ្វះមិនដល់សេរីល្អនៃព្រះ ដូច្នេះយើងបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់ ហើយបានមើលស្រាលសិរីល្អរបស់ទ្រង់ ដោយលើកតម្កើងរបស់ដែលព្រះអង្គបានបង្កើតមក ឲ្យមានតម្លៃជាងអង្គទ្រង់។ គ្រីស្ទបរិស័ទ

ទទួលស្គាល់ថា យើងសមនឹងទទួលការវិនិច្ឆ័យទោស។ យើងពិតជាស័ក្តិសម។ នេះគឺជាការទាស់ប្រឆាំងយ៉ាងធ្ងន់ធ្ងរ ចំពោះព្រះអាទិករដែលបានបង្កើតសកលលោក។

ហើយលើសជាងនេះទៅទៀត យើងបានទទួលស្គាល់ថា ព្រះជាម្ចាស់មិនគ្រាន់តែនឹងវិនិច្ឆ័យទោសប៉ុណ្ណោះទេ ទ្រង់ថែមទាំងមានសេចក្តីអត់ធ្មត់និងសេចក្តីស្រឡាញ់ផងដែរ។ ព្រះអម្ចាស់បានចាត់បញ្ជូនព្រះអង្គសង្គ្រោះជាព្រះរាជបុត្រាទ្រង់ជាព្រះដ៏ប្រោសលោះ គឺព្រះយេស៊ូវគ្រីស្ទមកកាន់ពិភពលោក ដើម្បីទទួលទោសទណ្ឌជំនួសយើង។ ព្រះគម្ពីរបានចែងថា៖ «បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត» (រ៉ូម ១០:៩)។ ការនេះមានន័យថា បានសង្គ្រោះចេញពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ បានសង្គ្រោះចេញពីការដាក់ទោសរបស់ព្រះជាម្ចាស់ បានសង្គ្រោះចេញពីនរក ហើយទទួលជីវិតអស់កល្បជានិច្ច។

ដូច្នេះ គ្រីស្ទបរិស័ទ គឺជាអស់អ្នកដែលជឿថា ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះដែលបានសុគតសម្រាប់អំពើបាបពួកគេ និងមានព្រះជន្មរស់ឡើងវិញ ព្រះអង្គកំពុងតែសោយរាជ្យនៅស្ថានសួគ៌ ទ្រង់នឹងយាងត្រឡប់មកវិញ ហើយពួកគេទុកចិត្តដល់ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះពួកគេពីបាប និងសេចក្តីជំនុំជម្រះជាប្រចាំថ្ងៃ ជាអំណាចកំពូល ព្រមទាំងជាកំណប់ទ្រព្យដ៏ថ្លៃវិសេសបំផុត។

### ការជួបជុំរបស់គ្រីស្ទបរិស័ទ

ដោយយោងទៅតាមព្រះគម្ពីរ គ្រីស្ទបរិស័ទមិនមែនគ្រាន់តែជាបុគ្គលដាច់ៗដោយឡែកពីគ្នានោះឡើយ ប៉ុន្តែជាការប្រមូលផ្តុំគ្នាដែលមានអវយវៈជាច្រើន ពីព្រោះពួកគេទាំងអស់គ្នាបានរួបរួមគ្នាក្នុងព្រះយេស៊ូវដោយសារសេចក្តីជំនឿ។ ហើយការនេះកើតឡើងដោយសារពួកគេរួមគ្នានៅក្នុងព្រះយេស៊ូវ ដោយលក្ខណៈនៃការជួបជុំបែបគ្រីស្ទបរិស័ទ នោះក្រុមជំនុំក៏កើតមានឡើង។ ក្រុមជំនុំមិនមែនគ្រាន់តែជាអាគារ។ វាមិនមែនជាគំនរឥដ្ឋ និងបាយអទេ។ ក្រុមជំនុំ គឺជាការជួបជុំរបស់អស់អ្នកជឿប្រមូលផ្តុំគ្នា ដើម្បីបង្ហាញពីការរួបរួម និងថ្វាយបង្គំព្រះយេស៊ូវ។

ព្រះគម្ពីរបានចែងថា៖ «អ្នករាល់គ្នា (គ្រីស្ទបរិស័ទ) ជារូបកាយនៃព្រះគ្រីស្ទ ហើយជាអវយវៈរបស់រូបកាយរៀងខ្លួន» (១កូរិនថូស ១២:២៧)។ ដូច្នេះ ការចូលរួមការប្រជុំផ្សេងៗ គឺមានសារៈសំខាន់ក្នុងការបង្ហាញពីការពិតដែលព្រះយេស៊ូវបានសុគតដើម្បីបង្កើតការរួបរួមក្នុងបណ្តាមនុស្សលោក មិនមែនគ្រាន់តែជាបុគ្គលដាច់ៗដោយឡែកពីគ្នានោះឡើយ។

### ការប្រជុំគ្នាជាទៀងទាត់

ដូច្នេះ យើងឃើញព្រះគម្ពីរបានចែងពីការប្រជុំគ្នាជាទៀងទាត់របស់ពួកគ្រីស្ទបរិស័ទនៅសតវត្សរ៍ទីមួយ។ នេះជាសំណួរ៖ តើហេតុអ្វីបានជាយើងត្រូវទៅក្រុមជំនុំ?

កណ្ឌគម្ពីរ ១កូរិនថូស ១១:១៨ ចែងថា៖ «ព្រោះមុនដំបូងខ្ញុំឮថា កាលណាអ្នករាល់គ្នាមូលមកក្នុងពួកជំនុំ...» ឬ ១កូរិនថូស ១៤:២៣ «ដូច្នេះ បើកាលណាពួកជំនុំទាំងមូលប្រជុំគ្នានៅកន្លែងណាមួយ...»

ដូច្នេះ អត្ថបទទាំងនេះបានបន្តទៅមុខទៀតដោយសេចក្តីណែនាំពីរបៀបដែលយើងត្រូវប្រព្រឹត្តនៅពេលប្រជុំគ្នានៅក្នុងក្រុមជំនុំ។ បន្ទាប់មកយើងឃើញមានការចង្អុលបង្ហាញខ្លះនៅក្នុងព្រះគម្ពីរពីអ្វីដែលយើងគួរធ្វើនៅពេលមកជួបជុំគ្នា។ ហេតុដូច្នេះ សំណួរប្រហែលជា៖ ហេតុអ្វីលោកអ្នកត្រូវទៅក្រុមជំនុំ ឬតើលោកអ្នកត្រូវធ្វើអ្វី នៅពេលលោកអ្នកទៅក្រុមជំនុំ? ហើយដូច្នេះ សូមឲ្យខ្ញុំផ្តល់ជាឧទាហរណ៍មួយចំនួន។

រាល់សេចក្ដីណែនាំទាំងឡាយនៅក្នុងព្រះគម្ពីរគឺហូរមកពីប្រភពនៃសេចក្ដីពិត ដែលព្រះយេស៊ូវមានព្រះជន្មគង់នៅ ព្រះយេស៊ូវស័ក្តិសមទទួលបានការទៅចូលរួម ការជួបប្រជុំ និងការថ្វាយបង្គំពីទ្រង់ជាទៀងទាត់។ ម៉្យាងទៀត រឿងរ៉ាវទាំងឡាយដែលព្រះគម្ពីរបានចែងឲ្យយើងធ្វើតាម យើងមិនគួរធ្វើតាមទំនើងចិត្តខ្លួនឯងឡើយ ព្រោះវាមានទំនាក់ទំនងបែបជាសរីរាង្គទៅនឹងសេចក្ដីពិតដែលគ្រីស្ទបរិស័ទស្គាល់ និងស្រឡាញ់ ហើយដើរតាមព្រះអង្គដ៏មានព្រះជន្មរស់ គឺព្រះយេស៊ូវគ្រីស្ទដែលបានសុគតដើម្បីបង្កើតសហគមន៍មួយសម្រាប់រាស្ត្រទ្រង់ ជាពួករាស្ត្រដែលថ្វាយបង្គំព្រះអង្គ។

## ការច្រៀងទៅកាន់គ្នាទៅវិញទៅមក

ឧទាហរណ៍៖ កណ្ឌគម្ពីរ អេភេសូរ ៥:១៩ ដែលយើងគួរតែលើកឡើង «ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ នឹងចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត»។ ប្រសិនបើយើងទៅចូលរួមនៅក្រុមជំនុំណាមួយក្ដី លោកអ្នកប្រហែលជានឹងលឺការច្រៀងចម្រៀងដ៏ពីរោះ ហើយការច្រៀងនោះបានបង្កើតឡើងដើម្បីបង្ហាញពីអារម្មណ៍ប៉ះពាល់នៃការសរសើរចំពោះព្រះជាម្ចាស់ និងចំពោះព្រះយេស៊ូវសម្រាប់អ្វីដែលទ្រង់បានធ្វើ ដើម្បីសង្គ្រោះយើងរាល់គ្នាចេញពីអំពើបាប ពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ ពីបឹងភ្លើង និងពីការរងទុក្ខវេទនាអស់កល្បជានិច្ច។

## ការអធិស្ឋានជាមួយគ្នា

ហើយបន្ទាប់មក យើងអានអំពីសេចក្ដីណែនាំអំពីការអធិស្ឋានបានផងដែរ មិនមែនគ្រាន់តែជាការច្រៀង ប៉ុន្តែជាសេចក្ដីអធិស្ឋាន។ ឧទាហរណ៍៖ កណ្ឌគម្ពីរ ១កូរិនថូស ១៤:១៦ បានចែងថា៖ «ពុំនោះ បើសូមពរដោយនូវវិញ្ញាណទទេ នោះធ្វើដូចម្ដេចឲ្យអ្នកដែលមិនចេះ បានថា «អាម៉ែន» បានក្នុងកាលដែលអ្នកអរព្រះគុណនោះ ដ្បិតអ្នកនោះមិនដឹងជាអ្នកថាដូចម្ដេចទេ» ដ្បិតនេះគឺជាចំណុចស្នូលនៃការអធិស្ឋាននៅទីសាធារណៈ។

## ការបង្រៀនព្រះបន្ទូល

នៅពេលយើងអានការណែនាំអំពីការបង្រៀនព្រះបន្ទូលដ៏ជំរុញចិត្តរបស់ព្រះជាម្ចាស់។ សាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ៣:១៦ «គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន»។ បន្ទាប់មកគាត់បាននិយាយបន្ថែមទៀតទៅកាន់គ្រូគង្វាលវ័យក្មេង ធីម៉ូថេ «ចូរឲ្យអ្នកផ្សាយព្រះបន្ទូលចុះ» (២ធីម៉ូថេ ៤:២)។ ដូច្នេះ ជាទូទៅ នៅក្នុងវេនថ្វាយបង្គំគ្រីស្ទបរិស័ទតែងបង្រៀនព្រះបន្ទូល ទីដែលគ្រូគង្វាលទទួលបានត្រាស់ហៅ ហើយទទួលបានអំណោយទានដោយព្រះជាម្ចាស់ ដើម្បីសិក្សា និងស្វែងយល់ពីព្រះគម្ពីរបន្ទាប់មកងើបឡើង ហើយប្រកាសពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរ ដើម្បីលើកទឹកចិត្ត ពង្រឹង ពង្រួបពង្រួម និងជំរុញដល់ដួងចិត្តប្រជារាស្ត្ររបស់ព្រះជាម្ចាស់អំពីការស្ដាប់បង្គាប់ និងកិច្ចការបម្រើផ្សេងៗនៅក្នុងចំណោមអ្នកជឿ ដើម្បីថ្វាយសិរីល្អដល់ព្រះគ្រីស្ទ។

## ការធ្វើពិធីជ្រមុជទឹក និងការធ្វើពិធីលាងព្រះអម្ចាស់

ហើយបន្ទាប់មក យើងឃើញសេចក្ដីណែនាំនៅក្នុងព្រះគម្ពីរអំពីពិធីលាងព្រះអម្ចាស់ និងបុណ្យជ្រមុជទឹក—ដូចដែលយើងបានដឹងថា ពិធីទាំងពីរនេះគួរតែសម្គាល់ការជួបជុំគ្នារបស់គ្រីស្ទបរិស័ទ។ សម្រាប់ពិធីបុណ្យជ្រមុជទឹក គឺវាជាព្រឹត្តិការណ៍ធ្វើតែម្ដងគត់នៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ ដែលបានណែនាំលោកអ្នកពីការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ហើយតាមរយៈការជ្រមុជចូលទៅក្នុងទឹក នោះលោកអ្នកបានក្លាយទៅជាអ្នកជឿព្រះយេស៊ូវគ្រីស្ទ។ ចំណែកឯពិធីលាងព្រះអម្ចាស់ គឺជា

បទពិសោធន៍ម្តងហើយម្តងទៀតនៃការចូលរួមជាមួយព្រះគ្រីស្ទ នៅពេលដែលយើងបរិភោគនំបុ័ង និងផឹកពីពែង ដើម្បីបង្ហាញប្រាប់ពីរូបអង្គដែលខ្ទេចខ្ទាំ និងការខ្ចាយព្រះលោហិតទ្រង់សម្រាប់អំពើបាបរបស់យើងរាល់គ្នា។ ហើយក្រុមជំនុំផ្សេងគ្នាតាមពេលវេលាខុសៗគ្នាផងដែរ។ ខ្លះធ្វើវាជារៀងរាល់សប្តាហ៍។ ខ្លះទៀតធ្វើវាជារៀងរាល់មួយខែម្តង។ ព្រះគម្ពីរមិនប្រាប់យើងថាត្រូវធ្វើញឹកញាប់ប៉ុណ្ណានោះទេ។ ដោយគ្រាន់តែមានចែងថា៖ «ដ្បិតរាល់វេលាណា ដែលអ្នករាល់គ្នាបរិភោគនំបុ័ងនេះ ហើយផឹកពីពែងនេះ នោះឈ្មោះថាសម្តែងពីសេចក្តីសុគតរបស់ផងព្រះអម្ចាស់ ដរាបដល់ទ្រង់យាងមក» (១កូរិនថូស ១១:២៦)។

### ថ្ងៃបរិសុទ្ធ ឬថ្ងៃសប្ប័ត (ថ្ងៃអាទិត្យ)

ប្រសិនបើសំណួរចង់សួរថា៖ ហេតុអ្វីបានជាលោកអ្នកត្រូវធ្វើវានៅថ្ងៃអាទិត្យ? ហេតុអ្វីបានជាលោកអ្នកជាគ្រីស្ទបរិស័ទទៅក្រុមជំនុំនៅថ្ងៃអាទិត្យ? ចម្លើយ គឺការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទមានឫសគល់នៅក្នុងសាសនាយូដា។ វាបានកើតឡើងនៅក្នុងចំណោមសាសន៍យូដា។ ហើយព្រះគម្ពីររបស់សាសន៍យូដា គឺផ្នែកដំបូងនៃព្រះគម្ពីររបស់គ្រីស្ទបរិស័ទ។ ក្នុងចំណោមសាសន៍យូដា ព្រះគម្ពីរមានចែងក្នុងក្រឹត្យវិន័យដប់ប្រការថា៖ «ចូរឲ្យនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ» (និក្ខមនំ ២០:៨)។ ហើយថ្ងៃឈប់សម្រាកនោះគឺជាថ្ងៃទីប្រាំពីរ ដែលត្រូវនឹងថ្ងៃសៅរ៍ មិនជាថ្ងៃអាទិត្យទេ។ ដូច្នេះ មានមួយថ្ងៃនៅក្នុងចំណោមថ្ងៃទាំងប្រាំពីរជាទម្លាប់ ដែលសាសន៍យូដាជួបប្រជុំគ្នា។

នៅក្នុងសតវត្សរ៍ទី១ នៅពេលដែលក្រុមជំនុំទើបតែបានកើតមានឡើង ដោយការយាងមករបស់ព្រះយេស៊ូវ ពីព្រោះយើងបានអាននៅក្នុងកណ្ឌគម្ពីរកិច្ចការ តាមទំនៀមទម្លាប់ នោះយើងឃើញថាសាវ័ក ប៉ុល បានទៅ



សាលាប្រជុំនៅថ្ងៃឈប់សម្រាក ហើយបានចូលរួមជាមួយនឹងពួកយូដា ដើម្បីប្រកាសអំពីព្រះគ្រីស្ទ។ គ្រីស្ទបរិស័ទបានប្តូរ និងបានចាប់ផ្តើមថ្វាយបង្គំនៅថ្ងៃដំបូងនៃសប្តាហ៍ ដោយសារព្រះយេស៊ូវបានរស់ពីសុគតឡើងវិញនៅថ្ងៃដំបូងនៃសប្តាហ៍នោះ។ យើងហៅថា «ថ្ងៃនៃព្រះអម្ចាស់» (វិវរណៈ ១:១០)។ យើងបានអានឧទាហរណ៍នៃការប្រជុំគ្នានៅថ្ងៃនៃព្រះអម្ចាស់ ឬថ្ងៃដំបូង យើងឃើញនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២០:៧ ពួកគេបានប្រជុំគ្នា៖ «នៅថ្ងៃដំបូងនៃអាទិត្យនោះ»។ កណ្ឌគម្ពីរ ១កូរិនថូស ១៦:២ ពួកគេមកប្រជុំគ្នា និងថ្វាយដង្វាយនៅថ្ងៃដំបូងនៃអាទិត្យនោះ។ ដូច្នេះ នោះហើយគឺជាអ្វីដែលយើងធ្វើវានៅថ្ងៃអាទិត្យ។ ព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ បានបង្កើតរាស្ត្រថ្មីសម្រាប់ផងទ្រង់ ហើយបានស្តារមនុស្សជាតិថ្មីឡើង ដែលជាការបង្កើតឲ្យមានថ្ងៃថ្មីនៃការថ្វាយបង្គំ។

ដូច្នេះ សូមឲ្យខ្ញុំសង្ខេបឡើងវិញដូចនេះ៖ ហេតុផលដែលគ្រីស្ទបរិស័ទទៅក្រុមជំនុំនៅថ្ងៃអាទិត្យ គឺដោយសារយើងបានសង្គ្រោះចេញពីអំពើបាប បានរួមជាមួយនឹងព្រះអង្គដែលរស់ឡើងវិញ រស់នៅក្នុងជីវិតដែលកាន់តែដូចព្រះគ្រីស្ទ និងរស់នៅជាមួយគ្នានឹងគ្នាដោយសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ។ ហើយដោយសារតែការរួបរួមជាមួយព្រះគ្រីស្ទ និងជាមួយគ្នានឹងគ្នាទៅវិញទៅមកជាមួយព្រះគម្ពីរ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្គាប់យើងឲ្យចូលរួមការប្រជុំគ្នា ជារៀងរាល់សប្តាហ៍ ឲ្យបានទៀងទាត់ ព្រមទាំងអរព្រះគុណនៅចំពោះព្រះជាម្ចាស់នៅក្នុងការថ្វាយបង្គំ—មិនមែនគ្រាន់តែជាគ្រីស្ទបរិស័ទតែម្នាក់ៗឯងដាច់ដោយឡែកដែលត្រូវបានខ្ចាត់ខ្ចាយនោះទេ ប៉ុន្តែជាក្រុមមនុស្សប្រជុំគ្នាអធិស្ឋាន ច្រៀងចម្រៀងសរសើរតម្កើងថ្វាយបង្គំ ស្តាប់ព្រះបន្ទូល ហើយកាន់តាមបញ្ញត្តិព្រះយេស៊ូវ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Why Do Christian Worship Together on Sundays?
**ហេតុអ្វីបានជាគ្រីស្ទបរិស័ទថ្វាយបង្គំជាមួយគ្នានៅថ្ងៃអាទិត្យ?**
https://www.desiringgod.org/interviews/why-do-christians-worship-together-on-sundays

# ផ្នែកទី៣
# ការអាន និងការមិនអានព្រះគម្ពីរ

# សំណួរទី១៥៖
# កត្តាជំរុញដ៏ល្អក្នុងការចងចាំព្រះគម្ពីរ

ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់គឺជាការពិបាកណាស់។ វាតម្រូវឲ្យមានពេលវេលា កម្លាំងឆន្ទៈ និងការផ្ដោតអារម្មណ៍ ហើយនេះមានន័យថា យើងត្រូវមានកត្តាជំរុញដ៏ល្អៗក្នុងការជំរុញចិត្តឲ្យទន្ទេញព្រះគម្ពីរ នៅពេលយើងចាប់ផ្ដើម។ នេះគឺជាអ្វីដែលលោកគ្រូ ចន ផាបភ័រ ធ្វើសម្រាប់យើង នៅក្នុងសេចក្ដីអធិប្បាយរបស់គាត់ដែលមានចំណងជើងថា «បើពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា» (“If My Words Abide in You”) ដែលគាត់បានអធិប្បាយនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០០៩។ ខាងក្រោមនេះគឺជាអ្វីដែលគាត់បានចែកចាយ៖

មូលហេតុដែលខ្ញុំចាប់ផ្ដើមដោយសូត្រកណ្ឌគម្ពីរ ទំនុកតម្កើង១; ១៦; ១០៣; រ៉ូម ៥:១-៨; រ៉ូម ៨; ម៉ាថាយ ៦:១, ២៥-៣៤ និង១កូរិនថូស ១៣ គឺដោយសារខ្ញុំសង្ឃឹមថា—ហើយក៏អធិស្ឋានយ៉ាងខ្លាំងសម្រាប់លោកអ្នក—គឺឲ្យព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតរបស់លោកអ្នកដូចដែលកាលព្រះអង្គបានធ្វើការនៅក្នុងជីវិតខ្ញុំកាលពី៣១ឆ្នាំមុន។

## កាលខ្ញុំមានអាយុ៣១ឆ្នាំ

កាលនោះខ្ញុំបានដើរចូលកន្លែងប្រជុំដែលខ្ញុំត្រូវបង្រៀន។ ហើយខ្ញុំក៏បានអង្គុយចាំ។ ពេលនោះ លោកបណ្ឌិត អាត លូវីស (Art Lewis) ដែលជាគ្រូបង្រៀនព្រះគម្ពីរសញ្ញាចាស់ បានងើបឡើងហើយសូត្រកណ្ឌគម្ពីរ ម៉ាថាយ ៦:២៥-៣៤។ ហើយគាត់បានធ្វើតែប៉ុណ្ណោះ។ គាត់គ្រាន់តែមើលមកកាន់យើង ហើយសូត្រយកតែម្ដង។ កាលនោះខ្ញុំមានការភ្ញាក់ផ្អើលណាស់។

កាលខ្ញុំមានអាយុ៣១ឆ្នាំ ហើយមិនដែលឃើញនរណាសូត្រព្រះគម្ពីរ

ដូចនោះ នៅក្នុងព្រះវិហារឡើយ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ការនោះបាននាំឲ្យខ្ញុំឈានចូលក្នុងដំណើរការ នៃការទន្ទេញព្រះគម្ពីរឲ្យចាំមាត់។ ហើយអ្វីដែលខ្ញុំចង់លើកឡើងក្នុងអត្ថបទនេះ គឺលើកទីបន្ទាល់របស់ខ្ញុំលាយជាមួយទីបន្ទាល់របស់ព្រះយេស៊ូវ ទាក់ទងនឹងការឲ្យតម្លៃលើការទន្ទេញព្រះគម្ពីរឲ្យចាំមាត់។

**គន្លឹះ៨យ៉ាងនៃការទន្ទេញព្រះគម្ពីរ**

ខ្ញុំកំពុងតែសូមអង្វរបងប្អូន។ ហើយនេះគឺជាទីបន្ទាល់របស់ខ្ញុំ។ ខ្ញុំនឹងលើកឡើង៨ប្រយោគ ដោយមិនមានការបកស្រាយបន្ថែមៈ

១. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់នាំឲ្យលោកអ្នកអាចសញ្ជឹងគិតលើព្រះគម្ពីរ ទោះបីលោកអ្នកមិនកំពុងអានព្រះគម្ពីរក៏ដោយ។ ហើយការសញ្ជឹងគិតគឺជាគន្លងផ្លូវនៃការឈានទៅដល់ការយល់ដឹងឲ្យកាន់តែជ្រៅជ្រះបន្ថែមទៀត។ ដូច្នេះ ប្រសិនបើលោកអ្នកនឹងរំពឹងគិតក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ (សូមមើលនៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ១:២) នោះដាច់ខាតលោកអ្នកត្រូវតែមានខគម្ពីរចងចាំខ្លះៗនៅក្នុងចិត្តគំនិតរបស់លោកអ្នក។

២. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ចម្រើនកម្លាំងដល់ជំនឿរបស់ខ្ញុំ ពីព្រោះ «សេចក្ដីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ» (រ៉ូម ១០:១៧)។ ហើយការនេះកើតឡើងនៅពេលដែលខ្ញុំឮព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងខួរក្បាលរបស់ខ្ញុំ។

៣. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់រចនា របៀបដែលខ្ញុំសង្កេតមើលពិភពលោកនេះ តាមរយៈការនាំឲ្យចិត្តគំនិតរបស់ខ្ញុំត្រាប់តាមទស្សនៈរបស់ព្រះជាម្ចាស់លើគ្រប់អ្វីៗទាំងអស់។

៤. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់នាំឲ្យយើងមានព្រះបន្ទូលយ៉ាងងាយស្រួលក្នុងការយកឈ្នះលើសេចក្ដីល្បួងឲ្យប្រព្រឹត្តអំពើបាប ពីព្រោះ



ការព្រមាន និងសេចក្ដីសន្យារបស់ព្រះជាម្ចាស់គឺជារបៀបដែលយើងយកឈ្នះលើការកុហកបាន—គឺការកុហកបោកបញ្ឆោតរបស់អារក្សសាតាំង។

៥. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ការពារគំនិតរបស់ខ្ញុំ ដោយនាំឲ្យខ្ញុំមានភាពងាយស្រួលក្នុងការដឹងសេចក្ដីខុសឆ្គង។ លោកីយ៍នេះមានពេញទៅដោយសេចក្ដីខុសឆ្គង ព្រោះព្រះក្នុងលោកីយ៍នេះគឺជាព្រះដែលកុហក។

៦. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់នាំឲ្យខ្ញុំអាចច្បាំងជាមួយនឹងអារក្សបាន ដោយប្រើកម្លាំងដែលវាមិនអាចតយុទ្ធជាមួយបាន ដើម្បីការពារខ្លួនខ្ញុំផ្ទាល់ និងគ្រួសាររបស់ខ្ញុំដែលវាកំពុងតែវាយប្រហារ។ តើលោកអ្នកកំពុងតែប្រយុទ្ធជាមួយវាដោយប្រើអ្វី? វាខ្លាំងជាងយើងរាប់លានដង។ ហើយវាស្អប់លោកអ្នក និងគ្រួសាររបស់លោកអ្នក និងជីវិតអាពាហ៍ពិពាហ៍របស់លោកអ្នក និងក្រុមជំនុំ ក៏ដូចជាព្រះជាម្ចាស់ដែរ។ ការដែលមានអ្នករស់នៅលើផែនដីនេះ ដែលគ្រប់គ្រងដោយអារក្ស ដើរដោយមិនមានដាវនៅក្នុងដៃ គឺជារឿងដ៏ភ្ញាក់ផ្អើលណាស់ចំពោះខ្ញុំ។

៧. ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ផ្ដល់មកកាន់យើងនៅពាក្យពេចន៍ដ៏ខ្លាំង និងផ្អែមល្ហែមក្នុងការធ្វើព័ន្ធកិច្ចជាមួយនឹងអស់អ្នកដែលមានតម្រូវការ។ តើធ្លាប់មានពេលទេ ដែលលោកអ្នកមិនបានត្រៀមក្នុងការធ្វើការជាមួយនឹងអ្នកដែលមានតម្រូវការ? លោកអ្នកមិនចាំបាច់មាន «ការមិនបានត្រៀមទុកជាមុន» ដូចនោះទេ។

៨. ហើយជាចុងក្រោយ ការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ប្រទាននូវរបៀបប្រកបគ្នាជាមួយនឹងព្រះយេស៊ូវ ពីព្រោះព្រះអង្គមានព្រះបន្ទូលមកកាន់ខ្ញុំនៅពេលដែលខ្ញុំសញ្ជឹងគិត លើព្រះបន្ទូលរបស់ទ្រង់—ដោយមានព្រះបន្ទូលមកកាន់ខ្ញុំផ្ទាល់យ៉ាងផ្អែមល្ហែម ពេញដោយអំណាច និងសេចក្ដីពិតមែន។ ហើយបន្ទាប់មក ខ្ញុំសន្ទនាជាមួយនឹងព្រះអង្គវិញ តាមរយៈការអធិស្ឋាន។ ហើយប្រសិនបើខ្ញុំមានព្រះបន្ទូលនៅក្នុងចិត្តគំនិតរបស់ខ្ញុំ នោះមានន័យ

ថា យើងអាចមានការសន្ទនាជាមួយគ្នានៅទីណាក៏បានដែរ។ វាពិតជាផ្អែមល្ហែមណាស់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
Good Motives for Bible Memory
**កត្តាជំរុញដ៏ល្អក្នុងការចងចាំព្រះគម្ពីរ**
https://www.desiringgod.org/interviews/good-motives-for-bible-memory



# សំណួរទី១៦៖
# តើខ្ញុំអាចទទួលប្រយោជន៍ជាច្រើនតាមរយៈការអានព្រះគម្ពីរជាប្រចាំថ្ងៃបានដោយរបៀបណា?

យើងកំពុងតែហៀបឆ្លងឆ្នាំថ្មី—ហើយក្នុងការចូលឆ្នាំថ្មី យើងក៏តែងតែមានការសម្រេចចិត្តថ្មី ហើយភាគច្រើនការសម្រេចចិត្តនោះទាក់ទងទៅនឹងការអានព្រះគម្ពីរទាំងមូលផ្ទាល់ដោយខ្លួនឯង។ ហើយដោយសារយើងដឹងថា នេះជាអ្វីដែលមិត្តអ្នកអានជាច្រើនកំពុងតែគិត ខណៈពេលដែលយើងហៀបនឹងឆ្លងឆ្នាំ យើងក៏ចង់យកឱកាសនេះ ដើម្បីឆ្លើយសំណួរទាក់ទងទៅនឹងការអានព្រះគម្ពីរជាប្រចាំថ្ងៃ។

«ជម្រាបសួរលោកគ្រូ! សំណួររបស់ខ្ញុំគឺទាក់ទងទៅនឹងផែនការនៃការអានព្រះគម្ពីរ។ ខ្ញុំស្គាល់ផែនការខ្លះៗហើយ គឺផែនការឲ្យអានព្រះគម្ពីរពីដើមដល់ចប់ ឬក៏ខ្លះទៀតផ្តោតទៅលើផែនការនៃការអានព្រះគម្ពីរសញ្ញាចាស់លាយឡំជាមួយនឹងព្រះគម្ពីរសញ្ញាថ្មី ហើយផែនការខ្លះទៀតត្រូវបានរៀបឡើងឲ្យយើងអានតាមដំណាក់កាលនៃដំណើររឿងដែលបានកើតឡើង ហើយក៏នៅមានផែនការផ្សេងទៀត ដែលយើងត្រូវចំណាយពេលពីរទៅបីជំពូក ដើម្បីអានព្រះគម្ពីរឲ្យចប់។ សំណួររបស់ខ្ញុំគឺថា៖ ក្នុងនាមជាអ្នកដែលទើបតែចាប់ផ្តើមអានព្រះគម្ពីរ ដោយមិនធ្លាប់បានអានចប់ពីមុនសោះ តើលោកគ្រូលើកទឹកចិត្តឲ្យខ្ញុំប្រើប្រាស់ផែនការអានមួយណា? សូមលោកគ្រូជួយផ្តល់យោបល់ខ្លះៗ ឲ្យខ្ញុំគិត ខណៈពេលដែលខ្ញុំចាប់ផ្តើមអាន»។

មុនខ្ញុំផ្តល់ជូនផែនការអាន ជាក់លាក់ណាមួយ—ជាអ្វីដែលខ្ញុំនឹងធ្វើ—សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវការសង្កេតមួយចំនួនសិន ដែលខ្ញុំគិតថាទាក់ទងទៅនឹងអ្វីដែលអ្នកសួរកំពុងតែសួរ៖ «សូមលោកគ្រូជួយផ្តល់

យោបល់ខ្លះៗ ឲ្យខ្ញុំគិត ខណៈពេលដែលខ្ញុំចាប់ផ្តើមអាន»។ គាត់មិនគ្រាន់តែបានស្នើសុំផែនការអាននោះទេ ប៉ុន្តែស្នើសុំយោបល់ខ្លះៗឲ្យគាត់គិត។ ខាងក្រោមនេះគឺជាអ្វីដែលខ្ញុំគិតថា គាត់កំពុងតែចង់បាន ហើយក៏ជាអ្វីដែលខ្ញុំនឹងព្យាយាមលើកឡើងផងដែរ។

**ការស្គាល់ខ្លួនឯង**

ដោយសារខ្ញុំមិនដឹងយ៉ាងហោចណាស់៥ចំណុចអំពីអ្នកសួរ នេះជាផែនការនៃការអានដែលខ្ញុំនឹងលើកឡើងមកប្រាប់។ បើនិយាយម្យ៉ាងវិញទៀតទៅ ខ្ញុំនឹងលើកឡើងផែនការនេះ ដោយសារខ្ញុំមិនស្គាល់អ្នកសួរ។

តើគាត់ចេះដាក់វិន័យលើខ្លួនឯងខ្លាំងដល់កម្រិតណា? តើគាត់មានពេលប៉ុណ្ណា ដើម្បីអាន? តើគាត់មានជំនាញអ្វីក្នុងការអាន—តើគាត់អានបានលឿនប៉ុណ្ណា ហើយអាចយល់បានប៉ុណ្ណា? តើគាត់ស្គាល់គ្រប់ចំណុចនៃព្រះគម្ពីរដល់កម្រិតណា សូម្បីតែចំណុចដែលគាត់ទំនងជាមិនទាន់បានអាននៅឡើយ? តើគាត់មានកម្រិតចម្ងល់ប៉ុណ្ណា ដែលអាចនឹងបណ្តាលឲ្យគាត់បង្អង់សិន ហើយព្យាយាមយល់នូវអ្វីដែលគាត់មិនយល់?

ដោយអាស្រ័យលើចម្លើយនៃសំណួរទាំងនោះ ខ្ញុំនឹងចែកចាយផែនការអាន។ ប៉ុន្តែ ខ្ញុំចង់ឲ្យគាត់ និងអ្នកដទៃដឹងថាមនុស្សយើងសុទ្ធតែមានលក្ខណៈខុសៗគ្នា ទាក់ទងទៅនឹងសមត្ថភាពនៃការអាន ការយល់ ល្បឿននៃការអាន ហើយកាលៈទេសៈនៃជីវិតរបស់យើងក៏សុទ្ធតែខុសៗគ្នាផងដែរ។ ផែនការនៃការអានដែលខ្ញុំនឹងចែកចាយទំនងជានឹងមិនសម្រាប់គ្រប់បុគ្គលនោះទេ ប៉ុន្តែខ្ញុំនឹងនៅតែចែកចាយអំពីផែនការនៃការអាននេះផងដែរ។ នេះជាចំណុចដំបូងដែលខ្ញុំចង់លើកឡើង ទាក់ទងទៅនឹងយោបល់ឲ្យគាត់គិតខណៈពេលដែលគាត់កំពុងតែអាន៖ គឺស្គាល់ខ្លួនឯងសិន។



**សូមស្តាប់ការអធិប្បាយព្រះបន្ទូល**

សូមប្រាកដឲ្យច្បាស់ថា លោកអ្នកជាសមាជិកក្នុងក្រុមជំនុំដែលអានព្រះគម្ពីរ សមាជិកក្នុងក្រុមជំនុំដែលអធិប្បាយតាមព្រះគម្ពីរ តាមដែលលោកអ្នកអាចធ្វើបាន។ មានចំណុចជាជំនួយតិចណាស់ដែលយើងអាចទទួលបាន ទាក់ទងទៅនឹងការយល់ព្រះគម្ពីរទាំងមូល ហើយចំណុចនោះគឺថា៖ យើងត្រូវតែចំណាយពេលពីមួយអាទិត្យទៅមួយអាទិត្យ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ មិនថា ១០-២០-៣០ ឆ្នាំក៏ដោយ ក្នុងការទទួលទានពីសេចក្តីអធិប្បាយនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។

នេះគឺជាចំណុចដែលសំខាន់ណាស់។ ប្រសិនបើគ្រូគង្វាលរបស់លោកអ្នកមិនអធិប្បាយតាមព្រះគម្ពីរ ហើយពន្យល់ថាខគម្ពីរនោះមានន័យយ៉ាងដូចម្តេច នោះខ្ញុំសូមលើកទឹកចិត្តឲ្យលោកអ្នកប្តូរព្រះវិហារទៅ ពីព្រោះការចំណាយពេលវេលារាប់ឆ្នាំរបស់លោកអ្នកក្នុងការអង្គុយក្រោមការអធិប្បាយតាមរយៈព្រះបន្ទូលនឹងបំផ្លាស់បំប្រែជីវិតរបស់លោកអ្នកក្នុងលក្ខណៈដ៏អស្ចារ្យ ដែលនឹងនៅមានឥទ្ធិពលជាទៅមុខទៀត។

**មានអ្នកមើលខុសត្រូវលើជីវិតលោកអ្នក ចំណាយពេលអធិស្ឋាន និងមានផែនការអាន**

សូមធ្វើជាសមាជិកក្នុងក្រុមណាមួយ ជាសមាជិកក្នុងក្រុមតូច ដែលអ្នកនៅក្នុងក្រុមនោះមានការរំពឹងថាបុគ្គលនីមួយៗកំពុងតែអានព្រះគម្ពីររបស់ខ្លួន ហើយនិយាយគ្នាអំពីអ្វីដែលបានអាននៅពេលដែលជួបជុំ។

សូមអធិស្ឋានឲ្យអស់ពីចិត្តមុនពេលលោកអ្នកនឹងអានព្រះគម្ពីរ ខណៈពេលដែលលោកអ្នកកំពុងអានព្រះគម្ពីរ និងក្រោយពេលដែលលោកអ្នកបានអានព្រះគម្ពីរ។ អធិស្ឋានទូលសូមឲ្យព្រះជាម្ចាស់បើកបង្ហាញនូវអ្វីដែលពិតជាមាននៅក្នុងខគម្ពីរនោះ ហើយឲ្យខគម្ពីរនោះក្លាយជាការពិតនៅក្នុងជីវិត

របស់លោកអ្នក។

សូមរកកន្លែង និងពេលវេលាដែលលោកអ្នកនឹងទៅអានព្រះគម្ពីរជារៀងរាល់ថ្ងៃ។ ប្រសិនបើលោកអ្នកមិនមានពេលវេលា និងទីកន្លែងជាក់លាក់ នោះសាតាំងនឹងប្រាកដជា—អមជាមួយនឹងសាច់ឈាមរបស់លោកអ្នក—រុញពេលអានព្រះគម្ពីររបស់លោកអ្នកចេញពីកាលវិភាគជាមិនខាន។

**ការត្រៀមព្រះគម្ពីរទុក**

ការអានព្រះគម្ពីរឲ្យចប់ ក្នុងរយៈពេលមួយឆ្នាំ តម្រូវឲ្យលោកអ្នកអាន៤ទៅ៥ជំពូកជារៀងរាល់ថ្ងៃ។ ប្រសិនបើលោកអ្នកគិតថា លោកអ្នកត្រូវតែចងចាំរាល់គ្រប់អ្វីៗដែលលោកអ្នកអាន ខណៈពេលដែលលោកអ្នកកំពុងតែអាន៤ទៅ៥ជំពូកនោះ ការរំពឹងទុកដូចនោះនឹងបំបាក់ចិត្តលោកអ្នក ហើយក៏គ្មានតម្លៃដែរ។

ខ្ញុំចង់លើកទឹកចិត្តលោកអ្នកថា នៅពេលដែលលោកអ្នកគិតថា ខ្លួនបានចងចាំ៩៥%នៃអ្វីដែលខ្លួនទើបតែបានអាន នេះអាចជាការពិតក្នុងពេលវេលាខ្លី។ ទោះជាយ៉ាងណាក៏ដោយក៏ព្រះបន្ទូលរបស់ព្រះជាម្ចាស់កំពុងតែគង់នៅក្នុងចិត្តគំនិតរបស់លោកអ្នក ក្នុងរបៀបដែលលោកអ្នកមិនអាចយល់បាន។

អ្វីដែលយើងហៅថាភាសា កថាខណ្ឌ ពាក្យពេចន៍ ដំណើររឿង ឬក៏ចំណុចដែលយើងបានភ្លេចអាចក្លាយជាកន្លែងផ្ទុកព័ត៌មាន ដែលព្រះវិញ្ញាណបរិសុទ្ធអាចបើកបង្ហាញនូវអ្វីដែលលោកអ្នកមិនទាន់ដឹងថាខ្លួនធ្លាប់ដឹង។ នៅពេលដែលលោកអ្នកបានអានព្រះគម្ពីរចប់ហើយនៅពេលព្រឹក សូមកុំបារម្ភត្រង់ថា លោកអ្នកមិនអាចសូត្រគម្រោងនៃរាល់ដំណើររឿងបានគ្រប់កថាខណ្ឌ ដែលលោកអ្នកទើបតែបានអាននោះឡើយ។ លោកអ្នកមិនអាចធ្វើបែបហ្នឹងបានឡើយ លុះត្រាតែលោកអ្នកជាមនុស្សដែលឆ្លាតវៃខ្លាំង



មែនទែន ដែលអាចចងចាំគ្រប់អ្វីៗដែលភ្នែកលោកអ្នកបានមើលឃើញ។

ផ្ទុយទៅវិញ សូមព្យាយាមចងចាំតែមួយឃ្លាដែលច្បាស់លាស់បានហើយ—ឃ្លាដែលបានលើកទឹកចិត្ត ឃ្លាដែលជំរុញចិត្ត ឃ្លាដែលផ្តល់កម្លាំងចិត្តដល់លោកអ្នក ឬក៏ឃ្លាដែលដឹកនាំជីវិតលោកអ្នក។ សូមសរសេរចុះនៅលើក្រដាសមួយ ហើយដាក់ក្នុងហោប៉ៅ ឬក៏បិតនៅកន្លែងណាមួយដែលលោកអ្នកងាយនឹងឃើញពេញមួយថ្ងៃ។ សូមមើលក្រដាសនោះម្តងហើយម្តងទៀតឲ្យពេញមួយថ្ងៃ។ សរុបទៅ ក្នុងមួយឆ្នាំ លោកអ្នកនឹងមានឃ្លាដូចៗនោះនឹងមានចំនួន៣៦៥ឃ្លា ដែលជាឃ្លាអស្ចារ្យ ពេញដោយអំណាច និងជាការប្រមូលទុកនូវសេចក្តីពិត។

**ការជ្រើសរើសផែនការអាន**

ខាងក្រោមនេះគឺជាផែនការអានព្រះគម្ពីរដែលខ្ញុំចង់លើកទឹកចិត្តឲ្យលោកអ្នកប្រើប្រាស់។ ខ្ញុំនឹងលើកទឹកចិត្តឲ្យអ្នកសួរប្រើប្រាស់ផែនការដែលខ្ញុំប្រើប្រាស់ដែរ។ មូលហេតុគឺដោយសារខ្ញុំស្រឡាញ់ផែនការនៃការអាននេះណាស់។ ខ្ញុំគិតថា វាមានតម្លៃ។ ប៉ុន្តែ ខ្ញុំក៏យល់ផងដែរថា នៅមានផែនការអានព្រះគម្ពីរជាច្រើនទៀត ដែលលោកអ្នកក៏អាចជ្រើសរើសប្រើប្រាស់អានតាមបានផងដែរ។

ឈ្មោះនៃផែនការនេះគឺ «ផែនការអានព្រះគម្ពីរ» ហើយខ្ញុំដឹងហើយថាឈ្មោះរបស់វាក៏មិនសូវជាឈ្មោះដែលគួរឲ្យចាប់អារម្មណ៍ប៉ុន្មានផងដែរ។ សូមចូលទៅកាន់គេហទំព័រ ផ្លូវពិត ហើយទាញយកដោយឥតគិតថ្លៃនូវផែនការនៃការអានមួយនេះ។ ផែនការអាននេះមានពីរចំណុចដែលខ្ញុំពេញចិត្តយ៉ាងខ្លាំង។

ទី១ លោកអ្នកនឹងចាប់ផ្តើមអានពីព្រះគម្ពីរសញ្ញាថ្មី ដែលការធ្វើបែបនេះនឹងជួយឲ្យលោកអ្នកយល់អំពីការបំពេញទំនាយនៅក្នុងព្រះគម្ពីរសញ្ញា

ថ្មី ដែលព្រះគម្ពីរសញ្ញាចាស់បានលើកឡើង។

ទី២ ជារៀងរាល់អាទិត្យ ផែនការនេះនឹងនាំឲ្យលោកអ្នកអានដោយមានការលាយឡំគ្នាជាមួយនឹងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី។ នេះមានន័យថា ប្រសិនបើលោកអ្នកមិនយល់ចំណុចណាមួយ នោះលោកអ្នកក៏នៅអាចយល់នូវចំណុចមួយផ្សេងទៀតបានដែរ។

ចំណុចមួយទៀតដែលខ្ញុំចូលចិត្តអំពីផែនការនេះគឺថា លោកអ្នកមិនចាំបាច់ត្រូវបញ្ចប់ការអានព្រះគម្ពីរទាំងមូលក្នុងរយៈពេលមួយឆ្នាំនោះទេ ដូចជាផែនការមួយចំនួនតម្រូវឲ្យលោកអ្នកធ្វើឡើយ។ ផ្ទុយទៅវិញ គម្រោងនៃការអានព្រះគម្ពីរមួយនេះមានរយៈពេល៣ឆ្នាំ៣ខែ។ ខ្ញុំគិតថា តាមរយៈផែនការមួយនេះ នោះលោកអ្នកអាចមានទំនុកចិត្តថាខ្លួននឹងអាចអានព្រះគម្ពីរឲ្យចប់ទាំងមូលបាន ពីព្រោះជារៀងរាល់ថ្ងៃលោកអ្នកគ្រាន់តែអានមួយជំពូកប៉ុណ្ណោះ។ ហើយសម្រាប់ជំពូកវែងៗដូចជាកណ្ឌគម្ពីរ ទំនុកតម្កើង ជំពូក១១៩ យើងក៏បានកាត់វាឲ្យខ្លីដែរ ដើម្បីឲ្យលោកអ្នកងាយអានចប់។

ការមានផែនការឲ្យអានតែមួយជំពូកក្នុងមួយថ្ងៃ គឺដើម្បីកុំឲ្យលោកអ្នកខកចិត្ត ឬក៏អន់ចិត្តជាមួយនឹងខ្លួន ដោយសារមិនបានបំពេញការផែនការអាន ដូចជាមានការអាន៤ទៅ៥ជំពូក ក្នុងមួយថ្ងៃដើម្បីឲ្យចប់ព្រះគម្ពីរទាំងមូលក្នុងមួយឆ្នាំ។

ម្សិលមិញនេះ ខ្ញុំបានអានកណ្ឌគម្ពីរ ទំនុកតម្កើង ជំពូក១ ខ២ «អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងគិតក្នុងក្រិត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ»។ ខគម្ពីរនេះបានរម្លឹកឲ្យខ្ញុំស្រឡាញ់ក្រឹត្យវិន័យរបស់ព្រះ។ ពីមុនៗ ខ្ញុំធ្លាប់គិតថា ក្រឹត្យវិន័យគឺជាអ្វីដែលអវិជ្ជមាន ពីព្រោះជាច្បាប់ដែលយើងត្រូវត្រាប់តាម។ ប៉ុន្តែ ប្រសិនបើយើងគិតទៅ ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់គឺជាអ្វីដែលល្អសម្រាប់យើងទេ។ ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរ រ៉ូម ៣:២០ បានប្រាប់យើងថា ក្រឹត្យវិន័យគឺ «គ្រាន់តែសម្ដែងឲ្យស្គាល់អំពើបាបប៉ុណ្ណោះ» ដែលនេះមានន័យថា យើងត្រូវការព្រះសង្គ្រោះពីព្រោះយើងជាមនុស្សមានបាប។ ទោះបីខ្ញុំមិនចាំខនានាក៏ដោយក៏ខ្ញុំដឹងថា ខ្ញុំត្រូវតែត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាប៉ុណ្ណោះ។

ខ្ញុំស្រឡាញ់ព្រះគម្ពីរណាស់ ហើយខ្ញុំក៏ចូលចិត្តលើកទឹកចិត្តឲ្យអ្នកដទៃអានព្រះគម្ពីរទាំងមូលផងដែរ ជាពិសេសក្នុងរបៀបដែលងាយនឹងអាចបញ្ចប់បាន។ ប្រសិនបើយើងមិនអានព្រះគម្ពីរទាំងមូលទេ នោះយើងអាចនឹងមើលរំលងចំណុចគន្លឹះមួយចំនួននៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ជាមិនខាន។

សរុបសេចក្ដីទៅ មិនថាលោកអ្នកជ្រើសរើសប្រើប្រាស់ផែនការអានព្រះគម្ពីរមួយណាក៏ដោយក៏ខ្ញុំសប្បាយចិត្តណាស់ដែលលោកអ្នកចង់អានព្រះគម្ពីរ។ ខ្ញុំអធិស្ឋានទូលសូមឲ្យព្រះជាម្ចាស់ជួយលោកអ្នកមានកម្លាំង និងភាពអត់ធ្មត់ក្នុងការអានព្រះគម្ពីរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How Do I Make the Most of Daily Bible Reading?
**តើខ្ញុំអាចទទួលប្រយោជន៍ជាច្រើនតាមរយៈការអានព្រះគម្ពីរជាប្រចាំថ្ងៃបានដោយរបៀបណា**
https://www.desiringgod.org/interviews/how-do-i-make-the-most-of-daily-bible-reading

# សំណួរទី១៧៖
# តើយើងអាចរកបានអត្ថន័យនៅក្នុងដំណើរនៃសាច់រឿងណាមួយបានយ៉ាងដូចម្តេច?

«ជម្រាបសួរលោកគ្រូ! វាគឺជាព្រះពរដល់ខ្ញុំក្នុងការទទួលបានចម្លើយដ៏ខ្លីៗ តាមរយៈការស្តាប់ ឬក៏អានអត្ថបទរបស់លោកគ្រូ ជាពិសេសទាក់ទងទៅនឹងសំណួរសំខាន់ៗសម្រាប់ជីវិតរបស់យើង។ ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងការយល់ពីដំណើរនៃសាច់រឿងណាមួយនៅក្នុងព្រះគម្ពីរ។ លោកគ្រូធ្លាប់បានលើកឡើងថា ការដែលលោកគ្រូបានចាប់ផ្តើមយល់អំពីរបៀបដែលអ្នកនិពន្ធព្រះគម្ពីររៀបរៀងការរែកញែក និងការយល់អំពីរបៀបនៃការរែកញែកនោះឲ្យបានត្រឹមត្រូវ នៅពេលអានព្រះគម្ពីរ នោះគឺជាអ្វីដែលបានបំផ្លាស់បំប្រែរបៀបនៃការដែលលោកគ្រូអានព្រះគម្ពីរយ៉ាងខ្លាំង ទាក់ទងទៅនឹងការយល់ពីអ្នកនិពន្ធ ដែលនេះមានន័យថា យើងក៏យល់អំពីគោលបំណងរបស់ព្រះជាម្ចាស់នៅក្នុងព្រះបន្ទូលរបស់ទ្រង់ដែរ។ ខ្ញុំយល់អំពីរបៀបនៃការធ្វើដូចនេះនៅក្នុងព្រះគម្ពីរសញ្ញាថ្មី និងនៅក្នុងកណ្ឌប្រាជ្ញា ដូចជាកណ្ឌសុភាសិតជាដើម។ ប៉ុន្តែ សំណួររបស់ខ្ញុំគឺទាក់ទងទៅនឹងការយល់ពីដំណើរនៃសាច់រឿងណាមួយ។ ក្រុមជំនុំខ្ញុំកំពុងតែសិក្សាកណ្ឌគម្ពីរ លូកា។ យើងដឹង និងយល់អំពីរបៀបដែលកណ្ឌមួយនេះបានរៀបរៀងឡើង ចុះចំណែកឯការយល់ពីដំណើរនៃសាច់រឿងណាមួយវិញ? តើមានចំណុចគន្លឹះខុសៗគ្នាដែលលោកគ្រូព្យាយាមរកដែរឬទេ? តើមានឈ្នាប់ផ្លាស់ប្តូរជាក់លាក់ ចំណុចសម្គាល់ ឬក៏គន្លឹះណាមួយដែលលោកគ្រូរកនៅក្នុងខគម្ពីរដែលរៀបរាប់អំពីដំណើររឿងទាំងនោះដែរទេ?

## ការឃើញអ្វីដែលអ្នកនិពន្ធកំពុងតែមានប្រសាសន៍

ខ្ញុំធ្លាប់បានផ្ដោតមើលអំពីរបៀបនៃការយល់នូវផ្នត់គំនិតរបស់អ្នកនិពន្ធយ៉ាងយកចិត្តទុកដាក់ ដើម្បីរកគោលបំណងដ៏ពិតរបស់គាត់។ ហើយខ្ញុំជឿថា គោលបំណងមូលដ្ឋាននៃការអានគឺ ដើម្បីស្វែងរកគោលបំណងរបស់អ្នកនិពន្ធ គឺរកនូវអ្វីដែលគាត់ព្យាយាមចង់ប្រាប់ដល់យើង។ សូមយល់ថា មានរបៀបខុសៗគ្នាជាច្រើននៃការធ្វើបែបនេះ ក្នុងការស្វែងរកគោលបំណងនោះនៅពេលដែលយើងអាន ដូចជាទទួលបានការកម្សាន្តនៅពេលអានព្រះគម្ពីរ។ ប៉ុន្តែ ប្រសិនបើគ្មានការស្វែងរកឥទ្ធិពលមូលដ្ឋាននៃគោលបំណងរបស់អ្នកនិពន្ធ នោះមានន័យថា យើងកំពុងបង្ហាញភាពឈ្លើយរបស់ខ្លួន ហើយយើងក៏កំពុងតែប្រព្រឹត្តចំពោះអ្នកនិពន្ធក្នុងរបៀបដែលយើងមិនចង់ឲ្យអ្នកផ្សេងប្រព្រឹត្តចំពោះយើង នៅពេលដែលយើងព្យាយាមប្រាប់អ្វីមួយ ហើយមានគេឆ្លើយតបថា «ខ្ញុំមិនខ្វល់ថាលោកអ្នកកំពុងតែព្យាយាមនិយាយអ្វីនោះទេ។ ខ្ញុំនឹងកាត់ស្រាយពាក្យសម្ដីរបស់លោកអ្នកទៅជារបៀបនេះ ឬក៏ជារបៀបនោះ តាមតែចិត្តរបស់ខ្ញុំ»។

ហើយក្នុងដំណើរការបែបនោះ គឺយើងនឹងបាត់បង់ឱកាសដ៏ធំក្នុងការលូតលាស់ជាមិនខាន។ ប្រសិនបើយើងមិនខ្វល់អំពីការរកឃើញនូវអ្វីដែលបុគ្គលម្នាក់ទៀតបានរកឃើញថា ជាការពិត ហើយយើងគ្រាន់តែបញ្ចូលគំនិតរបស់យើងលើអ្វីដែលគាត់បាននិពន្ធ នោះយើងនឹងមិនលូតលាស់ឡើយ។ ហើយកណ្ឌគម្ពីរ ២ពេត្រុស ៣:១៨ មានចែងថា «ចម្រើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា»។ ដូច្នេះ ខ្ញុំនឹងវែកញែកថា ចំណុចដ៏សំខាន់មួយនៃរបៀបនៃការរកគោលបំណងរបស់អ្នកនិពន្ធ និងការលូតលាស់ខាងឯចំណេះដឹង និងព្រះគុណ គឺដាច់ខាត យើងត្រូវតែយល់អំពីរបៀបវែកញែករបស់អ្នកនិពន្ធ។



ហើយតាមរយៈពាក្យ «វែកញែក» ខ្ញុំមិនមែនមានន័យថា យើង «ឈ្លោះគ្នា» នោះទេ។ ខ្ញុំយល់ថាពេលខ្លះគេប្រើប្រាស់ពាក្យ «វែកញែក» ខុសពីរបៀបដែលខ្ញុំប្រើប្រាស់នៅត្រង់នេះ។ អ្វីដែលខ្ញុំចង់មានន័យតាមរយៈពាក្យ «វែកញែក» គឺថាយើងយល់អំពីលំដាប់លំដោយនៃគំនិតពីការសាងសង់មូលដ្ឋានរហូតដល់ចប់។ ឧទាហរណ៍៖ កណ្ឌគម្ពីរ រ៉ូម ១:១៥-១៧ មានចែងដូចតទៅ (មានពាក្យ «ដ្បិត» ពីរដង និងពាក្យ «ពីព្រោះ» មួយដង)។

«ដូច្នេះ ឯខ្ញុំៗប្រុងប្រៀបតែនឹងប្រាប់ដំណឹងល្អមកអ្នករាល់គ្នា ដែលនៅក្រុងរ៉ូមដែរ ដ្បិតខ្ញុំគ្មាន សេចក្ដីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្ដានៃព្រះ សម្រាប់នឹងជួយ សង្គ្រោះដល់អស់អ្នកណាដែលជឿ... ដ្បិតសេចក្ដីសុចរិតនៃព្រះ បានសម្ដែងមកក្នុងដំណឹងល្អនោះ ដោយសារសេចក្ដីជំនឿ ហើយឲ្យបានសេចក្ដីជំនឿចម្រើនច្រើនឡើងផង»។

ខ្ញុំបានអានព្រះគម្ពីរអស់រយៈពេល២០ឆ្នាំមុនខ្ញុំរកឃើញអំពីរបៀបដែលសាវ័ក ប៉ុល សរសេរ។ នៅក្នុងខគម្ពីរប៉ុន្មាននេះ យើងឃើញថាមានប្រយោគដ៏សំខាន់ៗ និងធំៗ៤យ៉ាង។ ហើយចំណុចរបស់ខ្ញុំគឺថា លោកអ្នកមិនអាចយល់អំពីគោលបំណងរបស់សាវ័ក ប៉ុល បានទេ អំពីអ្វីដែលគាត់កំពុងតែព្យាយាមលើកឡើង លុះត្រាតែលោកអ្នកយល់អំពីទំនាក់ទំនងតក្កនៃការគិតរបស់គាត់រវាងប្រយោគទាំងបួននេះសិន។ ហើយរបៀបនៃការបង្ហាញរបស់សាវ័ក ប៉ុល ដែលយើងឃើញយ៉ាងច្បាស់លាស់ ក្នុងទំនាក់ទំនងនេះ គឺតាមរយៈការដែលគាត់ប្រើប្រាស់ពាក្យ «ដ្បិត» ពីរដង និង «ពីព្រោះ» មួយដង។ គាត់កំពុងតែរចនាការវែកញែកពីមូលដ្ឋានរហូតដល់ទីបញ្ចប់។

## តម្រុយនៅក្នុងដំណើររឿង

សំណួរដែលបានលើកឡើងគឺទាក់ទងទៅនឹងរបៀបលម្អិត ការផ្ដោតលើយ៉ាងខ្លាំងទៅលើតក្កនៃទំនាក់ទំនងនៃការគិតរវាងប្រយោគណាមួយ

ដែលទាក់ទងទៅនឹងរបៀបនៃការកាត់ស្រាយលើដំណើរនៃសាច់រឿងធំណាមួយនៅក្នុងព្រះគម្ពីរ ឬក៏ដំណើររឿងទាំងមូលនៅក្នុងព្រះគម្ពីរ។ ហើយអ្នកសួរក៏អាចទំនងជាសួរបន្ថែមទៀតថា៖ «តើរបៀបនៃការធ្វើដូចនេះទាក់ទងទៅនឹងកណ្ឌគម្ពីរកំណាព្យ រឿងប្រៀបប្រដូច។ល។ បានដោយរបៀបណា?» ព្រឹត្តិការណ៍ដែលបានចងចូលគ្នាក្នុងរបៀបជាក់លាក់ណាមួយ—ហើយនេះជាអ្វីដែលខ្ញុំមានន័យលើដំណើរនៃសាច់រឿងណាមួយ។ តើយើងគួរព្យាយាមស្វែងរកគោលបំណងរបស់អ្នកនិពន្ធក្នុងរបៀបដូចគ្នាមែនឬ?

ហើយចម្លើយរបស់ខ្ញុំគឺថា៖ មែនហើយ បើយោងតាមគោលការណ៍។ ប៉ុន្តែ ទាក់ទងទៅនឹងចំណុចលម្អិតនៃរបៀបដែលអ្នកនិពន្ធបានបង្ហាញគោលបំណងរបស់គាត់ គឺយើងត្រូវប្រយ័ត្នដោយព្យាយាមស្វែងរកចំណុចផ្សេងទៀត ក្រៅពីការគ្រាន់តែផ្តោតលើធ្នាក់មួយទៅធ្នាក់មួយទៀត ដោយមានតក្កភ្ជាប់មួយក្នុងចន្លោះ ទោះបីដំណើរនៃសាច់រឿងណាមួយមិនកើតឡើងដូច្នោះក៏ដោយ។ ប៉ុន្តែ អ្នកនិពន្ធព្រះគម្ពីរបានសរសេរចុះដំណើរនៃសាច់រឿងណាមួយដោយមានហេតុផល។ ពួកគាត់កំពុងតែព្យាយាមប្រាប់នូវចំណុចណាមួយមកកាន់យើង។ ហើយពួកគាត់ក៏ចង់ឲ្យយើងរកឃើញចំណុចនោះដែរ។

កាលខ្ញុំសរសេរសៀវភៅមួយមានចំណងជើងជាភាសាអង់គ្លេសថា "Reading the Bible Supernaturally" (ដែលប្រែជាភាសាខ្មែរថា «ការអានព្រះគម្ពីរបែបអធិធម្មជាតិ») ខ្ញុំបានឃើញចំណុចដ៏អស្ចារ្យជាច្រើន។ កាលនោះគឺជាលើកដំបូងដែលខ្ញុំបានឃើញ។ របៀបរិះគន់ដ៏ចម្បងមួយរបស់ព្រះយេស៊ូវអំពីពួកផារិស៊ីគឺថា ពួកគាត់មិនចេះរបៀបអានឡើយ។ ខ្ញុំគិតថា ការរិះគន់នេះទំនងជាបានធ្វើឲ្យពួកគេឈឺចាប់ចាប់ខ្លាំង ព្រោះដូចដែលយើងដឹងហើយថា ពួកគេគឺជាអ្នកអាន។ ព្រះអង្គបានលើកឡើងម្តងហើយម្តងទៀតថា «តើអ្នករាល់គ្នាមិនដែលមើលរឿង...ទេឬអី?» (ម៉ាថាយ ១២:៣; ២២:៣១)។ ហើយទំនងពួកគេកំពុងតែអេះក្បាល ហើយតបវិញថា «ការងាររបស់យើងគឺជាការអាន!»។ ពិតណាស់ ពួកគាត់បានអានមែន។ ដូច្នេះ តើព្រះយេស៊ូវកំពុងមានន័យយ៉ាងដូចម្តេច? ព្រះអង្គកំពុងតែមានន័យថា ពួកគាត់បានអានមែន ប៉ុន្តែមិនបានយល់ទេ ហើយបានមើលមែន ប៉ុន្តែមិនបានឃើញទេ។

និយាយម៉្យាងវិញទៀត មានគោលបំណងពិតៗរបស់អ្នកនិពន្ធ ដែលព្រះវិញ្ញាណបរិសុទ្ធបានបណ្តាលឲ្យតែង កំពុងតែចង់លើកឡើងថា—ក្នុងករណីនេះ គឺសំដៅទៅលើអ្នកនិពន្ធព្រះគម្ពីរសញ្ញាចាស់ដែលពួកផារិស៊ីអានជាប្រចាំថ្ងៃ—មិនថាអានដោយយកចិត្តទុកដាក់ ដោយបកស្រាយអត្ថន័យពីមួយឃ្លាទៅមួយឃ្លា ឬក៏ថាកំពុងអានកណ្ឌគម្ពីរកំណាព្យ អានដំណើររឿងណាមួយ ប៉ុន្តែអ្វីដែលកំពុងតែកើតឡើងនោះគឺថា ពួកផារិស៊ីទាំងនោះមិនយល់អ្វីទាល់តែសោះ។ នោះគឺជាអ្វីដែលកំពុងតែធ្វើឲ្យព្រះយេស៊ូវខកព្រះទ័យ។

ដូច្នេះ ចម្លើយគឺថា មែនហើយ ក្នុងគ្រប់កណ្ឌ គឺយើងត្រូវតែព្យាយាមស្វែងរកគោលបំណងចម្បងៗរបស់អ្នកនិពន្ធ—ការនិពន្ធឡើងទាំងអស់សុទ្ធតែមានតម្លៃ។ មែនហើយ យើងគួរតែព្យាយាមស្វែងរកតម្រុយទាំងអស់ដែលអ្នកនិពន្ធបានផ្តល់ដល់យើង ហើយអ្នកនិពន្ធល្អៗតែងតែផ្តល់តម្រុយ ដើម្បីជួយយើងឲ្យរកឃើញអ្វីដែលគាត់កំពុងតែព្យាយាមប្រាប់យើង។ តម្រុយទាំងនោះទាក់ទងទៅនឹងដំណើរនៃសាច់រឿងណាមួយទំនងជាអាចពាក់ព័ន្ធទៅនឹងការលើកឡើងនូវចំណុចដដែលៗម្តងហើយម្តង ឬក៏ទាក់ទងទៅនឹងដំណាក់កាលនៃព្រឹត្តិការណ៍ដែលបានកើតឡើង ឬក៏ថាតើការសន្ទនាកំពុងតែលើកឡើងនូវចំណុចពិតអ្វី ឬក៏គាត់អាចលើកឡើងអំពីលទ្ធផលនៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ ឬក៏ថាគាត់សរសេរបញ្ចូលការកាត់ស្រាយផ្ទាល់តែម្តង។ល។

## លោក យ៉ូសែប និងសាច់រឿងដែលមានជាច្រើនផ្នត់

សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវឧទាហរណ៍មួយចំនួនអំពីដំណើររឿងដ៏ល្អបំផុតមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ខ្ញុំកំពុងគិតអំពីលោក យ៉ូសែប ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក៣៧-៥០។ អ្នកខ្លះបានលើកឡើងថា ដំណើររឿងមួយនេះគឺជាដំណើររឿងដ៏ខ្លីល្អបំផុតមួយដែលធ្លាប់បានសរសេរចុះ ប្រសិនបើយើងចង់ដាក់វាចូលក្រោមចំណាត់ថ្នាក់ណាមួយ។  នេះគឺជាដំណើររឿងដែលពិតជារន្ធត់ណាស់ ហើយលោកអ្នកទំនងជាឆ្ងល់ថា៖ តើកំពុងមានអ្វីកើតឡើងនៅក្នុងវគ្គនេះ? តើអ្វីទៅជាចំណុចគោលនៅក្រោយដំណើររឿងនេះ?

មាន១៤ជំពូកសរុបដែលរៀបរាប់អំពី  សុបិន្តរបស់លោក  យ៉ូសែប ការស្អប់របស់បងៗ ការដែលបងៗបានលក់គាត់ធ្វើជាទាសករ ការដែលគាត់កាន់តែធ្លាក់ចូលការរងទុក្ខដោយសារប្រពន្ធរបស់លោក ប៉ូទីផារ បាននិយាយមួលបង្កាច់អំពីគាត់—ហើយបន្ទាប់មកគេបានដាក់គុកគាត់ ហើយគេក៏បានភ្លេចគាត់នៅក្នុងគុកដែរ។ ហើយបន្ទាប់មក គាត់ក៏បានក្លាយជាអ្នកដឹកនាំ ដែលមានឋានៈបន្ទាប់ពីស្តេច ផារ៉ោន នៅស្រុកអេស៊ីព្ទ ហើយតាមរយៈការនោះព្រះជាម្ចាស់ក៏បានរក្សារាស្ត្ររបស់ទ្រង់ពីគ្រោះទុរភិក្ស និងការពារខ្សែតំណនៃរាជវង្សព្រះមេស្ស៊ី។ នោះគឺជាអ្វីដែលកំពុងតែកើតឡើង!

ហើយក៏នៅមានផ្នត់គំនិតបន្ទាប់បន្សំមួយចំនួនទៀតនៃគោលបំណងរបស់អ្នកនិពន្ធក្នុងដំណើររឿងនេះដែរ។ ខ្ញុំចង់លើកទឹកចិត្តឲ្យលោកអ្នកឈប់គិតថា នៅពេលដែលលោកអ្នកអានដំណើរនៃសាច់រឿងណាមួយនោះលោកអ្នកនឹងទទួលបាននូវផ្ទាំងទស្សនីយភាពធំ ឬក៏ចំណុចចម្បងធំណាមួយនោះឡើយ។ ពិតណាស់ យើងក៏ត្រូវទទួលបានចំណុចចម្បងណាមួយមែនដែរ។ វាទំនងជាអាចនឹងគ្រប់គ្រងលើចំណុចតូចៗផ្សេងទៀតបានមែន ប៉ុន្តែសូមចងចាំថា ក៏នៅមានចំណុចតូចៗមួយចំនួនផ្សេងទៀតដែល



អ្នកនិពន្ធបានលើកឡើងក្នុងដំណាក់កាលផ្សេងៗនៃដំណើររឿងនោះដែរ។

## រឿងប្រៀបប្រដូចក្នុងព្រះគម្ពីរ

តោះ! ចូរចាប់ផ្តើមជាមួយនឹងរូបភាពធំនៃដំណើររឿងមួយនេះ។ ខ្ញុំគិតថា នៅពេលដែលលោក ម៉ូសេ សរសេរកណ្ឌគម្ពីរលោកុប្បត្តិ គឺគាត់មិនបានលាក់ទុកឲ្យយើងឆ្ងល់អំពីគោលបំណងចម្បងធំនៃដំណើររឿងនោះទេ។ គាត់បានបង្ហាញឲ្យយើងឃើញអំពីចំណុចយ៉ាងច្បាស់លាស់ពីរទៅបីដងតាមរយៈប្រយោគសង្ខេបៗអំពីអ្វីដែលគាត់កំពុងតែរៀបរាប់។ ឧទាហរណ៍៖ លោក យ៉ូសែប បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៤៥:៧-៨ ដូចតទៅ៖

«ព្រះទ្រង់បានចាត់ខ្ញុំឲ្យមកមុនអ្នករាល់គ្នា ដើម្បីនឹងរក្សាអ្នករាល់គ្នាឲ្យមានសំណល់សល់នៅផែនដី ហើយនឹងជួយសង្គ្រោះជីវិតនៃអ្នករាល់គ្នា ដោយសេចក្តីប្រោសប្រាណយ៉ាងធំ ដូច្នេះ មិនមែនអ្នក រាល់គ្នាដែលឲ្យខ្ញុំមកទីនេះទេ គឺជាព្រះវិញទេតើ ទ្រង់បានតាំងខ្ញុំទុកជាឪពុកដល់ផារ៉ោនជាម្ចាស់ លើដំណាក់ទ្រង់ទាំងអស់ ហើយជាចៅហ្វាយត្រួតត្រាលើស្រុកអេស៊ីព្ទទាំងមូលផង»។

បើនិយាយម្យ៉ាងវិញទៀត ព្រឹត្តិការណ៍ដែលមើលទៅហាក់បីដូចជាថាមនុស្សយើងជាតួអង្គដែលកំពុងតែធ្វើ ដែលយើងកំពុងតែអានអំពីជំពូកទាំង១៤ដំបូង ទោះបីមានរួមទាំងព្រឹត្តិការណ៍ដែលពេញទៅដោយអំពើបាបក៏ដោយ ក៏ជាព្រះដែលពេញទៅដោយអធិបតេយ្យភាព ដែលកំពុងតែគ្រប់គ្រងលើព្រឹត្តិការណ៍ទាំងនោះ ដោយព្រះអង្គបានចាត់អ្នកតំណាងទ្រង់ តាមរយៈទង្វើដែលមានពេញដោយអំពើបាបឲ្យទៅស្រុកអេស៊ីព្ទ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់។ នេះគឺពិតជាឆ្លូតមែន។ ហើយនេះពិតជារឿងអស្ចារ្យមែន។ នេះស្ទើរតែស្មើនឹងអត្ថន័យនៃរឿងប្រៀបប្រដូចនៅក្នុងព្រះគម្ពីរ។

ហើយបន្ទាប់មកនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៥០:២០ លោក យ៉ូសែប បាននិយាយទៅកាន់បងៗរបស់គាត់ដូចតទៅថា៖ «អ្នករាល់គ្នាបានគិតធ្វើអាក្រក់ដល់ខ្ញុំ តែព្រះទ្រង់សម្រេចជាការល្អវិញ ដើម្បីនឹងសង្គ្រោះដល់ជីវិតនៃមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ»។ ខ្ញុំគិតថា នៅពេលដែលលោកអ្នកអានខគម្ពីរមួយនេះ នោះលោកអ្នកចាំបាច់ត្រឡប់ទៅអានដំណើររឿងនោះម្តងទៀត ដើម្បីអានដំណើររឿងនោះម្តងទៀត ពីព្រោះឥឡូវនេះលោកអ្នកឃើញអំពីគោលបំណងរបស់អ្នកនិពន្ធហើយ។ ហើយលោកអ្នកទំនងជាលើកឡើងថា «អូ នេះគឺជាទិសដៅដែលដំណើររឿងនោះកំពុងតែតម្រង់ទៅ»។ ហើយលោកអ្នកអាចអានដំណើររឿងម្តងទៀត ដោយនឹកចាំអំពីតម្រុយរឿងនេះ «ដំណាក់កាលនៃដំណើររឿង ក្នុងចំណុចនេះ មានន័យយ៉ាងដូច្នេះ ហើយវាក៏កំពុងតែតម្រង់ទៅចំណុចនោះផងដែរ»។ ភ្លាមៗនោះលោកអ្នកនឹងអាចឃើញព្រះហស្តរបស់ព្រះជាម្ចាស់យ៉ាងច្បាស់លាស់បាន។

សរុបសេចក្តីទៅ រូបភាពធំគឺថា អំពើបាបរបស់មនុស្សអំពីរាស្ត្ររបស់ទ្រង់ ឬក៏អំពើបាបរបស់មនុស្សទាស់ប្រឆាំងនឹងរាស្ត្ររបស់ទ្រង់មិនគ្រាន់តែមិនបង្អាក់ផែនការនៃការសង្គ្រោះរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងនាំឲ្យដំណើរការនៃផែនការនៃការសង្គ្រោះនោះដំណើរការទៅមុខទៀត។ វាគឺជាផ្នែកមួយនៃផែនការរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះរាស្ត្ររបស់ទ្រង់ ហើយនៅចុងបញ្ចប់ក៏នឹងចាត់ឲ្យព្រះមេស្ស៊ីយាងមកផែនដីនេះ តាមរយៈខ្សែស្រឡាយនោះដែរ។ ហើយលោក ម៉ូសេ បានផ្តល់នូវតម្រុយក្នុងដំណាក់កាលនីមួយៗនៃដំណើររឿងដល់យើង ហើយគាត់ក៏បានលើកប្រយោគពន្យល់ដ៏ធំមួយ នៅចុងបញ្ចប់ទៀតផង។

## «ព្រះយេហូវ៉ាទ្រង់គង់នៅជាមួយនឹងគាត់»

ប៉ុន្តែ នៅមានតម្រុយផ្សេងទៀត ទាក់ទងទៅនឹងអត្ថន័យ និងអត្ថន័យ



បន្ទាប់បន្សំក្រៅពីប្រយោគកាត់ស្រាយដ៏ច្បាស់លាស់នៅចុងក្រោយ។ នៅក្នុងដំណាក់កាលនៃដំណើររឿង លោក ម៉ូសេ បានត្បាញកាលៈទេសៈដែលកាន់តែអាក្រក់ៗចូលគ្នាជាមួយនឹងពាក្យពេចន៍ដែលមានការលើកទឹកចិត្តផងដែរ។ គេបានបោះលោក យ៉ូសែប ចូលគុក។ បងៗរបស់គាត់បានលក់គាត់ឲ្យធ្វើជាទាសករ។ គាត់នៅស្រុកអេស៊ីព្ទដែលនៅឆ្ងាយពីស្រុកកំណើត។ ប្រពន្ធរបស់លោក បូទីផារ បាននិយាយបង្ខូចអំពីគាត់។ គេក៏បានភ្លេចអំពីគាត់ ខណៈពេលដែលគាត់កំពុងជាប់គុក។ មើលទៅហាក់បីដូចជា គាត់កាន់តែធ្លាក់ដុនដាបទៅៗ—បើយើងចង់គូសក្រាហ្វិកលើដំណើររឿងនេះ ហើយសភាពនៃដំណើររឿងនេះក៏មានភាពស៊ីគ្នាជាមួយនឹងជីវិតយើងជាច្រើននាក់ដែរ។ ខ្ញុំបានគូសក្រាហ្វិកអំពីដំណើររឿងនេះ ក្នុងការបង្ហាញក្រុមជំនុំយើង។ ហើយនៅពេលដែលខ្ញុំកំពុងតែគូស ខ្ញុំក៏បានសួរដែរថា «តើបងប្អូនកំពុងស្ថិតនៅក្នុងដំណាក់កាលមួយណា ទាក់ទងទៅនឹងចំណុចអាក្រក់ៗដែលកំពុងតែកើតឡើងនៅក្នុងជីវិត ដែលកាន់តែធ្លាក់ចុះដុនដាបទៅក្នុងកាលៈទេសៈដែលពេញទៅដោយទុក្ខព្រួយក្នុងជីវិតនេះ?»។ ហើយនៅក្នុងដំណាក់កាលចុងក្រោយ មើលទៅហាក់បីដូចជាថា ព្រះជាម្ចាស់ក៏បានភ្លេចគាត់ដែរ។ តើកំពុងមានអ្វីកើតឡើង? ចម្លើយគឺថា នៅពេលដែលយើងកំពុងតែអាន គឺយើងត្រូវតែយល់អំពីហេតុការណ៍នោះក្នុងរបៀបនេះដូច្នោះសិន។

ប៉ុន្តែ ក្នុងដំណាក់កាលនីមួយៗនៃដំណើររឿង លោក ម៉ូសេ បានលើកឡើងនូវប្រយោគខ្លះៗដូចនេះ «ព្រះយេហូវ៉ាទ្រង់គង់នៅជាមួយនឹងគាត់... ព្រះយេហូវ៉ាទ្រង់ធ្វើឲ្យគ្រប់ការទាំងអស់បានកើតឡើងដោយសារដៃគាត់» (លោកុប្បត្តិ ៣៩:៣)។ ឬក៏ក្នុងកន្លែងមួយទៀត គាត់បានសរសេរថា «តែព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងយ៉ូសែប ហើយក៏ផ្តល់សេចក្តីសប្បុរសដល់គាត់ ព្រមទាំងធ្វើឲ្យមេភូមិឃុំអាណិតមេត្តាដល់គាត់ផង» (លោកុប្បត្តិ

៣៩:២១)។ យើងទទួលបានតម្រុយដូចនេះ ក្នុងដំណាក់កាលនីមួយៗនៃដំណើររឿង ទោះបីពេលមើលទៅហាក់បីដូចជាថា គ្រប់អ្វីៗទាំងអស់កំពុងកាន់តែអាក្រក់ទៅៗសម្រាប់លោក យ៉ូសែប ក៏ដោយ ហើយនេះក៏មិនមែនដោយសារអំពើបាបរបស់គាត់ដែរ។ គាត់មិនបានធ្វើអ្វីមួយ ដើម្បីនាំឲ្យរឿងនោះកើតឡើងចំពោះខ្លួនឯងឡើយ។ ហើយក៏មិនមែនដោយសារព្រះជាម្ចាស់បានបោះបង់គាត់ចោលដែរ—ប៉ុន្តែ គឺដោយសារគោលបំណងអាថ៌កំបាំងរបស់ព្រះជាម្ចាស់វិញ។ ហើយខណៈពេលដែលយើងកំពុងតែអាន យើងក៏ចង់ដឹងផងដែរថា តើអ្វីទៅជាគោលបំណងនោះ? ឱព្រះអង្គអើយ ព្រះអង្គបានលើកឡើងថា ទ្រង់នៅខាងគាត់ ប៉ុន្តែនៅពេលដែលទូលបង្គំអាន មើលទៅហាក់បីដូចជាថា ព្រះអង្គកំពុងតែជំទាស់នឹងគាត់វិញ។

## សាច់រឿងនៅក្នុងសាច់រឿង

ខ្ញុំចង់លើកឡើងឧទាហរណ៍មួយទៀត អំពីរបៀបដែលអ្នកនិពន្ធបានផ្ដល់ជូនគោលបំណងរបស់គាត់ដល់យើង ហើយនេះគឺជារឿងមួយដែលពិបាកយល់ជាងគេបំផុតចំពោះខ្ញុំ ក្នុងដំណើររឿងទាំងមូល។ មើលទៅហាក់បីដូចជាថា រឿងនៅក្នុងជំពូក៣៨កំពុងតែនិយាយកាត់ដំណើររឿងទាំងមូល។ ដំណើររឿងរបស់លោក យ៉ូសែប បានចាប់ផ្ដើមនៅក្នុងជំពូក៣៧ អំពីសុបិន្ត និងការដែលពួកបងៗបានលក់គាត់ឲ្យធ្វើជាទាសករនៅស្រុកអេស៊ីព្ទ—ហើយភ្លាមនោះ—លោក ម៉ូសេ ក៏បានសរសេរបញ្ចូលជំពូក៣៨ (ស្ទើរតែក្រោយរំពេចដែលដំណើររឿងធំទើបតែបានចាប់ផ្ដើម) ឲ្យមើលទៅពុំមានការទាក់ទងគ្នាសោះ។ ជំពូកនេះបានលើកឡើងអំពីរឿងដែលគួរឲ្យចម្លែកអំពីលោក យូដា ដែលត្រូវជាបងច្បងរបស់លោក យ៉ូសែប។ លោក យូដាបានដេកជាមួយកូនប្រសាស្រីរបស់គាត់ ហើយនាំឲ្យនាងមានផ្ទៃពោះ ដោយបានគិតថានាងគាត់ជាស្រីសំផឹង។ សំណួររបស់ខ្ញុំសម្រាប់លោក ម៉ូសេ គឺ



ថា៖ តើកំពុងមានអ្វីកើតឡើងនៅក្នុងជំពូកនេះ ហើយហេតុអ្វីបានចាំបាច់ត្រូវសរសេរអំពីរឿងនេះ? បើដាក់ជំពូកនោះមុនជំពូក៣៧ នោះវានឹងមិនរំខានដល់ ដំណើររឿងឡើយ។ ហេតុអ្វីបានត្រូវជាចាំបាច់រំខានដំណើររឿងដោយដាក់ជំពូក៣៨ដូច្នេះ?

នេះគឺជាយោបល់របស់ខ្ញុំ ហើយខ្ញុំក៏ចង់ដឹងផងដែរថា តើយោបល់នេះត្រឹមត្រូវ ឬក៏អត់។ បន្ទាប់ពីយើងបានអានអំពីការធ្លាក់ក្នុងអំពើអសីលធម៌ដ៏អាក្រក់របស់លោក យូដា នៅក្នុងជំពូក៣៨—បន្ទាប់គឺដំណើររឿងរបស់លោក យ៉ូសែប—គឺដំណើររឿងអំពីការដែលលោក យ៉ូសែប ជ្រើសរើសផ្លូវដ៏ត្រឹមត្រូវ ហើយអស្ចារ្យទាក់ទងទៅនឹងទំនាក់ទំនងខាងផ្លូវភេទជាមួយនឹងប្រពន្ធលោក ប៉ូទីផារ ដែលបានព្យាយាមបង្ខំលោក យ៉ូសែប ឲ្យដេកជាមួយគាត់។ ហើយលោក ម៉ូសេ ក៏បានសរសេរនូវពាក្យពេចន៍នេះផងដែរ៖ «ធ្វើដូចម្ដេចឲ្យខ្ញុំប្រព្រឹត្តការ ដែលអាក្រក់យ៉ាងធំនេះទៅបាន ធ្វើយ៉ាងនោះនឹងមានបាបនៅចំពោះព្រះផង» (លោកុប្បត្តិ ៣៩:៩)។ ដូច្នេះ ខ្ញុំគិតថា លំដាប់លំដោយនៃដំណើររឿង ដោយមានការសរសេរបញ្ចូលអំពីការធ្លាក់ក្នុងអំពើអសីលធម៌របស់លោកយូដា មុនភាពស្អាតស្អំរបស់លោក យ៉ូសែប ដែលគាត់បានឆ្លើយតបក្នុងរបៀបដ៏ស្រស់ស្អាត និងពេញទៅដោយប្រសិទ្ធភាព ដែលនាំឲ្យយើងមានការភ្ញាក់ផ្អើល ទាក់ទងទៅនឹងក្រមសីលធម៌ដ៏ស្អាតស្អំរបស់គាត់ គឺដើម្បីលើកឡើងឲ្យច្បាស់លាស់អំពីចំណុចខុសគ្នារវាងភាពមិនស្មោះត្រង់របស់លោក យូដា និងភាពស្អាតស្អំរបស់លោក យ៉ូសែប ផ្នែកផ្លូវភេទ។ ដែលនេះបង្ហាញក្នុងរបៀបដ៏សាមញ្ញថា អាចមានចំណុចគោលៗបាននៅក្នុងដំណើរនៃសាច់រឿងធំ ហើយក៏នៅអាចមានចំណុចគោលៗបន្ទាប់បន្សំនៅក្នុងដំណើរនៃសាច់រឿងតូច ដែលយើងគួរតែកត់សម្គាល់ឃើញដែរ។

## សូមបន្តមើលទៀត

ដូច្នេះ ក្នុងការឆ្លើយតបនូវសំណួរខាងលើ៖ មិនថាយើងកំពុងតែអានសំបុត្ររបស់សាវ័ក ប៉ុល ដែលមានការវែកញែកយ៉ាងច្បាស់លាស់ ឬក៏ថាយើងកំពុងតែអានដំណើរនៃសាច់រឿងដែលមាន១៤ជំពូកក៏ដោយ ក៏យើងត្រូវតែព្យាយាមស្វែងរកនូវគោលបំណងដែលអ្នកនិពន្ធចង់ប្រាប់មកកាន់យើងដែរ។ ហើយយើងស្វែងរកតម្រុយដូចនោះដែលគាត់បានលើកឡើងសម្រាប់យើង មិនថានៅក្នុងសំបុត្របែបសេចក្ដីអធិប្បាយតាមព្រះបន្ទូល ឬក៏ក្នុងដំណើររឿងនៃសាច់រឿងណាមួយឡើយ គឺដើម្បីឲ្យចំណុចទាំងនោះជួយឲ្យយើងឃើញគោលបំណងរបស់អ្នកនិពន្ធ។

ខ្ញុំចង់បញ្ចប់ដោយលើកឡើងថា ខណៈពេលដែលខ្ញុំកាន់តែអាន ដោយមានគោលបំណងក្នុងការស្វែងរកតម្រុយ ឬក៏គោលបំណងដែលអ្នកនិពន្ធបានផ្ដល់ឲ្យយើង នោះយើងនឹងកាន់តែឃើញវាច្បាស់លាស់ថែមទៀតជាមិនខាន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How Do You Find Meaning in the Bible’s Narratives?
**តើយើងអាចរកបានអត្ថន័យនៅក្នុងដំណើរនៃសាច់រឿងណាមួយបានយ៉ាងដូចម្ដេច?**
https://www.desiringgod.org/interviews/how-do-you-find-meaning-in-the-bibles-narratives



# សំណួរទី១៨៖
# របៀបនៃអានព្រះគម្ពីរសម្រាប់ក្មេងៗវ័យជំទង់

នេះគឺជាសំណួរដ៏អស្ចារ្យមួយពីលោកឪពុកម្នាក់របស់ក្មេងៗវ័យជំទង់ដែលលោកមានឈ្មោះថា សាន ។ លោកពូ សាន គឺជាដៃគូរបំរើពន្ធកិច្ចយើង ហើយថ្មីៗនេះលោកពូ និងប្រពន្ធរបស់គាត់បានចូលរួមកម្មវិធីមួយជាមួយយើង។

បន្ទាប់ពីកម្មវិធីនោះមក លោកពូបានសរសេរមកសួរយើងបែបដូច្នេះថា «ជម្រាបសួរលោកគ្រូ! តាមរយៈ ការមើលការបង្រៀនរបស់លោកគ្រូទាក់ទងនិងការសិក្សា ដើម្បីវិភាគលើបទគម្ពីរ ការនោះពិតជាបានលើកទឹកចិត្តដល់ព្រលឹងវិញ្ញាណ និងការសិក្សាព្រះគម្ពីររបស់ខ្ញុំផ្ទាល់ណាស់។ សូមអរគុណច្រើន! ទោះជាយ៉ាងនេះក្ដី នៅពេលយើងសម្លឹងមើលទៅលើការធ្វើការបង្កើតសិស្សដល់ពួកកូនៗវ័យជំទង់របស់យើងនៅផ្ទះ យើងមានអារម្មណ៍ថា យើងមិនពូកែគ្រប់គ្រាន់ក្នុងការពន្យល់ព្រះបន្ទូលក្នុងរបៀបនេះទេ ហើយបារម្ភថា យើងមានចំណុចខ្វះខាតទាក់ទងលើចំណុចនេះ ឬយ៉ាប់ជាងនេះទៀត យើងអាចនឹងបង្រៀនពួកគេមិនបានត្រឹមត្រូវក៏ថាបាន។ ក្នុងការបង្ហាត់បង្រៀនដល់កុមារៗ តើលោកគ្រូណែនាំឲ្យប្រើប្រាស់វិធីសាស្ត្រដូចគ្នា ដែលលោកគ្រូបានធ្វើដូចនៅក្នុងថ្នាក់វិភាគបទគម្ពីរដែរឬទេ? ឬក៏លោកគ្រូណែនាំឲ្យប្រើវិធីសាស្ត្រផ្សេងទៀតក្រៅពីនេះ? តើឪពុកម្ដាយរបស់ក្មេងៗវ័យជំទង់ អាចបង្ហាត់បង្រៀនដល់កូនៗរបស់ពួកគេដោយរបៀបណា ដើម្បីឲ្យដូចជាអ្វីដែលបានបង្រៀននៅថ្នាក់វិភាគលើបទគម្ពីរ?»

## ការបង្កើតបរិយាកាស

សម្រាប់ខ្ញុំ រឿងដំបូងដែលឪពុកម្ដាយត្រូវពិចារណានោះគឺថា ក្នុង

បរិយាកាសដែលយើងបានបង្កើតឡើងនៅក្នុងក្រុមគ្រួសារ ឬក្រុមជំនុំ ដែលជាកន្លែងមានការបង្រៀនបែបនេះ តើយើងបានបង្កើតឡើងក្នុងរបៀបដែលស័ក្តិសមដល់មនុស្សមានវ័យក្មេងឬក៏អត់?

ខ្ញុំគិតថា យើងគួរតែព្យាយាមបង្រៀនយុវជនរបស់យើង ប៉ុន្តែយើងត្រូវផ្តើមដោយសួរសំណួរនេះវិញថា តើយើងបានបង្កើតបរិយាកាសហើយឬនៅ? អ្វីដែលខ្ញុំចង់សំដៅនោះគឺ តើគ្រួសារធ្លាប់ធ្វើការចំណាយពេលវេលាផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់ហើយឬនៅ ដែលធម្មតារួមមានការអានព្រះបន្ទូល និងការអធិស្ឋាន? បើសិនធ្លាប់ធ្វើបែបនេះមែន វាប្រហែលជាមានអារម្មណ៍ថាឆ្គងៗ ឬចម្លែកៗ បើភ្លាមៗយើងស្រាប់តែបង្វែរពេលវេលាបែបនេះនៅក្នុងគ្រួសាររបស់យើងឲ្យទៅជាបរិយាកាសក្នុងថ្នាក់រៀនដោយមានកិច្ចការផ្ទះ និងសំណួរផ្សេងៗជាដើម។ល។

សម្រាប់ខ្ញុំ គ្រប់គ្រួសារទាំងអស់ត្រូវតែឯកភាពគ្នាជាមួយនឹងរឿងនេះ។ តើយើងអាចបង្កើតពេលវេលា ឬបរិយាកាសមួយនៅក្នុងគ្រួសារ ឬនៅក្នុងពួកជំនុំដោយការប្រកបគ្នាជាមួយយុវជនទាំងឡាយ នៅកន្លែងដែលមានស្ថានភាពដូចនៅក្នុងថ្នាក់រៀន ដោយមានការរំពឹងទុកយ៉ាងហ្មត់ចត់ មានសំណួរនិងចម្លើយទាំងឡាយ ហើយនិងការវិភាគនានា និងកិច្ចការផ្ទះជាដើម ឲ្យមានអារម្មណ៍ធម្មតា ឬឲ្យមានការរំភើបកើតឡើងបានដែរឬទេ? នោះត្រូវតែធ្វើការបណ្តុះផ្នត់គំនិតឡើង។

វគ្គបង្រៀនទាំងនេះ សំដៅទៅការបណ្តុះបណ្តាលជំនាញមួយ ដូចជាការដែលលោកអ្នកបណ្តុះបណ្តាលជំនាញចំអិនអាហារដល់កូនម្នាក់ក្នុងចំណោមកូនៗរបស់លោកអ្នក ឬជំនាញច្រូតស្រូវ ឬការព្យាយាមគួចចំណងមួយទៅនឹងផ្លែសន្ទូច ដូច្នេះនៅពេលត្រីធំស៊ីផ្លែសន្ទូច នោះវានឹងមិនរបូតចេញឡើយ។

ចំណុចសំខាន់នោះ គឺមិនមែនគ្រប់ពេលទាំងអស់នៃវគ្គទាំងនេះ លោក



អ្នកនឹងទទួលបានបទពិសោធន៍យ៉ាងរីករាយបំផុតនៃការរកឃើញនូវអ្វីដែលថ្មីរហូតទេ ព្រោះក្រោយមកលោកអ្នកនឹងត្រូវញ៉ាំអាហារ លោកអ្នកនឹងមើលវាលស្រែដ៏ល្អល្អេវ ដែលទើបនឹងច្រូតកាត់រួច ហើយលោកអ្នកអាចស្ទូចត្រីបានដោយមិនចាំបាច់បាត់បង់ផ្លែសន្ទូចរបស់លោកអ្នកទេ។ លោកអ្នកនឹងព្យាយាមបណ្តុះបណ្តាលជំនាញមួយសម្រាប់ពេញមួយជីវិតដល់កូនៗ ហេតុនេះហើយឪពុកម្តាយចាំបាច់ត្រូវតែឯកភាពនឹងសំណួរមួយនេះថា តើខ្ញុំអាចបង្កើតបរិយាកាសមួយនៅក្នុងគ្រួសារឲ្យទៅជាកន្លែងមួយដែលបង្រៀនជំនាញផ្សេងៗឲ្យកើតឡើងបានដែរឬទេ?

## ទម្លាប់នៃគំនិតនិងដួងចិត្ត

បន្ទាប់មក នៅពេលលោកអ្នកបានឯកភាពគ្នាហើយ ខ្ញុំសង្ឃឹមថាលោកអ្នកនឹងអាចឯកគ្នាបាន ដូច្នេះសំណួរដែលត្រូវសួរនោះគឺ តើលោកអ្នកនឹងធ្វើអ្វីជាមួយនឹងពេលវេលានោះ? នេះគឺជាការណែនាំមួយ។

អ្វីដែលជាការណែនាំដល់ការផ្តល់មតិរបស់ខ្ញុំនៅទីនេះគឺ គោលដៅនៃការបង្រៀននេះ គឺជាទម្លាប់ នៃគំនិតនិងដួងចិត្តពេញមួយជីវិត ដើម្បីចូលទៅឲ្យជិតបទគម្ពីរតាមរបៀបជាក់លាក់មួយ។ ម្យ៉ាងទៀត ការដែលអាចធ្វើតាមរបៀបជាក់លាក់ណាមួយមិនមែនជាគោលដៅនោះឡើយ។ ការព្យាយាមធ្វើតាមបទ ពិសោធន៍មេរៀនរបស់គ្រូបង្រៀនមិនមែនជាគោលដៅនោះទេ។ តែវាជាទម្លាប់នៃគំនិត និងទម្លាប់នៃដួងចិត្ត ដែលលោកអ្នកបណ្តុះឡើង ឬជាការដែលលោកអ្នកសាបព្រោះឡើងក្នុងចិត្តកូនៗរបស់លោកអ្នក តាមរយៈការធ្វើការលើបច្ចេកទេសទេសទាំងនេះវិញទេតើ ទើបជាគោលដៅ។

ខ្ញុំនឹងពន្យល់គោលដៅនោះដល់កូនៗរបស់ខ្ញុំ។ ខ្ញុំអាចនិយាយបានថា «នោះហើយគឺជាអ្វីដែលយើងចង់បាន។ យើងមិនមែនកំពុងតែព្យាយាមធ្វើឲ្យកូនរបស់យើងដូចអ្នកដែលបង្រៀនគេនោះទេ។ យើងគ្រាន់តែចង់បណ្តុះ

ទម្លាប់នៃគំនិត និងទម្លាប់នៃដួងចិត្តយ៉ាងប្រាកដណាមួយដល់កូនៗ ដើម្បីឲ្យកូនអាចនឹងចូលជិតព្រះបន្ទូលប្រកបដោយផលផ្លែពេញមួយជីវិតរបស់ខ្លួន»។

### ការដើរតាមគំរូល្អ

មានវិធីផ្សេងទៀតដែលអាចនិយាយបាននោះគឺ «តើអ្វីទៅជាចំណុចជាក់លាក់ដែលគ្រូកំពុងរកមើលនៅពេលគាត់វិភាគព្រះបន្ទូល? ចូរធ្វើបញ្ជីមួយ។ សរសេរវាឲ្យបានជាក់លាក់ »។ រឿងនេះនឹងក្លាយជាឧបសគ្គមួយ ពីព្រោះជាញឹកញាប់យើងមិនដឹងអំពីអត្ថន័យនៃពាក្យដែលយើងកំពុងអាននោះទេ។ ការនេះធំណាស់។ ផ្នែកដ៏ធំមួយនៃការរៀនជំនាញមួយគឺការអាចនិយាយអំពីអ្វី ដែលខ្លួនកំពុងតែឃើញ។

បើសិនលោកអ្នកមិនអាចពណ៌នាអំពីអ្វីដែលខ្លួនកំពុងតែឃើញនោះទេ វាក្លាយជាការលំបាកជាមិនខាន។ ប្រសិនបើលោកអ្នកកំពុងចំអិនអាហារតាមរូបមន្តមួយ ហើយវាប្រាប់ថា «ត្រូវបន្ថែមជីត្រចៀកជ្រូកចូល»? វីវរហើយ លោកអ្នកមិនបានស្គាល់ទេថា ជីត្រចៀកជ្រូកនោះជាអ្វីនោះទេ។ ប្រាកដណាស់ លោកអ្នកប្រហែលជាស្ទាត់ជំនាញក្នុងការចំអិនអាហារ ប៉ុន្តែប្រសិនបើលោកអ្នកមិនស្គាល់ជីនោះ វាអាចនឹងធ្វើឲ្យពិបាកជាមិនខានឡើយ។ ការពិតដូចគ្នានេះដែរ ទាក់ទងនឹងការអានអត្ថបទមួយ ឬនៅក្នុងវេយ្យាករណ៍ និងការកំណត់ទំនាក់ទំនងផ្សេងៗនៅចន្លោះសេចក្ដីសន្និដ្ឋានណាមួយ។

### ១. ការឲ្យនិយមន័យពាក្យ

តើអ្វីទៅជាអត្ថន័យនៃពាក្យមួយជាក់លាក់នៅក្នុងបរិបទនេះ? ពាក្យដូចគ្នាអាចមានអត្ថន័យខុសៗគ្នានៅក្នុងបរិបទផ្សេងៗគ្នា។ ដូច្នេះ តើយើងសម្រេចលើអត្ថន័យនៃពាក្យ ដែលមាននៅក្នុងបរិបទណាមួយដ៏ជាក់លាក់បានដោយរបៀបណា?



ចម្លើយគឺថា យើងមើលទៅលើបរិបទភ្លាមៗ នៅក្នុងប្រយោគដែលបានប្រើប្រាស់ពាក្យនោះ បន្ទាប់មក យើងមើលទៅលើកថាខណ្ឌ ហើយបន្ទាប់មកទៀតយើងមើលទៅលើកណ្ឌគម្ពីរទាំងមូល។

ឧទាហរណ៍ ពាក្យមួយដែលត្រូវបានប្រើប្រាស់ទាំងនៅក្នុងកណ្ឌគម្ពីរអេភេសូរ និងកណ្ឌគម្ពីររ៉ូម៉ះ យើងនឹងមើលទៅលើកណ្ឌគម្ពីរទាំងពីរនេះ បន្ទាប់មកយើងអានសំបុត្រផ្សេងៗសាវ័ក ប៉ូល បន្ទាប់មកទៀត អានព្រះគម្ពីរទាំងមូល។ មានចំណុចផ្ចិតមួយនៅចំកណ្ដាល នៅពេលដែលយើងបែរចេញពីបរិបទភ្លាមៗ ដែលមានកម្លាំងចលករ និងមានអំណាចក្នុងការកំណត់និយមន័យលើពាក្យមួយ។

### ២. ការស្វែងរកសេចក្ដីសន្និដ្ឋាន

តើអ្វីទៅជាសេចក្ដីសន្និដ្ឋាន ដែលនិពន្ធបានបង្កើតឡើងដោយការផ្គុំពាក្យទាំងឡាយជាមួយគ្នា? សេចក្ដីសន្និដ្ឋាន គឺជាការសាងបណ្ដុំមូលដ្ឋាននៃអត្ថន័យពាក្យ។ គ្រប់ពាក្យសុទ្ធតែមានអត្ថន័យ នៅពេលពាក្យនោះត្រូវបានប្រើប្រាស់នៅក្នុងសេចក្ដីសន្និដ្ឋាននានា។ សេចក្ដីសន្និដ្ឋានគឺជាការអះអាងមូលដ្ឋាន។

ជាធម្មតា វាមានប្រធានមួយ និងកិរិយាសព្ទមួយជាមួយពាក្យបំពេញន័យខ្លះៗ។ ដូច្នេះ ទំនងជាយើងកំពុងអានកណ្ឌគម្ពីរ រ៉ូម ១:១៦ ហើយពាក្យដែលយើងចង់ឲ្យនិយមន័យលើនោះគឺ ដំណឹងល្អ ហើយសេចក្ដីសន្និដ្ឋានដែលតំណាងឲ្យវាគឺ «ខ្ញុំគ្មានសេចក្ដីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ»។ នោះហើយគឺជាអ្វី ដែលខ្ញុំចង់សំដៅទៅលើ ដោយប្រើពាក្យពេចន៍ ហើយនិងសេចក្ដីសន្និដ្ឋាននានា។

### ៣. ការបញ្ជាក់ពីទំនាក់ទំនង

តើសេចក្ដីសន្និដ្ឋានទាំងនោះមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច? តើ

សេចក្តីសន្និដ្ឋាន ចាប់ផ្តើមដោយ ពាក្យ ពីព្រោះ មែនទេ? ឬក៏ចាប់ផ្តើមដោយពាក្យ ដូច្នេះ ដើម្បី ឬទោះបី នៅពេល ជាដើមមែនទេ?

វាពិតជាមានប្រយោជន៍ណាស់ក្នុងការឲ្យឈ្មោះសម្រាប់ទំនាក់ទំនងទាំងនោះ។ នេះគឺជារបៀបមួយដែលអ្នកនិពន្ធប្រាប់ពីអត្ថន័យរបស់គាត់។ គាត់ផ្គុំពាក្យទាំងឡាយជាមួយគ្នា ដើម្បីឲ្យចេញជាសេចក្តីសន្និដ្ឋាន បន្ទាប់មក គាត់ដាក់សេចក្តីសន្និដ្ឋាននានាជាមួយគ្នាក្នុងទំនាក់ទំនងនៃតក្កយ៉ាងជាក់លាក់។

ឧទាហរណ៍ជាក់ស្តែង យើងសម្គាល់ឃើញនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:១៦ «ខ្ញុំគ្មានសេចក្តីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ» ដែលវាមានទំនាក់ទំនងជាមួយនិងអ្វីដែលនៅខាងមុខខគម្ពីរ និងអ្វីដែលនៅខាងក្រោយខគម្ពីរ។ ដែលមានសេចក្តីថា «ដូច្នេះ ឯខ្ញុំៗប្រុងប្រៀបតែនឹងប្រាប់ដំណឹងល្អមកអ្នករាល់គ្នា ដែលនៅក្រុងរ៉ូមដែរ ដ្បិតខ្ញុំគ្មានសេចក្តីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្តានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ»។ ដូច្នេះ យើងមានការវែកញែកដោយប្រើឈ្នាប់បីយ៉ាង។ នៅពេលដែលខ្ញុំបានចាប់ផ្តើមមើលឃើញការនោះ គឺកាលខ្ញុំអាយុ ២២ឆ្នាំ ពិភពលោករបស់ខ្ញុំបានផ្ទុះឡើងដោយក្តីរំភើប និងការយល់ឃើញកាន់តែច្បាស់។

## ៤. ការកំណត់ចំណុចសំខាន់

បន្ទាប់មកខ្ញុំសួរទៀត តើអ្វីទៅជាលំហូរនៃការវែកញែក នៅពេលសេចក្តីសន្និដ្ឋានទាំងនេះជាមួយទំនាក់ទំនងវាបានប្រមូលផ្តុំគ្នាឡើង ហើយតើអ្វីជាគំនិតសំខាន់នៃលំហូរនេះ?

## ៥. ប្រៀបធៀបអត្ថបទ

តើអ្វីជាលំហូរស្រដៀងគ្នានៃគំនិតនៅកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរ?



ឧទាហរណ៍៖ នៅក្នុងចំណុចនេះ «ដ្បិតខ្ញុំគ្មានសេចក្តីខ្មាសចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ» ហូរចេញពីកណ្ឌគម្ពីរ រ៉ូម ជំពូក១ យើងប្រហែលជាត្រូវមើលទៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ១:១២ ដែលសាវ័ក ប៉ុល បានលើកឡើងថា «តែខ្ញុំមិនខ្មាសទេ ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម»។

បន្ទាប់មកខ្ញុំសួរទៀតថា តើអ្វីជាទំនាក់ទំនងរវាងលំហូរនៃគំនិតនៅក្នុងរបៀប ដែលសេចក្តីខ្មាសត្រូវបានយកឈ្មោះនៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ហើយពីរបៀប ដែលសេចក្តីខ្មាសត្រូវបានយកឈ្មោះនៅក្នុង កណ្ឌគម្ពីរ រ៉ូម ជំពូក ១? នៅពេលខ្ញុំធ្វើការប្រៀបធៀបបែបនេះលំហូរស្រដៀងគ្នានៃគំនិតត្រូវបានប្រៀបធៀបឡើងមួយជ្រុងម្តង នោះខ្ញុំក៏កាន់តែទទួលការយល់ច្បាស់ជាងមុន។

## ៦. ការប្រឈមមុខនឹងការពិត

តើអ្វីទៅជាការពិតជាក់ស្តែង ដែលមានសារៈសំខាន់ខ្លាំងជាសេចក្តីពិតនៅពីក្រោយពាក្យនានា និងសេចក្តីសន្និដ្ឋានផ្សេងៗ ហើយនិងលំហូរទាំងឡាយនៃគំនិត? មនុស្សវ័យក្មេង និងមនុស្សវ័យចំណាស់ជាច្រើនមានសេចក្តីរំភើបក្រៃលែង នៅពេលពួកគេរកឃើញអំពីអត្ថន័យនៃពាក្យ រកឃើញអំពីរបៀបដែលសេចក្តីសន្និដ្ឋានដំណើរការ ហើយនិងរកឃើញអំពីរបៀបដែលលំហូរសមហេតុផលនៃគំនិតអភិវឌ្ឍឡើង នោះពួកគេមានក្តីរំភើបចិត្តជាខ្លាំងចំពោះពាក្យនានា និងតក្កនោះ។

ភ្លាមនោះ ពួកគេបានលេងល្បែងមួយ ហើយពួកគេកំពុងតែភ្លេចខ្លួនថា មានស្ថានសួគ៌ និងស្ថាននរក មានជីវិត និងសេចក្តីស្លាប់ មានព្រះ និងសាតាំងពិតមែន។ សេចក្តីពិតដ៏មហិមាជាច្រើន គឺនៅពីក្រោយពាក្យទាំងនេះ ដូច្នេះហើយខ្ញុំចង់រុញច្រានខ្លួនប្រាណខ្ញុំតាមរយៈពាក្យពេចន៍នានាឲ្យចូលទៅក្នុងសេចក្តីពិតវិញ។ នេះគឺចំណុចទី៦៖ តើអ្វីទៅជាសេចក្តីពិត?

## ៧. ការអនុវត្តន៍អត្ថបទ

ជាការបញ្ចប់ តើអ្វីទៅជាការអនុវត្តន៍ផ្ទាល់ខ្លួនដែលខ្ញុំអាចនាំឲ្យអត្ថន័យរបស់អ្នកនិពន្ធជ្រាបចូលក្នុងជីវិតរបស់ខ្ញុំ និងពិភពលោកដែលនៅជុំវិញខ្ញុំ?

នៅក្នុងសំណួរទាំង៧នោះ ឧបករណ៍ដែលមានប្រយោជន៍បំផុតគឺសៀវភៅខគម្ពីរយោង (concordance) គឺជាសៀវភៅ ឬជាកម្មវិធីកុំព្យូទ័រដែលអនុញ្ញាត ឱ្យយើងមើលឃើញគ្រប់នៃការប្រើប្រាស់ពាក្យជាក់លាក់មួយរបស់អ្នកនិពន្ធនៅគ្រប់កន្លែងដែលពាក្យនោះបានប្រើប្រាស់។ នេះជាឧបករណ៍ដ៏សាមញ្ញបំផុត ដែលខ្ញុំប្រើប្រាស់ក្នុងការសិក្សាព្រះគម្ពីរ។

សៀវភៅសេចក្តីអត្ថាធិប្បាយក៏មិនអាចពន្យល់បានដូចនេះ។ វចនានុក្រមព្រះគម្ពីរក៏មិនអាចពន្យល់បានដែរ។ អ្វីដែលជាឧបសគ្គចំពោះការយល់ដឹងស៊ីជម្រៅ ស្ទើរតែកៅសិបប្រាំបួនភាគរយនៃគ្រប់ពេលទាំងអស់តែម្តង គឺការកំពុងរកមើលអត្ថន័យពាក្យនានា ដែលនាំខ្ញុំឲ្យចាប់គិតដូចជាគំនិតរបស់អ្នកនិពន្ធ។

## ទម្លាប់ពេញមួយជីវិត

នៅពេលយើងជួយឲ្យកូនៗរបស់យើងកំណត់នូវសំណួរទាំង៧ប្រភេទនោះហើយ អ្វីដែលយើងចង់បានគឺគ្រាន់តែឲ្យពួកគេបង្កើតទម្លាប់ពេញមួយជីវិតនៃការចេះសួរ និងការឆ្លើយនូវសំណួរទាំងអស់នោះ។

យើងមិនអាចធ្វើជំនួសពួកគេឡើយ។ ពួកគេត្រូវតែធ្វើការនោះដោយខ្លួនឯងផ្ទាល់។ យើងអាចធ្វើដូច្នេះបានដោយតាមរយៈការធ្វើការមើលទៅលើអត្ថបទទាំងឡាយជាមួយសំណួរទាំងអស់នោះ។ យើងអាចធ្វើវាជាមួយគ្នាបាន។ យើងអាចបង្គាប់ឲ្យពួកគេធ្វើវាម្តងហើយម្តងទៀត។

ការផ្តល់យោបល់មួយចុងក្រោយ៖ ការសរសេរចុះនូវចម្លើយទាំងឡាយ



តបទៅសំណួរទាំង៧នោះសម្រាប់រាល់អត្ថបទដែលយើងសិក្សា គឺជាការជួយឲ្យកាន់តែបង្កើតផលផ្លែ ច្រើនជាងការគ្រាន់តែព្យាយាមធ្វើវាតែនៅក្នុងខួរក្បាលរបស់យើង។

សូមចាំថា គោលបំណង គឺមិនមែនតែដើម្បីឲ្យមានការស្ទាត់ជំនាញលើបច្ចេកទេសដូចការគូសពន្យល់ ឬដើម្បីឲ្យមានការស្ទាត់ជំនាញដូចការរៀនវិភាគលើបទគម្ពីរនោះទេ។ នេះមិនមែនជាគោលបំណងទេ។ គោលបំណងគឺដើម្បីបង្កើតទម្លាប់ពេញមួយជីវិតនៃគំនិត និងដួងចិត្តដែលចេះបន្ទាបខ្លួន ហើយនិងការឆេះឆួលក្នុងការសួរ និងឆ្លើយនូវសំណួរនានាអំពីព្រះគម្ពីរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How to Read the Bible for Teenagers
**របៀបនៃអានព្រះគម្ពីរសម្រាប់ក្មេងៗវ័យជំទង់**
https://www.desiringgod.org/interviews/how-to-read-the-bible-for-teenagers

## សំណួរទី១៩៖
# ខ្ញុំមានពេលមួយថ្ងៃមួយម៉ោងសម្រាប់អាន តើខ្ញុំគួរចំណាយពេលប៉ុន្មាននាទីសម្រាប់អានព្រះគម្ពីរ?

យើងបន្តទទួលបានសំណួរមកពីអ្នកស្តាប់ ដែលប្រឈមនឹងផែនការណ៍អានព្រះគម្ពីរប្រចាំឆ្នាំ។ សំណួរនេះបានមកពីលោក រុង។ «ជម្រាបសួរលោកគ្រូ។ តាមរយៈរដូវកាលផ្សេងៗនៃជីវិតរបស់ខ្ញុំ ខ្ញុំបានទទួលការប៉ះពាល់ជាច្រើនតាមរយៈព្រះគម្ពីរ និងតាមរយៈសៀវភៅផ្សេងៗ ជាពិសេសគឺសៀវភៅរបស់លោកគ្រូ។ សម្រាប់ឆ្នាំខាងមុខនេះ តើខ្ញុំអាចរក្សាតុល្យភាពនៃការអានព្រះគម្ពីរជាមួយនឹងសៀវភៅផ្សេងៗទៀតបានដោយរបៀបណា? ជាពិសេស បើខ្ញុំមានពេលតែមួយម៉ោងក្នុងមួយថ្ងៃ ដើម្បីអាន។ ដូច្នេះ តាមយោបល់របស់លោកគ្រូ តើខ្ញុំគួរបែងចែកពេលវេលាយ៉ាងណារវាងការអានព្រះគម្ពីរ និងការអានសៀវភៅផ្សេងៗ?»

### តើគួរអានសៀវភៅណា?

នោះជារបៀបមួយយ៉ាងល្អជាក់លាក់ក្នុងការសួរ។ លោកអ្នកមានពេលមួយម៉ោង លោកអ្នកមានព្រះគម្ពីរ ហើយនិងសៀវភៅផ្សេងៗទៀត—សូមប្រាប់ថា តើខ្ញុំត្រូវធ្វើអ្វី។ អស្ចារ្យណាស់! នេះក៏ជាគំនិតដែលប្រថុយណាស់ដែរ។ វាគឺពិតជាប្រថុយណាស់ក្នុងការប្រាប់នរណាម្នាក់អំពីរបៀបបែងចែកពេលវេលារបស់ពួកគាត់រវាងព្រះគម្ពីរ—គឺជាព្រះបន្ទូលរបស់ព្រះ—និងសៀវភៅផ្សេងៗទៀត។ ខ្ញុំនឹងផ្តល់ជាឱវាទជាក់លាក់នៅបន្តិចទៀត។ ប៉ុន្តែ ដំបូងខ្ញុំមានគំនិតមួយចំនួនសិន។

នៅពេលដែលខ្ញុំអានសំណួរនេះ ខ្ញុំមិនដឹងច្បាស់ថា តើគាត់មាន

សៀវភៅអ្វីខ្លះទេ ដែលគាត់មាននៅក្នុងគំនិតរបស់គាត់។ តើគាត់សួរអំពីការអានព្រះគម្ពីរ ធៀបនឹងការអានសៀវភៅ «វឌ្ឍនភាពនៃធម្មយាត្រា» ឬ «ការស្គាល់ព្រះ» របស់លោកគ្រូ ផាកើ ឬវិទ្យាស្ថាន របស់លោកគ្រូ ខិលវិន? ឬមួយគាត់សួរអំពីការអានព្រះគម្ពីរ ធៀបនឹងការអានទស្សនាវដ្ដីកីឡា ឬភូមិសាស្ត្រជាតិ ឬរឿងប្រលោមលោក ឬមួយសេចក្ដីណែនាំ អំពីរបៀបក្លាយជាជាងជួសជុលគ្រឿងម៉ាស៊ីន ឬមួយលំហាត់សាលា? តើគាត់កំពុងសួរអំពីអ្វី?

## ពិចារណាពីសត្វស្រមោច

សូមឲ្យខ្ញុំនិយាយអំពីការអានព្រះគម្ពីរ ធៀបនឹងការស្វែងរកចំណេះដឹងទូទៅ ដែលនៅខាងក្រៅព្រះគម្ពីរ។ ពីព្រោះខ្ញុំអាចស្រមៃអំពីមនុស្សម្នាក់និយាយថា «ពិតណាស់! ប្រសិនបើព្រះគម្ពីរគឺពិតជាព្រះបន្ទូលរបស់ព្រះអាទិករដែលបង្កើតចក្រវាលនេះមែន ចុះហេតុអ្វីលោកអ្នកមិនចំណាយពេលតែជាមួយព្រះគម្ពីរ ពេញមួយថ្ងៃ ហើយស្ដាប់ព្រះ? ដ្បិតទ្រង់គឺជាព្រះ»។

ចម្លើយទៅកាន់សំណួរនេះគឺថា ព្រះគម្ពីរមិនបានប្រាប់យើងឲ្យធ្វើបែបនេះនោះទេ៖ «ទៅមើលស្រមោចចុះ [ឱមនុស្សខ្ជិលច្រអូសអើយ] ចូរពិចារណាផ្លូវទាំងប៉ុន្មានរបស់វា ហើយមានប្រាជ្ញាឡើង» (សុភាសិត ៦:៦)។ នៅក្នុងរបៀបមួយទៀតគឺ បិទព្រះគម្ពីររបស់ខ្លួន ហើយចេញទៅមើលអ្វីដែលនៅជុំវិញ ហើយរៀនអ្វីម្យ៉ាងពីលោកីយ៍នេះ។ «ចូររំពឹងគិតតែពីផ្កាឈូកនៅក្នុងបឹង» (ម៉ាថាយ ៦:២៨)។ សូមបិទព្រះគម្ពីររបស់លោកអ្នក ហើយចេញទៅពិចារណាមើលផ្កាឈូកចុះ។ «ចូរពិចារណាពីសត្វស្លាបនៅលើអាកាស» (ម៉ាថាយ ៦:២៦)។ សូមបិទព្រះគម្ពីររបស់លោកអ្នក ហើយចេញទៅពិចារណាមើលសត្វស្លាបនៅលើអាកាស។ កុំគ្រាន់តែអានព្រះគម្ពីរ សូមអានពិភពលោករបស់ព្រះ និងព្រះបន្ទូលរបស់ព្រះ។

ពិតណាស់ ព្រះគម្ពីរក៏បានប្រាប់ឲ្យយើងធ្វើការជាមួយនឹងដៃរបស់



យើង ដើម្បីផ្គត់ផ្គង់ការរស់នៅប្រចាំថ្ងៃ (១ថែស្សាឡូនីច ៤:១០-១២)។ ប៉ុន្តែលោកអ្នកត្រូវរៀនធ្វើការជាអ្នកដេរតង់ដូចជាសាវ័ក ប៉ុល ឬធ្វើជាវេជ្ជបណ្ឌិតដូចជាលោក លូកា ឬធ្វើជាជាងឈើដូចជាឪពុករបស់ព្រះយេស៊ូវ ឬធ្វើជាអ្នកនេសាទត្រីអាជីពដូចជាសាវ័ក ពេត្រុស ដោយមិនចាំបាច់មកពីការអានព្រះគម្ពីរបានដែរ។ ព្រះគម្ពីរមិនបានប្រាប់អំពីអំបោះមួយណាដែលធ្វើឲ្យតង់នៅជាប់គ្នានៅពេលដែលស្បែកត្រូវទឹកសើមនោះឡើយ។ មិនមានប្រាប់បែបនោះទេ។ ព្រះជាម្ចាស់មិនបានរចនាព្រះគម្ពីរបែបនេះនោះទេ។ ព្រះគម្ពីរបានប្រាប់ឲ្យចេញទៅសង្កេតមើលពិភពលោក ឲ្យលោកអ្នកមានប្រាជ្ញា សិក្សាពីធម្មជាតិ ហើយរកដំណោះស្រាយ។

ដូច្នេះ នៅត្រង់នេះគឺចង់បញ្ជាក់ថា ព្រះគម្ពីរផ្ទាល់បានណែនាំយើងឲ្យរៀនអំពីពិភពលោក រៀនអំពីមនុស្ស រៀនអំពីការងារ រៀនអំពីសង្គម និងទំនាក់ទំនងដែលព្រះទ្រង់បានបង្កើតមក។ ព្រះគម្ពីរបានហៅយើងឲ្យរៀនដោយការសម្លឹងមើលរបស់ទាំងអស់នោះ។ យើងនឹងមិនឈប់ឃើញស្នាព្រះហស្តរបស់ព្រះ ដោយព្រោះតែយើងមិនអានព្រះគម្ពីរនោះឡើយ។

## ១៥នាទីក្នុងមួយថ្ងៃ

តាមពិតទៅ នោះប្រហែលមិនមែនជាអ្វីដែលលោក រុង ចង់សួរនោះទេ។ អ្វីដែលខ្ញុំគិតថាលោក រុង ចង់សួរគឺថា ប្រសិនបើខ្ញុំមានសៀវភៅដែលល្អអំពីព្រះ និងរបៀបរបស់ព្រះដែលសរសេរឡើងដោយអ្នកនិពន្ធដែលកោតខ្លាចព្រះ ហើយខ្ញុំមានពេលមួយម៉ោង ហើយខ្ញុំត្រូវបែងចែកការអានសៀវភៅនោះចេញពីព្រះគម្ពីរ តើខ្ញុំគួរបែងចែកបែបណា? គាត់សួរថា ប្រសិនបើអ្នកមាន «សៀវភៅពីវិទ្យាស្ថាន» របស់លោកគ្រូ ខិលវិន ឬ «ការស្គាល់ព្រះ» របស់លោកគ្រូ ជេ. អាយ. ផាកកើ ហើយគាត់ចង់អានសៀវភៅទាំងនោះខ្លះ ប៉ុន្តែគាត់ក៏ចង់អានព្រះគម្ពីរដែរ។ ដូច្នេះ តើគាត់នឹងធ្វើឡើងដោយរបៀប

ណា? នេះជាចម្លើយះ

សូមចាំថា ខ្ញុំមិនមានសិទ្ធអំណាចពីព្រះគម្ពីរក្នុងការនិយាយអំពីការនេះនោះឡើយ។ ការបែងចែកនេះគឺវាគ្រាន់តែជាអ្វីដែលខ្ញុំនឹងផ្តល់ឲ្យជាយោបល់ប៉ុណ្ណោះ។ ខ្ញុំនឹងរម្លឹកទៅកាន់អ្នកអាន និងអ្នកស្តាប់របស់យើងទាំងអស់គ្នា អំពីអ្វីមួយដែលខ្ញុំបាននិយាយពីមុនមក គឺតាំងតែពីយូរមកហើយ។

ឧបមាថា លោកអ្នកអានយឺតៗដូចខ្ញុំ គឺខ្ញុំអានប្រហែលជា ២០០ ពាក្យក្នុងមួយនាទី—នេះទំនងជាល្បឿនដែលខ្ញុំកំពុងនិយាយក៏ថាបាន ខ្ញុំមិនដឹងប្រាកដទេ។ ប្រសិនបើលោកអ្នកអាន១៥នាទីក្នុងមួយថ្ងៃ ក្នុងរយៈពេលមួយឆ្នាំ នោះគឺស្មើនឹងការចំណាយពេលអានចំនួន ៥.៤៧៥ នាទីក្នុងមួយឆ្នាំ។ បើយើងគុណនឹង ២០០ ពាក្យក្នុងមួយនាទី នោះស្មើនឹង ១.០៩៥.០០០ ពាក្យ ដែលលោកអ្នកបានអានក្នុងរយៈពេលមួយឆ្នាំ។

ជាមធ្យម សៀវភៅធំៗជាច្រើនគឺមានប្រហែលជា ៣៦០ ពាក្យក្នុងមួយទំព័រ។ ខ្ញុំបានរាប់ជាច្រើនដង។ ដូច្នេះ លោកអ្នកនឹងអានប្រហែលជា ៣.០៤១ ទំព័រក្នុងរយៈពេលមួយឆ្នាំ នៃចន្លោះពេល១៥នាទីក្នុងមួយថ្ងៃ។ សៀវភៅធំៗអាចមានជាមធ្យម ចំនួន ២៥០ទំព័រ។ សៀវភៅជាច្រើនមានប្រហែលជា ១៥០ ទំព័រ ប៉ុន្តែ ឧបមាថា សៀវភៅទេវវិទ្យាមួយក្បាលដែលធំ ហើយមានគុណភាពល្អ គឺមានប្រមាណជា ២៥០ ទំព័រ។ ខ្ញុំទើបតែបើកមើលមួយក្បាល ដែលខ្ញុំទទួលបានកាលពីម្សិលមិញ។ វាគឺមានប្រមាណជា ២៥០ ទំព័រ។ នោះគឺ ស្មើនឹងអានសៀវភៅសំខាន់ៗ ១២ក្បាលក្នុង១៥នាទីមួយថ្ងៃ សម្រាប់អ្នកអានដែលមានល្បឿនមធ្យម។

**អានដើម្បីអានព្រះគម្ពីរ**

ខ្ញុំនឹងផ្តល់ជាយោបល់ទៅកាន់លោក រុង ថាឲ្យគាត់គួរអានព្រះគម្ពីរក្នុងរយៈពេល៤៥នាទី—ដោយយឺតៗ មានការគិតពិចារណា សញ្ជឹងគិត



អធិស្ឋាន ការធ្វើបែបនេះនឹងអាចនាំឲ្យគាត់ឲ្យអានព្រះគម្ពីរទាំងមូលចប់ក្នុងរយៈពេលមួយឆ្នាំ—បន្ទាប់មក គាត់អាចចំណាយពេល១៥នាទី ដែលនៅសល់ ដើម្បីអានសៀវភៅដែលល្អៗ ដែលយកព្រះជាគោល និងពោរពេញដោយអត្ថបទព្រះគម្ពីរ ដែលនឹងជួយបម្រើដល់ការអានព្រះគម្ពីររបស់គាត់។ (ខ្ញុំសន្មតថាលោក រុង ក៏នឹងញែកពេលជាច្រើនទៀត ដើម្បីអធិស្ឋានដែរ)។

ប្រហែលជានឹងមាននរណាម្នាក់និយាយថា «តើគាត់អាចផ្តល់យោបល់ឲ្យមានសៀវភៅណាផ្សេងចូលមកឈ្លានពានពេលវេលាមួយម៉ោងដែលគាត់គួរតែចំណាយលើការអានព្រះគម្ពីរបានដោយរបៀបណា?»។ ហើយចម្លើយរបស់ខ្ញុំនោះគឺថា តាមរយៈបទពិសោធន៍របស់ខ្ញុំ ហើយព្រះគម្ពីរផ្ទាល់ក៏បានឆ្លុះបញ្ចាំងមកកាន់ខ្ញុំអំពីការយល់ដឹងរបស់មនុស្សផ្សេងៗទៀត ដែលពួកគាត់បានឃើញនៅក្នុងព្រះគម្ពីរ អាចជាមធ្យោបាយយ៉ាងល្អក្នុងការមើលឃើញបន្ថែមទៀត នៅក្នុងព្រះគម្ពីរ។ ខ្ញុំដឹងថា ចំណុចនេះជាការពិត។ ប្រសិនបើខ្ញុំចំណាយពេល១០នាទី ដើម្បីអានសៀវភៅរបស់លោកគ្រូ ចន អូវិន ឬសៀវភៅរបស់លោកគ្រូ យ៉ូណាថាន់ អែតវ៉ដ នោះខ្ញុំនឹងឃើញកាន់តែច្រើនចំណុចទៀត នៅក្នុងព្រះគម្ពីររបស់ខ្ញុំ។

ខ្ញុំគិតថា ប្រសិនបើលោក រុង ជ្រើសរើសសៀវភៅរបស់គាត់ដោយប្រើប្រាស់ប្រាជ្ញា នោះវានឹងមិនបន្ថយអ្វីដែលគាត់ឃើញមាននៅក្នុងព្រះបន្ទូលរបស់ព្រះ នៅក្នុងពេលមួយម៉ោងនោះរបស់គាត់ឡើយ។ ការមើលតាមរយៈភ្នែករបស់អ្នកដទៃនឹងជួយបង្កើនការយល់ដឹងរបស់លោក រុង អំពីអ្វីដែលអស្ចារ្យបំផុតនៅក្នុងពិភពលោកនេះ នៅពេលគាត់អានព្រះគម្ពីរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីះ**
I Have an Hour a Day to Read — How Much Should Be Bible?
**ខ្ញុំមានពេលមួយថ្ងៃមួយម៉ោងសម្រាប់អាន តើខ្ញុំគួរចំណាយពេលប៉ុន្មាននាទីសម្រាប់អានព្រះគម្ពីរ?**
https://www.desiringgod.org/
interviews/i-have-an-hour-a-day-to-read-how-much-should-be-bible

### សំណួរទី២០៖

# ខ្ញុំអានព្រះគម្ពីរ ហើយមិនមានអារម្មណ៍អ្វីសោះ តើខ្ញុំគួរធ្វើដូចម្ដេច?

ប្រសិនបើខ្ញុំអានព្រះគម្ពីរប៉ុន្តែមិនមានអារម្មណ៍អ្វីសោះក្នុងការស្រឡាញ់ដែលស៊ីគ្នាជាមួយនឹងតម្លៃ ភាពស្រស់ស្អាត និងអំណរដែលពាក្យពេចន៍ទាំងនេះគួរនាំឲ្យមានមកកាន់ខ្ញុំ តើមានអ្វីដែលខ្ញុំគួរធ្វើបន្ទាប់ពីការអានដែរឬទេ? ឬក៏ថា ខ្ញុំគ្រាន់តែត្រូវរង់ចាំ ហើយឲ្យបទពិសោធន៍ហ្នឹងកើតឡើងចំពោះខ្ញុំនៅឯអនាគត? សូមលោកគ្រូជួយឆ្លើយ។

ខ្ញុំសប្បាយចិត្តណាស់ដែលមានគេសួរសំណួរដូចនេះ ពីព្រោះនោះគឺជាអ្វីដែលខ្ញុំបានគិតថ្មីៗនេះ។ ខ្ញុំបានសញ្ជឹងគិតលើកណ្ឌគម្ពីរសុភាសិត ហើយខ្ញុំគិតថា ជំពូកដែលខ្ញុំកំពុងតែគិតលើ គឺអ្នកនិពន្ធបានលើកឡើងដើម្បីជួយឆ្លើយសំណួរនេះ។

ខ្ញុំបានសញ្ជឹងគិតលើកណ្ឌគម្ពីរ សុភាសិត ២២:១៧-២៤:២២។ ប្រសិនបើលោកអ្នកអានកណ្ឌគម្ពីរ សុភាសិត ២២:២០ ដែលបានចែងថា «អញបានកំណត់ទុកសេចក្តីដ៏វិសេសសម្រាប់ឯង គឺជាសេចក្ដីទូន្មាន ហើយនិងតម្រិះមិនមែនឬ»។ គេបានផ្គុំសេចក្ដីទូន្មាន៣០ដងនេះជាក្រុម។ នៅពេលដែលមានប្រធានបទថ្មី នោះសេចក្ដីទូន្មានថ្មី ហើយនៅក្នុងប៉ុន្មានខនេះមាន៣០នៃសេចក្ដីទូន្មាននោះ។ ខ១៧គឺជាកន្លែងដែលសេចក្ដីទូន្មាននេះបានចាប់ផ្តើម ហើយខនោះមានចែងដូចតទៅ៖ «ចូរផ្ទៀងត្រចៀក ស្តាប់ពាក្យសម្ដីនៃមនុស្សដែលមានប្រាជ្ញា» ភាគច្រើនគេហៅខគម្ពីរដូចនេះថា «ពាក្យសម្ដីរបស់មនុស្សដែលមានប្រាជ្ញា»។

ហេតុអ្វីបានជាខ្ញុំគិតថា ទំនងពីរទៅបីខដំបូង ឬក៏ក្នុងវគ្គថ្មីនៃសេចក្ដី

ទូន្មានទាំង៣០នេះគឺត្រូវបានសរសេរឡើងដើម្បីឆ្លើយសំណួរនេះ៖ តើយើងអាចឮពាក្យពេចន៍ទាំងនេះដោយរបៀបណា ហើយថាតើយើងអាចមានអារម្មណ៍ក្នុងការឲ្យតម្លៃបានដោយរបៀបណា?

## ផ្ទៀងចូល

សូមអានកណ្ឌគម្ពីរ សុភាសិត ២២:១៧-១៨ ជាមួយខ្ញុំ៖

«ចូរផ្ទៀងត្រចៀក ស្តាប់ពាក្យសម្ដីនៃមនុស្សដែលមានប្រាជ្ញា
ហើយផ្ចង់ចិត្តចំពោះតម្រិះរបស់អញចុះ
ដ្បិតបើឯងរក្សាទុកសេចក្តីនោះនៅក្នុងខ្លួន នោះសប្បាយហើយ
គឺបើសេចក្តីនោះស្ថិតនៅជាប់នឹងបបូរមាត់ឯង»។

សូមកត់សម្គាល់លើចំណុចពីរយ៉ាង។ ប្រយោគដំបូងបានចែងថា៖ «ចូរផ្ទៀងត្រចៀក ស្តាប់ពាក្យសម្ដីនៃមនុស្សដែលមានប្រាជ្ញា»។ ច្បាស់ណាស់ ចំណុចនេះគឺថា មានពាក្យពេចន៍ដែលកំពុងតែលើកឡើង ហើយលោកអ្នកក៏គួរតែ ផ្ទៀងចូល និងផ្ទៀងត្រចៀកស្តាប់។ និយាយឲ្យចំទៅ៖ ប្រសិនបើយើងមិនអាចស្តាប់ឮ តើយើងធ្វើអ្វីនៅពេលដែលលោកអ្នកមិនឮ? គឺលោកអ្នកផ្ទៀងត្រចៀកស្តាប់។ យើងងាកចូល ដើម្បីផ្ទៀងស្តាប់បន្ថែម។

ប៉ុន្តែ យើងក៏ធ្វើបែបនោះជាមួយនឹងចំណាប់អារម្មណ៍របស់យើងផងដែរ។ ប្រសិនបើលោកអ្នកកំពុងតែអានពាក្យពេចន៍ ឬក៏លោកអ្នកកំពុងតែឮពាក្យសម្ដី ហើយកំពុងតែមានពាក្យហោះឆ្លងកាត់លោកអ្នក នោះអ្នកនិពន្ធកំពុងតែមានប្រសាសន៍ថា «កុំឲ្យវាគ្រាន់តែហោះកាត់។ កុំឲ្យវាឆ្លងឲ្យសោះ។ ចូរផ្ទៀងដោយយកចិត្តទុកដាក់ មានការប្រុងប្រយ័ត្ន ការផ្តោតអារម្មណ៍លើពាក្យពេចន៍ទាំងនោះ ពីព្រោះពាក្យពេចន៍ទាំងនោះនឹងបង្កើតចំណេះដឹងនៅក្នុងខួរក្បាលរបស់លោកអ្នក»។



## ភ្ជាក់ឡើង

ឃ្លាបន្ទាប់លើកឡើងថា «ហើយផ្ចង់ចិត្តចំពោះតម្រិះរបស់អញចុះ»។ ដូច្នេះ ចំណេះដឹងគឺជាអ្វីដែលលេចជារូបរាងឡើងក្នុងខួរក្បាលនូវគំនិតខ្លះ—ការណែនាំអំពីអ្វីមួយដែលមានតម្លៃ សំខាន់ ឬក៏ពេញដោយប្រាជ្ញា ដែលគាត់នឹងលើកឡើងមកនិយាយ—ដែលកំពុងតែមានតាមរយៈពាក្យពេចន៍ដែលចូលត្រចៀករបស់លោកអ្នក ហើយបង្កើតឲ្យមានចំណេះដឹង។

ហើយនេះគឺជាឥទ្ធិពល៖ «នោះសប្បាយហើយ»។ ហើយខ្ញុំយល់ថាបេះដូងគឺជាសរីរាង្គនៃការអរសប្បាយ។ ហើយនោះគឺជាសំណួរ ត្រូវអត់? តែខ្ញុំអាចមានបទពិសោធន៍នៃការអរសប្បាយក្នុងរបៀបឲ្យតម្លៃ រាប់ជាទ្រព្យស្រឡាញ់ ឱបក្រសោប និងទទួលបានការស្កប់ចិត្តក្នុងអ្វីដែលខ្ញុំយល់ឃើញតាមរយៈពាក្យពេចន៍បានដោយរបៀបណា? ហើយអ្នកនិពន្ធបានលើកឡើងថា របៀបដែលលោកអ្នកអាចធ្វើការនោះបានគឺតាមរយៈការអនុវត្តនៅក្នុងចិត្ត។

ឥឡូវ ខ្ញុំនឹងពន្យល់បន្ថែមទៀតអំពីអត្ថន័យនេះ។ ប៉ុន្តែ សូមដឹងថា អ្នកនិពន្ធនេះ ជាអ្នកនិពន្ធដែលព្រះវិញ្ញាណបានបណ្តាលឲ្យតែង គឺគាត់កំពុងតែឆ្លើយលើសំណួរនេះថា «បាទ»។ តើមានអ្វីដែលលោកអ្នកអាចធ្វើ ដើម្បីបញ្ជូនអ្វីដែលត្រចៀកកំពុងតែផ្ទៀងស្តាប់ពាក្យពេចន៍ និងខួរក្បាលដែលកំពុងតែបង្កើតចំណេះដឹងឲ្យក្លាយជាបទពិសោធន៍នៅក្នុងចិត្ត ដែលមាននៅអំណរនៃអ្វីដែលមាននៅក្នុងពាក្យពេចន៍នោះ? តើមានអ្វីដែលលោកអ្នកអាចធ្វើបានទេ? ហើយចម្លើយរបស់គាត់គឺថា «មាន»។ ហើយពាក្យពេចន៍ដែលគាត់បានប្រើប្រាស់គឺថាឲ្យលោកអ្នក «យកចិត្តអនុវត្តនូវអ្វីដែលត្រចៀកបានឮ និងចំណេះដឹងដែលកំពុងតែចេញជារូបរាងនៅក្នុងខួរក្បាលរបស់លោកអ្នក»។

តើការនេះមានន័យយ៉ាងដូចម្តេច? ពាក្យ «ផ្ចង់ចិត្ត» ក្នុងភាសាហេព្រើរ

«បាលីបឆា ថាសិត» (Balibbcha tashit) មានអត្ថន័យចំៗថា «ដាក់» «ដាំ» «បណ្ដាលឲ្យ» «ជំរុញ» «បញ្ឈរ» ឬក៏ «តាំង»។ ដូច្នេះ លោកអ្នកយកចិត្តជំរុញវា។ លោកអ្នកតាំងវាជាមួយនឹងអ្វីដែលភ្នែកលោកអ្នកបានឃើញ ឬឮដោយត្រចៀក។ លោកអ្នករុញច្រមុះនៃបេះដូងឲ្យចូលទៅក្នុងភាពស្រស់ស្អាតនៃចំណេះដឹង។

ប្រសិនបើបេះដូងរបស់លោកអ្នកមិនមានអារម្មណ៍អ្វីសោះ នោះលោកអ្នកអាចនិយាយទៅកាន់បេះដូងថា «ឱបេះដូងអើយ សូមភ្ញាក់ឡើង»។ ហើយបន្ទាប់មក លោកអ្នកយកចិត្តអនុវត្ត។ លោកអ្នកបណ្ដាលឲ្យវាអនុវត្ត។ លោកអ្នកដាក់វាចូលទៅក្នុងចំណេះដឹង។ លោកអ្នកជំរុញវាចូល។ ពិតណាស់ មានអ្វីដែលលោកអ្នកអាចធ្វើបានមែន។

## បន្តភ្លក់ និងមើលទៀត

នេះគឺជាការប្រៀបធៀប។ ឧបមាថាលោកអ្នកចង់ភ្លក់សាច់គោអាំង។ លោកអ្នកអាចឮសម្លេងស៊ីៗពីខ្លាញ់ស្រក់លើបន្ទះអាំងចូលភ្លើង។ ដូច្នេះ លោកអ្នកក៏ចេញទៅក្រៅ ហើយបន្ទាប់មកភ្នែករបស់លោកអ្នកក៏ឃើញខ្លាញ់ស្រក់ពីបន្ទះអាំងចូលភ្លើង ឮសម្លេងស៊ីៗ។ ហើយប្រសិនបើលោកអ្នកអាចទៅដល់ជិតល្មម នោះច្រមុះលោកអ្នកក៏នឹងទំនងជាអាចហិតក្លិនខ្លាញ់ស្រក់លើបន្ទះអាំងចូលភ្លើង ឮសម្លេងស៊ីៗដែរ ប៉ុន្តែលោកអ្នកក៏នៅមិនទាន់បានភ្លក់រសជាតិសាច់គោអាំងនោះនៅក្នុងមាត់នៅឡើយទេ។

តើមានអ្វីដែលលោកអ្នកនៅអាចធ្វើបានដែរឬទេ? នេះគឺជាសំណួរ។ នេះគឺជាចំណុចស្នូលនៃសំណួរពីខាងលើ។ តើមានអ្វីដែលលោកអ្នកនៅអាចធ្វើបានជាមួយនឹង «សាច់គោអាំងរបស់ព្រះជាម្ចាស់» ជាមួយនឹង «សាច់គោអាំងរបស់ព្រះគ្រីស្ទ» ជាមួយនឹង «សាច់គោអាំងនៃសេចក្ដីសង្គ្រោះ» ជាមួយនឹង «សាច់គោអាំងនៃព្រះបន្ទូលរបស់ព្រះ»—ព្រះបន្ទូល



របស់ព្រះអាទិករដែលគ្មានព្រំដែន? តើមានអ្វីដែលលោកអ្នកអាចធ្វើបានដើម្បីភ្លក់រសជាតិនោះដែរឬទេ?

លោកអ្នកដឹងចម្លើយហើយ៖ យកកាំបិតមកកាត់មួយដុំ ដាក់ចូលក្នុងមាត់ ទំពារហើយទំពារទៀត ហើយបន្ទាប់មកលេប នោះលោកអ្នកនឹងស្គាល់រសជាតិជាមិនខាន។ ដូច្នេះ លោកអ្នកនិយាយទៅកាន់បេះដូងថា «ឱបេះដូងអើយសូមញ៉ាំ! ឱបេះដូងអើយសូមញ៉ាំចុះ!»។

សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវឧទាហរណ៍មួយចំនួនទៀត។ ខ្ញុំកំពុងតែដើរទៅព្រះវិហារ។ ពេលនោះគឺជារដូវចម្រូត។ កាលនេះបានកើតឡើងប្រមាណជាពីរអាទិត្យមុន។ ដើមស្រូវ និងគួរស្រូវនៅជុំវិញផ្ទះអ្នកជិតខាងរបស់ខ្ញុំមានពណ៌លឿងក្រហមឆ្អៅ ដែលមិនគួរឲ្យជឿសោះ ហើយព្រះអាទិត្យក៏កំពុងតែរះលើវាដែរ ហើយកាលនោះហួសរដូវចម្រូតបន្តិច—ខ្យល់ក៏បក់រវេចៗលើសធម្មតាដែរ។ គួរស្រូវកំពុងតែបក់ចុះបក់ឡើងភ្លឹបភ្លែតៗ ហើយវាពិតជាស្រស់ស្អាតមែន។

ប៉ុន្តែ កាលនោះខ្ញុំកំពុងតែដើរទៅព្រះវិហារ ដើម្បីចូលរួមការប្រជុំអធិស្ឋាន ហើយក៏មិនបានចាប់អារម្មណ៍អ្វីដែរ។ ភ្នែករបស់ខ្ញុំកំពុងតែឃើញព្រឹត្តិការណ៍នោះ ប៉ុន្តែខ្ញុំក៏មិនបានឃើញវាដែរ។ តើមានអ្វីបានកើតឡើង? គឺខ្ញុំបានបង្អង់ឈប់សិន។ ព្រះគុណរបស់ព្រះជាម្ចាស់បានបង្អង់ឲ្យខ្ញុំឈប់។ ឯកសារនេះក៏បានបណ្ដាលឲ្យខ្ញុំ និងលោកអ្នកបង្អង់ឈប់សិនដែរ។ លោកអ្នកក៏បានមើល ឬក៏ស្រមៃឃើញព្រឹត្តិការណ៍នេះម្ដងហើយម្ដងទៀត។ លោកអ្នកផ្ទៀងចូល ហើយនិយាយថា «ឱបេះដូងអើយ នោះគឺជាពណ៌លឿងទុំ។ នោះគឺជាពណ៌លឿង។ វាធ្លាប់មានពណ៌បៃតង ហើយឥឡូវនេះវាមានពណ៌លឿង ពណ៌លឿងទុំដូចមាស ហើយព្រះអាទិត្យក៏កំពុងតែធ្វើឲ្យវាមានពណ៌ចែងចាំងផងដែរ។ ហើយវាក៏កំពុងតែរេទៅមកតាមទំនោរខ្យល់បក់ ហើយព្រះជាម្ចាស់កំពុងតែព្យាយាមទាក់ទាញចំណាប់អារម្មណ៍របស់លោកអ្នក

គឺព្រះអង្គកំពុងតែមានបន្ទូលថា "សិរីល្អរបស់ព្រះជាម្ចាស់កំពុងតែចែងចាំងនៅទីនេះ"។ ឱបេះដូងអើយ សូមមើល»។ ហើយលោកអ្នកយកច្រមុះនៃបេះដូងរបស់លោកអ្នកឲ្យចូលកៀកគួរស្រូវនោះ។

ហើយពេលខ្ញុំបានត្រឡប់មកផ្ទះវិញពីរបីថ្ងៃក្រោយមក ខ្ញុំក៏បានឃើញព្រឹត្តិការណ៍ដូចនេះពីរបីដងទៀត គឺវាពិតជាស្រស់ស្អាតណាស់ នៅពេលដែលខ្ញុំមើលវាលស្រែទាំងនោះ ខ្ញុំក៏បាននិយាយថា «ស្អាតណាស់ៗ»។ ហើយខ្ញុំក៏បានចំណាយពេលដើរនៅក្នុងវាលស្រែនោះ ហើយអោនចុះ សម្លឹងមើលគួរស្រូវ។ ហើយខ្ញុំក៏បានដើរចេញឲ្យរាងឆ្ងាយ បន្ទាប់មកក៏ក្រឡេកមើលវាពីរបីដងទៀតដែរ។ ហើយខ្ញុំក៏បានទាញយកទូរស័ព្ទ ដើម្បីព្យាយាមថតរូបពីជ្រុងខុសៗគ្នា។ ហើយខ្ញុំក៏ថែមទាំងបានមើលវាលស្រែនោះ ចេញពីជ្រុងខាងក្រោយផ្ទះអ្នកជិតខាងខ្ញុំដែរ។

## សូមផ្ទៀងចិត្ត

នេះគឺជាការជំរុញចិត្តយើងឲ្យមើលឃើញការបើកសម្ដែងដ៏ស្រស់ស្អាតតាមរយៈធម្មជាតិ។ លោកអ្នកក៏ត្រូវធ្វើដូចនោះជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ ឧបមាថាគេបានឲ្យគ្រាប់ពេជ្រមួយគ្រាប់មកលោកអ្នក។ លោកអ្នកបានឃើញគ្រាប់ពេជ្រនោះ ប៉ុន្តែលោកអ្នកក៏មិនបានឃើញគ្រាប់ពេជ្រនោះដែរ ដូច្នេះលោកអ្នកត្រូវតែនិយាយទៅកាន់បេះដូងថា «ឱបេះដូងអើយ សូមបង្វិលមើលគ្រាប់ពេជ្រនេះ។ សូមមើលគ្រាប់ពេជ្រពីចំហៀងខាងនេះ និងចំហៀងខាងនោះចុះ»។

ហើយនៅពេលដែលបុគ្គលដែលបានកើតជាថ្មីមើលផ្នែកទី២នៃកណ្ឌគម្ពីរ សុភាសិត ២២:១៧—«ហើយផ្ទង់ចិត្តចំពោះតម្រិះរបស់អញចុះ» គឺ «ផ្ទង់ចិត្តឯង ហើយផ្ទង់ចិត្តទៀត»—នោះមិនមានអ្វីដែលលោកអ្នកអាចធ្វើបាន ក្រៅពីការអធិស្ឋានទេ។ នៅពេលដែលលោកអ្នកកំពុងតែអធិប្បាយ



ទៅកាន់បេះដូងរបស់អ្នក ហើយកំពុងតែនិយាយទៅកាន់បេះដូងរបស់លោកអ្នកថា «ឱបេះដូងអើយ សូមក្រោកឡើង សូមភ្ញាក់ឡើង។ ឱបេះដូងអើយ សូមមើលការនេះ។ ឱបេះដូងអើយ សូមស្គាល់អារម្មណ៍នេះ។ នេះពិតជាស្អាតណាស់។ ឱបេះដូងអើយ សូមភ្ញាក់ឡើង»។ នេះមានន័យថា លោកអ្នកកំពុងតែអធិស្ឋាន។ លោកអ្នកមិនគ្រាន់តែកំពុងនិយាយទៅកាន់បេះដូងទៀតទេ—ទោះបីលោកអ្នកកំពុងតែនិយាយសំដៅទៅកាន់បេះដូងមែន ពីព្រោះនោះគឺជាអ្វីដែលខគម្ពីរកំពុងតែប្រាប់ឲ្យលោកអ្នកធ្វើ៖ ចូលផ្ទៀងចិត្តឯងចុះ។ ប៉ុន្តែ លោកអ្នកក៏កំពុងតែអធិស្ឋានថា «ឱព្រះជាម្ចាស់អើយ សូមជួយទូលបង្គំផង។ សូមបើកភ្នែកទូលបង្គំ»។

ប្រសិនបើលោកអ្នកកំពុងតែអាន ឬក៏ស្ដាប់អត្ថបទនេះ ហើយលោកអ្នកលើកឡើងថា «ខ្ញុំបានព្យាយាមធ្វើដូច្នោះហើយ ប៉ុន្តែវាមិនបានដំណើរការសម្រាប់ខ្ញុំសោះ» ឬក៏ថា «ខ្ញុំទាំងមិនដឹងថា លោកគ្រូកំពុងតែលើកឡើងអំពីអ្វីផង» ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំលើកទឹកចិត្ត និងទូលអង្វរចំពោះលោកអ្នកសិនបានទេ? លោកអ្នកទំនងជាមិនដឹងអ្វីទាល់តែសោះទាក់ទងនឹងចំណុចនេះ ហាក់បីដូចជាកូនក្មេងម្នាក់ដែលមិនដឹងអំពីរឿងរបស់មនុស្សធំ ដូចជាទាក់ទងទៅនឹងការរួមដំណេក។ ដូច្នេះ លោកអ្នកជ្រើសរើសយកការប្រៀបប្រដូចមួយផ្សេងទៀត។ លោកអ្នកទំនងជាមិនដឹងអ្វីទាល់តែសោះ ដែលនេះមានន័យថា លោកអ្នកត្រូវការអនុវត្ត។ ខ្ញុំសូមអង្វរ៖ កុំទាន់បោះបង់ការព្យាយាមចោលឡើយ។ សូមកុំទាន់និយាយថា ខ្លួនមិនអាចមានសមត្ថភាពធ្វើការនេះ ដើម្បីឲ្យស្គាល់ភាពស្រស់ស្អាតនៃចំណេះដឹងរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរ និងចំណេះដឹងនៃរបៀបរបស់ទ្រង់ឡើយ។ ខគម្ពីរនេះគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅកាន់លោកអ្នក។ ចូរផ្ទៀងចិត្តអនុវត្តចុះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**

I Read the Bible and Feel Nothing—What Should I Do？

**ខ្ញុំអានព្រះគម្ពីរ ហើយមិនមានអារម្មណ៍អ្វីសោះ—តើខ្ញុំគួរធ្វើដូចម្ដេច？**

https://www.desiringgod.org/interviews/i-read-the-bible-and-feel-nothing-what-should-i-do



# សំណួរទី២១៖
# ខ្ញុំមិនដែលអានព្រះគម្ពីរទេ តើខ្ញុំគួរចាប់ផ្ដើមនៅត្រង់ណា?

«ជម្រាបសួរលោកគ្រូ ប្រសិនបើខ្ញុំមិនធ្លាប់ដែលអានព្រះគម្ពីរតែម្នាក់ឯងសោះ តើខ្ញុំគួរចាប់ផ្ដើមអាននៅក្នុងកណ្ឌមួយណា?»

ខ្ញុំចង់និយាយលេងជាមួយនឹងអ្នកសួរសំណួរនេះខ្លាំងណាស់។ ដូច្នេះខ្ញុំសង្ឃឹមថា គាត់កំពុងតែអាន ឬក៏ស្ដាប់ការឆ្លើយតបនេះ។ តោះ! ចូរយើងចាប់ផ្ដើមពីចំណុចសូន្យ ដោយពិនិត្យមើលរូបភាពធំសិន ដែលការធ្វើដូចនោះនឹងជួយឲ្យងាយយល់ចម្លើយដ៏សាមញ្ញរបស់ខ្ញុំ។

**ព្រះគម្ពីរគឺជា. . .**

ព្រះគម្ពីរគឺជាការប្រមូលផ្ដុំ៦៦កណ្ឌខុសៗគ្នាចូលជាសៀវភៅមួយ។ កណ្ឌទាំងនោះត្រូវបានសរសេរឡើងដោយមនុស្សខុសៗគ្នា អស់រយៈពេល ១៥០០ឆ្នាំ ដែលការនេះកាន់តែធ្វើឲ្យព្រះគម្ពីរកាន់តែអស្ចារ្យ ដោយសារកណ្ឌនីមួយៗមានភាពស៊ីគ្នា និងរួមគ្នាក្នុងដំណើរការសាច់រឿង។ ប៉ុន្តែ វាគឺជារឿងដ៏សំខាន់ណាស់ក្នុងការដែលយើងទទួលស្គាល់ថា មានអ្នកនិពន្ធជាច្រើននាក់—អ្នកនិពន្ធដែលជាមនុស្ស—មិនមែនតែម្នាក់នោះទេ។

ដូច្នេះ  ៦៦កណ្ឌនេះ នៅក្នុងសៀវភៅតែមួយក្បាល ដែលយើងហៅថាព្រះគម្ពីរ មានប្រភេទអក្សរសាស្ត្រខុសៗគ្នា។ ខ្លះជាប្រវត្តិសាស្ត្រ ខ្លះជាកំណាព្យ ខ្លះជាទំនាយ ខ្លះជាសំបុត្រ។ល។—ដែលទាំងអស់មានរបៀបសរសេរខុសៗគ្នា។ ហើយយើងក៏បានចែកកណ្ឌទាំងនេះទៅជាពីរផ្នែក៖ ព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី។ ពាក្យ «សញ្ញា» ក្នុងភាសាដើម

មានន័យថា «ការឯកភាព» ឬក៏ «សេចក្តីតាំងសញ្ញា» ទាក់ទងនឹងរបៀបដែលព្រះជាម្ចាស់បានធ្វើការជាមួយនឹងរាស្រ្តរបស់ទ្រង់។ ព្រះគម្ពីរសញ្ញាចាស់មានកណ្ឌដែលបានសរសេរឡើងមុនព្រះយេស៊ូវគ្រីស្ទយាងមកផែនដីនេះ ហើយព្រះគម្ពីរសញ្ញាថ្មី (ឬក៏ «សេចក្តីតាំងសញ្ញាថ្មី») មានកណ្ឌដែលបានសរសេរឡើងក្រោយព្រះយេស៊ូវគ្រីស្ទបានយាងមក។

ព្រះគម្ពីរសញ្ញាចាស់មានកណ្ឌដែលរៀបរាប់អំពីការត្រៀមទុកនៃការយាងមកផែនដីនេះរបស់ព្រះរាជបុត្រានៃព្រះ—ព្រះយេស៊ូវគ្រីស្ទ។ ហើយព្រះគម្ពីរសញ្ញាថ្មីគឺអំពីអ្វីដែលព្រះអង្គបានធ្វើថា ទ្រង់ជាអ្នកណា និងអំពីរបៀបដែលព្រះអង្គបង្កើតចលនាគ្រីស្ទបរិស័ទ ព្រមទាំងអំពីរបៀបដែលយើងគួររស់នៅ ក្នុងនាមជាគ្រីស្ទបរិស័ទ ទាក់ទងនឹងរាល់ចំណុចទាំងនោះ។ ព្រះគម្ពីរសញ្ញាចាស់មាន៣៩កណ្ឌ ហើយព្រះគម្ពីរសញ្ញាថ្មីមាន២៧កណ្ឌ។

## សូមចាប់ផ្តើមនៅចំណុចកណ្តាល

ក្នុងបណ្ណាល័យដ៏ធំមួយនេះ ដែលព្រះជាម្ចាស់បានបណ្តាលឲ្យតែងកណ្ឌដ៏ពិតទាំងនេះ តើលោកអ្នកគួរចាប់ផ្តើមអាននៅត្រង់ណា? ចម្លើយរបស់ខ្ញុំគឺថា ដោយសារព្រះយេស៊ូវគឺជាតួអង្គចម្បងនៅក្នុងព្រះគម្ពីរ ហើយព្រះអង្គក៏ជាអង្គដែលពន្យល់នូវរាល់គ្រប់ចំណុចទាំងអស់ផ្សេងៗទៀត—ប្រសិនបើលោកអ្នកយល់អំពីព្រះយេស៊ូវ នោះលោកអ្នកក៏នឹងអាចយល់ផ្នែកផ្សេងៗទៀតបានយ៉ាងល្អផងដែរ—ដូច្នេះ លោកអ្នកត្រូវតែស្គាល់ព្រះអង្គសិន។ មាន៤កណ្ឌនៅក្នុងការចាប់ផ្តើមព្រះគម្ពីរសញ្ញាថ្មី ដែលរៀបរាប់អំពីព័ន្ធកិច្ចរបស់ទ្រង់ និងរៀបរាប់អំពីព្រះជន្មរបស់ទ្រង់ ទោះបីគ្មានកណ្ឌណាបានរៀបរាប់រាល់ឆ្នាំនៃព្រះជន្មរបស់ទ្រង់ក៏ដោយ ដោយសារអ្វីដែលព្រះអង្គបានធ្វើនៅក្នុងអំឡុងបីឆ្នាំចុងក្រោយរបស់ទ្រង់គឺសុទ្ធតែសំខាន់។ នេះហើយជាមូលហេតុដែលអ្នកនិពន្ធបានផ្តោតលើបីឆ្នាំនោះ។



យើងហៅកណ្ឌទាំង៤នេះថា កណ្ឌដំណឹងល្អ—ដំណឹងល្អតាមរយៈលោក ម៉ាថាយ ដំណឹងល្អតាមរយៈលោក ម៉ាកុស ដំណឹងល្អតាមរយៈលោក លូកា និងដំណឹងល្អតាមរយៈលោក យ៉ូហាន។ ដំណឹងល្អគឺជាមូលដ្ឋាននៃជំនឿរបស់យើង។

## ចាប់ផ្តើមជាមួយនឹងសញ្ញាថ្មី

នេះគឺជាកន្លែងដែលខ្ញុំនឹងចាប់ផ្តើម៖ ចាប់ផ្តើមដោយអានកណ្ឌគម្ពីរ ម៉ាកុស ពីព្រោះកណ្ឌនេះខ្លីជាងគេបំផុត—មានតែ១៦ ជំពូកដ៏ខ្លីប៉ុណ្ណោះ។ ខ្ញុំនឹងចាប់ផ្តើមនៅកន្លែងនោះ ហើយនេះជារបៀបដែលខ្ញុំនឹងធ្វើ។ ខ្ញុំនឹងញែកពេលពីរម៉ោងនៅព្រឹកថ្ងៃអាទិត្យណាមួយ ឬក៏ល្ងាចថ្ងៃសៅរ៍ណាមួយ ឬក៏ពេលណាផ្សេងទៀតដែលខ្ញុំទំនេរ ហើយអង្គុយអានកណ្ឌគម្ពីរនេះទាំងមូលតែម្តង—១៦ជំពូក។ ហើយខ្ញុំញែកពេលពីរម៉ោងគឺដោយសារខ្ញុំជាអ្នកអានយឺតៗ ហើយនោះក៏ជាអ្វីដែលខ្ញុំបានធ្វើដែរ។ ខ្ញុំបានអានកណ្ឌគម្ពីរ ម៉ាកុស ទាំងមូលក្នុងពេលតែមួយ។ លោកអ្នកទំនងជាអាចធ្វើការនេះបានក្នុងពេលតែមួយម៉ោង។ ការអានបែបនោះនឹងនាំឲ្យលោកអ្នកយល់ត្រួសៗអំពីព័ន្ធកិច្ចរបស់ព្រះយេស៊ូវ ក្នុងរបៀបដ៏លឿន។ ពាក្យ «ភ្លាម» គឺជាពាក្យដ៏សាមញ្ញមួយនៅក្នុងកណ្ឌគម្ពីរ ម៉ាកុស។

ហើយបន្ទាប់មក ចំណុចទីពីរដែលខ្ញុំនឹងធ្វើគឺ អានដូចនោះជាមួយនឹងកណ្ឌគម្ពីរយ៉ូហានដែរ។ កណ្ឌគម្ពីរនេះវែងជាង—មាន២១ជំពូក ហើយជំពូកនេះមួយៗក៏វែងដែរ។ កណ្ឌគម្ពីរម៉ាកុស គឺជាកណ្ឌដែលរៀបរាប់ដំណើររឿងក្នុងរបៀបប្រញាប់ប្រញាប់ ពេញទៅដោយសកម្មភាព អំពីអ្វីដែលព្រះយេស៊ូវបានធ្វើ។ ចំណែកឯកណ្ឌគម្ពីរយ៉ូហាន គឺជាកណ្ឌដែលសញ្ជឹងគិត និងមិនសូវមានសកម្មភាពច្រើន។ កណ្ឌនេះមានការបង្រៀនជាច្រើនរបស់ព្រះយេស៊ូវ។ កណ្ឌគម្ពីរយ៉ូហាននាំឲ្យយើងអាចចូលទៅក្នុងព្រះតម្រិះ និង

ព្រះចិន្តារបស់ព្រះយេស៊ូវ ក្នុងរបៀបដែលមានការសហការ និងផ្ដោតជាមួយគ្នា។

ហើយបន្ទាប់ពីពេលដែលលោកអ្នកបានអានកណ្ឌគម្ពីរម៉ាកុស និងកណ្ឌគម្ពីរយ៉ូហាន ដើម្បីឲ្យបានស្គាល់អំពីអ្វីដែលព្រះអង្គបានធ្វើ បង្រៀន ដឹងថាព្រះអង្គជានរណា នោះខ្ញុំចង់តម្រង់ផ្លូវពីរទៀតឲ្យលោកអ្នកជ្រើសរើស អាស្រ័យត្រង់ថាលោកអ្នកជាមនុស្សដែលមានលក្ខណៈដូចម្ដេច។ ប្រសិនបើលោកអ្នកជាបុគ្គលដែលចូលចិត្តឃើញការរៀបចំយ៉ាងមានសណ្ដាប់ធ្នាប់ ក្នុងរបៀបដែលស្អាតទាំងមូល នោះជាបន្ទាប់ខ្ញុំចង់លើកទឹកចិត្តឲ្យលោកអ្នកទៅអានកណ្ឌគម្ពីររ៉ូម—ជាកណ្ឌដែលមាន១៦ជំពូកដែរ។

ឬក៏ថា ប្រសិនបើលោកអ្នកគឺជាបុគ្គលដែលចូលចិត្តដំណើររឿងដែលមានសកម្មភាពលឿនៗ ហើយលោកអ្នកចង់ឃើញថាមានអ្វីបានកើតឡើង—តើចលនានេះបានរាលដាលពាសពេញពិភពលោកយ៉ាងដូចម្ដេច—នោះខ្ញុំចង់លើកទឹកចិត្តឲ្យលោកអ្នកទៅអានកណ្ឌគម្ពីរកិច្ចការ ដ្បិតកណ្ឌនោះមានពេញទៅដោយសកម្មភាព។ កណ្ឌគម្ពីរកិច្ចការគឺជាកណ្ឌរៀបរាប់អំពីរបៀបដែលដំណឹងល្អបានចាកចេញពីទីក្រុងយេរូសាឡឹម បន្ទាប់ពីព្រះយេស៊ូវបានសុគត ហើយបានមានព្រះជន្មរស់ឡើងវិញ រហូតទៅដល់ទីក្រុងរ៉ូម ប្រមាណជា៣០ឆ្នាំក្រោយមក ហើយកណ្ឌគម្ពីរកិច្ចការក៏រៀបរាប់អំពីព័ន្ធកិច្ចដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងការដែលទ្រង់បង្កើតក្រុមជំនុំរបស់ទ្រង់ដែរ។

### ចំកណ្ដាលគម្ពីរទំនុកតម្កើងតែម្ដង

ហើយចំណុចចុងក្រោយដែលខ្ញុំនឹងលើកឡើងគឺថា មានកណ្ឌមួយនៅក្នុងព្រះគម្ពីរ គឺចំត្រង់កណ្ដាលនៃព្រះគម្ពីរ។ ប្រសិនបើលោកអ្នកបើកព្រះគម្ពីរចំកណ្ដាលតែម្ដង នោះលោកអ្នកនឹងបើកចំកណ្ឌគម្ពីរទំនុកតម្កើង—ដែលមាន១៥០ជំពូក។ កណ្ឌនេះគឺជាកំណត់ត្រានៃការអធិស្ឋាន និងបទចម្រៀងរបស់រាស្ត្ររបស់ព្រះជាម្ចាស់—ជំពូកជាច្រើនត្រូវបាននិពន្ធឡើងដោយស្ដេចដាវីឌ—កណ្ឌនេះមានសរសេរចុះអំពីរាល់អារម្មណ៍ ទាំងអារម្មណ៍សប្បាយ និងអារម្មណ៍ខូចចិត្ត ក៏ដូចជាការតយុទ្ធរបស់រាស្ត្ររបស់ព្រះជាម្ចាស់ដែរ។

មានមនុស្សជាច្រើនស្រឡាញ់កណ្ឌនេះខ្លាំងជាងកណ្ឌនានានៅក្នុងព្រះគម្ពីរ។ ប្រពន្ធរបស់ខ្ញុំធ្លាប់លើកឡើងថា គាត់ស្រឡាញ់កណ្ឌគម្ពីរទំនុកតម្កើងខ្លាំងជាងគេ។ នេះគឺជារបៀបដែលខ្ញុំនឹងធ្វើ។ តាមរយៈការអានកណ្ឌគម្ពីរទំនុកតម្កើង នោះលោកអ្នកនឹងមានរបៀបគ្រប់គ្រងលើអារម្មណ៍ជាច្រើនដែលលោកអ្នកនឹងមានក្នុងនាមជាគ្រីស្ទបរិស័ទថ្មីម្នាក់។

### ទាំងអស់ល្អណាស់

សូមបង្អង់ខ្លួនបន្តិច ហើយមើលនូវអ្វីដែលកំពុងតែទាក់ទាញចំណាប់អារម្មណ៍របស់លោកអ្នក។ សូមកុំគិតថាយោបល់របស់ខ្ញុំ ឬក៏យោបល់របស់អ្នកណាផ្សេងទៀតគឺជាអ្វីដែលលោកអ្នកត្រូវតែធ្វើ ក្នុងការចាប់ផ្ដើមអានព្រះគម្ពីរឡើយ។ ព្រះគម្ពីរទាំងមូលគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គគឺជាអង្គដែលបានបណ្ដាលឲ្យតែងគ្រប់ខទាំងអស់ ហើយយើងអាចទុកចិត្តលើបានគ្រប់ផ្នែកទាំងអស់—គ្រប់ផ្នែកទាំងអស់ដែលជាប្រយោជន៍ក្នុងការជួយឲ្យលោកអ្នកស្គាល់ព្រះគ្រីស្ទ នឹងដឹងអំពីរបៀបដែលអាចទទួលបានការសង្គ្រោះចេញពីអំពើបាប ចេញពីការជំនុំជម្រះ និងដឹងអំពីរបៀបដែលអាចទទួលបានជីវិតអស់កល្បជានិច្ច ក៏ដូចជាដឹងអំពីរបៀបរស់នៅដែលអាចផ្គាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់នៅលើលោកនេះបានដែរ។

លោកអ្នកកំពុងតែស្ថិតនៅក្នុងជំហាននៃការចាប់ផ្ដើមដំណើរផ្សងព្រេងដ៏អស្ចារ្យនៃជីវិតរបស់ខ្លួន។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖
I’ve Never Read the Bible, Where Should I Start?
ខ្ញុំមិនដែលអានព្រះគម្ពីរទេ តើខ្ញុំគួរចាប់ផ្តើមនៅត្រង់ណា?
https://www.desiringgod.org/interviews/ive-never-read-the-bible-where-should-i-start



# សំណួរទី២២៖
# តើការអានព្រះគម្ពីររបស់ខ្ញុំបែបជាការសិក្សាខ្លាំងពេកមែនឬ?

ប្អូនស្រី សោភ័ណ្ឌ បានផ្ញើសារសួរដូចតទៅ៖ «ស្ត្រីចាស់ៗនៅព្រះវិហារខ្ញុំបារម្ភអំពីរបៀបដែលខ្ញុំសិក្សាព្រះគម្ពីរ។ ពួកគាត់គិតថា ការអានព្រះគម្ពីររបស់ខ្ញុំវាបែបជាការសិក្សាខ្លាំងពេកហើយ ប៉ុន្តែនេះជារបៀបតែមួយដែលខ្ញុំចេះក្នុងការអានព្រះគម្ពីរ។ គ្មានអ្វីដែលធ្វើឲ្យខ្ញុំកាន់តែរំភើបជាងការឃើញភាពស៊ីគ្នារវាងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មីនោះទេ។ ដោយប្រើប្រាស់ប៊ិចមានពណ៌ខុសៗគ្នា ខ្ញុំគូសចំណាំ និងសរសេរចុះលើគែមទំព័រព្រះគម្ពីររបស់ខ្ញុំនូវអ្វីដែលព្រះជាម្ចាស់បានបើកសម្ដែងឲ្យខ្ញុំឃើញ។ ខ្ញុំជឿជាក់ថានេះគឺជារបៀបមួយដែលខ្ញុំថ្វាយបង្គំព្រះជាម្ចាស់ ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំកាន់តែស្និទ្ធស្នាលជាមួយនឹងព្រះអង្គ ខណៈពេលដែលខ្ញុំអានព្រះបន្ទូលរបស់ទ្រង់ ហើយឃើញអំពីការលាតត្រដាងឲ្យយល់នូវដំណើររឿងរបស់ព្រះអង្គនៅលើទំព័រនីមួយៗ។ ស្ត្រីចាស់ៗនៅព្រះវិហារខ្ញុំបានលើកឡើងថា ខ្ញុំគួរអានព្រះគម្ពីរបែបជាការចំណាយពេលជាមួយនឹងព្រះជាម្ចាស់ ជាជាងការសិក្សា។ ពួកគាត់បារម្ភថា ខ្ញុំផ្ដោតលើចំណុចភ្ជាប់គ្នាបែបចំណេះដឹងក្នុងខួរក្បាល ខ្លាំងជាងចំណុចភ្ជាប់គ្នាបែបផ្លាស់ប្រែដួងចិត្ត។ តើការអានព្រះគម្ពីររបស់ព្រះជាម្ចាស់បែបសិក្សាអាចនៅថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់បានដែរឬទេ?»

នៅពេលដែលខ្ញុំឮសំណួរដូចនេះ វាធ្វើឲ្យខ្ញុំកាន់តែចង់យល់អំពីអ្វីដែលស្ត្រីចាស់ៗកំពុងតែគិតទាក់ទងទៅនឹងការបារម្ភចំពោះប្អូនស្រី សោភ័ណ្ឌ ហើយខ្ញុំក៏កាន់តែចង់យល់អំពីអ្វីដែលប្អូនស្រីកំពុងតែគិតផងដែរ ដោយសារ

ខ្ញុំចង់យល់ថា តើពួកគាត់កំពុងតែគិតអំពីអ្វី។ ទំនងខ្ញុំនឹងគាំទ្ររបៀបសិក្សារបស់ប្អូនស្រីហើយផ្ដល់ជូនចំណុចមួយចំនួនសម្រាប់ស្ត្រីចាស់ៗ ក្នុងការឲ្យពួកគាត់មានអាកប្បកិរិយាខុសគ្នាអំពីអ្វីដែលពួកគាត់កំពុងតែគិតនេះ។ ខ្ញុំនឹងលើកឡើងអំពីចំណុចនេះនៅពេលក្រោយ។ ឬក៏ថា ទំនងខ្ញុំក៏នឹងគាំទ្រការបារម្ភរបស់ស្ត្រីចាស់ៗនៅឯព្រះវិហារនោះក៏ថាបានដែរ គឺឃើញអ្វីដែលកំពុងតែកើតឡើងនៅក្នុងចិត្តគំនិតរបស់ប្អូនស្រីហើយក៏នឹងលើកឡើងនូវចំណុចមួយចំនួន ដើម្បីឲ្យគាត់ប្រុងប្រយ័ត្ន ដោយមិនបោះបង់ចោលការបារម្ភ។

ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវចំណុចវិជ្ជមានអំពីការបារម្ភទាំងសងខាង ដើម្បីឲ្យប្អូនស្រី សោភ័ណ្ឌ ឃើញថា គាត់ស្ថិតនៅក្នុងការឆ្លើយតបមួយណា។

## មានអំណរជាមួយនឹងព្រះជាម្ចាស់ផ្ទាល់

ប្រសិនបើខ្ញុំគិតវិជ្ជមានអំពីស្ត្រីចាស់ៗនៅឯព្រះវិហារ នោះខ្ញុំនឹងសួរប្អូនស្រី សោភ័ណ្ឌ ថា តើគាត់សប្បាយចិត្តក្នុងការឃើញចំណុចភ្ជាប់គ្នារវាងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី ដល់ថ្នាក់ថា គឺគ្រាន់តែសប្បាយចិត្តក្នុងការឃើញចំណុចភ្ជាប់គ្នាដូចនោះនៅក្នុងចំណេះដឹង ប៉ុន្តែមិនសប្បាយចិត្ត ឬក៏មានអំណរជាមួយនឹងព្រះជាម្ចាស់ផ្ទាល់ដែរឬទេ?

តើអាចទេដែលស្ត្រីចាស់ៗឃើញថា ទំនងប្អូនស្រី សោភ័ណ្ឌ ស្រឡាញ់ចំណេះដឹងខ្លាំងជាងព្រះជាម្ចាស់ផ្ទាល់? ត្រង់ចំណុចនេះ ប្អូនស្រីត្រូវតែមានការប្រុងប្រយ័ត្ន ពីព្រោះវាមិនមែនជាចំណុចសខ្មៅនោះទេ។ ហើយវាក៏មិនមែនថាជាចំណុចមួយនេះ ហើយថាជាចំណុចមួយនោះដែរ។ វាមានភាពស្រពិចស្រពិលបន្តិច—គឺការស្រឡាញ់ដំណើរការនៃការស្វែងរកបានចំណុចអ្វីមួយ ជាជាងស្រឡាញ់អ្វីដែលរកបាន។ ឬក៏ថា វាកាន់តែពិបាករែកញែក



ទៅទៀត—តើប្អូនស្រីកំពុងតែស្រឡាញ់អ្វីដែលកំពុងតែរកបានខ្លាំងជាងបុគ្គលដែលបានបើកសម្ដែងឲ្យឃើញមែនឬ?

មិនមានបុគ្គលណាដែលអាចជៀសផុតពីគ្រោះថ្នាក់នេះបានឡើយ—មិនមានទេ។ មិនថាពួកគាត់កំពុងតែធ្វើអ្វីក៏ដោយ មិនថាពួកគាត់កំពុងតែថ្វាយបង្គំជុំគ្នា ឬក៏កំពុងតែអានព្រះគម្ពីររៀងៗខ្លួន ក៏ការនេះនៅអាចកើតឡើងបានដែរ៖ គឺពួកគាត់មានអំណរក្នុងដំណើរការនៃការសរសើរតម្កើងព្រះជាម្ចាស់ជាជាងមានអំណរក្នុងព្រះជាម្ចាស់ផ្ទាល់។ មានអ្នកខ្លះសប្បាយរីករាយក្នុងការច្រៀងសរសើរតម្កើងព្រះជាម្ចាស់ខ្លាំងជាងការមានអំណរក្នុងទ្រង់ផ្ទាល់។ សរុបសេចក្ដីទៅ នៅក្នុងពេលដូចនេះ យើងទាំងអស់គ្នាសុទ្ធតែមានចំណុចខ្សោយ។

ខ្ញុំទទួលបានការលើកទឹកចិត្តជាខ្លាំង នៅពេលដែលខ្ញុំឮអំពីរបៀបដែលប្អូនស្រី សោភ័ណ្ឌ និយាយ ពីព្រោះនៅពេលដែលគាត់លើកឡើងថា «ខ្ញុំជឿជាក់ថា នេះគឺជារបៀបមួយដែលខ្ញុំថ្វាយបង្គំព្រះជាម្ចាស់ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំកាន់តែស្និទ្ធស្នាលជាមួយនឹងព្រះអង្គ ខណៈពេលដែលខ្ញុំអានព្រះបន្ទូលរបស់ទ្រង់ ហើយឃើញអំពីការលាតត្រដាងឲ្យយល់នូវដំណើររឿងរបស់ព្រះអង្គនៅលើទំព័រនីមួយៗ»។ ខ្ញុំចង់ឯកភាពដោយលើកឡើងថា «អាម៉ែន! អាម៉ែន!»។ ខ្ញុំសប្បាយចិត្តណាស់ នៅពេលដែលឃើញគាត់លើកឡើងដោយប្រើពាក្យពេចន៍ដូចនេះ។ ហើយខ្ញុំមានចំណុចតែមួយទេក្នុងការឲ្យប្អូនស្រីមានការប្រុងប្រយ័ត្ន ខណៈពេលដែលខ្ញុំព្យាយាមយល់ថា តើស្ត្រីចាស់ៗនៅឯព្រះវិហាររបស់គាត់កំពុងតែគិតអំពីអ្វី ទាក់ទងនឹងការបារម្ភរបស់ពួកគាត់៖ គឺថាប្អូនស្រីអាចចាប់ផ្ដើមមានការចាប់អារម្មណ៍លើចំណុចលម្អិតនៃប្រវត្តិសាស្ត្រនៃការប្រោសលោះ និងអំពីការបកស្រាយដោយប្រើប្រាស់រចនាសម្ព័ន្ធនៃតួអង្គក្នុងព្រះគម្ពីរ ដែលទំនងមិនមានភាពស៊ីគ្នាជាមួយនឹងជីវិតរស់នៅជាក់ស្ដែង សម្រាប់ស្ត្រីដែលមានវ័យចាស់ៗនេះ ដែលមិនសូវ

មានចំណាប់អារម្មណ៍លើអ្វីដែលប្អូនស្រីកំពុងតែស្វែងរកឃើញ។

## ការបកស្រាយដោយប្រើប្រាស់រចនាសម្ព័ន្ធនៃតួអង្គ និងសេចក្ដីប្រាថ្នា

វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់—ព្រះអង្គពិតជាល្អមែន—ទើបតែព្រឹកមិញនេះ ខ្ញុំបានចំណាយពេលស្ងៀមស្ងាត់ជាមួយនឹងព្រះអង្គដោយអានកណ្ឌគម្ពីរ ១កូរិនថូសជំពូក១០។ នៅក្នុងជំពូកនេះសាវ័ក ប៉ុល បានស្ដីបន្ទោសពួកជំនុំកូរិនថូស ទាក់ទងនឹងអាកប្បកិរិយាអាក្រក់ៗ ហើយគាត់ក៏បានព្រមានពួកគេដែរ។ ហើយរបៀបដែលគាត់បានធ្វើការនោះគឺតាមរយៈការប្រើប្រាស់ព្រះគម្ពីរសញ្ញាចាស់ (ទាក់ទងទៅនឹងរាស្ត្រនៃសាសន៍អ៊ីស្រាអែលនៅក្នុងស្រុកអេស៊ីព្ទ នៅក្នុងកណ្ឌគម្ពីរនិក្ខមនំ នៅឯទីរហោស្ថាននៃភ្នំស៊ីណាយ) ដើម្បីជួយឲ្យពួកជំនុំកូរិនថូសមានសេចក្ដីស្រឡាញ់ និងអាកប្បកិរិយាត្រឹមត្រូវ។ ហើយខ៦បានប៉ះពាល់ចិត្តខ្ញុំណាស់៖ «ការទាំងនោះបានត្រឡប់ជាគំរូដល់យើង...»។ ពាក្យ «គំរូ» ក្នុងភាសាក្រិកគឺ tupoi («ធូផូយ»)។

ប៉ុន្តែ ខ្ញុំគិតថា ប្អូនស្រី សោភ័ណ្ឌ ដឹងហើយថា ខ្ញុំកំពុងតែចង់មានន័យយ៉ាងដូចម្ដេចនៅត្រង់នេះ ពីព្រោះការប្រើគំរូ (ឬក៏ការបកស្រាយដោយប្រើប្រាស់រចនាសម្ពន្ធនៃតួអង្គ) គឺជារបៀបមួយដែលព្រះជាម្ចាស់បានត្បាញសញ្ញាចាស់ជាមួយនឹងសញ្ញាថ្មី ក្នុងដំណើររឿងនៃប្រវត្តិសាស្ត្រដ៏អស្ចារ្យរបស់ទ្រង់។ មានគំរូដែលត្រូវត្រាប់តាម និងគំរូដែលមិនត្រូវត្រាប់តាម។ ហើយនេះជាអ្វីដែលខគម្ពីរបានលើកឡើង «ការទាំងនោះបានត្រឡប់ជាគំរូ [ឧទាហរណ៍] ដល់យើង ប្រយោជន៍កុំឲ្យយើងប្រាថ្នាចង់បានសេចក្ដីអាក្រក់ ដូចជាគេឡើយ»។ ពេលដែលខ្ញុំបានអានដល់ខគម្ពីរមួយនោះ ខ្ញុំក៏បានបង្អង់សិនហើយនិយាយមកកាន់ខ្លួនឯងថា «សាវ័ក ប៉ុល ពិតជាអស្ចារ្យមែន។ គាត់កំពុងតែលើកឡើងថា គំរូគឺអំពីអារម្មណ៍»។ នោះគឺជាអ្វីដែលគាត់បានលើកឡើង។ «ការទាំងនោះបានត្រឡប់ជាគំរូ [ឧទាហរណ៍] ដល់យើង ប្រយោជន៍កុំឲ្យយើងប្រាថ្នាចង់បានសេចក្ដីអាក្រក់ ដូចជាគេឡើយ»។ នេះពិតជាអស្ចារ្យមែន។

នេះគឺជាអ្វីដែលខ្ញុំចង់ប្រាប់ប្អូនស្រី សោភ័ណ្ឌ៖ ស្ត្រីដែលមានវ័យចាស់ៗនៅឯព្រះវិហាររបស់គាត់មិនមានការរំភើបទាក់ទងទៅនឹងគំរូដូចនេះទេ។ ប៉ុន្តែ ខ្ញុំគិតថា ពួកគាត់មានការរំភើបទាក់ទងទៅនឹងសេចក្ដីប្រាថ្នាចង់ធ្វើល្អ សេចក្ដីប្រាថ្នាចង់ស្អប់អំពើអាក្រក់ និងចង់ឃើញការផ្លាស់ប្រែដូចៗនោះ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់លើកជាសំណើទៅកាន់ប្អូនស្រីថា ខណៈពេលដែលប្អូនស្រីកំពុងតែរំភើប នោះចូរឲ្យចេះជួយអ្នកដទៃឲ្យរំភើបដែរ ដូចជាស្ត្រីដែលមានវ័យចំណាស់ៗនៅឯព្រះវិហាររបស់ខ្លួន គឺជួយឲ្យពួកគាត់ឃើញពីគុណប្រយោជន៍—គឺគុណប្រយោជន៍សម្រាប់ថ្វាយបង្គំ សម្រាប់អំណរ សម្រាប់ការចេះកោតខ្លាចព្រះជាម្ចាស់ ជាជាងគ្រាន់តែសប្បាយចិត្តជាមួយនឹងការគូសចំណាំដោយប្រើប្រាស់ប៊ិចដែលមានពណ៌ច្រើនដែលគាត់បានឃើញ។ ទំនងស្ត្រីដែលមានវ័យចំណាស់នៅឯព្រះវិហាររបស់ប្អូនស្រីមិនមានចំណាប់អារម្មណ៍បែបចំណេះដឹងដូចនេះទេ។ ពួកគាត់មិនទទួលបានការរំភើបដូចប្អូនស្រីទេ។

ប៉ុន្តែ ប្រសិនបើប្អូនស្រីអាចឆ្លងកាត់ចំណុចនេះបាន នោះពួកគាត់នឹងអាចជាទំនងលើកឡើងថា «បានៗ ប្រសិនបើប្អូនស្រីអាចឈានទៅដល់ចំណុចនៃការថ្វាយបង្គំ ការទទួលបានអំណរ ការចេះកោតខ្លាចព្រះ ហើយប្រសិនបើការសិក្សាបែបនោះកំពុងតែជះឥទ្ធិពលយ៉ាងអស្ចារ្យដូចនេះមែន នោះយើងនឹងគាំទ្ររបៀបចម្លែកដែលប្អូនស្រីកំពុងតែប្រើប្រាស់ក្នុងការអានព្រះគម្ពីរ»។

## ចូរឲ្យការសិក្សាបង្កើតឲ្យមានសេចក្ដីស្រឡាញ់

ប៉ុន្តែ សូមអនុញ្ញាតឲ្យខ្ញុំបញ្ចប់អត្ថបទនេះ ដោយគិតវិជ្ជមានអំពីប្អូនស្រី សោភ័ណ្ឌ បន្តិចដែរ។ ការណែនាំអំពីភាពប្រុងប្រយ័ត្នទាំងនេះទំនងមិនមែនជាអ្វីដែលគាត់កំពុងតែសួរនាំនោះទេ។ ហើយទំនងខ្ញុំត្រូវតែណែនាំស្ត្រីដែលមានវ័យចំណាស់ឲ្យពួកគាត់មានការប្រុងប្រយ័ត្នវិញ។ នេះជាអ្វីដែលខ្ញុំចង់ធ្វើក្នុងការបញ្ចប់អត្ថបទនេះ៖ គឺខ្ញុំចង់គិតវិជ្ជមានអំពីប្អូនស្រី សោភ័ណ្ឌ។ សូមអនុញ្ញាតឲ្យខ្ញុំណែនាំស្ត្រីដែលមានវ័យចំណាស់នៅឯព្រះវិហារគាត់ឲ្យមានការប្រុងប្រយ័ត្ន ពីព្រោះមើលទៅហាក់បីដូចជាពួកគាត់កំពុងតែបន្ទាបចំណុចសំខាន់នូវអ្វីដែលប្អូនស្រី សោភ័ណ្ឌ កំពុងតែធ្វើហើយ។

ចម្លើយរបស់ខ្ញុំសម្រាប់សំណួរ ប្អូនស្រី សោភ័ណ្ឌ ដែលថា «តើការអានព្រះគម្ពីររបស់ព្រះជាម្ចាស់បែបសិក្សាអាចនៅថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់បានដែរឬទេ?» ចម្លើយគឺ៖ «បាន»។ ហើយខ្ញុំក៏ចង់ឲ្យគាត់ប្រើប្រាស់ពាក្យផ្សេងទៀតដូចជា «បែបយកចិត្តទុកដាក់» «បែបម៉ត់ចត់» ឬក៏ «បែបលម្អិត»។ ពាក្យ «បែបសិក្សា» អាចនាំឲ្យមនុស្សមួយចំនួនគិតបែបអវិជ្ជមាន។ ប៉ុន្តែ ខ្ញុំដឹងអំពីអត្ថន័យដែលប្អូនស្រីកំពុងតែប្រើប្រាស់។ តើការអានព្រះគម្ពីររបស់ព្រះជាម្ចាស់បែបសិក្សាអាចនៅថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់បានដែរឬទេ? ចម្លើយគឺ៖ «បាន»។ ប្អូនស្រីកំពុងតែធ្វើជាគំរូហើយ ហើយខ្ញុំក៏សង្ឃឹមថា ខ្ញុំក៏អាចធ្វើជាគំរូម្នាក់បានដែរ។ ខ្ញុំចង់ថ្វាយសិរីល្អទៅព្រះជាម្ចាស់តាមរយៈការសិក្សាព្រះគម្ពីរបែបយកចិត្តទុកដាក់ បែបម៉ត់ចត់ និងបែបលម្អិតដែលអាចឈានទៅដល់កម្រិត ដែលព្រះជាម្ចាស់បានសរសេរចុះ។

ប៉ុន្តែ នេះជាចំណុចដែលយើងទាំងអស់គ្នាត្រូវតែចងចាំ៖ ព្រះជាម្ចាស់បានបង្កើតអ្នកខ្លះក្នុងករណីដែលថា ហ្សែនរបស់គាត់និងប៉ះពាល់របៀបសិក្សាបែបលម្អិត ត្រង់ថាខួរក្បាលរបស់គាត់នឹងបិទចលនាបេះដូងរបស់



គាត់។ ពិតជាមានមនុស្សដូចនោះមែន។ នៅពេលដែលពួកគាត់ព្យាយាមគិតដោយយកចិត្តទុកដាក់ នោះស្រាប់តែពួកគាត់ចាប់ផ្ដើមមានអារម្មណ៍ត្រជាក់ៗ។ ហើយសម្រាប់មនុស្សដូចយើងដែលចូលចិត្តការសិក្សាបែបលម្អិត ទំនងជាយើងគ្រវីក្បាល ហើយលើកឡើងថា «ទេៗ វាមិនដំណើរការក្នុងរបៀបនោះឡើយ»។ ហើយពួកគាត់ទំនងជាឆ្លើយតបវិញថា «តាមពិតទៅ វាដំណើរការក្នុងរបៀបនោះមែន»។ ប្រសិនបើយើងព្យាយាមយល់ពីពួកគាត់មែន ប្រសិនបើវាពិតជាដំណើរការក្នុងរបៀបនោះមែន នោះពួកគាត់នឹងប្រាកដជាសន្មតថា ត្រូវតែដំណើរការដូចនោះចំពោះលោកអ្នកដែរជាមិនខាន។ នេះហើយជាមូលហេតុដែលពួកគាត់សង្ស័យក្នុងរបៀបនៃការសិក្សាបែបនេះ—ពីព្រោះនោះគឺជាបទពិសោធន៍របស់ពួកគាត់។

នេះគឺជាអ្វីដែលខ្ញុំបានធ្លាប់ព្យាយាមធ្វើអស់រយៈពេល៣៣ឆ្នាំក្នុងការអធិប្បាយ ពីព្រោះខ្ញុំបានសិក្សាបែបលម្អិតក្នុងការរៀបចំសេចក្ដីអធិប្បាយរបស់ខ្ញុំ ហើយខ្ញុំក៏ស្គាល់មនុស្សជាច្រើននាក់ដែលថា ប្រសិនបើខ្ញុំផ្ទេរព័ត៌មានទាំងអស់ចេញពីការសិក្សារបស់ខ្ញុំទៅពួកគាត់ នោះពួកគាត់នឹងឆ្លើយតបថា «វាពិតជាស្មុគស្មាញ ហើយមិនសូវចាប់អារម្មណ៍សោះ»។ របៀបឈានទៅមុខទៀតដែលខ្ញុំដឹងគឺថា—ហើយនេះជាយោបល់របស់ខ្ញុំសម្រាប់ប្អូនស្រី សោភ័ណ្ឌ—បុគ្គលដែលចំណាយពេលយកចិត្តទុកដាក់ក្នុងការសិក្សាយ៉ាងម៉ត់ចត់ក៏ត្រូវតែព្យាយាមស្រឡាញ់ឲ្យអស់ពីចិត្តផងដែរ។ បើនិយាយម្យ៉ាងវិញទៀត ប្រសិនបើមានអ្នកដទៃគិតថារបៀបសិក្សារបស់យើងនឹងបំផ្លាញយើង នោះដាច់ខាតយើងត្រូវតែបង្ហាញឲ្យពួកគេឃើញថាវាផ្ទុយពីនោះទាំងស្រុង។ ដូច្នេះ ប្អូនស្រី សោភ័ណ្ឌ ត្រូវតែស្រឡាញ់ពួកគាត់ឲ្យលើសពីការដែលពួកគាត់ស្រឡាញ់ប្អូនស្រី ត្រូវតែមានអំណរឲ្យលើសពីការដែលពួកគាត់មានអំណរ ត្រូវតែកែប្រែចិត្តឲ្យលើសពីការដែលពួកគាត់កែប្រែចិត្ត នឹងត្រូវតែបម្រើពួកគាត់ឲ្យលើសពីការដែលពួកគាត់បម្រើប្អូន

ស្រីវិញ។ ការធ្វើបែបនេះនឹងមិនបណ្ដាលឲ្យពួកគាត់លើកឡើងថា របៀបដែលប្អូនស្រីសិក្សាកំពុងតែធ្វើឲ្យប្អូនស្រីមានការឈឺចាប់ ពីព្រោះភស្តុតាងមិនបង្ហាញយ៉ាងដូច្នោះឡើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is My Bible Reading Too Academic？
**តើការអានព្រះគម្ពីររបស់ខ្ញុំបែបជាការសិក្សាខ្លាំងពេកមែនឬ？**
https://www.desiringgod.org/interviews/is-my-bible-reading-too-academic



# សំណួរទី២៣៖
# តើការអានព្រះគម្ពីរត្រូវបញ្ចប់ដោយមានការអនុវត្តគ្រប់ពេល?

យើងបានទទួលសារជាច្រើនដែលសួរសំណួរស្រដៀងគ្នាៗ ដែលយើងអាចសង្ខេបបានដូចនេះ៖ គ្រប់ពេលដែលយើងអានព្រះគម្ពីរ តើយើងត្រូវតែបញ្ចប់ដោយមានគោលការណ៍នៃជីវិត ឬក៏ចំណុចជាក់លាក់ណាមួយ ដើម្បីអនុវត្តមែនឬ?

ពិតណាស់ ខ្ញុំមានការចាប់អារម្មណ៍លើសំណួរនេះខ្លាំងណាស់។ ចម្លើយគឺ៖ ទេ! ហើយនេះជាមូលហេតុដែលខ្ញុំមានការចាប់អារម្មណ៍លើសំណួរនេះ។ ខ្ញុំគិតថាប្រហែលជា ៩៩% នៃជីវិតយើងគឺយើងរស់នៅដោយមិនមានការសញ្ជឹងគិតភ្លាមៗ ទាក់ទងទៅនឹងគោលការណ៍នៃជីវិត។ តែផ្ទុយពីនោះ គឺយើងមានសកម្មភាពវិញ។ ប្រសិនបើលោកអ្នកគិតអំពីថ្ងៃណាមួយរបស់លោកអ្នក នោះលោកអ្នកនឹងឃើញថា មានការសម្រេចចិត្តធំៗរាប់រយដងដែលលោកអ្នកធ្វើក្នុងមួយថ្ងៃនោះ។ តាមរយៈពាក្យ «ធំៗ» ខ្ញុំមានន័យថា យើងធ្វើដោយមាន «សម្បជញ្ញៈ»។

ប៉ុន្តែ ឥឡូវនេះ ខ្ញុំគ្រាន់តែកំពុងសន្ទនាជាមួយនឹងលោកអ្នកប៉ុណ្ណោះ។ គឺខ្ញុំគ្រាន់តែជ្រើសរើសពាក្យពេចន៍និយាយ ឬក៏សរសេរតែម្ដង។ មុនខ្ញុំជ្រើសរើសពាក្យពេចន៍ណាមួយ ខ្ញុំមិនបានឈប់ ហើយសួរខ្លួនឯងថា «តើមានគោលការណ៍អ្វីកំពុងគ្រប់គ្រងលើពាក្យមួយនេះ? តើមានគោលការណ៍ណាមួយដែលនឹងគ្រប់គ្រងលើប្រយោគមួយនេះ?» តែពាក្យពេចន៍ទាំងនោះគឺហោះចេញពីមាត់របស់ខ្ញុំតែម្ដង។

តាមពិតទៅ នេះគឺពិតជាគួរឲ្យខ្លាចមែន។ ពិត ឬក៏អត់? តើពាក្យ

ពេចន៍ទាំងនោះកើតចេញមកពីណា? ភាគច្រើននៃជីវិតយើង គឺយើងរស់នៅដោយឯកឯង។ ភាគច្រើននៃជីវិតយើង គឺយើងមិនបានរស់នៅ បន្ទាប់ពីបានសញ្ជឹងគិតអស់រយៈពេល១០វិនាទី ដោយមានមូលដ្ឋានលើគោលការណ៍ណាមួយដែលស្របតាមព្រះគម្ពីរនោះទេ។ ដូច្នេះ តើការធ្វើបែបនេះកើតចេញពីណា? វាកើតចេញពីការដែលថា តើយើងជាបុគ្គលដែលមានលក្ខណៈបែបណារួចស្រេចទៅហើយ។

ដែលនេះលើកឡើងនូវសំណួរថា៖ តើលោកអ្នកអាចក្លាយជាបុគ្គលដែលមានលក្ខណៈ ដែលអាចជាដើមឈើល្អ ដែលបង្កើតផលផ្លែភ្លាមៗជាជាងជាដើមឈើអាក្រក់ដែលបង្កើតផលផ្លែអាក្រក់ភ្លាមៗបាន ដោយរបៀបណា? ចម្លើយគឺថា៖ លោកអ្នកត្រូវតែត្រាំខ្លួនក្នុងព្រះបន្ទូល ហើយអនុញ្ញាតឲ្យការដែលលោកអ្នកឃើញព្រះយេស៊ូវ និងការដែលលោកអ្នកភ្លក់រសជាតិអំពីព្រះយេស៊ូវ និងរបៀបរបស់ទ្រង់នៅក្នុងព្រះគម្ពីរជះឥទ្ធិពល និងរចនាព្រលឹងវិញ្ញាណរបស់លោកអ្នកឡើង។ សូមប្រឡាក់ព្រលឹងវិញ្ញាណរបស់លោកអ្នកក្នុងទឹកជ្រលក់នៃព្រះគុណ រហូតទាល់តែព្រលឹងនោះទន់ផុយ ងាយគ្រប់គ្រងលើបាន និងងាយឆ្លើយតបទៅនឹងការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យថាក្នុងរបៀបណាមួយ នោះលោកអ្នកនឹងឆ្លើយតបយ៉ាងដូចម្តេច។

## អានព្រះគម្ពីរ ដើម្បីមានការភ្ញាក់ផ្អើល

ព្រះយេស៊ូវបានមានបន្ទូលថា ព្រះអង្គនឹងហៅឲ្យយើងឆ្លើយលើគ្រប់ពាក្យពេចន៍ខ្ជះខ្ជាយ ដែលយើងនិយាយឡើង។ ពាក្យពេចន៍ខ្ជះខ្ជាយ គឺជាពាក្យពេចន៍ដែលយើងបាននិយាយឡើងដោយមិនបានយកពេលគិតលើគោលការណ៍ស្របតាមព្រះគម្ពីរដែលយើងបានទទួលចេញពីព្រះគម្ពីរពេលយើងអាន។ ដូច្នេះ ខ្ញុំគិតថា ទោះអ្នកដែលមានទំនោរក្នុងការព្យាយាមទទួលបានគោលការណ៍បីយ៉ាង ឬក៏ចំណុចបីយ៉ាង ឬក៏អ្វីផ្សេងទៀត ហើយបន្ទាប់មកពួកគាត់ព្យាយាមត្រាប់តាមគោលការណ៍នោះដោយចេតនា ខណៈពេលដែលគាត់រស់នៅ គឺពួកគាត់កំពុងតែធ្វើនូវអ្វីដែលមិនអាចធ្វើទៅរួចបានដែលព្រះអង្គមិនបានរចនាយើងឡើងក្នុងការប្រព្រឹត្តនៅឡើយ។

ខ្ញុំនឹងលើកឡើងដូចនេះ។ ជីវិតដែលកោតខ្លាចព្រះជាម្ចាស់គឺជាជីវិតដែលរស់នៅដោយកើតចេញពីបេះដូង ដែលមានការភ្ញាក់ផ្អើលជាមួយនឹងព្រះគុណ—«ព្រះគុណអស្ចារ្យ ជាស័ព្ទពីរោះ ដែលប្រោះមនុស្សយ៉ាងដូចខ្ញុំ»។ ដូច្នេះ យើងអានព្រះគម្ពីរ ដើម្បីឲ្យទទួលបានការភ្ញាក់ផ្អើល។ យើងអានព្រះគម្ពីរ ដើម្បីឲ្យទទួលបានការអស្ចារ្យអំពីព្រះជាម្ចាស់ ដើម្បីឲ្យទទួលបានការអស្ចារ្យអំពីព្រះគ្រីស្ទ អំពីឈើឆ្កាង អំពីព្រះគុណ និងទទួលបានការអស្ចារ្យចំពោះដំណឹងល្អ។ ហើយនៅពេលដែលយើងចាប់អារម្មណ៍ខ្លាំងទទួលបានការអស្ចារ្យ និងការបន្ទាបខ្លួន នោះយើងនឹងដើរចេញពីការសិក្សារបស់យើង ឬក៏ងើបចេញពីកៅអី ឬក៏ពីកន្លែងណាមួយដែលយើងកំពុងតែចំណាយពេលជាមួយនឹងព្រះជាម្ចាស់ ដោយមានចិត្ត និងគោលបំណងអំពីខ្លួនឯង ដែលធ្វើឲ្យយើងក្លាយជាមនុស្សល្អប្រសើរជាងមុននៅឯតុញ៉ាំបាយ ឬក៏នៅពេលដែលយើងចេញទៅធ្វើការ។

ខ្ញុំលើកឡើងចំណុចទាំងនោះ ដើម្បីលើកឡើងថា ខ្ញុំមិនជំទាស់ទៅនឹងការដែលខំព្យាយាមទទួលបានគោលការណ៍អនុវត្តនោះទេ។ បើខ្ញុំជំទាស់នោះខ្ញុំក៏នឹងមិនសរសេរសៀវភៅ ដើម្បីផ្តល់ជូនការព្យាយាមអនុវត្ត ដែលជាជំនួយក្នុងការគិតនោះទេ។ ប៉ុន្តែ នេះគឺជាគន្លឹះ៖ ការសញ្ជឹងគិតលើសេចក្តីពិតរចនាព្រលឹងវិញ្ញាណឡើង។ កណ្ឌគម្ពីរ ២កូរិនថូស ៣:១៨ បានលើកឡើងថា យើងក្លាយជាអ្វីដែលយើងមើល។ ដូច្នេះ គោលបំណងចម្បងរបស់ខ្ញុំក្នុងការអានព្រះគម្ពីរគឺ ដើម្បីក្លាយជាបុគ្គលដែលមានលក្ខណៈដូចនោះ។ សូមកុំព្យាយាមបង្កើតគោលការណ៍ច្រើនពេក។

## ការព្យាយាមបង្កើតការគិតដោយខ្លួនឯង ដែលរចនាឡើងដោយព្រះវិញ្ញាណ

*«លោកគ្រូ តើលោកគ្រូគិតថា សមទេដែលយើងគួរលើកឡើងមកនិយាយអំពីការចេះគិតដោយខ្លួនឯង? តើជាការត្រឹមត្រូវទេក្នុងការលើកឡើងថា យើងរស់នៅជីវិតបែបជាគ្រីស្ទបរិស័ទ ដែលទទួលបានការដឹកនាំដោយព្រះវិញ្ញាណ គឺការចេះគិតដោយខ្លួនឯងដែលព្រះវិញ្ញាណបណ្ដាលឲ្យយើងគិត?»*

ពិតណាស់ វាស័ក្តិសម។ នោះគឺជាអ្វីដែលខ្ញុំកំពុងតែព្យាយាមលើកឡើង គឺត្រង់ថា ភាគច្រើននៃជីវិតរស់នៅរបស់យើង គឺជាការរស់នៅដោយរំពឹងលើធនធានដែលយើងមិនមែនកំពុងតែសញ្ជឹងគិតឥឡូវនេះ ក្នុងខួរក្បាលយើងនោះទេ។ ពាក្យសម្ដីរបស់យើងកំពុងតែកើតចេញពីខាងក្នុង—«តែឯសេចក្ដីដែលចេញពីមាត់មក នោះមកអំពីចិត្តវិញ គឺសេចក្ដីទាំងនោះហើយ ដែលធ្វើឲ្យមនុស្សស្មោកគ្រោក» (ម៉ាថាយ ១៥:១៨)។ ហើយភាគរយច្រើននៃបេះដូងនេះគឺជាអ្វីដែលកើតឡើងដោយយើងមិនដឹងខ្លួន ឬក៏ថាវាកើតឡើងដោយឯងៗ ហើយទាំងនោះក៏បានរចនាឡើងពីមួយថ្ងៃទៅមួយថ្ងៃ តាមរយៈអ្វីដែលយើងកំពុងតែទទួលយក។ វាទទួលបានការរចនាឡើងតាមអ្វីដែលយើងធ្វើជាមួយនឹងភ្នែករបស់យើងនៅលើកញ្ចក់កុំព្យូទ័រ ហើយជាពិសេសនោះគឺថា វាទទួលបានការរចនាឡើងតាមអ្វីដែលយើងធ្វើជាមួយនឹងព្រះគម្ពីររបស់យើង និងជាមួយនឹងការចំណាយពេលអធិស្ឋាន។

នៅពេលដែលខ្ញុំបានអធិស្ឋាន គឺខ្ញុំកំពុងតែទូលអង្វរព្រះអង្គ «សូមព្រះអង្គធ្វើការឲ្យកាន់តែបានជ្រៅជាងអ្វីដែលទូលបង្គំអាចធ្វើបាន តាមរយៈការអានឥឡូវនេះ។ សូមយកកាំបិតវះចុងស្រួចរបស់ព្រះអង្គ ហើយកុំគ្រាន់តែកាត់អំពើបាបដែលទូលបង្គំដឹងចោលនោះឡើយ៖ សូមព្រះអង្គវះកាត់ទូលបង្គំ ដូចជាគ្រូពេទ្យជំនាញខាងឯវះកាត់ចុះ»។ គ្រូពេទ្យវះកាត់តែងតែដាក់ថ្នាំសណ្ដំឲ្យយើងដេក ហើយពួកគាត់វះកាត់ដោយចូលទៅក្នុងកន្លែងនៃរាងកាយរបស់យើង ដែលយើងមិនដឹងអ្វីអំពីកន្លែងនោះ ហើយធ្វើការវះកាត់លើយើង។ នេះគឺជាអ្វីដែលព្រះជាម្ចាស់ត្រូវតែធ្វើជាមួយនឹងយើងផងដែរ។ ដូច្នេះ ពិតណាស់ ខ្ញុំគិតថា ព្រះវិញ្ញាណបរិសុទ្ធធ្វើការគ្រប់ពេល ក្នុងការរចនាសតិសម្បជញ្ញៈរបស់យើងឡើង។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Must Bible Reading Always End with Application?
**តើការអានព្រះគម្ពីរត្រូវបញ្ចប់ដោយមានការអនុវត្តគ្រប់ពេល?**
https://www.desiringgod.org/interviews/must-bible-reading-always-end-with-application

## សំណួរទី២៩៖
# មូលហេតុ១០យ៉ាងក្នុងការអានព្រះគម្ពីរប្រចាំថ្ងៃ

អត្ថបទថ្ងៃនេះគឺសម្រាប់អ្នកជឿថ្មី ហើយក៏ជាការឆ្លើយលើសំណួរទូទៅមួយ ដែលយើងទទួលបានជាញឹកញាប់ផងដែរ។

«ជម្រាបសួរលោកគ្រូ! ខ្ញុំបារម្ភយ៉ាងខ្លាំងទាក់ទងទៅនឹងចំណុចជាច្រើនដែលខ្ញុំមិនដឹងអំពីព្រះគម្ពីរ។ ខ្ញុំចង់ស្គាល់ព្រះគម្ពីរ ដើម្បីឲ្យព្រះគម្ពីរដឹកនាំជីវិតខ្ញុំ និងដើម្បីឲ្យខ្ញុំអាចប្រើប្រាស់ព្រះគម្ពីរក្នុងការដឹកនាំអ្នកដទៃនៅឯអនាគតបានដែរ។ ប៉ុន្តែ ព្រះគម្ពីរមានចំណុចច្រើនណាស់។ ខ្ញុំមិនដឹងថាគួរចាប់ផ្ដើមនៅចំណុចណាទេ។ ប្រសិនបើខ្ញុំកំពុងតែត្រៀមប្រលង នោះខ្ញុំនឹងចាប់ផ្ដើមដោយសរសេរចុះចំណុចសំខាន់មួយចំនួនដែលខ្ញុំគិតថាគ្រូនិងសួរអំពីចំណុចទាំងនោះ។ ប៉ុន្តែ ទាក់ទងនឹងព្រះគម្ពីរ ខ្ញុំមានអារម្មណ៍ថាជីវិតគឺជាការប្រលង ហើយខ្ញុំមិនដឹងថាខ្ញុំត្រូវដឹងចំណុចអ្វីដើម្បីត្រៀមខ្លួននោះទេ។ បើសួរម្យ៉ាងទៀតទៅ តើខ្ញុំគួរចាប់ផ្ដើមនៅត្រង់ចំណុចណា? តើអ្វីទៅជាចំណុចចម្បង និងចំណុចសំខាន់ជាងគេបំផុតដែលខ្ញុំត្រូវដឹង ដើម្បីដើរតាមព្រះគ្រីស្ទ តាមរយៈការអានព្រះបន្ទូលរបស់ទ្រង់?»

ខ្ញុំគិតថាចម្លើយរបស់ខ្ញុំនឹងអាចធ្វើឲ្យគាត់អាចមានការខកចិត្តបន្តិចពីព្រោះគាត់កំពុងតែសួរទាក់ទងនឹងសេចក្ដីពិតណាមួយក្នុងព្រះគម្ពីរ ហើយចម្លើយរបស់ខ្ញុំគឺថា «ព្រះគម្ពីរ ព្រះគម្ពីរ ព្រះគម្ពីរ ព្រះគម្ពីរ»។

### ពិតជាសំខាន់ណាស់

ខ្ញុំមិនដែលធ្លាប់ជួបគ្រីស្ទបរិស័ទដែលពេញវ័យ មានពេញទៅដោយផលផ្លែ ខ្លាំង និងចេះវែកញែកខាងឯព្រលឹងវិញ្ញាណ ដែលក្នុងខ្លួនគាត់មិនមានពេញទៅដោយព្រះបន្ទូល មានការប្ដេជ្ញាចិត្តក្នុងការសញ្ជឹងគិតលើព្រះ

បន្ទូលជាទៀងទាត់ ហើយព្យាយាមរក្សាព្រះបន្ទូលនៅក្នុងចិត្តតាមរយៈការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ឡើយ—ហើយការនោះក៏មិនបានកើតឡើងដោយចៃដន្យនោះទេ។ ដូច្នេះ អ្វីដែលខ្ញុំចង់ធ្វើគឺទាក់ទាញមិត្តភក្តិរបស់យើងដែលជាអ្នកជឿថ្មីម្នាក់នេះឲ្យយល់ថាព្រះគម្ពីរពិតជាសំខាន់ណាស់ បន្ទាប់ពីគាត់ទើបតែបានទទួលជឿលើព្រះគ្រីស្ទ គឺឱ្យគាត់មានការប្តូរផ្តាច់យ៉ាងជ្រាលជ្រៅ និងពេញទៅដោយបទពិសោធន៍ដែលមានភក្តីភាព—ឥតរង្គើ ការទាក់ទាញដែលមិនមានភាពផរា—ត្រង់ថា ការអាន ការសញ្ជឹងគិតលើព្រះគម្ពីរ ការយល់ ការទន្ទេញឲ្យចាំមាត់ និងការមានអំណរជាមួយនឹងព្រះបន្ទូលគឺជាអ្វីដែលពិតជាសំខាន់ណាស់សម្រាប់ជីវិតគ្រីស្ទបរិស័ទ ដែលមានរួមទាំងការចំណាយពេលក្នុងព្រះបន្ទូលជាប្រចាំថ្ងៃ ដោយមានគោលបំណងថាយើងនឹងជួបព្រះជាម្ចាស់ក្នុងព្រះបន្ទូល ហើយបន្តិចម្តងៗ នោះសិរីល្អនៃសេចក្តីពិតរបស់ទ្រង់នឹងបំពេញ ក៏ដូចជាបំផ្លាស់បំប្រែជីវិតយើងដែរ។

ហើយចំណុចនេះហាក់បីដូចជាច្បាស់ណាស់ចំពោះគាត់ និងអ្នកដទៃ ប៉ុន្តែវាមិនច្បាស់លាស់ទេ ពីព្រោះខ្ញុំស្គាល់មនុស្សជាច្រើនដែលជាគ្រីស្ទបរិស័ទរាប់ឆ្នាំហើយ ដែលមិនបានធ្វើដូច្នោះឡើយ។ ពួកគាត់មិនបានធ្វើដូច្នោះ ទោះបីពួកគាត់ជាគ្រីស្ទបរិស័ទជាយូរឆ្នាំក៏ដោយ ហើយពួកគាត់ក៏មិនបានបង្ហាញសេចក្តីស្រឡាញ់គ្រប់គ្រាន់ដែរ។ ពួកគាត់គិតថា ការអានព្រះបន្ទូលជាប្រចាំថ្ងៃគឺជាជម្រើសធ្វើ ឬក៏មិនធ្វើក៏បាន ពីព្រោះពួកគាត់គិតថាខ្លួនចេះច្រើនហើយ ហើយក៏បានអានសៀវភៅជាច្រើនក្បាលដែរ។ ខ្ញុំគិតថា ការធ្វើបែបនេះគឺមិនមែនជាទម្លាប់ល្អនោះទេ។ ផ្ទុយទៅវិញ ខ្ញុំគិតថា វាគឺជាទម្លាប់ដែលពេញទៅដោយគ្រោះថ្នាក់។

## មូលហេតុ១០យ៉ាងក្នុងការអានព្រះគម្ពីរ

ដូច្នេះ ខ្ញុំមានមូលហេតុ១០យ៉ាងដែលខ្ញុំជឿថា—មូលហេតុ១០យ៉ាង



ក្នុងការអានព្រះគម្ពីរ ការយល់ព្រះគម្ពីរ និងការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ថាជាចំណុចដ៏សំខាន់ចំពោះជីវិតគ្រីស្ទបរិស័ទជាប្រចាំថ្ងៃ។ សូមព្យាយាមបដិសេធគំនិតដែលថា មានខ្លួនឯងគឺគ្រប់គ្រាន់ហើយ «ខ្ញុំមិនត្រូវការព្រះបន្ទូលជាប្រចាំថ្ងៃទេ»។ ខាងក្រោមនេះគឺជាមូលហេតុ១០យ៉ាងរបស់ខ្ញុំ៖

### ១. ព្រះបន្ទូលសង្គ្រោះ

ចូរប្រុងប្រយ័ត្ននឹងខ្លួនអ្នក ហើយនឹងសេចក្តីបង្រៀន ចូរកាន់ខ្ជាប់តាមសេចក្តីទាំងនេះ ដ្បិតដែលធ្វើដូច្នោះ នោះអ្នកនឹងសង្គ្រោះខ្លួនអ្នកបាន ព្រមទាំងពួកអ្នកដែលស្តាប់អ្នកផង (១ធីម៉ូថេ ៤:១៦)។

សេចក្តីសង្គ្រោះបានកើតឡើងចំពោះរាស្ត្ររបស់ព្រះជាម្ចាស់ សេចក្តីសង្គ្រោះក៏—នៅក្នុងពេលនេះ—កំពុងតែកើតឡើងចំពោះរាស្ត្ររបស់ព្រះជាម្ចាស់ ហើយសេចក្តីសង្គ្រោះក៏នឹងកើតឡើងជាស្រេចចំពោះរាស្ត្ររបស់ព្រះជាម្ចាស់ នៅពេលដែលពួកគាត់រស់ឡើងវិញផងដែរ ហើយការនេះក៏កំពុងតែកើតឡើងឥឡូវនេះដែរ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា ឲ្យយើងកាន់ភ្ជាប់តាមសេចក្តីបង្រៀន ហើយជាលទ្ធផល នោះយើងនឹងសង្គ្រោះខ្លួនឯង។ តាមរយៈព្រះបន្ទូល ព្រះជាម្ចាស់សង្គ្រោះយើងជាប្រចាំថ្ងៃ។

### ២. ព្រះបន្ទូលរំដោះយើងចេះពីសាតាំង

អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច (យ៉ូហាន ៨:៣២)។

បរិបទនៅក្នុងខគម្ពីរនេះគឺថា ព្រះយេស៊ូវកំពុងតែបង្ហាញអ្នកដឹកនាំសាសនាយូដាថា ទោះបីពួកគាត់គិតថាខ្លួនមិនមែនជាទាសករក៏ដោយក៏ «អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក ហើយអ្នករាល់គ្នាចូលចិត្តធ្វើតាមតណ្ហា ដែលគាប់ចិត្តដល់ឪពុករបស់អ្នក» (យ៉ូហាន ៨:៤៤)។ ឱគ្រីស្ទបរិស័ទដែលមានជំនឿរ័យក្មេងអើយ សាតាំងគឺជាខ្មាំងសត្រូវរបស់អ្នក។ វា

ខ្លាំងជាងអ្នករាប់លានដង។ ដូច្នេះ សាវ័ក យ៉ូហាន សរសេរទៅកាន់អ្នកជឿថ្មីថា៖

«កំឡោះរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នាពីព្រោះមានកម្លាំង ហើយព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ» (១យ៉ូហាន ២:១៤)។

នេះគឺជាសេចក្តីសង្ឃឹមតែមួយគត់របស់យើង ក្នុងការយកឈ្នះលើខ្មាំងសត្រូវអធិធម្មជាតិរបស់យើង។ គ្រប់ពេលដែលព្រះយេស៊ូវទទួលការល្បួងពីអារក្ស (ម៉ាថាយ ៤:១-១១; ម៉ាកុស ១:១២-១៣; លូកា ៤:១-១៣) ព្រះអង្គបានវាយប្រហារ ដោយឆ្លើយតបវិញជាមួយ «នឹងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល» (អេភេសូរ ៦:១៧) ហើយព្រះអង្គក៏បានទន្ទេញព្រះគម្ពីរនោះឲ្យចាំមាត់ដែរ ដូច្នេះព្រះអង្គមិនចាំបាច់កាន់ព្រះគម្ពីរតាមខ្លួន នៅក្នុងទីរហោស្ថានឡើយ។

## ៣. ព្រះបន្ទូលប្រទាននូវព្រះគុណ និងសេចក្តីសុខសាន្ត

«សូមឲ្យព្រះគុណ នឹងសេចក្តីសុខសាន្ត បានចម្រើនដល់អ្នករាល់គ្នាឲ្យបានស្គាល់ព្រះ នឹងព្រះ យេស៊ូវ ជាព្រះអម្ចាស់នៃយើង» (២ពេត្រុស ១:២)។

ចំណេះដឹងអំពីព្រះជាម្ចាស់ដែលយើងទទួលបាន តាមរយៈព្រះបន្ទូល គឺមិនដូចគ្នាទៅនឹងព្រះគុណទេ ប៉ុន្តែសាវ័ក ពេត្រុស កំពុងតែមានប្រសាសន៍ថា ចំណេះដឹងនោះគឺជាយាននៃព្រះគុណ។ ប្រសិនបើយើងចង់ទទួលបានសេចក្តីសុខសាន្ត និងពេញដោយអំណាចតាមរយៈព្រះគុណរបស់ព្រះ គឺសាវ័ក ពេត្រុស កំពុងតែលើកឡើងថា គឺវាកើតឡើងបានតាមរយៈ «[ការ] ស្គាល់ព្រះ និងព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើង»។ យើងអាចរកឃើញបានចំណេះដឹងនោះតែក្នុងមួយកន្លែងប៉ុណ្ណោះ៖ គឺក្នុងព្រះបន្ទូល។



## ៤. ព្រះបន្ទូលបន្សុទ្ធ

ព្រះយេស៊ូវបានអធិស្ឋានថា៖

«សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់» (យ៉ូហាន ១៧:១៧)។

ការញែកជាបរិសុទ្ធគឺជាដំណើរការនៃការក្លាយជាមនុស្សបរិសុទ្ធ—ដែលនេះមានន័យថា ការកាន់តែក្លាយដូចជាព្រះគ្រីស្ទ និងព្រះជាម្ចាស់ដែលទ្រង់បរិសុទ្ធឥតខ្ចោះ។ នេះមិនមែនជាជម្រើសដែលយើងធ្វើ ឬក៏មិនធ្វើនោះទេ។ កណ្ឌគម្ពីរ ហេព្រើរ ១២:១៤ មានចែងថា «ចូរដេញតាម...ឲ្យបានញែកជាបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ»។

យើងនឹងមិនអាចក្លាយជាមនុស្សល្អឥតខ្ចោះបានទេនៅក្នុងជីវិតនេះ ប៉ុន្តែយើងអាចក្លាយជាមនុស្សដែលបរិសុទ្ធបានដែរ។ ព្រះជាម្ចាស់ញែករាស្ត្ររបស់ទ្រង់ឲ្យបានបរិសុទ្ធ។ ហើយព្រះយេស៊ូវក៏បានអធិស្ឋានទៅកាន់ព្រះវរបិតារបស់ទ្រង់ថា «សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់»។ ព្រះអង្គមិនអាចមានបន្ទូលច្បាស់ជាងនោះ ឬក៏ថាវាសំខាន់ជាងនោះបានទេ។

## ៥. ព្រះបន្ទូលប្រទានសេចក្តីអំណរ

«អ្នករាល់គ្នាក៏បានត្រាប់តាមយើងខ្ញុំ ហើយនិងព្រះអម្ចាស់ ដោយបានទទួលព្រះបន្ទូល ដោយសេចក្តីអំណររបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងកាលដែលកំពុងតែកើតទុក្ខលំបាកជាខ្លាំងផង» (១ថែស្សាឡូនីច ១:៦)។

អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងគិតក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ (ទំនុកតម្កើង ១:២)។

យើងមិនអាចទ្រទ្រង់ជីវិតដោយគ្មានសេចក្តីអំណរបានឡើយ។ ជីវិត

គ្រីស្ទបរិស័ទគឺជាជីវិតដែលមានពេញទៅ ដោយទុក្ខលំបាកយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែ តាមរយៈទុក្ខលំបាកទាំងនោះ ព្រះជាម្ចាស់ទ្រទ្រង់យើងដោយប្រទានសេចក្ដីអំណរ ហើយព្រះអង្គធ្វើការនោះតាមរយៈព្រះបន្ទូល។

## ៦. ព្រះបន្ទូលការពារយើងពីសេចក្ដីខុសឆ្គងដែលនាំឲ្យមានការបំផ្លិចបំផ្លាញចោលទាំងស្រុង

«ទាល់តែយើងរាល់គ្នាបានរួបរួម ខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ...ដើម្បីកុំឲ្យយើងនៅជាកូនតូចទៀត ទាំងត្រូវគ្រប់អស់ទាំងខ្យល់នៃសេចក្ដីបង្រៀនបោក ហើយផាត់យើងចុះឡើង» (អេភេសូរ ៤:១៣-១៤)។

តើគ្រីស្ទបរិស័ទដែលមានជំនឿថ្មីអាចការពារខ្លួនពីការបក់បោកតាមរយៈគំនិតវប្បធម៌ និងទេវវិទ្យាបានដោយរបៀបណា? ចម្លើយ៖ «បានរួបរួមខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ»—ចំណេះដឹងដែលពួកគាត់ទទួលបាន ដែលមិនមែនជាគំនិតរបស់មនុស្សប៉ុន្តែជាព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ។ យើងអាចរកឃើញបានចំណេះដឹងនោះតែក្នុងមួយកន្លែងប៉ុណ្ណោះ៖ គឺក្នុងព្រះបន្ទូល។

## ៧. ព្រះបន្ទូលគឺជាសេចក្ដីសង្ឃឹមនៃស្ថានសួគ៌

តាមរយៈចំណុចនេះ អ្វីដែលខ្ញុំចង់ផ្ដល់អត្ថន័យគឺថា ការយល់ដឹងដ៏ពេញលេញ ការមានអំណរយ៉ាងពេញលេញជាមួយនឹងសេចក្ដីពិតនៃព្រះបន្ទូល គឺថាយើងអាចទទួលបានបទពិសោធន៍នេះនៅតែឯស្ថានសួគ៌ប៉ុណ្ណោះ។

«ឥឡូវនេះ ខ្ញុំស្គាល់មិនទាន់អស់ តែនៅវេលានោះ ខ្ញុំនឹងស្គាល់វិញ ដូចជាព្រះទ្រង់ស្គាល់ខ្ញុំដែរ» (១កូរិនថូស ១៣:១២)។

ចំណេះដឹងអំពីព្រះជាម្ចាស់—គ្រប់ចំណុចទាំងអស់ដែលមនុស្សយើងអាចយល់បានយ៉ាងត្រឹមត្រូវ និងមានអំណរជាមួយ—គឺថា ព្រះអង្គនឹងមិនលាក់ពីយើងអស់កល្បជានិច្ចទេ។ ព្រះអង្គនឹងដកចេញនូវការខកចិត្តរបស់យើងសព្វថ្ងៃនេះ ទាក់ទងនឹងដែនកំណត់នៃការយល់ដឹង និងការមានអំណរជាមិនខាន។ នេះគឺពិតជាស័ក្ដិសមមែន ព្រោះយើងកំពុងតែកើនចំណេះដឹងជាមួយនឹងអ្វីដែលជាអំណរចុងក្រោយរបស់យើងនៅគ្រាចុងក្រោយ។

## ៨. មានអ្នកខ្លះនឹងបដិសេធព្រះបន្ទូល

«ដ្បិតនឹងមានគ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវទេ គឺគេនឹងមានត្រចៀក រមាស់ ហើយនឹងហៅគ្រូកាន់តែច្រើនឡើង មកបង្រៀនឲ្យត្រូវចិត្ត» (២ធីម៉ូថេ ៤:៣)។

និយាយម្យ៉ាងវិញទៀត យើងត្រូវតែស្គាល់ព្រះបន្ទូល ដើម្បីកុំឲ្យយើងភ្លេចខ្លួន ហើយបាត់បង់លំនឹងតុល្យភាព ឬក៏ឲ្យគ្រូខុសឆ្គងមកនាំយើងឲ្យវង្វេង។ យើងត្រូវតែទទួលព្រះបន្ទូលជាប្រចាំ ដើម្បីឲ្យបានត្រៀមខ្លួនជាស្រេចក្នុងការជួបអស់អ្នកដែលបដិសេធមិនទទួលព្រះបន្ទូល។

## ៩. ព្រះជាម្ចាស់សព្វព្រះហឫទ័យជាមួយនឹងការកាត់ស្រាយព្រះបន្ទូលយ៉ាងត្រឹមត្រូវ

«ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការ ដែលមិន ត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ» (២ធីម៉ូថេ ២:១៥)។

វាគឺជារឿងដ៏មានតម្លៃណាស់ ក្នុងការទទួលបានការងារដ៏សំខាន់ ហើយបន្ទាប់មកឃើញថាចៅហ្វាយរបស់យើងក៏សព្វព្រះហឫទ័យជាមួយនឹងអ្វីដែលព្រះអង្គបានប្រាប់ឲ្យយើងធ្វើដែរ។ ព្រះអង្គបានបង្គាប់យើង ក្នុងកម្រិតណាមួយ ទាក់ទងនឹងការកាត់ស្រាយព្រះបន្ទូលរបស់ទ្រង់។ ហើយនេះគឺជាឱកាសដ៏អស្ចារ្យមែនក្នុងការផ្គាប់ព្រះហឫទ័យដល់ព្រះអម្ចាស់។

**១០. ព្រះបន្ទូលប្រទាន និងទ្រទ្រង់ជីវិត**

«មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤)។

ជីវិតខាងវិញ្ញាណ—ជីវិតដ៏អស់កល្បជានិច្ច—ក៏ដូចគ្នានឹងជីវិតខាងឯសាច់ឈាមដែរ គឺត្រូវទទួលទាន មិនមែនតាមរយៈនំបុ័ងទេ ប៉ុន្តែគឺតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ។ ប្រសិនបើលោកអ្នកគិតថា ការទទួលបានជីវិតអស់កល្បជានិច្ច ប្រៀបដូចជាការទទួលវ៉ាក់សាំងប្រឆាំងនឹងស្ថាននរក ដែលមិនត្រូវការទទួលទាន នោះមានន័យថាលោកអ្នកមិនស្គាល់ថា ជីវិតខាងវិញ្ញាណមានលក្ខណៈយ៉ាងដូចម្ដេចទេ។

សរុបសេចក្ដីទៅ ទាំងនេះគឺជាមូលហេតុ១០យ៉ាង ដែលអ្នកជឿថ្មីត្រូវតែប្ដេជ្ញាចិត្តឲ្យអស់ពីកម្លាំង—ឲ្យអស់ពីកម្លាំងដែលព្រះជាម្ចាស់បានប្រទានដល់គាត់—ក្នុងការធ្វើឲ្យការអាន ការសញ្ជឹងគិត ការយល់ដឹង និងការទន្ទេញព្រះបន្ទូលឲ្យចាំមាត់ក្លាយជាចំណុចដ៏សំខាន់ ដែលមិនអាចខកខានបាន នៅក្នុងជីវិតជាគ្រីស្ទបរិស័ទ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Ten Reasons to Read the Bible Every Day
**មូលហេតុ១០យ៉ាងក្នុងការអានព្រះគម្ពីរប្រចាំថ្ងៃ**
https://www.desiringgod.org/interviews/ten-reasons-to-read-the-bible-every-day



# ផ្នែកទី៤
# អំពើបាប និងសេចក្ដីសង្គ្រោះ

## សំណួរទី២៥៖
# ការតយុទ្ធនឹងសេចក្តីច្រណែនឈ្នានីស

ប្អូនស្រី ដាលីស បានសរសេរមកយើង ដើម្បីសួរថា «លោកគ្រូ តើនាងខ្ញុំត្រូវដោះស្រាយយ៉ាងណាចំពោះការច្រណែនឈ្នានីស និងការប្រច័ណ្ឌដែលកំពុងលេបត្របាក់នាងខ្ញុំទៅហើយនោះ?» ដ្បិត ការច្រណែនឈ្នានីស និងការប្រច័ណ្ឌ គឺជាប្រធានបទដែលដាក់នៅលើតុពីរខុសពីគ្នា។ ប្រហែលជាយើងឆ្លើយវាជាពីរប្រធានបទខុសគ្នា ហើយយើងលើកយកការប្រច័ណ្ឌមកនិយាយនៅពេលក្រោយទៀត។ លោកគ្រូ យើងនឹងចាប់ផ្តើមនិយាយពីការច្រណែនឈ្នានីសទៅមុន តើលោកគ្រូនឹងឆ្លើយតបយ៉ាងណាទៅនឹងប្អូនស្រី ដាលីស?

វាមិនខុសទេ ក្នុងការប្រាថ្នាចង់បានរបស់អ្វីមួយដែលលោកអ្នកមិនមាន។ យើងតែងតែគិតអំពីការច្រណែនក្នុងរបៀបនោះ។ ខ្ញុំចង់បានរបស់នោះ—ជារបស់ដែលបុគ្គលម្នាក់នោះមាន។ តាមពិតទៅ យើងនឹងមិនសូម្បីតែអធិស្ឋានផង ប្រសិនបើយើងមិនចង់បានរបស់អ្វីមួយដែលយើងមិនមាន។ នោះគឺជាសេចក្តីអធិស្ឋានសុំ។ តាមពិតទៅ ខ្ញុំចង់និយាយថា គ្រប់ជីវិតទាំងអស់គឺត្រូវអរព្រះគុណចំពោះអ្វីដែលព្រះជាម្ចាស់បានប្រទានមកយើង ឬអរគុណសម្រាប់ការប្រាថ្នាសម្រាប់អ្វីមួយដែលទំនងអាចជាការល្អសម្រាប់យើង។ ដូច្នេះសំណួរសួរថា តើអ្វីដែលធ្វើឲ្យការច្រណែនត្រឡប់ទៅជាការអាក្រក់? តើអ្វីដែលធ្វើឲ្យការចង់បានរបស់អ្វីមួយត្រឡប់ទៅជាការអាក្រក់?

«កុំឲ្យក្តៅចិត្ត ដោយព្រោះមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ឡើយ ក៏កុំឲ្យច្រណែននឹងមនុស្សកោងកាចដែរ» (សុភាសិត ២៤:១៩)។ វាហាក់បីដូចជាមនុស្សកំពុងសម្លឹងមើលទៅអស់អ្នកដែលកំពុងតែចម្រុងចម្រើន

នៅក្នុងអំពើខុសឆ្គងរបស់ពួកគេ។ ពួកគេមានរបស់របរជាច្រើន ហើយពួកគេតែងតែមានអារម្មណ៍ច្រណែននឹងអ្នកដទៃ។ ឬអាចពិចារណានូវចំណុចដូចខាងក្រោមនេះផងដែរ៖

សុភាសិត ១៤:៣០ «ឯជីវិតរបស់សាច់ឈាម នោះគឺជាចិត្តដែលស្ងប់រំងាប់ តែចិត្តច្រណែនជាសេចក្ដីពុករលួយដល់ឆ្អឹងវិញ»

ម៉ាថាយ ២៧:១៨ «ដ្បិតលោកបានជ្រាបថា គេបញ្ជូនទ្រង់ [ព្រះយេស៊ូវ] ដោយចិត្តឈ្នានីសទេ» ដូច្នេះ ការច្រណែនគឺជារឿងដ៏អាក្រក់។ វាបានបណ្តាលឲ្យមានការធ្វើគុតព្រះរាជបុត្រានៃព្រះ។ នោះជាហេតុផលនៅពីក្រោយការបំផ្លាញព្រះយេស៊ូវ។

រ៉ូម ១:២៨ «ហើយដោយព្រោះ [គេមិនចូលចិត្តនឹងស្គាល់ដល់ព្រះសោះ] បានជាទ្រង់ប្រគល់គេទៅតាមគំនិតចោលម្សៀតវិញ…ពួកគេមានពេញទៅដោយ សេចក្តីឈ្នានីស ការកាប់សម្លាប់ ការឈ្លោះប្រកែក»។

វាដូចគ្នាទៅនឹងកណ្ឌគម្ពីរ ១ពេត្រុស ២:១៖ «ដូច្នេះ ដែលអ្នករាល់គ្នាបានលះបង់ចោលអស់ទាំងសេចក្តីគំរក់ និងកិច្ចកលទាំងប៉ុន្មាន ព្រមទាំងពុតមាយា ចិត្តច្រណែន ហើយពាក្យនិយាយដើមគេទាំងអស់ចេញ»។

### ការរសាប់រសល់ និងការថ្នាំងថ្នាក់ចិត្ត

ច្បាស់ណាស់នេះគឺជាសំណួរដ៏ល្អមួយ។ យើងរាល់គ្នាមិនចង់ត្រូវលេបត្របាក់ដោយអ្វី ដែលបានឆ្កាងព្រះរាជបុត្រានៃព្រះទេ ហើយអ្វីទាំងអស់នោះត្រូវបានចងភ្ជាប់នឹងការលាក់ពុត និងការបោកបញ្ឆោត ការបង្កាច់បង្ខូច និងការច្រណែនឈ្នានីសផងដែរ។ ដូច្នេះ នៅពេលដែលខ្ញុំព្យាយាមស្វែងយល់ពីខ្លឹមសាររបស់វា និងពីរបៀបដោះស្រាយវា វាហាក់បីដូចជាខគម្ពីរទាំងនោះមានតម្រុយខ្លះនៅក្នុងនោះ។ ការច្រណែនឈ្នានីសហាក់បីដូចជាកើតចេញពីចិត្តដែលរសាប់រសល់ ដែលរកមិនឃើញការស្កប់ចិត្តក្នុងព្រះជាម្ចាស់។



យើងកំពុងតែប្រាថ្នាចង់បានយ៉ាងខ្លាំង ហើយយើងកំពុងតែស្រវាស្រទេញចង់បានវា។ យើងឈឺចាប់ចំពោះអ្វីដែលអ្នកដទៃមានដោយសារព្រះជាម្ចាស់ទ្រង់មិនបានបំពេញចិត្តយើងនោះទេ។

«ការច្រណែនឈ្នានីសហាក់បីដូចជាកើតចេញពីចិត្តដែលរសាប់រសល់ ដែលរកមិនឃើញការស្កប់ចិត្តក្នុងព្រះជាម្ចាស់»។ ដូច្នេះ ការច្រណែនឈ្នានីសគឺជាការប្រាថ្នាចង់បានអ្វីមួយ—អំណោយអ្វីមួយ ឬសមត្ថភាពអ្វីមួយ ឬរូបរាងខាងក្រៅ ឬរបស់អ្វីដែលអ្នកដទៃមាន—ជាមួយនឹងអារម្មណ៍មួយក្នុងចំណោមអារម្មណ៍ពីរដែលធ្វើឲ្យវាជាការអាក្រក់។ ទាំងការដែលលោកអ្នកមានការអាក់អន់ចិត្តនឹងការដែលគេមាន ហើយលោកអ្នកមិនមានដូច្នោះហើយបានជាវារំខានចិត្តលោកអ្នកមិនគ្រាន់តែថាលោកអ្នកចង់បានវាទេ ប៉ុន្តែដែលគេមាន ហើយលោកអ្នកមិនមានវិញ។ ហើយនោះមិនមែនជាការស្រឡាញ់ទេ។ ពេលដែលយើងមានចិត្តទោមនស្ស ដែលអ្នកផ្សេងមានអ្វីមួយហើយយើងមិនមាន ហើយវាធ្វើឲ្យរំខានចិត្តយើង និងមានសេចក្តីកំហឹងនោះយើងដឹងថា ការគ្មានសេចក្តីស្រឡាញ់បានឆក់យកព្រលឹងរបស់យើងហើយ។ ឬយើងមានអារម្មណ៍មិនស្កប់ចិត្ត—មិនត្រឹមតែថ្នាំងថ្នាក់ចិត្តនឹងអ្វីដែលពួកគេមានវាទេ ប៉ុន្តែជាការទោមនស្សនៅក្នុងព្រលឹងរបស់យើងផ្ទាល់ដែលធ្វើឲ្យយើងមិនទុកចិត្តលើព្រះជាម្ចាស់ ឬខឹងនឹងទ្រង់៖ ហេតុអ្វីបានជាទ្រង់មិនប្រទានការនោះឲ្យទូលបង្គំ? ហេតុអ្វីបានជាពួកគេមាន ហើយទូលបង្គំមិនមានទៅវិញ? ហេតុអ្វីបានជាទ្រង់រារាំងការនេះពីទូលបង្គំ?

### ការទុកចិត្តលើសេចក្តីល្អនៃព្រះជាម្ចាស់

ខ្ញុំដឹងថា កាលខ្ញុំនៅវ័យជំទង់តាមការពិតនោះ ខ្ញុំមិនអាចនិយាយនៅមុខក្រុមមនុស្សមួយបានទេ ដែលការនោះបានចូលមកជិតខ្ញុំបំផុតក្នុងការធ្វើឲ្យខ្ញុំមានចិត្តច្រណែន។ ខ្ញុំអាចឃើញមនុស្សទាំងនោះ អាចនិយាយបាន

យ៉ាងងាយនៅមុខក្រុមមនុស្ស។ ហើយខ្ញុំមិនអាចធ្វើបានទេ។

រហូតមកដល់សព្វថ្ងៃនេះ តាមការពិតនោះគឺខ្ញុំអានយឺតណាស់—ខ្ញុំត្រូវតែត្រឡប់ទៅរកព្រះដោយឥតឈប់ឈរ ហើយនិយាយថា “ព្រះអម្ចាស់អើយ! ទូលបង្គំគួរតែអាចសម្រេចបានច្រើនទៀត ទូលបង្គំគិតថា ប្រសិនបើទ្រង់គ្រាន់តែបានផ្តល់ឲ្យទូលបង្គំនូវសមត្ថភាពក្នុងការអានលឿនដូចដែលលោក តូនី រ៉េនខឺយ៍ (Tony Reinke) អាចអានបានដែរ។ ហើយលោកអ្នកពិតជាត្រូវពិនិត្យមើលរឿងទាំងនេះម្តងហើយម្តងទៀត ទាំងដាក់វាចុះដោយពោលថា «ឱព្រះអម្ចាស់អើយ!ទូលបង្គំទុកចិត្តលើទ្រង់ ដ្បិតព្រះអង្គល្អណាស់»។

ដូច្នេះ ខ្ញុំគិតថា ដំណោះស្រាយបានមកពីកណ្ឌគម្ពីរ ភីលីព ៤:១១-១២៖ «ខ្ញុំនិយាយដូច្នេះ មិនមែនដោយខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំបានរៀនឲ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ ប៉ុន្តែដែលអ្នករាល់គ្នាបានជួយដល់សេចក្តីកម្សត់របស់ខ្ញុំ នោះប្រពៃហើយ»។ ដូច្នេះ លោកអ្នកមានគ្រប់គ្រាន់—«ហើយទាំងឃ្លាន»—ឥឡូវនេះលោកអ្នកអាចផ្តើមមានអារម្មណ៍ថាច្រណែន។ «ពួកគេមានច្រើនជាង ខ្ញុំចង់បានច្រើនជាងហ្នឹងទៀត។ ខ្ញុំមិនមានគ្រប់គ្រាន់ទេ តែពួកគេមានយ៉ាងបរិបូរណ៍»។

ហើយសាវ័ក ប៉ុល បានលើកឡើងថា មានអាថ៌កំបាំងចំពោះការទុកចិត្តលើសេចក្តីល្អរបស់ព្រះជាម្ចាស់ ដែលបានធ្វើឲ្យលោកអ្នកមានអារម្មណ៍ស្កប់ស្កល់នៅក្នុងអ្វីដែលលោកអ្នកមាន។ ដូច្នេះ ខ្ញុំគិតថា គន្លឹះនោះគឺការទុកចិត្តទ្រង់ចំពោះអ្វីដែលទ្រង់បានប្រទានមកយើង ហើយគ្រាន់តែទូលសុំអ្វីដែលថ្វាយសិរីល្អដល់ព្រះជាម្ចាស់ បន្ទាប់មកចេះស្កប់ចិត្តនឹងអ្វីដែលព្រះជាម្ចាស់ប្រទានមកយើង។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Battling Envy
**ការតយុទ្ធនឹងសេចក្តីច្រណែនឈ្នានីស**
https://www.desiringgod.org/interviews/battling-envy

## សំណួរទី២៦៖

# តើខ្ញុំអាចជឿលើព្រះគម្ពីរទាំងមូល ហើយព្រះអង្គនៅមិនបានជ្រើសរើសខ្ញុំដែរឬទេ?

*«ជម្រាបសួរលោកគ្រូ តើអាចទេដែលយើងជឿលើព្រះគម្ពីរទាំងមូលនៅក្នុងខួរក្បាលរបស់យើង និងជឿលើគ្រប់ចំណុចនៃសេចក្តីពិតខាងឯជំនឿគ្រីស្ទបរិស័ទ ហើយទទួលយកថាជាសេចក្តីពិត១០០%—ក្នុងការចង់ស្រឡាញ់ព្រះយេស៊ូវ និងទទួលបានការសង្គ្រោះចេញពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់—ប៉ុន្តែនៅមិនមែនជាបុគ្គលដែលព្រះជាម្ចាស់បានជ្រើសរើស? តើការនេះអាចកើតឡើងបានដែរឬទេ?*

ខ្ញុំចង់និយាយថា «ទេ»។ ប៉ុន្តែ ខ្ញុំចង់បង្ហាញអំពីមូលហេតុឲ្យច្បាស់ដែលខ្ញុំត្រូវការវែកញែកឲ្យស៊ីជម្រៅបន្តិចត្រង់ចំណុចដែលថា «ហើយទទួលយកថាជាសេចក្តីពិត១០០%»។ នោះគឺជាចំណុចស្នូលនៃសំណួរ។ ខ្ញុំបានលើកឡើងជាញឹកញាប់ថា—ហើយប្រហែលនេះជាមូលហេតុដែលនាំឲ្យមានការលើកឡើងនូវសំណួរដូចនេះ—អារក្សសាតាំងស្គាល់សេចក្តីពិតច្រើនជាងទេវវិទូទៅទៀត ហើយមូលហេតុដែលវាមិនទទួលបានសេចក្តីសង្គ្រោះគឺដោយសារវាស្អប់សេចក្តីពិតនោះ។ សាវ័ក យ៉ាកុប បានមានប្រសាសន៍ថា «ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ» (យ៉ាកុប ២:១៩)។ ពួកវាជឿសេចក្តីពិតជាច្រើនអំពីព្រះជាម្ចាស់ថាជាការពិត ប៉ុន្តែពួកវាមិនបានទទួលសេចក្តីសង្គ្រោះទេ ពីព្រោះវាស្អប់សេចក្តីពិតទាំងនោះ។

### តម្រង់ជំនឿ និងតម្លៃទៅជាជួរ

ខ្ញុំមិនដឹងថា តើខ្ញុំអាចនិយាយថា បុគ្គលដែលអះអាងថារាល់ចំណុច

នៃព្រះគម្ពីរជាសេចក្ដីពិត១០០% ហើយនៅអាចជាបុគ្គលដែលបាត់បង់—អាចនៅជាបុគ្គលដែលមិនទទួលបានសេចក្ដីសង្គ្រោះ ឬក៏អត់។ ហើយនេះជាមូលហេតុរបស់ខ្ញុំ៖ ព្រះគម្ពីរមានពេញទៅដោយប្រយោគ មិនមែនគ្រាន់តែសេចក្ដីពិត ប៉ុន្តែគឺប្រយោគអំពីតម្លៃ ភាពសេចក្ដីល្អ និងការប្រាថ្នាចង់បានសេចក្ដីពិតទាំងនោះ។ ដូច្នេះ ព្រះគម្ពីរមិនគ្រាន់តែបានលើកឡើងថា ព្រះជាម្ចាស់មានពេញទៅដោយព្រះចេស្ដានោះទេ ប៉ុន្តែថាព្រះអង្គមានពេញទៅដោយសិរីល្អ ហើយអស្ចារ្យក្នុងសិរីរុងរឿង និងព្រះចេស្ដា ហើយថាព្រះអង្គក៏គ្មានព្រំដែនដែរ មានតម្លៃលើសគ្រប់អ្វីៗទាំងអស់ ហើយថាព្រះយេស៊ូវមិនគ្រាន់តែបានមានព្រះជន្មរស់ ប៉ុន្តែត្រង់ថាព្រះអង្គមានគ្រប់រាល់លក្ខណសម្បត្តិទាំងនោះដែលធ្វើឲ្យព្រះអង្គកាន់តែមានតម្លៃលើសជាងគ្រាប់ពេជ្រដ៏មានតម្លៃ ហើយថាទ្រង់មានតម្លៃលើសជាងទ្រព្យសម្បត្តិដ៏ស្ដុកស្ដម្ភទៀតផង។ ហើយសូមចងចាំថាសាវ័ក ប៉ុល ក៏បានលើកឡើងផងដែរថា គាត់បានមានការស្កប់ស្កល់ចិត្តក្នុងការស្គាល់ព្រះគ្រីស្ទជាងអ្វីផ្សេងទៀតទាំងអស់ (សូមអានបន្ថែមនៅក្នុងកណ្ឌគម្ពីរ ភីលីព ៣:៨)។

ដូច្នេះ តើនេះមានន័យយ៉ាងដូចម្ដេចក្នុងការលើកឡើងថា លោកអ្នកក៏ជឿនៅចំណុចនេះដែរ ប៉ុន្តែមិនបានឱបក្រសោបទ្រង់ថាជាព្រះដ៏ល្អមានពេញដោយតម្លៃ និងល្អប្រសើរជាងអ្វីៗទាំងអស់ផ្សេងទៀត? ខ្ញុំគិតថាមនុស្សជាច្រើននឹងលើកឡើងថា *«លោកអ្នកមិនមានអត្ថន័យដូចនោះទេ។ លោកអ្នកបានលើកឡើងថា លោកអ្នកជឿថា ព្រះអង្គមានតម្លៃតតផ្ទឹមបាន។ លោកអ្នកបានលើកឡើងថា លោកអ្នកជឿថា ព្រះអង្គមានតម្លៃលើសគ្រប់អ្វីៗទាំងអស់។ លោកអ្នកបានលើកឡើងថា លោកអ្នកជឿថា ព្រះអង្គមានពេញទៅដោយការស្កប់ស្កល់ ប៉ុន្តែមិនបានឱបក្រសោបទ្រង់ថាជាអង្គដែលបំពេញភាពស្កប់ស្កល់ទាំងអស់? លោកអ្នកមិនមានអត្ថន័យដូចអ្វីដែលលោកអ្នកនិយាយនោះទេ»*។ ដូច្នេះ ខ្ញុំមិនអាចនាំឲ្យខ្លួនឯងនិយាយ



ថា បុគ្គលណាម្នាក់ដែលពិតជាអះអាងគាំទ្រលើតម្លៃនៃរាល់ប្រយោគទាំងនោះនៃព្រះគម្ពីរ ហើយអាចនៅជាបុគ្គលដែលបាត់បង់បានទេ ពីព្រោះប្រសិនបើគាត់ពិតជាគាំទ្រតម្លៃនៃរាល់ប្រយោគទាំងនោះមែន នោះគាត់ក៏នឹងពិតជាឱបក្រសោបតម្លៃទាំងនោះមែនហើយ។

តាមពិតទៅ ទាក់ទងនឹងរបៀបដែលខួរក្បាលមនុស្សយើងដំណើរការនៅពេលដែលចិត្តចង់ជ្រើសរើសអ្វីមួយជាជាងអ្វីមួយផ្សេងទៀត នោះខួរក្បាលនឹងព្យាយាមរករបៀបចំណែកជាមួយនឹងដួងចិត្ត ក្នុងការរករបៀបដើម្បីបង្ហាញថាជម្រើសរបស់ដួងចិត្តគឺជាជម្រើសដែលត្រឹមត្រូវ។ ដូច្នេះ វានឹងមិនអាចកើតឡើងបានទេ ក្នុងការដែលបុគ្គលណាម្នាក់លើកឡើងយ៉ាងស្មោះត្រង់ថា *«ខ្ញុំជឿថា ព្រះគម្ពីរទាំងមូលគឺជាសេចក្ដីពិត១០០%»* ប៉ុន្តែនៅបន្តបដិសេធថា ព្រះយេស៊ូវមានតម្លៃទាបជាងនោះ មិនសូវមានតម្លៃ មិនសូវល្អ ជាងទ្រព្យសម្បត្តិរបស់គាត់នៅលើផែនដីនេះបានទេ។ បើនិយាយម្យ៉ាងវិញទៀតទៅ ខួរក្បាលរបស់គាត់នឹងមិនអាចធ្វើដូច្នោះបានឡើយ។ ប្រសិនបើពួកគាត់ចង់ឲ្យតម្លៃលើលោកីយ៍នេះជាជាងព្រះជាម្ចាស់—តម្លៃលើរបស់សព្វសារពើជាជាងលើព្រះអាទិករ—ប្រសិនបើគាត់ចង់ជឿដូច្នោះយ៉ាងខ្លាំងមែន នោះខួរក្បាលរបស់គាត់នឹងមិនទំនងទៅរកព្រះគម្ពីរ ហើយនិយាយថា *«នេះគឺជាការពិតមែន។ ឯងដឹងហើយថា ប្រយោគអំពីតម្លៃទាំងនេះក៏យ៉ាងហោចណាស់ពិតដែរ»*។ ទេ! ខួរក្បាលនៅឆ្លើយតបថា *«ទេ! ចំណុចនោះទំនងជារឿងព្រេងទេ ឬក៏វាទំនងជាមានចំណុចខុសឆ្គង ឬក៏អត្ថបទបានទទួលការកែបង្ខុស ឬក៏ថាមានចំណុចប្រឆាំងគ្នាគ្រប់ទីកន្លែងហើយ»*។ នេះគឺជាអ្វីដែលខួរក្បាលនឹងធ្វើ ដើម្បីការពារទ្រព្យសម្បត្តិរបស់ដួងចិត្តក្នុងមនុស្សជាជាងក្នុងព្រះ។

នេះគឺជាមូលហេតុចម្បងរបស់ខ្ញុំក្នុងការឆ្លើយថា «ទេ»។ លោកអ្នកមិនអាចទទួលជឿថា ព្រះគម្ពីរគឺជាសេចក្ដីពិត១០០% ហើយនៅតែជាមនុស្ស

បាត់បង់នោះទេ ប្រសិនបើអ្វីដែលខ្ញុំកំពុងតែលើកឡើងគឺជាការពិតមែន។ ប្រសិនបើលោកអ្នកពិតជាជឿថា ព្រះយេស៊ូវមានតម្លៃលើសអ្វីៗទាំងអស់ ល្អលើសអ្វីៗទាំងអស់ ហើយជាសេចក្ដីពិតផ្ទាល់នៅក្នុងចក្រវាលនេះ នោះលោកអ្នកក៏នឹងឱបក្រសោបទ្រង់ នេះគឺជាអត្ថន័យថា ការទទួលជឿលើទ្រង់ថា ល្អលើសគ្រប់អ្វីៗទាំងអស់ និងមានពេញទៅដោយការស្កប់ស្កល់។

## បបូរមាត់របស់អ្នកមានចិត្តរឹង

ដូច្នេះ ទំនងចំណុចចុងក្រោយដែលខ្ញុំនឹងសួរគឺថា «ចុះចំណែកអស់អ្នកនៅក្នុងកណ្ឌគម្ពីរម៉ាថាយជំពូក៧វិញ?»៖

*«មិនមែនអស់អ្នកណាដែលគ្រាន់តែនិយាយមកខ្ញុំថា "ឱព្រះអម្ចាស់ៗអើយ" ដែលនឹងចូលទៅក្នុង នគរស្ថានសួគ៌នោះទេ គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌វិញទេតើ នៅថ្ងៃនោះនឹងមានមនុស្សជាច្រើននិយាយមកខ្ញុំថា "ឱព្រះអម្ចាស់ៗអើយ តើយើងខ្ញុំមិនបានទាយ ដោយនូវព្រះនាមទ្រង់ ហើយដេញអារក្សដោយនូវព្រះនាមទ្រង់ ព្រមទាំងធ្វើការ ឫទ្ធិបារមីជាច្រើន ដោយនូវព្រះនាមទ្រង់ទេឬអី" នោះខ្ញុំនឹងនិយាយដោយត្រង់ថា អញមិនដែល បានស្គាល់ឯងរាល់គ្នាទេ នែពួកទទឹងច្បាប់អើយ ចូរថយចេញពីអញទៅ»* (ម៉ាថាយ ៧:២១-២៣)។

អ្នកនៅក្នុងកណ្ឌគម្ពីរម៉ាថាយបានលើកឡើងថា «ខ្ញុំជឿថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់»។ នេះគឺជាអ្វីដែលពួកគាត់កំពុងតែហៅព្រះយេស៊ូវ—«*ព្រះអម្ចាស់*»។ ប៉ុន្តែ ពួកគាត់មិនបានទទួលសេចក្តីសង្គ្រោះទេ។ ហេតុអ្វីបានជាពួកគាត់មិនបានទទួលសេចក្ដីសង្គ្រោះ? ហើយចម្លើយដែលព្រះយេស៊ូវបានប្រទានគឺថា ពួកគាត់គឺជាមនុស្សមានពុត។ ពួកគាត់គឺជាអ្នកប្រព្រឹត្តិល្មើសនឹងច្បាប់។ ពួកគាត់ហៅព្រះអង្គថា «ព្រះអម្ចាស់» ប៉ុន្តែពួកគាត់គឺជាអ្នកប្រព្រឹត្តិល្មើសនឹងច្បាប់វិញ។ ពួកគាត់ដូចជាពួកផារិស៊ី។ ចំពោះខ្ញុំ វាពិតជា



អស្ចារ្យណាស់ ដែលនៅក្នុងកណ្ឌគម្ពីរ លូកា ១៦:១៤ ព្រះយេស៊ូវបានមានបន្ទូលថា *«ឯពួកផារិស៊ី ដែលជាពួកអ្នកមានចិត្តលោភ»* ព្រោះពួកគាត់បានអះអាងថា ខ្លួនជឿលើព្រះគម្ពីរសញ្ញាចាស់ទាំងមូល។ ព្រះមានតម្លៃលើគ្រប់អ្វីៗទាំងអស់។ យើងគួរតែស្រឡាញ់ព្រះអង្គឲ្យអស់ពីចិត្ត ព្រលឹង គំនិត និងកម្លាំងរបស់យើង។ ហើយព្រះយេស៊ូវក៏បានបន្ថែមថា៖ ពួកគាត់គឺជាមនុស្សមានពុត ពីព្រោះតាមពិតទៅ ពួកគាត់ជាមនុស្សដែលមានចិត្តលោភទេតើ។

ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់ខ្ញុំគឺថា ការដែលពិតជាត្រូវជឿលើអ្វីដែលព្រះគម្ពីរបានចែងអំពីព្រះជាម្ចាស់ និងអំពីព្រះគ្រីស្ទ និងផ្លូវនៃសេចក្ដីសង្គ្រោះ—ការដែលពិតជាត្រូវជឿថា នោះគឺជាសេចក្ដីពិត—នឹងនាំឲ្យទទួលបានសេចក្ដីសង្គ្រោះជាមិនខាន ពីព្រោះព្រះគម្ពីរបានចែងថា *«ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ»* (រ៉ូម ១០:១៣)។ ហើយលោកអ្នកទទួលជឿលើចំណុចនេះ និងប្រព្រឹត្តតាមចំណុចនេះ នោះលោកអ្នកនឹងឃើញថា វាគឺជាការពិត។ វាគឺជាការពិតចំពោះលោកអ្នក។ ប្រសិនបើលោកអ្នកអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះលោកអ្នកនឹងទទួលបានសេចក្ដីសង្គ្រោះជាមិនខាន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Can I Believe the Whole Bible and Not Be Elect?
**តើខ្ញុំអាចជឿលើព្រះគម្ពីរទាំងមូល ហើយព្រះអង្គនៅមិនបានជ្រើសរើសខ្ញុំដែរឬទេ?**
https://www.desiringgod.org/interviews/can-i-believe-the-whole-bible-and-not-be-elect

## សំណួរទី២៧៖
# តើព្រះបានតម្រូវទុកជាមុន ឲ្យអ្នកខ្លះធ្លាក់នរកឬ?

*មានអ្នកស្តាប់ការបង្រៀនជាសំឡេងម្នាក់ ឈ្មោះ សុខា បានផ្ញើសារមកសួរត្រង់ៗថា៖ «លោកគ្រូ តើព្រះបានតម្រូវទុកជាមុន ឲ្យអ្នកខ្លះធ្លាក់នរកឬ?»*

មុននឹងខ្ញុំផ្តល់ឲ្យនូវចម្លើយច្បាស់លាស់ សម្រាប់សំណួរនេះ យើងខ្ញុំចាំបាច់ត្រូវនិយាយអំពីមូលដ្ឋាននៃសេចក្តីពិតខ្លះៗ ដែលយើងត្រូវយល់សិន ដើម្បីកុំឲ្យយើងមានការយល់ច្រឡំ។ ខាងក្រោមនេះ យើងខ្ញុំនឹងនិយាយអំពីចំណុចមូលដ្ឋានគ្រឹះមួយចំនួន បន្ទាប់មក យើងខ្ញុំនឹងលើកឡើងនូវខគម្ពីរខ្លះៗ ហើយបន្ទាប់មកផ្តល់ឲ្យនូវចម្លើយសម្រាប់សំណួរនេះ។

### ការបកស្រាយ អំពីសេចក្តីពិតជាមូលដ្ឋាន

មានមនុស្សជាច្រើននាក់យល់ឃើញថា បើព្រះទ្រង់បានតម្រូវទុកជាមុនឲ្យអ្នកខ្លះធ្លាក់នរក នោះមានន័យថា ព្រះអង្គមានភាពអយុត្តិធម៌ ហើយព្រះអង្គមិនមែនជាព្រះល្អទេ។ ដូចនេះ ពួកគេមិនអាចទទួលយកចម្លើយវិជ្ជមាន សម្រាប់សំណួរនេះបានឡើយ។ តាមពិត យើងខ្ញុំសូមនិយាយថា បើលោកអ្នកយល់ឃើញដូចនេះដែរថា ព្រះអង្គមិនសុចរិត ឬមិនយុត្តិធម៌ ឬក៏មិនល្អ បើសិនជាព្រះអង្គបានតម្រូវទុកជាមុន ឲ្យអ្នកខ្លះបានសង្គ្រោះ ហើយអ្នកខ្លះវិនាស នោះលោកអ្នកមិនគួរជឿដូចនេះឡើយ ទោះបើព្រះអង្គពិតជាបានតម្រូវទុកជាមុនឬអត់ក៏ដោយ ។ យើងខ្ញុំដឹងថា អ្វីដែលយើងខ្ញុំនិយាយនេះហាក់ដូចជាចម្លែក។ សូមជឿចុះ បើសិនជាព្រះគម្ពីរពិតជាបានបង្រៀនដូចនេះមែន ហើយបើវាមិនផ្ទុយនឹងសេចក្តីពិត និងសេចក្តីដ៏សំខាន់ ដែលយើងបានរៀនអំពីព្រះ ក្នុងព្រះគម្ពីរ។ ហើយយើងខ្ញុំដឹងថា អ្នកខ្លះប្រហែលជាខឹងនឹងយើងខ្ញុំ ពេលយើងខ្ញុំប្រាប់ពួកគេមិនឲ្យជឿថា

ព្រះអង្គអយុត្តិធម៌ និងមិនល្អ ទោះព្រះអង្គពិតជាបានតម្រូវទុកជាមុនឬអត់ក៏ដោយ។ ប៉ុន្តែ យើងខ្ញុំក៏មិនចង់ឲ្យនរណាម្នាក់ឈប់ជឿលើសេចក្តីល្អ និងភាពយុត្តិធម៌របស់ព្រះឡើយ។ ហើយយើងខ្ញុំដឹងអំពីបញ្ហាដែលនឹងកើតមានពេលដែលយើងទទួលយកចម្លើយ សម្រាប់សំណួរនេះ ដោយមិនបានយល់អំពីភាពយុត្តិធម៌ និងសេចក្តីល្អរបស់ព្រះជាមុនសិន។ យើងខ្ញុំធ្លាប់ទួញយំកាលយើងខ្ញុំទើបតែចូលវ័យ២០ឆ្នាំ ជារដូវកាលដែលផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់យើងខ្ញុំបានទទួលទារុណកម្មយ៉ាងខ្លាំង ដោយសារបញ្ហាវេទសាស្រ្តដូចនេះ។ យើងខ្ញុំធ្លាប់ភ្លក់រស់ជាតិ នៃការយកដៃច្រត់ទៅលើតុ ហើយគ្របពីលើមុខខ្លួនឯង ហើយស្រែកយំទៅរកព្រះថា៖ «ព្រះអង្គអើយ ទូលបង្គំមិនយល់ទេ»។

ដូចនេះ យើងខ្ញុំចង់មានចិត្តអត់ធ្មត់ចំពោះអ្នកដែលមិនយល់បញ្ហានេះ។ យើងខ្ញុំមិនចង់ឲ្យនរណាម្នាក់ឈប់មានការជឿជាក់ លើសេចក្តីសុចរិត និងសេចក្តីល្អរបស់ព្រះនោះឡើយ។ នេះជាសេចក្តីពិតដែលជាមូលដ្ឋានទីមួយ សម្រាប់យើងខ្ញុំ។

សេចក្តីពិតដែលជាមូលដ្ឋានទី២ ដែលយើងត្រូវយល់នោះគឺថា ព្រះទ្រង់នឹងមិនដែលឲ្យនរណាម្នាក់ធ្លាក់នរក ដោយអយុត្តិធម៌នោះឡើយ។ គ្មាននរណាម្នាក់ដែលនឹងធ្លាក់នរក ខណៈពេលដែលពួកគេមិនសមនឹងធ្លាក់នរកនោះទេ។ ហើយនៅថ្ងៃនោះ ព្រះទ្រង់នឹងបើកបង្ហាញ ក្នុងចក្រវាលទាំងមូល ឲ្យគេដឹងច្បាស់ថា ពួកគេពិតជាសមនឹងទទួលទោសនេះមែន។

សេចក្តីពិតទី៣៖ ការនេះមានន័យថា បើព្រះទ្រង់បានតម្រូវទុកជាមុនឲ្យនរណាម្នាក់ត្រូវវិនាស នោះមានន័យថា ទ្រង់បានតម្រូវគេទុកជាមុន តាមរបៀប ដែលប្រហែលជាហួសសមត្ថភាពដែលយើងអាចយល់បាន។ ព្រះអង្គតម្រូវអ្នកនោះទុកជាមុនឲ្យត្រូវវិនាស ដោយសារអ្នកនោះពិតជាត្រូវទទួលខុសត្រូវ ចំពោះការសម្រេចចិត្តរបស់ខ្លួន គឺពិតជាមានកំហុស និងពិតជាសមនឹងទទួលទោសមែន។ នេះជារឿងដែលពិបាកយល់បំផុត។ តែយើងចាំបាច់ត្រូវជឿបទគម្ពីរទាំងអស់ក្នុងព្រះគម្ពីរ។ មនុស្សដែលត្រូវវិនាសគឺសុទ្ធតែបានសម្រេចចិត្តជ្រើសរើសយកអំពើបាប តាមរបៀបដែលខ្លួនពិតជាត្រូវទទួលខុសត្រូវចំពោះការសម្រេចចិត្ត ពិតជាមានទោស និងពិតជាសមនឹងទទួលការជំនុំជម្រះ។ នេះជាសេចក្តីពិតដែលជាមូលដ្ឋានទី៣។

សេចក្តីពិតដែលជាមូលដ្ឋានចុងក្រោយ ដែលយើងខ្ញុំចង់លើកមកនិយាយនោះគឺថា យើងកំពុងរស់នៅក្នុងសម័យដែលមនុស្សហាក់ដូចជាមិនចង់ឲ្យព្រះទ្រង់បំពេញតួនាទីជាព្រះឡើយ។ មនុស្សសម័យទំនើបថែមទាំង ស្ទើរតែមិនអាចយល់ឃើញថា មានព្រះមួយអង្គ ដែលមានអំណាចច្រើនយ៉ាងនេះ មានលក្ខណៈដែលពិបាកយល់យ៉ាងនេះ មានព្រះចេស្តាខ្លាំងយ៉ាងនេះ។ ចូរប្រយ័ត្នដោយកុំឲ្យផ្នត់គំនិតសម័យនេះរារាំងមិនឲ្យយើងជឿព្រះគម្ពីរនោះឡើយ។

**ព្រះអង្គឆ្លើយថា "ព្រះអង្គពិតជាបានតម្រូវទុកជាមុនមែន"**

ឥឡូវនេះ យើងខ្ញុំសូមលើកយកខគម្ពីរខ្លះមកបង្ហាញ ដើម្បីធ្វើការសន្និដ្ឋាន៖

- អេភេសូរ ១:១១៖ "ឲ្យរួមគ្នាមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរអាករក្នុងទ្រង់ដែរ ដោយទ្រង់បានតម្រូវយើងទុកជាមុន តាមតម្រិះសម្រេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់"។ គ្រប់ការទាំងអស់។ ឥឡូវនេះ សំណួរគឺសួរថា តើគ្រប់ការទាំងអស់បានសម្រេចតាមបំណងព្រះទ័យទ្រង់ ដោយរាប់បញ្ចូលទាំងការសម្រេចជោគវាសនាចុងក្រោយ របស់បុគ្គលម្នាក់ៗដែរឬទេ? យើងខ្ញុំយល់ថា ព្រះអង្គពិតជាបានសម្រេចជោគវាសនារបស់ពួកគេមែន។
- សុភាសិត ១៦:៤៖ "ព្រះយេហូវ៉ាទ្រង់បានធ្វើគ្រប់របស់ទាំងអស់ ឲ្យ

សមនឹងប្រយោជន៍នៃរបស់នោះឯង អើ ទោះទាំងមនុស្សអាក្រក់ក៏បានកើតមកសម្រាប់ថ្ងៃនៃសេចក្តីអាក្រក់ដែរ»។ ដូចនេះ ព្រះបានឲ្យមនុស្សអាក្រក់កើតមក សម្រាប់ថ្ងៃនៃសេចក្តីអាក្រក់។

- ១ពេត្រុស ២:៧-៨៖ «“ថ្មដែលពួកជាងសង់ផ្ទះបានចោលចេញ បានត្រឡប់ជាថ្មជ្រុងយ៉ាងឯក” “ជាថ្មជំពប់ ហើយជាថ្មដាដែលនាំឲ្យរវាតចិត្ត”» គេជំពប់នឹងព្រះបន្ទូលដោយព្រោះតែមិនជឿ ហើយគេក៏ត្រូវតម្រូវទុកសម្រាប់ការនោះឯង»។ ដូចនេះ ពួកគេមិនស្តាប់បង្គាប់ ដោយសារទ្រង់បានតម្រូវពួកគេទុក សម្រាប់ការនោះឯង។
- យូដាស ១:៤៖ «ដ្បិតមានមនុស្សខ្លះបានលួចចូល គឺជាពួកអ្នកដែលមានទោសកត់ទុក តាំងពីដើមមក ជាមនុស្សទមិឡល្មើស ដែលបំផ្លាស់ព្រះគុណរបស់ព្រះនៃយើងរាល់គ្នា ឲ្យទៅជាសេចក្តីអាសអាភាស ហើយគេមិនព្រមទទួលព្រះអម្ចាស់យេស៊ូវនៃយើង ដែលទ្រង់ជាម្ចាស់តែ១ផងទេ»។
- ២ពេត្រុស ២:៣៖ «ហើយដោយគេមានចិត្តលោភ នោះគេនឹងប្រើអ្នករាល់គ្នាឲ្យបានចំណេញ ដោយពោលពាក្យបញ្ឆោតបំពោត តែតាំងពីយូរមកហើយ សេចក្តីជំនុំជម្រះគេមិននៅស្ងៀមស្ងាត់ទេ ហើយសេចក្តីហិនវិនាសរបស់គេក៏មិនងុយងោកដែរ»។
- រ៉ូម ៩:១១-១២៖ [យ៉ាកុប និងអេសាវ] គ្រាដែលកូនមិនទាន់កើតមកនៅឡើយ ហើយមិនទាន់ធ្វើការល្អឬអាក្រក់អ្វី នោះព្រះទ្រង់មានព្រះបន្ទូលប្រាប់នាងថា «កូនច្បងនឹងត្រូវបំរើប្អូន»។ ដូចមានសេចក្តីចែងទុកមកថា «អញបានស្រឡាញ់យ៉ាកុប តែស្អប់អេសាវវិញ» គឺដើម្បីឲ្យព្រះតម្រិះរបស់ព្រះ ខាងឯសេចក្តីរើសតាំងបានជាប់នៅ មិនមែនដោយអាងការប្រព្រឹត្តទេ គឺដោយអាងព្រះដែលទ្រង់ហៅវិញ។ ក្នុងកណ្ឌគម្ពីរ ម៉ាឡាគី ១:២-៣ យើងត្រូវតែអានខគម្ពីរនេះ ផ្អែកទៅលើបរិបទ ដែលក្នុងនោះ ខគម្ពីរនេះបានបង្ហាញច្បាស់ថា ព្រះទ្រង់មានអំណាចគ្រប់គ្រង ដោយការតម្រូវទុកជាមុន បាន



ជាទ្រង់ជ្រើសរើសយ៉ាកុប ជាជាងរើសអេសាវ ប៉ុន្តែ ព្រះអង្គក៏បានបង្ហាញឲ្យយើងដឹងថា អេសាវក៏ពិតជាមានភាពទុច្ចរិត និងសមនឹងទទួលការស្តីបន្ទោស ហើយត្រូវទទួលខុសត្រូវពិតមែនដែរ។

- រ៉ូម ៩:២២-២៣៖ «ចុះបើសិនជាព្រះទ្រង់ចង់សម្តែងសេចក្តីក្រោធព្រមទាំងបើកឲ្យស្គាល់ព្រះចេស្តា ដល់គ្រឿងប្រដាប់គួរនឹងក្រោធ ដែលរៀបចំឡើងសម្រាប់តែត្រូវបំផ្លាញដូច្នេះ ដែលទ្រង់ទ្រាំទ្រដោយអំណត់ជាយូរមកហើយ។ ហើយបើទ្រង់ចង់បើកឲ្យគ្រឿងប្រដាប់ ដែលគួរនឹងសេចក្តីមេត្តាករុណា ដែលទ្រង់បានរៀបចំជាមុន បានស្គាល់សេចក្តីវិសេសនៃសិរីល្អដ៏បរិសុទ្ធរបស់ទ្រង់វិញ»។

យើងខ្ញុំសូមមិនធ្វើការបកស្រាយច្រើន អំពីបទគម្ពីរនេះទេ។ ផ្អែកលើបទគម្ពីរនេះ យើងខ្ញុំសូមឆ្លើយថា ព្រះទ្រង់ពិតជាបានតម្រូវទុកឲ្យអ្នកខ្លះធ្លាក់នរកមែន។ ព្រះទ្រង់ពិតជាបានកំណត់ទុកជាមុន តាំងពីអស់កល្បជានិច្ច ឲ្យអ្នកខ្លះបានសង្គ្រោះ ហើយខ្លះទៀតត្រូវបាត់បង់។ តែទ្រង់បានធ្វើកិច្ចការនេះតាមរបៀបដែលអាថ៌កំបាំងចំពោះយើង ដើម្បីកុំឲ្យនរណាម្នាក់អាចចោទប្រកាន់ព្រះអង្គ នៅថ្ងៃនោះឡើយ។ ពួកអ្នកដែលបានទទួលការប្រោសលោះនឹងបានដឹងថា យើងបានសង្គ្រោះដោយសារព្រះគុណព្រះអង្គ ខណៈពេលដែលយើងសមនឹងធ្លាក់នរក ហើយអ្នកដែលមិនបានសង្គ្រោះ មិនបានស្គាល់ព្រះគុណព្រះអង្គ ហើយពួកគេក៏សមនឹងវិនាសផងដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Does God Predestine People to Hell
**តើព្រះបានតម្រូវទុកជាមុន ឲ្យអ្នកខ្លះធ្លាក់នរកឬ?**
https://www.desiringgod.org/interviews/does-god-predestine-people-to-hell

## សំណួរទី២៨៖

# តើការ «ធ្វើបាបស្ម័គ្រពីចិត្ត» គម្រាមកំហែងលើ សេចក្ដីសង្គ្រោះរបស់ខ្ញុំដែរឬទេ?

ក្នុងជីវិតនេះ គ្រីស្ទបរិស័ទតយុទ្ធជាមួយនឹងអំពើបាប ពីព្រោះយើងនៅតែជាមនុស្សមានបាប។ វត្តមាននៃអំពើបាបនៅក្នុងយើងនឹងមិនត្រូវបានដកចេញរហូតដល់ថ្ងៃដ៏រុងរឿង នៅពេលដែលយើងឃើញព្រះយេស៊ូវមុខទល់នឹងមុខ។ ថ្ងៃនោះនឹងពិតជាអស្ចារ្យណាស់! ប៉ុន្តែ រហូតដល់ថ្ងៃនោះ យើងបន្តតយុទ្ធជាមួយនឹងអំពើបាប ហើយយើងអាចមានបទពិសោធន៍នៃការធានាបាន ខណៈពេលដែលយើងនៅកំពុងតែធ្វើសង្គ្រាម។ ប៉ុន្តែ យើងក៏ជឿផងដែរថា នៅមានទម្រង់នៃការធ្វើបាបស្ម័គ្រពីចិត្ត ដែលបង្ហាញជាភស្តុតាងថាដួងចិត្តរបស់បុគ្គលណាម្នាក់មិនទាន់បានទទួលសេចក្ដីសង្គ្រោះនៅឡើយ។

«ជម្រាបសួរលោកគ្រូ! សំណួររបស់ខ្ញុំទាក់ទងគ្នាជាមួយនឹងខគម្ពីរពិបាកៗ ជាពិសេសនៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១០:២៦-២៩។ មើលទៅហាក់បីដូចជាថាអ្នកនិពន្ធកំពុងតែលើកឡើងថា យើងមានសមត្ថភាពក្នុងការបាត់បង់សេចក្ដីសង្គ្រោះ តាមរយៈការធ្វើបាបស្ម័គ្រពីចិត្ត ដូចដែលគេបានហៅនោះ។ សំណួររបស់ខ្ញុំគឺថា តើអ្វីទៅជាចំណុចផ្ទុយគ្នាពី «[ការ] ធ្វើបាបស្ម័គ្រពីចិត្ត»? តើនេះសំដៅលើអំពើបាបដែលយើងប្រព្រឹត្តដោយចៃដន្យ? ឬក៏អ្វីផ្សេងទៀត? ចំពោះខ្ញុំ មើលទៅហាក់បីដូចជាថា ដោយសារវត្តមាននៃការដែលព្រះវិញ្ញាណកាត់ឲ្យយើងជាប់ទោស គ្រប់អំពើបាបទាំងអស់ដែលអ្នកជឿគឺសុទ្ធតែបានប្រព្រឹត្តឡើងដោយការស្ម័គ្រពីចិត្ត។ តើមានចំណុចណាមួយដែលខ្ញុំមិនឃើញនៅក្នុងខគម្ពីរទាំងនេះមែនឬ?

អ្នកសួរបានសួរយ៉ាងត្រឹមត្រូវមែន។ ជារឿយៗកណ្ឌគម្ពីរ ហេព្រើរ ជំពូក

១០ និងជំពូក៦ ហាក់បីដូចជាបង្ហាញដល់អ្នកអានថា គាត់មានសេចក្តីសង្គ្រោះយ៉ាងពេញទី ហើយបន្ទាប់មកក៏បានបាត់បង់សេចក្តីសង្គ្រោះនោះវិញ។ មើលទៅ ហាក់បីដូចជាថា ខគម្ពីរទាំងនោះក៏កំពុងតែបង្រៀនដូច្នេះដែរ ប៉ុន្តែយើងដឹងថាមានតម្រុយដែលអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានលើកឡើងថា នោះមិនមែនជាអ្វីដែលគាត់កំពុងតែបង្រៀននោះទេ។ សំណួរនេះមានពីរចំណុចៈ

១. តើខគម្ពីរទាំងនេះបង្រៀនថា យើងអាចបាត់បង់សេចក្តីសង្គ្រោះរបស់យើងមែនឬ?

២. តើកណ្ឌគម្ពីរ ហេព្រើរ ១០:២៦ មានន័យយ៉ាងដូចម្តេចទាក់ទងទៅនឹង «[ការ] ធ្វើបាបស្ម័គ្រពីចិត្ត» ដោយសារក្នុងអត្ថន័យមួយ រាល់អំពើបាបទាំងអស់គឺជាការស្ម័គ្រចិត្តប្រព្រឹត្តដោយចេតនា?

## ការស្ម័គ្រចិត្តពីរយ៉ាង

ខគម្ពីរដែលគាត់កំពុងតែសួរគឺៈ «ដ្បិតក្រោយដែលយើងបានទទួលស្គាល់សេចក្តីពិតហើយ បើយើងធ្វើបាបស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណាសម្រាប់នឹងលោះបាបទៀតទេ» (ហេព្រើរ ១០:២៦)។ បើនិយាយម្យ៉ាងវិញទៀត យើងមិនអាចទទួលសេចក្តីសង្គ្រោះបានទេ។

ខ្ញុំមានការសង្កេតពីរយ៉ាងដែលសំខាន់លើឃ្លា «ធ្វើបាបស្ម័គ្រពីចិត្តទៀត»។

ទី១ ពាក្យ «ស្ម័គ្រពីចិត្ត» គឺជាការបកប្រែពីពាក្យ «ហេខូសីអូស៍» (hekousiōs) ក្នុងភាសាក្រិក។ ទី២ កណ្ឌគម្ពីរ ១ពេត្រុស ៥:២ ក៏បានប្រើប្រាស់ពាក្យនេះដែរ «ចូរឃ្វាលហ្វូងចៀមរបស់ព្រះ ដែលនៅជាមួយនឹងអ្នករាល់គ្នាចុះ ទាំងគ្រប់គ្រងដោយស្ម័គ្រពីចិត្ត [«ហេខូសីអូស៍»] មិនមែនដោយបង្ខំទេ ក៏មិនមែនដោយចង់បានកម្រៃដែរ គឺដោយគាប់ចិត្តវិញ»។ ខគម្ពីរទាំងពីរនេះបានប្រើប្រាស់ពាក្យដូចគ្នា។

ការប្រើប្រាស់ពាក្យ «ស្ម័គ្រពីចិត្ត» បង្ហាញថាមានការស្ម័គ្រចិត្តពីរយ៉ាង។ ទី១ អត្ថន័យមួយគឺកើតចេញពីការប្រាថ្នាចង់ធ្វើយ៉ាងអស់ពីចិត្ត ទី២ ហើយមួយទៀតគឺកើតចេញពីការបង្ខំ។

ក្នុងករណីទាំងពីរ យើងអាចវែកញែកថា ពួកចាស់ទុំកំពុងតែប្រើប្រាស់ឆន្ទៈរបស់ខ្លួនក្នុងការឃ្វាលហ្វូងចៀមរបស់ព្រះ។ ក្នុងករណីមួយគឺថា ពួកគាត់កំពុងតែធ្វើដោយមានការសប្បាយចិត្ត។ វាគឺជាទង្វើនៃការប្រព្រឹត្តដែលកើតចេញពីចិត្តទាំងស្រុង។ គឺជាការធ្វើដោយរីករាយ និងពេញដោយកម្លាំង។ ក្នុងករណីមួយទៀត គឺធ្វើដោយមិនចង់ធ្វើ គឺជាទង្វើដែលប្រព្រឹត្តឡើងដោយមានការប្រឆាំងនឹងផ្នែកដ៏ធំមួយនៃឆន្ទៈ ពីព្រោះគាត់ចង់ធ្វើអ្វីផ្សេងទៀត ក្រៅពីការនោះ។ ពួកគាត់មិនចង់ឃ្វាលហ្វូងចៀមរបស់ព្រះទេ ប៉ុន្តែដោយសារចង់បានលុយ បានភាពល្បីល្បាញ ឬក៏ចង់គេចចេញពីអារម្មណ៍ដែលមានពិរុទ្ធភាព ដូច្នេះពួកគាត់ក៏ខំបម្រើ និងឃ្វាលហ្វូងចៀមរបស់ព្រះ។

## អំពើបាបដែលបំផ្លាញ

នេះគឺជាការកែតម្រង់លើការសន្មតរបស់អ្នកសួរថា រាល់គ្រប់អំពើបាបគឺជាការប្រព្រឹត្តឡើងដោយមានការស្ម័គ្រចិត្ត ស្មើៗគ្នា—ឬក៏ថា គ្រប់ទង្វើរបស់មនុស្សគឺជាការប្រព្រឹត្តឡើងដោយមានការស្ម័គ្រចិត្ត ស្មើៗគ្នា—ដោយសារគ្រប់ទង្វើ ដែលមានរួមទាំងការប្រព្រឹត្តអំពើបាប គឺសុទ្ធតែជាទង្វើដែលកើតចេញពីឆន្ទៈនៃការប្រព្រឹត្តិដោយស្ម័គ្រពីចិត្ត។ នេះគឺជាការពិតមែន។ ទាំងនោះគឺសុទ្ធតែជាទង្វើនៃការប្រព្រឹត្តិដោយចេតនា។ យើងបានជ្រើសរើសប្រព្រឹត្តទង្វើទាំងនោះ។

កណ្ឌគម្ពីរ ហេព្រើរ ១០:២៦ កំពុងតែលើកឡើងអ្វីផ្សេងទៀតដែល

លើសពីអំពើបាបដែលបំផ្លាញព្រលឹងចោលថាជាទង្វើនៃការប្រព្រឹត្តឡើងដោយមានឆន្ទៈ។ ពិតណាស់ វាដូច្នោះមែន ប៉ុន្តែវាក៏លើសនោះផងដែរ។ គ្រប់អំពើបាបគឺជាទង្វើនៃការប្រព្រឹត្តដោយមានឆន្ទៈ ប៉ុន្តែមិនមែនថារាល់អំពើបាបបំផ្លាញយើងនោះទេ។ វាពាក់ព័ន្ធទៅនឹងការធ្វើដោយចេតនា ការមានសេចក្តីប៉ងប្រាថ្នាចង់ធ្វើ ដោយកើតចេញពីចិត្តទាំងស្រុង ទាក់ទងទៅនឹងទង្វើនៃការប្រព្រឹត្តដោយមានការស្ម័គ្រចិត្ត។ គឺជាទង្វើដែលបង្ហាញថាបុគ្គលនោះពិតជាមិនមានអត្តសញ្ញាណថ្មីខាងឯវិញ្ញាណនៅក្នុងគាត់ទេ ដែលអត្តសញ្ញាណនោះរាំង ឬក៏ទប់ឆន្ទៈប្រព្រឹត្តរបស់គាត់ យ៉ាងហោចណាស់ក្នុងកម្រិតណាមួយ។

## ទម្លាប់នៃការប្រព្រឹត្តអំពើបាប

នេះគឺជាចំណុចទី២ក្នុងការសម្គាល់លើឃ្លា «[ការ] ធ្វើបាបស្ម័គ្រពីចិត្ត» [ឬក៏ការជ្រើសរើសធ្វើបាបដោយចេតនា ឬក៏មានចិត្តប្រាថ្នាចង់ធ្វើ]។ ឃ្លា «ធ្វើបាបស្ម័គ្រពីចិត្តទៀត» (ឬក៏ «នៅតែប្រព្រឹត្តបាបដោយចេតនាទៀត» បកប្រែដោយព្រះគម្ពីរគ្រីស្ទបរិស័ទខ្មែរ) គឺជាការបកប្រែដែលល្អមួយក្នុងកាលសព្ទក្នុងភាសាក្រិក សម្រាប់កិរិយាសព្ទនៃពាក្យ «ប្រព្រឹត្តបាប»។

បើនិយាយម្យ៉ាងវិញទៀត នេះមិនមែនសំដៅទៅលើការប្រព្រឹត្តតែម្តងនោះទេ ហើយក៏មិនមែនសំដៅទៅលើការប្រព្រឹត្តម្តងម្កាលនោះដែរ ឬមួយតែជានិច្ចជាកាល។ ប៉ុន្តែ គឺសំដៅទៅលើការប្រព្រឹត្តម្តងហើយម្តងទៀត បែបជាទម្លាប់វិញ។ នេះសំដៅទៅលើការមានចិត្តចង់ប្រព្រឹត្តអំពើបាបម្តងហើយម្តងទៀតឥតឈប់ឈរ។ អ្វីដែលបំផ្លាញព្រលឹងវិញ្ញាណ អ្វីដែលនាំឲ្យព្រលឹងនោះលែងអាចទទួលការអត់ទោសនៅក្នុងខ២៦ គឺមិនមែនអំពើបាបផ្ទាល់នោះទេ ប៉ុន្តែគឺការមានចិត្តប្រាថ្នាចង់ធ្វើ ដោយមានចេតនា ការមានឆន្ទៈដែលមានការបន្ត និងលំនាំនៃទម្លាប់នៃការធ្វើបាបម្តងហើយម្តងទៀត។



យើងអាចឃើញអំពីចំណុចធ្ងន់ធ្ងរនេះ តាមរយៈការមើលខមុន និងខបន្ទាប់ពីខ២៦។ ខ២៦ចាប់ផ្តើមដោយប្រើពាក្យ «ដ្បិត» ដែលនេះបង្ហាញអំពីប្រភេទនៃអំពើបាបដែលខនេះសំដៅលើក្នុងខមុន—ដែលនេះសំដៅចំៗទៅលើអំពើបាបនៃការលែងប្រជុំគ្នា បែបជាការប្រកបជាមួយនឹងគ្រីស្ទបរិស័ទ និងការបដិសេធការកំឡាចិត្តគ្នាទៅវិញទៅមក។ បើនិយាយម្យ៉ាងវិញទៀត បុគ្គលនេះកំពុងតែដើរចេញពីព្រះគ្រីស្ទ និងក្រុមជំនុំ។

បន្ទាប់មក ប្រសិនបើលោកអ្នកមើលក្រោយខ២៦ ជាពិសេសខ២៩ នោះលោកអ្នកនឹងឃើញថាទម្លាប់នៃអំពើបាបគឺធ្ងន់ធ្ងរណាស់ ហើយក៏ជាអ្វីដែលប្រព្រឹត្តឡើងម្តងហើយម្តងទៀត ដែលអ្នកនិពន្ធបានហៅថាជាការ «ជាន់ឈ្លីព្រះរាជបុត្រានៃព្រះ ទាំងរាប់ព្រះលោហិតនៃសេចក្តីសញ្ញា ដែលបានញែកគេចេញជាបរិសុទ្ធ...ហើយត្មះតិះដៀលដល់ព្រះវិញ្ញាណដ៏មានព្រះគុណផងនោះ» (ហេព្រើរ ១០:២៩)។

ត្រង់នេះ មើលទៅហាក់បីដូចជាថា យើងអាចបាត់បង់សេចក្តីសង្គ្រោះរបស់យើងបាន ដោយសារប្រយោគ «ដែលបានញែកគេចេញជាបរិសុទ្ធ»។ តាមរយៈការបន្តប្រព្រឹត្តអំពើបាបដោយស្ម័គ្រពីចិត្ត ដោយចេតនា និងជាលំនាំ នោះលោកអ្នកអាចមិនគោរពព្រះលោហិតនៃសេចក្តីតាំងសញ្ញា ដែលបានញែកលោកអ្នកជាបរិសុទ្ធជាមិនខាន។ ដែលស្តាប់ទៅហាក់បីដូចជាថា «គាត់បានទទួលសេចក្តីសង្គ្រោះមែន ប៉ុន្តែឥឡូវគាត់មិនអាចនៅបន្តទទួលបានការអត់ទោសបានទៀតទេ។ ដូច្នេះ លោកអ្នកអាចបាត់បង់សេចក្តីសង្គ្រោះបាន»។

មានខគម្ពីរពីរនៅក្នុងកណ្ឌគម្ពីរហេព្រើរដែលជួយកុំឲ្យខ្ញុំគិតដូចនោះ។

## បាត់ហើយរកឃើញវិញ

មានខគម្ពីរពីរដែលជួយកុំឲ្យខ្ញុំគិតថា ការលើកឡើងរបស់គាត់ទាក់ទង

ទៅនឹងស្ថានភាពនៃការញែកជាបរិសុទ្ធចំពោះបុគ្គលដែលបានបាត់បង់មានន័យថា យើងអាចមានបទពិសោធន៍យ៉ាងពេញទី ក្នុងការទទួលបានសេចក្តីសង្គ្រោះនៅក្នុងព្រះគ្រីស្ទ ហើយបន្ទាប់មកអាចបាត់បង់ការសង្គ្រោះនោះទៅវិញបាន។ នេះគឺជាខគម្ពីរទាំងពីរនោះ៖ ហេព្រើរ ១០:១៤ និងហេព្រើរ ៣:១៤។

កណ្ឌគម្ពីរ ហេព្រើរ ១០:១៤ មានចែងដូចតទៅ៖ «ដ្បិតទ្រង់ធ្វើឲ្យពួកអ្នក ដែលបានញែកជាបរិសុទ្ធហើយ បានគ្រប់លក្ខណ៍អស់កល្បជានិច្ច ដោយសារតង្វាយតែ១នោះ»។ តើលោកអ្នកគិតយ៉ាងដូចម្តេច? ឃ្លា «ដោយសារដង្វាយតែ១»—នេះសំដៅទៅលើដង្វាយរបស់ព្រះគ្រីស្ទ—ព្រះជាម្ចាស់បានធ្វើឲ្យអស់អ្នកដែលទ្រង់បានញែកជាបរិសុទ្ធឲ្យបានគ្រប់លក្ខណ៍អស់កល្បជានិច្ច។ បើនិយាយម្យ៉ាងវិញទៀត មានប្រភេទនៃការញែកជាបរិសុទ្ធដែលធានាយ៉ាងពេញលេញថា យើងនឹងទទួលបានការគ្រប់លក្ខណ៍អស់កល្បជានិច្ច។ មួយវិញទៀត គ្មានបុគ្គលណាអាចបាត់បង់សេចក្តីសង្គ្រោះបានទេ ប្រសិនបើគាត់ធ្លាប់មានបទពិសោធន៍នៃការញែកជាបរិសុទ្ធប្រភេទនេះ។

នេះគឺជាខគម្ពីរទី២៖ ហេព្រើរ ៣:១៤៖ «ដ្បិតបើយើងរាល់គ្នាកាន់ខ្ជាប់តាមសេចក្តីជំនឿដើម ដរាបដល់ចុងបំផុតមែន នោះពិតជាយើងបានត្រឡប់ជាអ្នកមានចំណែកជាមួយនឹងព្រះគ្រីស្ទហើយ»។ សូមសម្គាល់ត្រង់ថា ខគម្ពីរនេះមិនបានលើកឡើងថា យើងមានចំណែកក្នុងព្រះគ្រីស្ទ ប្រសិនបើយើងកាន់ភ្ជាប់រហូតដល់ទីបញ្ចប់។ ប៉ុន្តែ ខគម្ពីរនេះបានលើកឡើងថា «បើយើងរាល់គ្នាកាន់ខ្ជាប់...ដរាបដល់ចុងបំផុតមែន នោះពិតជាយើងបានត្រឡប់ជាអ្នកមានចំណែកជាមួយនឹងព្រះគ្រីស្ទហើយ» ដែលនេះមានន័យថា ប្រសិនបើយើងមិនបានកាន់ភ្ជាប់ ដូចជាបុគ្គលនៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១០:២៦ នោះមានន័យថា យើងមិនដែលធ្លាប់មានចំណែកជាមួយនឹងព្រះ



គ្រីស្ទទេ។ នេះគឺជាការបង្រៀនដ៏ច្បាស់លាស់ចេញពីកណ្ឌគម្ពីរ ហេព្រើរ ៣:១៤។

យើងមិនបានបាត់បង់ចំណែករបស់យើងក្នុងព្រះគ្រីស្ទទេ។ ផ្ទុយទៅវិញ យើងមិនដែលធ្លាប់ទាំងមានចំណែកនោះផង។

## ការរួបរួមជាមួយនឹងព្រះគ្រីស្ទ

សេចក្តីសន្និដ្ឋានរបស់ខ្ញុំគឺថា៖ បទពិសោធន៍នៃការទទួលបានការញែកជាបរិសុទ្ធដែលកណ្ឌគម្ពីរ ហេព្រើរ ១០:២៦ និង១០:២៩ បានលើកឡើងសំដៅទៅលើបុគ្គលដែលបានបាត់បង់ គឺជាខ្នាតរង្វាស់នៃការជះឥទ្ធិពលពីព្រះជាម្ចាស់លើសីលធម៌ ទាក់ទងនឹងការបំផ្លាស់បំប្រែរបស់ទ្រង់លើជីវិតបុគ្គលនោះ ដែលមានចំណែកយ៉ាងខ្លាំងនៅក្នុងក្រុមជំនុំ ដោយប្រកាសផ្នែកណាមួយនៃជំនឿ មានចំណាប់អារម្មណ៍ជាច្រើនលើអ្វីដែលទាក់ទងទៅនឹងជំនឿគ្រីស្ទបរិស័ទ និងអ្នកជឿផ្សេងៗ។ ប៉ុន្តែ គាត់មិនធ្លាប់បានជឿលើព្រះគ្រីស្ទ ក្នុងរបៀបដែលនាំឲ្យគាត់មានការរួបរួមជាមួយនឹងទ្រង់ទេ—គឺការមានចំណែកក្នុងទ្រង់ និងជីវិតអស់កល្ប ក៏ដូចជាសេចក្តីសង្គ្រោះ។

## ចម្លើយរបស់ខ្ញុំទៅកាន់អ្នកសួរគឺដូចនេះ៖

១. ទេ! ខ្ញុំគិតថា អ្នកដែលជឿលើព្រះគ្រីស្ទពិតប្រាកដមិនអាចបាត់បង់សេចក្តីសង្គ្រោះរបស់គាត់បានឡើយ។

២. ខ្ញុំគិតថា មានប្រភេទនៃការប្រព្រឹត្តអំពើបាប ដែលលើសពីចេតនាពេញទៅដោយការប្រាថ្នាចង់ធ្វើ គឺការប្រព្រឹត្តអំពើបាបម្តងហើយម្តងទៀតដែលមិនដូចគ្នាទៅនឹងការដែលអ្នកជឿជាពិតប្រព្រឹត្តអំពើបាប—គឺអំពើបាបដែលពួកគាត់លន់តួ ហើយទទួលបានការអត់ទោស។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
How Does ‘Willful Sinning’ Threaten My Salvation
**តើការ «ធ្វើបាបស្ម័គ្រពីចិត្ត» គម្រាមកំហែងលើសេចក្ដីសង្គ្រោះរបស់ខ្ញុំដែរឬទេ?**
https://www.desiringgod.org/interviews/how-does-willful-sinning-threaten-my-salvation



## សំណួរទី២៩៖
# គ្រូគង្វាលរបស់ខ្ញុំមិនអធិប្បាយទាស់ប្រឆាំងនឹងអំពើបាបសោះ តើការនោះមិនអីទេ?

សំណួរសាមញ្ញមួយដែលបានទទួលតាមរយៈអ៊ីមែលពីប្អូនស្រីម្នាក់មកពីខេត្ត ជាប្រិយមិត្តអ្នកស្ដាប់ម្នាក់របស់ផ្លូវពិត។ នេះជាសាររបស់ប្អូនស្រី «មកដល់លោកគ្រូ និងក្រុមការងារផ្លូវពិត។ នាងខ្ញុំជាគ្រីស្ទបរិស័ទថ្មីម្នាក់ ហើយនាងខ្ញុំមានបញ្ហាជាមួយពួកជំនុំរបស់នាងខ្ញុំ។ នាងខ្ញុំបានទទួលបុណ្យជ្រមុជទឹកកាលពី៤ឆ្នាំមុន ហើយបានក្លាយជាសមាជិកម្នាក់នៅទីនោះ។ ពេលវេលាចេះតែកន្លងផុតទៅ នាងខ្ញុំសម្គាល់ឃើញថា ការអធិប្បាយមិនមាននិយាយទាក់ទងនឹងអំពើបាបទាល់តែសោះ និងមិនដែលប្រកាសឲ្យមានការប្រែចិត្តឡើយ។ នាងខ្ញុំបានសួរគ្រូគង្វាលម្នាក់ក្នុងចំណោមគ្រូគង្វាលទាំងនោះអំពីការនេះ គាត់និយាយថា ពួកគេមិនបានកំពុងបង្រៀនអ្វីផ្ទុយព្រះគម្ពីរនោះទេ ពួកគាត់គ្រាន់តែសម្រេចចិត្តថា មិននិយាយចំៗអំពីអំពើបាបតែប៉ុណ្ណោះ។ ពួកគាត់ចង់ផ្ដោតទៅលើសេចក្ដីស្រឡាញ់នៃព្រះយេស៊ូវ និងការទទួលយកមនុស្សមានបាប។ ជាដំបូង ពេលស្ដាប់ទៅមិនអីទេសម្រាប់ខ្ញុំ វាគ្រាន់តែជាការប្រឹងប្រែងទាក់ទាញមនុស្សជាច្រើនឲ្យចូលមកក្រុមជំនុំ។ ទន្ទឹមគ្នានេះដែរ ពួកគាត់មិនបានត្រេកអរនឹងការប្រែចិត្ត និងការស្ដាប់បង្គាប់ទេ។ តើលោកគ្រូគិតយ៉ាងដូចម្ដេចដែរអំពីពួកជំនុំដែលមិនអធិប្បាយទាស់ប្រឆាំងនឹងអំពើបាបជាក់លាក់ណាមួយ?»

ខ្ញុំគិតថា ពួកជំនុំគឺនៅមានកន្លែងខ្វះចន្លោះជាច្រើន។ វាជាការមិនស្មោះត្រង់ចំពោះព្រះបន្ទូលរបស់ព្រះទេ។ ម្ដងហើយម្ដងទៀត អស់ពីបញ្ហាមួយចូលដល់បញ្ហាមួយអស់ពីភាពចម្រូងចម្រាស់មួយចូលដល់ភាពចម្រូង

ចម្រាស់មួយអស់ពីអំពើបាបមួយចូលដល់អំពើបាបមួយទៀតជាន់ដានគ្នា ដូចខ្សែទឹកហូរទៅកាន់ជម្រាលដែលពេញដោយបញ្ហា៖ តើអ្នកដឹកនាំ និងមនុស្សម្នាទាំងឡាយបានចាត់ទុកព្រះបន្ទូលព្រះជាសម្បត្តិលើសពីមាសប្រាក់ដែរឬទេ? តើពួកគេបានភ្លក់ព្រះបន្ទូលព្រះថា ផ្អែមជាងទឹកឃ្មុំដែរឬទេ? ហើយតើពួកគេបានចុះចូលនឹងព្រះបន្ទូលព្រះដោយអំណរក្នុងសេចក្ដីពិត និងសមាមាត្រគ្នាដែរឬអត់? ជម្រាលនៃបញ្ហានោះកើតឡើងម្ដងហើយម្ដងទៀត ខ្ញុំនៅតែឃើញវាហូតសព្វថ្ងៃ—ដូចនៅពេលនេះអញ្ចឹង។

ហេតុអ្វីបានជាគ្រូគង្វាលសន្មតថា ខ្លួនគេជាម្នាក់ដែលមានភាពវៃឆ្លាតជាងព្រះគម្ពីរនៅក្នុងរបៀបមួយដែលពួកគាត់បង្រៀនទៅកាន់រាស្ត្ររបស់ព្រះទៅវិញ? ការនេះធ្វើឲ្យខ្ញុំឆ្ងល់ណាស់។ ប៉ុន្តែម្ដងហើយម្ដងទៀត ខ្ញុំឃើញថា វាជាករណីមួយលើបញ្ហានេះ និងបញ្ហាផ្សេងៗទៀត។ អ្នកដឹកនាំពួកជំនុំគិតថា ពួកគាត់ចេះជាងលំនាំនៃព្រះគម្ពីរផ្ទាល់ទៅទៀត។ ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំផ្ដល់ហេតុផល៤យ៉ាងអំពីព្រះគម្ពីរថា ហេតុអ្វីបានជាវាមានភាពខ្វះចន្លោះ ហេតុអ្វីបានជាមិនមានភាពស្មោះត្រង់ ការមិននិយាយឈ្មោះអំពើបាបដោយចំៗ ការប្រកាសទាស់ និងប្រកាសឲ្យប្រែចិត្តចេញពីអំពើបាបជាក់លាក់ណាមួយដែលមាននៅក្នុងលោកីយ៍ និងពួកជំនុំ។

## ពួកហោរា ពួកសាវ័ក និងព្រះយេស៊ូវ

ដំបូង តើលោកអ្នកមើលពួកហោរានៅក្នុងបទគម្ពីរសញ្ញាចាស់ ឬការបង្រៀនរបស់ព្រះយេស៊ូវមុនពេលទ្រង់ត្រូវបានគេឆ្កាង ឬការបង្រៀនរបស់ពួកសាវ័កបន្ទាប់ពីការឆ្កាងទ្រង់ និងបន្ទាប់ពីការចាក់បង្ហូរនៃព្រះវិញ្ញាណបរិសុទ្ធ លោកអ្នកបានមើលក្នុងការបង្រៀនតាមបទគម្ពីរ—អ្នកតំណាងរបស់ព្រះជាម្ចាស់មិនត្រឹមតែមិនប្រកាសអំពីសិរីរុងរឿងអំពីដំណឹងល្អនៃការប្រែចិត្តចេញពីអំពើបាប តែក៏ជាការប្រកាសខាងឯដំណឹងល្អទាស់នឹងអំពើបាប និងអំពើបាបជាក់លាក់ណាមួយផង ហើយក៏ជាការប្រកាសឲ្យប្រែចិត្ត និងការស្ដាប់បង្គាប់នៅក្នុងអំណាចនៃព្រះគុណរបស់ព្រះជាម្ចាស់ទៀតផង។ ឧទាហរណ៍៖ សូមក្រឡេកមើលទៅលើការសរសេររបស់ពួកហោរា ដូចជានៅក្នុងកណ្ឌគម្ពីរ ម៉ាឡាគី ៣:៥៖

«ហើយអញនឹងមកជិតឯងរាល់គ្នា ដើម្បីនឹងសំរេចតាមសេចក្ដីយុត្តិធម៌ អញនឹងធ្វើជាសាក្សីយ៉ាងរហ័ស ទាស់នឹងពួកគ្រូអាបធ្មប់ ទាស់នឹងពួកកំផិត ទាស់នឹងពួកអ្នកដែលស្បថបំពាន ទាស់នឹងពួកដែលកេងបំបាត់ឈ្នួលរបស់កូនឈ្នួល ព្រមទាំងសង្កត់សង្កិនស្រីមេម៉ាយ និងមនុស្សកំព្រាផង ហើយដែលបង្វែរសេចក្ដីយុត្តិធម៌ ចេញពីពួកអ្នកដែលស្នាក់នៅ ឥតកោតខ្លាចដល់អញដែរ នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ»។

ម្យ៉ាងវិញទៀត ពួកហោរានិយាយអំពីអំពើបាបទាំងឡាយ នោះគឺជារបៀបដែលពួកគាត់បានអធិប្បាយ។ ឬក៏មើលឧទាហរណ៍របស់ព្រះយេស៊ូវ៖

- ចំពោះអំពើបាបនៃសេចក្ដីភាពត្រេកត្រអាល៖ "បើភ្នែកស្តាំអ្នកនាំឲ្យវាតចិត្ត នោះចូរខ្វេះចេញបោះចោលទៅ ដ្បិតដែលភ្នែកអ្នក១ត្រូវវិនាស នោះមានប្រយោជន៍ ជាជាងឲ្យរូបកាយទាំងមូល ត្រូវបោះទៅក្នុងនរក" (ម៉ាថាយ ៥:២៩)។
- ឬសេចក្ដីលោភលន់៖ "តែវេទនាដល់អ្នករាល់គ្នា ជាអ្នកមាន ដ្បិតអ្នករាល់គ្នាកំពុងតែមានសេចក្ដីកំសាន្តចិត្តក្នុងសម័យនេះ" (លូកា ៦:២៤)។
- ឬមនុស្សមានពុត៖ "វេទនាដល់អ្នករាល់គ្នា ពួកអាចារ្យ និងពួកផារិស៊ី ជាមនុស្សកំពុតអើយ" (ម៉ាថាយ ២៣:២៩)។

ឬមើលការបង្រៀនរបស់សាវ័ក ប៉ុល៖ «ចូររត់ពីការសហាយស្មន់ចេញ» [នៅព្រះគម្ពីរដើមសរសេរថា ចូររត់គេចចេញពីអំពើអសីលធម៌ផ្លូវភេទទាំងឡាយចេញ (១កូរិនថូស ៦:១៨)]។

«កុំឲ្យចាញ់សេចក្ដីបោកបញ្ឆោតឡើយ៖ មិនថាការប្រព្រឹត្តអំពើ

អសីលធម៌ខាងផ្លូវភេទ អ្នកថ្វាយបង្គំរូបព្រះ អ្នកកំផិត អ្នកដែលរួមដំណេកនឹងភេទដូចគ្នា អ្នកលួចប្លន់ អ្នកលោភលន់ អ្នកប្រមឹក អ្នកជេរប្រមាថ អ្នកបោកបញ្ឆោត នឹងមិនបានគ្រងមរតកនគរព្រះទេ» ១កូរិនថូស ៦:៩-១០។

ដូច្នេះ នេះជារបៀបដែលពួកហោរា ព្រះយេស៊ូវ ពួកសាវ័កបានអធិប្បាយ។ ពួកលោករាប់ឈ្មោះអំពើបាបទាំងឡាយ និងពួកលោកប្រកាសទាស់នឹងវា ទាំងបានប្រកាសឲ្យមានការប្រែចិត្ត និងការស្ដាប់បង្គាប់នៅក្នុងអំណាចនៃដំណឹងល្អអំពីការអត់ទោស ដែលពួកលោកបានបង្រៀន។ ដូច្នេះ គ្រូគង្វាលនឹងមិនអាចរកឃើញក្នុងព្រះគម្ពីរបានឡើយ ប្រសិនបើគាត់ចង់រកនូវសិទ្ធិអំណាចមួយសម្រាប់ការបង្រៀនដែលមិនរាប់ឈ្មោះអំពើបាប និងប្រកាសទាស់នឹងវា ហើយប្រកាសឲ្យមានការប្រែចិត្តចេញពីអំពើបាបទេ។

## លំនាំនៃការញែកជាបរិសុទ្ធ

ប៉ុន្តែ នៅមានអ្វីសំខាន់លើសពីការនោះទៅទៀត ការបង្រៀនទាំងអស់តាមបទគម្ពីរ សុទ្ធតែបានលើកឡើងពីអំពើបាបចំៗ។ ព្រះគម្ពីរសញ្ញាថ្មីបានបង្ហាញពីលក្ខណៈនៃដំណើរការនៃការញែកជាបរិសុទ្ធ—ខ្ញុំសន្មតថា គ្រូគង្វាលទាំងនេះចង់ឲ្យពួកជំនុំរបស់គេបានបរិសុទ្ធ ពេញដោយសេចក្ដីស្រឡាញ់ និងជាម្នាក់ដែលល្អប្រសើរ ព្រមទាំងធ្វើជាអ្នកតំណាងដ៏ប្រសើររបស់អង្គព្រះយេស៊ូវទៀតផង។ របៀបមួយដែលការនេះអាចកើតឡើងបាន គឺ ដោយសារការផ្សំចូលគ្នារវាងការមានជ័យជំនះលើអំពើបាបដោយកិរិយាប្រព្រឹត្តខាងឯព្រះជាម្ចាស់ រួមជាមួយនឹងសេចក្ដីបង្គាប់របស់ព្រះជាម្ចាស់ក្នុងការសម្លាប់អំពើបាប ដោយការពឹងផ្អែកលើកិរិយាប្រព្រឹត្តមកពីព្រះជាម្ចាស់។ នេះហើយជាគំរូ។ វាមិនស្របតាមបទគម្ពីរទេក្នុងការញែកចេញពីគ្នារវាងការមានជ័យជំនះលើអំពើបាប និងសេចក្ដីបង្គាប់របស់ទ្រង់មកកាន់យើងរាល់គ្នាក្នុងការសម្លាប់អំពើបាប។



ឥឡូវនេះ ខ្ញុំនឹងបង្ហាញរបៀប៣យ៉ាង នៃលំនាំការញែកជាបរិសុទ្ធនោះដល់អ្នករាល់គ្នា។ ការនេះលើសពីបញ្ហាមូលដ្ឋានទៅទៀត។ គ្រូគង្វាលទាំងនេះគ្រាន់តែមិនដឹងពីរបៀបដែលព្រះជាម្ចាស់ធ្វើការប៉ុណ្ណោះ នោះហើយជាបញ្ហារបស់ពួកគាត់។ ពួកគាត់ប្រឌិតវាឡើងនៅពេលដែលខ្លួនបង្រៀនជាជាងចុះចូលក្រោមលំនាំនៃការញែកជាបរិសុទ្ធដំណើរការ។ ដូច្នេះ ពួកគាត់ត្រូវកាត់ទម្រទាំងឡាយចេញក្រោមគោលដៅខ្លួន ដើម្បីបង្កើតក្រុមដ៏ប្រសើរមួយឡើង។ ឧទាហរណ៍៖ ឈើឆ្កាង ការកើតជាថ្មី និងការបង្កើតផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ តើឈើឆ្កាងដំណើរការយ៉ាងដូចម្ដេច ក្នុងការសម្អាតអំពើបាបចេញពីជីវិតយើងរាល់គ្នា ហើយធ្វើឲ្យយើងរាល់គ្នាបានបរិសុទ្ធឡើង? តើការកើតជាថ្មីមានដំណើរការយ៉ាងដូចម្ដេចដែរ? ហើយតើផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធមានដំណើរការយ៉ាងដូចម្ដេច?

## សេចក្ដីបង្គាប់មកពីឈើឆ្កាង

សាវ័ក ពេត្រុស បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ១ពេត្រុស ២:២៤ «ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាប»។

ដូច្នេះ ព្រះគ្រីស្ទបានសុគតមិនគ្រាន់តែដើម្បីអត់ទោសចំពោះអំពើបាបប៉ុណ្ណោះទេ តែក៏ដើម្បីឲ្យអំពើបាបស្លាប់ក្នុងជីវិតរាស្ត្ររបស់ទ្រង់ផងដែរ។ ប៉ុន្តែ សិរីរុងរឿងនៃជ័យជម្នះរបស់ព្រះយេស៊ូវលើអំណាចនៃអំពើបាបនៅលើឈើឆ្កាងត្រូវបានប្រទានមកជាមូលដ្ឋាននៅក្នុងកណ្ឌគម្ពីរ ១ពេត្រុស ជំពូកទី២—ដោយផ្អែកទៅលើ—ខគម្ពីរ ២២-២៣៖ កុំជេរតបវិញ នៅពេលយើងត្រូវបានគេជេរប្រមាថ។ កុំគំហកកំហែងដល់គេ នៅពេលយើងរងទុក្ខ។ យើងអាចនិយាយម្យ៉ាងទៀតថា សាវ័ក ពេត្រុស មិនបានសន្មតថាវាជារបៀប

ដែលឈើឆ្កាងសម្លាប់អំពើបាបទេ—អំពើបាបនៃការជេរប្រមាថ និងគំហកកំហែង—ដោយស្វ័យប្រវត្តិឡើយ។ ផ្ទុយទៅវិញ គាត់បានរាប់ឈ្មោះអំពើបាប ហើយហៅឲ្យមានការស្តាប់បង្គាប់ដោយផ្អែកទៅលើឈើឆ្កាង និងអំណាចនៃឈើឆ្កាង។

ព្រះគ្រីស្ទបានយកឈ្នះលើការសងសឹកនៅលើឈើឆ្កាងសម្រាប់រាស្ត្ររបស់ទ្រង់។ បន្ទាប់មក ទ្រង់បានបង្គាប់មកពួកយើងរាល់គ្នា ដោយផ្អែកទៅលើជ័យជម្នះរបស់ទ្រង់ មិនមែនដើម្បីជេរប្រមាថដល់អស់អ្នកណាដែលបានជេរប្រមាថយើង មិនមែនគម្រាមកំហែងដល់អស់អ្នកដែលធ្វើឲ្យយើងឈឺចាប់ មិនបានសងចំពោះការអាក្រក់ដោយការអាក្រក់នោះដែរ។ នេះហើយជារបៀបដែលព្រះអង្គបានបង្កើតយើងជាថ្មី៖ ជាដំណើរនៃការបំផ្លាញអំពើបាបតាមនិស្ស័យជាព្រះរបស់ព្រះគ្រីស្ទ និងការរាប់ឈ្មោះអំពើបាបតាមនិស្ស័យជាព្រះរបស់ទ្រង់ និងព្រះបន្ទូលប្រកាសទាស់នឹងអំពើបាបរបស់ព្រះគ្រីស្ទ។ នេះហើយគឺជាលំនាំ៖ ជ័យជម្នះរបស់ព្រះគ្រីស្ទ និងការបង្គាប់ឲ្យសម្លាប់អំពើបាបរបស់ទ្រង់ជាកិច្ចការរបស់ព្រះជាម្ចាស់ និងជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីលើកឈ្មោះនៃអំពើបាបឲ្យចំៗ និងការសម្លាប់វាចេញ។

**កើតជាថ្មី ដើម្បីតយុទ្ធនឹងអំពើបាប**

នេះគឺជាការបង្ហាញមួយទៀត៖ ការកើតជាថ្មី។ សាវ័ក ពេត្រុស បានលើកឡើងនៅក្នុង ១ពេត្រុស ១:២៣ ដល់គ្រីស្ទបរិស័ទទាំងឡាយ «ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅជាប់លាប់»។

នៅត្រង់នេះ៖ វាពិតជាមានភាពម៉ឺងម៉ាត់ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងយើងរាល់គ្នា ដើម្បីធ្វើឲ្យយើងក្លាយជាមនុស្សថ្មី ដើម្បីធ្វើឲ្យយើងក្លាយជាប្រភេទមនុស្សដែលស្អប់អំពើបាប និងស្រឡាញ់សេចក្តីសុចរិត។ នេះជា



លទ្ធផលនៃការកើតជាថ្មី៖ ស្អប់សេចក្តីងងឹត ស្រឡាញ់ពន្លឺ បែរចេញពីអារក្សសាតាំង ឱបក្រសោបព្រះគ្រីស្ទ។ ព្រះវិញ្ញាណបានសម្រេចការទាំងនោះនៅក្នុងការកើតជាថ្មីរបស់យើង។ ប៉ុន្តែ នៅ៣ខគម្ពីរបន្ទាប់ គាត់បានលើកឡើងថា «ដូច្នេះ»—អាចនិយាយបានម្យ៉ាងទៀតថា ដោយផ្អែកទៅលើការកើតជាថ្មីនេះ ពីព្រោះការអស្ចារ្យនេះបានកើតឡើងក្នុងជីវិតរបស់លោកអ្នក—«ដែលអ្នករាល់គ្នាបានលះបង់ចោលអស់ទាំងសេចក្តីគំរក់ និងកិច្ចកលទាំងប៉ុន្មាន ព្រមទាំងពុតមាយា ចិត្តច្រណែន ហើយពាក្យនិយាយដើមគេទាំងអស់ចេញ» (សូមអាននៅក្នុងកណ្ឌគម្ពីរ ១ពេត្រុស ២:១)។

ឥឡូវនេះ លោកអ្នកអាចនឹងសួរ ប្រហែលជាគ្រូគង្វាលទាំងនេះក៏សួរដែរថា «ហេតុអ្វី? ប្រសិនបើយើងបានកើតជាថ្មី ហើយយើងមានហ្សែន (DNA) របស់ព្រះក្នុងខ្លួនរបស់យើង ដើម្បីឲ្យយើងបានបរិសុទ្ធ មានទំនោរនាំយើងចេញឆ្ងាយពីអំពើបាប ឲ្យស្រឡាញ់ព្រះជាម្ចាស់ ហេតុអ្វីសាវ័ក ពេត្រុស ក្រុមសាវ័កបានជំរុញចិត្តដោយព្រះដ៏ខ្ពស់បំផុត ត្រូវអំពល់នឹងលើកឈ្មោះអំពើបាបទាំងនោះមកនិយាយចំៗ ហើយប្រាប់ឲ្យយើងគេចចេញពីវាធ្វើអ្វី? ហើយចម្លើយគឺ៖ ព្រោះនោះគឺជារបៀបដែលព្រះជាម្ចាស់បានរចនាឡើងជាដំណើរការញែកជាបរិសុទ្ធ «ព្រះគ្រីស្ទបានយកឈ្នះអំពើបាបដោយការកើតជាថ្មី បន្ទាប់មកទ្រង់បានបង្គាប់ឲ្យយើងសម្លាប់នូវអ្វីដែលទ្រង់បានយកជ័យជម្នះនោះ។ សាវ័ក ពេត្រុស មិនបានសរសេរថា «ព្រះគ្រីស្ទបានយកឈ្នះវាហើយ ដូច្នេះ ខ្ញុំមិនចាំបាច់ត្រូវលើកឈ្មោះវាមកនិយាយចំៗទៀតនោះទេ ខ្ញុំមិនចាំបាច់ត្រូវបង្គាប់រាស្ត្ររបស់ព្រះឲ្យធ្វើសង្គ្រាមទាស់ប្រឆាំងនឹងអំពើបាបរបស់ពួកគេទៀតទេ»។ ទេ! នេះមិនមែនជារបៀបរបស់ព្រះជាម្ចាស់ទេ។ គ្រូគង្វាលទាំងនេះកំពុងប្រឌិតវាឡើងនៅពេលគេកំពុងតែបង្រៀនតែម្តង។ ពួកគេមិនបានចុះចូលទៅនឹងរបៀបរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរនោះឡើយ។

## ផលផ្លែនៃព្រះវិញ្ញាណ កិច្ចការខាងឯសាច់ឈាម

ការបង្ហាញមួយទៀត—ពោលគឺៈ ផលផ្លែនៃព្រះវិញ្ញាណ។ ខ្ញុំនៅចាំថា កាលនៅរៀនសាលាព្រះគម្ពីរ ខ្ញុំបានអង្គុយនៅក្នុងអាហារដ្ឋានមួយ កំពុងតែប្រទាញប្រទង់ជាមួយបញ្ហាត្រង់ព្រះបន្ទូល និងផលផ្លែនៃព្រះវិញ្ញាណជាប់ទាក់ទងគ្នាដោយរបៀបណា។ កណ្ឌគម្ពីរ កាឡាទី ៥:២២-២៣ សាវ័ក ប៉ុល បានលើកឡើងថា «ផលផ្លែនៃព្រះវិញ្ញាណគឺជាសេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់...» ហើយទាំងអស់ដែលនៅសល់ សរុបទាំងអស់ប្រាំបួនចំណុច។ «ហើយអស់អ្នកដែលជារបស់ផងព្រះគ្រីស្ទ» គាត់បានពោលថា «នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្ដីរំជួល និងសេចក្ដីប៉ងប្រាថ្នាទាំងប៉ុន្មានផង» (កាឡាទី ៥:២៤)។

ព្រះវិញ្ញាណនឹងបង្កើតផលផ្លែនៅក្នុងជីវិតរបស់លោកអ្នក។ ដូច្នេះ លោកអ្នកបានស្លាប់ជាមួយព្រះគ្រីស្ទ ហើយព្រះវិញ្ញាណនៅមានជីវិត ព្រមទាំងបង្កើតផលផ្លែក្នុងជីវិតរបស់លោកអ្នក។ «អូហ៍! ពិតជាអស្ចារ្យ និងវិជ្ជមានណាស់ នៅក្នុងការមើលឃើញជីវិតរបស់គ្រីស្ទបរិស័ទ។ សូមអធិប្បាយតែត្រឹមហ្នឹងចុះ»។ លោកអ្នកអាចនឹងមិនបង្រៀនតាមព្រះគម្ពីរទាំងស្រុង ប្រសិនបើលោកអ្នកចង់ ហើយប្រឌិតវាឡើងនៅពេលលោកអ្នកបង្រៀន និងដកស្រង់ឯកសារយោងដែលព្រះគម្ពីរមិនបានគូសបញ្ជាក់—ប៉ុន្តែ នោះមិនមែនជារបៀបដ៏ល្អក្នុងការធ្វើព័ន្ធកិច្ចនោះទេ។ ដូច្នេះ យើងប្រហែលជាគិតថា «នេះហើយជាអ្វីដែលយើងត្រូវការ។ យើងមានព្រះវិញ្ញាណបរិសុទ្ធ យើងមានឈើឆ្កាង យើងបានកើតជាថ្មី—ចូរមានសេចក្ដីស្រឡាញ់ សេចក្ដីអំណរ សេចក្ដីសុខសាន្តចុះ»។

សាវ័ក ប៉ុល បានលើកឡើងនៅក្នុងខគម្ពីរបន្ទាប់ គាត់បានលើកឈ្មោះកិច្ចការខាងឯសាច់ឈាមចំនួន ១៥ មកនិយាយចំៗដែលមានដូចខាងក្រោមៈ



«ឥឡូវនេះ រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្ដីកំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ថ្វាយបង្គំរូបព្រះ មន្តអាគម សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ច្រណែន កាប់សម្លាប់ ប្រមឹក ស៊ីផឹកជ្រុល និងការផ្សេងដែលស្រដៀងនឹងសេចក្ដីទាំងនេះផង» (កាឡាទី ៥:១៩-២១)។

ហើយបន្ទាប់មក គាត់បានរាប់បន្ថែមទៀតដើម្បីជាប្រយោជន៍គ្រីស្ទបរិស័ទឲ្យស្ដាប់—នៅត្រង់នេះគឺជាអ្វីដែលគ្រូគង្វាលទាំងនេះមិនបានធ្វើ។ សាវ័ក ប៉ុល បានយល់ថា ការនេះមានសារៈសំខាន់ណាស់។ គាត់បានលើកឡើងថា «ហើយខ្ញុំប្រាប់អ្នករាល់គ្នា [គ្រីស្ទបរិស័ទនៅទីក្រុងកាឡាទី] ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរដកឡើយ» (កាឡាទី ៥:២១)។

ដូច្នេះ ខ្ញុំសូមសួរម្តងទៀត ហេតុអ្វីបានជាត្រូវលើកឈ្មោះកិច្ចការខាងឯសាច់ឈាមទាំងនោះមកនិយាយឲ្យចំៗ និងបង្គាប់កុំឲ្យយើងធ្វើវា ប្រសិនបើផលផ្លែនៃព្រះវិញ្ញាណធំមហិមាដល់ម្ល៉េះក្នុងការធ្វើការនៅក្នុងជីវិតយើង? ហេតុអ្វី? នោះគឺជាអ្វីដែលខ្ញុំបានប្រទាញប្រទង់កាលខ្ញុំជាសិស្សនៅសាលាព្រះគម្ពីរមកម្ល៉េះ។ ចម្លើយគឺថា នេះគឺជារបៀបដែលព្រះជាម្ចាស់បានរចនាវាជាស្រេច ដើម្បីឲ្យដំណើរការទៅមុខ។ សូមកុំព្យាយាមធ្វើខ្លួនឯងឲ្យឆ្លាតជាងព្រះជាម្ចាស់។ ព្រះជាម្ចាស់មានជ័យជម្នះលើអំពើបាបរបស់យើងដោយព្រះវិញ្ញាណ និងបង្គាប់ឲ្យយើងសម្លាប់អំពើបាបទាំងនោះតាមរយៈជំនួយពីព្រះវិញ្ញាណ។ នោះហើយគឺជាលំនាំក្នុងព្រះគម្ពីរ។

ដូច្នេះសរុបមកវិញ ក្រុមជំនុំដែលបរាជ័យនៅក្នុងការលើកយកឈ្មោះអំពីបាបមកនិយាយចំៗ—ប្រកាសទាស់នឹងវា ប្រកាសឲ្យមានការប្រែចិត្ត—ដាក់ប្រាជ្ញាមនុស្សលើប្រាជ្ញាព្រះ ដោយមិនអើពើនឹងរបៀបដែលពួកហោរា ព្រះយេស៊ូវ និងពួកសាវ័កបានបង្រៀន ហើយដោយបរាជ័យនៅក្នុងកាន់

ខ្ជាប់ពីរបៀបដែលការញែកជាបរិសុទ្ធនៅក្នុងព្រះគម្ពីរពិតជាដំណើរការ៖ ពីរបៀបដែលឈើឆ្កាង ការកើតជាថ្មី ផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធយកឈ្នះលើអំពើបាប តាមរយៈសេចក្តីបង្គាប់របស់ព្រះជាម្ចាស់សម្រាប់យើងរាល់គ្នាក្នុងការសម្លាប់អំពើបាប។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
My Pastors Don't Preach Against Sin-Is That OK ?
**គ្រូគង្វាលរបស់ខ្ញុំមិនអធិប្បាយទាស់ប្រឆាំងនឹងអំពើបាបសោះ តើការនោះមិនអីទេ ?**
https://www.desiringgod.org/interviews/my-pastors-dont-preach-against-sin-is-that-okay



## សំណួរទី៣០៖
## ខគម្ពីរដ៏សំខាន់បំផុតក្នុងព្រះគម្ពីរ

«ជម្រាបសួរលោកគ្រូ! ខ្ញុំធ្លាប់ឮលោកគ្រូលើកឡើងថា កណ្ឌគម្ពីរ រ៉ូម ៣:២៥ គឺជាខគម្ពីរដ៏សំខាន់បំផុតនៅក្នុងព្រះគម្ពីរ។ ហេតុអ្វីបានជាលោកគ្រូគិតដូច្នេះ?»

ជាដំបូង ខ្ញុំចង់បញ្ជាក់ថា គ្រប់ខគម្ពីរទាំងអស់សុទ្ធតែសំខាន់។ ខ្ញុំលើកឡើងថា កណ្ឌគម្ពីរ រ៉ូម ៣:២៥ ជាខគម្ពីរដែលសំខាន់ជាងគេបំផុត ក្នុងករណីដែលថា ប្រសិនបើមានគេយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ ហើយសួរថា តើខមួយណាសំខាន់ជាងគេ នោះខ្ញុំនឹងយកខនេះជាមិនខាន។ កណ្ឌគម្ពីរ រ៉ូម ៣:២៥ មានចែងថា «ដែលព្រះបានតាំងទ្រង់ [ព្រះយេស៊ូវគ្រីស្ទ] ទុកជាទីសន្តោសប្រោស ដោយសារសេចក្តីជំនឿដល់ព្រះលោហិតទ្រង់ សម្រាប់នឹងសម្តែងឲ្យឃើញសេចក្តីសុចរិតរបស់ព្រះ ចំពោះការដែលទ្រង់មិនប្រកាន់អំពើបាប ដែលគេប្រព្រឹត្តពីដើម ដោយទ្រង់មានព្រះហឫទ័យអត់ធ្មត់»។

### បញ្ហាដ៏ធំពីរ និងដំណោះស្រាយដ៏ល្អឥតខ្ចោះពីរ

ខ្ញុំគិតថា ខគម្ពីរនេះគឺជាខគម្ពីរដ៏សំខាន់ជាងគេបំផុតនៅក្នុងព្រះគម្ពីរ។ ហេតុអ្វីបានជាខ្ញុំលើកឡើងដូច្នេះ? មូលហេតុគឺដោយសារខគម្ពីរនេះបានលើកឡើងនូវដំណោះស្រាយដ៏អស្ចារ្យពីរយ៉ាង ទាក់ទងទៅនឹងបញ្ហាដ៏អាក្រក់បំផុតពីរយ៉ាងនៃមនុស្សលោកយើងក្នុងចក្រវាលនេះ។ ប្រសិនបើលោកអ្នកសួរមតិយោបល់គេថា «តើអ្វីទៅជាបញ្ហាដ៏ធំបំផុតសម្រាប់មនុស្សយើង?» នោះនឹងមានមនុស្សតិចនាក់ណាស់ដែលនឹងឆ្លើយថា «សេចក្តីក្រោធរបស់ព្រះជាម្ចាស់»។ ប៉ុន្តែ នោះគឺជាបញ្ហាដ៏ធំមែន។ សេចក្តីក្រោធរបស់ព្រះជាម្ចាស់គឺជាបញ្ហាដ៏ធំបំផុត។ ហើយខគម្ពីរនេះប្រាប់យើងអំពីរបៀប

ដែលព្រះជាម្ចាស់ដោះស្រាយបញ្ហានោះ។

នៅក្នុងខគម្ពីរនេះ យើងឃើញថាមាន «ព្រះ» [ជាម្ចាស់] និង «ទ្រង់» ដែលនេះសំដៅទៅលើព្រះយេស៊ូវគ្រីស្ទ។ ព្រះជាម្ចាស់ «បានតាំង»—ដែលនេះសំដៅទៅលើការយាងមកយកកំណើតជាមនុស្ស។ យើងឃើញថាមាន «ព្រះលោហិត»—ដែលនេះសំដៅទៅលើការប្រោសលោះ។ យើងឃើញថាមាន «សន្ដោសប្រោស»—ដែលនេះសំដៅទៅលើចំណុចស្នូលនៃអ្វីដែលកើតឡើងក្នុងការប្រោសលោះ ខណៈពេលដែលព្រះជាម្ចាស់ដកសេចក្ដីក្រោធរបស់ទ្រង់ចេញ ហើយព្រះយេស៊ូវទទួលយកសេចក្ដីក្រោធនោះ។ យើងឃើញថាមាន «ដោយសារសេចក្ដីជំនឿ» ដែលនេះគឺជាដំណឹងដ៏ល្អបំផុតនៅលើផែនដីនេះ ពីព្រោះមិនសំដៅលើទង្វើដែលយើងប្រព្រឹត្តទេ។ យើងឃើញថាមាន «សម្រាប់នឹងសម្ដែងឲ្យឃើញសេចក្ដីសុចរិតរបស់ព្រះ» ដែលនេះមានន័យថា ការទាមទារដ៏យុត្តិធម៌របស់ទ្រង់ ទាក់ទងទៅនឹងសេចក្ដីក្រោធ គឺព្រះអង្គបានដោះស្រាយហើយ។ ហើយយើងក៏មាន «ដោយសារ...ទ្រង់មិនប្រកាន់អំពើបាប ដែលគេប្រព្រឹត្តពីដើម» ដែលនេះមានន័យថា ចំណុចចម្ងល់ចុងក្រោយគឺថា ព្រះអង្គនឹងមិនរាប់អំពើបាបរបស់យើងទាស់នឹងយើងទៀតទេ។ តាមដែលខ្ញុំស្គាល់ ខ្ញុំមិនដឹងថាមានខគម្ពីរណាផ្សេងទៀត ក្រៅពីខគម្ពីរមួយនេះ ដែលមានចំណុចដ៏អស្ចារ្យជាច្រើនៗ នៅក្នុងតែមួយខដែលបង្ហាញអំពីដំណោះស្រាយដ៏អាក្រក់បំផុតនៃបញ្ហាពីរយ៉ាងរបស់យើងទេ។

## បញ្ហាដ៏ធំបំផុតរបស់យើង

បញ្ហាដ៏ធំបំផុតរបស់យើងនៅក្នុងចក្រវាលគឺសេចក្ដីក្រោធរបស់ព្រះជាម្ចាស់លើមនុស្សលោកទាំងអស់ ក្នុងការអនុញ្ញាតឲ្យមនុស្សយើងជាប់ក្នុងបណ្ដាសាអស់កល្បជានិច្ច (សូមអានបន្ថែមនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន



៣:៣៦)។ ប្រសិនបើយើងមិនទទួលជឿលើព្រះយេស៊ូវ នោះយើងនឹងស្ថិតក្នុងស្ថានភាពបែបនោះ—ដែលនេះគឺអស់កល្បជានិច្ច—ក្រោមសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។ សូមពិចារណាលើ កណ្ឌគម្ពីរ រ៉ូម ៣:៥ ដែលរៀបរាប់អំពីសេចក្ដីខ្ញាល់ និងភាពឃោរឃៅ ដែលជាមូលហេតុនាំឲ្យព្រះអង្គមានសេចក្ដីក្រោធ៖ ព្រះជាម្ចាស់មានភាពយុត្តិធម៌ក្នុងការចាក់សេចក្ដីក្រោធរបស់ទ្រង់លើយើង។ ដូច្នេះ ទាំងនោះគឺជាចំណុចទាំងពីរ៖ សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ ហើយថាសេចក្ដីសុចរិតរបស់ទ្រង់តម្រូវឲ្យមានសេចក្ដីក្រោធ។ នេះមិនមែនគ្រាន់តែមានន័យថា ព្រះជាម្ចាស់កំពុងតែខ្ញាល់នោះទេ។ ទំនងអ្នកខ្លះគិតថា ព្រះអង្គជាអ្នកគ្រប់គ្រងដ៏ឃោរឃៅ។ ប៉ុន្តែ នោះគឺជាការគិតខុសហើយ ព្រះអង្គមិនដូច្នោះទេ។ ព្រះអង្គមានពេញទៅដោយភាពយុត្តិធម៌ និងសេចក្ដីសុចរិតក្នុងសេចក្ដីក្រោធដែលទ្រង់មានទាស់នឹងយើង។ ដូច្នេះ ចំណុចទាំងពីរនេះមាននៅក្នុងខគម្ពីរនេះ ក្រោយពាក្យ [សេចក្ដី] សន្ដោសប្រោស។

## ដំណោះស្រាយដ៏អស្ចារ្យ

### ១. ព្រះយេស៊ូវគ្រីស្ទបានខ្ចាយព្រះលោហិតរបស់ទ្រង់ ដើម្បីទទួលយកសេចក្ដីក្រោធដ៏សុចរិតរបស់ព្រះជាម្ចាស់

ដំណោះស្រាយដំបូងគឺថា ព្រះគ្រីស្ទបានខ្ចាយព្រះលោហិតរបស់ទ្រង់ ហើយតាមរយៈការខ្ចាយព្រះលោហិតរបស់ទ្រង់ នោះព្រះអង្គបានបំពេញសេចក្ដីសន្ដោសប្រោសនៃសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។ លោកអ្នកគ្រាន់តែត្រូវការគិតអំពីចំណុចនេះ៖ ព្រះអង្គហៀបនឹងចាក់សេចក្ដីក្រោធដែលពេញទៅដោយភាពឃោរឃៅនៃសព្វានុភាពរបស់ព្រះជាម្ចាស់ ភ្លាមនោះស្រាប់តែព្រះយេស៊ូវឈរវាងយើង និងសេចក្ដីក្រោធនោះ ហើយព្រះអង្គក៏បានទទួលយកជំនួសយើងផ្ទាល់ គឺថាព្រះអង្គបានសុគតជំនួសយើង ហើយយើងមិន

ស្ថិតក្រោមសេចក្ដីក្រោធនោះទៀតឡើយ។ យើងទទួលបានការរំដោះទាំងស្រុង។ ដូច្នេះ ខគម្ពីរមួយនេះដោះស្រាយបញ្ហាដ៏ធំបំផុតក្នុងចក្រវាលនេះ។

**២. ព្រះជាម្ចាស់នៅតែជាព្រះដែលសុចរិត ខណៈពេលដែលព្រះអង្គកំពុងតែចាក់សេចក្ដីក្រោធដ៏យុត្តិធម៌របស់ទ្រង់លើព្រះរាជបុត្រារបស់ព្រះអង្គ**

ដំណោះស្រាយបន្ទាប់គឺថា ព្រះជាម្ចាស់នៅតែជាព្រះដែលសុចរិតក្នុងការចាក់សេចក្ដីក្រោធរបស់ទ្រង់ ដូច្នេះតើព្រះអង្គនៅធ្វើដូច្នោះបានដោយរបៀបណា? ចម្លើយគឺថា៖ ព្រះអង្គមិនលាក់ ឬក៏មើលរំលងអំពើបាបទេ។ ព្រះអង្គបានដោះស្រាយបញ្ហានោះក្នុងព្រះរាជបុត្រារបស់ទ្រង់ ហេតុដូច្នេះហើយបានជាព្រះយេស៊ូវបង្ហាញភាពត្រឹមត្រូវនៃសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់។ ព្រះអង្គមិនគ្រាន់តែដកចេញសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ទេ—តែព្រះអង្គបានបង្ហាញពីភាពគ្មានទោសនៃសេចក្ដីក្រោធរបស់ព្រះជាម្ចាស់វិញ។ តាមដែលខ្ញុំដឹង ខ្ញុំមិនស្គាល់ខគម្ពីរណាផ្សេងដែលនិយាយយ៉ាងច្បាស់លាស់ដូចខគម្ពីរមួយនេះនោះទេ។ ហើយនោះគឺជាឧបសគ្គពីរដ៏ធំបំផុតដែលត្រូវមានដំណោះស្រាយ។

ហើយបន្ទាប់មក ខគម្ពីរនេះក៏បានលើកឡើងក្នុងរបៀបដ៏អស្ចារ្យថា យើងទទួលបាន «ដោយសារសេចក្ដីជំនឿ»។ ដែលនេះមានន័យថា ខ្ញុំមិនចាំបាច់ប្រព្រឹត្តទង្វើអ្វីមួយ ដើម្បីឲ្យទទួលបាននោះទេ។ ខ្ញុំមិនចាំបាច់ធ្វើអ្វីទាល់តែសោះ។ ខ្ញុំមើលព្រះជាម្ចាស់ធ្វើការសង្គ្រោះដោយរូបអង្គទ្រង់ផ្ទាល់ ដោយសារព្រះអង្គស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏គ្រាន់តែបានទទួលយក។ ហើយការធ្វើបែបនោះក៏ថ្វាយព្រះកិត្តិយសដល់ព្រះដែលរក្សាសេចក្ដីតាំងសញ្ញារបស់ទ្រង់ផងដែរ។

យើងអាចនៅបន្តបកស្រាយបន្ថែមទៀតបាននៅលើខគម្ពីរមួយនេះ ប៉ុន្តែទាំងនេះគឺជាចំណុចសំខាន់គោលៗដែលខ្ញុំបានលើកឡើង ដើម្បីបញ្ជាក់



ថា នេះគឺជាខគម្ពីរដ៏សំខាន់បំផុតចំពោះខ្ញុំ។ បញ្ហាដ៏ធំបំផុតពីរយ៉ាងនៅក្នុងចក្រវាលនេះទទួលបានការដោះស្រាយដ៏ធំពីរយ៉ាង។ ហើយបន្ទាប់មកព្រះអង្គបានប្រទានមកកាន់យើងដោយឥតគិតថ្លៃតាមរយៈសេចក្ដីជំនឿ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
The Bible’s Most Important Verse
**ខគម្ពីរដ៏សំខាន់បំផុតក្នុងព្រះគម្ពីរ**
https://www.desiringgod.org/interviews/the-bibles-most-important-verse

## សំណួរទី៣១៖
# តើអ្វីទៅជាការថ្វាយបង្គំរូបព្រះ?

*យើងទទួលបានសំណួរពីប្រិយមិត្តម្នាក់សុំមិនបញ្ចេញឈ្មោះទាក់ទងនឹងការថ្វាយបង្គំរូបព្រះ។ វាជាសំណួរដ៏ល្អមួយ។*

*«ជម្រាបសួរលោកគ្រូ! តើរូបព្រះជាអ្វីឲ្យប្រាកដ? គ្រីស្ទបរិស័ទតែងតែប្រើប្រាស់ពាក្យនេះគ្រប់ពេលវេលា ជាពិសេសនៅក្នុងការអធិប្បាយ។ ដូច្នេះខ្ញុំបើកព្រះគម្ពីររបស់ខ្ញុំ។ នោះខ្ញុំឃើញថារូបព្រះទាំងឡាយ គឺជារូបចម្លាក់ ឬរូបនានា អស់អ្នកដែលឱនក្រាបថ្វាយបង្គំរូបព្រះធ្វើពី «មាស ប្រាក់ លង្ហិន ដែក ឈើ និងថ្ម» (ដានីយ៉ែល ៥:៤)។ ពេលខ្លះរូបព្រះ វាហាក់បីដូចជាវត្ថុស័ក្ដិសិទ្ធិ ជារបស់ដែលបណ្ដេញរឿងអាក្រក់ៗ—ជាគ្រឿងកំប៉ិកកំប៉ុកដែលមានទម្រង់ដូចជាដុំមាស ឬកណ្ដុរមាសជាដើម។ ខ្ញុំកំពុងតែគិតអំពីកណ្ឌគម្ពីរ ១សាំយូអែល ៥:៦-៧:២។ ប៉ុន្តែ រូបព្រះនៅថ្ងៃនេះគឺពិតជាខុសប្លែកគ្នាខ្លាំងណាស់។ រូបព្រះទាំងនោះហាក់បីដូចជាសេចក្ដីប៉ងប្រាថ្នារបស់ចិត្តដែលចង់បានលុយកាក់ ការរួមដំណេក អំណាច និងរបស់ផ្សេងៗទៀតដែលមានលក្ខណៈបែបនេះ។ តើវាអាចក្លាយទៅជាអញ្ចឹងបានដោយរបៀបណា? រូបព្រះធ្លាប់តែជារបស់ដែលមនុស្សឆ្លាក់ តែឥឡូវពួកវាប្រែទៅជាចិត្តដែលឈ្លក់វង្វេងទៅវិញ។ ខ្ញុំមិនយល់ពីការជាប់ទាក់ទងគ្នារវាងរូបចម្លាក់និងរូបព្រះនានានៅក្នុងចិត្តទាល់តែសោះ។ តាមពិតទៅ នៅពេលខ្ញុំមើលនៅក្នុងព្រះគម្ពីរសញ្ញាចាស់រូបព្រះមានលក្ខណៈជាដុំៗ និងជាសត្វកណ្ដុរទាំងឡាយ ខ្ញុំពិតជាមិនយល់អំពីអំពើការទាំងនោះដែរ។ តើលោកគ្រូអាចពន្យល់អំពីរូបព្រះទាំងពីរទម្រង់នោះបានទេ ហើយថាតើពួកវាមានជាប់ទាក់គ្នាយ៉ាងដូចម្ដេច?»។*

បាទ អញ្ចឹងខ្ញុំនឹងព្យាយាមឆ្លើយ។ ខ្ញុំសូមចាប់ផ្តើមពីនិយមន័យជាមុនសិន។ ខ្ញុំគិតថានឹងធ្វើការពន្យល់គ្រប់ករណីទាំងអស់ យើងប្រហែលជាគួរតែឲ្យនិយមន័យពាក្យ «រូបព្រះ» (នេះជាការឲ្យនិយមន័យទៅតាមព្រះគម្ពីរ) ជាអ្វីក៏ដោយដែលយើងពឹងផ្អែកទៅលើ ដើម្បីទទួលបានព្រះពរ ឬជំនួយ ការណែនាំផ្សេងៗនៅចំណុចមួយដែលចិត្តពឹងផ្អែកទាំងស្រុងទៅលើព្រះពិតដ៏មានព្រះជន្មរស់។ នោះគឺជានិយមន័យដែលខ្ញុំធ្វើការកំណត់ទៅលើពាក្យថា «រូបព្រះ»។ ដើម្បីឲ្យយើងបានឃើញនូវអ្វីដែលនឹងត្រូវលើកឡើង ឧទាហរណ៍៖ ជាជើងទន្សាយមួយនៅក្នុងហោប៉ៅលោកអ្នក ជារូបថតសាវ័កម្នាក់ព្យួរនៅលើជញ្ជាំងលោកអ្នក ជាវត្ថុបុរាណបានមកពីកន្លែងទីសក្ការៈបូជាយកមកដាក់ក្នុងអាវធំរបស់លោកអ្នក រូបភាពបញ្ឈរជាច្រើនទៀតដែលបានយកមកពីវិហារសាសនាហិណ្ឌូ វិហារព្រះពុទ្ធសាសនា ឬគោមាសដែលលោក អើរ៉ុន បានធ្វើ ខណៈដែលលោក ម៉ូសេ នៅលើភ្នំ។

អ្វីដែលធ្វើឲ្យរូបព្រះទាំងអស់នោះនាំយើងងាកចេញពីចិត្តដែលពឹងផ្អែកលើសេចក្តីពិតទាំងស្រុង និងព្រះដ៏មានព្រះជន្មគង់នៅតាមរយៈព្រះយេស៊ូវគ្រីស្ទ ហើយត្រឡប់បែរទៅមើលជើងទន្សាយ ឬវត្ថុបុរាណ រូបភាពសម្រាប់ការការពារពិសេស ព្រះពរ ការដឹកនាំ និងជំនួយ ដែលយើងមិនគិតថា យើងនឹងអាចទទួលដោយគ្រាន់តែសម្លឹងមើលទៅកាន់ព្រះជាម្ចាស់។

## ការសិក្សាពីធាតុនៃរូបព្រះ

ឥឡូវនេះ មិត្តរបស់យើងដែលផ្ញើសំណួរនេះមកគឺត្រូវហើយ។ ខ្ញុំគិតថា នៅក្នុងព្រះគម្ពីរពាក្យ រូបព្រះ គឺមិនមានសណ្ឋានច្បាស់លាស់នៅក្នុងការប្រើទៅលើរបស់ជាក់លាក់ណាមួយ ដែលបានមកពីធម្មជាតិ ឬជាញើកញាប់ បានធ្វើឡើងដោយដៃមនុស្សនោះទេ។ លោកអ្នករកមិនឃើញពាក្យការថ្វាយបង្គំព្រះក្លែងក្លាយ នៅក្នុងការប្រើសម្រាប់ពណ៌នាទៅលើសេចក្តីស្រឡាញ់ដ៏លើសលុបចំពោះភរិយា ទឹកដី លុយកាក់ ឬកូនសៀវភៅដាក់តាមហោប៉ៅរបស់លោកអ្នកទេ។ ហេតុដូច្នេះហើយ ខ្ញុំគិតថា គាត់ត្រូវណាស់ ដែលនៅក្នុងព្រះគម្ពីរមានការផ្តោតសំខាន់ផ្សេងៗគ្នាទៅលើរបស់ដែលមនុស្សបង្កើត ឬក៏របស់បានមកពីធម្មជាតិ ជាជាងការគ្រាន់តែចង់បានខ្លាំង និងសេចក្តីប៉ងប្រាថ្នាចង់បានសម្រាប់របស់ផ្សេងៗនេះ។

ឥឡូវនេះ នៅពីក្រោយនោះគឺត្រូវជាមួយនឹងបញ្ញត្តិទីពីរ៖

«កុំឲ្យឆ្លាក់ធ្វើរូបណាសម្រាប់ឯងឲ្យសោះ ក៏កុំឲ្យធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង ក៏កុំឲ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាម នោះឡើយ ដ្បិតអញដែលជាយេហូវ៉ា ជាព្រះនៃឯង អញមានសេចក្តីប្រចណ្ឌ» (និក្ខមនំ ២០:៤-៥)។

ម៉្យាងវិញទៀត ព្រះជាម្ចាស់ទ្រង់មានសេចក្តីប្រចណ្ឌយ៉ាងខ្លាំងចំពោះការពឹងផ្អែកដោយផ្ទាល់របស់យើងចំពោះទ្រង់ និងការគោរពចំពោះទ្រង់ ព្រមទាំងការស្រឡាញ់ទ្រង់ ដល់ថ្នាក់ថាទ្រង់មិនអនុញ្ញាត មិនត្រឹមតែជាការប្រកួតប្រជែងជាមួយអ្វីដែលហៅថាព្រះ ដែលតំណាងឲ្យរូបព្រះក្លែងក្លាយប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែជាការបង្កើតរូបព្រះដែលសន្មតថាជាការតំណាងឲ្យទ្រង់—មិនមែនគ្រាន់តែជាព្រះក្លែងក្លាយ ដែលត្រូវបានប្រែក្លាយទៅជារូបចម្លាក់ប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែរូបអង្គទ្រង់ផ្ទាល់ដែលមនុស្សធ្វើឡើងពីវត្ថុអ្វីមួយ ដើម្បីគោរពទៀតផង។ ខ្ញុំគិតថា ប្រសិនបើយើងសួរថាហេតុអ្វី—នោះមានន័យថា ហេតុអ្វីបានជាទ្រង់ប្រចណ្ឌនឹងការពឹងផ្អែកផ្ទាល់ចំពោះការគោរព និងសេចក្តីស្រឡាញ់បែបនេះទៅវិញ?—បន្ទាប់មក យើងរកឃើញនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ៩៦:៥ «ពីព្រោះអស់ទាំងព្រះរបស់សាសន៍ដទៃសុទ្ធតែជារបស់ឥតប្រយោជន៍តែព្រះយេហូវ៉ាវិញ ទ្រង់បានបង្កើតផ្ទៃមេឃ»។

ម៉្យាងវិញទៀត បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនទាក់ទងនឹងរូប

ព្រះ គឺថាពួកវាផ្ទុយអំពីលក្ខណៈដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងនាមជាព្រះអាទិករ។ ការតំណាងណាមួយនៃព្រះដែលធ្វើឡើងដោយដៃមនុស្សនាំទៅរកការយល់ខុសពីវិសាលភាពរបស់ព្រះជាម្ចាស់។ វាធ្វើឲ្យមានការចាប់អារម្មណ៍ ប្រសិនបើមិនមែនជាការអះអាងដោយផ្ទាល់ទេថា ព្រះទ្រង់ស្ថិតនៅក្រោមអំណាចណាមួយរបស់យើង—យើងអាចឆ្លាក់ លាបពណ៌ ដាក់ក្នុងហោប៉ៅរបស់យើង ដាក់ទ្រង់នៅលើធ្នើររបស់យើង ព្រមទាំងសែងទ្រង់ដាក់នៅលើរទេះបានទៀតផង។ ហេតុដូច្នេះហើយបានជាអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងនិយាយថា៖ «ទេ! ព្រះអម្ចាស់បានបង្កើតស្ថានសួគ៌»។ ម្យ៉ាងវិញទៀត ទ្រង់ពិតជាអស្ចារ្យ ហើយលោកអ្នកមិនអាចឆ្លាក់ទ្រង់ ឬគ្រប់គ្រងទ្រង់តាមមធ្យោបាយណាមួយបានឡើយ។

ហេតុផលមួយផ្សេងទៀត ដែលព្រះជាម្ចាស់ស្អប់ខ្ពើមចំពោះអស់ទាំងរូបផ្សេងៗ អស់ទាំងរបស់ត្រូវបានហៅថា រូបព្រះ ឬរបស់តំណាងឲ្យរូបអង្គទ្រង់។ ខ្ញុំគិតថាទាំងអស់នេះត្រូវបានរកឃើញនៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ១១៥:៤-៨៖

ឯព្រះរបស់គេ នោះសុទ្ធតែជារូប ធ្វើពីប្រាក់ និងមាស
ជាស្នាដៃដែលមនុស្សធ្វើ
រូបទាំងនោះមានមាត់ តែមិនចេះនិយាយ
មានភ្នែក តែមើលមិនឃើញ
មានត្រចៀក តែស្តាប់មិនឮ
មានច្រមុះ តែធុំក្លិនមិនបាន
មានដៃ តែចាប់កាន់មិនបាន
មានជើង តែមិនចេះដើរឡើយ
ក៏មិនចេះបញ្ចេញសំឡេងតាមបំពង់កផង
ជាងដែលធ្វើ អើ អស់អ្នកដែលទុកចិត្តនឹងរូបទាំងនោះ



គេនឹងបានដូចជារូបនោះដែរ

សរុបមក រូបព្រះផ្សេងៗមិនត្រឹមតែបង្ហាញពីលក្ខណៈរបស់ព្រះជាម្ចាស់តាមរបៀបមិនត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបំផ្លាញលក្ខណៈធម្មជាតិរបស់មនុស្សផងដែរ។ ពួកវាប្រែក្លាយមនុស្សទៅជារូបសាច់ដែលគ្មានព្រលឹងវិញ្ញាណ និងជាដុំសាច់ដែលគ្មានអំណាច។ យើងអាចនឹងបានដូចជារូបចម្លាក់ទាំងនោះ។ ភាពឥតប្រយោជន៍នៃរូបព្រះទាំងនោះនឹងប្រែមនុស្សត្រឡប់ទៅជាឥតប្រយោជន៍ដែរ។

**ការដូរសិរីរុងរឿងរបស់ព្រះជាម្ចាស់ទៅនឹងរូបភាពផ្សេងៗ**

ដូច្នេះឥឡូវនេះ យើងត្រឡប់មកកាន់សំណួរមិត្តអ្នកសួររបស់យើងវិញ។ មែនហើយ ប្រសិនបើនោះជាអ្វីដែលព្រះគម្ពីរចាត់ទុកថាជារូបព្រះ ហើយគាត់និយាយថា «រូបព្រះសព្វថ្ងៃនេះ» គឺខុសគ្នាឆ្ងាយខ្លាំងណាស់ពីអ្វីដែលបានចែងនៅក្នុងព្រះគម្ពីរ។ ពួកវាទំនងជាបំណងប្រាថ្នានៃដួងចិត្ត ឬប្រាក់កាស ការរួមដំណេក អំណាច និងជារបស់ផ្សេងៗទៀតដែលមានលក្ខណៈបែបនោះ។ តើការនេះកើតឡើងបានដោយរបៀបណា? រូបព្រះធ្លាប់តែជារូបចម្លាក់ មិនមែនគ្រាន់តែជាការឈ្លក់វង្វេងក្នុងចិត្តនោះទេ»។

ខ្ញុំនិយាយថា «នេះជាសំណួរល្អណាស់» ។ តើវាល្អយ៉ាងដូចម្តេចដែរ? នេះជារឿងដំបូងដែលខ្ញុំចង់និយាយ—ពោលគឺថាការផ្លាស់ប្តូរនៃការផ្តោតសំខាន់ក្នុងការកំណត់ការថ្វាយបង្គំរូបព្រះនេះ គឺដោយសារតែការពិតនោះយើងរស់នៅលោកខាងលិចនៅក្នុងវប្បធម៌ដែលការប្រើប្រាស់រូបព្រះទាំងឡាយសម្រាប់ការថ្វាយបង្គំបែបសាសនាគឺ មិនមែនជារឿងធម្មតាដូចនៅក្នុងវប្បធម៌ផ្សេងទៀតមួយចំនួននោះទេ។ ដូច្នេះហើយបានជាមានការលើកជាសំណួរឡើង តើការបង្រៀនស្របតាមព្រះគម្ពីរ អំពីការថ្វាយបង្គំរូបព្រះទាំងនេះ មានការជាប់ពាក់ព័ន្ធអ្វីខ្លះ ទៅនឹងពួកយើងដែលរស់នៅក្នុងវប្បធម៌ដែល

ប្រើប្រាស់រូបចម្លាក់ តាំងពីមុនមក តាមពិតមនុស្សបានក្រាបចុះ ហើយទាំងថ្វាយបង្គំមិនសូវនិយមឬ? តើមានអ្វីពាក់ព័ន្ធដែរឬទេ?

ចម្លើយគឺថា មាន។ ខ្ញុំមិនគិតថា ការប្រើប្រាស់ពាក្យ *ការថ្វាយបង្គំរូបព្រះ* សំដៅទៅលើការស្រឡាញ់លុយកាក់ ការរួមភេទ និងអំណាចថាជាការប្រើប្រាស់ខុសន័យពាក្យ ថ្វាយបង្គំរូបព្រះ នៅពេលដែលនរណាម្នាក់ផ្តោតទៅលើអ្វីដែលកំពុងកើតឡើងជាមួយនឹងរូបព្រះនៅក្នុងព្រះគម្ពីរ។ ចង្អុលបង្ហាញនូវចំណុចពីរយ៉ាងនៅព្រះគម្ពីរសញ្ញាថ្មីក្នុងទិសដៅ ដើម្បីបង្ហាញពីមូលហេតុដែលខ្ញុំគិតថា វាមិនអីទេក្នុងការប្រើប្រាស់ពាក្យ *ថ្វាយបង្គំរូបព្រះ* តាមរបៀបដែលគាត់និយាយថា មនុស្សសម័យទំនើបមានទំនោរក្នុងការប្រើវា។

ជាដំបូងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:២១-២៣ សំដៅទៅដល់មនុស្សដែលមិនមានចំណេះដឹងអំពីដំណឹងល្អ ប៉ុន្តែពួកគេមានការជាប់ទាក់ទងទូទៅទៅនឹងធម្មជាតិ ដើម្បីឲ្យគេអាចស្គាល់ព្រះតាមរបៀបនោះ និងមានទំនួលខុសត្រូវក្នុងការថ្វាយសិរីល្អដល់ព្រះ ព្រមទាំងអរព្រះគុណទ្រង់។ នេះជាអ្វីដែលបានចែងទុក៖

បើទោះបីជាគេស្គាល់ព្រះជាម្ចាស់ ពួកគេមិនបានថ្វាយសិរីល្អដល់ទ្រង់ក្នុងនាមជាព្រះជាម្ចាស់ ឬអរព្រះគុណដល់ទ្រង់ទេ ប៉ុន្តែគំនិតរបស់ពួកគេត្រឡប់ជាឥតប្រយោជន៍ ហើយចិត្តដ៏ល្ងីល្ងើរបស់ពួកគេត្រឡប់ទៅជាខ្មៅងងឹតវិញ។ ការតាំងខ្លួនជាមនុស្សឆ្លាត *ពួកគេត្រឡប់ទៅជាល្ងីល្ងើ ថែមទាំងបំផ្លាស់បំប្រែសិរីរុងរឿងនៃព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅសម្រាប់រូបផ្សេងៗដូចជា មនុស្សដែលតែងតែស្លាប់ បក្សី សត្វ និងរបស់ចម្លែកផ្សេងៗ។*

ពេលនេះ ខ្ញុំគិតថា អត្ថបទនេះចង្អុលទៅខ្លឹមសាររបស់បញ្ហានៅក្រោមការបង្ហាញផ្នែកខាងក្រៅនៃការថ្វាយបង្គំរូបព្រះ។ ពោលគឺយើងប្តូរសិរីល្អរបស់ព្រះជាម្ចាស់ទៅនឹងរូបភាពទាំងនោះ។ រូបភាពប្រភេទទីមួយដែលលោកសាវ័ក ប៉ុល បានលើកឡើង គឺជារូបភាពដែលស្រដៀងនឹងមនុស្ស ហើយខ្ញុំគិតថា វាមិនមែនជាការអូសបន្លាយទេក្នុងការនិយាយថា រូបភាពមនុស្សដែលគម្រាមកំហែងជំនួសកន្លែងព្រះជាម្ចាស់ គឺជារូបភាពដែលយើងឃើញនៅក្នុងកញ្ចក់។ យើងជាអ្នកស្រឡាញ់ការលើកតម្កើងខ្លួនឯង ដែលគម្រាមកំហែងជាបន្តបន្ទាប់ ចំពោះសេចក្តីស្រឡាញ់របស់យើងចំពោះការលើកតម្កើងព្រះជាម្ចាស់។ ខ្ញុំគិតថា វាជាការត្រឹមត្រូវក្នុងការហៅការផ្លាស់ប្តូរនេះថាជាសណ្ឋាននៃការថ្វាយបង្គំរូបព្រះ។

## ចូររក្សាខ្លួនឲ្យផុតពីរូបព្រះទាំងឡាយ

ដូច្នេះ ត្រឡប់ទៅនិយមន័យដ៏ទូលំទូលាយរបស់ខ្ញុំវិញ។ វាកើតឡើងដូច្នេះ៖ អ្វីក៏ដោយដែលយើងពឹងផ្អែក ដើម្បីបានព្រះពរ ជំនួយ ការណែនាំ ជំនួសឲ្យការពឹងផ្អែកទាំងស្រុងទៅលើព្រះដ៏ពិត និងជាព្រះដ៏មានព្រះជន្មរស់។ ប្រសិនបើយើងចង់បានសេចក្តីស្រឡាញ់ ការពឹងពំនាក់ និងការទុកចិត្តក្នុងការទទួលបានពរតាមរយៈការដែលមនុស្សសរសើរយើង ដើម្បីបង្កើនភាពតម្កើងខ្លួនឯងរួមមាន៖ លុយកាក់ អំណាច ការរួមភេទ គ្រួសារ ទិន្នផល ឬក៏អ្វីផ្សេងទៀតក្រៅពីព្រះជាម្ចាស់ ដើម្បីបានព្រះពរដ៏ធំបំផុត ជំនួយ ការណែនាំ និងការស្កប់ចិត្ត បន្ទាប់មកអ្វីដែលសំខាន់នោះ គឺយើងកំពុងតែធ្វើអ្វីដែលជាការថ្វាយបង្គំរូបព្រះហើយ។

ខ្ញុំសូមផ្តល់ខគម្ពីរមួយបន្ថែមសម្រាប់លោកអ្នកពីកណ្ឌគម្ពីរ ១យ៉ូហាន ៥:២១។ វាជាខគម្ពីរចុងក្រោយបំផុតនៃសំបុត្រលោក យ៉ូហាន ដែលបានចែងថា៖ «កូនតូចៗ រាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះចេញ»។ ហេតុអ្វីបានជាសំបុត្ររបស់យ៉ូហានបានបញ្ចប់បែបនេះទៅវិញ? គាត់មិនដែលសូម្បីតែសំដៅលើរូបព្រះនៅក្នុងកណ្ឌគម្ពីរទាំងមូល។ គាត់មិនដែលសំដៅលើរូបព្រះនៅក្នុងកណ្ឌគម្ពីរដំណឹងល្អទាំងមូលរបស់គាត់

ទេ។ ដោយនឹកស្មានមិនដល់ ឃ្លាបញ្ចប់នេះភ្ជាប់ជាមួយនឹងពាក្យថា រូបព្រះ ដែលជាធម្មតាមានន័យថារូបអ្វីមួយដែលយើងប្រើជំនួសព្រះ។ «កុំចុះចាញ់នឹងរូបព្រះ។ ចូររក្សាខ្លួនឲ្យផុតពីរូបព្រះចេញ»។

ដូច្នេះ ហេតុអ្វីបានជាគាត់បញ្ចប់ដោយបែបនេះទៅវិញ? នេះជាការណែនាំចុងក្រោយរបស់ខ្ញុំ។ គាត់បានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ២:១៥-១៦ ថា «កុំឲ្យស្រឡាញ់លោកីយ៍ ឬរបស់អ្វីដែលនៅក្នុងលោកីយ៍នេះឲ្យសោះ បើអ្នកណាស្រឡាញ់លោកីយ៍ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ ដ្បិតអស់ទាំងសេចក្តី ដែលនៅក្នុងលោកីយ៍នេះ—គឺជាសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត—នោះមិនកើតមកពីព្រះវរបិតាទេ គឺមកតែពីលោកីយ៍នេះវិញ»។

ឥឡូវនេះ លោក យ៉ូហាន ប្រហែលជាមានរូបព្រះក្នុងចិត្ត នៅពេលដែលគាត់និយាយថា៖ «ចូររក្សាខ្លួនឲ្យផុតពីរូបព្រះចេញ»។ ប៉ុន្តែ ខ្ញុំគិតថាគាត់ក៏កំពុងគិតអំពីបញ្ហាដ៏ធ្ងន់ធ្ងរមួយចំនួនទៀត ដែលអ្វីៗនៅលើលោកីយ៍នេះ ប្រជែងជាមួយនឹងសេចក្តីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់នោះគឺជារូបព្រះ។ ដូច្នេះ ចូរអ្នករាល់គ្នាគេចចេញពីរូបព្រះ—ពោលគឺស្រឡាញ់ព្រះជាម្ចាស់ និងអ្វីៗទាំងអស់ដែលទ្រង់មានសម្រាប់យើងក្នុងព្រះគ្រីស្ទ ឲ្យលើសជាងស្រឡាញ់អ្វីៗផ្សេងទៀត។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
What is An Idol?
**តើអ្វីទៅជាការថ្វាយបង្គំរូបព្រះ?**
https://www.desiringgod.org/interviews/what-is-an-idol



## សំណួរទី៣២៖
# នៅពេលគ្រីស្ទបរិស័ទមិនព្រមប្រែចិត្តចេញពីអំពើបាបខាងផ្លូវភេទ

មានប្អូនស្រីម្នាក់ឈ្មោះ ធីតា បានសរសេរអ៊ីមែលមកកាន់ក្រុមការងារផ្លូវពិត ដើម្បីសួរសំណួរមួយអំពីការដាក់វិន័យក្នុងក្រុមជំនុំ។ ប្អូនស្រីបានសួរ «ជាប់ទាក់ទងនឹងកណ្ឌគម្ពីរ ម៉ាថាយ ១៨:១៥-២០ នាងខ្ញុំឆ្ងល់ថា ក្នុងនាមខ្ញុំជាគ្រីស្ទបរិស័ទ នាងខ្ញុំត្រូវមានទំនួលខុសត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យស្របទៅតាមព្រះគម្ពីរ នៅពេលមានមិត្តអ្នកជឿម្នាក់កំពុងរស់នៅក្នុងអំពើបាបខាងផ្លូវភេទ ហើយជ្រើសនៅតែបន្តវា បន្ទាប់ពី ពួកគេត្រូវបានហៅមកជួបមុខនិយាយផ្ទាល់ក្នុងរបៀបមួយដែលពេញដោយសេចក្តីស្រឡាញ់រួចហើយក្តី»។

ចម្លើយជាក់ស្តែងវាអាស្រ័យនៅត្រង់ថា ធីតា និងមនុស្សម្នាក់ដែលប្អូនស្រីបារម្ភនោះ—ប្រហែលមានមិត្តម្នាក់បានរួមដំណេកជាមួយមិត្តប្រុសរបស់នាង។ ខ្ញុំមិនបានដឹងទេ ថាមិត្តរបស់ប្អូនស្រីធីតាកំពុងស្ថិតក្នុងស្ថានភាពបែបណាទេ ប៉ុន្តែនិយាយថា អញ្ចឹងចុះ—តើមនុស្សទាំងពីរនាក់នោះនៅក្នុងក្រុមជំនុំមួយដែលមានសេចក្តីជំនឿស្មោះត្រង់ស្របទៅតាមបទគម្ពីរទេ? ជាក្រុមជំនុំដែលទុកព្រះគម្ពីរជាស្តង់ដារនៃសេចក្តីជំនឿ និងការអនុវត្តន៍របស់ពួកគេ។ ហើយប្រសិនបើពួកគេនៅក្នុងក្រុមជំនុំបែបនោះមែន ចម្លើយនោះគឺ ឬគួរតែជា៖ បាទ ការកាត់ចេញពីក្រុមជំនុំគួរតែអាច និងប្រហែលជាគួរតែកើតមានឡើង។

ប្រាកដណាស់ ប្អូនស្រីចង់សំដៅទៅលើកណ្ឌគម្ពីរម៉ាថាយជំពូក១៨។ វាប្រហែលជាមានប្រយោជន៍ក្នុងការធ្វើតាមជំហានទាំងនេះ ដើម្បីឲ្យគ្រប់គ្នាយល់អំពីស្ថានភាព ព្រោះវាខ្លីហើយច្បាស់ទៀតផង។ នេះជាអ្វីដែលកើត

ឡើងនៅក្នុងទំនាក់ទំនងពិតរបស់ក្រុមជំនុំពីមួយពេលទៅមួយពេល។

**ជំហានទី១៖ លោកអ្នក និងបងប្អូនរបស់លោកអ្នក**

ជំហានទី១៖ «បើបងប្អូនធ្វើបាបនឹងអ្នក នោះឲ្យទៅបន្ទោសគាត់ ក្នុងកាលដែលមានតែអ្នកហើយ និងគាត់ បើគាត់ស្ដាប់អ្នក នោះអ្នកនឹងបានបងប្អូននោះមកវិញ» (ម៉ាថាយ ១៨:១៥)។

ដូច្នេះ ជំហានទី១៖ ចូរលោកអ្នកទៅរកអ្នកដែលប្រព្រឹត្តអំពើបាបនោះរួចលោកអ្នកចូលទៅឯពួកគេ។ សូមលោកអ្នកកុំទាន់ធ្វើឲ្យបញ្ហានោះបែកធ្លាយជាសាធារណៈឡើយ។ ចូរលោកអ្នកកុំហ៊ានសក្នុងការលើកយកអំពើបាបផ្ទាល់ខ្លួនរបស់នរណាម្នាក់មកបង្ហាញជាសាធារណៈនោះឡើយ។ លោកអ្នកក៏មានបញ្ហាផ្ទាល់ខ្លួនរបស់លោកអ្នកដែរ។ «ចូរយកធ្នឹមពីភ្នែករបស់ខ្លួនចេញជាមុនសិន នោះទើបនឹងបានឃើញច្បាស់ អាចនឹងយកកម្ទេចចេញពីភ្នែករបស់បងប្អូនអ្នកបានដែរ» (ម៉ាថាយ ៧:៥)។ ប៉ុន្តែ...នៅពេលលោកអ្នកបានធ្វើការវាយតម្លៃខ្លួនឯងដោយត្រឹមត្រូវរួចរាល់ជាស្រេច ព្រមទាំងបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់ និងប្រកាសអំពីការពឹងផ្អែកទៅលើព្រះគុណតែមួយមុខគត់របស់លោកអ្នករួចហើយ បន្ទាប់មក ចូរលោកអ្នកចេញទៅឯគេចុះ។ នេះហើយ គឺជាអ្វីដែលសេចក្ដីស្រឡាញ់គួរធ្វើ។ នេះក្នុងករណីប្អូនស្រីម្នាក់នោះ—ប្រហែលជាមិត្តស្រីរបស់អ្នកបានរួមដំណេកជាមួយមិត្តប្រុសរបស់នាង—បន្ទាប់មក ប្អូនស្រីចូលទៅនិយាយជាមួយប្អូនស្រីម្នាក់នោះចុះ។ ប្អូនស្រីអាចនិយាយថា «ការនេះមិនស្របទៅតាមបទគម្ពីរទេ។ វាមិនត្រឹមត្រូវនោះឡើយ។ ព្រះជាម្ចាស់មិនសព្វព្រះទ័យនឹងការនេះទេ»។ ហើយប្អូនស្រីសូមអង្វរគាត់ឲ្យឈប់ប្រព្រឹត្តការនោះចុះ។ ប្អូនស្រីប្រហែលជាអាច ឬប្រហែលជាមិនអាចផ្លាស់ប្ដូរនាងឲ្យឈប់បានទេ។



**ជំហានទី២៖ ស្មរបន្ទាល់ពីរ ឬបីនាក់**

ជាជំហានបន្ទាប់ នៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១៨:១៦ បានចែងថា៖ «តែបើគាត់មិនព្រមស្ដាប់ទេ នោះត្រូវយកមនុស្សម្នាក់ឬ២នាក់ទៅជាមួយ ដើម្បីនឹងបញ្ជាក់គ្រប់ទាំងពាក្យ ដោយសារស្មរបន្ទាល់២ ឬ៣នាក់»។

លោកអ្នកអាចឃើញថា មិនចាំបាច់អ្វីត្រូវប្រញាប់ក្នុងការថ្កោលទោសឡើយ។ ហើយក៏មិនចាំបាច់ប្រញាប់នាំរឿងនេះទៅប្រាប់ក្រុមជំនុំទាំងមូលនោះដែរ។ យើងរាល់គ្នាត្រូវព្យាយាមរក្សាវាជារឿងតូចឲ្យអស់ពីសមត្ថភាពសិន និងរក្សាជាឯកជនតាមដែលអាចធ្វើបាន កុំទាន់ធ្វើឲ្យមានផលប៉ះពាល់និងឈឺចាប់ជាសាធារណៈលើសពីការចាំបាច់នោះឡើយ។ ដូច្នេះ ប្អូនស្រីនាំយកមិត្តម្នាក់ ឬពីរនាក់ដែលប្រហែលជាស្គាល់ និងស្រឡាញ់មិត្តរបស់ប្អូនស្រីនោះទៅជាមួយ ហើយនាំគ្នាទៅជួបនឹងនាងចុះ។ នាងប្រហែលមិនអនុញ្ញាតឲ្យប្អូនស្រីធ្វើបែបនេះទេ ប៉ុន្តែសូមប្អូនស្រីព្យាយាម ហើយនិយាយទាំងអស់គ្នាថា «ពួកយើងស្រឡាញ់ប្អូនស្រី។ ពួកយើងបារម្ភពីប្អូនស្រី។ តើពួកយើងអាចអធិស្ឋានឲ្យប្អូនស្រីបានទេ? ពួកយើងចង់ឲ្យប្អូនស្រីបានរួចចេញពីអំពើបាបនេះ ពីព្រោះវានឹងបំផ្លាញប្អូនស្រីជាមិនខាន។ វានឹងបំផ្លាញប្អូនប្រុសនោះផងដែរ។ វានឹងបំផ្លាញទីបន្ទាល់របស់ប្អូនស្រី។ វានឹងបំផ្លាញក្រុមជំនុំធ្ងន់ធ្ងរបំផុត ហើយវានឹងបន្ថុះបង្អាប់ដល់សិរីល្អរបស់ព្រះគ្រីស្ទ»។ ប្អូនស្រីត្រូវព្យាយាមបញ្ចុះបញ្ចូលនាង។

**ជំហានទី៣៖ ប្រាប់ក្រុមជំនុំ**

ហើយនៅជំហានទី៣៖ «ប្រសិនបើគាត់បដិសេធមិនព្រមស្ដាប់ពួកគេទេ ចូរប្រាប់វាទៅក្រុមជំនុំចុះ» (ម៉ាថាយ ១៨:១៧)។

ត្រង់នេះគឺជាចំណុចដែលត្រូវមានការប្រមូលគ្នាក្នុងក្រុមជំនុំធ្វើការប្រជុំមួយដែលមានការស្ដាប់ព័ត៌មាន និងការសម្រេចលើរឿងនោះដោយត្រឹម

ត្រូវ។ ទង្វើដំបូងរបស់ក្រុមជំនុំ គឺការនិយាយថា «ពួកយើងចង់ឲ្យប្អូនស្រីត្រឡប់ក្រោយវិញ» ពីព្រោះនេះមិនទាន់ជាការកាត់ការចេញពីក្រុមជំនុំនៅឡើយទេ។ វាជាការអធិស្ឋាន  ការឈឺចាប់ និងការប៉ងប្រាថ្នារបស់ក្រុមជំនុំទាំងមូលក្នុងការដែលឲ្យគាត់ប្រែចិត្តចេញពីអំពើបាបនោះ។

**ជំហានទី៤៖ ការកាត់ចេញពីក្រុមជំនុំ**

ជំហានចុងក្រោយគឺ៖ «បើគាត់មិនព្រមស្តាប់អ្នកទាំងនោះទេ នោះត្រូវតែប្រាប់ដល់ពួកជំនុំ ហើយបើមិនព្រមស្តាប់ពួកជំនុំទៀត នោះត្រូវតែរាប់គាត់ទុកជាអ្នកក្រៅសាសន៍ ឬជាអ្នកយកពន្ធវិញ» (ម៉ាថាយ ១៨:១៧)។

នោះមានន័យថា ក្រុមជំនុំមានជំហានមួយចំនួនក្នុងការកាត់មនុស្សម្នាក់នោះចេញ ដូចជាកាត់ចេញពីពិធីលាងព្រះអម្ចាស់ និងចេញពីទំនាក់ទំនងធម្មតា ដែលលោកអ្នកធម្មតាមានជាមួយអ្នកជឿម្នាក់ក្នុងការធ្វើការជាមួយគ្នាដូចអស់អ្នកដែលមានការប្ដេជ្ញាចិត្តដូចគ្នា ចំពោះព្រះយេស៊ូវ។ ចូរលោកអ្នកកាត់ពួកគេចេញចុះ។ នោះមានន័យថា មិនមែនលោកអ្នកដាក់បណ្ដាសារពួកគេទេ ប៉ុន្តែលោកអ្នកត្រូវតែដាក់ពួកគេនៅក្នុងចំណុចមួយ ដែលលោកអ្នកកំពុងតែប្រាថ្នាចង់បាន និងអធិស្ឋានសម្រាប់ការប្រែចិត្តរបស់ពួកគេ។

ខ្ញុំធ្លាប់ឃើញការនេះកើតឡើង ហើយវាតែងតែកើតឡើងនៅក្នុងព្រះគម្ពីរជាញឹកញាប់ ដែលការកាត់ចេញពីក្រុមជំនុំប្រភេទនេះ មានការប្រោសលោះទ្វេដង។ វាជាការប្រោសលោះសម្រាប់ក្រុមជំនុំ ដោយសារហេតុនេះសេចក្ដីពិតនៃដំណឹងល្អ ព្រមទាំងអំណាចរបស់ដំណឹងល្អនឹងមិនត្រូវបាត់បង់ ដោយសារពួកមនុស្សមានពុត ជាអ្នកជឿដែលមិនបង្កើតផលផ្លែទាល់តែសោះ។ ហើយវាជាការប្រោសលោះសម្រាប់បុគ្គលដែលត្រូវបានកាត់ចេញពីក្រុមជំនុំ ពីព្រោះយើងឃើញនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៥ គោលបំណង



នៃការបញ្ជូននេះ...ប្រយោជន៍ឲ្យវិញ្ញាណរបស់គេបានសង្គ្រោះ (១កូរិនថូស ៥:៥)។ នោះយើងចង់នាំពួកគេទៅកាន់ការប្រែចិត្ត និងការស្តារឡើងវិញក្នុងក្រុមជំនុំ។ ហើយដើម្បីបញ្ចប់ការនោះ យើងត្រូវតែនិយាយជាមួយពួកគេ។ យើងចូលទៅជិតពួកគេដូចដែលយើងចូលទៅកាន់អ្នកដែលមិនជឿដោយសេចក្ដីស្រឡាញ់។ យើងរីករាយនឹងលះបង់ជីវិតរបស់យើងឲ្យតែពួកគេបានប្រែចិត្ត។

គ្មានអ្វីអាក្រក់ ឬជាសត្រូវនឹងគ្នាទេ នៅក្នុងរឿងនេះ។ ការនេះត្រូវបានរចនាឡើង ដើម្បីធ្វើគ្រប់កិច្ចការទាំងអស់ដែលក្រុមជំនុំអាចធ្វើបានក្នុងការរក្សាសេចក្ដីពិតរបស់ខ្លួន និងសេចក្ដីទៀងត្រង់ សេចក្ដីបរិសុទ្ធ និងគ្មានស្នាមប្រឡាក់ ហើយដើម្បីស្រឡាញ់អ្នកដទៃ និងនាំពួកគេត្រឡប់ទៅឯព្រះសង្គ្រោះវិញ។

ដូច្នេះ ចម្លើយរបស់ខ្ញុំសម្រាប់ប្អូនស្រីគឺ៖ បាទ! មានការកាត់ការចេញពីក្រុមជំនុំ ហើយនៅក្នុងកណ្ឌគម្ពីរម៉ាថាយ ១៨ ប្រាប់ពីរបៀបនៅក្នុងការដើរតាមជំហានទាំងឡាយនោះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
When Christian Won't Repent From Sexual Sin
**នៅពេលគ្រីស្ទបរិស័ទមិនព្រមប្រែចិត្តចេញពីអំពើបាបខាងផ្លូវភេទ**
https://www.desiringgod.org/interviews/when-a-christian-wont-repent-from-sexual-sin

## សំណួរទី៣៣៖
# ហេតុអ្វីព្រះរើសពួកអ្នកល្ងង់ល្ងើ?

សួស្ដីមិត្តអ្នកស្ដាប់! សំណួរសម្រាប់ថ្ងៃនេះមានដូចតទៅ៖ «ហេតុអ្វីបានជាព្រះជ្រើសរើសពួកអ្នកល្ងង់ល្ងើនៃលោកីយ៍នេះ ហើយមិនរើសពួកអ្នកប្រាជ្ញ និងអ្នកខ្លាំងពូកែ។ ហេតុអ្វីមិនរើសអ្នកច្នៃប្រឌិតថ្មីដែលជាអ្នកមានបំផុត អ្នកមានទេពកោសល្យដែលឆ្លាតវៃបំផុត អ្នកដែលមានវោហារល្អបំផុត អគ្គពលិកដែលល្អបំផុតនៅលើលោកនេះហើយនិងតារាភាពយន្តដែលល្បីល្បាញបំផុត ដើម្បីផ្សព្វផ្សាយដំណឹងល្អរបស់ព្រះអង្គដល់ពិភពលោកទាំងមូល? ហេតុអ្វីបានជាព្រះសម្រេចជ្រើសរើស និងប្រើប្រាស់អ្នកទន់ខ្សោយសម្រាប់បេសកកម្មរបស់ព្រះអង្គទៅវិញ?»

សំណួរនេះបានមកពីអ្នកស្ដាប់សេចក្ដីអធិប្បាយម្នាក់ដែលមានឈ្មោះថា សុភី ដែលរស់នៅខេត្តកំពង់ចាម។ «ជម្រាបសួរលោកគ្រូ ខ្ញុំបានថ្វាយជីវិតខ្ញុំ ដើម្បីមហាបេសកកម្ម ហើយមានបំណងចិត្តក្នុងការប្រកាសដំណឹងល្អទៅកាន់គ្រប់ប្រជាជាតិទាំងអស់។ កណ្ឌគម្ពីរ ១កូរិនថូស ១:២៧ បានចែងថា «ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកម្សោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស»។ នេះជាសំណួររបស់ខ្ញុំ៖ «ហេតុអ្វីបានជាព្រះអង្គមិនសង្គ្រោះពួកអ្នកឆ្លាតវៃទាំងអស់នៅលើលោកីយ៍នេះ ដើម្បីប្រកាសដំណឹងល្អទៅកាន់ពិភពលោកទាំងមូល? តើការនោះវានឹងមិនធ្វើឲ្យលឿនជាង ហើយមានឥទ្ធិពលជាងក្នុងការផ្សាយដំណឹងល្អ ជាជាងការជ្រើសរើសមនុស្សល្ងង់ល្ងើជាច្រើន ដើម្បីធ្វើការនេះទេឬអី?»។

សូមសរសើរតម្កើងព្រះជាម្ចាស់ដែលទ្រង់ជ្រើសរើសមនុស្សល្ងង់ល្ងើ។

ចម្លើយដំបូងដែលខ្ញុំចង់និយាយគឺថា ឥទ្ធិពលរបស់មនុស្សមានប្រាជ្ញាទាំងអស់នោះ—មនុស្សឆ្លាតទាំងអស់នោះ មនុស្សដែលមានចំណេះដឹងទាំងនោះ មនុស្សដែលមានអំណោយទានទាំងនោះ—ប្រហែលជាអាចធ្វើបានលឿនជាងមែន ហើយប្រហែលជាមានផ្ទៃកធំជាងនៅខាងក្រៅមែន ប៉ុន្តែវានឹងមិនមែនជាជំនឿគ្រីស្ទបរិស័ទទេ។ ប្រសិនបើព្រះរាជបុត្រានៃព្រះជាម្ចាស់បានយាងមកផែនដីជាអ្នកចម្បាំង ឬជាទស្សនៈវិទូ ដើម្បីជះឥទ្ធិពលដល់ពិភពលោកដោយអំណាច ហើយនិងប្រាជ្ញាប៉ិនប្រសព្វរបស់ទ្រង់ នោះឥទ្ធិពលនឹងបានលឿនជាង ហើយនិងមានការចាប់អារម្មណ៍ខ្លាំងជាងពីខាងក្រៅមែន ប៉ុន្តែវានឹងមិនមែនជាជំនឿគ្រីស្ទបរិស័ទទេ។

## ឈើឆ្កាងជាស្នូលកណ្តាល

យើងស្ទើរតែមិនអាចប៉ាន់ស្មានបានអំពីសារៈសំខាន់នៃការសម្រេចព្រះទ័យរបស់ព្រះជាម្ចាស់នៅស្ថានសួគ៌បានទេ—ពិតណាស់ តាំងពីមុនកំណើតលោកីយ៍មកថា—ព្រះទ្រង់នឹងសង្គ្រោះ ហើយផ្តល់ការកំណត់របស់មនុស្សតាមរយៈភាពកម្សោយ ហើយនិងការស្លាប់ដ៏អាក្រក់បំផុតដែលមិនអាចស្រមៃបាន៖ ការសុគតដោយការជាប់ឆ្កាងរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ។ វាគឺជារឿងដែលគួរឲ្យអាម៉ាស់ វាជាការជំពប់ដួល វាជារឿងដែលល្ងីល្ងើបំផុត អាម៉ាស់បំផុត វាជាការប្រមាថមើលងាយខ្លាំងបំផុត ហើយនោះជារបៀបដែលយើងទទួលបានសេចក្តីសង្គ្រោះ។ នោះជារបៀបដែលដំណឹងល្អមានជ័យជម្នះ។

នៅក្នុងបីជំពូកដំបូងនៃសំបុត្ររបស់សាវ័ក ប៉ុល ទៅកាន់ក្រុមជំនុំកូរិនថូស គឺគាត់បានសរសេរឡើង ដើម្បីបញ្ជាក់ដល់ពួកជំនុំនៅទីនោះ—ហើយនិងមកកាន់យើងថា—ជំនឿគ្រីស្ទបរិស័ទ គឺមិនមែនកំណត់ដោយឬពង្រីកដោយភាពល្អឥតខ្ចោះនៃវោហាររបស់មនុស្ស ឬភាពទាក់ទាញនៃប្រាជ្ញារបស់មនុស្សនោះឡើយ។ ការផ្តោតលើទាំងពីរនោះគឺជាអំនួតរបស់អ្នកក្រុមជំនុំកូរិនថូស៖ អ្នកមានវោហារយ៉ាងល្អ ហើយនិងអ្នកប្រាជ្ញដ៏ឆ្នើម។ ហើយជាក់ស្តែង ក្រុមជំនុំនៅក្រុងកូរិនថូសពិតជាមានការជាប់ចិត្តយ៉ាងខ្លាំងចំពោះកិច្ចការទាំងនេះណាស់។ ពួកគាត់បានអួតអាងដោយនិយាយថា «ខ្ញុំជាសិស្សសាវ័ក ប៉ុល» ឬ «ខ្ញុំជាសិស្សលោក អ័ប៉ូឡូស» ឬ «ខ្ញុំជាសិស្សលោក កេផាស» (១កូរិនថូស ១:១២)។

ពួកគាត់បានព្យាយាមស្វែងរកខ្ញីការអួត ខ្ញីភាពល្បីល្បាញ ខ្ញីការសរសើរតាមរយៈការឈរតម្រង់ជួរពីខាងក្រោយគ្រូដែលពួកគាត់គិតជាអ្នកដែលមានវោហារ និងអ្នកប្រាជ្ញដ៏ខ្លាំងបំផុត។ សាវ័ក ប៉ុល បានយកបីជំពូកដើម្បីបង្ហាញថា នេះមិនមែនជាអត្ថន័យនៃជំនឿគ្រីស្ទបរិស័ទទេ ហើយក៏មិនមែនជារបៀបឆ្ពោះទៅមុខសម្រាប់ជំនឿគ្រីស្ទបរិស័ទដែរ។

## បញ្ហាជាមួយប្រាជ្ញារបស់មនុស្ស

នៅពេលដែលសាវ័ក ប៉ុល បានឮថាអ្នកជំនុំនៅទីក្រុងកូរិនថូសនិយាយថា «ខ្ញុំជាសិស្សរបស់ប៉ុល» (១កូរិនថូស ១:១២) គាត់ក៏បានតបឡើងថា «តើប៉ុលត្រូវឆ្កាងជំនួសអ្នករាល់គ្នាឬអី?» (១កូរិនថូស ១:១២)។ គាត់មិននឹកស្មានថា ពួកគាត់បានផ្លាស់ប្តូរព្រះរាជសារនៃការសុគតលើឈើឆ្កាងរបស់ព្រះគ្រីស្ទឲ្យទៅជាហេតុនៃការអួតអំពីទេពកោសល្យរបស់គាត់ទៅវិញ។ បន្ទាប់មក នៅក្នុងបីខបន្ទាប់ទៀតគាត់បានលើកឡើងថា «ព្រះគ្រីស្ទមិនបានចាត់ខ្ញុំ...ឲ្យមកផ្សាយដំណឹងល្អប៉ុណ្ណោះ តែមិនមែនដោយពាក្យឧត្តុង្គឧត្តមឡើយ ក្រែងឈើឆ្កាងនៃព្រះគ្រីស្ទទៅជាអសារឥតការវិញ» (១កូរិនថូស ១:១៧)។

បញ្ហាទាំងពីរនោះគឺជា៖ ភាពឧត្តុង្គឧត្តមរបស់មនុស្ស និងប្រាជ្ញារបស់មនុស្ស។ អ្នកមានវោហារ ចំណេះជ្រៅជ្រះ ភាពប៉ិនប្រសប់ក្នុងពាក្យសម្តី

ភាពមោះមុតនៃគំនិត—ទាំងនេះគឺជាចំណុចផ្ដោតយ៉ាងខ្លាំងបំផុតនៃការកោតសរសើរ និងអំនួតនៃអ្នកក្រុងកូរិនថូស។ ជាលទ្ធផលសាវ័ក ប៉ុល បាននិយាយថា «អ្នកមានវោហារ ហើយនិងអ្នកប្រាជ្ញដ៏ឧត្ដុង្គឧត្ដមប្រហែលជាអាចមានហ្វូងមនុស្សច្រើន ប្រហែលជាអាចទទួលការសាទរកាន់តែច្រើន និងប្រហែលជាអាចជះឥទ្ធិពលនៅទីសាធារណៈកាន់តែលឿនមែន ប៉ុន្តែវានឹងមិនមែនជាជំនឿគ្រីស្ទបរិស័ទទេ»។ តាមពិត វាអាចក្លាយជាការបដិសេធព្រះគ្រីស្ទ ហើយនិងការដកឈើឆ្កាងរបស់ព្រះគ្រីស្ទចេញ ពីព្រោះឈើឆ្កាងរបស់ព្រះគ្រីស្ទគឺជាទីបញ្ចប់នៃអំនួតនៅក្នុងការសម្រេចបានរបស់មនុស្ស។

វាមានន័យថា ជាការជំនួសអំនួតអួតអាងបែបនោះជាមួយការលើកតម្កើងព្រះគ្រីស្ទ ការទុកចិត្តដូចជាកូនក្មេងនៅក្នុងព្រះអង្គសង្គ្រោះ ពីព្រោះថាយើងពិតជាត្រូវការវាយ៉ាងខ្លាំង និងដោយសារយើងពេញដោយអំពើបាប។ ឈើឆ្កាងនៃព្រះគ្រីស្ទមិនមែនគ្រាន់តែជាការសុគតរបស់ព្រះគ្រីស្ទនោះទេ។ វាក៏ជាការស្លាប់របស់យើងដែរ។ ខ្ញុំបានជាប់ឆ្កាងជាមួយព្រះគ្រីស្ទ គឺជាការជាប់ឆ្កាងខាងឯការសង្គ្រោះខ្លួនឯង ហើយនិងការលើកតម្កើងខ្លួនឯងដោយអំនួត។ បន្ទាប់មក នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១:១៨ សាវ័ក ប៉ុល បានលើកឡើងថា «ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្ដីចំកួតដល់អស់អ្នកដែលកំពុងតែវិនាស តែជាព្រះចេស្ដានៃព្រះដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះវិញ»។

### ប្រាជ្ញារបស់ព្រះ

បីខបន្ទាប់មកទៀត នៅក្នុងខដ៏អស្ចារ្យនោះ គាត់បានប្រាប់យើងអំពីមូលហេតុដែលប្រាជ្ញារបស់មនុស្ស ភាពឈ្លាសវៃរបស់មនុស្ស ហេតុផល និងអ្វីដែលយើងមានពីពង្សជាតិតែមួយមុខ គឺមិនអាចរកឃើញប្រាជ្ញាដ៏អស់កល្បនៅក្នុងព្រះជាម្ចាស់ ឬសេចក្ដីសង្គ្រោះបានឡើយ។ នេះជាអ្វីដែលគាត់បានសរសេរ៖ «ដ្បិតដោយព្រោះព្រះទ្រង់បានសម្រេចតាមប្រាជ្ញានៃទ្រង់ថា [នោះគឺជាឃ្លាគន្លឹះ] មនុស្សលោកនឹងរកស្គាល់ព្រះដោយអាងប្រាជ្ញាខ្លួនមិនបានទេ បានជាទ្រង់សព្វព្រះហឫទ័យនឹងជួយសង្គ្រោះអស់លោកអ្នកដែលជឿ ដោយសារសេចក្ដីល្ងីល្ងើវិញ គឺជាការប្រកាសដំណឹងល្អ» (១កូរិនថូស ១:២១)។

ប្រាជ្ញារបស់ព្រះជាម្ចាស់បានសម្រេចថា ប្រាជ្ញារបស់មនុស្សមិនអាចជាផ្លូវនៃសេចក្ដីសង្គ្រោះបានទេ។ ផ្ទុយទៅវិញ ជំនឿនៅក្នុងភាពល្ងង់ល្ងើនៃព្រះជាម្ចាស់គឺជាផ្លូវនៃសេចក្ដីសង្គ្រោះ។ «ដ្បិតសេចក្ដីល្ងង់ល្ងើរបស់ព្រះ នោះមានប្រាជ្ញាលើសជាងមនុស្ស ហើយសេចក្ដីកម្សោយរបស់ព្រះ ក៏មានកម្លាំងលើសជាងមនុស្សដែរ» (១កូរិនថូស ១:២៥)។ ចំណុចដែលចង់សង្កត់ធ្ងន់សម្រាប់មិត្តភក្ដិរបស់យើងកញ្ញា សុភី ដែលរស់នៅខេត្តកំពង់ចាមគឺថា វាមិនអាចកើតឡើងក្នុងរបៀបនោះបានទេ។

ភាពល្ងង់ល្ងើរបស់ព្រះមានប្រាជ្ញាជាងមនុស្ស ប៉ុន្តែវាមិនកើតឡើងក្នុងរបៀបនោះទេ។ វាមើលទៅអាចដូចជាភាពល្ងង់ល្ងើវិញ។ ភាពកម្សោយរបស់ព្រះអង្គគឺខ្លាំងក្លាជាងមនុស្ស ប៉ុន្តែវាមិនកើតក្នុងរបៀបនោះទេ។ វាមើលទៅអាចដូចជាភាពទន់ខ្សោយវិញ។ នោះហើយគឺជាជំនឿគ្រីស្ទបរិស័ទ។ នេះគឺជារបៀបដែលដំណឹងល្អរីកសាយភាយនៅក្នុងពិភពលោកនេះ។ សាវ័ក ប៉ុល លើកឡើងម្ដងទៀតនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ២:១៖ «រីឯខ្ញុំ បងប្អូនអើយ កាលខ្ញុំបានមកឯអ្នករាល់គ្នា នោះមិនបានមកដោយប្រើវោហារ ឬប្រាជ្ញាដ៏ឧត្ដម»។ ជាថ្មីម្ដងទៀត៖ វោហារដ៏ឧត្ដុង្គឧត្ដម ភាពប៉ិនប្រសប់ ពាក្យពេចន៍ឬសម្ដីដ៏គួរឲ្យចាប់អារម្មណ៍ ឬក៏ទស្សនៈវិជ្ជាដែលគួរឲ្យទាក់ទាញចិត្ត។

### យុទ្ធសាស្ត្រនៃដំណឹងល្អរបស់ព្រះជាម្ចាស់

«ហេតុអ្វីសាវ័ក ប៉ុល?»។ នោះជាអ្វីដែលកញ្ញា សុភី បានសួរ។ «ហេតុ

អ្វីបានជាមិនប្រើប្រាស់អ្នកមានវោហារ និងប្រាជ្ញាដ៏ឧត្តមរបស់មនុស្សអញ្ចឹង?»។ កណ្ឌគម្ពីរ ១កូរិនថូស ២:៥ បានផ្ដល់ជាចម្លើយ៖ «ដើម្បីកុំឲ្យសេចក្ដីជំនឿរបស់អ្នករាល់គ្នាបានតាំងនៅ ដោយប្រាជ្ញារបស់មនុស្សឡើយ គឺដោយព្រះចេស្ដានៃព្រះវិញ»។ ឥឡូវនេះ កញ្ញា សុភី ចាប់ផ្ដើមស្រង់កណ្ឌគម្ពីរ ១កូរិនថូស ១:២៧ ហើយសួរថា «ហេតុអ្វីបានជាព្រះអង្គមិនសង្គ្រោះពួកអ្នកឆ្លាតវៃទាំងអស់នៅលើលោកីយ៍នេះ ដើម្បីប្រកាសដំណឹងល្អទៅកាន់ពិភពលោកទាំងមូល? តើការនោះវានឹងមិនធ្វើឲ្យលឿនជាង ហើយមានឥទ្ធិពលជាងក្នុងការផ្សាយដំណឹងល្អ ជាជាងការជ្រើសរើសមនុស្សល្ងង់ល្ងើជាច្រើន ដើម្បីធ្វើការនេះទេឬអី?»។

សូមឲ្យយើងបានបញ្ចប់នៅកន្លែងដែលកញ្ញា សុភី បានចាប់ផ្ដើមពីព្រោះកថាខណ្ឌនោះបានផ្ដល់ចម្លើយពីរយ៉ាងច្បាស់មកកាន់សំណួរ «ហេតុអ្វីបានជាព្រះមិនធ្វើនៅក្នុងរបៀបបែបនោះ?» នេះជាអ្វីដែលសាវ័កប៉ុល បានលើកឡើង៖

«ឱបងប្អូនអើយ អ្នករាល់គ្នាឃើញថា ក្នុងពួកអ្នកដែលទ្រង់បានហៅ មិនសូវមានអ្នកប្រាជ្ញច្រើនខាងឯសាច់ឈាម ឬច្រើននាក់មានអំណាច និងច្រើននាក់ដែលមានត្រកូលខ្ពស់នោះទេ។ ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកម្សោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែ មានសេចក្ដីខ្មាស។ ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកីយ៍នេះ និងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ» (១កូរិនថូស ១:២៦-២៨)។

នេះជាចម្លើយទីមួយរបស់គាត់៖ «ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ» (១កូរិនថូស ១:២៩)។ ហើយគាត់បានបន្តទៀតថា៖ «តែដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់បានតាំងឡើង ទុកជាប្រាជ្ញាដែលមកពីព្រះ ហើយជាសេចក្ដីសុចរិត សេចក្ដីបរិសុទ្ធ និងសេចក្ដីប្រោសលោះដល់យើងផង»។ ហើយនេះជាចម្លើយទីពីររបស់គាត់៖ «ដើម្បីឲ្យបានត្រូវនឹងសេចក្ដីដែលចែងទុកមកថា “អ្នកណាដែលអួត ត្រូវអួតតែពីព្រះអម្ចាស់ប៉ុណ្ណោះ”» (១កូរិនថូស ១:៣០-៣១)។

ដូច្នេះ ហេតុអ្វីបានជាមិនប្រកាសដំណឹងល្អនៅក្នុងគ្រប់ជាតិសាសន៍ឲ្យកាន់តែលឿន និងមានឥទ្ធិពលឲ្យកាន់តែខ្លាំងជាងមុនតាមរយៈអ្នកប្រាជ្ញ អ្នកមានអំណាច និងអ្នកខ្ពង់ខ្ពស់? ចម្លើយមានពីរ៖

១. ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ

២. អ្នកណាដែលអួត ត្រូវអួតតែពីព្រះអម្ចាស់ប៉ុណ្ណោះ

គោលបំណងរបស់ព្រះក្នុងការផ្សាយដំណឹងល្អទៅកាន់ពិភពលោកទាំងមូល គឺដើម្បីដាក់ទីបញ្ចប់នៃអំនួតរបស់មនុស្ស ហើយដើម្បីធ្វើឲ្យព្រះយេស៊ូវក្លាយជាចំណុចស្នូលនៃការសរសើរតម្កើងរបស់មនុស្សវិញ។ របៀបរបស់ទ្រង់គឺមិនមែនជារបៀបរបស់យើងឡើយ។ យើងគឺគ្រាន់តែជាអ្នកទទួលយកប៉ុណ្ណោះ។ របៀបរបស់ទ្រង់គឺមិនមែនជារបៀបរបស់យើងឡើយ។ ការសុគតរបស់ព្រះគ្រីស្ទបានកំណត់អ្វីៗគ្រប់យ៉ាង។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Why Does God Choose the Foolish?
**ហេតុអ្វីព្រះរើសពួកអ្នកល្ងង់ល្ងើ?**
https://www.desiringgod.org/interviews/why-does-god-choose-the-foolish

# ផ្នែកទី៥
# ការចែចង់គ្នា និងទំនាក់ទំនងស្នេហា

# សំណួរទី៣៩៖
# តើយើងមានអស្តេរភាពខាងហិរញ្ញវត្ថុនៅក្នុងការរៀបការមែនទេ?

*ថ្ងៃនេះ យើងបានទទួលសំបុត្រមួយមកពីប្អូនប្រុសម្នាក់ឈ្មោះ ជ័យ៉ា មកក្នុងកម្មវិធីយើងថា៖ «ជម្រាបសួរលោកគ្រូ! តើបញ្ហាខ្វះខាតថវិកាគឺជាហេតុផលផ្ទាល់គ្រប់គ្រាន់ នៅក្នុងការពន្យារពេលគូស្នេហ៍វ័យក្មេងពីការរៀបការ និងពន្យារពេលការភ្ជាប់ពាក្យរបស់ពួកគេក្នុងរយៈពេលដ៏វែងមែនទេ? សំណួរនេះសន្មតថាកត្តាផ្សេងទៀតទាំងអស់គឺ "ទៅ"៖ ទាំងសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ ក្រុមជំនុំនៅក្នុងតំបន់យល់ព្រមលើការផ្គូផ្គង ឪពុកម្ដាយយល់ព្រមចំពោះទំនាក់ទំនង និងភាពបរិសុទ្ធខាងផ្លូវអារម្មណ៍ និងផ្លូវភេទត្រូវបានគោរពជាដើម។ តើលោកគ្រូនឹងនិយាយអ្វីទៅកាន់ប្តីប្រពន្ធនេះដែរ?*

ជាទូទៅ ខ្ញុំនឹងនិយាយថា៖ ខ្ញុំពេញចិត្តនឹងការទុកចិត្តព្រះជាម្ចាស់សម្រាប់បំណងព្រះទ័យរបស់ព្រះអង្គ និងសមត្ថភាពរបស់ទ្រង់នៅក្នុងការជួយគូស្នេហ៍វ័យក្មេងមួយគូឲ្យសម្រេចធ្វើវាបាន។

នៅក្នុងស្ថានភាពបែបនេះ។ ម៉្យាងទៀត ខ្ញុំប្រហែលជាកំពុងខិតឆ្ពោះទៅ «សូមសម្រេចចិត្តចុះ សាកប្រថុយមើល៍។ រៀបការតែម្ដងទៅ»។ ប៉ុន្តែនេះគឺជាសំណួរខ្លះៗ ដែលខ្ញុំនឹងសួរ។

**ជាដៃគូជាជាងអ្នកផ្គត់ផ្គង់**

តើបុរសម្នាក់នោះមានសមត្ថភាពចិញ្ចឹមខ្លួនឯង និងប្រពន្ធរបស់គាត់ដែរឬទេ? ខ្ញុំគិតថា គាត់គួរតែចង់ធ្វើបែបនោះ ហើយគាត់គួរតែព្យាយាមធ្វើបែបនោះ។ ខ្ញុំគិតថា វាគឺជាផ្នែកមួយនៃការហៅគាត់ជាមេដឹកនាំ ជាអ្នក

ផ្គត់ផ្គង់ និងតួនាទីរបស់គាត់ ក្នុងនាមជាបុរស។ ប៉ុន្តែ ប្រហែលជាមានហេតុផលល្អដែលគាត់មិនអាចធ្វើបាន។ ឧទាហរណ៍៖ គាត់ប្រហែលជាអាចមានពិការភាព។ គាត់ប្រហែលជាទាហានចូលនិវត្តន៍ម្នាក់ដែលបានរងរបួសបានត្រលប់មកផ្ទះវិញ ហើយគាត់មិនអាចធ្វើការងារដែលគាត់ធ្លាប់ធ្វើ ដើម្បីរកប្រាក់ចំណូលបានទៀតនោះទេ។ ឥឡូវនេះ វាប្រហែលជារឿងបណ្ដោះអាសន្នហើយដែលប្រពន្ធវ័យក្មេងអាចនឹងចូលខ្លួនមក ហើយនាំពួកគេឆ្លងកាត់គ្រាដ៏លំបាកនោះដោយធ្វើការងារផ្ទាល់ខ្លួនរបស់នាង ឬវាអាចជាអចិន្ត្រៃយ៍។ ហើយនាងរៀបការជាមួយគាត់នោះដោយដឹងពីហេតុផលណាមួយ គាត់នឹងមិនអាចធ្វើអ្វីទាំងអស់ដែលគាត់ចង់ធ្វើ ដើម្បីផ្គត់ផ្គង់គ្រួសារនោះទេ ។ ហើយនាងនឹងគោរពភាពជាបុរសរបស់គាត់តាមរបៀបផ្សេងទៀត គាត់នឹងទទួលបន្ទុកតែមួយគត់របស់គាត់ជាមេដឹកនាំតាមរបៀបផ្សេងទៀត។ នាងប្រហែលជាអាចរកលុយបានច្រើនជាងគាត់ក្នុងស្ថានភាពបែបនោះ ហើយពួកគេនឹងចាប់ដៃគ្នាបង្កើតអាពាហ៍ពិពាហ៍នេះ ឲ្យដំណើរការបាន។

វាអាចនឹងល្អសម្រាប់យើងនៅក្នុងការរម្លឹកខ្លួនរបស់យើងថាសម្រាប់សង្គមភាគច្រើន—ជាពិសេសផ្នែកកសិកម្ម—ជាច្រើនសតវត្សរ៍មុន វាត្រូវបានបង្កើតនៅក្នុងតួនាទីនៃអាពាហ៍ពិពាហ៍ ដែលវាគឺជាការចែករំលែក ភាពជាដៃគូជំនួញ ដែលប្រកបដោយលទ្ធភាព។ កសិដ្ឋានដំណើរការបានដោយសារ គាត់ និងនាង និងកូនៗ និងកូនឈ្នួលបានធ្វើកិច្ចការរបស់ពួកគេ។ បើអ្នកណាម្នាក់គេចវេះពីកាតព្វកិច្ច នោះជំនួញនោះនឹងត្រូវបរាជ័យ។ មនុស្សគ្រប់គ្នាបានធ្វើការ។ វាមិនដូចជាកាលដែលនាងគ្រាន់តែមើលរឿងភាគនោះទេ។ ខ្ញុំដឹងថានោះជារឿងខុសកាលសម័យ ប៉ុន្តែនាងបានចូលរួមយ៉ាងពេញលេញនៅក្នុងផ្នែកនៅក្នុងស្រុកនៃអាជីវកម្មនេះហៅថា៖ «កសិដ្ឋាន» ហើយវាចាំបាច់សម្រាប់នាង ដើម្បីក្លាយជាផ្នែកមួយនៃអាជីវកម្មនោះ។



**ពេលដែលត្រូវផ្អាក**

ស្ត្រីវ័យក្មេងនៅក្នុងសាច់រឿងនេះ ដែលយើងកំពុងនិយាយគួរតែសួរថា៖ «តើគូរដណ្ដឹងនោះមានលក្ខណសម្បត្តិណា ដែលកំពុងរារាំងគាត់មិនឲ្យរកការងារធ្វើដែលអាចជួយផ្គត់ផ្គង់យើងដែរឬទេ? តើគាត់ខ្ជិលដែរឬទេ? តើគាត់ខ្លាចដែរឬទេ? តើគាត់រំខានដែរឬទេ? តើគាត់ពិតជាវក់នឹងកីឡា និងមិនទាន់ធំដឹងក្ដីដែរឬទេ? តើគាត់មិនមានទំនួលខុសត្រូវចំពោះលុយកាក់ដែរឬទេ? តើអ្វីដែលធ្វើឲ្យយើងជាប់គាំងនៅត្រង់ចំណុចនេះ?»។ ប្រសិនបើនាងរកឃើញថា តាមពិតទៅទាំងនេះគឺជាហេតុផលដែលពួកគេមិនអាចបង្កើតស្ថេរភាពខាងហិរញ្ញវត្ថុបាននោះទេ ប្រសិនបើខ្ញុំជានាង ខ្ញុំនឹងដកខ្លួនចេញពីទំនាក់ទំនងនេះ និងប្រាប់ឲ្យគាត់ដឹងថា នាងត្រូវតែឃើញអំពីភាពពេញវ័យគួរឲ្យកត់សម្គាល់ មុននឹងនាងអាចបន្តទៅមុខជាមួយនឹងអាពាហ៍ពិពាហ៍បាន។ នោះគឺជាភាពបរាជ័យផ្សេងទៀត ខុសពីពិការភាព ឬក៏ហេតុផលដទៃទៀតដែលប្រហែលជារារាំងបុរសម្នាក់ពីការផ្គត់ផ្គង់គ្រួសាររបស់គាត់។ នាងគួរតែដឹងថា ជាញឹកញយ មានលក្ខណសម្បត្តិដែលរារាំងបុរសម្នាក់ពីការចូលខ្លួនមក និងបង្កើតជីវិតមួយសម្រាប់ខ្លួនគាត់ និងភរិយារបស់គាត់។

**ចូរធ្វើវាចុះ**

រឿងចុងក្រោយដែលខ្ញុំនឹងនិយាយ គឺត្រង់កន្លែងដែលខ្ញុំចាប់ផ្ដើម។ ប្រសិនបើមានភាពចាស់ទុំ  ប្រសិនបើមានសេចក្ដីស្រឡាញ់ជ្រាលជ្រៅ ប្រសិនបើមានការគាំទ្រពីសហគមន៍ និងគ្រួសារ ប្រហែលខ្ញុំនឹងនិយាយថា៖ «ចូរធ្វើវាចុះ»។ មនុស្សពីរនាក់អាចរស់នៅដោយចំណាយតិចជាងការរស់នៅឆ្ងាយពីគ្នា។ អាពាហ៍ពិពាហ៍នៅជាចំណុចល្អបំផុត នៅក្នុងការជួយយើងនៅក្នុងគ្រាដ៏លំបាកទាំងឡាយ មិនមែនជាអ្វីដែលត្រូវបានបដិសេធដោយសារតែគ្រាលំបាកទាំងឡាយនោះទេ។

ខ្ញុំនៅចងចាំថា វាមានអ្វីខ្លះកើតឡើងសម្រាប់ខ្ញុំ និងប្រពន្ធរបស់ខ្ញុំ—កាលនោះ ខ្ញុំត្រៀមខ្លួនរួចរាល់ ដើម្បីរៀបការលឿនជាង ពេលជាក់ស្ដែងដែលយើងបានរៀបការ។ ប្រសិនបើខ្ញុំត្រូវតែរៀបការសារជាថ្មី ខ្ញុំនឹងត្រូវរៀបការជាមួយប្រពន្ធខ្ញុំមុនហ្នឹងមួយឆ្នាំ លើកលែងតែឪពុករបស់ប្រពន្ធខ្ញុំ គាត់ចង់ឲ្យប្រពន្ធខ្ញុំបញ្ចប់ការសិក្សានៅមហាវិទ្យាល័យសិន មុនពេលឲ្យពួកយើងរៀបការជាមួយគ្នា។ ហើយយើងក៏អាចធ្វើវាបានដែរ។ យើងទាំងពីរនៅរៀនមហាវិទ្យាល័យ ប៉ុន្តែយើងក៏ដឹងថាយើងនៅអាចរកដំណោះស្រាយបានដែរ។

ដូច្នេះ ខ្ញុំមានទំនោរនៅក្នុងការនិយាយថា មានគុណវិបត្តិនៅក្នុងការស្រឡាញ់យ៉ាងជ្រាលជ្រៅពេក ការត្រៀមខ្លួននៅក្នុងការរៀបការនៅគ្រប់វិធី ប៉ុន្តែបញ្ហាហិរញ្ញវត្ថុនេះមិនអាចធ្វើឲ្យអាពាហ៍ពិពាហ៍ដំណើរការទៅមុខបាន—និងការល្បួងខាងផ្លូវភេទគឺជាបញ្ហាមួយនៅក្នុងចំណោមបញ្ហាទាំងនោះ ក៏ដូចជាការដែលរស់នៅក្នុងជីវិតមួយដែលខកចិត្តយ៉ាងខ្លាំង។ ខ្ញុំគិតថា ព្រះជាម្ចាស់ត្រាស់ហៅឲ្យគូរស្នេហ៍រីករាយក្នុងការតយុទ្ធមួយនេះជាមួយនឹងគ្នា ប្រសិនបើពួកគេមានភាពចាស់ទុំ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Are We Too Financially Unstable to Get Married?
**តើយើងមានអស្ថេរភាពខាងហិរញ្ញវត្ថុនៅក្នុងការរៀបការមែនទេ?**
https://www.desiringgod.org/interviews/are-we-too-financially-unstable-to-get-married



## សំណួរទី៣៩៖
# តើជារឿងសំខាន់ទេដែលយើងត្រូវទទួលបានការយល់ស្របពីឪពុកម្ដាយសម្រាប់អាពាហ៍ពិពាហ៍?

*«តើលោកគ្រូគិតថា វាជារឿងសំខាន់ដែរឬទេដែលកូនៗត្រូវទទួលបានការយល់ស្របពីឪពុកម្ដាយខ្លួនសម្រាប់ជម្រើសដៃគូរជីវិតអាពាហ៍ពិពាហ៍?»*

បាទ! សំខាន់ ប៉ុន្តែមិនចាំបាច់ទាំងស្រុងនោះទេ។

ខ្ញុំតែងតែផ្ដល់ប្រឹក្សាដល់អ្នកមានស្នេហាឲ្យមានការខិតខំប្រឹងប្រែងនៅក្នុងចំណុចនេះ។ សូមកុំគិតលើចំណុចនេះដោយមិនមានការយកចិត្តទុកដាក់ឡើយ។ ប្រសិនបើឪពុកម្ដាយខាងស្រី ឬក៏ខាងប្រុសកំពុងតែមានប្រសាសន៍ថា «យើងគិតថា នេះមិនមែនជាបុគ្គលសមនឹងកូនទេ»។ សូមកុំព្រងើយកន្ដើយនឹងពាក្យសម្ដីនេះ។ សូមផ្ដល់ឱកាសឲ្យមានពេលវេលា។ សូមអធិស្ឋានឲ្យមានការអស្ចារ្យនៃការផ្លាស់ប្រែ។ សូមនាំអ្នកដទៃឲ្យមានចំណែកដែរ។

និយាយម្យ៉ាងវិញទៀតទៅ ខ្ញុំមិនមែនកំពុងតែលើកឡើងថា នេះជាការចាំបាច់ទាំងស្រុងនោះទេ។ ពីមុននោះគឺជាការងាររបស់ឪពុកម្ដាយមែន។ ប៉ុន្តែ ឥឡូវនេះ ក្នុងនាមលោកអ្នកជាមនុស្សធំម្នាក់ក្រោមការដឹកនាំរបស់ព្រះជាម្ចាស់ ដោយសារលោកអ្នកជាមនុស្សពេញវ័យ នោះលោកអ្នកក៏មានទំនាក់ទំនងផ្ទាល់ខ្លួនរបស់លោកអ្នកដែរ ហើយលោកអ្នកក៏កំពុងតែហៀបនឹងបង្កើតគ្រួសារថ្មី ដែលជាពេលដែលលោកអ្នកចាកចេញពីឪពុកម្ដាយ ហើយចំណុចនេះគឺជាចំណុចចាំបាច់។ ខ្ញុំគ្រាន់តែកំពុងលើកឡើងថា វាពិតជាផ្អែមល្ហែមមែន។ ហើយវាក៏ពិតជាសំខាន់ណាស់ដែរ។

សូមគោរពប្រតិបត្តិដល់ឪពុកម្ដាយ ដោយស្ដាប់នូវអ្វីដែលគាត់កំពុងតែ

មានប្រសាសន៍ដោយយកចិត្តទុកដាក់។ សូមផ្តល់ឱកាសឲ្យមានពេលវេលាយ៉ាងយូរ។ ប៉ុន្តែ ខ្ញុំក៏មិនដឹងថា លោកអ្នកត្រូវតែផ្តល់ឱកាសយូរប៉ុណ្ណានោះដែរ។ សូមចំណាយពេលអធិស្ឋានឲ្យបានច្រើន។ ប៉ុន្តែ ខ្ញុំក៏មិនដឹងថា លោកអ្នកត្រូវតែអធិស្ឋានច្រើនប៉ុណ្ណាដែរ។ សូមនាំឲ្យអ្នកដទៃមានចំណែកក្នុងការព្យាយាមនាំឲ្យឪពុកម្តាយរបស់លោកអ្នកយល់ ទាក់ទងនឹងចំណុចនេះ។

សូមស្តាប់ឪពុកម្តាយ ហើយព្យាយាមយល់ថា «ទាក់ទងនឹងចំណុចនេះ តើព្រះជាម្ចាស់កំពុងតែមានព្រះបន្ទូលអំពីពេលវេលា ឬក៏អំពីបុគ្គល?» ហើយប្រសិនបើលោកអ្នកបានព្យាយាមយល់អស់រយៈពេលជាច្រើន ដោយមានការអធិស្ឋានជាច្រើន ហើយមានមនុស្សជាច្រើនបានព្យាយាមពន្យល់ថា ព្រះជាម្ចាស់គឺជាអង្គដែលបានរៀបចំបុគ្គលនេះសម្រាប់លោកអ្នក ហើយឪពុកម្តាយមិនបានយល់ ឬក៏បានមើលរំលងចំណុចនេះ—ពួកគាត់កំពុងតែយល់ស្ថានភាពខុស ពួកគាត់មិនដឹងថា បុគ្គលនេះពិតជាមានលក្ខណៈយ៉ាងដូចម្តេច ឬក៏ថាពួកគាត់កំពុងតែយល់ដោយមានទស្សនៈដែលមិនស្របតាមព្រះគម្ពីរ—ដូច្នេះ សូមបន្តព្យាយាមគោរពពួកគាត់តាមការនោះចុះ។ ប៉ុន្តែ ខ្ញុំគិតថា លោកអ្នកមិនចាំបាច់ចុះចូលក្រោមអំណាចរបស់ពួកគាត់ ក្នុងទំនាក់ទំនងជាបុគ្គលបែបមនុស្សធំម្នាក់នោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is It Important to Have Your Parents' Blessing in Marriage?
**តើជារឿងសំខាន់ទេដែលយើងត្រូវទទួលបានការយល់ស្របពីឪពុកម្តាយសម្រាប់អាពាហ៍ពិពាហ៍?**
https://www.desiringgod.org/interviews/
is-it-important-to-have-your-parents-blessing-in-marriage



# សំណួរទី៣៦៖
# តើទំនាក់ទំនងនៃការចែចង់របស់ខ្ញុំមានលក្ខណៈដូចការថ្វាយបង្គំរូបព្រះមែនឬ?

មានប្អូនម្នាក់ឈ្មោះ ណូរ៉ា បានផ្ញើសារសួរយើងដូចតទៅ *«ជម្រាបសួរលោកគ្រូ ខ្ញុំជាសិស្សថ្មីម្នាក់នៅសាកលវិទ្យាល័យមួយ ហើយខ្ញុំទើបតែចាប់ផ្តើមមានទំនាក់ទំនងថ្មីៗ។ យើងទាំងពីរនាក់ជាគ្រីស្ទបរិស័ទ ហើយយើងក៏ចង់ដាក់ព្រះអង្គនៅក្នុងចំណុចកណ្តាលនៃទំនាក់ទំនងរបស់យើងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំយល់ថា ខ្ញុំធ្វើឲ្យទំនាក់ទំនង និងមិត្តប្រុសរបស់ខ្ញុំក្លាយជារូបព្រះសម្រាប់ខ្ញុំ។ ខ្ញុំពឹងផ្អែកលើមិត្តប្រុសរបស់ខ្ញុំសម្រាប់ក្តីសុខ ហើយខ្ញុំគិតអំពីទំនាក់ទំនងរបស់យើងខ្លាំងជាងទំនាក់ទំនងរបស់ខ្ញុំជាមួយព្រះជាម្ចាស់។ តើខ្ញុំអាចជៀសឆ្ងាយពីការនេះបានដោយរបៀបណា? ហើយតើទំនាក់ទំនងនៃការឲ្យតម្លៃខ្លាំងពេកមានលក្ខណៈដូចម្តេចសម្រាប់អ្នកដែលទើបតែមានទំនាក់ទំនងថ្មីៗដូចជាទំនាក់ទំនងរបស់ខ្ញុំនេះ?»*

ល្អណាស់! ដែលពួកគាត់មានសេចក្តីប្រាថ្នាដូចគ្នាក្នុងការយកព្រះជាម្ចាស់ធ្វើជាចំណុចស្នូលក្នុងទំនាក់ទំនងរបស់ខ្លួន។ សម្រាប់ខ្ញុំ វាហាក់បីដូចជា ណូរ៉ា មានរូបភាពដ៏សំខាន់មួយនៅក្នុងគំនិតរបស់គាត់រួចទៅហើយ ដែលថា តើការថ្វាយបង្គំរូបព្រះមានលក្ខណៈដូចម្តេច ពីព្រោះគាត់គិតថា គាត់កំពុងតែនៅក្នុងទំនាក់ទំនងនោះ ហើយយ៉ាងហោចណាស់ក៏នៅក្នុងកម្រិតណាមួយដែរ។ ខ្ញុំគិតថា គាត់កំពុងតែព្យាយាមយ៉ាងស្មោះត្រង់នៅទីនេះ ប៉ុន្តែដួងចិត្តរបស់គាត់កំពុងតែប្រឆាំងនឹងការនេះ ដែលនោះជាសញ្ញាសម្គាល់ដ៏ល្អមួយ។

ខ្ញុំគិតថា វាអាចនឹងជាជំនួយបន្ថែមទៀតសម្រាប់ខ្ញុំចំពោះ ណូរ៉ា ក្នុងការ

ពណ៌នាអំពីលក្ខណៈវិជ្ជមានមួយបែបទៀតទាក់ទងនិងការថ្វាយបង្គំរូបព្រះនៅក្នុងទំនាក់ទំនងថ្មីៗ ដើម្បីឲ្យនាងបានដឹងថា ការថ្វាយបង្គំរូបព្រះផ្ទុយពីការទាំងនេះ ហើយដើម្បីឲ្យនាងអាចនឹងដាក់កម្លាំងរបស់ខ្លួនមិនច្រើនពេកក្នុងការជៀសវាងលើអ្វីមួយ ដូចជាសង្វាតស្វែងរកអ្វីមួយផ្សេងទៀតឡើយ។ នេះគឺជារបៀបដែលខ្ញុំនឹងលើកឡើង។ សម្រាប់ខ្ញុំ ហាក់បីដូចជាយ៉ាងហោចណាស់ក៏មានបីចំណុចដែល ណូរ៉ា អាចគិតអំពីរបៀបវ៉ូមែនទិចថ្មីរបស់គាត់ទាក់ទងជាមួយនឹងទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះយេស៊ូវ។

ទី១ នាងអាចគិតអំពីវាបែបជាការប្រៀបធៀប។ តើសេចក្ដីស្រឡាញ់របស់នាងចំពោះមិត្តប្រុសមានកម្រិតយ៉ាងដូចម្ដេចទៅនឹងសេចក្ដីស្រឡាញ់របស់នាងសម្រាប់ព្រះគ្រីស្ទ? នាងដូចជាបានគិតក្នុងរបៀបនោះរួចហើយ។ ទី២ នាងអាចគិតអំពីទំនាក់ទំនងរបស់នាងចំពោះបុរសម្នាក់នេះថាជាការបង្ហាញអំពីទំនាក់ទំនងរបស់នាងជាមួយព្រះយេស៊ូវ។ ហើយទី៣ នាងអាចចាត់ទុកភាពរ៉ូមែនទិកថ្មីរបស់នាងក្នុងរបៀបមួយដែលផ្ដល់ជាកម្លាំង ឬក៏ស្អាងទំនាក់ទំនងរបស់នាងជាមួយព្រះយេស៊ូវវិញ។ ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវចំណុចទាំងបីនោះម្ដងមួយៗ ហើយចង្អុលបង្ហាញទៅកាន់បទគម្ពីរ និងរបៀបដែលនាងអាចគិតអំពីចំណុចទាំងនោះ។

១) ព្រះគម្ពីរមានលើកឡើងអំពីទំនាក់ទំនងរបស់យើងថាជាការល្អ ឬបុគ្គលល្អដែលព្រះជាម្ចាស់បានបង្កើតមកដែលក្នុងរបៀបមួយហាក់បីដូចជារបស់ទាំងនោះមិនអាចប្រៀបធៀបជាមួយព្រះអង្គបានឡើយ។ ប៉ុន្តែ ព្រះគម្ពីរបានលើកឡើងជាការប្រៀបធៀប។ នោះទាក់ទងទៅនឹងតម្លៃដែលគ្មានដែនកំណត់របស់ព្រះយេស៊ូវ ជាតម្លៃដែលការផ្សេងៗ ឬក៏មនុស្សដទៃទៀតប្រៀបដូចជាគ្មានតម្លៃអ្វីទាល់តែសោះ។ ឧទាហរណ៍ អ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ៧៣:២៥-២៦ បានលើកឡើងថា «ឯនៅស្ថានសួគ៌ តើទូលបង្គំមានអ្នកឯណាក្រៅពីទ្រង់ ហើយនៅផែនដីទូលបង្គំប្រាថ្នាចង់បានតែទ្រង់ទេ»។



នាងស្រឡាញ់មិត្តប្រុសរបស់ខ្លួន។ «នៅផែនដីទូលបង្គំប្រាថ្នាចង់បានតែទ្រង់ទេ ឯសាច់ នឹងចិត្តទូលបង្គំ នោះនឹងសាបសូន្យទៅបាន ប៉ុន្តែព្រះទ្រង់ជាទីពឹងនៃចិត្ត ហើយជាចំណែកមរដកនៃទូលបង្គំជាដរាបដែរ»។ ឬក៏នេះជារបៀបដែលសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ភីលីព ៣:៨ «ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ»—ក៏មានរួមបញ្ចូលទាំងមិត្តប្រុសដែរ—«ដោយព្រោះសេចក្ដីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ» វិញ។

ឥឡូវនេះ ដោយសារយើងដឹងចេញពីការផ្សេងៗដែលអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង និងពីសាវ័ក ប៉ុល បានលើកឡើងដែលការល្អដែលព្រះជាម្ចាស់បង្កើតមក ដូចជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ជាដើម យើងឃើញថាទាំងអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង និងសាវ័ក ប៉ុល បានលើកឡើងថាពួកគាត់រកបានអំណរដ៏អស្ចារ្យនៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ១៦:៣ និងកណ្ឌគម្ពីរ ភីលីព ៤:១ ហើយទាំងអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង និងសាវ័ក ប៉ុល ក៏និយាយអំពីប្រជារាស្ត្ររបស់ព្រះជាម្ចាស់ថាជាអំណរដ៏អស្ចារ្យដល់ពួកគាត់ដែរ។ ដូច្នេះ ពួកគាត់មិនមែនគ្មានតម្លៃអ្វីសោះនោះទេ។ ពួកគាត់គឺជាអំណរដ៏អស្ចារ្យ។

ហើយយើងក៏បានដឹងចេញពីប្រយោគដែលថា ការបង្កើតរបស់ព្រះជាម្ចាស់គឺមិនបានរាប់ថាជាគ្មានតម្លៃ ឬគ្រាន់តែជាឱកាសក្នុងការថ្វាយបង្គំរូបព្រះនោះទេ ប៉ុន្តែជាការល្បងលនូវភាពស្មោះត្រង់របស់យើង។ ហើយការល្បងលនោះគឺថា៖ តើយើងនៅតែអាចនិយាយជាមួយអ្នកដែលបានសរសេរព្រះគម្ពីរបានដែរឬទេដោយថា ទោះប្រសិនបើខ្ញុំបានបាត់បង់អ្វីៗទាំងអស់ក៏ដោយក៏ព្រះជាម្ចាស់នៅតែជាសេចក្ដីអំណរដ៏ល្អមរបស់ខ្ញុំដ៏នៅអស់កល្បជានិច្ចដែរឬទេ? នោះគឺជាគំនិតប្រៀបធៀប។ ដូច្នេះ នាងអាចមើលឃើញទំនាក់ទំនងមួយនេះថាជាការប្រៀបធៀប ហើយនោះគឺជាការមួយដែលនាង

មានបញ្ហាជាមួយ។ ដូច្នេះ ប្រហែលជាចំណុចពីរបន្ទាប់នេះនឹងជួយនាងក្នុងការគ្រប់គ្រងចំណុចមួយនោះបានប្រសើរជាងមុន។

២) ណូរ៉ា គួរតែបណ្ដុះទំនាក់ទំនងថ្មីនេះជាមួយបុរសថ្មីនេះថាជាការបង្ហាញអំពីទំនាក់ទំនងរបស់នាងជាមួយនឹងព្រះយេស៊ូវ—ជារបៀបនៃការប្រព្រឹត្តចេញ ឬបង្ហាញទំនាក់ទំនងរបស់នាងជាមួយព្រះយេស៊ូវ មិនមែនគ្រាន់តែជាការគម្រាមកំហែងចំពោះទំនាក់ទំនងរបស់នាងជាមួយព្រះយេស៊ូវ ឬក៏ជាការប្រកួតប្រជែងជាមួយទំនាក់ទំនងនេះនោះទេ។ ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរអេភេសូរ ជំពូក៥ បានពណ៌នាអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីទុកដូចជារឿងល្ខោន ឬក៏ជារូបភាពដែលបង្ហាញអំពីទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំអញ្ចឹងដែរ។

ឥឡូវនេះ ការនោះបានផ្លាស់ប្ដូរយ៉ាងខ្លាំងក្នុងរបៀបដែលបុរស និងស្ត្រីគិតអំពីទំនាក់ទំនងរបស់ពួកគេ។ វាមិនមែនគ្រាន់តែជារឿងអំពីពួកគេនោះទេ។ វាជាការបង្ហាញបុរសនោះអំពីទំនាក់ទំនងនៃសេចក្ដីតាំងសញ្ញារបស់ព្រះគ្រីស្ទចំពោះកូនក្រមុំ និងក្រុមជំនុំទ្រង់។ ហេតុដូច្នេះហើយ សេចក្ដីស្រឡាញ់យ៉ាងធំធេងដែលស្ត្រីមានចំពោះបុរស ឬក៏បុរសមានចំពោះស្ត្រីអាច និងគួរតែបញ្ចូលទៅក្នុងបទចម្រៀងនៃសាច់រឿងដ៏អស្ចារ្យមួយ ដើម្បីឲ្យកម្លាំងនៃអារម្មណ៍សម្រាប់បុគ្គលនោះគឺមិនផ្ទុយគ្នាពីអារម្មណ៍ដែលមានសម្រាប់ព្រះយេស៊ូវឡើយ ប៉ុន្តែជាការបង្ហាញអារម្មណ៍សម្រាប់ព្រះយេស៊ូវវិញ។

ដូច្នេះ នេះគឺជាគោលការណ៍ដែលសាវ័ក ប៉ុល បានកត់ចុះនៅក្នុងកណ្ឌគម្ពីរ កាឡាទី ៥:៦។ គាត់បានលើកឡើងថា «ពីព្រោះក្នុងព្រះគ្រីស្ទយេស៊ូវ ដែលកាត់ស្បែកឬមិនកាត់ នោះមិនជាប្រយោជន៍អ្វីទេ មានប្រយោជន៍តែសេចក្ដីជំនឿ ដែលប្រព្រឹត្តដោយសេចក្ដីស្រឡាញ់ប៉ុណ្ណោះ»។ និយាយម្យ៉ាងវិញទៀត សេចក្ដីជំនឿមិនកើតមានឡើងដោយឯងៗនៅឯខាងវិញ្ញាណនោះទេ។ សេចក្ដីជំនឿបង្ហាញខ្លួនឯងផ្ទាល់។ សេចក្ដីជំនឿបង្ហាញខ្លួនឯងផ្ទាល់តែម្ដង។ ហើយរបៀបនៃមូលដ្ឋានគ្រឹះដែលជំនឿសបញ្ជាក់ ឬក៏បង្ហាញខ្លួនផ្ទាល់នោះគឺនៅក្នុងផលផ្លែនៃសេចក្ដីស្រឡាញ់ «សេចក្ដីជំនឿ ដែលប្រព្រឹត្តដោយសេចក្ដីស្រឡាញ់ប៉ុណ្ណោះ»។ ដូច្នេះ ណូរ៉ា គួរតែសួរខ្លួនឯងផ្ទាល់ថា៖ «ខណៈពេលដែលខ្ញុំស្រឡាញ់មិត្តប្រុសរបស់ខ្ញុំ តើការនោះគ្រាន់តែកំពុងប្រកួតប្រជែងជាមួយសេចក្ដីជំនឿរបស់ខ្ញុំក្នុងព្រះយេស៊ូវ ឬក៏វាជាការបង្ហាញសេចក្ដីជំនឿរបស់ខ្ញុំនៅក្នុងព្រះយេស៊ូវ?»។

៣) ដែលជាចំណុចចុងក្រោយ និងជារបៀបក្នុងការពិនិត្យមើលទំនាក់ទំនងរបស់នាងជាមួយនឹងបុរសនោះគឺ៖ តើទំនាក់ទំនងមួយនេះកំពុងតែផ្ដល់ជាកម្លាំង និងស្អាងសេចក្ដីជំនឿរបស់នាង និងបុរសនោះដែរឬទេ? ជាទូទៅ នៅពេលដែលព្រះគម្ពីរបានរៀបរាប់អំពីទំនាក់ទំនង គឺព្រះគម្ពីរប្រើប្រាស់គោលការណ៍មួយនេះ៖ «ត្រូវឲ្យធ្វើការទាំងអស់ សម្រាប់នឹងស្អាងចិត្តឡើង» (១កូរិនថូស ១៤:២៦)។ នោះគឺជាអត្ថន័យក្នុងការមានទំនាក់ទំនង។ ចូរឲ្យអ្វីៗគ្រប់យ៉ាងសម្រាប់ជាការស្អាងចិត្តគ្នាឡើងចុះ។ ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ៣:១៣ មានចែងថា «តែចូរកំឡាចិត្តគ្នាទៅវិញទៅមកជារាល់ថ្ងៃវិញ ក្នុងកាលដែលនៅតែហៅថា "ថ្ងៃនេះ" នៅឡើយ ក្រែងអ្នករាល់គ្នាណាមួយមានចិត្តរឹងរូស ដោយសេចក្ដីបញ្ឆោតរបស់អំពើបាប»។ ដូច្នេះគោលបំណងនៃទំនាក់ទំនងគឺថា វានឹងបំពេញសេចក្ដីជំនឿ និងបំពេញភាពបរិសុទ្ធ—បំពេញក្នុងការយកឈ្នះលើអំពើបាប។

សំណួរសម្រាប់ ណូរ៉ា គឺថា៖ តើទំនាក់ទំនងថ្មីនេះដំណើរការទៅមុខដែរឬទេ? តើវាមានឥទ្ធិពលក្នុងការស្អាងចិត្តខ្ញុំ និងបុរសនោះនៅក្នុងសេចក្ដីជំនឿរបស់ខ្លួនដែរឬទេ? តើពួកយើងបានទុកចិត្តព្រះជាម្ចាស់ជាងមុនដែរឬទេ? តើពួកយើងបានស្រឡាញ់ព្រះជាម្ចាស់ជាងមុនដែរឬទេ? តើជីវិតរបស់ពួកយើងត្រូវបានកត់សម្គាល់ក្នុងការប្រាថ្នាចង់បានភាពបរិសុទ្ធកាន់តែច្រើន

ឡើង ដោយសារតែអ្វីដែលយើងកំពុងតែស្វែងរកក្នុងគ្នាទៅវិញទៅមកដែរឬទេ? តើវាជាការជួយធ្វើឲ្យសេចក្តីស្រឡាញ់របស់យើងសម្រាប់ព្រះគ្រីស្ទកាន់តែខ្លាំងជាងមុន ឬក៏ធ្វើឲ្យយើងកាន់តែខ្សោយជាងមុន?

ដូច្នេះ នេះគឺជាសេចក្តីសង្ខេប។ ប្អូន ណូរ៉ា អើយ! ចូរដេញតាមទំនាក់ទំនងនៅក្នុងរបៀបបីនេះ៖ ទី១ ចូរដេញតាមវាថាជាការដែលល្អ ដែលនោះជាការប្រៀបធៀបទៅកាន់ការដ៏គ្មានដែនកំណត់គឺជាភាពគ្មានអ្វីៗទាំងអស់។ ទី២ ចូរដេញតាមវាទុកជាការបង្ហាញសេចក្តីជំនឿរបស់ប្អូននៅក្នុងព្រះយេស៊ូវ មិនមែនជាការប្រកួតប្រជែងជាមួយសេចក្តីជំនឿរបស់ប្អូននៅក្នុងព្រះយេស៊ូវនោះទេ។ ចូរស្វែងរករបៀបក្នុងការបង្ហាញសេចក្តីជំនឿរបស់ប្អូននៅក្នុងទំនាក់ទំនងមួយនេះ។ ទី៣ ចូរដេញតាមវានៅក្នុងអត្ថន័យមួយដែលធ្វើឲ្យយើងចម្រើនកម្លាំង និងស្អាងចិត្តគ្នានៅក្នុងសេចក្តីជំនឿរបស់ប្អូន និងជំនឿរបស់គាត់ មិនមែនធ្វើឲ្យកាន់តែខ្សោយនោះទេ។ ហើយប្រសិនបើប្អូនដឹងអំពីចំណុចទាំងបីនេះហើយ ខ្ញុំគិតថាព្រះអម្ចាស់កំពុងតែរក្សាប្អូនចេញពីការមានទំនាក់ទំនងក្នុងលក្ខណៈជាការថ្វាយបង្គំរូបព្រះចេញហើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is My Dating Relationship Idolatrous?
**តើទំនាក់ទំនងនៃការចែចង់របស់ខ្ញុំមានលក្ខណៈដូចការថ្វាយបង្គំរូបព្រះមែនឬ?**
https://www.desiringgod.org/interviews/is-my-dating-relationship-idolatrous



# សំណួរទី៣៧៖
# តើមិត្តប្រុសរបស់អ្នកមានភាពចាស់ទុំគ្រប់គ្រាន់ឬនៅសម្រាប់អ្នក?

សំណួរទី១៖ ជាការពិតណាស់ ព្រះគម្ពីរបង្គាប់ឲ្យគ្រីស្ទបរិស័ទរៀបការ «ក្នុងព្រះអម្ចាស់» ដែលនោះមានន័យថា រៀបការជាមួយគ្រីស្ទបរិស័ទផ្សេងទៀត។ ប៉ុន្តែ សព្វថ្ងៃនេះ ដោយសារគេងាយទទួលស្គាល់អ្នកដែលថាខ្លួនជាគ្រីស្ទបរិស័ទ ជាគ្រីស្ទបរិស័ទលឿនពេក ដូច្នេះយើងងាយនឹងកត់សម្គាល់អំពីការលូតលាស់ខាងឯវិញ្ញាណដែលថា៖ បុរស និងស្ត្រីគួរមានលក្ខណៈយ៉ាងដូចម្តេចទើបអាចធ្វើជាប្តី ឬប្រពន្ធបាន។

ជាការពិតណាស់ ខ្ញុំគិតថាអ្វីដែលលោកអ្នកកំពុងស្វែងរកគឺជាភាពម៉ត់ចត់មួយអំពីការលូតលាស់នៅក្នុងសេចក្តីជំនឿរបស់បុគ្គលណាម្នាក់។

## ការលូតលាស់ក្នុងការគោរពកោតខ្លាចព្រះ

ខ្ញុំគិតថារបៀបដែលក្រុមជំនុំពិតជាអាចបម្រើដល់ និងជួយដល់គ្រីស្ទបរិស័ទនៅលីវបាន ក្នុងការគិតពិចារណាអំពីចំណងអាពាហ៍ពិពាហ៍ និងការចែចង់បានគឺថា នៅក្នុងសម្ពន្ធនៃសហគមន៍នៅក្នុងសេចក្តីជំនឿ បុគ្គលម្នាក់គួរតែស្គាល់ និងគួរតែមានអ្នកដទៃនៅជុំវិញពួកគាត់ដែលអាចនិយាយអំពីលក្ខណសម្បត្តិរបស់ពួកគាត់៖ មិនថាពួកគាត់កំពុងលូតលាស់នៅក្នុងព្រះអម្ចាស់ មិនថាពួកគាត់មានភាពម៉ត់ចត់អំពីការលូតលាស់នៅក្នុងព្រះអម្ចាស់ ឬក៏ថាតើពួកគាត់កំពុងសម្លាប់អំពីបាបនៅក្នុងជីវិតរបស់គាត់ឬក៏អត់។ នោះគឺជាអ្វីដែលលោកអ្នកគួរតែចង់ស្វែងយល់។ លោកអ្នកកំពុងសួរថា តើមានភាពម៉ត់ចត់នៅក្នុងបុគ្គលម្នាក់នេះក្នុងការលូតលាស់ក្នុងទំនាក់ទំនង ហើយ

ក្នុងការយល់ដឹងរបស់ពួកគាត់ជាមួយព្រះអម្ចាស់ដែរឬទេ?

ដោយសារអ្វីដែលខ្ញុំបានឃើញនោះគឺជារឿងសោកស្ដាយណាស់ត្រង់ថា គ្រីស្ទបរិស័ទនៅលីវ ពួកគេនឹងមកដល់ចំណុចមួយដែលត្រូវការខ្លាំង ជាពិសេសសម្រាប់ស្ត្រីវ័យក្មេង ហើយពួកគាត់នឹងលើកឡើងថា «មិនអីទេ គាត់ជាគ្រីស្ទបរិស័ទ គាត់ក៏មកព្រះវិហារដែរ»។ ហើយអ្វីដែលពួកគេកំពុងនិយាយនោះគឺថា ពួកគេមកព្រះវិហារតែពីរទៅបីដងក្នុងមួយខែ ប៉ុន្តែនៅពេលមិនមកថ្វាយបង្គំវិញ ពួកគេមិនមានភាពម៉ត់ចត់អំពីការលូតលាស់ក្នុងការយល់ដឹងពីព្រះអម្ចាស់ ឬការរីកចម្រើនក្នុងការយល់ដឹងពីព្រះគម្ពីរ ឬក៏ជាបុគ្គលដែលចំណាយពេលអធិស្ឋាននោះទេ។ មិនមានភាពរស់រាន ឬក៏ការស្ដាប់ពិតប្រាកដណាមួយដែលគេអាចរកឃើញក្នុងបុគ្គលបែបនេះ ហើយក៏គ្មាននរណាម្នាក់ស្គាល់ពួកគេគ្រប់គ្រាន់ក្នុងការនិយាយអំពីភាពរីកចម្រើននៅក្នុងអត្តចរិតរបស់ពួកគេបានឡើយ។

ដូច្នេះ ខ្ញុំគិតថា នេះគឺជាអ្វីដែលលោកអ្នកកំពុងស្វែងរក៖ តើបុគ្គលនោះមានភាពម៉ត់ចត់ណាមួយទាក់ទងនិងការលូតលាស់ក្នុងអ្វីដែលទាក់ទងនឹងព្រះអម្ចាស់ដែរឬទេ?

## ភាពជាសិស្សក្នុងសហគមន៍

ជាការអនុវត្ត៖ ពួកគាត់បានចូលរួមនៅក្នុងជីវិតរបស់ក្រុមជំនុំ។ ពួកគាត់បានស្វែងរកអ្នកដទៃ ដើម្បីនិយាយណែនាំមកកាន់ជីវិតរបស់ខ្លួន។ ពួកគាត់ទទួលបានការបង្រៀនក្នុងភាពជាសិស្ស មិនថាតាមរយៈខ្លួនឯង ឬក៏អ្នកដទៃនោះទេ។ ដូច្នេះ ពួកគាត់មានចំណែកក្នុងក្រុមជំនុំទាក់ទងនិងភាពជាសិស្ស ឬក៏ពួកគាត់អាចស្វែងរកអ្នកចាស់ទុំជាង ហើយអញ្ជើញគាត់ក្នុងការនិយាយណែនាំមកកាន់ជីវិតរបស់គាត់បានដែរ។

ហើយខ្ញុំគិតថា ប្រសិនបើពួកគាត់មានចំណែកដូចដែលបានលើកឡើងខាងលើ នោះជារង្វាស់ដែលមានសុវត្ថិភាពជាងដែលថា ពួកគាត់គូសចំណាំលើព្រះគម្ពីរ ការស្គាល់ព្រះគម្ពីរ ឬក៏ការដែលលោកអ្នកឃើញពួកគាត់នៅពេលថ្វាយបង្គំរៀងរាល់សប្ដាហ៍ទៀតផង។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is Your Boyfriend Mature Enough for You?
**តើមិត្តប្រុសរបស់អ្នកមានភាពចាស់ទុំគ្រប់គ្រាន់ឬនៅសម្រាប់អ្នក?**
https://www.desiringgod.org/interviews/is-your-boyfriend-mature-enough-for-you

## សំណួរទី៣៨៖
# បែបបទនៃការចែចង់គ្នា ដោយមានការពឹងអាងលើ

យើងលើកឡើងអំពីការច្រណែនគ្នាក្នុងទំនាក់ទំនងស្នេហា។ ប៉ុន្តែ យើងពិតជាមិនដែលបាននិយាយអំពីបែបបទនៃចែចង់គ្នាដោយមានការពឹងលើនោះទេ។ ប្រធានបទនោះក៏សំខាន់ផងដែរ។ សំណួរបានមករកយើងពីយុវជនម្នាក់មិនបានផ្តល់ឈ្មោះឲ្យយើង។ «ជម្រាបសួរគ្រូ ខ្ញុំសូមអរគុណលោកគ្រូសម្រាប់ការឆ្លើយសំណួររបស់លោកគ្រូផងដែរ។ ខ្ញុំមានទំនាក់ទំនងស្នេហាដល់កម្រិតដែលមិត្តស្រីរបស់ខ្ញុំបានមកពឹងលើខ្ញុំចំពោះអ្វីដែលខ្ញុំមានអារម្មណ៍ថា មិនជាសុខភាពល្អ។ គាត់ចំណាយពេលតិចទៅៗជាមួយមិត្តភក្តិរបស់គាត់ សូម្បីតែតិចទៅៗជាមួយគ្រួសាររបស់គាត់ ហើយបានកាន់តែពឹងផ្អែកលើខ្ញុំជាទំនាក់ទំនងតែមួយគត់របស់គាត់វិញ។ នេះហាក់ដូចជាមិនមានសុខភាពល្អទេចំពោះខ្ញុំ។ តើមែនទេ? ហើយតើខ្ញុំគួរធ្វើដូចម្តេច?

ទោះបីជាបុរសវ័យក្មេងនេះ មិនបាននិយាយឲ្យចំៗក៏ដោយក៏ខ្ញុំនឹងសន្មតថា ផ្នែកនៃអ្វីដែលនៅពីក្រោយសំណួរនេះគឺការរំពឹងទុកនៃអាពាហ៍ពិពាហ៍ ហើយការបារម្ភថាស្ត្រីដែលពឹងផ្អែកខ្លាំងពេកលើគាត់ម្នាក់នេះអាចខ្លាំងជាងមុនចំពោះអ្វីដែលគាត់នឹងក្លាយទៅជា ក្នុងនាមជាភរិយា និងជាដៃគូអស់មួយជីវិត។

### ឫសគល់ជ្រៅសម្រាប់កិច្ចព្រមព្រៀងពេញមួយជីវិត

ជីវិតអាពាហ៍ពិពាហ៍មិនមែនជាការពិសោធន៍នោះទេ វាជាកិច្ចសន្យាពេញមួយជីវិត។ ជាការល្អដែលមានពាក្យសច្ចានៅពេលរៀបការ តាមប្រពៃណីដោយមានឃ្លាថា «ដរាបណាយើងទាំងពីរនៅរស់» ឬ «ដរាបណាយើងចែកផ្លូវគ្នា»។ ការសន្យាបែបនោះមានឫសគល់តាមព្រះគម្ពីរ គឺ

ត្រឹមត្រូវ។ យើងគួរតែសន្យាបែបនោះនៅក្នុងកម្មពិធីអាពាហ៍ពិពាហ៍របស់យើង។ ដូច្នេះ បុរស និងស្ត្រីគ្រប់រូបដែលកំពុងសញ្ជឹងគិតអំពីសេចក្ដីតាំងសញ្ញាពេញមួយជីវិតបែបនេះគួរតែស្វែងរកភស្តុតាងនៃជំនឿដែលមិនអាចរង្គោះរង្គើលើព្រះគ្រីស្ទ និងមានឫសគល់ជ្រៅនៃចរិតលក្ខណៈ និងកម្លាំងរបស់គ្រីស្ទបរិស័ទដែលគាត់កំពុងសញ្ជឹងគិតអំពី។

ជាការពិតណាស់ គ្មាននរណាម្នាក់ជាចៅក្រមអាចកាត់ថ្លៃបានលើសេចក្តីជំនឿ និងចរិតលក្ខណៈនោះទេ លើកលែងតែព្រះជាម្ចាស់។ នោះហើយជាមូលហេតុដែលបុរសគ្រីស្ទបរិស័ទ និងស្ត្រីគ្រីស្ទបរិស័ទគួរតែអធិស្ឋានដោយស្មោះ ដោយទូលសូមឲ្យព្រះជាម្ចាស់ការពារពួកគេចេញពីការរៀបការជាមួយនឹងនរណាម្នាក់ដែលនឹងបំផ្លាញអាពាហ៍ពិពាហ៍ ឬនរណាម្នាក់ដែលនឹងធ្វើឲ្យទំនាក់ទំនងនេះបង្អាប់ដល់ព្រះគ្រីស្ទ។ ដូច្នេះ យុវជនដែលសួរសំណួរនេះគឺដាក់ម្រាមដៃលើលក្ខណៈវិនិច្ឆ័យដែលយើងគួររកមើលនៅពេលចែចង់នរណាម្នាក់ដែលអាចក្លាយជាប្ដីឬប្រពន្ធរបស់ខ្លួន។ គាត់កំពុងដាក់ម្រាមដៃលើអ្វីដែលយើងអាចហៅថា ភាពខ្វះខាតរបស់យុវនារីនេះ។

## ៥សំណួរ ដើម្បីវាយតម្លៃទៅលើការចែចង់ដោយមានការពឹងលើ

តាមពិតទៅ ខ្ញុំគ្មានសិទ្ធិវិនិច្ឆ័យលើបញ្ហារបស់ស្ត្រីម្នាក់នេះដែលគាត់កំពុងនិយាយនោះទេ។ ខ្ញុំដឹងតិចតួចអំពីគាត់ ហើយមានកត្តាជាច្រើនដែលអាចកំណត់អាកប្បកិរិយារបស់គាត់។ ខ្ញុំនឹងល្ងង់ណាស់ក្នុងការកាត់ទោសគាត់។ ដូច្នេះ ខ្ញុំនឹងគ្រាន់តែនិយាយបែបទូទៅអំពីអ្វីដែលគាត់គួរតែស្វែងរកជាពិសេសទាក់ទងនឹងតម្រូវការខាងវិញ្ញាណ ឬផ្លូវចិត្ត ឬក៏អ្វីដែលគាត់ចង់សំដៅលើដែលខ្ញុំគិតថាជាការពឹងលើ។

ខ្ញុំមានសំណួមពរប្រាំយ៉ាងដោយផ្អែកលើខគម្ពីរទាំងប្រាំ ហើយដោយសារបុរសដែលជាអ្នកបានសួរអំពីស្ត្រីដែលគាត់កំពុងតែចែចង់ នោះខ្ញុំនឹងប្រាប់ជាការផ្ដល់យោបល់ទាំងនេះទាក់ទងនឹងប្រភេទស្ត្រីដែលគាត់គួរស្វែងរក ទោះបីជានៅក្នុងចំណុចទាំងប្រាំនេះជាអ្វីដែលខ្ញុំគិតថា មនុស្សស្រីក៏គួរតែស្វែងរកក្នុងមនុស្សបុរសដែរ។

### ១.តើព្រះយេស៊ូវមានតម្លៃបំផុតសម្រាប់គាត់ឬ?

តើគាត់ឲ្យតម្លៃលើព្រះយេស៊ូវ និងទំនាក់ទំនងរបស់គាត់ជាមួយព្រះយេស៊ូវថា មានតម្លៃជាងទំនាក់ទំនងណាផ្សេងទៀតដែលគាត់មានដែរឬទេ?

«ប៉ុន្តែ សេចក្តីអ្វីដែលមានប្រយោជន៍ដល់ខ្ញុំពីមុន នោះខ្ញុំបានរាប់ជាខាតវិញ ដោយព្រោះព្រះគ្រីស្ទ។ ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេចក្តីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ» (ភីលីព ៣:៧-៨)។

នេះគឺជាសំណួរដ៏សំខាន់បំផុត។ តើក្មួយអាចដឹងថា ក្មួយជាអ្នកលេខពីរក្នុងជីវិតរបស់គាត់ ហើយមិនមែនជាលេខមួយបានទេ? តើក្មួយអាចយល់ឃើញថា គាត់នឹងរីករាយដែលក្មួយជាប់ជាលេខពីរក្នុងជីវិតរបស់គាត់ ហើយមិនមែនជាលេខមួយដែរទេ? ប្រសិនបើឧត្តមភាពរបស់ព្រះគ្រីស្ទមិនស្ថិតស្ថេរ នោះគ្មានអ្វីផ្សេងទៀតនៅក្នុងទំនាក់ទំនងនេះដែលនឹងនៅកន្លែងដ៏ត្រឹមត្រូវបានទេ។

### ២. តើព្រះគ្រីស្ទធ្វើឲ្យគាត់មានស្ថេរភាពដែរឬទេ?

តើព្រះគ្រីស្ទបានក្លាយជាអ្នកផ្ដល់ក្ដីសង្ឃឹម ហើយមានស្ថេរភាព និងពេញចិត្តចំពោះគាត់ដែលក្មួយអាចមើលឃើញថា តើកម្លាំង និងអត្តសញ្ញាណរបស់គាត់ និងស្ថេរភាពរបស់គាត់ត្រូវបានបំផ្លាញចោល ឬក៏អត់ដោយសារចំណុចទាប និងចំណុចខ្ពស់នៃជីវិតរបស់គាត់ដែរឬទេ?

«ខ្ញុំនិយាយដូច្នេះ មិនមែនដោយខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំបានរៀនឲ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង។ ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ។ ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បានដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ» (ភីលីព ៤:១១-១៣)។

តើគាត់បានរៀនអំពីចំណុចនេះហើយឬនៅ? តើក្មួយបានឃើញកម្លាំងពីខាងក្នុងបែបនេះកើតចេញពីសេចក្តីជំនឿរបស់គាត់លើព្រះគ្រីស្ទ ដល់ថ្នាក់ថាគាត់នៅអាចមានដំណើរការ និងបង្កើតផ្លែផ្កាក្នុងនាមជាមនុស្សក្នុងគ្រាដ៏ល្អបំផុត និងគ្រាដ៏អាក្រក់បំផុតបានដែរឬទេ?

## ៣. តើគាត់គោរពឲ្យតម្លៃក្មួយដែរឬទេ?

វាមិនមែនតែបែបជាជំនឿគ្រីស្ទបរិស័ទទេ—យើងគ្រាន់តែត្រូវទទួលស្គាល់ចំណុចនេះថា—សម្រាប់ឲ្យមនុស្សម្នាក់ (ដែលមានជំនឿលើព្រះគ្រីស្ទ) មានអារម្មណ៍ថា ខ្លួនត្រូវការមនុស្សម្នាក់ទៀត។ មានសេចក្តីត្រូវការក្នុងគម្ពីរមួយប្រភេទដែលមិនដូចគ្នាទៅនឹងសេចក្តីត្រូវការបែបនោះ។ តើគាត់មានតម្រូវការសម្រាប់ក្មួយ ដែលនៅឫសគល់នោះ ដែលមានសមត្ថភាពគោរពក្មួយ មិនមែនប្រើប្រាស់ក្មួយដែរឬទេ?

នេះជាកន្លែងដែលខ្ញុំទទួលបានគំនិតនោះ។ សូមពិចារណាអំពីរបៀបដ៏ពិសេសដែលសាវ័ក ប៉ុល បានប្រកែកនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១២:២១-២៣។ ក្នុងការពណ៌នាអំពីទំនាក់ទំនងរវាងគ្រីស្ទបរិស័ទក្នុងរូបកាយរបស់ព្រះគ្រីស្ទ គាត់បានមានប្រសាសន៍ថា៖ «ហើយភ្នែកពុំអាចនិយាយទៅដៃថា "អញមិនត្រូវការនឹងឯងទេ"»។ ផ្ទុយទៅវិញ ផ្នែកនៃរាងកាយដែលហាក់ដូចជាទន់ខ្សោយគឺមិនអាចខ្វះបាន ហើយចំពោះផ្នែកនៃរាងកាយដែលយើងគិតថា មិនសូវមានកិត្តិយស នោះយើងផ្តល់កិត្តិយស



ឲ្យច្រើនជាង។

ម្យ៉ាងទៀត គាត់បានបកស្រាយអំពីតម្រូវការដែលអវយវៈក្នុងខ្លួនមានចំពោះអវយវៈផ្សេងទៀតថាជាតម្រូវការដែលផ្តល់កិត្តិយសដល់អវយវៈផ្សេងទៀត។ នោះពិតជាចម្លែក និងអស្ចារ្យណាស់។ នោះក៏ជាតម្រូវការមិនធម្មតាដែរ។ ដូច្នេះ សំណួរសម្រាប់បុរសនេះគឺថា តើតម្រូវការរបស់យុវនារីនេះសម្រាប់គាត់ជាតម្រូវការដូចដែលសាវ័ក ប៉ុល កំពុងនិយាយដែរឬទេ? តើវាមានសមត្ថភាព និងការប្តេជ្ញាចិត្តក្នុងការមិនធ្វើស៊ីគាត់ដោយការមានពេញទៅដោយតម្រូវការ ប៉ុន្តែជាការផ្តល់កិត្តិយសដល់គាត់វិញដែរឬទេ?

## ៤. តើគាត់ទ្រាំទ្រនឹងព្រះគ្រីស្ទដែរឬទេ?

តើគាត់មានចិត្តស្ងប់ និងភាពរឹងប៉ឹងដើម្បីកុំឲ្យសេចក្តីអំណររបស់គាត់ក្នុងព្រះគ្រីស្ទត្រូវបានបំផ្លាញចោល បើមានគេបដិសេធគាត់ដែរឬទេ?

មានពរហើយ កាលណាមនុស្សនឹងស្អប់អ្នករាល់គ្នា ព្រមទាំងកាត់កាល់ ដៀលត្មះ...ទុកដូចជាអាក្រក់ដោយព្រោះកូនមនុស្ស។ ចូរអ្នករាល់គ្នាអរសប្បាយឡើងនៅថ្ងៃនោះ ហើយលោតកញ្ឆេងចុះ ដ្បិតមើល អ្នករាល់គ្នាមានរង្វាន់ជាយ៉ាងធំនៅឯស្ថានសួគ៌ ឯពួកឰយុកោរបស់គេ ក៏បានប្រព្រឹត្តចំពោះពួកហោរាពីដើមយ៉ាងដូច្នោះដែរ (លូកា ៦:២២-២៣)។

ម្យ៉ាងទៀត រង្វាន់យ៉ាងធំ មានស្ថិរភាព ចិត្តស្កប់ស្កល់ដល់ថ្នាក់ថា ការបដិសេធពីមនុស្សមិនធ្វើឲ្យយើងខូចចិត្តឡើយ។ តើក្មួយឃើញភស្តុតាងនៅក្នុងគាត់ត្រង់ថា គាត់នឹងឆ្លើយតបតាមរបៀបដែលសាវ័ក ប៉ុល បានធ្វើនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៤:១២-១៣ ដែរឬទេ? «កាលណាគេជេរ នោះយើងខ្ញុំឲ្យពរវិញ កាលណាគេបៀតបៀន នោះយើងខ្ញុំទ្រាំទ្រ កាលណាគេប្រមាថ នោះយើងខ្ញុំអង្វរដល់គេ»។ ឬក៏ តើក្មួយឃើញមានភស្តុតាងដែលថា ប្រសិនបើមានគេប្រព្រឹត្តបែបនោះដាក់គាត់ នោះគាត់នឹងមានអារម្មណ៍

អសមត្ថភាពវិញ?

### ៥. តើគាត់អាចរីករាយនឹងទុក្ខព្រួយបានដែរឬទេ?

តើគាត់មានបទពិសោធន៍ខ្លះនៃបទពិសោធគ្រីស្ទបរិស័ទដែលខុសប្លែកពីគេអំពី «មានសេចក្តីព្រួយ តែចេះតែបានសប្បាយវិញ» ឬទេ? នោះជារបៀបដែលសាវ័ក ប៉ុល បានពណ៌នាអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ថា «មានសេចក្តីព្រួយ តែចេះតែបានសប្បាយវិញ» (២កូរិនថូស ៦:១០)។

ម្យ៉ាងវិញទៀត មិនថាការបាត់បង់ពិតប៉ុណ្ណា ឬឈឺចាប់ខ្លាំងយ៉ាងណានោះទេ ផ្ទាំងថ្មនៃសេចក្តីអំណររបស់ព្រះជាម្ចាស់នៅក្រោមរលកនៃទុក្ខសោកមិនដែលរើបានទ្បើយ។

### ក្បួនខ្នាតដែលត្រូវខិតខំចង់បាន

សំណួរទាំងប្រាំនេះដែលខ្ញុំនឹងសួរ ក្នុងការព្យាយាមស្វែងយល់ថា តើការពឹងផ្អែកខាងផ្លូវអារម្មណ៍ និងនៅក្នុងទំនាក់ទំនងនៃការចែចង់គ្នានោះមានការពឹងពាក់លើ ជាទំនាក់ទំនងដំណើរការមិនមានដំណើរការត្រឹមត្រូវ ឬក៏មិនមានសុខភាពល្អ ឬក៏មានការពឹងលើ។

ហើយប្រសិនបើដូចដែលខ្ញុំអាចស្រមៃបានដល់ថា ការឆ្លើយតបរបស់ក្មួយចំពោះសំណួរទាំងនេះគឺនិយាយថា «លោកគ្រូ គ្មាននរណាម្នាក់អាចរស់នៅបានតាមស្តង់ដារនោះទេ» នោះការឆ្លើយតបរបស់ខ្ញុំគឺថា គ្មាននរណាម្នាក់ (ដើម្បីប្រាកដគ្នា) គ្មាននរណាម្នាក់ល្អឥតខ្ចោះក្នុងវិធីទាំងប្រាំនេះទេ។ ប៉ុន្តែ បុគ្គលដែលកើតមកពីព្រះជាម្ចាស់ពិតប្រាកដនឹងដឹងអំពីរង្វាស់ខ្លះៗនៃកិច្ចការទាំងនេះ ពិតជាបានភ្លក់រសជាតិវា ហើយនឹងមិនរុញរាពីសំណួរបែបនេះទេ ប៉ុន្តែនឹងពិតជាចង់រីកចម្រើនតាមវិធីទាំងអស់នេះជាមិនខាន។ ដូច្នេះ ចូររកមើលចំណុចទាំងនេះ ហើយសូមឲ្យព្រះជាម្ចាស់ប្រទានឲ្យក្មួយ



នូវការយល់ដឹង នៅក្នុងការសម្រេចចិត្តដ៏ធំបំផុតទីពីរនៃជីវិតរបស់ក្មួយចុះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
On Codependent Dating Relationships
**បែបបទនៃការចែចង់គ្នាដោយមានការពឹងលើ**
https://www.desiringgod.org/interviews/on-codependent-dating-relationships

# សំណួរទី៣៩៖
# តើសេចក្តីស្រឡាញ់ជាអ្វី?

សំណួរដ៏ពេញនិយមបំផុតដែលបានសួរនៅហ្គូហ្គល (Google) ក្នុងបរិបទភាសាអង់គ្លេស៖ «តើសេចក្តីស្រឡាញ់ជាអ្វី?» (What is love? ) តើលោកគ្រូគិតថា ហេតុអ្វីបានជាមានមនុស្សជាច្រើនកំពុងប្រឈមមុខនឹងការលំបាកយ៉ាងខ្លាំង ដើម្បីឲ្យបានយល់ពីអត្ថន័យនៃសេចក្តីស្រឡាញ់? ហើយតើលោកគ្រូអាចកំណត់អត្ថន័យរបស់វាដោយរបៀបណា?

ខ្ញុំគិតថា ប្រសិនបើយើងចាប់ផ្តើមពីនិយមន័យទៅ នោះវានឹងធ្វើឲ្យកាន់តែច្បាស់ថែមទៀត ហេតុអ្វីបានជាមនុស្សជាច្រើនមានការពិបាកយល់អំពីសេចក្តីស្រឡាញ់ថាជាអ្វី។ ដូច្នេះ សូមទទួលស្គាល់ថា សេចក្តីស្រឡាញ់មានច្រើនប្រភេទខុសៗគ្នា ឬអាចនិយាយបានក្នុងរបៀបផ្សេងទៀត ពាក្យថា សេចក្តីស្រឡាញ់ ត្រូវបានប្រើប្រាស់ជាច្រើនរបៀបខុសៗគ្នា។ នៅពេលណាដែលយើងសួរថា សេចក្តីស្រឡាញ់ជាអ្វី នៅក្នុងគំនិតមួយរបស់ខ្ញុំត្រូវតែឆ្លើយតបទៅវិញថា «យោងទៅតាមនិយមន័យរបស់នរណា?» ឬ«យោងទៅតាមឯកសារអ្វី?» ឬយោងទៅតាមអត្ថបទមួយណានៃព្រះគម្ពីរ?» ជាដើម។ល។

### តើយើងចាប់ផ្តើមនៅកន្លែងណា?

នៅក្នុងសៀវភៅរបស់លោក ស៊ី.អេស. លូហ្វីស (C.S. Lewis) ដែលមានចំណងជើងថា «សេចក្តីស្រឡាញ់បួនប្រភេទ» (“The Four Loves”) ដែលបែងចែកជា អេរ៉ូស (Eros) ជាប្រភេទមួយនៃស្នេហារ៉ូមែនទិចដែលអ្នកមានស្នេហាខ្វះគ្នាមិនបាន និង ហ្វីឡូ (Philos) ជាសេចក្តីស្រឡាញ់បែបមិត្តភាពដែលមនុស្សពីរពួតដៃ កៀកស្មាគ្នា ដោយមានចក្ខុវិស័យ គោល

ដៅមួយដូចគ្នា ព្រមទាំងមានសេចក្ដីអំណរ និងភាពជាដៃគូរដែលនាំគ្នាឆ្ពោះទៅរកគោលដៅតែមួយ។ ហើយ ស្តរហ្គេ (Storge) គឺជាសេចក្ដីស្រឡាញ់ដែលបុគ្គលម្នាក់ប្រហែលជាមានរបស់សំណព្វចិត្តដូចជា អាវក្រៅកញ្ចាស់មួយ ស្បែកជើងផ្ទាត់កញ្ចាស់មួយគូ ឆ្កែចាស់មួយក្បាល ដែលគាត់មិនដាច់ចិត្តនឹងបោះចោលវាសោះ។ ចុងក្រោយ អាហ្គាប៉េ (Agape) គឺជាសេចក្ដីស្រឡាញ់ដែលល្អឥតខ្ចោះ ត្រូវបានកំណត់លក្ខណៈដោយការលះបង់សម្រាប់ជាប្រយោជន៍ដល់អ្នកដទៃ។

ដូច្នេះ តាមរយៈលោក ល៊ូហ្វិស លោកអ្នកអាចសួរបានថា «តើមួយណាក្នុងចំណោមចំណុចទាំងអស់នោះ ដែលលោកអ្នកចង់ឲ្យខ្ញុំឲ្យនិយមន័យ នៅពេលលោកអ្នកនិយាយថា «តើសេចក្ដីស្រឡាញ់ជាអ្វី?» ដោយហេតុនេះ នោះជាផ្នែកនៃហេតុផល ដែលមនុស្សកំពុងស្វែងរកដោយងងឹតងងុល។ ពាក្យថា សេចក្ដីស្រឡាញ់ មានអត្ថន័យច្រើនយ៉ាងខុសៗគ្នា។ ហើយវាមិនមែនជារឿងអវិជ្ជមាន ដែលវាមានអត្ថន័យជាច្រើននោះទេ។

ឥឡូវនេះ អ្វីដែលខ្ញុំរកឃើញថាមានប្រយោជន៍បំផុត គឺការបែងចែកសេចក្ដីស្រឡាញ់ជាពីរប្រភេទ។ ខ្ញុំទទួលបានប្រភេទទីមួយ ពីលោកយ៉ូណាថាន អេឌវើដស៍ (Jonathan Edwards) ប៉ុន្តែវាមានតាំងពីមុនគាត់ទៅទៀត។ គាត់បែងចែកសេចក្ដីស្រឡាញ់ចេញជា «សេចក្ដីស្រឡាញ់ដោយការពេញចិត្ត» និង «សេចក្ដីស្រឡាញ់ប្រកបដោយក្ដីមេត្តាករុណា»។

ការពេញចិត្ត គឺនៅក្នុងឃ្លា «ខ្ញុំចូលចិត្តភីហ្សា» ដែលយើងអាចនិយាយម្យ៉ាងទៀតថា «ខ្ញុំដឹងថា ខ្លួនខ្ញុំចូលចិត្តនឹងអ្វីដែលមាននៅក្នុងភីហ្សា ពោលគឺ រសជាតិវាតែម្ដង»។ នេះគឺជាសេចក្ដីស្រឡាញ់ដោយការពេញចិត្ត។ ឬក៏ប្រហែលជាលោកអ្នកចូលចិត្តកន្លែងណាមួយ ប្រទេសណាមួយ ឬអ្វីៗជាច្រើនទៀត។ លោកអ្នកអាចនិយាយបានថា លោកអ្នកចូលចិត្តវា ដោយសារតែវាគួរឲ្យស្រឡាញ់។ វាជាទីគាប់ចិត្តដល់លោកអ្នកណាស់។



ផ្ទុយទៅវិញ សេចក្ដីស្រឡាញ់ប្រកបដោយក្ដីមេត្តាករុណា គឺមិនមែនអាស្រ័យទៅលើភាពគួរឲ្យស្រឡាញ់របស់វត្ថុដែលយើងស្រឡាញ់នោះទេ ប៉ុន្តែជាចេតនាល្អ—ប្រកបដោយក្ដីមេត្តាករុណា—ចេតនាល្អរបស់លោកអ្នកមានទៅកាន់មនុស្ស ឬវត្ថុដែលលោកអ្នកកំពុងស្រឡាញ់។ គោលបំណងរបស់លោកអ្នកនៅក្នុងការស្រឡាញ់ប្រភេទនេះ គឺដើម្បីធ្វើការល្អ នាំយកនូវអ្វីដែលស្រស់ស្អាត មិនមែនគ្រាន់តែឆ្លើយតបចំពោះភាពស្រស់ស្អាតប៉ុណ្ណោះទេ។

## សេចក្ដីស្រឡាញ់នៃព្រះជាម្ចាស់

ដូច្នេះយើងបានចំណាយពេលយ៉ាងយូរក្នុងការពិភាក្សាគ្នាអំពីលក្ខណៈនៃការពេញចិត្តនៅក្នុងព្រះជាម្ចាស់ និងតើវាមានលក្ខណៈយ៉ាងដូចម្ដេចដើម្បីឲ្យបានដឹង រីករាយ ព្រមទាំងសរសើរតម្កើង និងស្កប់ចិត្តក្នុងផងព្រះជាម្ចាស់ ហើយយើងអាចចំណាយបានយូរក្នុងការនិយាយអំពីក្ដីមេត្តាករុណា ទៅកាន់មនុស្សដែលមិនមានលក្ខណៈសម្បត្តិគួរឲ្យកោតសរសើរដែលធ្វើឲ្យយើងចង់ចូលទៅជិតពួកគេ។

ដូច្នេះ អ្វីដែលខ្ញុំគិតថាមានប្រយោជន៍បំផុតក្នុងការឆ្លើយតបទៅនឹងសំណួរនេះគឺ ការឲ្យនិយមន័យទៅតាមបទគម្ពីរនៃសេចក្ដីស្រឡាញ់ប្រកបដោយក្ដីមេត្តាករុណា ពីព្រោះនេះជាប្រភេទនៃសេចក្ដីស្រឡាញ់ដែលមាននៅក្នុងព្រះគម្ពីរ ព្រះគម្ពីរបានលើកឡើងថា ជាចំណុចស្នូលនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ ដោយហេតុនេះ ទំហំនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ប្រកបដោយសេចក្ដីមេត្តាករុណា ត្រូវបានវាស់វែងក្នុងព្រះគម្ពីរដោយលក្ខណៈវិនិច្ឆ័យបួនយ៉ាងដូចខាងក្រោមនេះ៖

១. កម្រិតចំពោះបុគ្គលម្នាក់ត្រូវបានគេស្រឡាញ់ ទាំងដែលគេមិនសមនឹងទទួលបានការស្រឡាញ់នោះ។

២. វិសាលភាពនៃតម្លៃដែលត្រូវបង់ ដើម្បីស្រឡាញ់មនុស្សម្នាក់។

៣. វិសាលភាពនៃអំពើល្អដែលបានធ្វើសម្រាប់បុគ្គលម្នាក់ នៅពេលគេទទួលបានសេចក្តីស្រឡាញ់។

៤. កម្រិតនៃបំណងប្រាថ្នា ដែលព្រះមានសម្រាប់ជាប្រយោជន៍ដល់អស់អ្នកណាដែលទ្រង់ស្រឡាញ់។

ដូច្នេះ សូមឲ្យខ្ញុំបានផ្តល់នូវខគម្ពីរយោងមួយចំនួនសម្រាប់លក្ខណៈវិនិច្ឆ័យមួយៗ៖

១. កណ្ឌគម្ពីរ រ៉ូម ៥:៦-៨ ព្រះជាម្ចាស់ស្រឡាញ់អស់អ្នកដែលមិនសមនឹងទទួលសេចក្តីស្រឡាញ់ទ្រង់ទាល់តែសោះ ហេតុដូច្នេះហើយបានជាក្តីស្រឡាញ់ទ្រង់គឺធំអស្ចារ្យណាស់។ «ដ្បិតកាលយើងនៅខ្សោយនៅឡើយ លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគត ជំនួសមនុស្សទមិលល្មើស កម្រនឹងមានអ្នកណាព្រមស្លាប់ជំនួសមនុស្សសុចរិតណាស់ ប៉ុន្តែប្រហែលជាមានអ្នកខ្លះហ៊ានស្លាប់ជំនួសមនុស្សល្អដែរទេដឹង តែឯព្រះទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង»—ព្រះជាម្ចាស់ខុសពីចំណុចទាំងអស់នោះ—«ទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់»—នេះហើយជាអត្ថន័យនៃសេចក្តីស្រឡាញ់—«ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង»។ ដូច្នេះ រង្វាស់ខ្នាតទី១ចំពោះទំហំនៃសេចក្តីស្រឡាញ់របស់ផងព្រះ គឺយើងរាល់គ្នាមិនសមនឹងទទួលបានក្តីស្រឡាញ់នោះទេ។ ហេតុដូច្នេះហើយ បានជាវាធំអស្ចារ្យ។

២. ការពិចារណាទៅលើតម្លៃដែលទ្រង់ស្ម័គ្រព្រះទ័យបង់សងជំនួសយើងរាល់គ្នា «គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ» (យ៉ូហាន ១៥:១៣)។



សេចក្តីស្រឡាញ់នេះត្រូវបានវាស់ដោយមិនគ្រាន់តែពឹងផ្អែកទៅលើការពិតដែលយើងមិនសមនឹងទទួលវានោះទេ។ វាត្រូវបានវាស់ដោយតម្លៃដែលទ្រង់ស្ម័គ្រព្រះទ័យបង់សងជំនួសយើងរាល់គ្នា ពោលគឺ ព្រះជន្មរបស់បុត្រាទ្រង់ផ្ទាល់។

៣. រង្វាស់ខ្នាតទី៣ គឺសំដៅទៅលើអត្ថប្រយោជន៍ដែលយើងរាល់គ្នាបានទទួលតាមរយៈសេចក្តីស្រឡាញ់មួយនេះ។ នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ បានហៅថា «ជីវិតអស់កល្បជានិច្ច»។ ខគម្ពីរ៖ «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។ ហើយបន្ទាប់មក ទ្រង់បានឲ្យនិយមន័យលើពាក្យ «ជីវិតអស់កល្បជានិច្ច» នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៧:៣ ដោយបញ្ជាក់ថា វាជាការស្គាល់ព្រះជាម្ចាស់ និងការស្គាល់ព្រះគ្រីស្ទ។ ដ្បិតសេចក្តីស្រឡាញ់ដ៏អស្ចារ្យទំនងនឹងត្រូវផ្តល់ឲ្យនូវអំណោយដ៏អស្ចារ្យតាមដែលអាចនឹងផ្តល់ឲ្យបាន ដែលជារូបអង្គទ្រង់ផ្ទាល់។

៤. តើព្រះជាម្ចាស់បង្ហាញសេចក្តីស្រឡាញ់នេះដោយមិនសព្វព្រះទ័យ ឬដោយអស់ពីព្រះទ័យទ្រង់វិញ? កណ្ឌគម្ពីរ សេផានា ៣:១៧ ចែងថា «ព្រះយេហូវ៉ា ដ៏ជាព្រះនៃឯង ទ្រង់គង់នៅកណ្តាលឯង ទ្រង់ជាព្រះដ៏មានឥទ្ធិឫទ្ធិដើម្បីជួយសង្គ្រោះ ទ្រង់នឹងមានសេចក្តីរីករាយអរសប្បាយចំពោះឯង ទ្រង់នឹងសម្រាកក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ ក៏នឹងអរសប្បាយនឹងឯង ដោយសំឡេងច្រៀង»។ យើងអានការឆ្លើយតបដូចគ្នានៅក្នុងរឿងប្រស្នា «កូនពៅវង្វេង» នៅត្រង់កន្លែងដែលឪពុកឃើញកូនប្រុសគាត់ត្រឡប់មកផ្ទះវិញ គាត់ស្ទុះទៅឱបកូនប្រុសព្រមទាំងបំពាក់ចិញ្ចៀនទៅនឹងដៃរបស់គាត់ ពាក់អាវថ្មីឲ្យគាត់ ព្រមទាំងបំពាក់ស្បែកជើងថ្មីឲ្យគាត់ ថែមទាំងធ្វើពិធីជប់លៀងមួយឲ្យគាត់ទៀតផង (លូកា ១៥:២០-២៤)។ បើនិយាយម៉្យាងវិញទៀត

ព្រះជាម្ចាស់ពិតជាសព្វព្រះហឫទ័យក្នុងការសង្គ្រោះយើង។ គ្មាននរណាម្នាក់បង្ខំទ្រង់ទេ។

ដូច្នេះ សេចក្ដីស្រឡាញ់ដែលប្រសើរជាងបំផុតនៅលើលោក គឺជាសេចក្ដីស្រឡាញ់ល្អឥតខ្ចោះដែលបង់ថ្លៃលោះដ៏ខ្ពស់បំផុត គឺព្រះជន្មនៃព្រះរាជបុត្រារបស់ទ្រង់ សម្រាប់ពួកខ្មាំងសត្រូវទាំងឡាយដែលមិនសមនឹងទទួលបានសេចក្ដីស្រឡាញ់មួយនេះ ដើម្បីផ្ដល់ឲ្យយើងរាល់គ្នានូវភាពរីករាយដ៏យូរអង្វែង និងអស្ចារ្យបំផុតនៅក្នុងព្រះវត្តមានទ្រង់។ ហើយទ្រង់សព្វព្រះទ័យយ៉ាងក្រៃលែងនឹងធ្វើការនេះ។

## សេចក្ដីស្រឡាញ់របស់យើងសម្រាប់ព្រះ

ចំណុចមួយចុងក្រោយ៖ ប្រសិនបើវាស្ដាប់ទៅដូចជាមានភាពផ្ទុយស្រឡះក្នុងការនិយាយថា ព្រះចិន្ដានៃសេចក្ដីស្រឡាញ់របស់ព្រះ ជាសេចក្ដីមេត្តាករុណាចំពោះមនុស្សដូចជាយើងរាល់គ្នាដែលមិនសមនឹងទទួលសេចក្ដីស្រឡាញ់នោះ ប៉ុន្ដែទោះជាយ៉ាងណាក៏ដោយ ក៏គោលបំណងចម្បងនៃជីវិតមនុស្សជាតិ គឺជាការស្រឡាញ់ព្រះជាម្ចាស់។ ខ្ញុំមិនគិតថាវាពិតជាមានអ្វីផ្ទុយពីគ្នានោះទេ។ ហើយហេតុផលនោះ វាមិនមែនដោយសារតែគោលបំណងចម្បងធំបំផុតនៃសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះយើងរាល់គ្នា ក្នុងការផ្ដល់ឲ្យយើងនូវការពេញចិត្តក្នុងទ្រង់ផ្ទាល់នោះទេ។ ហេតុដូច្នេះហើយ បានជាសេចក្ដីស្រឡាញ់ដោយមេត្តាករុណាបានដក់ជាប់យ៉ាងជ្រៅនៅក្នុងចិត្តយើងនូវសេចក្ដីស្រឡាញ់ដោយការពេញចិត្តក្នុងព្រះជាម្ចាស់ដែរ។

ព្រះជាម្ចាស់មិនមានការស្កប់ព្រះទ័យយ៉ាងជ្រាលជ្រៅក្នុងយើងទេ គឺមានតែយើងទេតើដែលមានការស្កប់ចិត្តយ៉ាងខ្លាំងនៅក្នុងទ្រង់។ ព្រះជាម្ចាស់នឹងក្លាយជាអង្គដែលថ្វាយបង្គំរូបព្រះវិញ ប្រសិនបើគោលដៅដ៏ធំបំផុតរបស់ទ្រង់ គឺជាសេចក្ដីស្រឡាញ់ដោយការពេញចិត្តចំពោះយើង។ ផ្ទុយទៅវិញ ព្រះអង្គបានផ្ដល់ឲ្យយើងនូវសេចក្ដីស្រឡាញ់ដោយការពេញចិត្តយ៉ាងជ្រាលជ្រៅចំពោះទ្រង់។ យើងមិនបានស្រឡាញ់ព្រះជាម្ចាស់ដោយការជួយឲ្យព្រះជាម្ចាស់បានរួចចេញពីភាពមិនពេញលក្ខណៈឆ្ពោះទៅកាន់សេចក្ដីអំណរនោះទេ។ ប៉ុន្ដែ ព្រះជាម្ចាស់ស្រឡាញ់យើងដោយការជួយឲ្យយើងរួចចេញពីភាពមិនពេញលក្ខណៈឆ្ពោះទៅកាន់សេចក្ដីអំណរវិញ។ ក្នុងករណីទាំងពីរនេះ សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ និងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើង មានគោលដៅចម្បងដូចគ្នា៖ យើងនឹងរកឃើញការស្កប់ចិត្តយ៉ាងស៊ីជម្រៅក្នុងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់បានរកឃើញ ឬដេញតាមការស្កប់ព្រះទ័យក្នុងទ្រង់ផ្ទាល់ និងការបង្ហាញភាពជាព្រះរបស់ទ្រង់ ពោលគឺការលើកតម្កើងអង្គទ្រង់ឡើង។

ដូចនេះ គោលដៅដ៏ចម្បងបំផុតនៃគ្រប់ការទាំងអស់—ហើយនេះប្រហែលជារឿងមានប្រយោជន៍ជាងគេបំផុតសម្រាប់ចម្លើយ ឬសំណួរនេះ—ជាគោលបំណងធំបំផុតនៃគ្រប់រឿងរ៉ាវទាំងអស់ នៅពេលផែនដីនេះត្រូវបានលម្អទៅដោយតម្លៃគ្មានព្រំដែននៃព្រះជាម្ចាស់ គឺតាមរយៈការយកទ្រង់ទុកដូចជាទ្រព្យសម្បត្តិ។ អស់អ្នកណាដែលទុកទ្រង់ដូចជាទ្រព្យសម្បត្តិ នឹងមានសេចក្ដីអំណរចំពោះទ្រង់លើសគ្រប់អ្វីៗទាំងអស់ ក្នុងន័យនេះគោលដៅនៃគ្រប់អ្វីៗទាំងអស់ គឺការស្រឡាញ់ទ្រង់។

ដូច្នេះហើយ ប្រសិនបើលោកអ្នកសួរខ្ញុំថា «តើលោកគ្រូគិតថា ហេតុអ្វីបានជាមានមនុស្សជាច្រើនកំពុងប្រឈមមុខនឹងការលំបាកយ៉ាងខ្លាំង ដើម្បីឲ្យបានយល់ពីអត្ថន័យនៃសេចក្ដីស្រឡាញ់?»—សំណួរនេះ នឹងត្រឡប់ទៅកន្លែងដើមវិញ គឺថា «ហេតុអ្វីបានជាមានមនុស្សជាច្រើនកំពុងប្រឈមមុខខ្លាំងនឹងការយល់អំពីអត្ថន័យសេចក្ដីស្រឡាញ់?»—ខ្ញុំនឹងឆ្លើយថា «ក្រៅពីព្រះវិញ្ញាណបរិសុទ្ធ គ្មាននរណាម្នាក់អាចនឹងគិតអំពីសេចក្ដីស្រឡាញ់

ដូចអ្វីដែលខ្ញុំទើបនឹងបានគិតនោះឡើយ។ ដោយសារអំពើបាបពីកំណើត របស់យើង យើងគិតតែពីខ្លួនឯង ហើយមិនយកព្រះជាម្ចាស់ទុកជាចំណុច កណ្ដាលទេ។ យើងរត់គេចទៅរាប់ពាន់ទិសដៅ ដើម្បីគេចចេញពីសេចក្ដីពិត មួយនេះ ដែលថាយើងអាចរកឃើញភាពពេញលេញ និងការស្កប់ចិត្តយូរ អង្វែងក្នុងព្រះជាម្ចាស់។ ហើយព្រះជាម្ចាស់ ផ្ដល់ក្ដីមេត្តាករុណាមកកាន់ យើងយ៉ាងច្បាស់ ដើម្បីនាំយើងចូលទៅកាន់សេចក្ដីអំណរនោះ»។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
What is Love?
**តើសេចក្ដីស្រឡាញ់ជាអ្វី?**
https://www.desiringgod.org/interviews/what-is-love



## សំណួរទី៩០៖
## បើព្រះមានភាពគ្រប់គ្រាន់សម្រាប់គាត់ ហេតុអ្វីលោក អ័ដាម មានភាពឯកោ?

*មិត្តអ្នកអានម្នាក់បានផ្ញើសារមកសួរថា «“លោកគ្រូ ថ្មីៗនេះ ខ្ញុំបាន អានសៀវភៅមួយក្បាល ហើយឃើញគេសរសេរថា 'ព្រះទ្រង់បានបង្កើត ពិភពលោកមក ក្នុងគោលបំណង ដើម្បីឲ្យពិភពលោកមានដំណើរការ តាម របៀបដែលធ្វើឲ្យយើងគិតថា ព្រះអង្គមានភាពមិនគ្រប់គ្រាន់សម្រាប់យើង។ ហេតុនេះហើយបានជាព្រះអង្គក៏បានមានបន្ទូលថា 'ដែលមនុស្សនេះនៅតែ ម្នាក់ឯង នោះមិនស្រួលទេ'។ បើព្រះទ្រង់ជាអ្វីគ្រប់យ៉ាង ដែលលោក អ័ដាម ត្រូវការ នោះមានន័យថា លោក អ័ដាម មិនឯកោឡើយ។ មិនមែនដោយសារ ព្រះទ្រង់មានវត្តមាននៅក្បែរគាត់នោះទេ តែដោយសារមិនមានមនុស្សផ្សេង ទៀត នៅក្បែរគាត់។ ព្រះទ្រង់បានសម្រេចព្រះទ័យ កំណត់សមត្ថភាពរបស់ ទ្រង់ ឲ្យនៅត្រឹមជាអ្វីគ្រប់យ៉ាង ដែលលោក អ័ដាម ត្រូវការ។*

*ការនិយាយដូចនេះ បានធ្វើឲ្យមនុស្សជាច្រើនមានការភ្ញាក់ផ្អើល។ តាម ធម្មតា ខ្ញុំឮគេនិយាយថា 'ព្រះជាអ្វីគ្រប់យ៉ាង ដែលអ្នកត្រូវការ។ ព្រះទ្រង់ មានភាពគ្រប់គ្រាន់សម្រាប់យើងហើយ។' និយាយដូចនេះ គឺពីរោះស្ដាប់ ណាស់ ប៉ុន្តែ បញ្ហាស្ថិតនៅត្រង់ថា នេះមិនមែនជាការពិតទេ ហើយព្រះគម្ពីរ ក៏មិនបានបង្រៀនដូចនេះដែរ ក្នុងបរិបទនៃការនិយាយអំពីទំនាក់ទំនង។ បើយើងនិយាយ អំពីព្រះគុណ នោះអ្វីដែលបានលើកឡើងខាងលើ គឺត្រឹម ត្រូវ។ ព្រះគុណព្រះមានភាពគ្រប់គ្រាន់។ ទោះជាយ៉ាងណាក៏ដោយ បើយើង និយាយអំពីទំនាក់ទំនង នោះទំនាក់ទំនងមិនមានភាពគ្រប់គ្រាន់ឡើយ”»។*

«ដូចនេះ លោកគ្រូ តើគោលលទ្ធិនៃការស្វែងរកអំណររបស់គ្រីស្ទ

*បរិស័ទ បានបង្រៀនថា ព្រះទ្រង់មានភាពគ្រប់គ្រាន់ ក្នុងការបំពេញការស្រេកឃ្លានគ្រប់យ៉ាងនៃវិញ្ញាណយើង ក្នុងទំនាក់ទំនងមែនទេ? ពុំនោះទេ តើព្រះអង្គបានបង្កើតយើងមក ឲ្យត្រូវការអ្នកដទៃ ដែលនេះជាតម្រូវការជាមូលដ្ឋាន ដែលទ្រង់មិនអាចបំពេញឲ្យបានឬ?»*

នេះជាសំណួរល្អណាស់ ហើយព្រោះសំណួរនេះបានកើតចេញពីបរិបទក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ២:១៨ ដែលបានចែងថា «ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលថា "ដែលមនុស្សនេះនៅតែម្នាក់ឯង នោះមិនស្រួលទេ អញនឹងធ្វើឲ្យមានម្នាក់ជាជំនួយសម្រាប់ជួយវា"»។ ត្រង់ចំណុចនេះច្បាស់ណាស់ ព្រះទ្រង់មិនសព្វព្រះទ័យឲ្យលោក អ័ដាមឆ្លើយតបថា «ទេ! ទូលបង្គំអរព្រះគុណព្រះអង្គ។ ប៉ុន្តែ ព្រះអង្គខុសហើយ។ ទូលបង្គំមិននៅម្នាក់ឯងទេ។ ទូលបង្គំមានព្រះអង្គគង់នៅជាមួយហើយ»។ ព្រះទ្រង់យល់ឃើញថា សណ្ឋាននៃរបស់សព្វសារពើ ដែលព្រះអង្គបានបង្កើត មានភាពល្អដែលមិនទាន់ឈានដល់ចំណុចចុងក្រោយ ដែលព្រះអង្គសព្វព្រះទ័យ ដែលទាំងបុរស និងស្ត្រីត្រូវមានព្រះទាំងអស់គ្នា។ ក្នុងគំនិតរបស់ព្រះ ការបង្កើតឲ្យមានមនុស្សម្នាក់ទៀត ជារឿងមិនចាំបាច់ទេ។

**ព្រះទ្រង់បង្កើតសេចក្តីត្រូវការ**

ករណីដែលប្អូនបានដកស្រង់មកនេះ ហាក់ដូចជាខ្លាំងបន្តិច។ ពាក្យសម្តីហាក់ដូចជាខ្លាំងបន្តិច ពេលដែលគេនិយាយទៅកាន់លោកអ័ដាម នៅក្នុងសួនច្បារអេដែនថា «ព្រះទ្រង់ជាអ្វីៗគ្រប់យ៉ាង ដែលអ្នកត្រូវការ»។ ចូរយើងធ្វើឲ្យករណីនេះកាន់តែខ្លាំងថែមមួយកម្រិតទៀត ដោយបន្ថែមខគម្ពីរដទៃទៀត ដែលមានដូចជា «ព្រះទ្រង់បានដាក់ចុះនូវអវយវៈនីមួយៗ ក្នុងរូបកាយតាមព្រះហឫទ័យទ្រង់ បើគ្រប់ទាំងអស់សុទ្ធតែជាអវយវៈតែ១ នោះតើរូបកាយនឹងនៅឯណា? តែមានអវយវៈជាច្រើនវិញ ប៉ុន្តែរូបកាយតែ១ទេ



ហើយភ្នែក (ឧបមាថា៖ ប្អូនគឺជាភ្នែក) ពុំអាចនិយាយទៅដៃ (ឧបមាថា៖ ខ្ញុំជាដៃ) ថា អញមិនត្រូវការនឹងឯងទេ ឬក្បាលនិយាយទៅជើងថា អញមិនត្រូវការនឹងឯងដែរនោះឡើយ» (១កូរិនថូស ១២:១៨-២១)។

ដូចនេះ ព្រះដ៏មានគ្រប់ព្រះចេស្តា មានបន្ទូលត្រង់ៗថា «អ្នកមិនត្រូវនិយាយ ទៅសមាជិកដទៃទៀតនៃរូបកាយព្រះគ្រីស្ទថា "ខ្ញុំមិនត្រូវការអ្នក"» នោះឡើយ។ ការនិយាយដូចនេះ គឺជាអំពើបាប។ ម្យ៉ាងទៀត ព្រះទ្រង់បានហាមយើង មិនឲ្យនិយាយថា «ខ្ញុំមានព្រះហើយ។ ខ្ញុំមិនត្រូវការសមាជិកដទៃទៀតនៃរូបកាយព្រះគ្រីស្ទឡើយ»។

យើងខ្ញុំអាចលើកយកឧទាហរណ៍ជាច្រើនទៀតមកនិយាយបាន។ ព្រះយេស៊ូវបានបង្គាប់យើងឲ្យអធិស្ឋានថា «សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ» (ម៉ាថាយ ៦:១១)។ ហើយព្រះអង្គក៏បានប្រាប់យើងកុំឲ្យថប់បារម្ភអំពីចំណីអាហារ ឬសំលៀកបំពាក់ឡើយ ព្រោះព្រះយេស៊ូវមានបន្ទូលថា «ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ» (ម៉ាថាយ ៦:៣១-៣២)។ ដូចនេះ ព្រះទ្រង់បានបង្កើតចក្រវាលដែលអាចមើលឃើញ គឺមិនគ្រាន់តែពិភពខាងវិញ្ញាណប៉ុណ្ណោះទេ។ ហើយទ្រង់បង្កើតវិញ្ញាណដទៃទៀត គឺមិនមែនតែវិញ្ញាណរបស់មនុស្សម្នាក់ ឲ្យមានទំនាក់ទំនងជាមួយព្រះអង្គនោះដែរ។ ហើយព្រះអង្គបង្កើតសង្គម និងពួកជំនុំ មិនមែនវិញ្ញាណនៅដាច់ដោយឡែកពីគ្នា ក្នុងការទំនាក់ទំនងជាមួយព្រះអង្គ។ ហើយក្នុងការដែលព្រះអង្គបង្កើតពិភពលោក ពួកជំនុំ និងសង្គមមក ព្រះអង្គបានកំណត់ឲ្យយើងទទួលផលប្រយោជន៍ពីការទាំងនេះ ដើម្បីឲ្យយើងមានអាហារ ទឹកជម្រក សំលៀកបំពាក់ ខ្យល់ដកដង្ហើម និងអ្នកដទៃទៀត ហើយក៏ដើម្បីឲ្យយើងស្តាប់បង្គាប់តាមព្រះរាជបញ្ញារបស់ព្រះអង្គ ដែលមានដូចជា «ចូរស្រឡាញ់អ្នកដទៃ ដូចខ្លួនឯង» ជាដើម (ម៉ាកុស ១២:៣១) ។ អ្នកមិន

អាចស្តាប់បង្គាប់តាមព្រះរាជបញ្ជាមួយនេះបានទេ បើអ្នកគ្មានអ្នកជិតខាងសម្រាប់ស្រឡាញ់ទេនោះ។

ដូចនេះ យើងមិនខុសទេ ពេលដែលយើងនិយាយថា យើងត្រូវការអ្នកជិតខាង ក្នុងន័យថា ព្រះទ្រង់បានរៀបចំមកយ៉ាងដូចនេះឯង។ ព្រះអង្គបានបង្កើតរបស់ទាំងនេះមក។ ព្រះអង្គបានបង្កើតយើង ឲ្យមានតម្រូវការ ដែលមានតែព្រះអង្គទេ ដែលអាចបំពេញបាន ក្នុងន័យថា ព្រះអង្គប្រទានរបស់ទាំងនេះមកយើង តែមិនមែនធ្វើជារបស់ទាំងនេះ សម្រាប់យើងនោះឡើយ។

## ព្រះទ្រង់ជាចំណុចកណ្តាលនៃតម្រូវការរបស់យើង

សំណួរនោះគឺថា៖ តើយើងគួរតែនិយាយថា «ព្រះទ្រង់មានភាពគ្រប់គ្រាន់សម្រាប់យើង» ឬក៏ថា «ខ្ញុំមិនត្រូវការអ្វីផ្សេងទៀត ក្រៅពីព្រះនោះឡើយ» មែនឬ? មានហេតុផលដ៏ល្អមួយ ដែលពាក្យពេចន៍ទាំងនេះ បានដក់ជាប់ក្នុងផ្នត់គំនិតយើង។ យើងខ្ញុំអាចប្រាប់អំពីហេតុផលនោះ ដោយចោទសួរទៅវិញថា៖ «ហេតុអ្វីពាក្យពេចន៍ទាំងនេះ ហាក់ដូចជាមិនសំខាន់ចំពោះព្រះ ពេលដែលយើងនិយាយចេញមកដូចនេះ?» ពេលណាយើងនិយាយថា «ព្រះមិនមានភាពគ្រប់គ្រាន់សម្រាប់យើង» ឬថា «ខ្ញុំមានគ្រប់គ្រាន់ហើយ ខ្ញុំមិនត្រូវការព្រះទេ» ហេតុអ្វីការនិយាយដូចនេះ ហាក់ដូចជាមិនសំខាន់ចំពោះព្រះអញ្ចឹង?

មូលហេតុនោះគឺថា ការបង្រៀនមួយ ក្នុងចំណោមការបង្រៀនសំខាន់បំផុតនៃព្រះគម្ពីរ បានបង្រៀនថា ពេលដែលតម្រូវការរបស់យើងជាមនុស្សមិនបានទទួលការបំពេញ ហើយយើងនៅកណ្តោចកណ្តែង និងហៀបនឹងស្លាប់ នោះព្រះទ្រង់នឹងមិនខាននឹងបំពេញតម្រូវការយើងឡើយ។ ស្ថិតក្នុងពេលនោះ ព្រះអង្គនឹងមានភាពគ្រប់គ្រាន់សម្រាប់យើង។ នេះជាអត្ថន័យនៃការថ្វាយព្រះកិត្តិនាមដល់ព្រះ ដោយនិយាយថា ព្រះអង្គជាអ្វីៗគ្រប់



យ៉ាង ដែលយើងត្រូវការ។ យើងអាចនិយាយបានម្យ៉ាងទៀតថា បើតម្រូវការទាំងអស់របស់ខ្ញុំ មិនបានទទួលការបំពេញ នោះព្រះអង្គនឹងមិនដែលខានឡើយ។ នេះជាចំណុចសំខាន់ នៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:៣៥ ដែលបានចែងថា «តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន តើសេចក្តីទុក្ខលំបាក ឬសេចក្តីវេទនា សេចក្តីបៀតបៀន សេចក្តីអត់ឃ្លាន សេចក្តីអាក្រាត សេចក្តីអន្តរាយ ឬដាវឬអី?» ខគម្ពីរនេះបានបង្ហាញថា តម្រូវការដែលព្រះទ្រង់ឲ្យយើងមាន (សម្រាប់ឲ្យយើងរស់នៅ និងការស្តាប់បង្គាប់) គឺសុទ្ធតែអាចខកខានមិនបានទទួលការបំពេញ។ ការអត់ឃ្លានអាចធ្វើឲ្យខ្វះអាហារ។ ភាពអាក្រាតអាចធ្វើឲ្យយើងគ្មានអ្វីស្លៀកពាក់។ ដាវអាចផ្តាច់ជីវិត ឬកាត់ដៃជើងយើងបាន។ ម្យ៉ាងទៀត «គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍» ដែលយើងត្រូវការ មិនមែនជាអ្វីដែលយើងត្រូវការនៅទីបញ្ចប់នោះឡើយ។ ទេ! ក្នុងសេចក្តីទាំងនោះ យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យជម្នះទៅទៀត។ គ្មានអ្វីអាចពង្រាត់យើង ចេញពីក្តីស្រឡាញ់របស់ព្រះបានឡើយ (រ៉ូម ៨:៣៧-៣៩)។ ព្រះអង្គមានភាពគ្រប់គ្រាន់ ក្នុងពេលនោះ។ ហេតុនេះហើយ យើងមានអារម្មណ៍ថា យើងកំពុងតែខ្វះការគោរពចំពោះព្រះអង្គ បើយើងនិយាយថា យើងមិនត្រូវការព្រះអង្គ ឬថា យើងមានអ្វីផ្សេងទៀត ដែលយើងត្រូវការផងដែរ ដែលព្រះអង្គមិនអាចបំពេញឲ្យបាន។

ឥឡូវនេះ ខ្ញុំបាននិយាយសង្កត់ធ្ងន់ ដោយប្រើពាក្យ ក្នុងពេលនោះ ព្រោះព្រះទ្រង់នៅតែមានព្រះទ័យប្តូរផ្តាច់ ចំពោះពិភពលោក ដែលព្រះអង្គបានបង្កើត ហើយនៅក្នុងគ្រានៃការរស់ឡើងវិញ ព្រះអង្គនឹងប្រទានមកវិញនូវអ្វីដែលបានបាត់បង់ នៅក្នុងការស្លាប់។ ក្នុងពេលស្លាប់ ព្រះអង្គនឹងបង្រៀនយើងឲ្យពឹងផ្អែកលើព្រះអង្គ។ សាវ័ក ប៉ុល បាននិយាយអំពីរឿងនេះ ក្នុងបទគម្ពីរ ២កូរិនថូស ១:៨-៩។

បន្ទាប់មក មានចំណុចមួយទៀត ដែលត្រូវនិយាយសង្កត់ធ្ងន់។ សូម្បីតែ ក្នុងតម្រូវការនៃប្តីប្រពន្ធ ចំណីអាហារ សមាជិកពួកជំនុំ និងគ្រឿងទ្រទ្រង់ជីវិត គ្រឿងធ្វើឲ្យជីវិតប្រសើរឡើង ដែលព្រះទ្រង់បានប្រទានឲ្យយើងមាន ក៏ព្រះអង្គនៅតែធ្វើឲ្យភាពសប្បាយរីករាយរបស់យើងមានន័យ គឺដូចអ្វីដែលពួកព្យួរីតិនតែងនិយាយ។ ពេលណាយើងមានការសប្បាយដ៏ត្រឹមត្រូវ យើងអរសប្បាយនឹងព្រះ នៅក្នុង និងតាមរយៈប្តីប្រពន្ធ ធម្មជាតិ  ការអស្ចារ្យ និងចំណីអាហារ ដើម្បីកុំឲ្យយើងយកការទាំងនេះជាសំខាន់ជាងព្រះអង្គឡើយ។ ហើយក្នុងន័យមួយ យើងក៏អាចនិយាយថា «ខ្ញុំមានព្រះ នៅក្នុងការទាំងអស់នេះ គឺមិនគ្រាន់តែមានព្រះអង្គ បន្ថែមពីលើអ្វីទាំងអស់ ដែលធ្វើឲ្យខ្ញុំស្កប់ចិត្ត»។ ដូច្នេះ ព្រះទ្រង់ប្រើសេចក្តីត្រូវការរបស់យើង នូវមនុស្ស និងចំណីអាហារ ដើម្បីនិយាយមកកាន់យើងថា «ឃើញទេ បិតានៅក្នុងអំណោយនេះហើយ។ តើកូនឃើញបិតាទេ? តើកូនអរសប្បាយនឹងបិតា ក្នុងអំណោយទាំងនេះទេ?» ដូចនេះ តាមពិតក្នុងការដែលព្រះទ្រង់បង្កើតអ្វីដែលមិនមែនជាព្រះ ព្រះអង្គបានបង្កើតពិភពលោក ដែលក្នុងនោះ គេនឹងបានស្គាល់ និងអរសប្បាយនឹងព្រះអង្គបានពេញលេញ លើសអ្វីៗទាំងអស់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
Why Was Adam Lonely If God Is Enough？
**បើព្រះមានភាពគ្រប់គ្រាន់សម្រាប់គាត់ ហេតុអ្វីលោក អ័ដាម មានភាពឯកោ？**
https://www.desiringgod.org/interviews/why-was-adam-lonely-if-god-is-enough



# ផ្នែកទី៦
# ការចិញ្ចឹមបីបាច់ថែរក្សាកូន

## សំណួរទី៩១៖
# រកពេលអានព្រះគម្ពីរ សម្រាប់ម្ដាយដែលរវល់

«ជម្រាបសួរលោកគ្រូ! ខ្ញុំជាម្ដាយម្នាក់ដែលរវល់ ដោយសារខ្ញុំមានកូនបីនាក់នៅផ្ទះ។ តើខ្ញុំអាចរកពេលអានព្រះគម្ពីរបានដោយរបៀបណា?

នេះគឺជារបៀបដែលខ្ញុំចង់ឆ្លើយតប៖ ប្រសិនបើអ្នកជាប្រពន្ធក្នុងស្ថានភាពដូចនេះ មិនមែនម្ដាយដែលមេម៉ាយ—ដែលនោះជាចំណុចលំបាកមួយទៀតដែលខ្ញុំនឹងចែកចាយ—ប៉ុន្តែ បើអ្នកជាប្រពន្ធដែលមានប្ដីរស់នៅជាមួយក្នុងផ្ទះ សូមស្ដាប់ ឬក៏អានអត្ថបទនេះជាមួយនឹងប្ដី។ ពីព្រោះខ្ញុំក៏នឹងចង់ស្នើឲ្យគាត់មានទំនួលខុសត្រូវលើសំណួរនេះផងដែរ។ ប្ដីក៏មានទំនួលខុសត្រូវដែរ។ ពិតណាស់ ប្ដីមាន។ ហើយខ្ញុំក៏នឹងចែកចាយខ្លះៗអំពីទំនួលខុសត្រូវនេះចំពោះប្ដីដែរ។ គោលគំនិតរបស់ព្រះជាម្ចាស់សម្រាប់ជីវិតអាពាហ៍ពិពាហ៍ និងការមើលកូនគឺសម្រាប់ឪពុកម្ដាយទាំងពីរនាក់។ នោះគឺជាអ្វីដែលព្រះអង្គបានរចនាឡើង។ ហើយមូលហេតុចម្បងមួយនៃគោលគំនិតនោះគឺ ដើម្បីឲ្យម្ដាយ ឬក៏ឪពុកអាចជំនួសវេនគ្នាមើលកូន ដើម្បីឲ្យអ្នកទាំងពីរអាចមានពេលចំណាយជាមួយនឹងព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូវក្នុងព្រះបន្ទូលជាប្រចាំថ្ងៃ។

### ទំនួលខុសត្រូវរបស់ប្ដី

ខ្ញុំចង់និយាយសំដៅទៅកាន់ប្ដី៖ ប្រពន្ធលោកចង់ដឹងថា តើគាត់អាចរកពេលអានព្រះគម្ពីរតែឯងបានដោយរបៀបណា ខណៈពេលដែលកូនៗត្រូវការចំណាប់អារម្មណ៍ពីគាត់គ្រប់ពេល? នេះគឺជាអ្វីដែលខ្ញុំគិតថា ប្ដីអាចធ្វើបាន ដើម្បីជួយដល់ប្រពន្ធ។

### ១. នាំកូនដាក់ក្រោមអំណាចរបស់ខ្លួន

ដាក់ច្បាប់ និងរបៀបរបបនៅក្នុងផ្ទះ ដើម្បីកុំឲ្យកូនរត់រញ៉េរញ៉ៃ ប៉ុន្តែឲ្យពួកគាត់មានការចុះចូល ការស្តាប់បង្គាប់ និងចេះគ្រប់គ្រងលើខ្លួនឯង។ សូមសហការជាមួយនឹងប្រពន្ធក្នុងការឲ្យកូនៗចេះមានការគ្រប់គ្រងលើខ្លួនឯង។ ប្តីត្រូវមានចំណែកក្នុងការសហការនេះ ចាប់តាំងពីពេលដែលកូនទើបតែកើតមក។ ប្តីអាចចាប់ផ្តើមបង្រៀនពួកគាត់កុំឲ្យធ្វើនេះ ឬធ្វើនោះ ឬក៏ថាយើងមិនអនុញ្ញាតឲ្យការដូចនេះមាននៅក្នុងផ្ទះយើងទេ។ ម៉ោងកូនគេង និងម៉ោងញ៉ាំបាយគឺជាពេលដែលប្តីអាចពង្រឹងសណ្តាប់ធ្នាប់បាន។

សព្វថ្ងៃនេះ ខ្ញុំយល់ឃើញថា មានឪពុកម្តាយជាច្រើនបណ្តោយតាមចិត្តកូនៗរបស់ខ្លួន។ នេះគឺជាកំហុសដ៏ធំមួយ ក្នុងច្រើនកម្រិត។ ដូច្នេះឪពុកត្រូវជួយទ្រទ្រង់ទំនួលខុសត្រូវ។ សូមសហការជាមួយនឹងប្រពន្ធក្នុងការបង្កើតសភាពធម្មតា ហើយរំពឹងឲ្យមានការស្តាប់បង្គាប់—ចូររំពឹងឲ្យពួកគាត់ចុះចូលក្រោមអំណាចរបស់ខ្លួន និងអំណាចរបស់ម្តាយ។ នេះគឺជាចំណុចទីមួយ៖ ឪពុកម្តាយត្រូវតែគ្រប់គ្រងលើគ្រប់ផ្នែកនៃបរិយាកាសនៅក្នុងផ្ទះ ដោយមានសណ្តាប់ធ្នាប់។

### ២. សូមចំណាយពេលលេងជាមួយកូនជារៀងរាល់ថ្ងៃ

សូមបង្កើតពេល ដើម្បីចំណាយពេលលេងជាមួយកូនជារៀងរាល់ថ្ងៃ។ របៀបលេងនឹងមានការផ្លាស់ប្រែ អាស្រ័យទៅលើអាយុរបស់កូន ប៉ុន្តែសូមផ្តោតចំណាប់អារម្មណ៍ទាំងអស់របស់លោកអ្នកទៅកាន់កូនៗជារៀងរាល់ថ្ងៃ ដែលការធ្វើបែបនោះនឹងឲ្យប្រពន្ធមានពេលទំនេរ។

សម្រាប់គ្រួសារខ្ញុំផ្ទាល់ ខ្ញុំបានចំណាយពេលលេងជាមួយកូនៗក្រោយម៉ោងបាយ ហើយយើងបានធ្វើបែបនោះជាច្រើនឆ្នាំ។ យើងញ៉ាំបាយល្ងាចនៅម៉ោង ៥:៣០ ហើយចប់នៅម៉ោង ៦:០០។ ចាប់ពីម៉ោង ៦:០០-៧:០០ ខ្ញុំចំណាយពេលលេងជាមួយនឹងកូនៗរបស់ខ្ញុំទាំងអស់ ដោយខ្ញុំជាអ្នកមើលគាត់—ព្រោះប្រពន្ធខ្ញុំបានមើលកូនពេញមួយថ្ងៃហើយ។ ខ្ញុំអាចមើលកូនបានមួយម៉ោង ហើយប្រពន្ធខ្ញុំអាចធ្វើអ្វីដែលគាត់ចង់ធ្វើក៏បានដែរ នៅពេលនោះ។ ហើយប្រសិនបើនោះជាពេលដែលគាត់ត្រូវអានព្រះគម្ពីរ ឥឡូវគាត់មានពេលហើយ។

### ៣. សូមញែកពេលឲ្យបានញឹកញាប់ ដើម្បីឲ្យឪពុក ឬក៏ម្តាយមានពេលចេញដើរលេង

សូមញែកពេលដើរលេងក្នុងជីវិតលោកអ្នក និងប្រពន្ធ ដើម្បីឲ្យគាត់អាចមានពេលសម្រាកកន្លះថ្ងៃ ឬក៏មួយថ្ងៃពេញម្តងម្កាលដែរ។ ប្តីត្រូវមានទំនួលខុសត្រូវក្នុងចំណែកនៃការចំណាយពេលឆ្លាស់គ្នាជាមួយប្រពន្ធ។ ឧទាហរណ៍៖ ប្តីអាចមើលកូននៅព្រឹកថ្ងៃសៅរ៍ ឬក៏រកអ្នកឲ្យជួយមើល ដែលទាំងពីរនាក់ត្រូវឆ្លាស់គ្នាដូចនេះជានិច្ចជាកាល ដោយយកពេលចំណាយជាមួយនឹងព្រះជាម្ចាស់ឲ្យបានច្រើន។

### ៤. សង្វាតដេញតាមព្រះជាម្ចាស់ក្នុងព្រះបន្ទូលរបស់ទ្រង់

សូមដឹកនាំប្រពន្ធដោយចំណាយពេលក្នុងព្រះបន្ទូល ដើម្បីកុំឲ្យសេចក្តីប្រាថ្នារបស់គាត់មានការរេរា ដោយសារគំរូរបស់ប្តីការសង្វាតដេញតាមទ្រព្យសម្បត្តិ និងភាពផ្អែមល្ហែមនៃព្រះបន្ទូលជាមួយនឹងគាត់។

### ៥. សូមញែកពេលនិយាយគ្នាអំពីរឿងរ៉ាវដែលមានប្រយោជន៍

ពេលសន្ទនា សូមនិយាយជាមួយនឹងប្រពន្ធ អំពីរឿងសំខាន់ៗ ដែលមានរួមទាំងអ្វីដែលមានចែងនៅក្នុងព្រះបន្ទូល ដើម្បីកុំឲ្យគាត់បាត់បង់ទស្សនៈនៅពេលដែលគាត់ចំណាយពេលជាមួយនឹងកូនៗ។

### ៦. សូមអធិស្ឋានឲ្យប្រពន្ធ

ហើយជាចុងក្រោយ សូមអធិស្ឋានឲ្យប្រពន្ធ—អធិស្ឋានឲ្យគាត់មានកត្តាជំរុញចិត្ត មានការដាក់វិន័យ និងការសប្បាយចិត្តក្នុងការចំណាយពេលក្នុងព្រះបន្ទូល។

### ពេលវេលាជាមួយព្រះជាម្ចាស់

ឥឡូវ ខ្ញុំចង់បញ្ចប់ពេលយើង ដោយលើកឡើងសំដៅទៅកាន់អ្នកម្ដាយម្ដង។ អ្នកទំនងជាមិនមានប្ដីដែលមានចិត្តដូចនោះ។ បើដូចនោះមែន សូមព្យាយាមធ្វើដោយខ្លួនឯងចុះ ហើយព្រះជាម្ចាស់ក៏នឹងជួយអ្នកដែរ។ ពិតណាស់ ព្រះអង្គនឹងជួយ។ មិនមានសេចក្ដីល្បួង ឬក៏សេចក្ដីល្បងលណាដែលនឹងកើតឡើងចំពោះអ្នក ដែលព្រះជាម្ចាស់នឹងមិនប្រទានព្រះគុណដល់អ្នកក្នុងការទ្រទ្រង់ទេ (សូមអាននៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១០:១៣)។ ដូច្នេះ អ្នកអាចមើលគំរូរបស់លោកស្រី សូសាណា វេសលី (Susannah Wesley) ដែលជាម្ដាយរបស់លោក ឆាលស៍ (Charles) និងលោក ចន វេសលី (John Wesley)។ គាត់មានកូន១៩នាក់។ ប្រាំបួននាក់បានស្លាប់កាលនៅជាទារក ដែលនេះមានន័យថា គាត់នៅសល់កូន១០នាក់។ គាត់បានសន្យាទៅកាន់ព្រះអម្ចាស់ថា គាត់នឹងចំណាយពេលអធិស្ឋាន និងអានព្រះបន្ទូលជារៀងរាល់ថ្ងៃ ហើយមានពេលមួយ យុទ្ធសាស្ត្ររបស់គាត់គឺដូចនេះ៖ គាត់បានបង្រៀនកូនបងៗថា ពួកគាត់មានទំនួលខុសត្រូវជាមួយនឹងកូនប្អូនៗ។ ហើយនៅពេលដែលកូនៗឃើញម្ដាយយកអៀមចំអិនម្ហូបមកគ្របលើក្បាលនៅតុញ៉ាំបាយ នោះមានន័យថា កូនៗមិនត្រូវមកឆាឆៅគាត់ឡើយ។ កូនបងៗត្រូវកុំឲ្យប្អូនៗមានការរញ៉េរញ៉ៃ ព្រោះនោះគឺជាពេលដែលគាត់កំពុងចំណាយពេលជាមួយនឹងព្រះជាម្ចាស់។

ដូច្នេះ សូមបង្រៀនកូនៗរបស់លោកអ្នកឲ្យមានទំនួលខុសត្រូវដូចនេះដែរចុះ។ ចូររំពឹងឲ្យពួកគាត់ចេះស្ដាប់បង្គាប់។ ម្ដាយអាចត្រាប់តាមលោកស្រី សូសាណា វេសលី ឬក៏រកកន្លែងស្ងាត់ណាមួយបាន។ ហើយប្ដីត្រូវមានការទ្រាំទ្រ និងការសហការយ៉ាងខ្លាំងជាមួយនឹងប្រពន្ធដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Bible Time for Busy Moms
**រកពេលអានព្រះគម្ពីរ សម្រាប់ម្ដាយដែលរវល់**
https://www.desiringgod.org/interviews/bible-time-for-busy-moms

សំណួរទី៩២៖

# តើការចិញ្ចឹមកូនគឺជារឿងស្មុគស្មាញ ឬក៏ជារឿងសាមញ្ញ?

*គោះ! ចូរយើងចាប់ផ្ដើមដោយមើលរូបភាពធំ៖ ការចិញ្ចឹមកូនគឺជារឿងពិបាក ហើយក៏តម្រូវឲ្យមានការទាមទារពេលវេលាជាច្រើន—ខ្ញុំគិតថា ឪពុកម្ដាយគ្រប់ៗរូបនឹងឯកភាពលើចំណុចនេះ។ ប៉ុន្តែ តើគោលដៅ និងគោលបំណងនៃការចិញ្ចឹមបីបាច់ថែរក្សាកូនៗពិតជារឿងដែលស្មុគស្មាញមែនឬ? បើសួរម៉្យាងវិញទៀតទៅ៖ តើឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទ ហាក់បីដូចជាបានធ្វើឲ្យវាសាមញ្ញពេក ទាក់ទងនឹងការចិញ្ចឹមកូន ឬក៏ធ្វើឲ្យវាស្មុគស្មាញពេក។*

ខ្ញុំឯកភាពថា ការចិញ្ចឹមកូនគឺជារឿងដែលពិបាក ដែលទាមទារពេលវេលា ការផ្ដោតលើជាច្រើន និងការធ្វើដោយឆន្ទៈ ប៉ុន្តែខ្ញុំគិតថាវាមិនចាំបាច់មានការស្មុគស្មាញខ្លាំងពេកនោះទេ។ បញ្ហាមួយដែលយើងមាន ក្នុងសម័យទំនើបនេះ គឺថាមនុស្សយើងចង់មានកូន ប៉ុន្តែពួកគាត់មិនចង់ធ្វើជាឪពុកម្ដាយទេ។ ហាក់បីដូចជាថា យើងមានទស្សនៈថាកូនយើងគឺជាកម្មសិទ្ធិរបស់យើង «ខ្ញុំមានកូន។ ពួកគាត់ស្អាតដែរឬទេ?» ជាពិសេសនៅពេលដែលពួកគាត់នៅក្មេង ហើយមនុស្សគ្រប់គ្នាសរសើរកូនយើង។ ប៉ុន្តែ ការត្រាស់ហៅឲ្យធ្វើជាឪពុកម្ដាយគឺជាការផ្ដោតទៅលើពេលវេលាទាំងអស់។ ដាច់ខាត! វាត្រូវតែជាចំណុចចម្បងមួយ ដែលលោកអ្នកត្រូវតែមានចំណែកក្នុងការចិញ្ចឹមកូន។

## ការមើលថែ មិនមែនគ្រាន់តែជាការគ្រប់គ្រងទេ

ដូច្នេះ ខ្ញុំគិតថាការស្គាល់ព្រះជាម្ចាស់ និងត្រាប់តាមគំរូរបស់ទ្រង់ សម្រាប់កូនៗយើង គឺជារូបភាពធំដ៏ពិត—ត្រង់ថា ខ្ញុំគឺជាគ្រីស្ទបរិស័ទ ខ្ញុំស្រឡាញ់ព្រះជាម្ចាស់ និងខ្ញុំចង់នាំឲ្យកូនៗរបស់ខ្ញុំចូលមកក្នុងពិភពនៃវិញ្ញាណទាំងមូលនៃព្រះដ៏អស្ចារ្យ ដើម្បីឲ្យពួកគាត់ស្រឡាញ់ទ្រង់និងមានអំណរក្នុងទ្រង់។ ហើយបន្ទាប់មកជួយឲ្យពួកគាត់ឃើញ និងឱបក្រសោបសេចក្តីល្អនៃផ្លូវរបស់ព្រះជាម្ចាស់ និងទ្រព្យសម្បត្តិដ៏ពិតនៃសេចក្តីពិតរបស់ទ្រង់។ នេះគឺជាទិសដៅដែលខ្ញុំចង់ទៅដល់ ជាមួយនឹងកូនៗរបស់ខ្ញុំ ក្នុងគ្រប់ពេលវេលា។

ក្នុងពាក្យពេចន៍ដ៏សាមញ្ញបំផុត នេះគឺជាទស្សនៈត្រួសៗ ដែលខ្ញុំចង់ឲ្យឪពុកម្តាយទាំងអស់ទទួលបាន៖ គោលដៅរបស់យើងគឺមិនមែនគ្រាន់តែដើម្បីគ្រប់គ្រងលើអាកប្បកិរិយាប៉ុណ្ណោះនោះទេ។ គោលដៅដ៏ពិតនោះគឺ ការថែរក្សាដួងចិត្តរបស់កូនៗយើងទេ។ ការអប់រំគឺជាគោលដៅត្រង់ថាទំនួលខុសត្រូវរបស់យើងក្នុងនាមជាឪពុកម្តាយគឺមិនមែនគ្រាន់តែដើម្បីត្រួតពិនិត្យ ឃាត់ឃាំង ដាក់កំហិតលើជម្រើស ឬក៏ដើម្បីគ្រប់គ្រងលើកូន ដើម្បីឲ្យគាត់អាចបត់បែនតាមច្បាប់របស់យើង ហើយធ្វើតាមអ្វីដែលយើងចង់ឲ្យគាត់ធ្វើតាមនោះទេ។ ខ្ញុំគិតថា ឪពុកម្តាយជាច្រើនមិនបានធ្វើអ្វីលើសពីការផ្តោតបែបនេះ សូម្បីតែឪពុកម្តាយដែលជាគ្រីស្ទបរិស័ទដែរ។

ប៉ុន្តែ អ្វីដែលយើងចង់ធ្វើនោះគឺ ថែរក្សាដួងចិត្តរបស់គាត់។ យើងចង់ឲ្យពួកគាត់យល់ថា ដួងចិត្តពួកគាត់គឺជារន្ធអណ្តូងនៃជីវិត៖ «ចូររក្សាចិត្តដោយអស់ពីព្យាយាម ដ្បិតអស់ទាំងផលនៃជីវិត សុទ្ធតែចេញពីក្នុងចិត្តមក» (សុភាសិត ៤:២៣)។ ហើយជាលទ្ធផល គ្រប់ជម្រើស សេចក្តីប្រាថ្នា និងគោលបំណងរបស់បុគ្គលណាម្នាក់គឺមានចងភ្ជាប់នៅក្នុងចិត្ត ហេតុដូច្នេះហើយបានជាយើងធ្វើការសម្រេចចិត្ត និងការជ្រើសរើស ដោយមានមូលដ្ឋានលើអ្វីដែលជាចំណាប់អារម្មណ៍យើង និងសំខាន់ដល់យើង។

## ការនិយាយទៅកាន់ដួងចិត្តរបស់កូនយើង

នេះគឺជាអ្វីដែលយើងចង់ធ្វើក្នុងគ្រប់ដំណាក់កាលនៃការចិញ្ចឹមកូន។ ហើយរបៀបដែលយើងធ្វើនឹងមានលក្ខណៈខុសៗគ្នាពីរបៀបដែលយើងធ្វើជាមួយនឹងកូនដែលមានអាយុពីរឆ្នាំ និងជាមួយកូនដែលមានវ័យជំទង់។ កូនដែលមានអាយុពីរឆ្នាំនឹងមិនមានការយល់ដឹងខ្លួនឯងអំពីការជំរុញ។ យើងមិនអាចសួរគាត់អំពីដួងចិត្តរបស់គាត់បានឡើយ។ ដ្បិតគាត់មិនទាំងយល់បានផង។ គាត់មិនស្គាល់ពាក្យដើម្បីនិយាយ មិនមានការយល់ដឹងជ្រៅជ្រះ មិនទាន់មានចំណេះដឹង ហើយគាត់ក៏ថែមទាំងមិនទាន់មានខួរក្បាលដើម្បីធ្វើអន្តរអំពើលើសំណួរនេះផង។ ដូច្នេះ យើងចាប់ផ្តើមនិយាយជាមួយកូនៗរបស់យើងអំពីដួងចិត្ត នៅពេលដែលយើងប្រដៅគាត់។ ឧទាហរណ៍៖ កូនពៅយើងរុញប្អូនស្រីរបស់គាត់ ហើយដណ្តើមយករបស់លេងគាត់ ពិតណាស់យើងចង់កែតម្រង់អាកប្បកិរិយានោះ៖ «អត់ទេកូន! អត់ទេ! កូនមិនអាចធ្វើដូចនេះបានទេ។ ប្អូនស្រីកូនកំពុងតែលេងរបស់នោះ។ យើងត្រូវតែឲ្យគាត់លេងវិញ»។

នៅពេលដែលយើងកែតម្រង់កូនៗ យើងត្រូវតែប្រើភាសាបេះដូងក្នុងការពណ៌នា៖ «កូន! កូនឯងកំពុងតែមិនមានចិត្តល្អដាក់ប្អូនស្រី។ កូនកំពុងតែស្រឡាញ់ខ្លួនឯង ហើយមិនស្រឡាញ់ប្អូនទេ។ កូនកំពុងតែបម្រើខ្លួនឯង មិនមែនបម្រើប្អូន។ កូនត្រូវតែឲ្យរបស់លេងនោះទៅកាន់ប្អូនវិញ។ ប្អូនកំពុងតែលេងជាមួយនឹងរបស់នោះ។ នេះគឺជារបៀបដែលកូនអាចបង្ហាញសេចក្តីស្រឡាញ់ចំពោះប្អូន»។

ដូច្នេះ សូម្បីតែនៅពេលដែលយើងកំពុងតែកែតម្រង់កូនរបស់យើងដែលមានអាយុពីរឆ្នាំ យើងត្រូវតែនិយាយឲ្យលើសពីការគ្រាន់តែ «ឲ្យរបស់

នោះទៅប្អូនវិញភ្លាម។ នេះមិនល្អទេ។ កុំធ្វើជាមនុស្សអាក្រក់។ ត្រូវធ្វើល្អដាក់ប្អូន»។ ការប្រើប្រាស់ពាក្យពេចន៍ដូចនោះមិនមានអត្ថន័យទេ។ ចំពោះគាត់ វាមិនមានន័យអ្វីឡើយ។ ដូច្នេះ យើងត្រូវផ្តល់អត្ថន័យលើពាក្យទាំងនោះ ដោយនិយាយសំដៅទៅកាន់ដួងចិត្តវិញ។ ហើយចំពោះកូនៗដែលមានវ័យជំទង់ ពិតណាស់យើងអាចនិយាយអំពីបញ្ហាដួងចិត្តបានជ្រៅជ្រះជាងនោះ ហើយក៏ថែមទាំងអាចបង្រៀនគាត់អំពីអាកប្បកិរិយានៃដួងចិត្ត និងអំពីរបៀបដែលអាកប្បកិរិយានោះទទួលការរុញច្រានពីអ្វីៗដែលកំពុងតែកើតឡើងនៅជុំវិញពួកគាត់។

សរុបសេចក្តីទៅ តាមរយៈព្រះគុណរបស់ព្រះជាម្ចាស់ តាមពិតទៅ គោលបំណងនៃការចិញ្ចឹមកូន គឺដើម្បីឲ្យពួកគាត់ក្លាយជាគ្រីស្ទបរិស័ទដែលពេញដោយជំនឿ។

ពិតណាស់ យើងក៏ចង់ឲ្យកូនយើងយល់អំពីធាតុពិតនៃពិភពលោកដែលនៅជុំវិញពួកគាត់ផងដែរ។ ត្រង់ថា មានព្រះដែលគង់នៅស្ថានសួគ៌។ ព្រះអង្គពេញទៅដោយសិរីល្អ។ ព្រះអង្គពេញទៅដោយសេចក្តីសប្បុរស។ ហើយយើងក៏ចង់ឲ្យពួកគាត់ឃើញសេចក្តីសប្បុរសរបស់ទ្រង់ផងដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is Parenting Complicated or Simple?
**តើការចិញ្ចឹមកូនគឺជារឿងស្មុគស្មាញ ឬក៏ជារឿងសាមញ្ញ?**
https://www.desiringgod.org/interviews/is-parenting-complicated-or-simple



## សំណួរទី៤៣៖
# របៀប៦យ៉ាងសម្រាប់ឪពុកម្តាយដែលមានកូនរឹងចចេស អាចតយុទ្ធជាមួយបាន ដើម្បីជំនឿ

*សូមលោកគ្រូចែកចាយលើប្រធានបទទាក់ទងទៅនឹងការដែលមានកូនរឹងចចេសបានដែរឬទេ? តើយើងអាចបន្តទុកចិត្តលើព្រះជាម្ចាស់បានដោយរបៀបណា នៅពេលដែលយើងឃើញថាមិនមានភស្តុតាងនៃការដែលព្រះអង្គកំពុងតែធ្វើការនៅក្នុងជីវិតកូនយើង?*

នេះគឺជាសំណួរដ៏ត្រឹមត្រូវក្នុងការសួរថា៖ តើយើងអាចបន្តទុកចិត្តលើព្រះជាម្ចាស់បានដោយរបៀបណា?

## អ្វីដែលឪពុកម្តាយ និងកូនៗត្រូវការខ្លាំងជាងគេបំផុត

តម្រូវការដ៏សំខាន់បំផុតសម្រាប់ឪពុកម្តាយគ្រប់ៗរូបគឺទុកចិត្តលើព្រះជាម្ចាស់៖

- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់បានធ្វើការសម្រាប់យើងក្នុងព្រះយេស៊ូវ ដើម្បីសង្គ្រោះយើងចេញពីអំពើបាបរបស់យើង
- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងបំពេញរាល់គ្រប់សេចក្តីសន្យារបស់ទ្រង់ទៅកាន់កូនៗរបស់ទ្រង់
- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងទ្រទ្រង់យើង—“កុំឲ្យភ័យខ្លាចឡើយ ដ្បិតអញនៅជាមួយនឹងឯង កុំឲ្យស្រយុតចិត្តឲ្យសោះ ពីព្រោះអញជាព្រះនៃឯង អញនឹងចម្រើនកម្លាំងដល់ឯង អើ អញនឹងជួយឯង អើ អញនឹងទ្រឯង ដោយដៃស្តាំដ៏សុចរិតរបស់អញ” (អេសាយ ៤១:១០)—ព្រះអង្គនឹងរក្សាសេចក្តីសន្យានោះ

- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងមិនបដិសេធមិនប្រទាននូវអ្វីដែលល្អសម្រាប់អស់អ្នកដែលដើរនៅក្នុងផ្លូវត្រឹមត្រូវ (ទំនុកតម្កើង ៨៤:១១)
- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងគ្រាន់តែប្រទានមកកាន់យើងនូវអ្វីដែលល្អសម្រាប់យើង ហើយថារាល់ផ្លូវរបស់ទ្រង់យុត្តិធម៌ និងពេញដោយប្រាជ្ញា

អ្វីដែលកូនៗយើងត្រូវការពីយើងខ្លាំងជាងគេនោះគឺឃើញយើងមានអំណរ មានសេចក្តីសង្ឃឹម មានសន្តិភាព មានការស្តាប់បង្គាប់ ការទុកចិត្តព្រះជាម្ចាស់ និងការសម្រាកក្នុងទ្រង់។ ហើយចម្លើយដែលដកស្រង់ចេញពីព្រះគម្ពីរលើសំណួរនេះ—តើយើងអាចបន្តទុកចិត្តលើព្រះជាម្ចាស់ក្នុងចំណុចនេះ និងក្នុងរាល់កាលៈទេសៈបានដោយរបៀបណា—គឺថាយើងឃើញយ៉ាងច្បាស់នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១០:១៧ «ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ»។

ហើយខ្ញុំគិតថា នេះមិនមែនមានន័យថា វាគ្រាន់តែពាក់ព័ន្ធទៅនឹងការដែលលោកអ្នកបានកែប្រែចិត្ត ហើយទទួលបានជំនឿនៅលើកដំបូង តាមរយៈការឮអំពីព្រះគ្រីស្ទនោះទេ ប៉ុន្តែក៏អំពីការដែលលោកអ្នកទទួលបានជំនឿដែលទទួលបានកម្លាំងជាថ្មីជារៀងរាល់ថ្ងៃ តាមរយៈការឮផងដែរ។ ជំនឿកើតឡើងជាប្រចាំថ្ងៃតាមរយៈការឮ។ ជំនឿមិនកើតឡើងតាមរយៈបុគ្គលណាម្នាក់នោះទេ លើកលែងតែតាមរយៈព្រះយេស៊ូវ។ ជំនឿកើតឡើងតាមរយៈការដែលគ្រូណាម្នាក់អានព្រះគម្ពីរ និងអនុវត្តតាម—បើមិនដូច្នោះ នោះវានឹងមិនបានកើតឡើងឡើយ។

## ការរម្លឹកដ៏មានតម្លៃ៦យ៉ាងសម្រាប់ឪពុកម្តាយ

សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវខគម្ពីរមួយចំនួនដែលខ្ញុំសង្ឃឹមថានឹងចម្រើនកម្លាំងដល់ជំនឿរបស់យើង ទាក់ទងទៅនឹងកូនៗរបស់យើង។



### ១. ឪពុកម្តាយដ៏ល្អបំផុតនៅក្នុងចក្រវាលនេះមានកូនដែលរឹងចចេស

ជាដំបូង ខ្ញុំគិតថា វាជាជំនួយដល់ឪពុកម្តាយក្នុងការដឹងថា ទោះបើថាវាចម្លែកប៉ុណ្ណាក៏ដោយ ក៏កូនៗរបស់ព្រះជាម្ចាស់ផ្ទាល់ក៏បានបះបោរទាស់ប្រឆាំងនឹងទ្រង់ផងដែរ។

«ឱស្ថានសួគ៌អើយ ចូរស្តាប់ ហើយផែនដីអើយ ចូរផ្ទៀងត្រចៀកចុះ
　　ដ្បិតព្រះយេហូវ៉ាទ្រង់បានមានព្រះបន្ទូលហើយថា
អញបានចិញ្ចឹមបីបាច់រក្សាកូន
　　តែវារាល់គ្នាបានបះបោរនឹងអញវិញ
ឯគោវាស្គាល់ម្ចាស់
　　ហើយលាក៏ស្គាល់ស្នូករបស់ម្ចាស់វាដែរ
ប៉ុន្តែអ៊ីស្រាអែលមិនស្គាល់សោះ
　　រាស្ត្រអញមិនពិចារណាទេ» (អេសាយ ១:២-៣)។

មិនមានឪពុកម្តាយណានៅលើផែនដីនេះដែលជាមនុស្សមិនមានបាបតែពេញទៅដោយប្រាជ្ញា ពេញទៅដោយការស្រឡាញ់ ឬក៏ពេញទៅដោយការអត់ធ្មត់នោះទេ។ ក្នុងនាមជាឪពុកម្តាយ អំពើបាបដែលយើងបានប្រព្រឹត្តនូវក្នុងវត្តមានរបស់កូនៗយើង និងអំពើបាបដែលយើងបានប្រព្រឹត្តទៅលើកូនៗរបស់យើងគឺរាប់មិនអស់ទេ ហើយយើងត្រូវតែកែប្រែចិត្តជាប្រចាំ ហើយសូមការអត់ទោស—ទាំងពីព្រះជាម្ចាស់ និងកូនៗរបស់យើង។ ប៉ុន្តែ សូម្បីតែឪពុកដែលល្អបំផុតនៅលើចក្រវាលនេះ—ព្រះជាម្ចាស់ផ្ទាល់—ក៏មានកូនៗដែលទាស់ប្រឆាំងនឹងទ្រង់ផងដែរ។ ដូច្នេះ កុំអនុញ្ញាតឲ្យសាតាំងទាញទម្លាក់លោកអ្នកឡើយ ដោយមានពិរុទ្ធភាពដែលបំផ្លាញជំនឿរបស់ខ្លួនខ្លាំងជាងលោកអ្នកអាចទ្រទ្រង់បាន។

## ២. ព្រះគុណរបស់ព្រះជាម្ចាស់ក៏អាចឈោងចាប់មនុស្សមានបាបដ៏ខ្លាំងបំផុតបានដែរ

សាវ័ក ប៉ុល បានលើកឡើងខ្លួនគាត់ជាឧទាហរណ៍ថាជាមនុស្សមានបាបដ៏ខ្លាំងជាងគេបំផុត ដែលនេះមិនគ្រាន់តែមានន័យថា គាត់បានប្រព្រឹត្តនូវអ្វីដែលអាក្រក់ៗខ្លាំងជាងគេនោះទេ ប៉ុន្តែមានន័យថាគាត់បានប្រព្រឹត្តទាស់នឹងពន្លឺដ៏ខ្លាំងបំផុត គឺព្រះជាម្ចាស់ផ្ទាល់។ គាត់បានធំធាត់ឡើងក្រោមការដឹកនាំរបស់លោក កាម៉ាលាល ដែលជាគ្រូបង្រៀនព្រះគម្ពីរសញ្ញាចាស់ដ៏ល្អបំផុតដែលមាននៅក្នុងសម័យកាលនោះ។ គាត់បានលើកឧទាហរណ៍នេះដើម្បីលើកទឹកចិត្តយើងថា គ្មានអ្នកណាក្នុងចំណោមយើង ឬក៏ក្នុងចំណោមកូនៗរបស់យើង ដែលព្រះមិនអាចកែបាននោះឡើយ។ ហេតុដូច្នេះហើយបានជាគាត់សរសេរនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ១:១២-១៥៖

«ខ្ញុំមិនបើកឲ្យស្ត្រីណាបង្រៀន ឬឲ្យមានអំណាចលើបុរសទេ ត្រូវឲ្យគេនៅដោយស្រគត់ស្រគំចុះ ពីព្រោះព្រះបានបង្កើតលោកអ័ដាមមកជាមុន រួចមកនាងអេវ៉ា ហើយមិនមែនលោកអ័ដាម ដែលចាញ់បញ្ឆោតទេ គឺជាស្ត្រីវិញទេតើ ដែលចាញ់បញ្ឆោតនោះព្រមទាំងរំលងច្បាប់ផង តែបើសិនជានាងនៅជាប់ក្នុងសេចក្តីជំនឿ សេចក្តីស្រឡាញ់ នឹងសេចក្តីបរិសុទ្ធ ទាំងមានគំនិតមារយាទ នោះនាងនឹងបានសង្គ្រោះក្នុងកាលដែលបង្កើតកូន»។

នេះមានន័យថា មិត្តអ្នកអានសុទ្ធតែស្គាល់នរណាម្នាក់ ឬក៏ខ្លួនធ្លាប់ជាបុគ្គលដែលបានប្រព្រឹត្តអំពើបាបយ៉ាងសាហាវ ដែលពីមុនធ្លាប់បានធំធាត់ឡើងក្នុងផ្ទះ ដែលមានឪពុកម្តាយល្អ ប៉ុន្តែបានបោះបង់ឱកាសនោះចោលជាច្រើនដង គឺជាបុគ្គលដែលមិនមែននៅឆ្ងាយពេក ដល់ថ្នាក់ថាការអត់ធ្មត់របស់ព្រះយេស៊ូវមិនអាចឈោងចាប់គាត់បានឡើយ។ ដូច្នេះ យើងរម្លឹកចំណុចនេះមកកាន់ខ្លួនឯង ហើយយើងចម្រើនកម្លាំងដល់ជំនឿរបស់យើងតាមរយៈប្រយោគដ៏អស្ចារ្យនោះរបស់សាវ័ក ប៉ុល។



## ៣. ព្រះជាម្ចាស់មានពេញទៅដោយអធិបតេយ្យភាពលើដួងចិត្តរបស់មនុស្ស

សូមសញ្ជឹងគិតឲ្យបានច្រើនដងលើសេចក្តីពិតត្រង់ថា ព្រះជាម្ចាស់មានពេញទៅដោយអធិបតេយ្យភាពលើដួងចិត្តរបស់មនុស្ស ហើយជាលទ្ធផលអាចនាំឲ្យសត្វអូដ្ឋចូលតាមរយៈរន្ធម្ជុលបាន ដែលនោះគឺជាការមិនអាចទៅរួចបាន។

ខ្ញុំលើកឡើងដូច្នេះគឺដោយសារនៅពេលដែលបុរសដែលជាអ្នកមានបានដើរចេញពីព្រះយេស៊ូវ គឺគាត់បានធ្វើដូច្នោះ ពីព្រោះគាត់ស្រឡាញ់លោកីយ៍—ហើយលោកអ្នកទំនងជាគិតថា នោះគឺជាអ្វីដែលកូនៗរបស់ខ្ញុំកំពុងតែធ្វើ ហើយក៏ធ្លាប់បានធ្វើ៖ ពួកគាត់បានដើរចេញ ហើយឥឡូវនេះពួកគាត់កំពុងតែស្រឡាញ់លោកីយ៍។ នេះគឺជាអ្វីដែលព្រះយេស៊ូវបានលើកឡើងអំពីបុរសម្នាក់នោះ «"កូនអើយ ពួកអ្នកដែលជាប់ចិត្តនឹងទ្រព្យសម្បត្តិនោះនឹងចូលទៅក្នុងនគរព្រះពិបាកណាស់"...គេ [ពួកសិស្ស] ក៏មានសេចក្តីប្លែកក្នុងចិត្តជាខ្លាំង ទាំងនិយាយគ្នាទៅវិញទៅមកថា "ចុះបើដូច្នេះ តើអ្នកណាអាចនឹងបានសង្គ្រោះ"» (ម៉ាកុស ១០:២៤, ២៦)។ ពួកសិស្សមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

ហើយព្រះយេស៊ូវក៏បានឆ្លើយតបនៅក្នុងកណ្ឌគម្ពីរ ម៉ាកុស ១០:២៧ «ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន. . .»។ នេះគឺជាអ្វីដែលឪពុកម្តាយជាច្រើនមានអារម្មណ៍។ ពួកគាត់មិនគួរផ្តោតលើចំណុចនេះឡើយ។ ពួកគាត់គួរផ្តោតលើផ្នែកទី២នៃខគម្ពីរនេះ៖ «ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន»។

ឱឪពុកម្តាយទាំងឡាយអើយ យើងត្រូវតែរម្លឹកខ្លួនឯងម្តងហើយម្តងទៀតថា៖ «ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត តែព្រះទ្រង់

ធ្វើកើត គ្រប់ទាំងអស់ព្រះទ្រង់ធ្វើកើត»។ ព្រះអង្គកំពុងតែមានបន្ទូលអំពីការនាំបុគ្គល ដែលស្រឡាញ់ទ្រព្យសម្បត្តិរបស់ខ្លួន និងលោកីយ៍ ចូលក្នុងនគររបស់ព្រះ។ ហើយព្រះអង្គបានមានបន្ទូលថា «យើងអាចធ្វើបាន។ យើងអាចធ្វើបាន។ ឯងមិនអាចធ្វើបានទេ។ ប៉ុន្តែ យើងអាចធ្វើបាន។ ដូច្នេះ ចូរទុកចិត្តយើងចុះ»។

## ៤. ចូរយកព្រះយេហូវ៉ាជាសេចក្តីអំណររបស់អ្នក

សូមផ្តោតចំណាប់អារម្មណ៍របស់លោកអ្នកក្នុងការយកព្រះជាម្ចាស់ជាសេចក្តីអំណររបស់ខ្លួន មិនមែនលើការដែលកូនៗរបស់លោកអ្នកនឹងកែប្រែចិត្តឡើយ។ សូមកុំយល់ច្រឡំថា លោកអ្នកបានគួរសប្បាយចិត្តនៅពេលដែលកូនៗកែប្រែចិត្តឡើយ។ វាគឺជារឿងត្រឹមត្រូវក្នុងការដែលលោកអ្នកសប្បាយចិត្តនៅពេលដែលកូនៗរបស់ខ្លួនកែប្រែចិត្ត។ ប្រសិនបើលោកអ្នកមិនសប្បាយចិត្ត នោះមានន័យថា លោកអ្នកមិនប្រក្រតីទេ។ អ្វីដែលខ្ញុំកំពុងតែលើកឡើងនោះគឺថា តើលោកអ្នកផ្តោតលើអ្វីក្នុងជីវិតខ្លួន។

ខ្ញុំកំពុងតែគិតអំពីកណ្ឌគម្ពីរ ទំនុកតម្កើង ៣៧:៤ «ចូរយកព្រះយេហូវ៉ាជាសេចក្តីអំណររបស់អ្នក នោះទ្រង់នឹងប្រទានឲ្យអ្នកបានដូចបំណងចិត្ត»។ សូមផ្តោតកម្លាំងខាងឯវិញ្ញាណរបស់លោកអ្នកលើការបង្កើតសេចក្តីអំណរក្នុងព្រះជាម្ចាស់ថាទ្រង់ជាព្រះ ក្នុងរបៀបដែលរឹងមាំ ជ្រាលជ្រៅ ឥតរង្គើ និងពេញទៅដោយការស្កប់ចិត្ត។ គឺនៅក្នុងតែរបៀបនេះទេ នោះទើបយើងអាចស្ថិតក្នុងកាលៈទេសៈដែលអាចទទួលបាននូវអ្វីដែលមានសល់នៅក្នុងខគម្ពីរនេះ៖ «នោះទ្រង់នឹងប្រទានឲ្យអ្នកបានដូចបំណងចិត្ត»។

## ៥. ចូរមានបំណងចិត្តចង់ឃើញមនុស្សបាត់បង់ទទួលជឿ

សូមបណ្តាលឲ្យការមានបំណងចិត្ត ការឈឺចាប់ ការអធិស្ឋាន និងសម្រែកយំ របស់លោកអ្នកមានសម្រាប់កូនៗខ្លួន—សូមអនុញ្ញាតឲ្យការដែលលោកអ្នកចង់ឃើញកូនៗរបស់ខ្លួនកែប្រែចិត្ត និងស្តាប់បង្គាប់—ក្លាយជាម្ចាស់នៃការដែលលោកអ្នកចង់ឃើញអ្នកដទៃ ដែលបានបាត់បង់ទទួលជឿផងដែរ។ ចំពោះខ្ញុំ ចំណុចនេះបានក្លាយជាមេរៀនដ៏ធំបំផុត ខណៈពេលដែលខ្ញុំចិញ្ចឹមបីបាច់កូនៗ និងអំពីរបៀបដែលខ្ញុំពិតជាចង់ឃើញពួកគាត់ដើរតាមព្រះគ្រីស្ទ។ ហើយបន្ទាប់មក ខ្ញុំក៏បានយល់ឃើញថា៖ ខ្ញុំមិនបានមានបំណងចិត្តក្នុងការឃើញអ្នកដទៃទទួលជឿដែរ ដូចជាខ្ញុំមានសម្រាប់កូនៗខ្ញុំទេ។ នេះគឺជាចំណុចដែលបានប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំងមែនទែន។

សូមអនុញ្ញាតឲ្យកិច្ចការរបស់ព្រះជាម្ចាស់នៃការបង្កើតសេចក្តីប្រាថ្នានៅក្នុងចិត្តរបស់លោកអ្នកសម្រាប់ឲ្យកូនៗរបស់លោកអ្នកកែប្រែចិត្តបង្កើតសេចក្តីប្រាថ្នាសម្រាប់ឲ្យមនុស្សបាត់បង់កែប្រែចិត្តនៅក្នុងជីវិតរបស់លោកអ្នកផងដែរ។

## ៦. សូមបន្តអធិស្ឋាន

អធិស្ឋាន អធិស្ឋាន អធិស្ឋាន អធិស្ឋាន ហើយអធិស្ឋានទៀត។ ព្រះយេស៊ូវបានមានបន្ទូលថាឲ្យបន្តគោះ (លូកា ១១:៩)។ ព្រះអង្គសព្វព្រះហឫទ័យនៅពេលដែលលោកអ្នកគោះ។ ព្រះអង្គនឹងមិនដែលធុញទ្រាន់ជាមួយនឹងសេចក្តីអធិស្ឋានដែលលោកអ្នកលើកឡើងទៅកាន់ព្រះអង្គសម្រាប់កូនៗរបស់លោកអ្នកឡើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Six Ways Parents of Rebellious Children Fight for Faith
**របៀប៦យ៉ាងសម្រាប់ឪពុកម្តាយដែលមានកូនរឹងចចេសអាចតយុទ្ធជាមួយបាន ដើម្បីជំនឿ**
https://www.desiringgod.org/interviews/
six-ways-parents-of-rebellious-children-fight-for-faith

## សំណួរទី៨៤៖

# ការថែរក្សាព្រលឹងសម្រាប់អ្នកម្តាយវ័យក្មេងដែលនឿយហត់

យើងតែងតែទទួលបានសំណួរជាបន្តបន្ទាប់ពីម្តាយដែលមានកូនតូចៗ ដូចជាសំណួរមួយនេះមកពីអ្នកអានម្នាក់ឈ្មោះ រក្សា។ «ជម្រាបសួរលោកគ្រូ! ខ្ញុំ និងស្វាមីទើបតែបានក្លាយជាឳពុកម្តាយថ្មោងថ្មីទៅកាន់កូនប្រុសអាយុពីរខែ។ ការមើលថែរក្សាគាត់គឺមានពោពេញដោយសេចក្តីអំណរ និងការនឿយហត់។ ខ្ញុំស្ទើរតែមិនអាចផ្តោតលើអ្វីដែលខ្ញុំធ្លាប់ធ្វើពីមុនមកប៉ុន្តែត្រូវការព្រះជាម្ចាស់កាន់តែខ្លាំងជាងមុន ដើម្បីទ្រទ្រង់ខ្ញុំ។ តើលោកគ្រូមានយោបល់យ៉ាងណា ដើម្បីប្រឹក្សាដល់អ្នកដែលជាម្តាយថ្មោងថ្មី ក្នុងការបន្តដំណើររបស់ពួកគេជាមួយព្រះ?»

ខ្ញុំមិនមែនជាម្តាយ ហើយក៏នឹងមិនក្លាយជាម្តាយដែរ ប៉ុន្តែខ្ញុំបានរស់នៅជាមួយស្ត្រីម្នាក់ដែលជាម្តាយអស់រយៈពេល៤៧ឆ្នាំមកហើយ។ ខ្ញុំបន្តរស់នៅជាមួយស្ត្រីម្នាក់នេះ ហើយខ្ញុំបានមើលគាត់ក្លាយជាម្តាយវ័យក្មេងទៅកាន់កូនៗទាំង៥នាក់៖ បួននាក់ជាកូនដែលកើតចេញពីផ្ទៃ ហើយកូនមួយទៀតត្រូវបានទទួលចូលមកក្នុងគ្រួសារនៅអាយុ៨សប្តាហ៍។ ខ្ញុំព្យាយាមក្នុងការអានព្រះគម្ពីររបស់ខ្ញុំដោយភ្នែករំពៃមើលពីអ្វីដែលល្អសម្រាប់អ្នកដែលជាឳពុកម្តាយ និងសម្រាប់គ្រប់គ្នា។ ដូច្នេះ នេះជាយោបល់មួយចំនួនចេញពីបទពិសោធន៍ និងពីព្រះបន្ទូលព្រះ។ ហើយប្រហែលជាវាមិនមែនជាចំណុចសំខាន់បំផុតប៉ុន្តែវាសុទ្ធតែចេញពីសេចក្តីអធិស្ឋានជាមុន។

### ស្វែងរកព្រះ

កុំបាត់បង់ទិសដៅអ្នកស្រី រក្សា សូមកុំបាត់បង់ទិសដៅរបស់ខ្លួនក្នុងការពិតនៃដំណើររបស់អ្នកជាមួយព្រះគឺមានសារៈសំខាន់សម្រាប់កូនរបស់អ្នកដូចជាទឹកដោះរបស់អ្នក ឬរូបមន្តណាមួយដែលអ្នកអាចឲ្យទៅកាន់គាត់បាន។ កូនៗមិនមែនរស់ ដោយសារតែនំប៉័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ (ម៉ាថាយ ៤:៤)។ ប្រសិនបើអ្នកបាត់បង់ការប្រកបជាមួយព្រះនោះអ្នកនឹងមិនមែនគ្រាន់តែបាត់បង់ប្រភពនៃកម្លាំងសម្រាប់ធ្វើជាឪពុកម្តាយឡើយ ប៉ុន្តែអ្នកនឹងបាត់បង់អ្វីៗគ្រប់យ៉ាងដែលអ្នកចង់ឲ្យខ្លាំងបំផុតទៅកាន់កូនរបស់អ្នក។

ហើយអ្នកចង់ឲ្យគាត់ស្គាល់ព្រះជាជាងចង់ឲ្យគាត់មានជីវិតរស់ទៅទៀត។ អ្នកចង់ឲ្យគាត់ភ្លក់ និងឃើញថាព្រះជាម្ចាស់ទ្រង់នឹងបំពេញគ្រប់ទាំងសេចក្តីត្រូវការរបស់គាត់ដោយរួមបញ្ចូលទាំងភាពជាឪពុកម្តាយរបស់គាត់ផ្ទាល់ផងដែរ។ ហើយប្រសិនបើអ្នកបាត់បង់ព្រះខណៈពេលដែលអ្នកធ្វើជាឪពុកម្តាយនោះគឺជាអ្វីដែលសំខាន់បំផុតដែលអ្នកចង់ឲ្យទៅគាត់គឺត្រូវបានបាត់បង់រួចទៅហើយ។ ដូច្នេះ នេះគឺជាអ្វីដែលសំខាន់បំផុតសម្រាប់អ្នកក្នុងការតស៊ូប្រឆាំងជាមួយអ្វីគ្រប់យ៉ាង ដើម្បីរក្សាភាពផ្អែមល្ហែម រីកចម្រើន ស្កប់ចិត្តក្នុងដំណើររបស់អ្នកជាមួយនឹងព្រះរបស់អ្នក។

### ដាក់វិន័យបានល្អ

កុំអនុញ្ញាតិឲ្យក្មេងប្រុសម្នាក់នេះក្លាយទៅជាស្តេចអធិរាជឡើយ។ ខ្ញុំបានមើលឃើញមានឪពុកម្តាយច្រើនណាស់ដែលត្រូវបានកូនត្រួតត្រាលើ៖ មិនអាចគ្រប់គ្រងកូនបាននៅលើយន្តហោះ មិនអាចគ្រប់គ្រងកូនបាននៅតាមភោជនីយដ្ឋាន មិនអាចគ្រប់គ្រងកូនបាននៅតាមផ្សារទំនើប។ បញ្ហាទាំងអស់ដែលឪពុកម្តាយទាំងអស់នេះជួបប្រទះគឺជាការដែលខកខានដាក់វិន័យពួកគេនៅផ្ទះបានធ្លាក់មកលើគេនៅទីសាធារណៈវិញ។

វានឹងធ្លាក់មកលើក្បាលកូនរបស់ពួកគេដោយការសងសឹកនៅពេលក្រោយទៀតនៃជីវិតពួកគេ។ ក្មេងៗត្រូវបានរចនាឡើង និងដាក់គោលបំណងដោយព្រះក្នុងការឲ្យកូនៗចុះចូល និងស្តាប់បង្គាប់ទៅកាន់ឪពុកម្តាយរបស់ពួកគេ។ ព្រះជាម្ចាស់មិនមានបំណងក្នុងការឲ្យពួកគេត្រួតត្រាផ្ទះត្រួតត្រាលើទំនាក់ទំនង ត្រួតត្រាពេលមានមិត្តភក្តិមកលេងជាមួយឡើយ។ ហើយវាពិតជាសំខាន់ណាស់សម្រាប់ពួកគេក្នុងការរៀនតាំងពីដំបូង ពីព្រោះបើសិនជាពួកគេគិតថាពួកគេគឺជាចំណុចសំខាន់នៃពិភពលោកនោះវានឹងពិបាកក្នុងការបំបែកការបំភាន់ដ៏បំផ្លិចបំផ្លាញនេះនៅពេលក្រោយ។

ការអនុវត្តជាក់ស្តែង៖ យើងមិនត្រូវដាក់ក្មេងជាអាទិភាពសំខាន់នៅក្នុងកាលវិភាគរបស់យើងរហូតដល់យើងមិនមានពេលគ្រប់គ្រាន់ ដើម្បីធ្វើអ្វីដែលព្រលឹងរបស់យើងត្រូវការនោះឡើយ។ គាត់មិនត្រូវការចំណាប់អារម្មណ៍របស់អ្នកគ្រប់ពេលទេ។ អ្នកអាចបង្ហាញគាត់ពីចំណាប់អារម្មណ៍ដ៏មានតម្លៃ និងផ្តល់ឲ្យគាត់នូវសេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមពេលគាត់ត្រូវការដោយមិនចាំបាច់បណ្តុះគំនិតគាត់ថាអ្នកនឹងធ្វើជាអ្នកឆ្លើយតបទទួលខុសត្រូវគ្រប់យ៉ាងគ្រប់ពេលដែលគាត់បន្លឺសំឡេងយំនោះឡើយ។

ព្រះទ្រង់ស្រឡាញ់យើងយ៉ាងខ្លាំងក្រៃលែងហើយផ្នែកមួយនៃសេចក្តីស្រឡាញ់នោះគឺទ្រង់បានធ្វើឲ្យប្រាកដថាយើងដឹងខ្លួនថាយើងមិនមែនជាចំណុចស្នូលដែលសំខាន់បំផុតនៃចក្រវាលនេះឡើយ។ នេះជាអ្វីដែលសេចក្តីស្រឡាញ់ធ្វើ។ សូមឲ្យប្រាកដថាកូនៗរបស់អ្នកមានអារម្មណ៍សុវត្ថិភាព មិនមែនតែក្នុងពេលដែលមានវត្តមានអ្នកនៅជុំវិញឡើយ ប៉ុន្តែឲ្យពួកគេប្រាកដថា អ្នកនឹងត្រឡប់មកវិញដោយសេចក្តីស្រឡាញ់។

## ថ្វាយបង្គំដោយឥតឈប់ឈរ

សូមប្តូរការអនុវត្តការងារជាម្តាយរបស់អ្នកទៅជាការថ្វាយបង្គំ។ ពេលចំអិនម្ហូប ពេលប្តូរខោរទឹកនោមកូននៅពេលរុញរទេះ «អ្វីក៏ដោយដែលអ្នកធ្វើអ្វីដែលអ្នកញ៉ាំ ឬផឹក» ឬលេងវ៉ាក់អីជាមួយកូនរបស់អ្នក «សូមធ្វើគ្រប់យ៉ាងសម្រាប់ថ្វាយសិរីល្អដល់ព្រះ» (១កូរិនថូស ១០:៣១)។ នេះមានន័យថាជាអ្វីដែលខ្ញុំគិតថាវាជាការងារដែលអ្នកធ្វើជាក់ស្តែងការងារទាំងនោះវាមានចំនួនរាប់រយជំពូក៖

១. ពឹងផ្អែកលើការទ្រទ្រង់ការបំពាក់បំប៉ន និងការដឹកនាំដោយព្រះគុណនៃព្រះ។

២. អរព្រះគុណព្រះសម្រាប់គ្រប់ទាំងព្រះពរនៃកូននោះហើយនិងកម្លាំងរបស់អ្នកក្នុងការថែទាំពួកគេ។

៣. សូមស្ញប់ស្ញែងពីអ្វីដែលអស្ចារ្យអំពីគាត់ និងអំពីអ្វីដែលគាត់នឹងក្លាយទៅជាហើយប្តូរការស្ញប់ស្ញែងទាំងនោះទៅជាការសរសើរតម្កើងព្រះជាម្ចាស់។

៤. នៅពេលដែលអ្នកឆាប់ខឹង សូមលន់តួប្រែចិត្ត៖ ថ្វាយបង្គំព្រះដោយការលន់តួប្រែចិត្ត។ លន់តួហើយលើកតម្កើងព្រះដោយការលន់តួរបស់អ្នក និងការទទួលយកសេចក្តីសន្យានៃការអត់ទោសរបស់ទ្រង់។ ហើយបន្តអធិស្ឋាន អធិស្ឋាន អធិស្ឋានទៀតឥតឈប់ឈរពីអ្វីដែលអ្នកត្រូវការ។ នោះហើយជារបៀបដែលអ្នកអាចឲ្យពេលវេលាពេញមួយថ្ងៃរបស់អ្នកទៅជាការថ្វាយបង្គំព្រះជាម្ចាស់។ ពេលនោះប្រហែលជាអ្នកនឹងឃើញថា វាមិនមានគម្លាតយ៉ាងឆ្ងាយនៅក្នុងគំនិតរបស់អ្នករវាងទំនោរទៅកាន់កូនរបស់អ្នក និងទំនោរទៅព្រលឹងរបស់អ្នកឡើយ។



## តួនាទីរបស់ក្រុមជំនុំ

បន្តទៅក្រុមជំនុំហើយភ្ជាប់ទំនាក់ទំនងជាមួយមនុស្សផ្សេងៗជុំវិញខ្លួន។ សូមប្រយ័ត្នពីការដកខ្លួនចេញឆ្ងាយពីអ្នកដទៃនៅតែជាមួយកូន។ អ្នកត្រូវការមនុស្សផ្សេងៗទៀត។ ព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ជាពិសេសនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ជំពូក១២។ ហើយតម្រូវការនោះវានឹងមិនចេញឆ្ងាយពីយើងពីព្រោះតែមានកូននៅក្នុងផ្ទះឡើយ។ ដូច្នេះ ត្រូវស្ពាយកូននោះឲ្យជាប់ហើយចេញក្រៅ និងចំណាយពេលជាមួយមនុស្សជុំវិញ ជាពិសេសគឺនៅក្នុងការថ្វាយបង្គំ និងការប្រកបគ្នាជុំវិញព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ខ្ញុំនៅចាំបានកាលពី៤៤ឆ្នាំមុន ពេលកូនទី១របស់យើងបានកើតនៅប្រទេសអាល្លឺម៉ង់។ ភ្លាមៗពេលដែលយើងនាំយកកូនតូចដ៏គួរឲ្យស្រឡាញ់មកដល់ផ្ទះហើយព្យាយាមរៀនធ្វើជាឪពុកម្តាយនៅពេលដែលយើងយកគាត់មកដល់ផ្ទះភ្លាមយើងក៏បានទៅចូលរួមការជួបជុំក្រុមតូចនៅយប់ថ្ងៃសុក្រហើយនោះគឺជាអ្វីដែលយើងធ្វើរៀងរាល់ថ្ងៃសុក្រក្នុងពេលដែលយើងរស់នៅក្នុងប្រទេសអាល្លឺម៉ង់។

វាគឺជាខ្សែជីវិតរបស់យើងពីព្រោះថាជីវិតនៅក្នុងក្រុមជំនុំវាមិនល្អគ្រប់គ្រាន់តាមការដែលយើងចង់បាននោះឡើយ។ ប៉ុន្តែ យើងមានក្រុមតូច។ ហេតុដូច្នេះបានជាយើងទៅទីនោះឲ្យបានលឿនៗ។ ពេលខ្លះកូនម៉ែតញ៉ាំរួចហើយ ឬពេលខ្លះយើងក៏បញ្ចុកគាត់នៅខណៈពេលដែលអ្នកផ្សេងទៀតកំពុងបរិភោគ។ ដូច្នេះ នៅពេលដែលត្រូវសិក្សាព្រះគម្ពីរ និងពេលអធិស្ឋាននោះយើងនឹងដាក់គាត់ឲ្យគេងផ្កាប់មុខនៅក្នុងគ្រែហើយដាក់ខ្នើយនៅជ្រុងទាំងបួនជុំវិញគាត់ ហើយគោះគូទរបស់គាត់ រួចដើរចេញពីបន្ទប់ដោយទុកគាត់នៅក្នុងបន្ទប់នោះសម្រាករយៈពេលបីម៉ោងបន្ទាប់។

បន្ទាប់មកយើងក៏ជិះឡានក្រុងត្រឡប់ទៅផ្ទះវិញនៅអាល្លឺម៉ង់ ពីព្រោះយើងមិនមានឡានទេនៅពេលនោះ ហើយការដាក់ឲ្យគាត់គេងនៅផ្ទះនៅ

ម៉ោង១១យប់ ហើយជាធម្មតាគាត់មិនដែលភ្ញាក់ឡើយនៅក្នុងចន្លោះរហូតដល់ម៉ោង៧ព្រឹក ឬប្រសិនបើគាត់នៅក្មេងគឺប្រាកដណាស់គាត់នឹងភ្ញាក់ញ៉ាំមួយរយៈពេល។ ដូច្នេះ កុំឲ្យកូនរបស់អ្នកបង្អាក់ដំណើររបស់អ្នកឡើយ។ ត្រូវធ្វើអ្វីដែលអ្នកត្រូវធ្វើសម្រាប់ព្រលឹងរបស់អ្នក។

**ការចែកគ្នាប្តូរខោទឹកនោម**

សូមចរចាជាមួយប្តីរបស់អ្នក ដើម្បីប្តូរវេនគ្នាក្នុងការក្រោកនៅពេលយប់។ គាត់គួរតែដឹងថាអ្នកត្រូវការគេងដូចជាគាត់ត្រូវការដែរ។ បំណងព្រះហឫទ័យព្រះសម្រាប់ការចិញ្ចឹមកូនគឺមានទាំងឪពុកនិងម្តាយ។ វាមានមូលហេតុសម្រាប់ការនោះ។ ដូច្នេះ សូមប្រាប់ប្តីរបស់អ្នកថា «ខ្ញុំត្រូវការឲ្យបងជួយដែរ»។ បង្កើតឲ្យមានពេលវេលានៅកាលវិភាគរបស់អ្នកមិនមែនសម្រាប់តែសម្រាក ប៉ុន្តែសម្រាប់អានដែរ។

ហើយការនោះវានាំទៅកាន់ចំណុចចុងក្រោយដែលខ្ញុំចង់និយាយ។ អានសៀវភៅដែលមានពោពេញដោយអត្ថបទព្រះគម្ពីរ។ ហើយសៀវភៅដែលមានពោពេញដោយអត្ថបទព្រះគម្ពីរនោះគឺជាព្រះគម្ពីរផ្ទាល់។ ប៉ុន្តែអានសៀវភៅផ្សេងៗដែរប្រហែលជាអាចស្តាប់ការអានសៀវភៅនៅក្នុងខណៈពេលដែលអ្នកកំពុងតែធ្វើការងារ។ ហើយនេះគឺជាមូលហេតុ៖ ព្រះគម្ពីរសុភាសិតបានចាប់ផ្តើមជាមួយនឹងឃ្លាថា «នែកូនអើយ ចូរស្តាប់ពាក្យប្រៀនប្រដៅរបស់ឪពុកចុះកុំឲ្យកូនបោះបង់ចោលសេចក្តីដំបូន្មានរបស់ម្តាយឯងឡើយ» (សុភាសិត ១:៨)។ ទំនួលខុសត្រូវរបស់អ្នកគឺត្រូវបង្ហូរសិរីល្អនៃការបង្រៀនដ៏ល្អអំពីព្រះ ផ្លូវរបស់ព្រះ និងពិភពលោករបស់ព្រះអង្គទៅកាន់ចិត្តគំនិតរបស់កូនតូចមួយនេះ។ ដូច្នេះ កុំធ្វើឲ្យកូនបរាជ័យដោយការដែលអ្នកបរាជ័យក្នុងការអាន ហើយលូតលាស់ក្នុងអ្វីដែលអ្នកត្រូវការ ដើម្បីបង្រៀនគាត់អំពីព្រះជាម្ចាស់ និងអំពីជីវិតនេះឡើយ។



ហេតុដូច្នេះបានជាខ្ញុំអធិស្ឋាន សូមឲ្យព្រះជាម្ចាស់ទ្រង់ប្រទានឲ្យអ្នកនូវកម្លាំង និងប្រាជ្ញាក្នុងការធ្វើកិច្ចការនេះគឺជាកិច្ចការយ៉ាងធំធេងគឺការចិញ្ចឹមបីបាច់កូននេះ៖ គឺការចិញ្ចឹមបីបាច់ និងការប្រៀនប្រដៅនៃព្រះអម្ចាស់ (អេភេសូរ ៦:៤)។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Soul Care for Exhausted Young Mothers
**ការថែរក្សាព្រលឹងសម្រាប់អ្នកម្តាយវ័យក្មេងដែលនឿយហត់**
https://www.desiringgod.org/interviews/soul-care-for-exhausted-young-mothers

## សំណួរទី៩៥៖
# តើអ្វីទៅជាគោលដៅប្រចាំថ្ងៃនៃការចិញ្ចឹមកូន?

*ក្នុងនាមជាឪពុកម្ដាយ យើងគិតអំពីការចិញ្ចឹមបីបាច់កូនៗហាក់បីដូចជាការគូរគំនូរ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងបន្តផាត់ពណ៌។ យើងសង្ឃឹមថាពណ៌ដែលយើងបានផាត់គឺជាពណ៌ត្រឹមត្រូវ។ យើងក៏សង្ឃឹមថា យើងក៏បានផាត់នៅចំកន្លែងដែលត្រឹមត្រូវដែរ។ ប៉ុន្តែ ការចិញ្ចឹមបីបាច់កូនៗក៏នាំមកនូវភាពប្រែប្រួល អសុវត្ថិភាព និងការមានមន្ទិលសង្ស័យលើខ្លួនឯងដែរ។*

*តើលោកគ្រូគិតថា អ្វីទៅជាគោលបំណងនៃការចិញ្ចឹមកូនពីមួយថ្ងៃទៅមួយថ្ងៃ?*

«គំនិតធំ» នៃការចិញ្ចឹមបីបាច់កូនៗមានពីរយ៉ាង៖

### អំណាចរបស់ព្រះជាម្ចាស់

*គំនិតទី១៖* អំណាច។ កូនៗត្រូវតែយល់ចាប់តាំងពីពួកគាត់ទើបតែកើតមកថា ពួកគាត់បានកើតមកក្នុងពិភពលោកនៃអំណាច ហើយពួកគាត់មិនមែនជាអំណាចនោះទេ។ នៅពេលដែលកូនៗកាន់តែឆាប់ទទួល ដោយចុះចូលជាមួយនឹងចំណុចនេះ នោះពួកគាត់នឹងកាន់តែទទួលបានព្រះពរនៅក្នុងជីវិតរស់នៅជាមិនខាន។ កូនៗរបស់យើងមិនមែនជាកម្មសិទ្ធិរបស់យើងនោះទេ តែពួកគាត់គឺជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់វិញ។ ព្រះអង្គគឺជាម្ចាស់កម្មសិទ្ធិផ្ដាច់ការ និងអំណាចចុងក្រោយ។ ដែលនេះមានន័យថា យើងគឺជាអ្នកតំណាង និងជាទូតនៃអំណាចរបស់ព្រះជាម្ចាស់។ ក្នុងនាមជាឪពុកម្ដាយ យើងគឺជាសំឡេងរបស់ព្រះជាម្ចាស់។ ចំពោះកូនៗ យើងតំណាងមុខឲ្យទ្រង់។ ចំពោះកូនៗ យើងតំណាងឲ្យដៃរបស់ព្រះអង្គក្នុងការវាយប្រដៅ។

ចំណុចនេះទំនងជាធ្វើឲ្យលោកអ្នកញ័រជង្គង់បន្តិច។ នេះជាអត្ថន័យៈ គ្រប់ពេលដែលយើងប្រើប្រាស់ អំណាចលើកូនៗរបស់យើងក្នុងគ្រប់កាលៈទេសៈទូទៅទាំងអស់ ដាច់ខាតវាត្រូវតែជារូបភាពដ៏ស្រស់ស្អាតនៃអំណាចរបស់ព្រះជាម្ចាស់។ យើងចង់ឲ្យកូនៗរបស់យើងឃើញអំណាចថាជាអ្វីដែលស្រស់ស្អាត ការប្រទាន ការបម្រើ ការស្រឡាញ់ ការមានចិត្តអាណិតអាសូរ ការចេះអត់ធ្មត់ និងពេញដោយព្រះគុណ ពីព្រោះនោះគឺជាអំណាចរបស់ព្រះជាម្ចាស់។ កូនៗទាំងអស់គ្នាសុទ្ធតែកើតមកដោយមានចិត្តជំទាស់នឹងអំណាច មានចិត្តស្អប់អំណាចតាំងពីកំណើតមក។ ហើយយើងចង់បង្ហាញអំណាចក្នុងរបៀបនៃភាពស្រស់ស្អាតដែលកើតចេញមកពីព្រះជាម្ចាស់ ដើម្បីឲ្យពួកគាត់អាចលើកឡើងថា «អំណាចគឺជាអ្វីដែលល្អ។ អំណាចគឺជាអ្វីដែលពេញដោយប្រាជ្ញា។ អំណាចគឺជាអ្វីដែលការពារ។ អំណាចមិនជាន់ឈ្លីសេរីភាពរបស់ខ្ញុំទេ។ អំណាចផ្តល់មកខ្ញុំនូវសេរីភាព»។ នេះគឺជាគំនិតធំទី១។

## អាថ៌កំបាំងនៃចក្រវាល

*នេះគឺជាគំនិតធំទី២៖* យើងដឹងថា ក្នុងនាមជាឪពុកម្តាយ គឺមានអាថ៌កំបាំងនៃចក្រវាល ប្រសិនបើយើងមិនយល់អំពីអាថ៌កំបាំងទាំងនេះ នោះយើងនឹងមិនអាចក្លាយជាបុគ្គលដែលយើងគួរតែមានលក្ខណៈបានទេ ហើយយើងក៏នឹងមិនធ្វើអ្វីដែលយើងត្រូវតែធ្វើផងដែរ។ ការបង្ហាញដ៏ច្បាស់បំផុតនៃអាថ៌កំបាំងនេះ គឺអាថ៌កំបាំងនៃព្រះគុណរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែលនៅលើឈើឆ្កាង។ ប៉ុន្តែ ក៏នៅមានអាថ៌កំបាំងជាច្រើនទៀត ដូចជាអាថ៌កំបាំងនៃអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ផងដែរ។

យើងត្រូវតែចង់ឲ្យកូនៗយើងស្គាល់អំពីអាថ៌កំបាំងទាំងនេះ។ ដូច្នេះ យើងត្រូវតែស្វែងរកឱកាសនៃពេលវេលាដ៏ធម្មតាៗដូចនោះ ហើយពន្យល់



អំពីអាថ៌កំបាំងនេះទៅកាន់កូនៗរបស់យើង៖

- ពួកគាត់មិនមែនជាអ្នកគ្រប់គ្រង។
- ជីវិតនេះគឺមិនមែនអំពីពួកគាត់ទេ។
- ការស្រឡាញ់អ្នកជិតខាងគឺជាអ្វីដែលសំខាន់។
- ការទុកដាក់ធនធានគឺជាអ្វីដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យខ្ញុំធ្វើ។
- យើងរស់នៅលើផែនដីដែលមិនមែនគ្រាន់តែជាផែនដីនៃអំណាច ប៉ុន្តែក៏ជាផែនដីនៃព្រះគុណផងដែរ។

ដូច្នេះ យើងស្វែងរកឱកាសទាំងនោះ ដើម្បីពន្យល់និយាយអាថ៌កំបាំងដែលព័ន្ធកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធបានផ្ទេរទុកមកកាន់យើង តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបកស្រាយទៅកាន់កូនៗរបស់យើង ដើម្បីឲ្យពួកគាត់អាចយល់អំពីអត្ថន័យនៃមនុស្សជាតិ ដែលពួកគាត់ត្រូវរស់នៅតាម។

នេះគឺជាអ្វីដែលយើងត្រូវតែដឹង៖ ប្រសិនបើភ្នែករបស់យើងបានឃើញ ហើយត្រចៀករបស់យើងបានឮអំពើបាប ការអាក្រក់ និងបរាជ័យរបស់កូនៗ នោះវាមិនមែនជាការជួបប្រទះដោយចៃដន្យនោះទេ វាក៏មិនមែនជាការរំខានទាំងនោះសុទ្ធតែបានកើតឡើងដោយសារព្រះគុណ។ ព្រះជាម្ចាស់ស្រឡាញ់កូនៗរបស់យើង។ ព្រះអង្គបានដាក់ពួកគាត់ក្នុងគ្រួសារដែលមានជំនឿ។ ព្រះអង្គនឹងបើកសម្តែងតម្រូវការរបស់ពួកគាត់មកកាន់យើង ក្នុងនាមជាឪពុកម្តាយ ដើម្បីឲ្យយើងអាចធ្វើជាឧបករណ៍នៃអំណាច សេចក្តីពិត ប្រាជ្ញា និងព្រះគុណរបស់ទ្រង់។ នេះឯងគឺជារចនាសម្ព័ន្ធ។ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់នឹងតែងតែប្រទានមកកាន់យើងនូវឱកាសថែមទៀត។ យើងត្រូវតែបន្តព្យាយាមបកស្រាយក្នុងឱកាសតូចៗដូចនោះ។ វានឹងតែងតែឈានដល់ចំណុចមិនបញ្ចប់ ពីព្រោះការផ្លាស់ប្រែគឺជាដំណើរការ មិនមែនជាព្រឹត្តិការណ៍ដែលកើតឡើងតែមួយដងទេ។ ប៉ុន្តែ យើងមានឋានៈដ៏ល្អ—នេះគឺជាចំណុចដ៏អស្ចារ្យណាស់—នៃការធ្វើជាឧបករណ៍ក្នុងព្រះហស្តរបស់ព្រះ

ជាម្ចាស់ ដើម្បីរចនាព្រលឹងមនុស្ស។ តើមានអ្វីផ្សេងទៀតដែលល្អប្រសើរជាងនេះដែរឬទេ?

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
What Is the Daily Aim of Parenting?
**តើអ្វីទៅជាគោលដៅប្រចាំថ្ងៃនៃការចិញ្ចឹមកូន?**
https://www.desiringgod.org/interviews/what-is-the-daily-aim-of-parenting



# ផ្នែកទី៧
# ការប្រើប្រាស់បណ្ដាញសង្គម និងបច្ចេកវិទ្យា

## សំណួរទី៩៦៖
# តើការស្វែងរកខគម្ពីរដោយប្រើប្រព័ន្ធឌីជីថល ( digital ) ល្អជាងការចងចាំខគម្ពីរមែនឬ?

*តើការមានប្រព័ន្ធឌីជីថល និងកម្មវិធីព្រះគម្ពីរជាច្រើនសព្វថ្ងៃនេះ ដែលយើងអាចប្រើប្រាស់បាន អាចបន្ថយតម្រូវការរបស់យើងនៃការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ដែរឬទេ? ប្រសិនបើខ្ញុំដឹងថាមានខគម្ពីរដ៏សំខាន់មួយអំពី ដើមទំពាំងបាយជូរ និងមែករបស់វា ប៉ុន្តែខ្ញុំមិនចាំព័ត៌មានលម្អិត ខ្ញុំមិនចាំបាច់ត្រូវការចងចាំព័ត៌មានលម្អិតទេ ពីព្រោះខ្ញុំអាចប្រើកម្មវិធីព្រះគម្ពីរ ដើម្បីស្វែងរកពាក្យគន្លឹះពីរនោះនៅក្នុងខបាន ហើយខ្ញុំក៏នឹងរកឃើញព័ត៌មានលម្អិតនោះបាន។ តើលោកគ្រូគិតថា ការមានកម្មវិធីព្រះគម្ពីរនឹងកាត់បន្ថយតម្រូវការរបស់យើងនៃការទន្ទេញព្រះគម្ពីរឲ្យចាំមាត់ដែរឬទេ? ហើយតើយើងគួរប្រើប្រាស់វាទេ?*

ទេ! ការវែកញែកដូចនោះនឹងនាំឲ្យមានការសន្មតថា គោលដៅចម្បងនៃការទន្ទេញព្រះគម្ពីរឲ្យចាំមាត់គឺ ដើម្បីប្រើប្រាស់នៅក្នុងបរិបទណាមួយ។ ទោះបីនោះគឺជាកត្តាជំរុញចិត្តដ៏ល្អមួយក៏ដោយ ក៏វាមិនមែនជាកត្តាជំរុញចិត្តតែមួយគត់ប៉ុណ្ណោះទេ ឬក៏ថាជាកត្តាចម្បងដែរ។

### កែគំនិតជាថ្មីឡើងវិញ

កត្តាចម្បងគឺត្រង់ថា មានអ្វីកើតឡើងទៅកាន់ខួរក្បាលរបស់លោកអ្នក នៅពេលដែលវាមានពេញទៅដោយព្រះគម្ពីរ—ក្នុងចំណុចនេះ ខ្ញុំគិតថាមានរឿងជាច្រើនដែលមានភាពស៊ីជម្រៅកើតឡើង។ ខ្ញុំមិនមែនជាអ្នកវិទ្យាសាស្ត្រខាងឯសរសៃប្រសាទទេ។ ខ្ញុំមិនដឹងអំពីរបៀបដែលកោសិកា

សរសៃប្រសាទ ធាតុគីមី និងថាមពលដំណើរការយ៉ាងដូចម្ដេចនៅក្នុងខួរក្បាលទេ ប៉ុន្តែខ្ញុំដឹងល្មមត្រង់ថា ការទន្ទេញអ្វីមួយឲ្យចាំមាត់ ឬក៏ការដែលខួរក្បាលគិតអំពីអ្វីមួយជាទម្លាប់មានការពាក់ព័ន្ធទៅនឹងសរីរាង្គវិទ្យា និងខាងឯព្រលឹងវិញ្ញាណ ហើយខួរក្បាលក៏កំពុងតែទទួលបានការរចនាឡើងដែរ។

ដូច្នេះ នៅពេលដែលសាវ័ក ប៉ុល បានមានប្រសាសន៍ថា «កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង» (រ៉ូម ១២:២) នេះពិតជាអស្ចារ្យមែន។ នេះគឺជាខគម្ពីរដែលមានពេញទៅដោយព្រះចេស្ដាមួយនៅលើលោកនេះ ដោយខួរក្បាលដែលព្រះជាម្ចាស់បានប្រទានមកកាន់លោកអ្នកគឺថា ឲ្យផ្ដើមគំនិតជាថ្មី។ ហើយខ្ញុំគិតថា របៀបដ៏ចម្បងមួយដែលការនេះកើតឡើង គឺតាមរយៈការពន្លិចខួរក្បាលរបស់លោកអ្នកចូលទៅក្នុងគំនិតរបស់ព្រះជាម្ចាស់។ ហើយរបៀបដ៏ចម្បងមួយនៃការពន្លិចខួរក្បាលរបស់លោកអ្នកចូលទៅក្នុងគំនិតរបស់ព្រះជាម្ចាស់ ដែលការនេះអាចកើតឡើងបាន គឺតាមរយៈការទន្ទេញព្រះគម្ពីរឲ្យចាំមាត់។

## ពាក្យពេចន៍ក្នុងភាពទៀងពេល

ជាការអនុវត្ត៖ វាមានអំណាចខ្លាំងជាង។ ខ្ញុំបានឃើញការនេះកើតឡើងម្ដងហើយម្ដងទៀត។ ខ្ញុំបានឃើញការនេះកើតឡើងក្នុងកម្មវិធីថ្វាយបង្គំ។ ខ្ញុំបានឃើញការនេះកើតឡើងនៅពេលដែលកំពុងធ្វើពិធីលៀងព្រះអម្ចាស់។ ខ្ញុំបានឃើញការនេះកើតឡើងនៅក្នុងមន្ទីរពេទ្យ។ ខ្ញុំបានឃើញការនេះកើតឡើងនៅក្នុងបន្ទប់ប្រឹក្សាយោបល់។ ខណៈពេលដែលលោកអ្នកកំពុងតែនិយាយលេងជាមួយនឹងបុគ្គលណាម្នាក់ ឬក៏ខណៈពេលដែលលោកអ្នកកំពុងតែនាំកម្មវិធីលៀងព្រះអម្ចាស់ ឬក៏ខណៈពេលដែលលោកអ្នកកំពុងតែឈរនៅក្បែរគ្រែអ្នកជំងឺ ប្រសិនបើព្រះអម្ចាស់នាំឲ្យលោកអ្នកនឹក



ចាំអំពីផ្នែកដ៏សំខាន់ណាមួយនៃព្រះគម្ពីរ ហើយលោកអ្នកអាចសូត្រកណ្ឌគម្ពីរ រ៉ូម ៨:៣៥-៣៩ ដោយមើលចំមុខបុរសដែលហៀបនឹងស្លាប់ នោះវាមានអំណាចខ្លាំងជាងការដែលលោកអ្នកលើកឡើងថា «ចាំបន្តិច ខ្ញុំយកទូរស័ព្ទ.... ហើយចុច ចុច ចុច ចុច ចុច ចុច»។ នៅក្នុងពេលដូចនោះ ទាំងអស់គ្នានឹងមានអារម្មណ៍ថា នៅឆ្ងាយពីគ្នា ហើយហាក់បីដូចជាមិនបានកើតឡើងចេញពីចិត្តដែរ។

ប៉ុន្តែ ប្រសិនបើខគម្ពីរនោះផុសចេញពីចិត្តរបស់លោកអ្នក ដោយមានអំណាច ពីព្រោះព្រះជាម្ចាស់បានដាក់ខគម្ពីរនោះនៅក្នុងចិត្តលោកអ្នក ហើយព្រះអង្គបានត្បាញវាចូលក្នុងខួរក្បាលរបស់លោកអ្នក នោះទាំងអស់គ្នានឹងមានអារម្មណ៍ថា ការសូត្រខគម្ពីរនោះកើតឡើងចេញពីចិត្ត ហើយក៏មានពេញទៅដោយអំណាចពេលលោកអ្នកកំពុងសូត្រខគម្ពីរហ្នឹងនៅក្បែរគ្រែអ្នកឈឺនៅក្នុងមន្ទីរពេទ្យ ឬក៏នៅក្នុងកម្មវិធីលៀងព្រះអម្ចាស់ដែរ។ មានពេលមួយ នៅក្នុងកម្មវិធីលៀងព្រះអម្ចាស់ ខ្ញុំបានសូត្រកណ្ឌគម្ពីរអេសាយជំពូក៥៣ ចេញពីការចងចាំ។ បន្ទាប់ពីកម្មវិធីបានចប់ហើយ ប្រពន្ធគ្រូគង្វាលម្នាក់ ដែលទទួលបានការប៉ះពាល់តាមរយៈខគម្ពីរនោះបានមកប្រាប់ខ្ញុំថា៖ «ខ្ញុំស្រឡាញ់ជំពូកនេះណាស់ តែវាមិនដែលធ្លាប់មានពេញទៅដោយអំណាចចំពោះខ្ញុំដូចដែលពេលលោកគ្រូសូត្រខគម្ពីរទាំងនោះ ខណៈពេលដែលមើលមកកាន់ខ្ញុំឡើយ»។ ហើយខ្ញុំដឹងថា នេះគឺជាការពិត។ នៅពេលដែលខ្ញុំនៅក្បែរនរណាម្នាក់ដែលអាចមើលមកកាន់ខ្ញុំ ហើយលើកទឹកចិត្តខ្ញុំដោយព្រះបន្ទូលខណៈពេលដែលគាត់មើលមកកាន់ខ្ញុំ ខគម្ពីរនោះមានអំណាចខ្លាំងជាងបើគាត់គ្រាន់តែអានឲ្យខ្ញុំស្ដាប់។

ដូច្នេះចម្លើយរបស់ខ្ញុំគឺថា ទេ! ការមានប្រព័ន្ធឌីជីថល និងកម្មវិធីព្រះគម្ពីរនឹងមិនបន្ថយ ឬក៏ដកចេញតម្រូវការនៃការទន្ទេញព្រះគម្ពីរឲ្យចាំមាត់

ទេ។ សូមព្រះកុំអនុញ្ញាតឲ្យការនេះកើតឡើងឡើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
Do Digital Bible Searches Relativize Memorization?
**តើការស្វែងរកខគម្ពីរដោយប្រើប្រព័ន្ធឌីជីថល** ( digital ) **ល្អជាងការចងចាំខគម្ពីរមែនឬ**?
https://www.desiringgod.org/interviews/do-digital-bible-searches-relativize-memorization



## សំណួរទី៩៧៖
# ធ្វើដូចម្ដេចឲ្យខ្ញុំអាចស្រឡាញ់ព្រះ ខ្លាំងជាងការកម្សាន្តសប្បាយរបស់ខ្ញុំ?

*អត្ថន័យជាមូលដ្ឋាននៃពាក្យ ការកម្សាន្តសប្បាយ គឺមានន័យថា «ការជាប់»។ វាជាពាក្យដែលគេប្រើ ដើម្បីពិពណ៌នា អំពីការជាប់ចិត្តនឹងអ្វីមួយ។ ការកម្សាន្តគឺជាការដែលមនុស្សម្នាក់ជាប់ចិត្ត ឬជាប់អារម្មណ៍។ ហើយយើងថា ធម្មជាតិរបស់យើងគឺជាប់ចិត្តនឹងការអង្គុយមើលទូរទស្សន៍ ខ្លាំងជាងការបញ្ចេញពលកម្ម។ការកម្សាន្តសប្បាយធ្វើឲ្យយើងជាប់ចិត្តជិតអារម្មណ៍។ ប៉ុន្តែ ការកម្សាន្តសប្បាយរហ័សទាន់ចិត្ត ដែលយើងអាចទទួលនៅពេលណាក៏បាន ដោយគ្រាន់តែយកម្រាមដៃចុចលើអេក្រង់ ក៏បាននាំឲ្យគេចោទជាសំណួរដ៏សំខាន់ថា យើងកំពុងតែជាប់ចិត្តនឹងអ្វីជាងគេ។ តើយើងនឹងមានការជាប់ចិត្តចំពោះព្រះ ខ្លាំងជាងរឿងហូលីវូឌឬទេ? ខាងក្រោមនេះជាសំណួររបស់ប្រិយមិត្តអ្នកអានម្នាក់ឈ្មោះ រ៉ូ។*

*«សួស្តី! លោកគ្រូ ខ្ញុំដឹងថា ខ្ញុំបានទូលសូមព្រះគ្រីស្ទ ឲ្យទទួលយកចិត្ត និងជីវិតរបស់ខ្ញុំហើយ។ ខ្ញុំក៏បានប្រែចិត្តចេញពីអំពើបាប ដោយអស់ពីចិត្តផងដែរ។ ខ្ញុំបានឈប់ធ្វើអំពើបាប ដោយស្ម័គ្រពីចិត្ត ហើយកំពុងខិតខំអស់ពីលទ្ធភាព ដើម្បីរស់នៅក្នុងជីវិតបរិសុទ្ធ។ ខ្ញុំសូមសួរលោកគ្រូ អំពីបំណងចិត្ត និងការស្អប់ចិត្តរបស់ខ្ញុំ ក្នុងការលត់ដំខាងវិញ្ញាណ និងការថ្វាយបង្គំ។ ខ្ញុំចូលចិត្តការកម្សាន្តសប្បាយ ខ្លាំងជាងការចំណាយពេលជាមួយព្រះ។ ខ្ញុំសូមចែកចាយការពិតនេះ ដោយស្មោះត្រង់។ ការចំណាយពេលជាមួយព្រះ គឺប្រៀបដូចជាការធ្វើពលកម្ម។ ការកម្សាន្តសប្បាយ គឺជាកន្លែងដែលខ្ញុំទៅរក ដើម្បីសម្រាកពីការងារមួយរយៈ។ ប៉ុន្តែ  ខ្ញុំក៏មានការ*

*ភ័យខ្លាចចំពោះវិញ្ញាណរបស់ខ្ញុំ ព្រោះអតីតកាលរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំមិនបានប្រឹងប្រែងឲ្យបានល្មមគ្រប់គ្រាន់ ក្នុងការចំណាយពេលជាមួយព្រះ ហើយខ្ញុំនឹងមានការសោកស្ដាយនៅពេលអនាគត។ តើការដែលខ្ញុំចូលចិត្តការកម្សាន្តសប្បាយ ខ្លាំងជាងការប្រកបស្និទ្ធស្នាលជាមួយព្រះ គ្រាន់តែជាបញ្ហានៃការដាក់វិន័យផ្ទាល់ខ្លួនឬ?»។*

គ្មានរឿងអ្វីដែលសាមញ្ញនោះទេ។ សំណួរនេះពិតជាសំខាន់ណាស់ ហើយខ្ញុំរីករាយនឹងឆ្លើយសំណួរនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងដឹងថា នៅចុងបញ្ចប់ យើងត្រូវតែដកពិសោធន៍ជាមួយនឹងការអស្ចារ្យ ដើម្បីអរសប្បាយក្នុងព្រះ ជាជាងអរសប្បាយក្នុងការកម្សាន្តក្នុងលោកីយ៍នេះតាមរយៈការកម្សាន្តសប្បាយដែរ។ យើងមិនអាចធ្វើអ្វីម៉្យាង ដើម្បីឲ្យការនេះកើតឡើងបានឡើយ។ វាជាអំណោយទានមកពីព្រះ។ តែព្រះទ្រង់បានប្រទានមកកាន់យើងនូវវិធី ដើម្បីទទួលអំណោយទាននោះ ដូចនេះខ្ញុំសូមឆ្លើយសំណួរនេះ ដូចតទៅ។

## គ្រាន់តែជាការសម្រាកលម្ហែឬ?

រឿងមួយដែលខ្ញុំចង់និយាយនោះគឺថា ខ្ញុំដឹងថា មានមនុស្សមួយចំនួនដែលនឹងផ្ដល់យោបល់ដល់លោក រ៉ូ ដោយគ្រាន់តែនិយាយថា «សូមស្ដាប់ខ្ញុំសិន។ អ្នកនិយាយដូចមនុស្សក្រឹត្យវិន័យនិយម។ ចូរសម្រាក ហើយអរសប្បាយនឹងការកម្សាន្តសប្បាយ ដែលអ្នកមានអារម្មណ៍ថា វាហាក់ដូចជាគម្រាមកំហែងមកលើភាពបរិសុទ្ធរបស់អ្នកអញ្ចឹង។ អ្នកមានភាពគ្រប់លក្ខណ៍ក្នុងព្រះយេស៊ូវ ព្រោះព្រះអង្គបានរាប់អ្នកជាសុចរិតហើយ។ ទោះអ្នកមើលរឿងអ្វី ឬអ្នកបានចំណាយពេលច្រើនប៉ុណ្ណា ក្នុងការមើលទូរទស្សន៍ ឬលេងវីដេអូហ្គេម ឬហ្វេសប៊ុក ឬយូធូបក្តី វាមិនមានបញ្ហាអ្វីទេ។ ចូរកុំតឹងរ៉ឹងចំពោះខ្លួនឯងពេក ចូរគ្រាន់តែអរសប្បាយនឹងសេរីភាព ដែលអ្នកមានក្នុង



ព្រះយេស៊ូវប៉ុណ្ណោះ»។

ការផ្ដល់យោបល់បែបនេះ មានបញ្ហា ព្រោះវាបានធ្វើឲ្យមនុស្សគិតថា ទំនាក់ទំនងរវាងការរាប់ជាសុចរិត និងការញែកជាបរិសុទ្ធ មានភាពផ្ទុយគ្នាទាំងស្រុង។ ព្រះយេស៊ូវ សាវ័ក ប៉ុល អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរ និងអ្នកនិពន្ធកណ្ឌគម្ពីរសញ្ញាថ្មីដទៃទៀត បានពណ៌នាអំពីសេចក្ដីពិតដ៏រុងរឿងដែលថា ពេលដែលព្រះទ្រង់បានទទួលយកយើង គឺមានន័យថា ព្រះអង្គបានរាប់យើងជាសុចរិត ឬស្រឡាញ់យើង ដោយសារព្រះគុណព្រះអង្គ ដោយផ្អែកទៅលើព្រះគ្រីស្ទតែមួយអង្គ និងតាមរយៈជំនឿតែមួយគត់។ សេចក្ដីពិតនេះបញ្ចេញអំណាចនៃភាពបរិសុទ្ធ ដែលយើងដកពិសោធន៍តាមរយៈសង្គ្រាមខាងឯវិញ្ញាណដ៏ធំមួយ ទាស់នឹងលោកីយ៍ សាច់ឈាម និងអារក្ស។

ខ្ញុំមិនយល់ឃើញថា ព្រះគម្ពីរសញ្ញាថ្មីធ្លាប់ប្រាប់យើង «ឲ្យធ្វើអ្វីៗដោយសេរី ដោយគ្មានការប្រុងប្រយ័ត្ន» នោះទេ។ តែព្រះគម្ពីរបានប្រាប់យើងឲ្យ «តយុទ្ធដល់ទីបញ្ចប់»។ ជាការពិតណាស់ ផ្នែកមួយនៃការតយុទ្ធនេះ គឺត្រូវអរសប្បាយ នៅក្រោមបន្ទុកស្រាល ហើយងាយរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវបានប្រាប់យើងឲ្យកាត់ដៃ ឬខ្វេះភ្នែកខ្លួនឯងចោល ជាជាងបណ្ដោយខ្លួនឲ្យកម្សាន្តសប្បាយនឹងការត្រេកត្រអាល។ ព្រះអង្គមានបន្ទូលថា «អ្នកណាដែលស្រឡាញ់ឪពុក ឬម្ដាយ ជាជាងខ្ញុំ នោះមិនគួរនឹងខ្ញុំទេ ហើយអ្នកណាដែលស្រឡាញ់កូនប្រុស ឬស្រី ជាជាងខ្ញុំ នោះក៏មិនគួរនឹងខ្ញុំដែរ» (ម៉ាថាយ ១០:៣៧)។ បើអ្នកមិនសម្លាប់កិច្ចការរបស់សាច់ឈាមទេ នោះមិនអាចរស់នៅខាងឯវិញ្ញាណបានឡើយ។ កណ្ឌគម្ពីរយ៉ូហានបានចែងថា«កុំឲ្យស្រឡាញ់លោកីយ៍ ឬរបស់អ្វីដែលនៅក្នុងលោកីយ៍នេះឲ្យសោះ បើអ្នកណាស្រឡាញ់លោកីយ៍ អ្នកនោះគ្មានសេចក្ដីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ» (១យ៉ូហាន ២:១៥)។

ពួកសេរីភាពនិយម ក្នុងសម័យបច្ចុប្បន្ន បានប្រើខួរក្បាលខ្លួនផ្ទុយពីព្រះ

គម្ពីរ ដើម្បីពណ៌នាថា គ្រីស្ទបរិស័ទអាចរស់នៅ ដោយសេរីភាព ព្រោះព្រះបានរាប់ពួកគេជាសុចរិតហើយ។ ពួកគេកំពុងនាំមនុស្សជាច្រើនឲ្យវង្វេង។ ខ្ញុំសូមអបអរលោក រ៉ូ ដែលបានយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅ ចំពោះរឿងភាពបរិសុទ្ធផ្ទាល់ខ្លួន ហើយខ្ញុំសង្ឃឹមថា អ្នកនឹងមិនទទួលយកចម្លើយសម្រាប់សំណួរនេះ ដោយឱបក្រសោបយកការបង្រៀនដែលផ្ទុយពីព្រះគម្ពីរនោះឡើយ។ វាមិនមែនជាដំណោះស្រាយដ៏ត្រឹមត្រូវទេ។

**ការតយុទ្ធ ក្នុងការមើលឃើញ**

តើយើងគួរធ្វើដូចម្តេច? តើយើងគួរធ្វើដូចម្តេច ពេលដែលយើងមានអារម្មណ៍ធុញទ្រាន់ ឬមិនពេញចិត្តនឹងការផ្តោតទៅលើព្រះជាម្ចាស់ ព្រះគ្រីស្ទ និងព្រះវិញ្ញាណ និងព្រះរាជកិច្ចនៃការសង្គ្រោះរបស់ព្រះអង្គ ក្នុងលោកីយ៍នេះ? តើយើងគួរធ្វើដូចម្តេច នៅពេលដែលការកម្សាន្តសប្បាយ នៅលើកញ្ចក់ទូរទស្សន៍ និងក្នុងខ្សែភាពយន្ត វីដេអូហ្គេម និងកីឡា មានលក្ខណៈគួរឲ្យទាក់ទាញ ឬមានភាពរំភើបរីករាយយ៉ាងខ្លាំង ពោលគឺគួរឲ្យចាប់អារម្មណ៍ជាងព្រះឆ្ងាយណាស់? តើយើងគួរតែធ្វើដូចម្តេចទៅ?

បើអ្នកយល់ថា ការកម្សាន្តក្នុងលោកីយ៍មានលក្ខណៈគួរឲ្យទាក់ទាញជាង នោះអ្នកគួរតែញាប់ញ័រផង។ យើងប្រហែលជាគួរតែញាប់ញ័រផង។ ហើយមូលហេតុដែលយើងគួរតែញាប់ញ័រ គឺពីព្រោះការដែលមនុស្សចង់ជ្រើសរើសយកលោកីយ៍ គឺជាបញ្ហានៃពិភពលោកទាំងមូល។ មនុស្សខាងសាច់ឈាម មិនអាចទទួល ឬអរសប្បាយ ឬក៏ស្កប់ចិត្ត ឬមួយចាប់អារម្មណ៍ខ្លាំង ចំពោះសេចក្តីខាងឯព្រះវិញ្ញាណនោះឡើយ។ ព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ (១កូរិនថូស ២:១៤)។ នេះជាលក្ខណៈសម្គាល់នៃមនុស្សខាងសាច់ឈាម។ ដូចនេះ ប្រសិនបើយើងមានអារម្មណ៍ដូចនេះ យើងគួរតែញាប់ញ័រ ព្រោះយើងកំពុងតែប្រព្រឹត្តដូចមនុស្សធម្មតាហើយ គឺមិនដូចកូនព្រះឡើយ។



មានអ្វីកំពុងតែរាំងអ្នក (និងមនុស្សរាប់លាននាក់) មិនឲ្យមើលឃើញព្រះ និងផ្លូវរបស់ទ្រង់ ផ្អែកទៅលើសេចក្តីពិត ដែលថា ទ្រង់ជានរណា។ នៅក្នុងបទគម្ពីរ ២កូរិនថូស ៣:១៨ សាវ័ក ប៉ុល បានមានប្រសាសន៍ថា បើយើងឃើញព្រះអង្គ តាមសេចក្តីពិតដែលថា ទ្រង់ជានរណា នោះយើងក៏បាន «មើលសិរីល្អរបស់ព្រះអង្គ» ហើយយើងក៏នឹងបានផ្លាស់ប្រែ ដោយទទួលសិរីល្អថែមមួយកម្រិតទៀតដែរ។ មានអ្វីមួយកំពុងរាំងអ្នក មិនឲ្យមើលឃើញ និងស្គាល់ព្រះ ដែលមានភាពស្រស់ស្អាត គួរឲ្យចាប់អារម្មណ៍ និងគួរឲ្យស្កប់ចិត្តទាំងស្រុង ក្នុងព្រះគ្រីស្ទ និងក្នុងការគ្រប់យ៉ាងដែលទ្រង់មានសម្រាប់យើង។ ក្នុងករណីរបស់អ្នក ខ្ញុំមិនដឹងថា ឧបសគ្គនោះជាអ្វីទេ។ តែនោះជាកន្លែងដែលយើងតយុទ្ធក្នុងសង្គ្រាម គឺសង្គ្រាម ដើម្បីឲ្យមើលឃើញបាន។ យើងចាំបាច់ត្រូវតែមើលឃើញ។

ខាងក្រោមនេះជា ការលើកទឹកចិត្តបីយ៉ាង ហើយព្រះអម្ចាស់ប្រហែលជានឹងប្រើការលើកទឹកចិត្តណាមួយ ក្នុងចំណោមការលើកទឹកចិត្តទាំងបីនេះ ក្នុងជីវិតអ្នក។

**ចូរចែកចាយអំពីភាពស័ក្តិសមរបស់ព្រះ**

ទី១ ចូរទូលសូមឲ្យព្រះអម្ចាស់នាំអ្នកទៅជួបមនុស្សម្នាក់ ដែលជាអ្នកមិនជឿ ជាអ្នកជឿថ្មី ឬជាគ្រីស្ទានដែលបានបែកចេញឆ្ងាយពីព្រះវិញ ដើម្បីឲ្យអ្នកអាចចែកចាយអស់ពីចិត្ត អំពីសេចក្តីពិតដែលចែងអំពីព្រះ ដែលពួកគេគួរតែដឹង ហើយនាំពួកគេងាកមករកព្រះ។ ស្តាប់មើលទៅ ការនេះហាក់ដូចជាផ្ទុយនឹងសភាវគតិរបស់អ្នក។ អ្នកមានអារម្មណ៍ថា ហាក់ដូចជាមិនចង់ធ្វើដូចនេះទេ។

ប៉ុន្តែ ខ្ញុំបានឃើញការនេះម្តងហើយម្តងទៀត ក្នុងជីវិតខ្ញុំ និងក្នុងទីបន្ទាល់របស់អ្នកដទៃ។ រនាំងក៏បានកើតមាន រវាងខ្ញុំ និងព្រះដែរ។ ពេល

ណាខ្ញុំធ្លាក់ចូលទៅក្នុងស្ថានភាពមួយ ដែលក្នុងនោះ សេចក្តីស្រឡាញ់ដែលខ្ញុំមានចំពោះព្រះ ត្រូវបានល្បងល ដោយសេចក្តីស្រឡាញ់ ដែលខ្ញុំមានចំពោះមនុស្ស និងបំណងចិត្តដែលខ្ញុំចង់ឲ្យពួកគេស្គាល់ព្រះ និងអរសប្បាយនឹងជីវិតអស់កល្ប។

រនាំងនោះ គឺផ្អែកទៅលើបទពិសោធន៍ដែលខ្ញុំមាន ក្នុងការស្គាល់សេចក្តីពិត និងភាពស្រស់ស្អាតរបស់ព្រះ។ ទោះអ្នកចង់ឬមិនចង់ក៏ដោយ ខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យទៅរកមនុស្សម្នាក់ ដែលមិនមែនជាអ្នកជឿ ដើម្បីប្រាប់ពួកគេឲ្យដឹងថា ព្រះយេស៊ូវស័ក្តិសមនឹងឲ្យពួកគេជឿយ៉ាងណា ហើយចាំមើលថា នឹងមានរឿងអ្វីកើតឡើង។

**ចូរពិចារណាអំពីពេលសម្រាករបស់លោកអ្នក**

ទី២ សូមគិតថា តើពេលសម្រាកប្រភេទណា ដែលអ្នកត្រូវការ ហើយការសម្រាកមានទម្រង់បែបណា ដែលបរិសុទ្ធ ហើយមិនប្រាសចាកពីភាពបរិសុទ្ធរបស់អ្នក។ ដោយមិនបាច់គិតច្រើន ខ្ញុំអាចស្មានដឹងថា អ្នកកំពុងតែយកការកម្សាន្តសប្បាយបែបលោកីយ៍ជាទីមួយ ដែលនាំឲ្យអ្នកមានការចរចារ ដោយព្រោះទស្សនៈបែបលោកីយ៍ ដែលជ្រួតជ្រាបពេញ ក្នុងការកម្សាន្តសប្បាយទាំងនោះ (និងភាពអសីលធម៌ដទៃទៀត ក្នុងនោះដែរ) កំពុងតែធ្វើឲ្យសម្បជញ្ញៈរបស់អ្នកខូចហើយ។

ព្រះទ្រង់សព្វព្រះទ័យឲ្យយើងមានពេលសម្រាក យើងមិនអាចមានភាពរឹងមាំគ្រប់ពេលនោះឡើយ។ ដូចនេះ សូមពិចារណា អំពីប្រភេទនៃពេលសម្រាកដែលបរិសុទ្ធ ហើយមិនប្រជែងខ្លាំង ជាមួយនឹងការអរសប្បាយដែលអ្នកមានក្នុងព្រះ។ ចូរឲ្យពេលសម្រាកនោះ ក្លាយជាពេលបង្ហាញចេញនូវការអរសប្បាយក្នុងព្រះ។



**ចូរស្វែងរកសៀវភៅល្អៗ**

នេះជាការលើកទឹកចិត្តចុងក្រោយ ហើយក៏ជាចំណុចសំខាន់ណាស់ដែរ។ សូមស្វែងរកសៀវភៅ របស់អ្នកនិពន្ធដែលបានស្លាប់ហើយ (អ្នកនិពន្ធថ្មីៗមួយចំនួន) ឬអ្នកនិពន្ធដែលនៅរស់ ដែលនិយាយ ឬសរសេរអំពីព្រះក្នុងនាមជាអ្នកដែលពិតជាបានភ្លក់រសជាតិ និងមើលឃើញថា ព្រះទ្រង់មានពេញដោយសិរីល្អ និងភាពស្រស់ស្អាត ហើយជាទីស្ងប់ស្ងល់ ហើយពួកគាត់បានសរសេរសៀវភៅនោះ តាមរបៀប ដែលធ្វើឲ្យអ្នកបានស្គាល់រសជាតិនោះ ពេលដែលអ្នកបានអានសៀវភៅពួកគាត់។

សព្វថ្ងៃនេះ ខ្ញុំកំពុងអានសៀវភៅដែលលោកគ្រូ ចន អូវិន (John Owen) បាននិពន្ធ មានចំណងជើងថា កាតព្វកិច្ចនៃការប្រុងប្រយ័ត្នខាងឯវិញ្ញាណ។ នោះជាអ្វីដែលលោកគ្រូ អូវិន បានធ្វើសម្រាប់ខ្ញុំ។ ខ្ញុំបានចំណាយពេលអានសៀវភៅរបស់លោកអូវិន នៅថ្ងៃអាទិត្យ។ ខ្ញុំមានពេលទំនេរច្រើននៅពេលរសៀលថ្ងៃអាទិត្យ ដែលតាមធម្មតា ខ្ញុំមិនមានគម្រោងធ្វើអ្វីផ្សេង។ ដូចនេះ ខ្ញុំអង្គុយនៅលើសាឡុង ហើយខ្ញុំនឹងទទួលការបង្រៀនព្រះបន្ទូលព្រះពីលោកគ្រូ អូវិន។ សៀវភៅរបស់គាត់កំពុងជួយខ្ញុំ ឆ្លើយសំណួរដែលអ្នកបានលើកឡើង អំពីការកម្សាន្តសប្បាយ។

ពេលដែលខ្ញុំបានអានសៀវភៅគាត់ ខ្ញុំបានទទួលការក្រើនរម្លឹក អំពីអត្ថន័យពិតនៃការប្រុងប្រយ័ត្នខាងឯវិញ្ញាណ ដែលមានចែងក្នុងព្រះគម្ពីរ។ ខ្ញុំក៏បានដឹងថា ខ្ញុំមានភាពល្ងង់ខ្លៅប៉ុណ្ណា។ លោកគ្រូ អូវិន បានលើកយកខគម្ពីរមកប្រើ តាមរបៀបដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ហាក់ដូចជាមិនដែលបានអានខគម្ពីរទាំងនោះ។ បន្ទាប់មក ក្តីអំណររបស់ខ្ញុំក៏ចាប់ផ្តើមកើតមាន។ បាទ ខ្ញុំដឹងច្បាស់ថា គាត់កំពុងនិយាយអំពីអ្វី។ ប៉ុន្តែ វាជាសេចក្តីពិតពេញដោយសិរីល្អ ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ស្រស់ថ្លា។

ខ្ញុំសូមអធិស្ឋានថា អ្នកនឹងមិនបោះបង់ការតយុទ្ធនេះចោលទេ ហើយ

បានទៅដល់ទីបញ្ចប់នៃជីវិតរបស់អ្នក ដោយនិយាយជាមួយសាវ័ក ប៉ុលថា «ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាជំនឿទៅហើយ» (២ធីម៉ូថេ ៤:៧)។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
How Do I Love God More Than My Entertainment
**ធ្វើដូចម្តេចឲ្យខ្ញុំអាចស្រឡាញ់ព្រះ ខ្លាំងជាងការកម្សាន្តសប្បាយរបស់ខ្ញុំ?**
https://www.desiringgod.org/interviews/how-do-i-love-god-more-than-my-entertainment



## សំណួរទី៩៨ៈ
# ប្រសិនបើខ្ញុំស្តាប់ការអធិប្បាយ ហេតុអ្វីខ្ញុំត្រូវអានព្រះគម្ពីរទៀត?

យើងមានសំណួរមួយដែលអ្នកអានរបស់យើងបានសួរ «សួស្តីលោកគ្រូ! ខ្ញុំពឹងផ្អែកលើគ្រូគង្វាលរបស់ខ្ញុំក្នុងការសិក្សាព្រះគម្ពីរ ហើយប្រាប់ខ្ញុំពីអ្វីដែលព្រះជាម្ចាស់ចង់មានបន្ទូលមកកាន់ខ្ញុំតាមរយៈព្រះគម្ពីរនោះឯង។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនចាំបាច់អានព្រះគម្ពីរទៀតទេ ពីព្រោះខ្ញុំបានស្តាប់សេចក្តីអធិប្បាយរបស់គាត់រៀងរាល់សប្តាហ៍ហើយ»។ តើលោកគ្រូគិតដូចម្តេចដែរចំពោះបុគ្គលដែលគិតថា សេចក្តីអធិប្បាយនៅថ្ងៃអាទិត្យ គឺគ្រប់គ្រាន់ហើយសម្រាប់ចំណេះដឹងព្រះគម្ពីរពេញមួយសប្តាហ៍របស់គាត់?

ខ្ញុំគឺជាគ្រូគង្វាល ហើយខ្ញុំចូលចិត្តណាស់នៅពេលមានអ្នកស្តាប់ខ្ញុំ។ ខ្ញុំចូលចិត្តណាស់នៅពេលអ្នកដទៃទុកចិត្តលើគ្រូគង្វាលរបស់ខ្លួន ហើយពួកគាត់រីករាយក្នុងការស្តាប់គ្រូគង្វាល ពន្យល់អំពីព្រះគម្ពីររៀងរាល់សប្តាហ៍។ អាម៉ែន! នោះគឺជាការដ៏ល្អប្រសើរមួយ។

### តើលោកអ្នកស្រេកឃ្លានទេ?

ប៉ុន្តែ មានអ្វីមួយដែលមិនប្រក្រតីនៅទីនេះ។ ខ្ញុំចង់មានន័យថា វាធ្ងន់ធ្ងរមែន។ មានអ្វីមួយមិនប្រក្រតីនៅទីនេះ ពីព្រោះប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលមកដោយមានពេញដោយអំណាចព្រះចេស្តារៀងរាល់សប្តាហ៍ នោះព្រះបន្ទូលមិនគ្រាន់តែ បំពេញភាពស្កប់ស្កល់នៃការស្រេកឃ្លាននោះទេ ប៉ុន្តែព្រះបន្ទូលនោះបង្កើតឲ្យមានភាពស្រេកឃ្លានផងដែរ។ ខ្ញុំនឹងមានអារម្មណ៍ថា ខ្ញុំជាអ្នកបរាជ័យទាំងស្រុងតែម្តង ប្រសិនបើពួកជំនុំរបស់ខ្ញុំ

និយាយថា «ដោយសារសេចក្ដីអធិប្បាយរបស់លោកគ្រូ ពួកយើងមិនចាំបាច់អានព្រះគម្ពីរទៀតនោះទេ»។ នោះខ្ញុំនឹងគិតថា «តើខ្ញុំបានធ្វើអ្វី? ខ្ញុំបានផ្ដល់អាហារដល់លោកអ្នកដែលមិនគួរឲ្យចាប់អារម្មណ៍ ឬគួរឲ្យធុញទ្រាន់ ឬក៏មិនមានសញ្ញាណាមួយ ឬជាសេចក្ដីសង្ឃឹមដែលលោកអ្នកមិនមាន សូម្បីតែចាប់យកក្នុងអំឡុងពេលមួយសប្ដាហ៍ផង»។

ដូច្នេះ ខ្ញុំពិតជាឆ្ងល់ណាស់អំពីអ្វីដែលមាននៅក្នុងចិត្តរបស់បុគ្គលម្នាក់នេះក្នុងការនិយាយថា «ខ្ញុំត្រូវការតែសេចក្ដីអធិប្បាយប៉ុណ្ណោះ»។ ហើយសំណួររបស់ខ្ញុំគឺដូចនេះ «តើលោកអ្នកចង់បានតែប៉ុណ្ណោះមែនឬ? ហេតុអ្វីបានជាអាហារនៅថ្ងៃអាទិត្យមិនធ្វើឲ្យរសជាតិរបស់លោកអ្នកកាន់តែឆ្ងាញ់នៅថ្ងៃចន្ទ? ហេតុអ្វីមិនដូច្នោះ?» សម្រាប់ខ្ញុំ មើលទៅហាក់បីដូចជាមានបញ្ហាពីរនៅត្រង់ចំណុចនេះ។ ទី១គឺថា តើយើងត្រូវការព្រះគម្ពីរដល់កម្រិតណា? ហើយមួយទៀតគឺថា តើយើងចង់បានព្រះគម្ពីរខ្លាំងដល់កម្រិតណា?

**តើយើងចង់បានដល់កម្រិតណា?**

ដូច្នេះ ចូរពិនិត្យមើលលើសំណួរដែលថា ចង់បានដល់កម្រិតណា។ ហេតុអ្វីបានជាលោកអ្នកចង់បានសេចក្ដីអធិប្បាយតែមួយដងចេញពីព្រះគម្ពីរក្នុងមួយសប្ដាហ៍? ហេតុអ្វីបានជាលោកអ្នកចង់បានសេចក្ដីអធិប្បាយតែមួយហ្នឹងក្នុងមួយសប្ដាហ៍ តាមរយៈអ្នកផ្សេង? ចំពោះខ្ញុំ នោះប្រៀបដូចជាការនិយាយថា «ខ្ញុំមានស្នេហាហើយ។ សង្សាររបស់ខ្ញុំសរសេរសំបុត្រមកខ្ញុំជារៀងរាល់ថ្ងៃ ហើយខ្ញុំនឹងអានសំបុត្ររបស់គាត់តែមួយប៉ុណ្ណោះក្នុងមួយសប្ដាហ៍ ហើយខ្ញុំគិតថា ខ្ញុំនឹងឲ្យអ្នកណាម្នាក់ផ្សេងទៀតអានឲ្យខ្ញុំស្ដាប់ ហើយប្រាប់ខ្ញុំពីអ្វីដែលគាត់ចង់និយាយ»។ អ្នកកំពុងនិយាយលេងទេឬអី? មានពេលមួយ ខ្ញុំមានស្នេហា គឺនៅរដូវក្ដៅក្នុងឆ្នាំ១៩៦៧ ដែលកាលនោះខ្ញុំគឺជាគ្រូបង្វឹកហែលទឹកម្នាក់ (និងអ្នកការពារនៅកន្លែងលេងទឹក)។ ខ្ញុំហិត



ស្រោមសំបុត្រនោះ៥នាទីមុនពេលខ្ញុំបើកវា។ ខ្ញុំក៏នឹងមិនឲ្យទៅនរណាផ្សេងទៀតនោះទេ។ ខ្ញុំពិតជាមានចិត្តចង់ចេញទៅក្រៅជារៀងរាល់ថ្ងៃជាមួយនឹងស្រោមសំបុត្រដែលមានជាប់ក្លិនផ្កាកុលាប និងក្លិនដៃរបស់អនាគតប្រពន្ធខ្ញុំណាស់។

ការចង់អានសំបុត្រស្នេហាតែមួយដងក្នុងមួយសប្ដាហ៍ នៅពេលដែលនាងសរសេរវាជារៀងរាល់ថ្ងៃគឺជាសញ្ញាបង្ហាញថា មានអ្វីមួយមិនប្រក្រតីហើយ។ ការនោះប្លែកណាស់។ មានអ្វីមួយមិនប្រក្រតីនៅក្នុងទំនាក់ទំនងរបស់បុគ្គលម្នាក់នេះជាមួយព្រះជាម្ចាស់ជាមិនខាន។

ប៉ុន្តែ សាវ័ក ប៉ុល បានលើកឡើងថាគាត់រស់នៅសម្រាប់ព្រះយេស៊ូវដែលទ្រង់ស្រឡាញ់គាត់ ហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសគាត់ (កាឡាទី ២:២០)។ នោះគឺជាការពិត។ ព្រះយេស៊ូវស្រឡាញ់យើងដល់ម៉្លេះ បានជាទ្រង់ប្រគល់ព្រះជន្មរបស់ទ្រង់ជំនួសយើងរាល់គ្នា។ ព្រះជាម្ចាស់ស្រឡាញ់យើងដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រារបស់ទ្រង់សម្រាប់យើង។ ហើយព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវនេះឯងដែលព្រះអង្គបានស្រឡាញ់យើង ហើយព្រះវរបិតាដែលស្រឡាញ់យើង—ទាក់ទងជាមួយរបៀបដែលព្រះអង្គមានទំនាក់ទំនងជាមួយយើង និងអំពីអ្វីដែលព្រះអង្គកំពុងធ្វើលើផែនដីនេះ។ ព្រះគម្ពីរទាំងមូលគឺជាសំបុត្រនៃសេចក្ដីស្រឡាញ់របស់ព្រះដែលមិនអាចប្រៀបផ្ទឹមបានរបស់ព្រះជាម្ចាស់ទៅកាន់រាស្ត្ររបស់ព្រះអង្គ។ ដូច្នេះហើយបានជាអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងបានចែងថា «ព្រះបន្ទូលនៃទ្រង់ផ្អែមនៅអណ្ដាតទូលបង្គំណាស់ហ្ន៎ អើ ក៏ផ្អែមជាងទឹកឃ្មុំដល់មាត់ទូលបង្គំទៅទៀត» (ទំនុកតម្កើង ១១៩:១០៣)។ វាមិនសមហេតុផលនោះទេសម្រាប់អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងក្នុងការលើកឡើងថា «ទូលបង្គំទទួលបានទឹកឃ្មុំមួយស្លាបព្រាយ៉ាងពេញ ហើយវាលើសលប់ណាស់ហើយ ទូលបង្គំមិនចង់បានសម្រាប់ថ្ងៃចន្ទ អង្គារ ពុធ ព្រហស្បតិ៍

សុក្រ ឬថ្ងៃសៅរ៍ទៀតនោះទេ»។ ប៉ុន្តែ ផ្ទុយទៅវិញគាត់បានលើកឡើងថា៖

- “ទូលបង្គំត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងគិតក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ” (សូមមើលនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ១:២)។
- “សេចក្តីទាំងនោះគួរចង់បានលើសជាងមាស” (ទំនុកតម្កើង ១៩:១០)។
- “បើឯងខំរកដូចជារកប្រាក់ ហើយស្វែងរកដូចជារកកំណប់ទ្រព្យ នោះឯងនឹងបានយល់សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា ហើយប៉ះប្រទះនឹងសេចក្តីស្គាល់ដល់ព្រះអង្គ» (សុភាសិត ២:៤-៥)។

ដូច្នេះ ខ្ញុំសូមសួរដល់អ្នកអាន និងអ្នកស្តាប់របស់យើង—សូមព្រះបានប្រទានពរដល់ដួងចិត្តរបស់គាត់—ហេតុអ្វីបានជាអ្នកចង់ឃើញភាពស្រស់ស្អាតត្រឹមមួយសប្តាហ៍ ឬក៏ភ្លក់ទឹកឃ្មុំតែមួយដងក្នុងមួយអាទិត្យ ឬការដាក់ប្រាក់តែមួយដងក្នុងមួយសប្តាហ៍ក្នុងកុងធនាគាររបស់លោកអ្នក ឬក៏ទទួលសំបុត្រតែមួយក្នុងមួយសប្តាហ៍ពីមនុស្សជាទីស្រឡាញ់របស់អ្នក? តើមានរឿងអ្វីកើតឡើង? សូមភ្ញាក់ឡើង! ក្រោកឡើង ចូរភ្ញាក់មកឯភាពពិតជាក់ស្តែងចុះ។

## តើយើងត្រូវការខ្លាំងដល់កម្រិតណា?

បន្ទាប់មក ខ្ញុំចង់ប្តូរសំណួរសួរថា តើលោកអ្នកត្រូវការអ្វី? តើលោកអ្នកត្រូវការអាហារតែមួយពេលទេឬអីក្នុងមួយសប្តាហ៍? មិនមែនគ្រាន់តែថា តើលោកអ្នកចង់បានអ្វី ប៉ុន្តែតើលោកអ្នកត្រូវការអ្វី? ព្រះយេស៊ូវបានមានព្រះបន្ទូលថា «មនុស្សមិនមែនរស់ ដោយសារតែនំប៉ុងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤)—គឺគ្រប់ទាំងព្រះបន្ទូល។ នេះគឺជារបៀបដែលលោកអ្នករស់នៅ។ លោកអ្នកត្រូវការទទួលទានអាហារ។

ខ្ញុំគិតថា ខ្ញុំអាចនិយាយចេញពីបទពិសោធន៍ ចេញពីប្រវត្តិសាស្រ្ត និងចេញពីព្រះគម្ពីរផ្ទាល់៖ គ្រប់គ្រីស្ទបរិស័ទទាំងអស់គួរតែចំណាយពេលលើព្រះគម្ពីរច្រើនជាងនេះ ចំណាយពេលលើអាហារខាងឯព្រលឹងវិញ្ញាណច្រើនជាងមួយដងក្នុងមួយសប្តាហ៍—ដែលមិនធ្វើការខាងឯរាងកាយ ឬព្រលឹងវិញ្ញាណនោះទេ។ ការល្បួងមានឥតឈប់ឈរ។ មន្ទិលសង្ស័យមានជាញឹកញាប់។ សាតាំងសកម្មយ៉ាងខ្លាំង។ មានទុក្ខព្រួយយ៉ាងធ្ងន់ក្រៃ។ ជម្លោះមានច្រើនអនេក។ អារម្មណ៍ប្រែប្រួលយ៉ាងខ្លាំង។ ភាពច្របូកច្របល់ពិបាកខ្លាំងពេក។ សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ត្រូវបានទទួលកាគម្រាមកំហែងយ៉ាងខ្លាំងក្នុងការគិតថា ខ្ញុំអាចដោះស្រាយជាមួយការទាំងនេះពេញមួយសប្តាហ៍បានចេញពីព្រះបន្ទូលដែលខ្ញុំទទួលបាននៅថ្ងៃអាទិត្យ។ ខ្ញុំផ្ទាល់មិនអាចធ្វើបានទេ។ ហើយខ្ញុំក៏គិតថា មិនមាននរណាម្នាក់អាចធ្វើបានដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
If I Listen to Sermons, Why Do I Need to Read My Bible?
**ប្រសិនបើខ្ញុំស្តាប់ការអធិប្បាយ ហេតុអ្វីខ្ញុំត្រូវអានព្រះគម្ពីរទៀត?**
https://www.desiringgod.org/interviews/how-do-i-love-god-more-than-my-entertainment

### សំណួរទី៩៩៖

# តើការចំណាយពេលស្តាប់ព្រះគម្ពីរជាសំឡេងគ្រប់គ្រាន់សម្រាប់ការចំណាយពេលជាមួយនឹងព្រះជាម្ចាស់ដែរឬទេ?

*យើងទទួលបានសំណួរជាច្រើនទាក់ទងទៅនឹងការស្តាប់ព្រះគម្ពីរជាសំឡេង ឬក៏ការស្តាប់អត្ថបទជាសំឡេង។ នេះជាសំណួរមួយ៖ «ជម្រាបសួរលោកគ្រូ! ខ្ញុំជាអ្នកបើកបរម្នាក់ ខ្ញុំតែងតែទទួលបានការចំណាយពេល «អាន» ព្រះគម្ពីរ ខណៈពេលដែលខ្ញុំកំពុងតែបើកបរ។ ប៉ុន្តែ តើលោកគ្រូគិតថា ការស្តាប់ព្រះគម្ពីរជាសំឡេងមានឥទ្ធិពលដូចគ្នាទៅនឹងការអានព្រះគម្ពីរផ្ទាល់ជាក្រដាសជាមួយនឹងភ្នែកយើងដែរឬទេ? ខ្ញុំអាចត្រឡប់ក្រោយ ហើយស្តាប់ជំពូកចាស់ម្តងទៀតបាន ប្រសិនបើខ្ញុំចង់។ ខ្ញុំសូមអរគុណលោកគ្រូទុកជាមុន ទាក់ទងនឹងយោបល់ដែលលោកគ្រូនឹងផ្តល់ឲ្យ»។*

អ្វីដែលខ្ញុំនឹងធ្វើ ដើម្បីឆ្លើយសំណួរនេះគឺ៖ លើកឡើងនូវចំណុចសង្ខេបត្រួសៗ១០យ៉ាងអំពីអត្ថប្រយោជន៍នៃការស្តាប់ព្រះគម្ពីរជាសំឡេង ហើយបន្ទាប់មកលើកឡើងនូវចំណុចសង្ខេបមួយចំនួនទាក់ទងទៅនឹងដែនកំណត់នៃការស្តាប់។ ខ្ញុំគិតថា ការធ្វើបែបនេះនឹងឆ្លើយសំណួរខាងលើត្រង់ថា តើការស្តាប់ព្រះគម្ពីរជាសំឡេងមានឥទ្ធិពលដូចគ្នាទៅនឹងការអានព្រះគម្ពីរផ្ទាល់ដែរឬទេ?

**១. គ្រប់ការប្រាថ្នាក្នុងការចំណាយពេលក្នុងព្រះគម្ពីរគឺពិតជាអស្ចារ្យណាស់**

វាពិតជាល្អណាស់ ពេញទៅដោយអធិធម្មជាតិ និងជាអំណោយទានដ៏អស្ចារ្យពីព្រះជាម្ចាស់ ដែលអ្នកសួរមានចិត្តប្រាថ្នាចង់ស្តាប់ព្រះគម្ពីរ

ជាសំឡេង ខណៈពេលដែលគាត់កំពុងបើកបរ។ នេះគឺជាចំណុចដំបូង ដែលមាននៅក្នុងគំនិតរបស់ខ្ញុំ៖ ត្រង់ថាការដែលគាត់ប្រាថ្នាចង់ស្ដាប់ព្រះបន្ទូលព្រះគឺជាចំណុចដ៏អស្ចារ្យណាស់ ពីព្រោះមានមនុស្សរាប់លាននាក់មិនខ្វល់អំពីព្រះគម្ពីរទាល់តែសោះ។ វាគឺជារឿងដែលគួរឲ្យសោកស្ដាយណាស់ ហើយក៏ជារឿងដែលនាំឲ្យយើងខូចចិត្តដែរ។

ព្រះបានមានបន្ទូល—ព្រះអាទិករនៃចក្រវាលនេះបានមានបន្ទូល—ហើយមនុស្សរាប់លាននាក់មិនស្ដាប់ទាល់តែសោះ។ ប៉ុន្ដែ តាមរយៈសំណួរនេះ យើងមានបុគ្គលម្នាក់ដែលដួងចិត្តរបស់គាត់ចង់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនេះគឺពិតជាអស្ចារ្យមែន។

## ២. នីតិវិធីនៃការស្ដាប់ និងការអានរបស់យើងមានភាពខុសៗគ្នាទាំងអស់

ខួរក្បាលរបស់មនុស្សយើងមានលក្ខណៈខុសៗគ្នាក្នុងរបៀបដែលយើងវិភាគអ្វីដែលយើងអាន និងអ្វីដែលយើងស្ដាប់ឮ។ កូនៗរបស់ខ្ញុំសុទ្ធតែមានលក្ខណៈខុសៗគ្នាទាក់ទងនឹងចំណុចនេះ។ អ្នកខ្លះស្ទើរតែចងចាំរាល់គ្រប់ចំណុចដែលគាត់ស្ដាប់ឮ ប៉ុន្ដែគាត់ស្ទើរតែមិនចាំរាល់អ្វីដែលគាត់អានទាល់តែសោះ ហើយក៏នៅមានអ្នកខ្លះទៀតដែលចងចាំស្ទើរតែរាល់គ្រប់ចំណុចដែលគាត់អាន ប៉ុន្ដែគាត់ស្ទើរតែមិនចាំរាល់អ្វីដែលគាត់ស្ដាប់ឮឡើយ។

ដូច្នេះ ទាក់ទងនឹងចំណុចនេះ ខ្ញុំចង់និយាយទៅកាន់អ្នកសួរថា អាស្រ័យទៅលើរបៀបដែលព្រះជាម្ចាស់បានបង្កើតអ្នក នោះទំនងចំពោះអ្នក ការស្ដាប់នឹងបង្កើតជាផលផ្លែច្រើនជាងការអានទៅទៀតក៏ថាបាន។ ខ្ញុំមិនអាចដឹងបានទេអំពីចំណុចនេះ។ អ្នកសួរបានសួរថា «តើវាមានប្រសិទ្ធភាពដូចគ្នាដែរឬទេ?» ហើយចម្លើយរបស់ខ្ញុំគឺថាខ្ញុំមិនដឹងទេ ព្រោះមានតែគាត់ទេដែលអាចដឹង។ ទំនងការស្ដាប់របស់គាត់ល្អប្រសើរជាងការអានក៏ថាបានដែរ។



## ៣. រាល់ការអានព្រះគម្ពីរគឺជាការកាត់ស្រាយ

គ្រប់ពេលដែលយើងស្ដាប់ការអានព្រះគម្ពីរជាសំឡេង គឺយើងមិនគ្រាន់តែកំពុងស្ដាប់ព្រះគម្ពីរទេ ប៉ុន្ដែយើងក៏កំពុងតែកាត់ស្រាយព្រះគម្ពីរដែរ។ ការអានឲ្យឮៗគឺជាការកាត់ស្រាយ៖ តាមល្បឿន តាមចង្វាក់ តាមការសង្កត់ធ្ងន់ តាមការបង្អង់ តាមអារម្មណ៍ តាមការស្ដាប់ដោយមានសំឡេងស្រទន់ តាមការស្ដាប់ដោយមានសំឡេងឮៗ និងតាមការលើកដាក់សំឡេងរបស់លោកអ្នក—គ្រប់ចំណុចទាំងអស់នេះផ្ដល់ជូនដល់លោកអ្នកនូវផ្នែកណាមួយនៃគោលបំណងរបស់អ្នកនិពន្ធ ក្នុងរបៀបដែលអ្នកអានយល់ និងទទួលបាននូវបទពិសោធន៍។

ខ្ញុំលើកឡើងនូវចំណុចនេះដោយសារវាអាចជាអ្វីដែលល្អយ៉ាងខ្លាំង ឬក៏ជាអ្វីដែលអាចជាបញ្ហាយ៉ាងធំ។ ប្រសិនបើការកាត់ស្រាយគឺជាអ្វីដែលអាចយល់បាន ហើយកំពុងតែពិតជាជ្រាបចូលក្នុងចិត្តក្នុងរបៀបដែលមានពេញទៅដោយអំណាច នោះមានន័យថាការស្ដាប់គឺជាប្រយោជន៍ដល់អ្នកឮ។ ប្រសិនបើការកាត់ស្រាយជាអ្វីដែលផ្ទុយពីគោលបំណងរបស់អ្នកនិពន្ធក្នុងអត្ថន័យ ឬក៏សូរសំឡេងសំណេរ នោះវាអាចជាបញ្ហាក្នុងការទទួលបានប្រយោជន៍ក្នុងរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងទទួលបានពេលយើងអាន ឬក៏ស្ដាប់ព្រះបន្ទូល។ យើងត្រូវតែដឹងថា នៅពេលដែលយើងស្ដាប់ គឺយើងកំពុងតែស្ដាប់ការកាត់ស្រាយមួយ ហើយយើងគួរតែមានការវែកញែកអំពីរឿងនេះ។ វាទំនងជារឿងត្រឹមត្រូវ ហើយវាក៏ទំនងជារឿងខុសឆ្គងដែរ។

## ៤. យើងត្រូវតែមានចិត្តបង្អង់ឈប់ ហើយដោះស្រាយជាមួយនឹងព្រះជាម្ចាស់

តើអ្នកបានត្រៀមចិត្តហើយឬនៅ ត្រៀមចិត្តក្នុងការបង្អង់ ហើយឈប់

បើកបរបន្តិច ដើម្បីផ្តោតចិត្តទាំងមូលរបស់ខ្លួន ក្នុងការសញ្ជឹងគិតលើផ្នែកណាមួយនៃព្រះបន្ទូល លើគំនិត ឬអារម្មណ៍ដែលព្រះជាម្ចាស់ទើបតែបានប្រើប្រាស់ ដើម្បីប៉ះពាល់ចិត្ត?

ខ្ញុំលើកសំណួរនេះឡើង ដោយសារមានមនុស្សជាច្រើន—ទើបតែប៉ុន្មានថ្ងៃមុននេះ—មានគេបានប្រាប់ខ្ញុំថា ជាច្រើនឆ្នាំកន្លងមក ក្នុងផ្នែកណាមួយនៃសេចក្តីអធិប្បាយ ខណៈពេលដែលពួកគាត់កំពុងតែបើកបរ ហើយក៏កំពុងតែស្តាប់សេចក្តីអធិប្បាយ ហើយនៅពេលនោះពួកគាត់មានការប៉ះពាល់ចិត្តយ៉ាងខ្លាំង រហូតដល់ថ្នាក់ថាត្រូវតែអែបរថយន្តបន្តិច ហើយចំណាយពេលដោះស្រាយជាមួយនឹងព្រះជាម្ចាស់ ក៏ដូចជាសម្រួលអារម្មណ៍ដោយមិនមានការរំខានពីការបើកបរ។ ខ្ញុំគិតថា គ្រប់បុគ្គលដែលស្តាប់ព្រះគម្ពីរជាសំឡេង ខណៈពេលដែលគាត់កំពុងតែបើកបរ ឬក៏កំពុងតែធ្វើអ្វីមួយផ្សេងទៀត គឺពួកគាត់ត្រូវតែមានចិត្តក្នុងការបង្អង់សិន ដើម្បីដោះស្រាយជាមួយនឹងព្រះជាម្ចាស់។

### ៥. ការស្តាប់ព្រះគម្ពីរជាសំឡេង ខណៈពេលដែលកំពុងបើកបរ ផ្តល់ជូននូវការផ្តោតតែមួយផ្នែកប៉ុណ្ណោះ

យើងត្រូវតែទទួលស្គាល់ថា ការស្តាប់ព្រះគម្ពីរជាសំឡេង ខណៈពេលដែលយើងកំពុងតែបើកបរ មានន័យថា ព្រះគម្ពីរកំពុងតែទទួលបានការផ្តោតលើតែមួយផ្នែកនៃចំណាប់អារម្មណ៍ទាំងមូលរបស់យើង។ ប្រសិនបើយើងមិនយកចិត្តទុកដាក់លើផ្លូវ ការបើកបរឡាន និងស្លាកសម្គាល់ នោះមានន័យថា យើងក៏មិនបានស្តាប់បង្គាប់ព្រះដែរ ពីព្រោះការធ្វើបែបនោះនាំឲ្យយើងដាក់ខ្លួនឯង និងអ្នកដទៃក្នុងស្ថានភាពដែលអាចមានគ្រោះថ្នាក់បាន។

ដូច្នេះ នេះគឺជាចំណុចអវិជ្ជមានដ៏សំខាន់មួយក្នុងការទទួលបាននូវអ្វីដែលទំនងជាមានសម្រាប់យើង តើព្រះគម្ពីរកំពុងតែមានការប្រកួតប្រជែងជាមួយនឹងអារម្មណ៍ដែលយើងត្រូវផ្តោតលើទាក់ទងនឹងការបើកបរដែរទេ? នេះមិនមែនជារឿងអាក្រក់ទេ។ វាគ្រាន់តែជាការដាក់កំណត់លើអ្វីដែលព្រះបន្ទូលទំនងជាអាចសម្រេចបាន ប្រសិនបើយើងអាចផ្តោតចំណាប់អារម្មណ៍លើទាំងស្រុង។

### ៦. យើងមិនអាចបើកមើលខយោងបានទេ ខណៈពេលដែលយើងកំពុងបើកបរ

នៅមានដែនកំណត់មួយទៀត ប្រសិនបើយើងអាន ដោយមិនកំពុងបើកបរ នោះយើងអាចផ្តោតចំណាប់អារម្មណ៍លើទាំងស្រុងបាន ដែលនេះមានន័យថាយើងអាចបង្អង់ ហើយបើកមើលខគម្ពីរយោង ដែលនឹងពន្យល់បន្ថែមទៀតលើពាក្យ ឃ្លា ឬក៏គំនិតដែលយើងកំពុងតែសញ្ជឹងគិត។ ខ្ញុំធ្វើបែបនោះស្ទើរតែគ្រប់ពេលដែលខ្ញុំអានព្រះគម្ពីរ។

មានពេលមួយ ខ្ញុំបានធ្វើការប្រៀបធៀបលើការកើតជាថ្មីរបស់សាវ័កពេត្រុស និងការកើតជាថ្មីរបស់លោក យ៉ាកុប និយាយឲ្យស្មោះទៅខ្ញុំនឹងមិនអាចធ្វើការដូច្នោះបានទេ ប្រសិនបើកាលនោះខ្ញុំកំពុងតែបើកបរ។

### ៧. ការបើកបរដាក់កំហិតលើការកត់ត្រា

ចំណុចមួយទៀតដែលយើងមិនអាចធ្វើបាន ខណៈពេលដែលយើងកំពុងតែបើកបរ គឺការសរសេរចុះនូវអ្វីដែលយើងទើបតែបានគិត ឬក៏ឃើញនៅក្នុងព្រះបន្ទូល។ ខ្ញុំយល់ថា មិនមែនគ្រប់គ្នាកត់ត្រាទុកនូវអ្វីដែលគាត់គិតដូចខ្ញុំនោះទេ ខ្ញុំចូលចិត្ត—មិនថាកត់ចំណាំនៅក្នុងទូរស័ព្ទ ឬក៏ iPad របស់ខ្ញុំ ឬក៏សរសេរចុះនៅលើក្រដាស និងប៊ិច—កត់ចំណាំលើគំនិត ឬក៏ខគម្ពីរទាក់ទងនឹងអ្វីដែលខ្ញុំកំពុងតែអាន សរសេរចុះនូវការយល់ដឹងថ្មីដែលខ្ញុំទើបតែទទួលបាន។ យើងដឹងហើយថា យើងមិនអាចធ្វើការនេះបានដោយងាយស្រួលទេ ប្រសិនបើយើងកំពុងតែបើកបរ។

## ៨. កុំគ្រាន់តែស្តាប់ព្រះគម្ពីរជាសំឡេងតែប៉ុណ្ណោះ

ដោយយោងតាមអ្វីដែលខ្ញុំបានលើកឡើង រហូតដល់ពេលនេះ ខ្ញុំចង់លើកទឹកចិត្តថា យើងមិនគួរយកការស្តាប់ព្រះគម្ពីរជាសំឡេងធ្វើជារបៀបមួយដែលយើងប្រកបគ្នាជាមួយនឹងព្រះបន្ទូលរបស់ទ្រង់ជាគោលឡើយ។ ការស្តាប់គឺជារបៀបដ៏ល្អមួយក្នុងការជួបជាមួយព្រះជាម្ចាស់។ ពិតណាស់ តាមរយៈការស្តាប់ យើងក៏អាចទទួលបានអត្ថប្រយោជន៍ និងគុណសម្បត្តិមួយចំនួនមែន ប៉ុន្តែការស្តាប់ក៏នៅមានដែនកំណត់ដែរ។ ដូច្នេះ យើងគួរតែចំណាយពេលស្តាប់ខ្លះ និងអានខ្លះ។

## ៩. សូមសាកស្តាប់ ខណៈពេលដែលកំពុងអាន

នេះគឺជាអ្វីដែលខ្ញុំធ្វើ៖ លាយឡំការស្តាប់ជាមួយនឹងការអាន ដោយធ្វើទាំងពីរឡើងក្នុងពេលតែមួយ។ ពេលខ្លះ ប្រសិនបើខ្ញុំអស់កម្លាំងខ្លាំង ប៉ុន្តែនៅចង់អានពីរបីជំពូកនៃព្រះគម្ពីរ ប៉ុន្តែភ្នែក និងខួរក្បាលរបស់ខ្ញុំបដិសេធ «យើងមិនអាចធ្វើដូចនេះបានទេឥឡូវនេះ យើងអស់កម្លាំងណាស់» នោះខ្ញុំក៏បើកទូរស័ព្ទ ឬក៏ iPad របស់ខ្ញុំ ហើយចាក់ព្រះគម្ពីរស្តាប់។ ខ្ញុំផ្ទៀងស្តាប់ព្រះគម្ពីរជាសំឡេង ដោយយកភ្នែកអានជាមួយដែរ។

មូលហេតុដែលខ្ញុំមិនសូវធ្វើបែបនេះរាល់ពេលវេលា គឺដោយសារខ្ញុំមិនត្រូវការប្រើខួរក្បាលរបស់ខ្ញុំខ្លាំងពេក នៅពេលមានអ្នកផ្សេងអានព្រះគម្ពីរឲ្យខ្ញុំស្តាប់ ហើយខ្ញុំគិតថា នៅពេលដែលខ្ញុំអានដោយខ្លួនឯង នោះខ្ញុំអាចកាន់តែផ្តោតអារម្មណ៍លើព្រះគម្ពីរដោយអានឲ្យឮៗផ្ទាល់ ដែលការធ្វើបែបនោះកាន់តែនាំឲ្យខ្ញុំទទួលបានផលផ្លែច្រើនជាងការដែលគ្រាន់តែស្តាប់អ្នកផ្សេងអាន។ ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំនៅគិតថា វាអាចជាជំនួយដល់ខ្ញុំ នៅពេលដែលមានអ្នកដទៃអានឲ្យខ្ញុំស្តាប់ខ្លះដែរ។



## ១០. សូមបន្តព្យាយាមស្គាល់ ក្នុងព្រះបន្ទូលរបស់ទ្រង់

ជាចុងក្រោយ សូមបន្តស្តាប់ព្រះគម្ពីរជាសំឡេង តាមដែលអ្នកអាចធ្វើបាន ខណៈពេលដែលកំពុងតែបើកបរចុះ។ សូមព្រះជាម្ចាស់បំពេញលោកអ្នកដោយព្រះវិញ្ញាណនៃប្រាជ្ញា និងការបើកសម្តែង ខណៈពេលដែលលោកអ្នកស្តាប់ ហើយបើកបរ (ដូចដែលសាវ័ក ប៉ុល បានអធិស្ឋាន [«សូមឲ្យព្រះនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង គឺជាព្រះវរបិតាដ៏មានសិរីល្អ បានប្រទានឲ្យអ្នករាល់គ្នាបានព្រះវិញ្ញាណ ដែលប្រោសឲ្យមានប្រាជ្ញា ហើយក៏បើកសម្តែង ឲ្យដឹងពីដំណើរស្គាល់ទ្រង់»] អេភេសូរ ១:១៧)។ សូមព្រះអង្គបំភ្លឺភ្នែករបស់លោកអ្នក ឲ្យបានឃើញសេចក្តីអស្ចារ្យ នៅក្នុងក្រឹត្យវិន័យរបស់ទ្រង់ចុះ (ទំនុកតម្កើង ១១៩:១៨)។ នេះហើយគឺជាគោលបំណងរបស់យើង មិនថាយើងអាន ឬក៏ស្តាប់ព្រះគម្ពីរជាសម្លេងក៏ដោយ។ យើងចង់ឃើញព្រះអង្គឲ្យកាន់តែច្បាស់ កាន់តែស្រឡាញ់ព្រះអង្គ ហើយកាន់តែដើរតាមព្រះអង្គឲ្យបានកៀកបង្កើយថែមទៀត។ ហើយរបៀបដែលព្រះអង្គបានធ្វើការនោះគឺកើតឡើងតាមរយៈព្រះបន្ទូលរបស់ទ្រង់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**
Is an Audio Bible Sufficient for Devotions?
**តើការចំណាយពេលស្តាប់ព្រះគម្ពីរជាសំឡេងគ្រប់គ្រាន់សម្រាប់ការចំណាយពេលជាមួយនឹងព្រះជាម្ចាស់ដែរឬទេ?**
https://www.desiringgod.org/interviews/is-an-audio-bible-sufficient-for-devotions

## សំណួរទី៥០៖

# ហេតុអ្វីទំនាក់ទំនងមានភាពទន់ខ្សោយនៅក្នុងសម័យកាលដ៏ទំនើបនេះ?

*ដូចដែលលោកគ្រូបានរៀបរាប់ពីមុនថា ការភ្ជាប់ទំនាក់ទំនងជាមួយអ្នកផ្សេងទៀតនៅក្នុងសហគមន៍គឺចាំបាច់សម្រាប់ពួកយើងណាស់ ដើម្បីយល់ថាយើងជានរណា។ តាមនិយមន័យ អត្តសញ្ញាណរបស់យើង គឺយើងត្រូវតែរកឃើញនៅខាងក្រៅខ្លួនរបស់យើងវិញ។ ដូច្នេះ តើសហគមន៍ឌីជីថលរបស់យើងផ្តល់អ្វីខ្លះ—ឬមិនផ្តល់អ្វីខ្លះ—ដល់ទីបញ្ចប់នៃការរកឃើញនេះថា តើយើងជានរណា?*

ខ្ញុំគិតថា យើងនៅឆាប់បន្តិចក្នុងបដិវត្តន៍នេះ ដើម្បីឲ្យដឹងច្បាស់។ ប្រាកដណាស់ មានតម្រុយគ្រប់គ្រាន់ហើយ ដើម្បីប្រាប់យើងថា ទំនាក់ទំនងដែលគ្រាន់តែជាទំនាក់ទំនងឌីជីថលតាមអ៊ីនធឺណិតគឺមានភាពទន់ខ្សោយ និងមិនមានខ្លឹមសារ។ តាមពិតទៅ វាមិនមែនតែងតែជាករណីនេះនោះទេ។ ហើយខ្ញុំចង់ប្រយ័ត្នថា យើងមិននិយាយអ្វីដែលលើសពីនេះទេ។

### ការចង់បានច្រើនទៀត

បើនិយាយឲ្យទូលំទូលាយទៅ ចំនួនទំនាក់ទំនងដែលយើងមាន និងទទួលបានតាមរយៈការរស់នៅក្នុងយុគសម័យឌីជីថលមានន័យថា គ្មានទំនាក់ទំនងណាមួយអាចរឹងមាំខ្លាំងទេ។ គ្មានអ្នកណាម្នាក់អាចមានទំនាក់ទំនងយ៉ាងស៊ីជម្រៅបានទេ។ ជាលទ្ធផលនៃសម័យកាលនេះគឺថា យើងរស់នៅលើផ្ទៃក្រៅនៃជីវិតរបស់គ្នាទៅវិញទៅមក។ ធ្លាប់មានពេលមួយក្នុងជីវិតខ្ញុំប្រហែលជាពី៥ទៅ៧ឆ្នាំមុន ជាពេលដែលយើងធ្លាប់បានគិតថា ហ្វេសប៊ុក

(Facebook) នឹងត្រូវជំនួសដោយអ្វីផ្សេងទៀត។ អស់អ្នកដែលធំធាត់ពេញវ័យឡើងជាមួយហ្វេសប៊ុកចាប់ផ្តើមទទួលស្គាល់ថា វាគឺជាការរស់នៅបែបបង្ហាញរូបភាព និងការចាប់អារម្មណ៍ ហើយជាលទ្ធផលគឺយើងរស់នៅដោយបង្ហាញតែពីភាពខាងក្រៅ។

អ្វីដែលចម្លែកនោះគឺថា តាមពិតទៅ វាមិនបានទៅណាទេ។ វាបានផ្លាស់ប្តូរ និងផ្លាស់ទី។ ស្ថិតិបានបង្ហាញថា មនុស្សនៅចុងបញ្ចប់នៃដំណាក់កាលអាយុខុសៗគ្នាដំណាក់កាលគ្នា ដំណាក់កាលជីដូនជីតា ក៏ដូចជាដំណាក់កាលក្មេងជំទង់កាន់តែមានការញៀនថែមទៀត។ ដូច្នេះ អ្វីដែលយើងទទួលស្គាល់នោះគឺថា ការរស់នៅលើផ្ទៃខាងក្រៅនៃជីវិតរបស់យើងអាចមានភាពទាក់ទាញយ៉ាងខ្លាំង ព្រោះវាហាក់ដូចជាមិនចំណាយច្រើននោះទេ។ យើងពិតជាមិនចាំបាច់ឈ្លោះជាមួយរឿងរ៉ាវដែលជ្រាលជ្រៅៗនោះទេ។ ប៉ុន្តែ វាក៏មិនសូវពេញចិត្តយ៉ាងខ្លាំងណាស់ណាផងដែរ។

ដូច្នេះហើយបានជាយើងតែងតែរំពឹងអ្វីមួយបន្ថែមទៀត ហើយដូចជាអាយដល (idol ដែលអាចប្រែថា «ព្រះក្លែងក្លាយ ឬរូបបដិមាករ») ដែលមិនបំពេញតាមការសន្យារបស់ខ្លួន ជំនួសឲ្យការបោះបង់ចោលអាយដលរបស់យើង យើង បែរជានៅបន្តត្រឡប់ទៅវាវិញដោយសង្ឃឹមថា វានឹងផ្តល់ឲ្យយើងកាន់តែច្រើនជាងមុន។ ដូច្នេះ មានការផ្លាស់ប្តូរដ៏សំខាន់មួយដែលកើតឡើងរវាងខ្លួនយើង និងពិភពលោកជុំវិញយើង។ យើងបន្តប្រាថ្នារំពឹងចង់ឲ្យវាប្រគល់អ្វីមួយដែលវាមិនអាចផ្តល់ឲ្យបាន ហេតុដូច្នេះជាជាងការវិលត្រឡប់ទៅរកព្រះដ៏មានព្រះជន្មគង់នៅដែលជាប្រភពនៃសេចក្តីសុខ និងសុវត្ថិភាពរបស់យើង យើងក៏បន្តត្រឡប់ទៅវិញ ហើយសុំឲ្យវាធ្វើអ្វីបន្ថែមទៀតសម្រាប់យើងវិញ។

ប៉ុន្តែ ជាថ្មីម្តងទៀត ខ្ញុំចង់ឲ្យមានការប្រុងប្រយ័ត្នក្នុងការនិយាយថាហ្វេសប៊ុកគឺជាអ្វីដែលអាក្រក់ ដែលស្មាតហ្វូន (smartphone) របស់យើងជាមូលដ្ឋាននៃការបំផ្លិចបំផ្លាញ។ ការប្រើប្រាស់វាដែលយើងអនុញ្ញាតឲ្យខ្លួនលេងទេ ដែលជាកង្វល់របស់ខ្ញុំ។

**ការប្រៀបធៀបអត្តសញ្ញាណ**

*ជីវិតជាច្រើននៅលើបណ្តាញសង្គមប្រព័ន្ធអ៊ីនធឺណិតគឺទាក់ទងទៅនឹងការបង្កើត និងការរក្សាកេរ្តិ៍ឈ្មោះរបស់ខ្លួនឯង។ យើងផ្តល់ជូនពិភពលោករបស់យើងនូវកំណែដែលយើងបានកែសម្រួលអំពីខ្លួនឯង។ តើចំណុចនេះទាក់ទងនឹងការថ្វាយបង្គំរូបព្រះ និងអត្តសញ្ញាណរបស់យើងដោយរបៀបណា?*

នេះជាសំណួរដ៏ល្អ។ តើយើងបង្កើតអត្តសញ្ញាណដោយរបៀបណា? យើងភាគច្រើនដឹងអំពីភាពខ្លាំងនៃការបង្កើតចំណាប់អារម្មណ៍ និងកេរ្តិ៍ឈ្មោះ។ យើងដឹងយ៉ាងច្បាស់នៅក្នុងបរិបទវប្បធម៌របស់យើងអំពីអ្វីដែលអ្នកដទៃគិតចំពោះយើង។ យើងប្រៀបធៀបខ្លួនយើងទៅនឹងអ្នកដទៃ។ ខ្ញុំគិតថាវាតែងតែជាការពិត។ ប៉ុន្តែ ល្បឿនដែលកើតឡើងក្នុងជីវិតរបស់យើងគឺលឿនជាងពេលមុនយ៉ាងខ្លាំងទៅទៀត។

ដូច្នេះ យើងដឹងថា អត្តសញ្ញាណរបស់យើងមានភាពផុយស្រួយក្នុងកម្រិតណាមួយ ប្រសិនបើយើងកំពុងប្រៀបធៀបខ្លួនយើងឥតឈប់ឈរទៅនឹងពិភពលោកដែលកំពុងផ្លាស់ប្តូរ និងទំនាក់ទំនងដែលកំពុងផ្លាស់ប្តូរ—មិនមែនគ្រាន់តែជាក្រុមមិត្តភក្តិកំណត់នោះទេ ប៉ុន្តែជាមួយអ្នកស្គាល់គ្នាស្ទើរតែគ្មានដែនកំណត់តាមរយៈប្រព័ន្ធអ៊ីនធឺណិត។ ហើយនឹងតែងតែមាននរណាម្នាក់ដែលនឹងអាចធ្វើអ្វីមួយដែលល្អប្រសើរជាងអ្វីដែលលោកអ្នកអាចធ្វើបានជាមិនខាន។ ខ្ញុំមិនខ្វល់ថា វាជាអ្វីនោះទេ តែនឹងតែងតែមាននរណាម្នាក់។ ដូច្នេះ បើនោះជាការប្រៀបធៀប នោះលោកអ្នកនឹងតែងតែមានអារម្មណ៍អសន្តិសុខជានិច្ច។

ហើយសំណួរគឺថា តើលោកអ្នកដោះស្រាយបញ្ហាអសន្តិសុខទាំងនោះដោយរបៀបណា? តើលោកអ្នកនឹងដោះស្រាយដោយរបៀបណាចំពោះសុវត្ថិភាពនោះ? ហើយខ្ញុំគិតថា វាមិនមែនជាបញ្ហានៅទីនេះនោះទេ—ទុកឲ្យខ្ញុំមើលទៅភាពទុទិដ្ឋិនិយមតាមដែលខ្ញុំអាចធ្វើបានចុះ—ដែលយើងនឹងអាចដោះស្រាយបានខណៈពេលដែលយើងកំពុងតែរស់នៅក្នុងជីវិតនេះ។ វាជាផ្នែកមួយនៃពិភពលោកដែលបានធ្លាក់ក្នុងអំពើបាប។ ប៉ុន្តែ សុទិដ្ឋិនិយមនៅទីនេះ និងជាប្រភេទនៃការឆ្ពោះទៅរកដំណឹងល្អនាពេលនេះគឺថា ព្រះគុណពិតជាបានបង្វែរការនេះឲ្យទៅជាទម្រង់ដើមវិញ ប៉ុន្តែប្រសើរជាងមុន។ ដូច្នេះ បញ្ហាប្រឈមនៃការរស់នៅក្នុងយុគសម័យអនឡាញគឺគ្រាន់តែជាភាពរហ័សរហួនប៉ុណ្ណោះ គឺចំនួនមនុស្សដ៏ច្រើនលើសលប់ដែលយើងអាចប្រៀបធៀបខ្លួនយើងទៅនឹងពួកគេ ក៏ដូចជាចំនួននៃការចាប់អារម្មណ៍នានា។

## តស៊ូដល់ទីបញ្ចប់

ដូច្នេះ យើងមានទោសដូចអ្នកសង្គមវិទ្យាសម័យទាំងអស់រម្លឹកយើងនៅក្នុងពិភពលោកនៃការផ្សាយដំណឹងល្អ។ តាមពិត យើងមានជំនាញល្អនៅក្នុងពិភពផ្សាយដំណឹងល្អនៃការបង្កើតតារាល្បីៗ ការបង្កើតការចាប់អារម្មណ៍ និងការបង្កើតរូបភាពដែលឆ្នៃប្រឌិត ដែលការនោះធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍នៃសារៈសំខាន់ និងសុវត្ថិភាពរបស់យើង។ ដូច្នេះ យើងត្រូវតែប្រុងប្រយ័ត្នបំផុត។ យើងដែលតម្រង់ទៅរកដំណឹងល្អ តម្រង់ទិសដើម្បីមើលឃើញព្រះថាជាព្រះដ៏មានព្រះជន្មរស់ នោះយើងក៏ងាយនឹងទម្រង់នៃការថ្វាយបង្គំរូបព្រះដែលយើងបង្កើតដោយខ្លួនឯងផងដែរ។

ប្រសិនបើអ្នកអានព្រះគម្ពីរ នោះលោកអ្នកនឹងឃើញថា វាមិនមែនជារឿងចម្លែកទេត្រង់ថា គឺរាស្ត្ររបស់ព្រះដែលតែងតែស្ថិតនៅក្រោមការចោទប្រកាន់ដ៏មុតស្រួចនៃការថ្វាយបង្គំរូបព្រះក្លែងក្លាយ។ ដូច្នេះ យើងក៏ត្រូវតែ



ប្រុងប្រយ័ត្នត្រង់ចំណុចថា ចំណាប់អារម្មណ៍ដែលយើងផ្តល់ឲ្យអ្នកដទៃថា ប្រសិនបើពួកគាត់មករកព្រះយេស៊ូវ ប្រសិនបើពួកគាត់ដោះស្រាយភាពខ្ទេចខ្ទាំរបស់ខ្លួន នោះវានឹងបញ្ចប់នូវភាពស្ទាហាប់នៃការថ្វាយបង្គំរូបព្រះក្លែងក្លាយនេះ។ វាមិនមែនដូចនេះនោះទេ។ វាប្រាកដជារម្លឹកយើងថា ព្រះអង្គសង្គ្រោះរបស់យើងគឺមិនមែនជាខ្លួនយើងនោះទេ។ គឺនៅពីខាងក្រៅយើងវិញ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**
Why Are Relationships Thin in the Digital Age?
**ហេតុអ្វីទំនាក់ទំនងមានភាពទន់ខ្សោយនៅក្នុងសម័យកាលដ៏ទំនើបនេះ?**
https://www.desiringgod.org/interviews/why-are-relationships-thin-in-the-digital-age

# កំណត់យោង

## សំណួរទី១

Contrary to Roman Catholics, the Bible Is Our Sufficient Authority
ផ្ទុយពីសាសនាកាតូលិករ៉ូម៉ាំង ព្រះគម្ពីរគឺជាអំណាចគ្រប់គ្រាន់សម្រាប់យើង
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ភស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/
contrary-to-roman-catholics-the-bible-is-our-sufficient-authority
ដោយមានការអនុញ្ញាត។

## សំណួរទី២

Do You Accept "Old Earth" and Evolution?
តើ «ផែនដីចាស់» ហើយកើតចេញពីការវិវត្តន៍មែនឬ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ភស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/do-you-accept-old-earth-and-evolution
ដោយមានការអនុញ្ញាត។

## សំណួរទី៣

Five Ways Jesus Changes Our Relationship to the Old Testament
វិធីប្រាំយ៉ាងព្រះយេស៊ូវផ្លាស់ប្តូរទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគម្ពីរសញ្ញាចាស់
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ភស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/
five-ways-jesus-changes-our-relationship-to-the-old-testament
ដោយមានការអនុញ្ញាត។

## សំណួរទី៤

Pornography and Resisting the Power of Temptation
រូបភាពអាសអាភាស និងការទប់ទល់នឹងអំណាចនៃសេចក្តីល្បួង
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កស,
លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/pornography-and-resisting-the-power-of-temptation
ដោយមានការអនុញ្ញាត។

## សំណួរទី៥

What Is the Baptism of the Holy Spirit?
តើការជ្រមុជទឹកដោយព្រះវិញ្ញាណបរិសុទ្ធជាអ្វី?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, កញ្ញា សឿន ចាន់, លោក
ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោក ហុង សម្កស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/what-is-the-baptism-of-the-holy-spirit
ដោយមានការអនុញ្ញាត។

## សំណួរទី៦

Why Does the Bible Stress the Power of Jesus’s Name?
ហេតុអ្វីបានជាព្រះគម្ពីរសង្កត់ធ្ងន់ទៅលើអំណាចនៃព្រះនាមព្រះយេស៊ូវ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ, សឹម រក្សា និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-does-the-bible-stress-the-power-of-jesuss-name
ដោយមានការអនុញ្ញាត។



## សំណួរទី៧

Does the Bible Say I Am Unique?
តើព្រះគម្ពីរបង្រៀនថា ខ្ញុំពិសេសដែរឬទេ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង លោកស្រី ឡូញ ស្រីរដ្ឋ និងលោក ជួប ប៊ុនហាក់
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/does-the-bible-say-i-am-unique
ដោយមានការអនុញ្ញាត។

## សំណួរទី៨

How Do I Glorify God in My Daily Life
តើខ្ញុំអាចថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំបានដោយរបៀបណា?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឯក សត្យា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង និងលោក ជួប ប៊ុនហាក់
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-glorify-god-in-my-daily-life
ដោយមានការអនុញ្ញាត។

## សំណួរទី៩

How Do We walk by the Spirit?
តើយើងដើរដោយព្រះវិញ្ញាណដោយរបៀបណា?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង, កញ្ញា សឿន ចាន់ និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-we-walk-by-the-spirit
ដោយមានការអនុញ្ញាត។

## សំណួរទី១០

How Does God’s Joy Become My Joy?
តើសេចក្ដីអំណររបស់ព្រះត្រឡប់ក្លាយជាសេចក្ដីអំណររបស់ខ្ញុំបានដោយរបៀបណា?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក វេន ប៉ុក
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង, លោក ហុង សម្គស, លោកស្រី ឡូញ ស្រីរដ្ឋ និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-does-gods-joy-become-my-joy
ដោយមានការអនុញ្ញាត។

## សំណួរទី១១

I Will Die Young—How Can I Fight for Hope?
ខ្ញុំនឹងស្លាប់ទាំងវ័យក្មេង តើខ្ញុំអាចតយុទ្ធសម្រាប់សេចក្ដីសង្ឃឹមបានដោយរបៀបណា
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្គស, លោក ស៊ូ ទិត្យ, កញ្ញា សឿន ចាន់ និងលោក ឡង់ គីមឡុង
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/i-will-die-young-how-do-i-fight-for-hope
ដោយមានការអនុញ្ញាត។

## សំណួរទី១២

Is the Great Commission for Every Individual Christian?
តើមានមហាបេសកកម្មសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូបមែនឬ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឡង់ គីមឡុង, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ហុង សម្គស, លោក សឹម រក្សា, និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/
is-the-great-commission-for-every-individual-christian
ដោយមានការអនុញ្ញាត។



## សំណួរទី១៣

Three Motivations to Pray
កត្តាជំរុញចិត្តបីយ៉ាងដើម្បីអធិស្ឋាន
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្គស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/three-motivations-to-pray
ដោយមានការអនុញ្ញាត។

## សំណួរទី១៤

Why Do Christian Worship Together on Sundays?
ហេតុអ្វីបានជាគ្រីស្ទបរិស័ទថ្វាយបង្គំជាមួយគ្នានៅថ្ងៃអាទិត្យ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ស៊ូ ទិត្យ, លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឡង់ គីមឡុង, លោក ឯក សត្យា, លោក ហុង សម្គស និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-do-christians-worship-together-on-sundays
ដោយមានការអនុញ្ញាត។

## សំណួរទី១៥

Good Motives for Bible Memory
កត្តាជំរុញដ៏ល្អក្នុងការចងចាំព្រះគម្ពីរ
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្គស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/good-motives-for-bible-memory
ដោយមានការអនុញ្ញាត។

## សំណួរទី១៦

How Do I Make the Most of Daily Bible Reading?
តើខ្ញុំអាចទទួលប្រយោជន៍ជាច្រើនតាមរយៈការអានព្រះគម្ពីរជាប្រចាំថ្ងៃបានដោយរបៀបណា?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ និងលោក ជួប ប៊ុនហាក់
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-make-the-most-of-daily-bible-reading
ដោយមានការអនុញ្ញាត។

## សំណួរទី១៧

How Do You Find Meaning in the Bible's Narratives?
តើយើងអាចរកបានអត្ថន័យនៅក្នុងដំណើររឿងនៃសាច់រឿងណាមួយបានយ៉ាងដូចម្ដេច?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ និងលោក ជួប ប៊ុនហាក់
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-you-find-meaning-in-the-bibles-narratives
ដោយមានការអនុញ្ញាត។

## សំណួរទី១៨

How to Read the Bible for Teenagers
របៀបនៃអានព្រះគម្ពីរសម្រាប់ក្មេងៗវ័យជំទង់
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង,
លោក ឯក សត្យា, លោក ហុង សម្កស, លោក សឹម រក្សា និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-to-read-the-bible-for-teenagers
ដោយមានការអនុញ្ញាត។

## សំណួរទី១៩

I Have an Hour a Day to Read — How Much Should Be Bible?
ខ្ញុំមានពេលមួយថ្ងៃមួយម៉ោងសម្រាប់អាន តើខ្ញុំគួរចំណាយពេលប៉ុន្មាននាទីសម្រាប់អានព្រះគម្ពីរ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក វេន ប៉ុក
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា,
លោក ហុង សម្កស, លោក សឹម រក្សា, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង, លោក ឈាង បូរ៉ា
និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/
interviews/i-have-an-hour-a-day-to-read-how-much-should-be-bible
ដោយមានការអនុញ្ញាត។

## សំណួរទី២០

I Read the Bible and Feel Nothing—What Should I Do?
ខ្ញុំអានព្រះគម្ពីរ ហើយមិនមានអារម្មណ៍អ្វីសោះ—តើខ្ញុំគួរធ្វើដូចម្ដេច?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កស,
លោក សឹម រក្សា, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងកញ្ញា ហុង រស្មី
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/i-read-the-bible-and-feel-nothing-what-should-i-do
ដោយមានការអនុញ្ញាត។

## សំណួរទី២១

I've Never Read the Bible, Where Should I Start?
ខ្ញុំមិនដែលអានព្រះគម្ពីរទេ តើខ្ញុំគួរចាប់ផ្ដើមនៅត្រង់ណា?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/ive-never-read-the-bible-where-should-i-start
ដោយមានការអនុញ្ញាត។

## សំណួរទី២២

Is My Bible Reading Too Academic?
តើការអានព្រះគម្ពីររបស់ខ្ញុំបែបជាការសិក្សាខ្លាំងពេកមែនឬ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ឈាង បូរ៉ា , លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-my-bible-reading-too-academic
ដោយមានការអនុញ្ញាត។

## សំណួរទី២៣

Must Bible Reading Always End with Application?
តើការអានព្រះគម្ពីរត្រូវបញ្ចប់ដោយមានការអនុវត្តគ្រប់ពេល?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/must-bible-reading-always-end-with-application
ដោយមានការអនុញ្ញាត។

## សំណួរទី២៤

Ten Reasons to Read the Bible Every Day
មូលហេតុ១០យ៉ាងក្នុងការអានព្រះគម្ពីរប្រចាំថ្ងៃ
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/ten-reasons-to-read-the-bible-every-day
ដោយមានការអនុញ្ញាត។



## សំណួរទី២៥

Battling Envy
ការតយុទ្ធនឹងសេចក្ដីច្រណែនឈ្នានីស
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, កញ្ញា សឿន ចាន់,
លោកស្រី ឡូញ ស្រីរដ្ឋ, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោក ហុង សម្កស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/battling-envy
ដោយមានការអនុញ្ញាត។

## សំណួរទី២៦

Can I Believe the Whole Bible and Not Be Elect?
តើខ្ញុំអាចជឿលើព្រះគម្ពីរទាំងមូល ហើយព្រះអង្គនៅមិនបានជ្រើសរើសខ្ញុំដែរឬទេ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/can-i-believe-the-whole-bible-and-not-be-elect
ដោយមានការអនុញ្ញាត។

## សំណួរទី២៧

Does God Predestine People to Hell
តើព្រះបានតម្រូវទុកជាមុន ឲ្យអ្នកខ្លះធ្លាក់នរកឬ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្កស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/does-god-predestine-people-to-hell
ដោយមានការអនុញ្ញាត។

## សំណួរទី២៨

How Does ‘Willful Sinning’ Threaten My Salvation
តើការ «ធ្វើបាបស្ម័គ្រពីចិត្ត» គម្រាមកំហែងលើសេចក្តីសង្រ្គោះរបស់ខ្ញុំដែរឬទេ ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ស៊ូ ទិត្យ,
លោក ឡង់ គីមឡុង, លោក ហុង សម្ផស, លោក ស៊ឹម រក្សា និងលោក ង៉ែត វិទូ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-does-willful-sinning-threaten-my-salvation
ដោយមានការអនុញ្ញាត។

## សំណួរទី២៩

My Pastors Don't Preach Against Sin-Is That OK ?
គ្រូគង្វាលរបស់ខ្ញុំមិនអធិប្បាយទាស់ប្រឆាំងនឹងអំពើបាបសោះ តើការនោះមិនអីទេ ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស,
លោក ស៊ឹម រក្សា, លោក ស៊ូ ទិត្យ និងលោក ឡង់ គីមឡុង
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/my-pastors-dont-preach-against-sin-is-that-okay
ដោយមានការអនុញ្ញាត។

## សំណួរទី៣០

The Bible’s Most Important Verse
ខគម្ពីរដ៏សំខាន់បំផុតក្នុងព្រះគម្ពីរ
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/the-bibles-most-important-verse
ដោយមានការអនុញ្ញាត។

## សំណួរទី៣១

What is An Idol ?
តើអ្វីទៅជាការថ្វាយបង្គំរូបព្រះ ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ស៊ូ ទិត្យ, លោក ទេព រ៉ូ, លោក ឯក សត្យា,
លោក ហុង សម្ផស, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ និងកញ្ញា សឿន ចាន់
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/what-is-an-idol
ដោយមានការអនុញ្ញាត។

## សំណួរទី៣២

When Christian Won't Repent From Sexual Sin
នៅពេលគ្រីស្ទបរិស័ទមិនព្រមប្រែចិត្តចេញពីអំពើបាបខាងផ្លូវភេទ
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ស៊ូ ទិត្យ, លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា,
លោក ហុង សម្ផស, លោកស្រី ឡូញ ស្រីរដ្ឋ និងលោក ឡង់ គីមឡុង
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/when-a-christian-wont-repent-from-sexual-sin
ដោយមានការអនុញ្ញាត។

## សំណួរទី៣៣

Why Does God Choose the Foolish ?
ហេតុអ្វីព្រះរើសពួកអ្នកល្ងង់ល្ងើ ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក វេន ប៊ុក
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស,
លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ,លោក ង៉ែត វិទូ
និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-does-god-choose-the-foolish
ដោយមានការអនុញ្ញាត។

## សំណួរទី៣៤

Are We Too Financially Unstable to Get Married?
តើយើងមានអស្ថេរភាពខាងហិរញ្ញវត្ថុនៅក្នុងការរៀបការមែនទេ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា,
លោក ហុង សម្ភស, លោក សឹម រក្សា, លោកស្រី ឡូញ ស្រីរដ្ឋ, កញ្ញា សឿន ចាន់, លោក ស៊ូ ទិត្យ,
លោក ឡង់ គីមឡុង និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/are-we-too-financially-unstable-to-get-married
ដោយមានការអនុញ្ញាត។

## សំណួរទី៣៥

Is It Important to Have Your Parents' Blessing in Marriage?
តើជារឿងសំខាន់ទេដែលយើងត្រូវទទួលបានការយល់ស្របពីឪពុកម្ដាយសម្រាប់អាពាហ៍ពិពាហ៍?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស,
លោក ឡង់ គីមឡុង  និងលោក ជួប ប៊ុនហាក់
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/
is-it-important-to-have-your-parents-blessing-in-marriage
ដោយមានការអនុញ្ញាត។

## សំណួរទី៣៦

Is My Dating Relationship Idolatrous?
តើទំនាក់ទំនងនៃការចែចង់របស់ខ្ញុំមានលក្ខណៈដូចការថ្វាយបង្គំរូបព្រះមែនឬ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ឈាង បូរ៉ា, លោក ហុង សម្ភស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-my-dating-relationship-idolatrous
ដោយមានការអនុញ្ញាត។

## សំណួរទី៣៧

Is Your Boyfriend Mature Enough for You?
តើមិត្តប្រុសរបស់អ្នកមានភាពចាស់ទុំគ្រប់គ្រាន់ឬនៅសម្រាប់អ្នក?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ឈាង បូរ៉ា, លោក ហុង សម្ភស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-your-boyfriend-mature-enough-for-you
ដោយមានការអនុញ្ញាត។

## សំណួរទី៣៨

On Codependent Dating Relationships
បែបបទនៃការចែចង់គ្នាដោយមានការពឹងលើ
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ពេជ្រ ប៊ុនណា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស,
លោក សឹម រក្សា, លោក ឡង់ គីមឡុង, កញ្ញា ហុង រស្មី និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/on-codependent-dating-relationships
ដោយមានការអនុញ្ញាត។

## សំណួរទី៣៩

What is Love?
តើសេចក្ដីស្រឡាញ់ជាអ្វី?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក
ជំនួយការបកប្រែ៖ លោក ឈាង ប៉ូរា
កែសម្រួលដោយ៖ លោក ខែម បូឡុង, ស៊ូ ទិត្យ, លោក ទេព រ៉ូ, លោក ឯក សត្យា,
លោក ហុង សម្ភស, លោក សឹម រក្សា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/what-is-love
ដោយមានការអនុញ្ញាត។

## សំណួរទី៤០

Why Was Adam Lonely If God Is Enough?
បើព្រះមានភាពគ្រប់គ្រាន់សម្រាប់គាត់ ហេតុអ្វីលោក អ័ដាម មានភាពឯកោ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឯក សត្យា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឈាង ប៉ូរ៉ា, លោក ហុង សម្ផស, លោក សឹម រក្សា, កញ្ញា ហុង រស្មី ស្រីរដ្ឋ, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ នឹងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-was-adam-lonely-if-god-is-enough
ដោយមានការអនុញ្ញាត។

## សំណួរទី៤១

Bible Time for Busy Moms
រកពេលអានព្រះគម្ពីរ សម្រាប់ម្ដាយដែលរវល់
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/bible-time-for-busy-moms
ដោយមានការអនុញ្ញាត។

## សំណួរទី៤២

Is Parenting Complicated or Simple?
តើការចិញ្ចឹមកូនគឺជារឿងស្មុគស្មាញ ឬក៏ជារឿងសាមញ្ញ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-parenting-complicated-or-simple
ដោយមានការអនុញ្ញាត។



## សំណួរទី៤៣

Six Ways Parents of Rebellious Children Fight for Faith
របៀប៦យ៉ាងសម្រាប់ឪពុកម្ដាយដែលមានកូនរឹងចចេសអាចតយុទ្ធជាមួយបាន ដើម្បីជំនឿ
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/six-ways-parents-of-rebellious-children-fight-for-faith
ដោយមានការអនុញ្ញាត។

## សំណួរទី៤៤

Soul Care for Exhausted Young Mothers
ការថែរក្សាព្រលឹងសម្រាប់អ្នកម្ដាយវ័យក្មេងដែលនឿយហត់
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ នឹងកែសម្រួលចេញពី
https://www.desiringgod.org/interviews/soul-care-for-exhausted-young-mothers
ដោយមានការអនុញ្ញាត។

## សំណួរទី៤៥

What Is the Daily Aim of Parenting?
តើអ្វីទៅជាគោលដៅប្រចាំថ្ងៃនៃការចិញ្ចឹមកូន?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ, លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ នឹងកែសម្រួលចេញពី
https://www.desiringgod.org/interviews/what-is-the-daily-aim-of-parenting
ដោយមានការអនុញ្ញាត។

## សំណួរទី៩៦

Do Digital Bible Searches Relativize Memorization?
តើការស្វែងរកខគម្ពីរដោយប្រើប្រព័ន្ធឌីជីថល (digital) ល្អជាងការចងចាំខគម្ពីរមែនឬ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/do-digital-bible-searches-relativize-memorization
ដោយមានការអនុញ្ញាត។

## សំណួរទី៩៧

How Do I Love God More Than My Entertainment
ធ្វើដូចម្ដេចឲ្យខ្ញុំអាចស្រឡាញ់ព្រះ ខ្លាំងជាងការកម្សាន្តសប្បាយរបស់ខ្ញុំ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ឯក សត្យា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ង៉ែត វិទូ, លោក ហុង សម្ផស, លោក
សឹម រក្សា, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-love-god-more-than-my-entertainment
ដោយមានការអនុញ្ញាត។

## សំណួរទី៩៨

If I Listen to Sermons, Why Do I Need to Read My Bible?
ប្រសិនបើខ្ញុំស្ដាប់ការអធិប្បាយ ហេតុអ្វីខ្ញុំត្រូវអានព្រះគម្ពីរទៀត?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ឈាង បូរ៉ា, លោក ហុង សម្ផស, លោក ឯក សត្យា,
លោក ស៊ូ ទិត្យ, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/
if-i-listen-to-sermons-why-do-i-need-to-read-my-bible
ដោយមានការអនុញ្ញាត។



## សំណួរទី៩៩

Is an Audio Bible Sufficient for Devotions?
តើការចំណាយពេលស្ដាប់ព្រះគម្ពីរជាសំឡេងគ្រប់គ្រាន់សម្រាប់ការចំណាយពេលជាមួយនឹងព្រះ
ជាម្ចាស់ដែរឬទេ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-an-audio-bible-sufficient-for-devotions
ដោយមានការអនុញ្ញាត។

## សំណួរទី១០០

Why Are Relationships Thin in the Digital Age?
ហេតុអ្វីទំនាក់ទំនងមានភាពទន់ខ្សោយនៅក្នុងសម័យកាលដ៏ទំនើបនេះ?
យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ Richard Lints
បកប្រែដោយ៖ លោក ពេជ្រ ប៊ុនណា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ផស, លោក ស៊ូ ទិត្យ,
លោក ឯក សត្យា, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរដ្ឋ, លោក សឹម រក្សា,
លោក ង៉ែត វិទូ និងលោក ឈាង បូរ៉ា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-are-relationships-thin-in-the-digital-age
ដោយមានការអនុញ្ញាត។

playpit.com

សូមចូលមើលបណ្ណាគារ
ONLINE របស់យើងខ្ញុំ។


















